សារិន ឆាក

បណ្ឌិត សេដ្ឋកិច្ចនយោបាយ

(មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច នៃទីក្រុងប៉ារីស)



មជ្ឈមណ្ឌលសិក្សា នៃបណ្ដាប្រទេសនៅចុងបូព៌ានៃ

អាស៊ីអាគ្នេយ៍


# ព្រំដែន នៃប្រទេសកម្ពុជា

ជាមួយបណ្ដាប្រទេសនៃ

## អតីតសហព័ន្ធឥណ្ឌូចិន

ឡាវ-វៀតណាម (កូសាំងស៊ីន-អណ្ណាម)






ផែនទី បង្ហាញការបាត់បង់ទឹកដីរបស់ កម្ពុជា

នៅក្នុងឱកាសធ្វើប្រតិបត្តិការកំណត់ព្រំដែន ជាបន្តបន្ទាប់

ក្រោយសន្ធិសញ្ញា ១១ សីហា ឆ្នាំ ១៨៦៣

(...)..ក្នុងមួយជាតិខ្ញុំនេះ ខ្ញុំមិនចង់ឲ្យ ប្រជាពលរដ្ឋរបស់ខ្ញុំរងទុក្ខវេទនាទេ, រូបខ្ញុំក៏ដូចជាខ្មែរឯទៀត ដែលស្នេហាមាតុភូមិរបស់ខ្លួនដែរ មិនអាចចៀសវាងការវាយប្រហារប្រឆាំងនឹងអំណាចបរទេសដែលចូលមកធ្វើអាណានិគមកិច្ចឬឈ្លានពានប្រទេសខ្ញុំ ឬ មកជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់ជាតិយើង ឬក៏គំរាមកំហែងបូរណភាពទឹកដីរបស់យើងបានឡើយ.....

(...)..ឆ្នាំ១៩៥២-១៩៥៣ ខ្ញុំបានដឹកនាំចលនាតស៊ូប្រឆាំងអាណានិគមបារាំងទាមទារឯករាជ្យជូនកម្ពុជា...។ ...ក្នុងចន្លោះឆ្នាំ ១៩៧០-១៩៧៥ ខ្ញុំបានធ្វើការតស៊ូប្រឆាំងចក្រពត្តិអាមេរិកាំង... ។ ...ខែមករា ១៩៧៩ ខ្ញុំបានធ្វើដំណើរទៅកាន់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដើម្បីធ្វើមេធាវីឲ្យប្រទេសខ្ញុំប្រឆាំងនឹងសាធារណរដ្ឋសង្គមនិយមវៀតណាមអ្នកឈ្លានពានប្រទេសកម្ពុជា ... ។

(...)...ប្រជាពលរដ្ឋខ្មែរពិតៗមិនសុខចិត្តបំរើរបបណាដែលមិនបានប្រសូតចេញពីសេចក្តីសម្រេចផ្ទាល់របស់ខ្លួននោះឡើយ..., ប៉ុន្តែគេសុខចិត្តទ្រាំនូវការលំបាកវេទនាគ្រប់បែបយ៉ាងទាំងអស់....ទោះជាសេចក្តីស្លាប់ក្តីដើម្បីបុព្វហេតុរំដោះប្រទេស កម្ពុជានិងរក្សាជាតិខ្មែរ ពូជខ្មែរឲ្យបាននៅគង់វង្ស...។

...គួរឲ្យសោកស្តាយបំផុតចំពោះជនបរទេសដែលមិនយល់អំពីមនោសញ្ចេតនាពិតៗរបស់ប្រជាពលរដ្ឋខ្មែរ.... ។

នរោត្តម សីហនុ

មានព្រះបន្ទូលនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩០

(ក្នុងតំបន់តស៊ូរំដោះជាតិជាយដែនកម្ពុជា-ថៃ)

រោងពុម្ព ឥន្ទ្រទេវី ១៦៣ ម.វិ ម៉ៅសេទុង ភ្នំពេញ,
E-mail : indradevi@camnet.com.kh

តម្លៃ : ៩៥០០ រៀល

# ជីវប្រវត្តិរបស់
# លោក សារិន ឆាក



**SARIN CHHAK**

Ministre Plénipotentiaire de 2e classe, Secrétaire Général du Ministère des Affaires Etrangères.

Né le 2 Janvier 1922 à Phnom-Penh, fils de M. Sarin et de Mme née Sann. Marié avec Mlle Koy Vann Sinn. Enfants : V , V , C , C .

Bachelier en Droit, Ancien élève de l'Ecole d'Administration Cambodgienne et de la Faculté de Droit de Phnom-Penh.

Carrière : Percepteur, Chef de Poste Administratif, Chauvaysrok, Secrétaire Général à la Municipalité de Phnom-Penh, Directeur des Bureaux.

Officier du Monisaraphon, Chevalier de l'ORC, Médaille de la Défense Nationale.

Adresse privée : 113 rue Trasak-Paem, P.-Penh.

ដកស្រង់ពីសៀវភៅ **ឥស្សរជនកម្ពុជា ឆ្នាំ ១៩៦៣**
From "Les Personalités Du Cambodge, 1963"

លោក **សារិនឆាក**(អានថា៖**សារិនឆាក់**) ដែលមាននាមដើម **ឃិនគាំង** មានដើមកំណើតពិតប្រាកដនៅឯ ភូមិក្រាំងស្វា ស្រុកព្រែកប្បាស ខេត្រតាកែវ។ លោកបានប្រសូតនៅថ្ងៃទី២ខែ មករាឆ្នាំ១៩២២។ លោកត្រូវជាបុត្រទី៣របស់បិតា លោកឈ្មោះ**ឃិន** និងមាតាឈ្មោះ **ឆាយឡាក់**។ ឪពុកម្តាយលោកប្រកបអជីវកម្មជាកសិករ។

នៅក្នុងជំនាន់អាណានិគមនិយមបារាំង ដោយលោកពុំបានចូលរៀនសូត្រទាន់ពេលអាយុវ័យក្មេង លោកក៏ត្រូវផ្លាស់ប្តូរ បញ្ជីជាតិ ដើម្បីបានចូលរៀនសូត្រនឹងគេ ហេតុ ដូច្នេះហើយបានជាលោកប្រែឈ្មោះមកជា **សារិនឆាក** តាំងពីនោះរៀងរហូតមក។

លោកបានសិក្សាច្បាប់នៅឯប្រទេសកម្ពុជាហើយលោកក៏បានបន្តការសិក្សារបស់លោកនៅឯប្រទេសបារាំងរហូតដល់បានជាប់ជាបណ្ឌិតខាងសេដ្ឋកិច្ចនយោបាយនៅឆ្នាំ១៩៦៦។ ដើម្បីបំពេញសញ្ញាប័ត្រលោកនៅឯប្រទេសបារាំង លោកក៏បានជ្រើសរើសកិច្ចសិក្សាអំពីរឿង ព្រំដែននៃប្រទេសកម្ពុជានេះឡើង។ និក្ខេបទ (Thesis) របស់លោកជាភាសាបារាំងមាន ចំនួន៤ភាគ គឺ៖

ភាគ១៖ ព្រំដែនខ្មែរថៃ (La frontière Khmero-Thailandaise)

ភាគ២៖ ស្ថិរភាពនៃព្រំដែន សហការបារាំងសៀម ឆ្នាំ១៩០២-១៩៣៩ (La stabilization de la frontière. La collaboration Franco-Siamoise. 1902-1939)

ភាគ៣៖ ចំណោទថ្មីអំពីព្រំដែន ឆ្នាំ១៩៤០ (La remise en cause des frontières)

ភាគ៤៖ គំនូសព្រំដែនកម្ពុជាជាមួយប្រទេសលាវនិងវៀតណាមខាងត្បូង (Le Tracé de la frontière Cambodgienne avec le Laos et le Sud-Vietnam)

សៀវភៅដែលបងប្អូនរួមជាតិកំពង់តែអាននេះជាស្នាដៃរបស់លោកដែលប្រសូតចេញ អំពីនិក្ខេបទរបស់លោកខាងលើនេះ។

នៅមុនថ្ងៃ១៨មិនា១៩៧០ លោក **សារិនឆាក** បានបំពេញមុខងារលោកជា ឯកអគ្គរាជទូតខ្មែរប្រចាំប្រទេសអេហ្ស៊ីប (Egypt)។ ក្រោយពីការទម្លាក់សម្តេចសីហនុអំពី ដំណែងមគ្គុទេសក៏ខ្មែរមក លោកក៏បានដង្ហែរសម្តេចសីហនុទៅកាន់ទីក្រុងប៉េកាំង ព្រមទាំងបានបន្តបេសកកម្ម ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNC) ដឹកនាំដោយសម្តេចសីហនុ។ នៅពេលដែលកងទ័ពខ្មែរក្រហមបានទទួលជ័យជំនះនៅឆ្នាំ១៩៧៥ លោក **សារិនឆាក** និងភរិយាព្រមទាំងបុត្រមួយចំនួន ក៏បានវិលនិវត្តត្រឡប់ចូលទៅមាតុភូមិវិញដែរ។ ចាប់ពីពេលនោះមក គេក៏ពុំសូវបានដំណឹងច្បាស់លាស់អំពីរូបលោកនិងគ្រួសារទៀតឡើយ។ នៅពេលដែលទ័ពយួនបានវាយប្រហារមកលើរបប ប៉ុលពតនៅចុងឆ្នាំ១៩៧៨ មជ្ឈដ្ឋានមួយចំនួនបានអះអាងថាបានឃើញរូបលោកព្រមទាំងភរិយា នៅឯទីក្រុងភ្នំពេញ នៅពេលមុនថ្ងៃដែលទ័ពយួនចូលកាន់កាប់ទីក្រុងភ្នំពេញបន្តិច។ ទោះជាយ៉ាងណាក្តីក្រោយពេល ដែលប្រទេសចិនបានដឹកនាំសម្តេចសីហនុចេញអំពី ភ្នំពេញផុតទៅ ក៏គេពុំបានឃើញរូបលោកទៅតាមសម្តេចសីហនុឡើយ។ ប្រភពខ្លះទៀតបានអះអាងថាលោកបានត្រូវទ័ពយួនចាប់បាន នៅពេលដែលវាចូលមកដល់ក្រុងភ្នំពេញ។ ដោយសារតែលោកបានសរសេរអត្ថបទនិង សៀវភៅជាច្រើនដែលប៉ះពាល់ដល់យួន លោក ក៏ត្រូវពួកវាចាប់យកទៅដាក់គុកនៅឯប្រទេសវា។ ដោយគេពុំដែលបានឃើញវត្តមាន របស់លោកនិងភរិយាតាំងពីពេលនោះមក មជ្ឈដ្ឋានក្រុមគ្រួសាររបស់លោកបាន យល់ថាលោកប្រហែលជាបានទទួលមរណៈភាពនៅឯគុកយួន នោះជាប្រាកដ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពវិញ្ញាណក្ខ័ន្ធរបស់លោកដែលបាន ចែកឋានយើងនេះទៅ ហើយយើងក៏សូមថ្លែងការវះភក្តីអំណរគុណដល់លោកដែលបានវាងវៃទុកស្នាដៃ របស់លោកចែកជូនជាមរតកដល់បងប្អូនរួមជាតិខ្មែរទាំអស់គ្នាឲ្យបានយល់ដឹងអំពីការ ឈ្លានពានរបស់សត្រូវជិតខាងយើងមកលើបូរណភាពទឹកដីខ្មែរជាពិសេសនៅក្នុងអំឡុង ពេលថ្មីៗនេះទៀត។

ខែឧសភាឆ្នាំ២០០៥

# Biography of Mr. Sarin Chhak

*Plenipotentiary Minister (Rank 2), General-Secratry of the Foreign Minister.*

*Born January 2, 1922 in Phnom Penh, son of Mr. Sarin and Mrs. Sann. Maried to Miss Koy Vann Sinn. Children: V…, V…, C…, C….*

*Bachelor Degree in Law, Former student of the Cambodian Administration School and the Faculty of Law in Phnom Penh.*

*Career: Collector, Administrative Chief, Chauvaysrok, Secretray-General of the Phnom Penh Municipality, Office Director.*

*Honor: Monisaraphon Officer, Knight of the Royal Order of Cambodia, National Defense Medal.*

*Private address: 113 Trasak Paem Rd., Phnom Penh.*

- From "Les Personalités du Cambodge" 1963 Edition

Mr. Sarin Chhak whose real name is Khin Kaing, was born in the village of Krangsla, district of Prey Kabbas, province of Takeo. He was born on January 2, 1922 to Mr. Khin and Mrs. Chhay Lak who are farmers.

During the French colonial period, because he was not able to attend school early on, when his parents decided to put him in school, due to his advanced age, he was not able to do so unless he changed his birth certificate. Thus, he was forced to adopt a new identity, under the new name of Sarin Chhak, in order to attend school.

He studied law in Cambodia, and obtained his Doctoral Degree in Economic Law in France in 1966. For his doctoral degree thesis, he selected the "Cambodia's Borders" issues as the topic of his research. To fulfill the requirement of his doctoral degree, he wrote his thesis (in French) which included the following four volumes:

1- The Khmer-Thai border,
2- The stabilization of the border. The collaboration between France and Thailand. 1902-1939,
3- The new questioning of the borders, and
4- The delineation of the Cambodian border with Laos and South Vietnam.

The book you are currently holding in your hand constitutes a portion of his doctoral thesis above.

Prior to March 18, 1970, Mr. Sarin Chhak acted as Ambassador of the Kingdom of Cambodia attached to Egypt. He was then stationed in Cairo. Following the removal from power of Prince Sihanouk, Mr. Sarin Chhak decided to follow the latter to Peking where he eventually became the Foreign Minister of the Royal Government of National Union of Cambodia (under the French acronym of GRUNC) under the leadership of Prince

Sihanouk. Following the Khmer Rouge victory in 1975, Mr. Sarin Chhak, his wife, and a number of his children decided to return back to Cambodia. Since then not much information was available regarding his whereabouts. It was not until the end of 1978, when the Vietnamese forces invaded Cambodia and routed the Khmer Rouge regime out of Phnom Penh, that several people claimed to have seen him and his wife in Phnom Penh. Nevertheless, following the airlift of Prince Sihanouk from Phnom Penh prior to the arrival of the invading Vietnamese force, Mr. Sarin Chhak and his wife disappeared again. Finally, his family learned that he was captured by the occupying Vietnamese forces. Because of his involvement on border issues related to Vietnam, it appeared that after his capture, Mr. Sarin Chhak was imprisoned in Vietnam where he and his wife found their death.

We take this occasion to honor the memory of Mr. Sarin Chhak, and to thank him for leaving the legacy of his books and thesis detailing the encroachments of our neighbors on the Cambodian territorial integrity – encroachments never abated even to these days.

May 2005.

មជ្ឈមណ្ឌលសិក្សា នៃបណ្ដាប្រទេសនៅចុងបូព៌ានៃអាស៊ីអាគ្នេយ៍

# ព្រំដែននៃប្រទេសកម្ពុជា

ជាមួយបណ្ដាប្រទេសនៃអតីតសហព័ន្ធឥណ្ឌូចិន

ប្រទេស កម្ពុជា ឡាវ  និង វៀតណាម (កូសាំងស៊ីន និង អណ្ណាម)

ដោយ


**សារិន ឆាក**

បណ្ឌិតសេដ្ឋកិច្ចនយោបាយ

(តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា ប្រចាំនៅអង្គការ យូណេស្កូ)


**អារម្ភកថា របស់ :**

**សម្ដេច នរោត្ដម សីហនុ**

**ព្រះប្រមុខរដ្ឋ នៃប្រទេសកម្ពុជា**

និង របស់ :


**លោក PAUL REUTER**

សាស្ត្រាចារ្យ មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទីក្រុងប៉ារីស



**បោះពុម្ពផ្សាយលើកទី២ ជាខេមរភាសា ដោយ :**

ឥន្ទ្រទេវី



ឥន្ទ្រទេវី
The Indradevi Publishing

ឯកសារប្រែសម្រួលជាខេមរភាសាដោយ ឥន្ទ្រទេវី បោះពុម្ពផ្សាយ

| | |
|---|---|
| ស្រាវជ្រាវ និង និពន្ធដោយ | សារិន ឆាក |
| ប្រែសម្រួលជាខេមរភាសាដោយ | គីម យ៉ាន |
| រៀបរៀង និង កែសម្រួលដោយ | ទៀ ថេន |
| រចនា និង តួសៀវភៅ | ជា សុភាព , ជា វុត្ថា |
| កុំព្យូទ័រ | ជាត សុភក្ត្រី |

ឆ្នាំ ២០០៤ បោះពុម្ព ចំនួន ៥០០០ច្បាប់,
បោះពុម្ពនៅកម្ពុជា ដោយរោងពុម្ព ឥន្ទ្រទេវី
រក្សាសិទ្ធិគ្រប់យ៉ាង



# ទាចារ្យអ្នករៀបរៀង

សៀវភៅមួយដែលមានអាយុប្រមាណ៤០ឆ្នាំ មកហើយនេះបានបង្ហាញខ្លឹមសារជាភាសាបារាំងរបស់ខ្លួននៅក្នុងក្របខ័ណ្ឌនៃអ្នកតវ៉ាទៅនឹងភាពមិនត្រឹមត្រូវអំពីការបែងចែកនិងកាត់យកនូវទឹកដីទាំងឡាយដែលអតីតមហាអំណាចជាអ្នកការពាររបស់ខ្លួនបានប្រព្រឹត្តមកលើ,ហើយបានព្យាយាមតស៊ូមតិវែកញែកដ៏ច្បាស់លាស់មួយជាលក្ខ័ខ័ណ្ឌវិទ្យាសាស្ត្រ-ស្របច្បាប់ និងថ្លៃថ្នូរជាពិសេសបំផុត ។ ....នោះគឺជាការប្រឹងប្រែងដ៏ខ្ពង់ខ្ពស់ដែលមាន លោក សារិន ឆាក (បណ្ឌិត សេដ្ឋកិច្ចនយោបាយ-អតីតតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំ នៅអង្គការ យូណេស្កូឆ្នាំ ១៩៦៥) ជាអ្នកដឹកនាំការស្រាវជ្រាវដែលបានទទួលការគាំទ្រយ៉ាងខ្ពង់ខ្ពស់អំពីថ្នាក់ដឹកនាំកំពូលបំផុតនៃប្រទេសកម្ពុជា និង ក្រុមបណ្ឌិតច្បាប់របស់ ប្រទេសបារាំងជាច្រើនរូប ។

ស្នាដៃមួយដែលអ្នកសិក្សាអំពីភូមិសាស្ត្រ ប្រទេសកម្ពុជាទាំងឡាយ និងជាច្រើនបានគោរពពេញចិត្ត យកធ្វើជាគោលគំនិតសំខាន់ចាប់ពីដើមឆ្នាំ ១៩៦៦ មកនោះ, ពេលនេះត្រូវបានផ្នែកបោះពុម្ពផ្សាយឥន្ទ្រទេវី ជ្រើសរើសយកមកប្រែសម្រួល និង រៀបរៀងហើយបោះពុម្ពផ្សាយលើកទី២ជាខេមរភាសា (បោះពុម្ពផ្សាយលើកទី១ជាភាសាបារាំង) ជូនអ្នកសិក្សាស្រាវជ្រាវទាំងឡាយដែលតែងមានកង្វល់អំពីបញ្ហាព្រំ,គោលសីមានៃប្រទេសកម្ពុជា ជាមួយអតីតសហព័ន្ធឥណ្ឌូចិន (ឡាវ, (ចំប៉ាសាក់) វៀតណាម, (កូសាំងស៊ីន និង អណ្ណាម) ដែលកាលណោះអ្នកមេចំណែក អាណានិគមបារាំង (ជាអ្នកការពារ)បានកាត់, ពុះ, បង្វិលចុះឡើងនូវទឹកដីនៃប្រទេស ទាំង៣ (ខាងលើ)តាមតែទិដ្ឋភាពផ្សេងៗ ។

សៀវភៅនេះត្រូវបាននិងកំពុងតែបញ្ចូលខ្លួននៅក្នុងកម្មវត្ថុ "**ជាសាក្សីប្រវត្តិសាស្ត្រ**" នៃរឿងរ៉ាវព្រំដែនដែលកំពុងរងនូវការរំកិលរុលចូលមកយ៉ាងច្របូកច្របល់ និងមិន

បេះឈប់ឈរអំពីប្រទេសវៀតណាម; ប្រទេសថៃឡង់ដ៍ និងថ្មីៗកន្លងទៅនេះថែមប្រទេសឡាវមួយទៀតក៏បានហ៊ាន រំលោភឈ្លានពានមកលើព្រំសីមាប្រទេសកម្ពុជានាពេលបច្ចុប្បន្ន (ឆ្នាំ២០០៤) នេះដែរ ។ ទាំងអស់នេះហើយដែលធ្វើអោយយើងសែនសោកស្តាយខ្លាំងណាស់ ដោយសៀវភៅនេះ ដែលបានបោះពុម្ពផ្សាយពីក្រុងប៉ារីសឆ្នាំ១៩៦៦នោះ ត្រូវរងការបាត់បង់ទៅអស់ទៅវិញយ៉ាងច្រើន ពីព្រោះតែសង្គ្រាមរ៉ាំរ៉ៃយូរឆ្នាំ បានបំផ្លាញអស់ជាច្រើនទូវឯកសារមានតម្លៃយូរអង្វែងទាំងឡាយម្ល៉ោះហើយធ្វើឲ្យការផ្សាយពុំបានទូលាយជាបច្ច័យពិបាកចំពោះអ្នកសិក្សាភាគច្រើននាំឲ្យមានការប្រឆាំងប្រទូស្ត...។

រឿងមួយដែលគួរលើកយកមកនិយាយដែរនោះគឺថា : ប្រទេសកម្ពុជាវៀតណាម-ឡាវ, គឺជាអតីតដៃគូគ្នាក្នុងក្របខ័ណ្ឌនៃសហព័ន្ធអាណានិគមដែលបានបង្កើតឡើងនូវសហភាពឥណ្ឌូចិន ហើយយើងបានដឹងថែមទៀតថា ការកាត់ចេញពីកម្ពុជានូវទឹកដីទាំងឡាយហើយបញ្ចូលទៅឲ្យប្រទេសវៀតណាម និង ឡាវនោះឯកសារបានបង្ហាញច្បាស់អំពី អំពីទិដ្ឋភាពចាប់បង្ខំក្នុងលក្ខណៈខុសៗគ្នា នោះហើយទើបវាបង្កើតចេញមកនូវសញ្ញាជាមូលដ្ឋាននៃបញ្ហាទាំងអស់នេះដែលជាចំណោទវិបត្តិព្រំដែនរបស់ប្រទេសទាំងពីរកម្ពុជា-វៀតណាម (ជាសំខាន់)។ អ្វីដែលប្រទេសកម្ពុជាខាតបង់គឺជាអ្វីដែលដាច់ខាតមិនមែនត្រឹមត្រូវទៅតាមគន្លងគតិយុត្តអន្តរជាតិនោះ ឡើយ គឺវាកើតឡើងអំពីអ្វីដែលលោកបណ្ឌិត សារិន ឆាក បានហៅថា : ជា "ផលិតផលនៃនយោបាយផ្ទៃក្នុង របស់មហាអំណាចអាណានិគម និយមបារាំងដោយសុទ្ធសាធ "....។

នៅក្នុងសៀវភៅនេះ, ខ្ញុំបាទរំពឹងថា នឹងមានវគ្គខ្លះនៅក្នុងចំណោមវគ្គខាងដើម និងនៅជិតពាក់កណ្តាលនៃសៀវភៅនេះមានទំព័រមួយចំនួនតូចប្រហែលជាវាអាចធ្វើឲ្យលោក/អ្នកសិក្សាខ្លះមិនសូវជាចាប់ចិត្តប៉ុន្មានទេដោយហេតុថាមានការពន្យល់



លំអិតតាំងពីពេល ៤០ឆ្នាំមុននូវទីតាំងបោះគោលសីមាទឹកដីខ្លះ, ដែលឥឡូវនេះត្រូវបានផ្លាស់ប្តូរមុខមាត់ថ្មីជាផ្នែកអភិវឌ្ឍន៍របស់ទីកន្លែងនោះៗ, ហេតុដូច្នេះសូមលោក/អ្នកសិក្សាមេត្តាចាត់ទុកថា នោះជាចំណែកនៃប្រវត្តិសាស្ត្រនៅពេលនោះ, ដែលយើងសូមសរសើរលោក សារិន ឆាក បានបង្ហាញអំពីការស្ទិតស្ទាញក្នុងបេសកកម្មស្រាវជ្រាវរបស់ក្រុមលោក ។

ហើយជាចុងក្រោយ,សៀវភៅឯកសារដ៏មានសារៈប្រយោជន៍នេះកំពុងតែដណ្តើមបានដំណែងជា"ឋានៈគំរូនៃចំណោមគំរូប្រវត្តិសាស្ត្រកម្ពុជា ត្រឹមត្រូវតាមច្បាប់ និងមានលក្ខណៈវិទ្យាសាស្ត្រដែល និយមកណ្តាល និង សុភនិច្ឆ័យ" *(សេចក្តីព្យាករណ៍របស់ សម្តេច ព្រះនរោត្តម សីហនុ ១៩៦៥)* ។

- សូមអ្នកសិក្សាទាំងឡាយទទួលបានអត្ថប្រយោជន៍សមតាមប្រាថ្នាគ្រប់ៗរូប...។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត... ។

ព្រះរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤

អ្នករៀបរៀង

ទៀ ថេន



លោក សារិន ឆាក



## អារម្ភកថា

ការងារនេះអាចសម្រេចទៅបានក៏ដោយសារតែព្រះរាជហឫទ័យដ៏ល្អខ្ពង់ខ្ពស់របស់សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ដែលព្រះអង្គជាអ្នកទីមួយ ដែលបានគិតគូរដល់ឲ្យផលប្រយោជន៍ជាតិ ព្រះអង្គសព្វព្រះរាជហឫទ័យឲ្យមានការស្រាវជ្រាវមួយបែបនេះ ដោយបានព្រះរាជទានកិត្តិយសនិងការទុកចិត្តដល់យើងខ្ញុំ ព្រមទាំងមធ្យោបាយទាំងឡាយដល់យើងខ្ញុំ ដើម្បីធ្វើឲ្យបានសម្រេចនូវការងារនេះ ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ចំពោះឯកឧត្តម ប៉ែន នុត ទីប្រឹក្សាពិសេសរបស់ព្រះប្រមុខរដ្ឋ ដែលបានផ្តល់នូវការយល់ដឹងនិងការគាំទ្រដោយឥតសំចៃដល់យើងខ្ញុំ , ចំពោះឯកឧត្តម សឺន សាន ទីប្រឹក្សាពិសេសម្នាក់ទៀត របស់ព្រះប្រមុខរដ្ឋ និងជាទេសាភិបាលនៃធនាគារជាតិកម្ពុជា ដែលបានផ្តល់នូវយោបល់ដ៏មានតម្លៃ ដល់យើងខ្ញុំ ចំពោះឯកឧត្តម ទ្រឿង កាង ឯកអគ្គរាជទូតកម្ពុជា ប្រចាំនៅរដ្ឋធានីប៉េកាំងប្រទេសចិន និងជាភ្នាក់ងារកម្ពុជានៅតុលាការអន្តរជាតិនៃយុត្តិធម៌នៅទីក្រុងឡាអេ នៅក្នុងរឿងក្តីព្រះវិហារ ដែលបានផ្តល់នូវបទពិសោធន៍ដល់យើងខ្ញុំ ចំពោះលោក ចាន់ យូរ៉ាន់ ទីប្រឹក្សាស្ថានទូត ប្រធានលេខាធិការដ្ឋាន ពិសេសរបស់ព្រះប្រមុខរដ្ឋ ដែលបានខំខ្នះខ្នែង ដើម្បីជួយសម្រួលដល់ការងាររបស់យើងខ្ញុំ ។

ចំពោះខាងបារាំងវិញ យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការទទួលដោយយោគយល់ ដែលយើងខ្ញុំបានជួបលោកឡារ៉ូស (La Roche) ចាងហ្វាងមន្ទីរដឹកល់ឯកសារនៃអតីតក្រសួងនៃប្រទេសបារាំងនៅឯនាយសមុទ្រ ផ្លូវ Oudinot ដែលបានធ្វើគ្រប់បែបយ៉ាង ដើម្បីជួយសម្រួលដល់ការរុករករបស់យើងនូវឯកសារផ្លូវការទាំងឡាយរបស់បារាំង ។

ប៉ុន្តែជាពិសេស យើងខ្ញុំសូមគូសបញ្ជាក់អំពីជំនួយ និងយោបល់របស់សាស្ត្រាចារ្យរបស់យើងខ្ញុំនៅសាកលវិទ្យាល័យ ដែលបានផ្តល់ដល់យើងខ្ញុំ ដោយឥតសំចៃ និងដល់ទិជម្រៅ។ គឺពិតជាដោយសារលោកសាស្ត្រាចារ្យទាំងអស់នេះហើយ ដែលធ្វើឲ្យការស្រាវជ្រាវនេះដណ្តើមបាននូវលក្ខណៈច្បាស់លាស់ និងមានលក្ខណៈវិទ្យាសាស្ត្រ ដែលមានវិទ្យាល័យច្បាប់នៃទីក្រុងប៉ារីស បានផ្តល់កិត្តិយសដល់យើង ក្នុងការបំពេញការងារនេះ ។

ត្រង់ចំណុចនេះ ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះលោកសាស្ត្រាចារ្យ រ៉ឺទ័រ (Reuter) នៃមហាវិទ្យាល័យច្បាប់ទីក្រុងប៉ារីស មេធាវីនៃប្រទេសកម្ពុជា នៅក្នុងកិច្ចការព្រះវិហារ និងជាប្រធាននិក្ខេបបទរបស់យើង ។ លោក សាកលវិទ្យាធិការ រ៉ូប្លូ (Roblot) និងលោក ព្រឹទ្ធបុរស ហ្សំ.អ៊ីមប៊ែរ (J.Imbert) អតីតព្រឹទ្ធបុរសនៃមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទីក្រុងភ្នំពេញ ដែលនៅពេលត្រឡប់មកប្រទេសបារាំងវិញ លោកបានបន្តផ្តល់ការទទួលប្រកបដោយមេត្តាធម៌ ដែលលោកទាំងពីរធ្លាប់បានធ្វើចំពោះយើងនៅឯប្រទេសកម្ពុជានោះ ។

លោកសាស្ត្រាចារ្យ ពិនតូ (Pinto) នៃមហាវិទ្យាល័យច្បាប់នៅទីក្រុងប៉ារីស លោកក៏ជាមេធាវីនៅប្រទេសកម្ពុជានៅក្នុងរឿងក្តីព្រះវិហារដែរ និងលោកសាស្ត្រាចារ្យ ឡាវ៉ូ (Lavau) នៅមហាវិទ្យាល័យដដែលនេះ ដែលបានតាមដានគិតគូរដោយយកចិត្តទុកដាក់នូវការស្រាវជ្រាវរបស់យើង ។

នៅទីបញ្ចប់លោក ហ្គួរ (Gour) សាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់នៅ Aixen - Provence ដែលបានស្រឡាញ់ប្រទេសកម្ពុជាដូចជាមាតុភូមិទីពីររបស់ខ្លួន ហើយដែលបន្ទាប់ពីបានបង្រៀនដល់យើងខ្ញុំនៅថ្នាក់បរិញ្ញាបត្រ នៅមហាវិទ្យាល័យច្បាប់នៃទីក្រុងភ្នំពេញមក លោកបានផ្តួចផ្តើមគំនិតដល់យើងខ្ញុំក្នុងការស្រាវជ្រាវ និងបានចូលរួមយ៉ាងសកម្មដល់ការដឹកនាំនៅក្នុងការងាររបស់យើង ។

*

* *







ប៉ែន នុត

សឺន សាន

ទ្រឿង កាង

ចាន់ យូរ៉ាន់

La Roche

Reuter

Roblot

J.Imbert

Pinto

Lavan

Gour

សារិន ឆាក



*(...)..ប្រជារាស្ត្រខ្ញុំបានដឹងច្បាស់លាស់ថា ខ្ញុំបានធ្វើការពុះពាររាល់ឧបសគ្គដោយឥតឈប់ឈរ ដើម្បីពួកគេ ។ ខ្ញុំពុំមានមហិច្ឆតាផ្ទាល់ខ្លួនទេ ហើយខ្ញុំក៏មិនបោះបង់នូវវាសនាដ៏អភ័ព្វរបស់ប្រជារាស្ត្រខ្ញុំ ដែលកំពុងជឿទុកចិត្តមិនអាចដកបានមកលើរូបខ្ញុំដែរ ។ បំណងតែមួយគត់របស់ខ្ញុំ គឺរិះរកឱកាសល្អជូនប្រជារាស្ត្រខ្ញុំ ដើម្បីឱ្យគេសម្រេចនូវជោគវាសនាផ្ទាល់របស់គេបាន....។*

*ន.សីហនុ (១៩៨១)*



# ព្រះរាជលិខិតប្រារព្ធ
# របស់សម្តេច ព្រះនរោត្តម សីហនុ
# ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា

អ្នកដែលចាប់អារម្មណ៍ដ៏តិចតួចចំពោះអាស៊ីអាគ្នេយ៍ បាននិយាយថា "នៅក្នុងសម័យកាលដ៏វែងបំផុតមួយនោះ ប្រទេសកម្ពុជាគឺជាមហាអំណាចមួយដោយរួមបញ្ចូលទាំងអាងទឹកទន្លេមេណាម និងទាំងអាងទឹកទន្លេមេគង្គ" ។ បូជនីយដ្ឋាន និងរមណីយដ្ឋាន អង្គរវត្ត សហគមន៍ខ្មែរដ៏សំខាន់ទាំងឡាយ ដែលរស់នៅតាមបណ្តាខេត្តមួយចំនួននៅប្រទេសថៃ និងវៀតណាមខាងត្បូង ស្ថិតនៅធ្វើជាសាក្សីដែលមិនអាចបំផ្លាញបាននៅក្នុងប្រវត្តិសាស្ត្រ ។

រាប់សតវត្សរ៍នៃភាពរុងរឿងរបស់យើង និងរាប់សតវត្សរ៍នៃការរងទុក្ខវេទនារបស់យើងការប្រយុទ្ធដោយអស់សង្ឃឹមរបស់យើង ប្រឆាំងនិងពួកអ្នកលុកលុយ នៅព្រំដែនខាងលិច និងព្រំដែនខាងកើត ការរួមតូចទៅវិញ នៃទឹកដីរបស់ជាតិយើងការធ្វើអន្តរាគមន៍របស់ប្រទេសបារាំង និងការបង្កើតនូវអាណាព្យាបាលរបស់ខ្លួន គឺបានស្គាល់និងដឹងឮជាទូទៅនៅក្នុងពេលបច្ចុប្បន្ននេះ ។ មានអ្នកប្រាជ្ញជាច្រើនបានយកចិត្តទុកដាក់និងអនាគតកាលរបស់យើង និងបានផ្សព្វផ្សាយនូវការងាររបស់ខ្លួនដ៏ប្រសើរ។

ប៉ុន្តែពុំមានការសិក្សាណាមួយស្តីអំពីព្រំដែនបច្ចុប្បន្នរបស់ប្រទេសកម្ពុជាអំពីការរៀបចំ អំពីអនុភាព គតិយុត្ត អំពីតម្លៃនៃឋានៈ នៃអធិបតេយ្យភាពរបស់អ្នកជិតខាងយើងទៅលើអតីតខេត្តទាំងឡាយរបស់ខ្មែរ នោះនៅមិនទាន់បានបំពេញនៅឡើយ ។ គេអាចឆ្ងល់ចំពោះបញ្ហានេះពីព្រោះថា នៅក្នុងពិភពលោកមួយដែលបណ្តារដ្ឋទាំងឡាយបានខិតខំប្រឹងប្រែង ដើម្បីផ្អែកទៅលើឥរិយាបថនយោបាយរបស់ខ្លួន ចំពោះសេចក្តីសំអាងដោយគតិយុត្តនោះ ការសិក្សាមួយបែបនេះអាចធ្វើឲ្យការវាយតម្លៃបានល្អជាងនូវតម្លៃនៃការទាមទារពិតប្រាកដ និង យល់បានល្អជាងនូវប្រតិកម្មជាច្រើននៃការការពារ ។

គឺដោយការចាប់ផ្តើមធ្វើនេះហើយ ដែលផលប្រយោជន៍នឹងមិនត្រូវបានរបូតចេញពីយើងហើយដែលលោក សារិន ឆាក (SARIN CHHAK) បានជំពាក់ចិត្តនោះ ។

វាពិតជាមានគ្រោះថ្នាក់ ជាពិសេសចំពោះអ្នកដែលបណ្តោយខ្លួនទៅតាមគំនិតដែលប្រែប្រួល ដើម្បីធ្វើជាភស្តុតាងនៃការប្រកាន់ចិត្តយកនៅទីបំផុតដែលអាចយល់បាន ។ ប៉ុន្តែខ្ញុំមានហឫទ័យ រីករាយដោយបានសម្គាល់ឃើញលោក សារិន ឆាក បានដឹកនាំការស្រាវជ្រាវរបស់ខ្លួន ប្រកបដោយការបារម្ភដោយឡែកនិងបង្ហាញតែហេតុការណ៍ពិតនិងឯកសារទាំងឡាយប្រកបដោយលក្ខណៈត្រឹមត្រូវតាមច្បាប់និងមានលក្ខណៈវិទ្យាសាស្ត្រដែលមិនអាចប្រកែកបាន ។

ខ្ញុំអាចតាមសង្កេតអ្នកនិពន្ធ នៅក្នុងការងាររបស់លោកក្នុងការពិនិត្យបញ្ជីឯកសារដោយមានរបៀបនិងបានស្គាល់នូវការលំបាកទាំងឡាយដែលលោកត្រូវជំនះពុះពារ ដើម្បីរុករកឯកសារដីកម្រទាំងឡាយនិងជាញឹកញាប់អាចចូលទៅជិតបាន ដោយតិចតួច ។ ខ្ញុំក៏សូមសម្តែងនូវការគោរពចំពោះអនុភាពការងារដ៏មានភាពមធ្យ័ត តស៊ូស្វិតស្វាញរបស់លោកដែលជាគុណសម្បត្តិទាំងអស់នោះ...ដែលធ្វើឲ្យលោកក្លាយទៅជាអ្នកស្រាវជ្រាវដ៏ពិតប្រាកដ ។

លទ្ធផលនៃសៀវភៅមួយដែលនិយមកណ្តាលបែបនេះ គឺដោយសាររបៀបសរសេរមានការថ្លឹងថ្លែងតាមការវិនិច្ឆ័យរបស់ខ្លួនត្រឹមត្រូវតាមឯកសារសំអាងរបស់ខ្លួនប្រកបដោយលក្ខណៈទៀងត្រង់ប្រាជ្ញាឈ្លាសវៃ ស្មោះត្រង់មិនអាចប្រកែកបានឡើយ ។ ខ្ញុំក៏សូមសរសើរដោយស្មោះស្ម័គ្របំផុតចំពោះលោក សារិន ឆាក និងសូមប្រសិទ្ធិពរឲ្យនិក្ខេបបទរបស់លោកទទួលបាននូវឋានៈគំរូនៅក្នុងចំណោមគំរូនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។

ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៦៥

**នរោត្តម សីហនុ**



# អារម្ភកថា

## របស់លោក Paul Reuter

**(សាស្ត្រាចារ្យនៃមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃរដ្ឋធានីប៉ារីស)**

ការបោះពុម្ពផ្សាយនៃនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួនលោក ដែលទទួលបាននូវការគាំទ្រដ៏ត្រចះត្រចង់ នៅចំពោះមុខ**មហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៃទីក្រុងប៉ារីស** ធ្វើឲ្យលោក សារិន ឆាក រកឃើញនូវការស្តាប់ដ៏ទូលំទូលាយពីសាធារណជន ដែលមិនភ្លេចក្នុងការវាយតម្លៃចំពោះសម្បជញ្ញៈបំពេញការងារមិនចេះហត់នឿយ និងគុណូបការៈនៃការនិពន្ធរបស់លោក ។

ប្រវត្តិសាស្ត្រនៃព្រំដែនប្រទេសកម្ពុជា បើនិយាយអំពីទំនាក់ទំនងជាមួយប្រទេសសៀម (SIAM) គឺមានការដឹងឮដោយអន្លើៗ ។ តែបើនិយាយអំពីទំនាក់ទំនងទាំងឡាយរបស់ប្រទេសកម្ពុជាជាមួយប្រទេសដទៃទៀត ដែលបង្កើតបានជាឥណ្ឌូចិនបារាំងសេស (L'Indochine française) នោះគេមិនបានដឹងឮទាំងស្រុងនូវព្រំដែននេះទេ ។ គេថែមទាំងអាចនិយាយបានថា នៅប្រទេសបារាំងក៏គេមិនសូវយកចិត្តទុកដាក់នូវបញ្ហាទាំងឡាយដែលជាញឹកញាប់ត្រូវបានលះបង់ទុកឲ្យទេសាភិបាលក្នុងស្រុកដែលគេបានប្រព្រឹត្តតាមអំពើចិត្តនោះ ។ ប៉ុន្តែសៀវភៅរបស់លោក សារិន ឆាក បានបង្ហាញថា ខ្សែបន្ទាត់បែងចែកដែលរៀបចំឡើង និងពិនិត្យឡើងវិញ ដោយអាជ្ញាធរបារាំង នៅក្នុងខ្នាតមួយដែលប្រែប្រួល ប៉ុន្តែដោយមានលក្ខណៈប្លែកនៃភាពដូចគ្នានៃលទ្ធផលនោះបានបង្រួញទឹកដីនៃប្រទេសកម្ពុជា ដើម្បីជាគុណប្រយោជន៍នៃប្រទេសជិតខាងនិងជាពិសេសគឺទឹកដីកូសាំងស៊ីន (Cochinchine) ហើយវាមិនមែនដោយគ្មានការរអែងចិត្តខ្លះនោះទេ ដែលអ្នកអានបារាំងនឹងបានដឹងតាមមធ្យោបាយណាដែលលទ្ធផលនោះ អាចនឹងទទួលបាននោះ ។

ការប្រព្រឹត្តខុសបែបនេះ មិនគ្រាន់តែចាប់អារម្មណ៍ដោយអ្នកវិទ្យាសាស្ត្រប៉ុណ្ណោះទេ ការដែលប្រព្រឹត្តនេះបានលើកឡើងនូវបញ្ហាគតិយុត្តជាច្រើន ដែលនាំទៅរកបញ្ហាសំខាន់ដើម្បីដឹងថា ប្រហែលជាក្រោយពីការចប់ទៅនៃរបបអាណានិគមនៅឥណ្ឌូចិន

តើតម្លៃនៃខ្សែបន្ទាត់ដែលត្រូវបានបែងចែកនោះ នឹងក្លាយទៅជាយ៉ាងណា...?

គេយល់ច្រាកដណាស់ថា នៅក្នុងទ្វីបទាំងមូលមួយ ដូចជាអាមេរិកខាងត្បូងបាន ជ្រើសរើសយកឯករាជ្យភ្លាមៗ ដោយមានព្រំដែនជារដ្ឋថ្មី គឺព្រំដែនរដ្ឋបាលដែល កំណត់ដោយអាណានិគមនិយមអេស្ប៉ាញ៉ុល ដើម្បីជាការក្លែងដែលជាញឹកញាប់ ប្រទេសថ្មីទាំងឡាយនេះបានធ្វើនោះ គឺគ្មានមូលហេតុណាមួយ ដែលមិនអាចឆ្លើយ សារភាពបាននោះឡើយ និងពុំមានចេតនាណាមួយ ដើម្បីធ្វើការផ្តើមដែលមិន បានផុសចេញពីទឹកចិត្តរបស់បណ្តាប្រទេសទាំងនោះឡើយ ។ គេអាចយល់បានដូចគ្នា នេះ នៅក្នុងផ្នែកដទៃទៀត នៃពិភពលោក និងនៅក្នុងហេតុផលដូចគ្នានេះដែរ ដែល រដ្ឋថ្មីទាំងឡាយបានដើរតាមគោលការណ៍ដូចគ្នានេះ នោះ ។

ប៉ុន្តែ នៅពេលដែលខ្សែបន្ទាត់បែងចែកត្រូវបានកែសម្រួលនៅក្នុងបន្ទុកនៃរដ្ឋ មួយដែលស្ថិតនៅក្រោមការទំនុកបម្រុង ប៉ុន្តែដោយផ្អែកលើផលប្រយោជន៍នៃទឹកដី មួយនោះ ដែលនៅក្នុងនោះ អ្នកធ្វើអាណានិគមបានអនុវត្តច្បាប់ទូលំទូលាយជាងរដ្ឋ ដែលស្ថិតនៅក្រោម អាណាព្យាបាលទៅទៀត ។ គេអាចសួរខ្លួនឯងថា នៅលើឋានៈ នៃគោលការណ៍ និងកាលណាអាណានិគមកិច្ចបានចប់នោះ តើឯណាទៅដែលជាតម្លៃ នៃខ្សែបន្ទាត់ទាំងនេះ ។

ប្រភពនៃការខុសគ្នាទាំងឡាយដែលមិនអាចប្រដូចនូវកម្មតិកម្មនេះ ទៅនឹងកម្ម-តិកម្មដទៃទៀត ដូចជានៅអាមេរិកខាងត្បូងនោះ គឺថារដ្ឋដែលស្ថិតនៅក្រោមការ ទំនុកបម្រុងមិនដែលឈប់ទៅជារដ្ឋមួយនោះទេ ហើយចំពោះឋានៈនេះ ការកែប្រែនូវ ព្រំដែនទាំងឡាយរបស់ខ្លួន ចាំបាច់ត្រូវតែស្ថិតនៅក្រោមលក្ខខ័ណ្ឌដែលកំណត់ដោយ ច្បាប់អន្តរជាតិ ។

ហេតុដូច្នេះហើយ ចំពោះប្រទេសកម្ពុជា អ្នកនិពន្ធបាននាំមកនូវការពិភាក្សានូវ បញ្ហាព្រំដែនបច្ចុប្បន្នរបស់ប្រទេសខ្លួន នៅក្នុងទំព័រទាំងឡាយដែលនឹងត្រូវបានវិភាគ និងពិភាក្សា ប៉ុន្តែនៅក្នុងរឿងមួយដែលពិបាកដោះស្រាយបែបនេះ អ្នកនិពន្ធបានចេះ រក្សាការប្រមាណនិងការសរសេរក្នុងការស្រាវជ្រាវដោយវិទ្យាសាស្ត្រ ។ អ្នកទ្រឹស្តី ខាងច្បាប់អន្តរជាតិ មិនភ្លេចថ្លឹងថ្លែងផលវិបាកជាក់ស្តែងនានា ដែលគេអាចភ្ជាប់ទៅ



នឹងសញ្ញាណទាំងឡាយដូចជាសញ្ញាណនៃអំពើអាក្រក់ នៃការយល់ព្រមឬសញ្ញាណនៃ ការជំពាក់គុណ ដែលដាក់បង្ខំដោយក្រុមអ្នកតំណាងនៃរដ្ឋមួយទៀត ឬក៏ប្រទេសដទៃ ទៀតជាច្រើន ដែលត្រូវបានពិនិត្យដោយអ្នកនិពន្ធ ។ ទ្រឹស្តីនៃព្រំដែនអន្តរជាតិមាន ការបញ្ជាក់នូវការវិភាគមួយដែលប្រឈមមុខជាមួយខ្សែបន្ទាត់បែងចែកផ្សេងៗ ទៀត ដែលអាចធ្វើឲ្យកើតមានជារូបរាងនូវព្រំប្រទល់នៃការកាន់កាប់នូវមុខងារ ផ្សេងៗនៃរដ្ឋាភិបាលជាតិ ឬអន្តរជាតិ ប៉ុន្តែគេមិនដឹងថា មានតែមុខងារទាំងនេះ ឬយ៉ាងណាដែលសម្រេចនូវការកំណត់អំពីឋានៈនៃអធិបតេយ្យភាពនោះ ។

ដោយជៀសវាងនូវសង្គ្រាមចាំកា និងដោយរក្សានូវការឈឺចាប់យ៉ាងខ្លាំងនោះ លោក សារិន ឆាក ក៏បាននាំឲ្យយើងជឿជងដែរថា អំពើហិង្សាមិនមែនជាការពឹងផ្អែក តែមួយគត់នោះទេ បើសិនជាក្តីសង្ឃឹមនេះនៅតែមានតម្លៃជានិច្ច និងនៅគ្រប់ ទីកន្លែងនោះ ក្តីសង្ឃឹមនេះគឺសម្រាប់ទាំងអស់គ្នា និងក៏ចំពោះប្រជាជនបារាំងផងដែរ គឺជាតម្លៃពិសេសមួយនៅពេលដែលប្រទេសទាំងនេះបានទទួលរងទុក្ខយ៉ាងខ្លាំងរួចមក ហើយនោះ ។

**Paul Reuter**

# សេចក្តីផ្តើម

សៀវភៅនេះ គឺជាផ្នែកទីមួយស្តីពីការសិក្សារួម អំពីព្រំដែនបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា ។

នៅពេលដែលបូរណភាពទឹកដីរបស់ប្រទេសខ្មែរស្ថិតនៅក្រោមការគំរាមកំហែងពីគប់ទិសទី ដោយការចង់បានពីប្រទេសជិតខាង ដែលព្យាយាមរកឃើញនៅទីនោះនូវការលំបាកផ្ទៃក្នុងរបស់ខ្លួនថែមទាំងអត្ថប្រយោជន៍នៃការចាំបាច់នៅក្នុងទស្សនៈវិស័យជាតិនោះ ការសិក្សាមួយប្រកបដោយវិទ្យាសាស្ត្រស្តីពីព្រំដែនកម្ពុជាគ្រាន់តែជាការបង្ហាញនូវការទាមទារប្រឆាំងនឹងបញ្ចេញឲ្យឃើញនូវការវាស់តម្លៃរបស់ខ្លួន និងជាគ្រឹះដ៏សំខាន់មួយនៃនយោបាយក្រៅប្រទេសរបស់កម្ពុជាហើយនឹងរកឃើញនូវការបំភ្លឺកាន់តែច្បាស់ជាង ។

សៀវភៅនេះ គឺសិក្សាតែទៅលើព្រំដែននៃប្រទេសកម្ពុជា ជាមួយប្រទេសឡាវនិងប្រទេសវៀតណាម គឺជាមួយអតីតជាដៃគូនៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធអាណានិគមដែលបានបង្កើតឡើងនូវសហភាពឥណ្ឌូចិន ។ យើងទុកការសិក្សាអំពីព្រំដែនខ្មែរ–ថៃនៅក្នុងសៀវភៅទីពីរដែលកំពុងតែរៀបចំ(កកន :យើងកំពុងតាមរកសៀវភៅនោះ) ។

ការកាត់ចេញនេះ មិនមែនជាការបំពានធ្វើឡើងដោយអំណាចចិត្តនោះទេ ។ ផ្ទុយទៅវិញ វាត្រូវបានចាប់បង្ខំដោយទិដ្ឋភាពខុសៗគ្នា ជាមូលដ្ឋាននូវបញ្ហាទាំងឡាយដែលបានចោទឡើងអំពីបញ្ហាព្រំដែននៃប្រទេសទាំងពីរ ។

ព្រោះថា នៅពេលដែលមានការគូសព្រំដែនខ្មែរ–ថៃ នោះគឺលទ្ធផលដែលធ្វើឡើងទៅតាមច្បាប់គតិយុត្តអន្តរជាតិ ដែលរៀបចំឡើងនៅចំពោះមុខប្រទេសស្យាម (ថៃឡង់ដ៍) ជាប្រទេសដែលស្ថិតនៅឯករាជ្យពីបារាំងជារៀងរហូត ដែលបារាំងជាមហាអំណាចការពារប្រទេសកម្ពុជានៅពេលដំបូង បន្ទាប់មកប្រទេសកម្ពុជាខ្លួនឯងបានទទួលឯករាជ្យ ហើយព្រំដែនជាមួយប្រទេសឡាវ និងប្រទេសវៀតណាម (អាណ្ណាម និងកូសាំងស៊ីន) គឺជាផលិតផលនៃនយោបាយផ្ទៃក្នុងរបស់អាណានិគមនិយមបារាំងដោយសុទ្ធសាធ ។



ម្យ៉ាងប្រទេសបារាំងបានការពារឥទ្ធិពលនៃតំបន់របស់ខ្លួនថែមទាំងអធិបតេយ្យភាពស៊ើរតែទាំងអស់ (នៃប្រទេសកម្ពុជា) ប្រឆាំងនឹងការរុញច្រានរបស់ អនុត្តរភាពនិយមនៃរដ្ឋជិតខាងមួយដែលបានគេចចេញពីអំណាចរបស់ខ្លួនម្យ៉ាងទៀត បារាំងបានគូសការបែងចែកខាងក្នុងនៅក្នុងក្របខ័ណ្ឌនៃទឹកដីទាំងអស់ ដើម្បីស្តារនូវអំណាចរបស់ខ្លួនទៅតាមឋានៈផ្សេងៗគឺ :

ម្យ៉ាងគឺ "ព្រំដែន" ដែលបង្កើតឡើងដោយកាត់ចេញពីអាណាព្យាបាលនៃប្រទេសកម្ពុជានូវទឹកដីអាណានិគមកូសាំងស៊ីន ឲ្យស្ថិតនៅក្រោមអធិបតេយ្យភាពទាំងស្រុងរបស់បារាំងដែលជាអាណាព្យាបាលដ៏សកម្មនៅអាណ្ណាម និងម្យ៉ាងទៀត គឺទឹកដីមិនច្បាស់លាស់ដែលបារាំងបានខិតខំបង្កើតទៅជាព្រះរាជាណាចក្រ ឡាវ ។

គឺថា ការប្រព្រឹត្តនូវអំណាចគ្របសង្កត់របស់បារាំង នៅក្នុងពេលធ្វើឲ្យមានស្ថិរភាពព្រំដែននៅដំណាច់សតវត្សរ៍ទី១៩ និងនៅដើមសតវត្សរ៍ទី២០ មិនអាចយកធ្វើជាគោលដៅបានឡើយ ។

បើប្រៀបធៀបនឹងអតីតប្រទេសទាំងឡាយនៅឥណ្ឌូចិន បើប្រៀបធៀបនឹងដីកូសាំងស៊ីនអាណានិគម ការខិតខំប្រឹងប្រែងនិងការទាមទាររបស់ប្រទេសអណ្ណាម , ប្រទេសឡាវ , ការកសាងអាណានិគមលើប្រទេសកម្ពុជា (ប្រទេសដែលគ្មានបញ្ហានោះ ) គឺត្រូវបានធ្វើឲ្យចាញ់ប្រៀបគេជានិច្ច និងជា យថាក្រម ។

ផែនទីដែលយើងភ្ជាប់មកជាមួយជាឧបសម្ព័ន្ធនេះ នឹងធ្វើឲ្យឃើញច្បាស់នូវការបាត់បង់ទឹកដី ដែលប្រទេសកម្ពុជាបានទទួលរងនៅក្នុងអំឡុងពេលកំណត់ព្រំដែននៅក្នុងតំបន់ទាំងនេះ ហើយជាពិសេសបើប្រៀបធៀបទៅនឹងអតីតទឹកដីអាណានិគមតាមប្រវត្តិសាស្ត្ររបស់ខ្មែរ ក្រៅពីកូសាំងស៊ីននោះ ។

ដើមកំណើតនៃស្ថានភាពនេះ ប្រហែលជាត្រូវបានកំណត់នៅក្នុងវិធានការដ៏ទូលំទូលាយមួយទៅតាមការរៀបចំនៃសន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ (សន្ធិសញ្ញាទីមួយនៃអាណាព្យាបាលបារាំងលើប្រទេសកម្ពុជា) ដែលបានដាក់តំណាង អា–ណាព្យាបាលបារាំងនៅប្រទេសកម្ពុជានៅក្រោមអំណាចទេសាភិបាលនៅកូសាំងស៊ីន។

ទឹកដីនៃអាណាព្យាបាល (កម្ពុជា) និងទឹកដីអាណានិគមកូសាំងស៊ីនជាប់គ្នាមែន

ប៉ុន្តែផលប្រយោជន៍របស់ទឹកដីទាំងពីរគឺផ្ទុយគ្នា ។ ភាពផ្ទុយគ្នានៃផលប្រយោជន៍ និងការខុសគ្នានៃលក្ខន្តិកៈមានឥទ្ធិពលផ្តល់ទោសដល់ប្រទេសដែលស្ថិតនៅក្រោមការទំនុកបម្រុងការពារ គឺប្រទេសកម្ពុជា ។ នៅចំពោះមុខនៃអាណានិគមកូសាំងស៊ីនទេសាភិបាលរង ដែលដើរតួជាប្រធានផងនោះ បានប្រព្រឹត្តខ្លួនដូចជាចៅហ្វាយខេត្តបារាំងម្នាក់ ហើយចំពោះប្រទេសវិញ គាត់បានចាត់ទុកខ្លួនគាត់ដូចជាតំណាងនៃសាធារណរដ្ឋបារាំងនៅអមទឹកដីផ្សេងគ្នា ដែលមានប្រធាននិងស្ថាប័នដោយឡែករបស់ខ្លួននៅក្នុងស្រុក ។

ដាក់តំណាងអាណាព្យាបាលបារាំងនៅប្រទេសកម្ពុជា នៅក្រោមអំណាចរបស់ទេសាភិបាលរងនៃអាណានិគម គឺស្មើនឹងដាក់ប្រទេសដែលស្ថិតនៅក្រោមការទំនុកបម្រុងការពារឲ្យនៅក្រោមអំណាចនៃអាណានិគម ។ ប្រការនេះហើយដែលអនុញ្ញាតឲ្យទេសាភិបាលមានសិទ្ធិទទួលបន្ទុកនៅក្នុងពេលជាមួយគ្នា ជាប្រធានអាណានិគម ផង និងជាចៅក្រមផង ក្នុងនាមជាឋានានុក្រមជាន់ខ្ពស់នៃតំណាងប្រទេសបារាំងប្រចាំប្រទេសកម្ពុជា ។

នៅក្នុងការអនុវត្តន៍នៃការបែងចែកនូវសមត្ថកិច្ចទាំងឡាយនេះបាននាំឲ្យប្រទេសដែលស្ថិតនៅក្រោមការការពារទទួលនូវផលវិបាកដ៏អកុសល ហើយផលវិបាកដ៏ធ្ងន់ធ្ងរបំផុតនោះគឺព្រំដែននៃទឹកដី ។

ព្រោះយើងនឹងឃើញថា គំនូសព្រំដែនបច្ចុប្បន្នដែលជាអច្ច័យទាន (Lc legs) នៃសម័យអាណានិគម តាមការពិតត្រូវបានកំណត់ជាឯកតោភាគី ដោយទេសាភិបាលកូសាំងស៊ីន ឬអគ្គទេសាភិបាលឥណ្ឌូចិន ហើយហេតុដូច្នេះផ្នែកសំខាន់ៗនៃទឹកដីរបស់ប្រទេសកម្ពុជាត្រូវបានដាក់ជាឧបសម្ព័ន្ធទៅឲ្យទឹកដីនៃអតីតកូសាំងស៊ីន ។

ដូច្នេះយើងមិនសរសេរអំពីការទាមទារ ដែលមានតែនៅលើការអះអាងដែលនៅឆ្ងាយពីការរៀបចំនៃប្រវត្តិសាស្ត្រនោះទេ ដែលជួនកាលតម្លៃមានការលំបាក ដើម្បីពន្យល់ដោយគតិយុត្ត និងធ្វើឲ្យជឿដោយតិចតួច តាមវិធីនយោបាយនៅក្នុងពេលបច្ចុប្បន្ន។ផ្ទុយទៅវិញយើងកំណត់នូវការរិះគន់មួយដោយគតិយុត្តឥតល្អៀងនូវព្រំដែនមួយ ដែលបានបង្កើតឡើងនៅក្នុងដំណាក់កាលប្រែប្រួលថ្មីៗនេះ ហើយដែលនៅតែ



ស្ថិតនៅលើច្បាប់គតិយុត្តនៅឡើយ។ យើងបានមើលឃើញនូវសារៈសំខាន់របស់វា ។

នៅចំពោះមុខនៃស្ថានការណ៍មួយបែបនេះ បញ្ហាសំខាន់ដែលយើងបានចោទសួរ និងដែលការស្រាវជ្រាវរបស់យើងមានបំណងប្រាថ្នាចង់បានយ៉ាងខ្លាំងនោះ គឺជាចម្លើយមួយស្តីអំពីលក្ខណៈនៃគំនូសព្រំដែនដែលបានកំណត់នៅក្នុងពេលធ្វើអាណានិគម ។ ចំពោះចម្លើយនេះនឹងស្ថិតនៅក្នុងចំណុះនៃជំហរដែលយើងនឹងជ្រើសរើសយកចំពោះបញ្ហាព្រំដែនកម្ពុជា ជាមួយនឹងបណ្តាប្រទេសនៃអតីតឥណ្ឌូចិនបារាំង ។

តើមានព្រំដែនអន្តរជាតិពិតប្រាកដ រវាងប្រទេសកម្ពុជា និងប្រទេសទាំងឡាយដែលនៅក្នុងនោះប្រទេសកម្ពុជាភ្ជាប់នៅក្នុងក្របខ័ណ្ឌនៃអតីតឥណ្ឌូចិនបារាំងដែរឬទេ? នៅក្នុងករណីដែលវាមាននោះតើតម្លៃនៃព្រំដែនទាំងនេះជាអ្វី ? តើមានគោរពច្បាប់នៃប្រទេសកម្ពុជាដែរឬទេ ? តើវាផ្ទុយឬប្រឆាំងនិងប្រទេសកម្ពុជាដែរឬទេ នៅពេលដែលប្រទេសនេះបានឯករាជ្យឡើងវិញនោះ ?

* *

*

យើងនិយាយហើយនិយាយទៀត អំពីព្រំដែននៃប្រទេសកម្ពុជានិងទឹកដីដែលបញ្ចូលជាសហព័ន្ធតាំងពីដើម នៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធឥណ្ឌូចិន គឺជាលទ្ធផលនៃការកំណត់ព្រំដែន ដែលការពិតត្រូវបានធ្វើឡើងជាឯកតោភាគី ដោយមហាអំណាចអាណានិគម ។

អំពើនេះនឹងពន្យល់នូវបញ្ហាទាំងឡាយថា ការទទួលស្គាល់របស់ពួកគេ ការកែតម្រូវជា យថាហេតុរបស់ពួកគេនិងការធានារបស់ពួកគេ មិនត្រូវបានបំភ្លេចក្នុងការលើកឡើងនៅក្នុងពេលបច្ចុប្បន្ននេះទេ ។ ការលំបាកទាំងនេះ តាមអាការៈខាងក្រៅទំនងជាមិនស្រដៀងគ្នា ជាមួយនឹងការលំបាកទាំងឡាយ ដែលបានធ្វើឲ្យឈឺចាប់ដល់អតីតអាណានិគមពិភពលោកនោះទេ ដែលកើតមាននៅអាហ្វ្រិក ឬក៏នៅអាស៊ី និងការលំបាកទាំងឡាយដែលគេបានស្គាល់នៅក្នុងអំឡុងពេលឈឺចាប់របស់គេ នៅអាមេរិកខាងត្បូងនោះទេ ។

ព្រោះថា តាមរបៀបជាទូទៅ ព្រំដែនដែលបានបង្កើតឡើងដោយមហាអំណាច

អាណានិគម កម្រមានមូលដ្ឋាននៃការពិនិត្យពិច័យតាមឋានានុក្រមនៃប្រវត្តិសាស្ត្រក្នុងស្រុកនៃជាតិពន្ធុនិងភាសានោះណាស់ ។ ព្រំដែននេះជានិច្ចជាកាល មិនត្រូវបានកសាងឡើងទៅជុំវិញទិន្នន័យភូមិសាស្ត្រធម្មជាតិនោះឡើយ ។ បើតាមស្ថានការណ៍ទាំងឡាយ ព្រំដែននេះជួនកាលគឺជាលទ្ធផលនៃកិច្ចព្រមព្រៀងអន្តរជាតិដែលបានរៀបចំនូវការបែងចែកនូវតំបន់ឥទ្ធិពលរបស់ខ្លួន ដែលឆ្លើយតបទៅនឹងស្ថិរភាពនៃកងទ័ពនៃបណ្តាប្រទេសអាណានិគម (ជាស្ថានការណ៍ដែលគេជួប ជាពិសេសនៅអាហ្វ្រិក) ។

ជួនកាលព្រំដែននេះមានដើមកំណើតមកតែពីនយោបាយគ្រប់គ្រងរបស់អាណានិគមដែលដឹកនាំដោយមហាអំណាចគ្របសង្កត់នៅក្នុងក្របខ័ណ្ឌនៃទឹកដីវិសភាគ (hétérogène) ទាំងអស់ដោយលើកកម្ពស់នូវអំណាចរបស់ខ្លួន ។ គឺទឹកដីឥណ្ឌូចិនបារាំងដែលយើងផ្តល់ជាឧទាហរណ៍ ។

នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះ វាជាការធម្មតា និងជាការចាំបាច់ដែលការសម្រេចដោយបំពាននេះ និងកិច្ចព្រមព្រៀងជាឯកច្ឆន្ទអំពីការដោះលែងពីអាណានិគមរបស់ប្រទេសដែលពីដើមស្ថិតនៅក្នុងចំណុះនោះ មិនដែលរកឃើញវិញឡើយ ។ម្យ៉ាងទៀតបញ្ហានេះគឺងាយស្រួលនឹងពន្យល់ណាស់ គឺនៅក្នុងគ្រប់វិធានការដែលការគូសព្រំដែនធ្វើឲ្យមានវិបរិតដល់ច្បាប់របស់ប្រទេសមួយនោះ វានឹងផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជិតខាង ហើយប្រទេសជិតខាងនេះ ថ្វីបើមានការប្រកែកក៏ដោយ ក៏តែងបង្ហាញនូវការចូលរួមសាមគ្គីចំពោះសកម្មភាព អាណានិគមនេះ ។

ជាការឲ្យទាស់ចិត្តណាស់ ដែលឥរិយាបថនេះ ទាំងនៅលើផ្លូវសីលធម៌ ទាំងនៅលើភាពសមហេតុសមផល (និងថែមទាំងនៅក្នុងផ្នែកតិយុត្តទៀតផង)គឺវាមាននៅក្នុងជីវភាពអន្តរជាតិបច្ចុប្បន្ននូវចរន្តមួយ ដែលនឹងត្រូវបានគេអត់ធ្មត់សុខចិត្តទទួលយកនោះ ។

ការគ្មានព្រំដែនពិតប្រាកដ នៅមុនពេលការធ្វើអាណានិគមកិច្ច ភាពមិនច្បាស់លាស់នៃច្បាប់ទាំងឡាយដែលសំអាងដោយភាគីនានា ការរំដើបរំជួលខាងនយោបាយដ៏ជ្រាលជ្រៅដែលនឹងបណ្តាលឲ្យមានការបោះបង់ចោលនូវអតីតព្រំដែនអាណានិគមបានញុះញង់ដល់លទ្ធិនិងការអនុវត្តន៍អន្តរជាតិ ឲ្យប្រាថ្នាចង់បាននូវការការពាររបស់ខ្លួន ។



ដើម្បីនឹងសម្រេចបានក្នុងរឿងនេះ គេបានឧទ្ទិសនូវគោលការណ៍គតិយុត្តមួយដែលវាមានកំណើតមកពីការរំដោះចេញពីអាណានិគមនៅអាមេរិកខាងត្បូង ដែលរួមបញ្ចូលនូវការគោរពនៃស្ថានភាពទឹកដីដែលបង្កើតឡើងដោយអាណានិគមកិច្ច គឺគោលការណ៍ L'uti possidetis (កាន់កាប់ទឹកដីពេលចប់សង្គ្រាមជាម្ចាស់កម្មសិទ្ធិ)។

តាំងពីនោះមក យើងត្រូវតែសួរជាដំបូងចំពោះការស្រាវជ្រាវទាំងអស់អំពីសារៈសំខាន់នៃគោលការណ៍នេះ និងអំពីភាពដែលអាចអនុវត្តបានជា យថាហេតុចំពោះស្ថានការណ៍ដែលកើតចេញពីការផ្ទុះឡើងនូវសហភាពឥណ្ឌូចិន និងជាពិសេសចំពោះព្រំដែននៃប្រទេសកម្ពុជា និងព្រំដែនរបស់អតីតដៃគូ នៅក្នុងក្របខ័ណ្ឌនៃការប្រជុំឡើងវិញ នូវអាណានិគមនេះ គឺមួយផ្នែកមានប្រទេសឡាវ និងមួយផ្នែកទៀតមានកូសាំងស៊ីនព្រមទាំងអណ្ណាមដែលប្រមូលផ្តុំនៅក្នុងពេលបច្ចុប្បន្ននៅក្នុងរដ្ឋវៀតណាម ។

រីមនទែនការឆ្លើយតបជាវិជ្ជមានមួយចំពោះភាពដែលអាចអនុវត្តបាននៃគោលការណ៍នេះនឹងធ្វើឲ្យឥតប្រយោជន៍ដល់ការស្រាវជ្រាវដោយប្រឹងប្រែងយ៉ាងខ្លាំងនូវរឿងនេះ ។

* *

*

គោលការណ៍នៃ L'uti possidetis : ចំពោះគោលការណ៍តែមួយនេះ នឹងអាចបង្កើតបាននូវកម្មវត្ថុនៃការសិក្សាស្វ័យតមួយដែលដឹកនាំនៅក្នុងទស្សនៈវិស័យទូទៅ ។ នៅក្នុងក្របខ័ណ្ឌនៃសេចក្តីផ្តើមនេះ យើងនឹងកម្រិតការចង្អុលបង្ហាញ ដោយសង្ខេបថាតើហេតុអ្វីបានជាយើងគិតថា មិនត្រូវរក្សាទុកចំពោះឥណ្ឌូចិន ការបំបាត់ជាលើកដំបូង ដែលធ្វើឲ្យទទួលស្គាល់ថា ត្រឹមត្រូវតាមច្បាប់នូវការស្រាវជ្រាវជាក់ស្តែងនៃច្បាប់ស្តីពីទឹកដីរបស់រដ្ឋជាសាមុី ។

**គោលការណ៍** L'uti possidetis **(ម្ចាស់កម្មសិទ្ធិកាន់កាប់ទឹកដីពេលចប់សង្គ្រាម) ត្រូវបានបំបែកចេញជាបីហេតុផល គឺ :**

- សម្រាប់ហេតុផលសជ្ឈន្តិកៈ (intrinsèque) ដែលកាន់នាទីចំពោះតម្លៃអនុវត្តនៃគោលការណ៍ ។

- សម្រាប់ហេតុផលដែលកាន់នាទីចំពោះសារៈសំខាន់នៃគតិយុត្ត ។
- សម្រាប់ហេតុផល ចំពោះលក្ខណៈដោយឡែកនៃករណីឥណ្ឌូចិន ។

មែនទែននៅក្នុង ១-មួយ ទស្សនៈយ៉ាងសង្ខេបមួយនៃបញ្ហាទាំងឡាយដែលជឿថា គោលការណ៍ដែលនៅក្នុងនោះ ព្រំដែនរដ្ឋបាលអាណានិគមស្ថិតនៅដោយហេតុនោះ ឯង នៅក្នុងពេលដែលបានឯករាជ្យ ត្រូវបានកែប្រែទៅជាព្រំដែនអន្តរជាតិ ដែលមានសក្តានុពលសម្រាប់ដោះស្រាយ រាល់ការលំបាកទាំងអស់ ។ ក៏ដូចគ្នាដែរ នៅពេលដែលរដ្ឋទាំងឡាយមានការព្រមព្រៀងជាគោលការណ៍ ដើម្បីទទួលស្គាល់ព្រំដែននោះ L'uti possidetis មិនភ្លេចនឹងលើកឡើងនូវបញ្ហាទាំងឡាយដែលសាន់វីណ្ឌ នោះ ឡើយ ។ ជាគំរូនៅអាមេរិកខាងត្បូងដែលបានបង្កើតនូវគោលការណ៍នេះ នៅមិនទាន់ជំនះបាននូវការលំបាកទាំងអស់ខាងព្រំដែននៅឡើយ ដែលគ្រប់គ្រាន់សម្រាប់ធ្វើឲ្យយើងជឿបាននោះ ។

លោកសាស្ត្រាចារ្យ ដឺ ហ្សូហ្វ្រឹស ដឺឡាប្រាដែល (De Geouffre de la Pradelle) នៅក្នុងសៀវភៅរបស់លោកស្តីអំពី "La Frontière" (ព្រំដែន) (និក្ខេបបទ ប៉ារីស ឆ្នាំ១៩២៨) (Thesè Paris 1928) ការពិតបានគូសបញ្ជាក់អំពីភាពមិនប្រាកដប្រជា ដែល "ធ្វើឲ្យខូច កិត្យានុភាព" នៃគោលការណ៍ និងជាពិសេសអំពីជម្លោះរវាងការបកស្រាយទាំងពីរនៃ L'uti possidetis គឺ uti possidetis នៃសិទ្ធិដែលសំដៅធ្វើឲ្យមានស្ថិរភាពព្រំដែននៅលើមូលដ្ឋាននៃភាពគតិយុត្តរបស់ភាគីនានា ប៉ុន្តែនៅពេលនោះ វាបានបើកផ្លូវទៅរកវិវាទកម្មជាច្រើន (ដែលអាមេរិកខាងត្បូងបានផ្តល់នូវឧទាហរណ៍ដល់យើង) អំពីសារៈសំខាន់ត្រឹមត្រូវពិតប្រាកដនៃស្ថានភាពទាំងនេះ ។ uti possidetis នៃហេតុការណ៍ពិត ដែលសំដៅចម្លងទាំងងងឹតងងល់នូវព្រំដែននៅលើស្ថានការណ៍នៃហេតុការណ៍ពិត ដែលកើតមាននៅពេលបានទទួលឯករាជ្យ ប៉ុន្តែវាទុកដូចជាប្រភេទនៃការអញ្ជើញមួយដោយប្រយោល ដើម្បីដណ្តើមយកទីតាំងនៃកម្លាំងនៅពេលចេញដំណើរជាពិសេសនៅពេលដែលព្រំដែន និងការតាំងការអភិបាលនៃសម័យអាណានិគម មានលក្ខណៈមួយមិនប្រាកដប្រជា ដែលករណីនេះកើតមានជាញឹកញាប់នោះ ។



ភាពទន់ខ្សោយទាំងនេះ បានកាត់បន្ថយជាអាទិ៍នូវផលប្រយោជន៍ដែលនឹងត្រូវបានរក្សាទុកជាគោលការណ៍សម្រាប់ឥណ្ឌូចិន ។

ប៉ុន្តែចំពោះកត្តាអវិជ្ជមានទីមួយនេះ ត្រូវបានបន្ថែមដោយកត្តាទី២ នៅលើគម្រោងនៃច្បាប់ គឺថា uti possidetis មិនមែនជាគោលការណ៍ដែលជាទម្លាប់ទូទៅរបស់ច្បាប់អន្តរជាតិនោះឡើយ ។ ចំពោះស្ថានភាពនេះវាពុំមានតម្លៃគតិយុត្តជាវិជ្ជមាននោះឡើយ ។ នៅក្នុងពេលបច្ចុប្បន្ននេះ វាហាក់ដូចជាមានប្រៀបនៅអាហ្វ្រិកចាប់តាំងពីមានសន្និសីទនៅទីក្រុង Addis-Abbeba (cf. កាសែត Le Monde Diplo-matique ថ្ងៃទី៣ ខែកក្កដា ឆ្នាំ ១៩៦៣ របស់អ្នកនិពន្ធ A.Blanchet : នៅទីក្រុង Addis-Abbeba គឺអាហ្វ្រិកដែលបានសម្តែងចេញនូវមនោសញ្ចេតនា និងសំអាងលើ ហេតុការណ៍និយមដែលបានឲ្យសច្ចាប័នលើសន្និសញ្ញានៃទីក្រុងប៊ែរឡាំង -Berlin) បញ្ហានេះបណ្តាលឲ្យមានការទទួលយកដោយសេរីរបស់បណ្តារដ្ឋនៅអាហ្វ្រិកនូវការយល់ព្រមដ៏ជាក់លាក់មួយ។ បញ្ហានេះវាគ្រាន់តែជាតម្លៃមួយដែលនៅមានកម្រិត នៅឡើយនិងមិនអាចរារាំងបាននូវការរក្សាការទាមទារទឹកដីខ្លះៗនោះបានឡើយ ។ ម្យ៉ាងទៀតការឧទ្ទិសចំពោះភាពមិនអាចប៉ះពាល់បាននៃក្របខ័ណ្ឌទឹកដីដែលកើតមកពីការធ្វើអាណានិគមបានលេចឡើងនៅទីនេះដូចជាមធ្យោបាយមួយនិងជាដំណាក់កាលមួយនៅលើផ្លូវនៃការប្រមូលផ្តុំឡើងវិញនូវរដ្ឋអាហ្វ្រិក ដែលបង្កើតបាននូវការ ទូន្មានមួយដែលគ្របដណ្តប់ទៅ Oharte នៃ O.U.A ។

ប៉ុន្តែនៅអាស៊ី ការយល់ព្រមបែបនេះមិនមានឡើយ ។ ពិតហើយគេនឹងធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍នៅក្នុងជម្លោះរវាងចិន និងឥណ្ឌា ។ ប៉ុន្តែគេមិនបានរកឃើញអ្វីច្រើននៅក្នុងទំនាក់ទំនងរបស់អតីតរដ្ឋជាសមាគមទាំងឡាយនោះឡើយ គឺប្រទេសកម្ពុជាមិនដែលបញ្ឈប់នូវការតវ៉ារបស់ខ្លួនប្រឆាំងនឹងការកំណត់នៃវៀត-ណាមនូវទឹកដីអាណានិគមកូសាំងស៊ីន ដូចដែលត្រូវបានកម្រិតព្រំដែនដោយប្រទេសបារាំងនោះ។ ប្រទេសកម្ពុជាបានធ្វើការតវ៉ាជាថ្មីនៅក្នុងសន្និសីទទីក្រុង ហ្សឺណែវនិងធ្វើជាច្រើនលើកជាបន្តមកទៀត ។

ប៉ុន្តែការបដិសេធនៃគោលការណ៍ មិនមែនជាហេតុការណ៍របស់ប្រទេសកម្ពុជា

តែមួយនោះឡើយ ។ ប្រទេសកម្ពុជាបានដកចេញនូវការទាមទារថ្មីៗនេះរបស់ប្រទេសលាវ ដែលរៀបចំឡើងដោយព្រះអង្គម្ចាស់ស៊ូវណ្ណាភូមា (Souvanna-Phouma ។ ប្រទេសកម្ពុជាបានអះអាងបញ្ជាក់យ៉ាងច្បាស់នៅក្នុងការទាមទារនូវកោះទាំងឡាយនៅតាមឆ្នេរសមុទ្រដែលធ្វើឡើង ដោយប្រទេសវៀតណាម ។ ដូច្នេះគេអាចនិយាយបានថា អតីតរដ្ឋទាំងឡាយនៅឥណ្ឌូចិន មិនចង់ឲ្យមានការជាប់ទាក់ទងជាមួយនឹងការកម្រិតព្រំដែន ដែលធ្វើឡើងដោយមហាអំណាចអាណានិគមនោះឡើយ។ ការបដិសេធ L' uti possidetis គឺជា ចំណុចរួមតែមួយនៃជំហររបស់ពួកគេ និងជាមូលដ្ឋានអវិជ្ជមានតែមួយគត់នៅក្នុង លទ្ធភាពនៃការចរចា ។

កិច្ចព្រមព្រៀងនេះនៅតែអាចពន្យល់បានដោយល្អឥតខ្ចោះ ព្រោះគោលការណ៍នេះមានលក្ខណៈសង្ខេបបន្តិចនិងចាស់បន្តិចហើយ វាមិនត្រូវនឹងសភាពការណ៍នៅឥណ្ឌូចិនឡើយ ។ វាមិនអាចនាំផ្លូវអ្វីបានក្នុងការស្វែងរកដំណោះស្រាយនិងបំផុសគំនិតរកមធ្យោបាយ ដើម្បីបំបាត់នូវការលំបាកបានឡើយ ។ នៅទីនេះយើងជួបប្រទះនូវហេតុផលទីពីររបស់យើង ដើម្បីបដិសេធនូវច្បាប់ L' uti possidetis ។

ការមិនអាចយកលំនាំតាមនូវគោលការណ៍ជាគ្រឹះនេះ នៅតំបន់របស់យើង ១-មួយគឺបណ្តាលមកពីរចនាសម្ព័ន្ធ អាណានិគមនៅឥណ្ឌូចិន មិនបានផ្តល់នូវសទិសភាពណាមួយពិតប្រាកដជាមួយនឹងអាមេរិកខាងត្បូងឬក៏សហព័ន្ធអាណានិគមនៅអាហ្វ្រិកស្បែកខ្មៅ នោះឡើយ ។

ព្រោះថា ឥណ្ឌូចិនត្រូវបានកសាងឡើងដោយទឹកដីដែលមានលក្ខន្តិកៈ គតិយុត្តខុសគ្នា ។ កម្ពុជា គឺជាប្រទេសមួយស្ថិតនៅក្រោមអាណាព្យាបាល ដូច្នេះមានកម្រិតនៃការរួមបញ្ចូលរបស់ខ្លួន (ម្យ៉ាងទៀតមានការជំរុញដោយតិចតួចនៅពេលគូសព្រំដែន) មិនដែលបាត់បង់នូវលក្ខណៈជារដ្ឋ និងបានគេចចេញពីស្ថានភាពនេះនៅក្នុងវិធានការមួយដ៏ពិតប្រាកដពីអាជ្ញាធរបារាំង ។ អ្នកជិតខាងដ៏សំខាន់របស់ខ្លួន គឺទឹកដីកូសាំងស៊ីន ជាទឹកដីអាណានិគម គឺជាភាគីរួមបញ្ចូលនៃសាធារណរដ្ឋបារាំង ។

ផ្ទុយទៅវិញ នៅអាមេរិកខាងត្បូង និងនៅអាហ្វ្រិកស្បែកខ្មៅ វាមានភាពដូចគ្នាមួយនៃលក្ខន្តិកៈអាណានិគម ។



*ភាពខុសគ្នាដោយគតិយុត្តនេះ វាមានផលប្រតិឃាត ចំពោះការគូសព្រំដែន ។* នៅពេលដែលមហាអំណាចអាណានិគមបង្កើតនូវខ្សែបន្ទាត់បែងចែកទឹកដីដែលលើកទៅដល់កម្រិតមួយស្មើនឹងអាជ្ញាធររបស់ខ្លួននោះ គេអាចទទួលស្គាល់ថា វាត្រូវបានលើកទឹកចិត្តដោយការកង្វល់ខាងបច្ចេកទេសដោយសុទ្ធសាធ ។ ពុំមានការប្រព្រឹត្តដោយមិនស្មើភាពណាមួយដែលមិនអាចត្រូវបានលើកឡើង នៅក្នុងការប្រព្រឹត្តរបស់ខ្លួន ចំពោះមណ្ឌលរដ្ឋបាលផ្សេងៗនោះឡើយ ។ *ភាពមិនស្មើភាពគ្នានេះបានខិតខំខ្នះខ្នែងគោរពនូវសមតាពិតប្រាកដមួយ ។* នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះ ការរក្សាឲ្យស្ថិតនៅជារដ្ឋនៅពេលដែលទទួលបានឯករាជ្យហើយនោះ មិនបានលើកឡើងនូវការជំទាស់ដ៏សំខាន់នោះទេ ។

ផ្ទុយទៅវិញ នៅចំពោះមុខវត្តមាននៃសហព័ន្ធដែលខុសគ្នា ដូចជាករណីនៅឥណ្ឌូចិននេះនិន្នាការធម្មជាតិ ហើយដែលការពិតបានធ្វើតាមនោះ គឺស្ថិតនៅលើការយោគយល់អនុគ្រោះដល់ទឹកដីអាណានិគមដែលធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសដែលស្ថិតនៅក្រោមការការពារ ។ មានវិសមភាពមួយនៃការប្រព្រឹត្តពីសំណាក់មហាអំណាចជាអ្នកការពារនឹងគោលការណ៍នៃការរក្សាឲ្យស្ថិតនៅជារដ្ឋ ដែលបានកើតឡើងចាប់ពីពេលនោះមកដោយកម្លាំងនៃវត្ថុទាំងឡាយ ដូចជាគោលការណ៍ដឹកនាំមួយ ដើម្បីប្រឆាំងនូវភាគីមួយជាគោលការណ៍មួយដែលមិនអនុគ្រោះ ហើយដែលដូច្នេះបាននាំឲ្យខូចរហូតដល់មូលដ្ឋានដោយទិដ្ឋភាពវិសមភាពរបស់ខ្លួន ។

នៅក្នុង ១- ទី២ គេត្រូវតែមើលឃើញឲ្យច្បាស់ថា អាស៊ីនៅសម័យមុនអាណានិគមបានបង្ហាញនូវកម្រិតនៃការវិវត្តន៍មួយចម្រុងចម្រើនយ៉ាងខ្លាំង ហើយដែលអង្គភាពទាំងឡាយរបស់ជាតិ ដែលបានប្រឆាំងនោះត្រូវបានបង្កើតឡើងដោយពេញលេញ និងមានមនសិការចំពោះការឯកភាពរបស់ខ្លួន ។

ច្បាប់ទឹកដីនៃរដ្ឋទាំងឡាយបានកំណត់មិនទៀងទាត់ (cf. ការស្រាវជ្រាវរបស់បេសកកម្ម Doudart de Lagreé) ។ *ដូច្នេះរដ្ឋអំណាចអាណានិគមមិនមែននៅចំពោះមុខនៃផែនទីនយោបាយមួយ ដោយគ្មានខ្លឹមសារនោះទេ ។ ពួកគេត្រូវប្រឈមមុខនឹងការពិតនៃភាពដែលមានមកពីមុន ហើយនៅក្នុងវិធានការដែលអាជ្ញាធរបារាំង មិន*

*បានគោរពនូវគោលការណ៍នៃប្រវត្តិសាស្រ្ត និងប្រជាភិវឌ្ឍន៍ទេនោះ ការកម្រិតព្រំដែនរបស់ខ្លួន គឺជាការប្រឆាំងដោយផ្ទាល់ជាមួយនឹងច្បាប់ទាំងឡាយ ដែលរដ្ឋនានាបានបង្កើតឡើងដោយឥតខ្ចោះនោះ ។ ដូច្នេះ គេនឹងស្ថិតនៅចំពោះមុខនៃជម្លោះនៃច្បាប់ ហើយមិនគ្រាន់តែជាភាពទទេដែលបំពេញដោយរំលោភនោះទេ ។ យកលំនាំតាមគោលការណ៍ L' uti possidetis (ច្បាប់អន្តរជាតិ : រូបមន្តការទូត សម្រាប់ប្រើប្រាស់ទាក់ទងនឹងសន្ធិសញ្ញាលើបញ្ហាកម្មសិទ្ធទឹកដីបច្ចុប្បន្ននៃអ្នកផ្ញើសង្រ្គាម) (The principle which vests in either of the belligerents at the end of a war all territory actually occupied and controlled by them) មិនមែនជា ការដោះស្រាយប្រកបដោយគតិបណ្ឌិត ដើម្បីបំពេញចិត្តនូវអ្វីដែលមានហើយ នោះទេ ថ្វីបើបញ្ហានេះមិនសូវពេញចិត្តក៏ដោយតែផ្ទុយទៅវិញ គឺដើម្បីយកឈ្នះការប្រព្រឹត្តរបស់អាណានិគមនិង "ច្បាប់" ទាំងឡាយដែលគេអាចធ្វើឲ្យកើតឡើងនូវច្បាប់របស់ជាតិពីមុន ។*

នៅទីបញ្ចប់និងជាពិសេស សភាពការណ៍នៅឥណ្ឌូចិន គឺខុសគ្នានឹងសភាពការណ៍ដែលបានផ្តល់កំណើតឲ្យ L' uti possidetis (នៅពេលចប់សង្រ្គាមអ្នកណាជាអ្នកកាន់កាប់ទឹកដីនោះ អ្នកនោះជាកម្មសិទ្ធិបុគ្គល) ដោយលក្ខណៈមួយទៀត ដែលពន្យល់និងបង្ហាញឲ្យឃើញថា ត្រូវជា យថាក្រមនូវការទាមទារទឹកដី គឺព្រំដែនអាមេរិក ឬអាហ្វ្រិក (នៅក្នុងវិធានការដ៏តូចតាច) បានកំណត់ព្រំដែនទឹកដីជាញឹកញាប់ក្នុងភាពទទេ និងជួនកាលថែមទាំងមិនទាន់មានគេរុករានទៀតផង ។ អំណាចផ្តាច់ការ គឺជាការចំបាច់ហើយក៏គ្មានផលវិបាកដោយផ្ទាល់ទៅលើជោគវាសនារបស់បុគ្គលទាំងឡាយដែរ ។

នៅប្រទេសកម្ពុជា នៅឥណ្ឌូចិនមានការប្រព្រឹត្តទៅខុសគ្នា ។ ព្រំដែនអាណានិគមបានពុះជ្រែកនៅចំកណ្តាលតំបន់មានជីវជាតិ និងមានប្រជាជនរស់នៅច្រើន ដែលតំបន់ទាំងនេះត្រូវបានផ្តាច់ចេញពីជាតិរបស់ពួកគេ (ពុះចំកណ្តាលនៃជាតិមួយឲ្យទៅជាជាតិពីរ) ពីសហគមន៍ភាសា ជាតិពន្ធ និងសាសនា របស់ពួកគេ ព្រមទាំងភូមិទាំងអស់ដែលបានឱនក្បាលដោយខ្លាច ដោយគ្មានការងើបឡើងបះបោរ ឬក៏ធ្វើការ



តវ៉ានោះ ។ ព្រំដែននោះវាបានធ្វើឲ្យខូចខាតដោយផ្ទាល់ដល់សិទ្ធិរបស់ប្រជាជនដែលគេបានចាត់ចែងដោយខ្លួនឯង ។ ព្រំដែននោះ វាបានធ្វើឲ្យជនជាតិភាគតិចទទួលរងនូវការជិះជាន់សង្កត់សង្កិន ។ ដូច្នេះវាមិនអាចទៅរួចទេ ក្នុងការស្វែងរកដំណោះស្រាយតាមគោលការណ៍ L'uti possidetis (The principle which vests in either of the belligerents at the end of a war all territory actually occupied and controlled by them) នោះ ។

បើសិនជាគេចង់យោងទៅរកនយោបាយសមាហរណកម្មនៃជនជាតិភាគតិចដែលបន្តស្វែងរកដោយរដ្ឋខ្លះនោះ ចំពោះការខិតខំប៉ុនប៉ង ដើម្បីលុបបំបាត់ដើមកំណើតនៃសង្គមវប្បធម៌ និងសាសនារបស់ខ្លួន ដែលជួនកាល បើកច្រកឲ្យមានការធ្វើទុក្ខ បុកម្នេញនោះ គេពិតជានឹងទទួលយល់ព្រមថា ការបដិសេធន៍នូវព្រំដែនអាណានិគម និងការទាមទារទឹកដីមិនមែនជាសញ្ញានៃចក្រព័ត្រនិយម ដែលមកក្នុងផ្លូវអាក្រក់នោះទេ ប៉ុន្តែគឺជាករណីយកិច្ចមួយដែលទប់មិនឈ្នះ ដែលនៅក្នុងនោះ គ្មានរដ្ឋណា ឬរដ្ឋាភិ-បាលណា ដែលស្ថិតនៅក្រោមសភាពការណ៍ស្រដៀងគ្នានេះមិនចេះគេចវេះដោយគ្មានការធ្វើខុសចំពោះបេសកកម្មរបស់ខ្លួននោះឡើយ ។

ក្នុងទីបំផុត វាដូចជាថា ការទទួលយកដោយអសកម្មនូវព្រំដែនអាណានិគម ដោយអនុវត្តតាមគោលការណ៍ L' uti possidetis ត្រូវបានបំបាត់ចោល ពីព្រោះថា គោលការណ៍នេះ គឺស្ថិតនៅឆ្ងាយពីប្រសិទ្ធិភាពផងដែរ ដែលមានអ្នកខ្លះចង់និយាយនោះពីព្រោះវាមិនមែនជាក្បួនអាជ្ញាបញ្ហានៃច្បាប់អន្តរជាតិវិជ្ជមាន ហើយដែលភាគីទាំងអស់ពាក់ព័ន្ធក្នុងរឿងហេតុនៅទីនេះបានព្រមព្រៀង ដើម្បីបដិសេធនូវច្បាប់នេះ ហើយនៅទីបញ្ចប់ពីព្រោះវាមិនត្រូវយកលំនាំតាមទាំងស្រុងចំពោះបញ្ហាទាំងឡាយក្នុងការដោះលែងពីអាណានិគមឥណ្ឌូចិននេះ ។

នៅក្នុងលក្ខខ័ណ្ឌទាំងនេះ ផ្លូវនៅទំនេរសម្រាប់ធ្វើការសិក្សាប្រកបដោយគតិយុត្តនិងមានប្រយោជន៍ចំពោះព្រំដែនកម្ពុជា–វៀតណាម និងលាវ ។

* * * * *

* * *

ការពិតវាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់អំពីច្បាប់ស្តីពីទឹកដីរបស់ប្រទេសកម្ពុជា ដើម្បីអាចប្រឈមមុខចំពោះសភាពបច្ចុប្បន្នដែលជាលទ្ធផលនៃនយោបាយអាណានិគម ។ ប៉ុន្តែនៅទីនេះគេត្រូវប៉ះទង្គិចនឹងការពិបាកមួយ គឺបើសិនជាអត្ថិភាពនៃការរួបរួមជាតិកម្ពុជានៅមុនការធ្វើអន្តរាគមន៍របស់អាណានិគមបារាំងមិនធ្វើឲ្យមានការសង្ស័យ និងបើសិនជាមានលទ្ធភាព ដើម្បីកំណត់ដោយជាក់ច្បាស់នូវទឹកដីនៃអធិបតេយ្យភាពខ្មែរនោះទេ តែថាគេត្រូវតែទទួលស្គាល់ថាវាមិនមានព្រំដែននៅក្នុងន័យទំនើបនៃពាក្យនោះទេ ។

ត្រង់ចំណុចនេះ ប្រទេសបារាំងអាចសប្បាយរីករាយដោយទទួលបាននូវសេរីភាពត្រឹមត្រូវតាមច្បាប់ពិតប្រាកដ ដើម្បីបង្កើតនូវខ្សែបន្ទាត់បែងចែកសមត្ថកិច្ច ហើយទើបនឹងធ្លាក់ទៅក្នុងការប្រកែកជាប្រវត្តិសាស្ត្រនិងដោយគ្មានតម្លៃ គឺការគូសព្រំដែនទាំងនេះដែលប្រតិបត្តិការដោយមហាអំណាចអាណានិគម ដែលត្រូវយកធ្វើជាការចេញដំណើរជាមូលដ្ឋាននៃការពិភាក្សា ។ គេត្រូវពិនិត្យលក្ខខណ្ឌនៃការបង្កើត និងអត្ថន័យរបស់វា ។

ការស្រាវជ្រាវនេះ បានធ្វើឲ្យលេចឡើងភ្លាមនូវសំណួរពីរជាបន្តបន្ទាប់ដែលបញ្ជាដល់របទាសម្ព័ន្ធទាំងអស់នៃការងាររបស់យើង ។

តើនៅក្នុងវិធានការណាដែលប្រទេសបារាំងបានបង្កើតនូវព្រំដែនគោកឬក៏ខ្សែបន្ទាត់រដ្ឋបាលដ៏ងាយស្រួលមួយ ដែលទុកនៅដោយគ្មានសៅហ្មងនូវបញ្ហាព្រំដែននេះ?

តើនៅក្នុងវិធានការណា ដែលខ្សែបន្ទាត់បង្កើតឡើង មានលក្ខណៈជាសេចក្តីប្រកាសសុទ្ធសាធ និងបង្កើតឡើងនៅលើច្បាប់នៃភាគីទាំងឡាយ ឬក៏ផ្ទុយទៅវិញ បានលើកឡើងនូវបញ្ហានៃសុពលភាព គតិយុត្ត ស្តីពីការផ្ទេរដែលបានសម្រេចឡើងដូច្នេះ ដែលជាទូទៅត្រូវបានគេវិភាគថា ដូចជាការបញ្ចូលជាឧបសម្ព័ន្ធនោះ ?

* * * * *

* * *

ការពិភាក្សាបែបនេះ មិនអាចដឹកនាំបានតាមរបៀបជារួមសម្រាប់ព្រំដែនទូទៅនោះបានឡើយ ។ ព្រោះថា បញ្ហានេះមិនបានបណ្តាលឲ្យមានអំពើប្រកបដោយគតិយុត្ត



ឬទាំងមិនមែនជាប្រតិបត្តិការដែលមានតែមួយនោះឡើយ ។ បញ្ហានេះវាបានសម្រេចធ្វើឡើងនៅក្នុងសម័យខុសគ្នា តាមផ្លូវគតិយុត្តទាំងឡាយដែលប្រែប្រួល និងនៅក្នុងលក្ខខណ្ឌនៃហេតុការណ៍ពិសេស នៅតាមសម័យនីមួយៗ និងនៅតាមវិស័យព្រំដែននីមួយៗ ។ ប៉ុន្តែកត្តាទាំងអស់នេះងាយទទួលប្រតិកម្មទៅលើចម្លើយទាំងឡាយដែលឆ្លើយតបនឹងសំណួរទូទៅរបស់យើង ។ ដូច្នេះការប្រែប្រួលនេះតម្រូវឲ្យមានការសិក្សាដោយមានការវិភាគតាមផ្នែកមួយទៅផ្នែកមួយទៀតនៃព្រំដែន ។

ប៉ុន្តែការបែងចែកជាផ្នែកនេះ មិនបានលើកឡើងនូវបញ្ហាដ៏ធ្ងន់ធ្ងរនៃវិធីនោះ ឡើយ ព្រោះថា ការលើកឡើងដដែលៗនូវគោលការណ៍មួយចំនួននៃហេតុការណ៍រួមមុខជានឹងនាំយើងទៅរកស្ថានភាពដដែលៗនៃការអះអាងហេតុផលគួរឲ្យធុញទ្រាន់ដែលបានរីកចម្រើនរួចហើយនោះ ។ ប៉ុន្តែម្យ៉ាងទៀត គេត្រូវតែគូសបញ្ជាក់ដោយការបង្ហាញជាយថាក្រមនូវលក្ខណៈនៃការធ្វើឲ្យខូចប្រយោជន៍ជាប់ជាប្រចាំដែលប្រទេសកម្ពុជាបានទទួលរង ។

ព្រមជាមួយគ្នានេះដែរ យើងត្រូវបាននាំឆ្ពោះទៅរកការប្រើប្រាស់នូវវិធីនៃការដាក់តាំងបង្ហាញចំពោះសេចក្តីគោរពរួម និងការគោរពផ្សេងៗទៀត ដោយមានលក្ខណៈប្លែកៗគ្នាយ៉ាងខ្លាំង ។ ចំពោះផ្នែកនីមួយៗ ដែលបានសិក្សាយើងត្រូវគូសបញ្ជាក់ពីខាងដើមអំពីវិសាលភាពនៃច្បាប់របស់ប្រទេសកម្ពុជា ក្នុងការដកចេញនូវព្រំដែន តែងតែត្រូវបានរៀបចំ ។

ចាប់ពីគោលការណ៍ជាមូលដ្ឋាននេះ យើងបានសិក្សានូវលក្ខណៈគតិយុត្តនិងសម្ភារៈនៃការរៀបចំព្រំដែន ជួនកាលដោយមានការភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការពិភាក្សាទៅលើលក្ខណៈជាគតិយុត្ត និងតម្លៃនៃព្រំដែន ជួនកាលនៅពេលដែលរឿងនេះមានលក្ខណៈស្មុគស្មាញពិសេស ដោយបំបែកចេញនូវរឿងនៃការអះអាងហេតុផលគតិយុត្ត ។

នៅក្នុងករណីចុងក្រោយទាំងនេះ យើងបានប្រកាន់យកនូវក្បួនដែលរំលឹកឡើងវិញដោយចាប់រហ័ស ការអះអាងហេតុផលគតិយុត្តដែលបានរីកចម្រើនរួចហើយ និងងាយរកឃើញនូវការអនុវត្តន៍នៅក្នុងផ្នែកផ្សេងៗទៀតតាមការផ្លាស់កន្លែងដោយងាយស្រួលហើយផ្ទុយទៅវិញ ដើម្បីបង្ហាញផ្លូវចំពោះការពិចារណាទាំងអស់របស់យើង ទៅ

រកការដាក់ឲ្យមានតម្លៃនូវទឡ្ហីករណ៍ដាក់លាក់ថ្មីដែលទាក់ទងទៅនឹងផ្នែកផ្សេងៗទៀត ហើយដែលនាំមកនូវការពង្រឹងចំពោះអ្នកដែលបានទទួលរួចហើយ ។

វិធីនេះតម្រូវឲ្យចាប់យកនៅក្នុងការសន្និដ្ឋានដ៏ទូលាយ នូវការពិចារណាទាំងអស់ និងការដាក់ឲ្យមានរបៀបរៀបរយនៅជុំវិញ ការអះអាងបញ្ជាក់ជាទូទៅខ្ញុំមានកម្រិតត្រូវបានគូសបញ្ជាក់ ។

ការសន្និដ្ឋានដោយការធ្វើសំយោគនេះ ក៏អាចឲ្យយើងកត់សម្គាល់បានផងដែរនូវទិដ្ឋភាពផ្លាស់គ្នាទាំងពីរ នៃនិក្ខេបបទរបស់យើង ដែលបានដឹកនាំដោយជៀសមិនផុតទៅរកភាពចាំបាច់នៃការគូសព្រំដែនថ្មី ឬមួយដោយមកពីគ្មានព្រំដែនគោកនៅឡើយ ឬមួយក៏ដោយសារព្រំដែនបច្ចុប្បន្នធ្លាក់ទៅក្រោមអំណាចនៃការទាមទារនូវការដោះលែងពីអាណានិគម ។

ការងាររបស់យើង គឺជាលទ្ធផលនៃការស្រាវជ្រាវរកឯកសារដោយម៉ត់ចត់ ដែលយើងបានដឹកនាំធ្វើជាបន្តបន្ទាប់នៅទីក្រុងភ្នំពេញ និងនៅទីក្រុងប៉ារីស ។

ហេតុការណ៍មួយចំនួនដែលយើងបានបញ្ចេញឲ្យឃើញ គឺមានការស្គាល់រួចហើយ ឯហេតុការណ៍មួយចំនួនច្រើនទៀត គឺមានលក្ខណៈថ្មីប្លែកមិនដែលមាន ។

ដើម្បីកុំឲ្យមានការថយចុះ កម្លាំងដែលជាភស្តុតាងនៃការពិចារណារបស់យើង ហើយនិងដើម្បីការពារឲ្យបានល្អនូវគោលដៅវិទ្យាសាស្ត្រ នៃការស្រាវជ្រាវរបស់យើងនោះ យើងបានផ្តល់នូវក្បួនដើម្បីជៀសវាងឲ្យអស់លទ្ធភាព ដើម្បីសង្កត់ទៅលើអត្ថបទទាំងឡាយ ឬសៀវភៅទាំងឡាយ ដែលកម្រមានដែលអាចផ្តើមជជែកនូវចំណុចមួយចំនួនដែលធ្វើឲ្យយើងចាប់អារម្មណ៍នោះ ។ ជាញឹកញាប់បំផុត យើងមានបំណងដើម្បីពឹងទៅលើការអះអាងអាថ្វាធរ និងដើម្បីបិទបាំងយើងនៅពីក្រោយការអះអាងដោយសង្ខេបដែលមិនអាចត្រួតពិនិត្យបាន ឬក៏ធ្វើឲ្យខូចទ្រង់ទ្រាយដោយក្តីកង្វល់របស់អាណានិគម ឬក៏របស់ជាតិ ។

សូមជឿថា ពុំមានសញ្ញានៃការមើលងាយចេញពីខាងយើងចំពោះការងារទាំងឡាយដែលជាញឹកញាប់មានលក្ខណៈល្អប្រសើរ និងពុំមានការធ្វេសប្រហែសនៅក្នុងការស្រាវជ្រាវនៃគន្ថនិទ្ទេស (bibliographique) ។



នៅរាល់ពេលដែលបញ្ហានេះអាចមាននោះ យើងត្រូវលុបនៅពីក្រោយគុណកថានៃរបាយការណ៍រដ្ឋបាល នៃលិខិត ឬសារជាផ្លូវការ ។ ដូច្នេះយើងបានសាកល្បងទុកឲ្យអ្នកដើរតួនានានិយាយ ឬក៏សាក្សីនៃព្រឹត្តិការណ៍ទាំងឡាយ ដោយកម្រិតទៅតាមលទ្ធភាពដែលអាចធ្វើបាននូវការអធិប្បាយរបស់យើង ។

សេចក្តីសន្និដ្ឋានទាំងឡាយ ដែលយើងបានសម្រេចដោយមានសេរីភាពពេញលេញគឺមានលក្ខណៈស្អាតទាំងស្រុង ។ សេចក្តីសន្និដ្ឋាននេះមិនមែនជាលេស ដើម្បីបង្កបង្កើតទស្សនៈ នៃរាជរដ្ឋាភិបាលខ្មែរ ឬក្រសួងកិច្ចការបរទេសនៃប្រទេសកម្ពុជាឡើយ ។ ត្រង់ចំណុចនេះ យើងចង់ធ្វើឲ្យបានសម្រេចនូវស្នាដៃមួយ នៃឯកសារដែលជួយសម្រួលដល់ការបង្កបង្កើតនូវការវិនិច្ឆ័យមួយ និងយោបល់មួយ ។

* * * * *

* * *

## ភាគទី I
## ព្រំដែន ខេត្ត ស្ទឹងត្រែង
## (ត្រើយខាងឆ្វេងនៃទន្លេមេគង្គ)
## ផ្នែកដែលរាប់បញ្ចូលរវាងទន្លេមេគង្គ និងប្រភពនៃ Dar - Hoyt
## (១៨៩៣ – ១៩២៩)

ព្រំដែនខ្មែរ – វៀតណាម បច្ចុប្បន្ននៅក្នុងខេត្តស្ទឹងត្រែង នៃប្រទេសកម្ពុជាបានបណ្តោយឲ្យស្ថិតនៅក្រោមអំណាចរបស់វៀតណាម នូវព្រំដែនមួយមិនច្បាស់លាស់ ដែល បើតាមទស្សនៈប្រវត្តិសាស្ត្រ ជាតិពន្ធ និងគតិយុត្តនោះ គឺជារបស់កម្ពុជាដោយមិនអាចប្រកែកបាន ។

ការសិក្សាមួយស្តីពីការវិវត្តន៍ នៃលក្ខខ័ណ្ឌនយោបាយ ឬខាងរដ្ឋបាលនៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធឥណ្ឌូចិន ស្តីពីតំបន់ទាំងនេះ គឺជាការគ្រប់គ្រាន់ ដើម្បីធ្វើឲ្យយើងជឿបាន ។

មែនហើយចម្ងាយផ្លូវដែលទៅដល់ទឹកដីជាតិខ្មែរ គឺមានលក្ខណៈស្មុគស្មាញ ដោយសារវាមានសភាពបត់បែនជាច្រើន ។ ការទៅដល់ទាំងនេះ ក៏មានលក្ខណៈទូលាយ និងប្រែប្រួលផងដែរ : យើងនឹងចូលរួមពិនិត្យមើលជាបន្តបន្ទាប់នូវការលុបបំបាត់ការគ្របសង្កត់របស់សៀម នៅវិទ្យាស្ថាននៃអធិបតេយ្យភាពអាណានិគមបារាំង ការភ្ជាប់ទៅប្រទេសលាវ បន្ទាប់មកគឺការផ្ទេរជាផ្នែក។ ចំពោះព្រះមហាក្សត្រដ៏ពិតប្រាកដតែមួយគត់របស់ប្រទេសកម្ពុជា ។

ម្យ៉ាងទៀតការប្រែត្រឡប់នេះ មានការបង្ហាត់បង្រៀនជាច្រើនចំពោះខ្លួនឯង ។ ការនេះវាបានបង្ហាញថា ការប្រែប្រួលនៃព្រំដែន គឺគ្រាន់តែជាល្បែងនៃការគិតគូររបស់ពួកអាណានិគម ដែលពួកគេមិនអាចឈ្នះបាននូវការពិតជាក់ច្បាស់ដែលនាំមកដោយប្រវត្តិសាស្ត្រនោះ... នោះគឺការពិតនៃអធិបតេយ្យភាពកម្ពុជា ដែលគេរកបានមកវិញនៅពេលចាប់ផ្តើមការទាមទារដែលធ្វើឡើង ចំពោះប្រទេសសៀម នៅក្នុងនាមនៃប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៨៩៣ និងការមកដល់នៅក្នុងការរៀបចំឡើងវិញ តែជាអភ័ព្វមានលក្ខណៈជាផ្នែក។អំពីច្បាប់នៃប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩០៤ ។



## ការលុបបំបាត់ការគ្របសង្កត់ពីប្រទេសសៀម
## សន្ធិសញ្ញាចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ ១៨៩៣

អនុសញ្ញាឆ្នាំ ១៨៩៣ ពុំមានសកម្មភាពដោយផ្ទាល់ចំពោះព្រំដែនកម្ពុជានៅត្រើយខាងឆ្វេងនៃទន្លេមេគង្គនោះទេ ។ កិច្ចព្រមព្រៀងជាអន្តរជាតិនេះ មានអនុភាពគ្រាន់តែ ដើម្បីកត់សម្គាល់នូវការបោះបង់ចោលរបស់សៀមនូវអធិបតេយ្យភាពដោយពិតដែលសៀមបានអនុវត្តនៅលើទឹកដី ទាំងនៅប្រទេសលាវ អណ្ណាមឬកម្ពុជាដែលស្ថិតនៅលើត្រើយខាងឆ្វេងនៃទន្លេមេគង្គ និង ដែលរួមមានតំបន់នានានៅក្នុងខេត្តស្ទឹងត្រែងរបស់កម្ពុជា ។

ការផ្តុំឲ្យដូចដើមឡើងវិញនូវបណ្តាខេត្តទាំងនេះត្រូវបានធ្វើឡើងនៅឯប្រទេសបារាំង ។ ប៉ុន្តែប្រទេសនេះនៅក្នុងកំឡុងពេលនៃការចរចាគឺបានធ្វើឡើងនៅក្នុងនាមនៃប្រទេសអណ្ណាម និង ប្រទេសកម្ពុជា ។ គឺនៅលើមូលដ្ឋាននៃច្បាប់របស់ប្រទេសទាំងនេះហើយដែលបារាំងបានធ្វើការទាមទារ និងទទួលបាននូវការប្រគល់មកវិញនូវទឹកដីទាំងនេះ ។ បើសិនជាសន្ធិសញ្ញា ឆ្នាំ ១៨៩៣ គឺជាសន្ធិសញ្ញាបរទេសដែលបានគូសវាសព្រំដែនខាងក្នុងក្របខ័ណ្ឌនៃទឹកដីទាំងអស់ដែលបានផ្តុំឡើងវិញនោះក៏ដោយ ប៉ុន្តែវាបានរួមបញ្ចូលនូវការត្រឡប់មកវិញនូវទឹកដីដែលបានបោះបង់ចោលទៅឲ្យគ្រូដើមរបស់ពួកគេរៀងៗខ្លួន ។ នោះហើយគឺជាកាតព្វកិច្ចអន្តរជាតិ ដែលត្រូវបានផ្តល់ឲ្យធ្វើជាគ្រឹះនៃការទាមទាររបស់បារាំង ។

សន្ធិសញ្ញានេះ គឺគ្រាន់តែជាចំណុចមួយនៃការចេញដំណើរតែប៉ុណ្ណោះ ។ វាបានចោទឡើងនូវការចែងមិនច្បាស់នូវគោលការណ៍នៃការបែងចែកទឹកដីនៅក្នុងពេលអនាគត ។ គោលការណ៍នេះមានតម្លៃជាអន្តរជាតិ វាជាកាតព្វកិច្ចសម្រាប់ប្រទេសបារាំងដែលជាភាគីនៃសន្ធិសញ្ញា ហើយគោលការណ៍នេះបានធ្វើឲ្យកើតឡើងនូវច្បាប់សម្រាប់ជាគុណប្រយោជន៍ដល់រដ្ឋនានា ដែលឈ្មោះរបស់ប្រទេសទាំងនោះត្រូវបានគេសំអាងលើវាបានចោទនូវព្រំដែននៃច្បាប់ទាំងនេះរៀងៗខ្លួន ។

ប៉ុន្តែចាប់ពីចំណុចនៃការចេញដំណើរនេះ ប្រទេសបារាំងត្រូវធ្វើឲ្យបានសម្រេចនូវវិធានការទាំងឡាយសម្រាប់អនុវត្ត ឬមួយតាមផ្លូវនៃសេចក្តីសម្រេចខាងរដ្ឋបាល

ស្របទៅតាមច្បាប់អន្តរជាតិ ឬមួយក៏តាមផ្លូវនៃការធ្វើសន្ធិសញ្ញាធ្វើកិច្ចព្រមព្រៀងជាមួយប្រទេសដែលខ្លួនការពារ [១] ។

យើងនឹងឃើញឥឡូវនេះអំពីការបែងចែកទឹកដីដែលប្រគល់ឲ្យវិញមានដំណើរការដោយមហាអំណាចជាអ្នកការពារយ៉ាងដូចម្ដេចខ្លះ...? ។

## ផ្នែកទី I
## ការភ្ជាប់ទៅក្នុងអាណានិគមកូសាំងស៊ីន នូវទឹកដីខ្មែរដែលបានផ្ដល់មកវិញ
## ( ខែតុលា ១៨៩៣ ‑ ខែមិថុនា ១៨៩៥ )

គឺដោយសារដំណោះស្រាយដ៏ចម្លែកនេះហើយ ដែលអគ្គទេសាភិបាល De Lanessan ( Gouverneur Général de Lanessan) បានយល់ស្រប ។

### ១/ – ការបែងចែកជាជុំនៃទឹកដីរដ្ឋបាល

សូមរំលឹកថា ទឹកដីដែលបានផ្ដល់មកវិញ ដែលមិនមែនជាទឹកដីកម្ពុជាទាំងអស់នោះត្រូវបានបែងចែកជាបី :

- លួងប្រាបាងខាងជើងបង្កបង្កើតដោយអតីតរាជាណាចក្រលួងប្រាបាង ។
- ទន្លេមេគង្គលើដែលស្ថិតនៅចន្លោះ Kemmarat និងលួងប្រាបាង ។
- ទន្លេមេគង្គកណ្ដាលលាតសន្ធឹងចាប់តាំងពីខេត្តស្ទឹងត្រែង និង ខោនរហូតដល់ប៉ាក់មូន ។

អគ្គទេសាភិបាលឥណ្ឌូចិន បានបង្ហាញនូវហេតុផលនៃការបែងចែកនេះនៅក្នុងលិខិតមួយច្បាប់ផ្ញើទៅជូនរដ្ឋមន្ត្រីនៃអាណានិគមចុះកាលបរិច្ឆេទថ្ងៃទី២ ខែធ្នូ ឆ្នាំ ១៨៩៣ ដែលមានសេចក្ដីជាអាទិ៍ថា ÷ "ប្រឡោះដីដ៏ធំសម្បើមដែលលាតសន្ធឹងតាមបណ្ដោយដងទន្លេមេគង្គ ដែលមានឈ្មោះថា ប្រទេសលាវ គឺស្ថិតនៅឆ្ងាយបន្តិចនៃការមានភាពជាប់ទាក់ទងគ្នា ដើម្បីអាចរួមផ្សំបានទៅជាអង្គការនយោបាយមួយ ។ មិនគ្រាន់តែស្មារតីរបស់អ្នកវិសេសនិយម (particulariste) នៃអ្នកស្រុកនៅតាមតំបន់នីមួយៗ ដែលបានប្រឆាំងប៉ុណ្ណោះទេ ប៉ុន្តែនៅមានការលំបាកខាងផ្លូវគមនាគមន៍រវាងចំណុចផ្សេងៗដែលជាឧបសគ្គមួយចំពោះមជ្ឈការនៃអាជ្ញាធរ ។ ខ្ញុំមិនត្រូវការបន្ថែមចំពោះការខ្វះខាតនៃធនធាន និង មិនអាចអនុញ្ញាតឲ្យអង្គការដូចគ្នានេះមានគ្រប់គ្រាន់ដោយខ្លួនឯងនោះទេ " [២] ។

ហេតុដូច្នេះវាមានមូលហេតុ ៣ ជាសំខាន់ ដែលបានញាំងឲ្យមានការបែងចែកនេះគឺភាពពិសេសនិយមរបស់ប្រជាជន ការខ្វះខាតផ្លូវគមនាគមន៍ ភាពមិនគ្រប់គ្រាន់នៃធនធានហិរញ្ញវត្ថុ ។

រដ្ឋការនៅលួងប្រាបាង ត្រូវបានប្រគល់ការទុកចិត្តទៅឲ្យ តុងកឹង ដែលបានផ្គត់ផ្គង់នូវសេចក្ដីត្រូវការខាងបុគ្គលិក និងសម្ភារៈរបស់ពួកគេ ។ "តាមលក្ខណៈភូមិសាស្ត្រ គឺជាមួយ តុង កឹង នេះហើយ ដែលលួងប្រាបាងមានការទាក់ទងដោយស្រួលបំផុត [៣] ។

តំបន់ទី ២ "មេគង្គលើ" ត្រូវបានភ្ជាប់ទៅខាងអណ្ណាម "គឺនៅក្នុងទឹកដីនេះហើយដែលមានផ្លូវគមនាគមន៍ពីរដ៏ល្អប្រសើរពីឆ្នេរសមុទ្រទៅដល់ទន្លេមេគង្គ ។ ផ្លូវធ្វើដំណើរដែលស្ថិតនៅខាងត្បូងបំផុត គឺផ្លូវពីកាមឡូ (Camlo) ទៅ កឹម ម៉ារ៉ាត (Kemmarat) តាមមួងធិន (Muong Thin) និង សុងខោន (Song - khône) ផ្លូវ មួយទៀតគឺពី វិញ (Vinh) ទៅអ៊ូថែន (Outhene) តាមណាប៉េ (Napé) កាម ម៉ុន (Cammon) កាមកាត (Kamcat) និងកៀន គិច (Kien-kiec) ផ្លូវនីមួយៗក្នុងផ្លូវទាំងពីរនេះបានយកមជ្ឈមណ្ឌលមួយធ្វើជាផ្នែករងខាងរដ្ឋបាល" [៤] ។ ប៉ុន្តែប្រវត្តិសាស្ត្រពីមុន និង លក្ខណៈពិសេសខាងជាតិពន្ធបានដាក់ឲ្យអគ្គទេសាភិបាល ស្ថិតនៅក្នុងកាតព្វកិច្ចផ្ដល់នូវលក្ខណៈមួយក្នុងការបន្ទន់ចិត្តចំពោះការភ្ជាប់នេះ ។

*(១) / យើងនឹងបានឃើញឡើងវិញ នូវសភាពការណ៍ដដែលនេះ ស្ដីពីអនុសញ្ញាបារាំង – សៀម ឆ្នាំ ១៩០៤ ។ គេនឹងបានឃើញនូវការសិក្សាដោយលំអិតអំពីសន្ធិសញ្ញាទាំងឡាយ ដែលបានបង្ហាញផ្លូវប្រវត្តិសាស្ត្រនៃទំនាក់ទំនងបារាំង–សៀម ចាប់តាំងពីការបង្កើត អាណាព្យាបាលបារាំង ទៅប្រទេសកម្ពុជានៅក្នុងភាគ II នៃសៀវភៅរបស់យើង ។*



*(២) / លិខិតរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ ១៨៩៣ ផ្ញើទៅឲ្យអនុរដ្ឋលេខាធិការ អាណានិគម សៀម (៥៣) ។*

*(៣) / ដូចគ្នា លិខិតខាងលើ ។*

*(៤) / ដូចគ្នា លិខិតខាងលើ ។*

ដូច្នេះខ្ញុំបានបង្កើតផ្នែករងនីមួយៗនៃផ្នែករងទាំងពីរទៅជា daos ពីរ [៥] គឺ dao នៃសុងខោន នឹង dao នៃកាមម៉ុន ។ ដូច្នេះខ្ញុំក៏បានបំពេញឲ្យពួកគេតាមទស្សនៈអណ្ណាមគឺលក្ខណៈនៃភាពនៅក្នុងចំណុះជាបរិវារនៃខេត្ត ក្វាងប៊ិញ និងក្វាងទ្រី សម្រាប់ dao ទី១ ខេត្ត ង៉េអាន និងហាទិញ សម្រាប់ dao ទី២ ។ ប៉ុន្តែការភ្ជាប់នេះមិនមានផលវិបាកដើម្បីពង្រីករដ្ឋការអណ្ណាមទៅដល់ទឹកដីលាវទាំងនេះទេ " [៦] ។

តំបន់ទាំងពីរនេះគឺគេមិនស្គាល់ទេ នៅក្នុងប្រទេសកម្ពុជា ហើយមិនបានធ្វើឲ្យយើងចាប់អារម្មណ៍ដោយផ្ទាល់នោះឡើយ ។

ការចង្អុលបង្ហាញខ្លះៗនេះ មិនមានគោលដៅណាផ្សេងក្រៅតែពីការផ្តល់នូវទិដ្ឋភាពរួមនៃបញ្ហាទាំងឡាយដែលបានកើតចេញពីការអនុវត្តសន្ធិសញ្ញាឆ្នាំ ១៨៩៣ នោះទេ ។ ហើយក៏ដើម្បីគូសបញ្ជាក់ផងដែរនូវការរួញរារបស់បារាំង និង ភាពមិនប្រាកដប្រជាដែលបានសារភាពពីនយោបាយអាណានិគម និងការភ្ជាប់ខាង រដ្ឋបាលនេះ ។

## ២ – សភាពការណ៍រដ្ឋបាលនៃទន្លេមេគង្គកណ្តាល

### ក) ការភ្ជាប់ទៅដែនដីកូសាំងស៊ីន

តំបន់មេគង្គកណ្តាលមានរួមបញ្ចូលទឹកដី ដែលផ្តុំឡើងវិញ ដោយប្រទេសសៀមបន្ទាប់ពីការទាមទារដែលធ្វើឡើងនៅក្នុងនាមប្រទេសកម្ពុជា ។ តំបន់នេះលាតសន្ធឹងចាប់តាំងពីខេត្តស្ទឹងត្រែងរហូតដល់ចាក់មូន និងត្រូវបានបែងចែកបន្តទៅជាពីរផ្នែកទៀតគឺ ៖

– ម្យ៉ាង គឺទន្លេពិតប្រាកដជាមួយនឹងកោះទាំងឡាយដែលសំខាន់ គឺកោះខុង ។

– ម្យ៉ាងទៀត គឺត្រើយខាងឆ្វេងជាមួយខេត្តស្ទឹងត្រែង សៀមប៉ាង និងអាតូពើ ធ្វើជាមជ្ឈមណ្ឌលដ៏សំខាន់ ។ ទីស្នាក់ការរដ្ឋបាលស្ថិតនៅស្ទឹងត្រែង ។

ដូយនឹងការរង់ចាំទាំងអស់ តំបន់នេះត្រូវបានភ្ជាប់ទៅឲ្យកូសាំងស៊ីន ។

ការដោះស្រាយមានលក្ខណៈសមហេតុផលដោយតិចតួច ព្រោះថា តំបន់ដែល

*(៥) / មណ្ឌល រដ្ឋបាល*

*(៦) / លិខិតចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ ១៨៩៣ របស់អគ្គទេសាភិបាលឥណ្ឌូចិន ដូចបានបែងខាងលើ ។ គឺយើងដែលបានគូសបញ្ជាក់នូវឃ្លាចុងក្រោយ ពីព្រោះថា រដ្ឋការអាណានិគមជាទូទៅមានសម្បជញ្ញៈពេញលេញអំពីលក្ខណៈរដ្ឋបាល ដែលមិនរួមបញ្ចូលនូវគំនូសព្រំដែនដែលគេធ្វើបានសម្រេចនោះ ។*



បានពិនិត្យនេះត្រូវបានកាត់ចេញពីដែនកូសាំងស៊ីនដោយប្រទេសកម្ពុជា ។

ភាពមិនសមតាមតក្កវិជ្ជានេះ បានធ្វើឲ្យប៉ះពាល់ដល់អគ្គទេសាភិបាលស្តីទី លោក Chavassieux ដែលលោកបានសរសេរថា "គួរឲ្យឆ្ងល់បង្គួរដោយបានសង្កេត ឃើញថាប្រទេសកម្ពុជាត្រូវបានបញ្ចូលទៅប្រទេសលាវ ដោយសារទីតាំងភូមិសាស្ត្រ របស់ខ្លួន ភាពដូចគ្នានៃជាតិសាសន៍ អតីតកាល និងប្រពៃណីរបស់ខ្លួន ប៉ុន្តែប្រវត្តិសាស្ត្ររបស់ខ្លួនបានស្ថិតនៅ ពុំនោះទេ នឹងមានការខ្វែងគំនិតគ្នា ក្នុងព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរនាឆ្នាំ ១៨៩៣ ហើយយ៉ាងហោចណាស់ ក៏គេមិនដែលស្គាល់ចំពោះការកែប្រែ ទឹកដីដែលចេញជាលទ្ធផលនេះដែរ ។ មានតែប្រទេសកម្ពុជាមួយទេ នៅក្នុងចំណោមរដ្ឋឥណ្ឌូចិន បារាំងដែលមិនបានបន្ថយនូវព្រំដែនរបស់ខ្លួន ប៉ុន្តែដូយទៅវិញប្រទេសនេះមិនបានចុះបញ្ជីនៅក្នុងថវិការបស់ខ្លួននូវឥណទានថ្មីណាមួយឡើយ ។ បច្ចុប្បន្ននេះនៅកណ្តាលព្រះរាជាណាចក្ររបស់ព្រះមហាក្សត្រ ព្រះនរោត្តម គឺភូឈួយទេសាភិបាលជាអ្នកគ្រប់គ្រងប្រទេសទាំងឡាយ ដែលលោកទទួលបន្ទុកនៅលើដែនដីទន្លេមេគង្គ" [៣] ។ ទេសាភិបាលស្តីទី បានរកឃើញថា អង្គការដែលគ្មានការទាក់ទងគ្នានេះ គឺមិនសូវល្អ និងថែមទាំងគ្រោះថ្នាក់ទៀតផង ។

រដ្ឋមន្ត្រីអាណានិគម ខ្លួនលោកផ្ទាល់មិនបានរកឃើញនូវសភាពការណ៍នេះដោយគ្មានការងឿងឆ្ងល់នោះឡើយ ។ លោកបានចុះនៅលើលិខិតរបស់អគ្គទេសាភិបាលស្តីទីនូវសេចក្តីសង្កេតដូចតទៅ ៖ "ប្រហែលជាដោយសារព្រះអង្គ (ព្រះមហាក្សត្រ នរោត្តម) មិនបានពិគ្រោះយោបល់ក្នុងការចាត់ចែងរឿងនេះ" ។

ដូច្នេះ តើហេតុផលអ្វីក្នុងការភ្ជាប់នេះដែលដំណើរការដោយអគ្គទេសាភិបាល de Lanessan ?

គេត្រូវតែញែកចេញឲ្យច្បាស់រវាងហេតុផល ដែលស៊ីជម្រៅ និងលេសនានា ។

### ១ ) ហេតុផល ស៊ីជម្រៅ

ការភ្ជាប់នៃតំបន់ទន្លេមេគង្គ មិនមែនជាលទ្ធផលនៃការផ្តួចផ្តើមដោយចៃដន្យ

*(៣) / លិខិតរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ ១៨៩៤ ផ្ញើទៅជូនរដ្ឋមន្ត្រីអាណានិគមឥណ្ឌូចិន D 831 ។*

នោះឡើយ វាបានចារិកនៅក្នុងអាគារនយោបាយដែលបានរៀបចំទុកជាមុន និងសំដៅទៅរកគោលដៅជាក់លាក់ ។

**ក –** នៅឆ្នាំ ១៨៨៦ ទេសាភិបាលកូសាំងស៊ីន លោកFilippini បានរាយការណ៍អំពីចក្រពត្តិនិយម អាណានិគមនៅកូសាំងស៊ីនចំពោះទន្លេមេគង្គកណ្ដាលដែលជាយូរក្រោយមកបានញុំាងឲ្យ de lanessan ចង់ធ្វើ " ដូចដឹងស្រាប់ហើយ ខ្ញុំគ្រាន់តែធ្វើដើម្បីចង្អុលបង្ហាញជាបន្ទាប់បន្សំនូវបញ្ហានៃប្រទេសលាវនេះ ដែលនៅក្នុងនោះ ខ្ញុំអាចផ្ដល់នៅពេលក្រោយ បើសិនជាអ្នកយល់ថា មានប្រយោជន៍នូវព័ត៌មានជាក់លាក់បំផុត ដោយបង្ហាញអំពីផលប្រយោជន៍ទាំងអស់ដែលយើងត្រូវបែរទៅរកកូសាំងស៊ីននូវការធ្វើពាណិជ្ជកម្មជាមួយទេសភូមិ (Contreés) ដ៏ធំធេងនេះ និងជាពិសេសចំពោះទេសភូមិនៃជ្រលងអាតូពើដ៏មានទេះជីវជាតិ...។

"ស្ទឹងត្រែងត្រូវតែជាគោលដៅទីមួយរបស់យើង ។ មជ្ឈមណ្ឌលនេះស្ថិតនៅលើទន្លេធំ ត្រង់ពាមនៃទន្លេមេគង្គត្រូវបានដាក់គួរឲ្យស្ញើច ដើម្បីអាចឲ្យសង្កេតមើលនូវអ្វីៗដែលកើតមាននៅទីខ្ពស់បំផុត ដើម្បីពង្រីកឥទ្ធិពលបារាំងទៅលើខេត្តនានា នៅទន្លេរពៅនិងម្លូព្រៃនិងដើម្បីស្គាល់ជ្រលងអាតូពើនេះដោយក្ដីសង្ឃឹមដ៏ពេញលេញ... ស្ទឹងត្រែងទទួលបាននូវសារៈសំខាន់ដ៏ធំធេង ហើយយើងត្រូវធ្វើនូវអ្វីៗទាំងអស់ ដើម្បីយើងជួបទាក់ទងកាន់តែជិតស្និទ្ធថែមទៀតជាមួយពាណិជ្ជកម្មអង់គ្លេស ដែលនឹងបានទទួលឥទ្ធិពលធំបង្គួរនៅតាមបណ្ដោយទន្លេអ៊ូ ប៊ុន...។

"សង្ខេបមកលោករដ្ឋមន្ត្រី ខ្ញុំមានយោបល់ចំពោះហេតុផលដែលបានលើកឡើងខាងលើដើម្បីប្រកាន់យកជាបន្ទាន់នូវវិធានការទាំងឡាយដូចតទៅនេះ គឺបញ្ជូនទៅស្ទឹងត្រែងនូវមន្ត្រីម្នាក់របស់រដ្ឋការកូសាំងស៊ីន ដើម្បីទទួលបន្ទុកនៅក្នុងល័ក្ខខ័ណ្ឌទាំងឡាយដែលបានបង្ហាញនៅផ្នែកខាងដើមនៃរបាយការណ៍នេះ ដើម្បីសិក្សាអំពីធនធានទាំងឡាយរបស់ប្រទេស ដើម្បីផ្ដល់ពាណិជ្ជកម្មរបស់យើងនូវព័ត៌មានទាំងអស់ដែលគេអាចត្រូវការ និងដើម្បីបញ្ចូលឥទ្ធិពលបារាំងរហូតដល់ក្នុងខេត្តទាំងឡាយរបស់លាវ..." (៨) ។

***(៨) / លិខិតរបស់អគ្គទេសាភិបាលកូសាំងស៊ីន លោក** Filippini **ចុះថ្ងៃសីហា ឆ្នាំ ១៨៨៦ ផ្ញើទៅក្រសួងដែនដីទឹក និងអាណានិគម សៀម ២៨ ។***



**ខ –** ម្យ៉ាងទៀតទស្សនៈនយោបាយនេះបានចេញរបាយការណ៍ទាំងឡាយដោយផ្ទាល់ដែលរៀបចំឡើងដោយ**បេសកកម្ម** Doudart de Lagrée **ពីឆ្នាំ ១៨៦៧ ទៅ ដល់ឆ្នាំ ១៨៦៩** ដែលបានបញ្ចេញឲ្យដឹងអំពីផលប្រយោជន៍ខាងនយោបាយ និង សេដ្ឋកិច្ចនៃតំបន់ស្ទឹងត្រែង ។

**១ – ផលប្រយោជន៍ខាងនយោបាយ**

បេសកកម្ម Doudart de Lagée អាចយល់ដឹងបាននៅទីងកន្លែងក្រៅពីខេត្តបាត់ ដំបង សៀមរាប ដែលបានប្រគល់ឲ្យសៀម ដោយសន្ធិសញ្ញាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៨៦៧ នូវទឹកដីផ្សេងៗទៀតរបស់កម្ពុជា ត្រូវបានដណ្ដើមយកដោយប្រទេសសៀមដោយ "មធ្យោបាយដែលគួរឲ្យសារភាពដោយតិចតួច" ។ មានខេត្តទាំងឡាយដូចជា ធុនកាន (ចុងកាល់) សង្កា (សង្កៀក) កូកាន (គោកខ័ណ្ឌ) ស៊ូរ៉ែន ទន្លេរពៅ និងម្លូព្រៃ ដែលរស់នៅដោយប្រជាជនកម្ពុជាទាំងស្រុង ។ ដូច្នេះប្រទេសបារាំងមានទឡ្ហីករណ៍ប្រាកដប្រជាល្អណាស់ដើម្បីទាមទារនៅក្នុងនាមប្រទេសកម្ពុជាដើម្បីធ្វើឲ្យដូចដើមឡើងវិញនូវខេត្តទាំងឡាយដែលមាននៅចន្លោះបឹងធំ និងទន្លេកូរ៉ាត ។

បេសកកម្មថែមទាំងបានស្នើដើម្បីជាការដោះស្រាយនូវការប្ដូរខេត្តបាត់ដំបង និងខេត្តសៀមរាបដែលកាន់កាប់ដោយប្រទេសសៀមត្រូវបានធ្វើឲ្យទៅជាស្របច្បាប់ដោយសន្ធិសញ្ញាឆ្នាំ ១៨៦៩ ជាមួយនឹងខេត្តចុងកាល់ សង្កៀក គោកខ័ណ្ឌ និងសូរ៉ែន ។ "ចំពោះខេត្តទន្លេរពៅ និងម្លូព្រៃ ក៏ត្រូវបង្វិលទៅឲ្យប្រទេសកម្ពុជាវិញដែរ ពីព្រោះខេត្តទាំងនេះអាចត្រូវបានចាត់ទុកថា ជាកូនសោរនៃជ្រលងទន្លេ និងការឆ្លងកាត់របស់ទឹកធ្លាក់ នៅខោន" (៩) ។

ម្យ៉ាងទៀតវាមានប្រយោជន៍សម្រាប់ប្រទេសបារាំងដើម្បីរៀបចំនៅទន្លេបាសាក់។ ព្រះរាជាណាចក្រនេះ ដែលជាផ្នែកមួយរបស់ប្រទេសកម្ពុជានោះ ស្ថិតនៅក្រោមអំណាចចាមជាបន្តបន្ទាប់ ហើយបន្ទាប់មកស្ថិតនៅក្រោមនឹមរបស់សៀមដែលព្រះរាជាណាចក្រនេះបានក្លាយទៅជាចំណុះគេ ។ នៅសង្កាត់នៃបេសកកម្ម Doudart de Lagrée ព្រះមហាក្សត្រនៃបាសាក់បានបើកចំហរជាច្រើនដងដល់ប្រធានបេសកម្ម

***(៩) / របាយការណ៍ស្រាវជ្រាវរុករកទន្លេមេគង្គ ថ្ងៃទី២ កុម្ភៈ ១៨៦៩ ចុះហត្ថលេខាដោយ លោក** F.Garnier . Indochine C. 10 ( 73 ) ។*

ដើម្បីទទួលបានអាណាព្យាបាលបារាំងដូចដែលបានធ្វើនៅក្នុងប្រទេសកម្ពុជា ដែលប្រាថ្នាចង់បានយ៉ាងក្លៀវក្លា "ចំពោះព្រះមហាក្សត្រនៃបាសាក់វិញ ព្រះអង្គបានគាំទ្រទាំងក្ដីអំណត់នូវនឹមរបស់ក្រុមបាងកក និងបានស្នើដោយទទូចចំពោះមេបញ្ជាការ de Lagrée នៅក្នុងអំឡុងពេលស្នាក់នៅរបស់គណៈកម្មការនៅបាសាក់ ដើម្បីទទួលយកអាណាព្យាបាលបារាំងនៅក្នុងលក្ខខ័ណ្ឌដូចគ្នានឹងព្រះមហាក្សត្រកម្ពុជា ដែលទ្រង់បានធ្វើ"(១០) ។

ដូច្នេះប្រទេសបារាំងបានឈានទៅដល់គោលដៅពីរ គឺជំរុញឲ្យដូចដើមឡើងវិញចំពោះប្រទេសដែលខ្លួនការពារ គឺប្រទេសកម្ពុជា នូវទឹកដីទាំងឡាយ ដែលខ្លួនបានដកហូតដោយការមើលងាយទៅលើច្បាប់ទាំងអស់ ហើយបានទៅតាំងនៅត្រើយខាងស្ដាំនៃទន្លេមេគង្គកណ្ដាលដើម្បីទប់ទល់គ្នាបានជាមួយនឹងឥទ្ធិពលរបស់សៀម ។

នោះហើយគឺជាសុបិនរបស់ Doudart de Lagrée និងមេបញ្ជាការរងរបស់លោក គឺលោក F.Garnier ជាសុបិនដែលគ្មានអ្នកណាម្នាក់មានសំណាងដើម្បីធ្វើឲ្យបានសម្រេចនោះឡើយ ។ ហើយដែលនឹងត្រូវបានសម្រេចចេញជារូបរាងនៅពេលយូរក្រោយមកទៀតក្រោយពីការស្លាប់របស់ពួកគេទៅនោះ ។

ប៉ុន្តែមួយផ្នែកធំនៃគុណូបការៈនេះបានត្រឡប់មករកពួកគេវិញ គឺពួកគេនេះហើយដែលបានយល់នូវគំនិតនេះ និងដែលបានចង្អុលបង្ហាញផ្លូវសម្រាប់គេធ្វើតាម។ "ការសម្រេចបាននូវការផ្សំផ្គុំនេះ ច្បាស់ជានឹងមានលក្ខណៈលំបាកខ្លាំង ដើម្បីធ្វើឲ្យក្រុងបាងកកយល់ព្រម ហើយនឹងធ្វើភាពជាម្ចាស់របស់បារាំងនៅឥណ្ឌូចិននូវភាពជុំគ្នាបំផុត និងណែនបំផុតដែលលាតសន្ធឹងរហូតដល់មាត់ពាមនៃទន្លេអ៊ូបុន នៅលើទន្លេធំ ហើយដូច្នេះនិងបានធានាដល់យើងនូវប្រែកលំហដ៏សំខាន់នៃខ្ពង់រាបដ៏មានជីវជាតិនៅកូរ៉ាត (១១) ។

ការប្រគល់ឲ្យវិញនូវត្រើយខាងឆ្វេងនៃទន្លេមេគង្គដោយប្រទេសសៀម ត្រូវបានផ្ដល់ឲ្យបារាំងនូវលទ្ធភាព ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួននៅត្រើយខាងស្ដាំ ។

**២ – ផលប្រយោជន៍ខាងសេដ្ឋកិច្ច**

*(១០) / ដូចគ្នា របាយការណ៍ខាងលើ ។*
*(១១) / របាយការណ៍ក្រោកទន្លេមេគង្គ ដែលបានរៀបរាប់ខាងលើ ។*



បេសកកម្មរបស់លោក Doudart de Lagrée បានប្រាប់លក្ខណៈអំពីផលប្រយោជន៍សម្រាប់កូសាំងស៊ីនឲ្យងាកទៅរកទីក្រុងសាយហ្គន ដើម្បីធ្វើពាណិជ្ជកម្មនៅតំបន់នេះ ។ ជាជាងដឹកតាមផ្លូវធម្មជាតិតាមបឹង និងទន្លេមេគង្គនោះ ផលិតផលទាំងឡាយត្រូវបានដឹកតាមផ្លូវគោកដ៏វែង និងពិបាកបំផុត ដើម្បីទៅកាន់ទីក្រុងបាងកក ។ ទីក្រុងកូរ៉ាត គឺជាទីផ្សារមួយដ៏រុងរឿង ។

ដូច្នេះគេត្រូវប្រឆាំងនឹងការប្រជែងគ្នាមួយ ប៉ុន្តែវាមានលក្ខណៈទៀងត្រង់ និងស្មោះត្រង់ចំពោះការធ្វើពាណិជ្ជកម្មតាមផ្លូវទឹកនេះ" (១២) ។

បេសកកម្មនេះបានបង្ហាញថា តំបន់នេះជាតំបន់មួយដ៏មានប្រយោជន៍បំផុត គេបានរាប់រៀបនូវផលិតផលទាំងឡាយ គឺ "ចំពោះការផលិតដ៏ធំធេងរបស់ខ្លួនអំពីស្រូវនោះនៅមានបន្ថែមផលិតផលពិសេសដ៏មានតម្លៃជាច្រើនថែមទៀត ដូចជាក្រមួន ភ្លុក ឈើសំណង់ គ្រឿងទេស" ។ នៅក្នុងខេត្តទន្លេរពៅមានស្រទាប់លោហធាតុក្នុងដី ថ្មម៉ាប នៅលើត្រើយទន្លេប្រកបដោយសោភ័ណភាពដ៏ល្អក្រៃលែង និងមានលក្ខណៈផ្សេងៗគ្នា ហើយនិងរ៉ែដែក ។ កោះកុង និង កោះជិតខាងដទៃទៀតបានផលិតសូត្រអំបោះ សំឡីកប្បាស ថ្នាំជក់នៅក្នុងចំនួនដ៏ច្រើនសម្បើម ។ នៅបាសាក់ គេបានជួបប្រទះនូវធនធានលោហុស្សាហកម្មដ៏សំខាន់ ។ "នៅតាមជើងភ្នំដែលទីតាំងខេត្តបានតាំងនៅនោះ គេឃើញមានរ៉ែស្ពាន់" (១៣) ។

ចំណែកត្រើយខាងឆ្វេងវិញ មិនសូវជាមានប៉ុន្មានទេ ។ ស្ទឹងត្រែងមានសភាពសម្បូរណ៍ដោយផលិតផលព្រៃឈើ ។ នៅអាតតូពើ មានរ៉ែ សំណប៉ាហាំង មានរ៉ែ សំណ " ហើយប្រហែលជាមានប្រាក់ផង" អាតតូពើនៅមានផលិតបានរ៉ែមាសថែម ទៀតដែលគេបានរែងលាងចេញពីខ្សាច់នៅក្នុងទន្លេ ។

ដោយសារតែជួបការលំបាកយ៉ាងខ្លាំងក្នុងការធ្វើដំណើរតាមផ្លូវទឹកនៅតំបន់ដោយសារទឹកធ្លាក់នៅខណៈនោះបេសកកម្មនេះថែមទាំងបានស្នើឲ្យកសាងផ្លូវថ្នល់មួយតភ្ជាប់ពីព្រៃនគរទៅអាតតូពើ ដោយឆ្លងកាត់តាមតៃនិញ ។ "ចំពោះខេត្តនៅត្រើយខាងឆ្វេង គឺស្ទឹងត្រែង សៀងប៉ាង និង អាតតូពើ មានផ្លូវរទេះមួយត្រូវបាន

*(១២) / របាយការណ៍ដែលបានរៀបរាប់ពីមុន ។*
*(១៣) / របាយការណ៍នៃបេសកកម្មដូចគ្នានេះចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៨៦៣ Indochine C-10 ( 79 ) ។*

បង្កើតឡើងនៅចន្លោះតៃនិញ និងស្ថានមួយនៅក្នុងចំណោមស្ថានទាំង៣នោះ ខ្ញុំជឿថាស្ទឹងត្រែងនឹងទទួលផលសប្បាយរីករាយ ហើយនឹងបញ្ឈប់នៅក្នុងពេលឆាប់ៗនេះនូវការទាក់ទងខាងពាណិជ្ជកម្មរបស់ពួកគេជាមួយបាងកក ។ ផ្លូវនេះមិនសូវជាថ្លៃទេ ដើម្បីគូសនៅក្នុងតំបន់មួយដែលមានលក្ខណៈរាបស្មើដាច់ខាតនេះ ហើយនឹងមានផលប្រយោជន៍ច្រើនជាងផ្លូវទឹកដែលមានបង្កើនចម្ងាយពិតប្រាកដយ៉ាងច្រើននៅចន្លោះអាតតូពើ និងព្រៃនគរ [១៤] ។

**គ** – ផ្លូវថ្នល់ព្រៃនគរ ស្ទឹងត្រែងនេះ ដែលឆ្លងកាត់តាមតៃនិញដែលបង្កើតដោយបេសកកម្ម Doudart de Lagrée នៅឆ្នាំ ១៨៦៨ និងត្រូវបានធ្វើឲ្យសម្រេចដោយអគ្គទេសាភិបាល Doudart នៅឆ្នាំ ១៨៩៣ ។

ប៉ុន្តែដូចដឹងស្រាប់ហើយ របាយការណ៍បេសកកម្មរបស់លោក Doudart de Lagrée មិនបានរួមបញ្ចូលទាល់តែសោះអំពីការចាំបាច់នៃការភ្ជាប់ទៅជាមួយដែនដីកូសាំងស៊ីន ជាជាងជាមួយទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានការពារនោះទេ ។

បើសិនជាអាជ្ញាធរបារាំងនៅកូសាំងស៊ីនចង់បានរបៀបនេះ ក៏ព្រោះតែពួកគេត្រូវបានលើកទឹកចិត្តដោយមនោសញ្ចេតនានៃការអភិបាលរបស់ចក្រពត្តិនិយមដែលគេបានជួបជាញឹកញាប់នៅក្នុងការអភិបាលជាទូទៅ និងជាពិសេសនៅឥណ្ឌូចិន ដែលមាននៅអែបនយោបាយរបស់រដ្ឋាភិបាលជាទូទៅនូវនយោបាយរបស់អ្នកបដិបក្ខនៅតាមតំបន់ដោយពិតប្រាកដ (ដែលម្យ៉ាងទៀតជួនកាលគ្រាន់តែបញ្ចេញឲ្យដឹងអំពីការប្រដែងគ្នាខាងទឹកដី ឬប្រជារាស្ត្រនៅក្រោមការត្រួតត្រាដែលផលប្រយោជន៍និងចំណង់ទាំងឡាយត្រូវបានយកធ្វើជារបស់ខ្លួនដោយពួកអ្នកត្រួតត្រា) ។

អគ្គទេសាភិបាល de Lanessan គឺពិតជាបានដើរតាមឆន្ទៈរបស់កូសាំងស៊ីនពីព្រោះលោកចូលចិត្តបង្កើតអធិបតេយ្យភាពអាណានិគមរបស់បារាំងដោយផ្ទាល់ នៅលើខេត្តទាំងនេះ " ដែលពីមុនជាខេត្តរបស់ខ្មែរនោះ " [១៥] ។ គឺស្ទឹងត្រែង សៀង ប៉ាង អាតតូពើ ដែលភាពសម្បូរខាងផលប្រយោជន៍សម្រាប់អភិវឌ្ឍន៍ពាណិជ្ជកម្មនៃ

(១៤) / របាយការណ៍ ថ្ងៃទី២ ខែកុម្ភៈ ១៨៦៩ ដែលបានរៀបរាប់ខាងលើ ។
(១៥) / របាយការណ៍ ថ្ងៃទី២ ខែកុម្ភៈ ១៨៦៩ ដែលបានរៀបរាប់ខាងលើ ។



ក្រុងព្រៃនគរ និង កូសាំងស៊ីន ត្រូវបានគូសបញ្ជាក់ដោយពួកអ្នករុករក ។ ដូច្នេះលោកយល់ថា ត្រូវទុកឲ្យអាជ្ញាធរអាណានិគមនូវសេរីភាពធ្វើសកម្មភាពខាងសេដ្ឋកិច្ច និងនយោបាយឲ្យបានខ្លាំងបំផុត ។

មានតែសភាពការណ៍ដែលកើតជាលទ្ធផលនេះទេ គឺមានសភាពជុយនិងភ្លាំងភ្លាត់យ៉ាងខ្លាំង ហើយបញ្ហានេះគ្រាន់តែបានឃើញម្តង លោករដ្ឋមន្ត្រីអាណានិគមខ្លួនឯង បានសម្តែងចេញដោយភ្ញាក់ផ្អើល និងថែមទាំងមិនសប្បាយចិត្តទៀតផង [១៦] ។ ដូច្នេះគេធ្វើការអំពាវនាវជាផ្លូវការទៅរកហេតុផលមួយទៀត គឺការបដិសេធន៍របស់ព្រះមហាក្សត្រនរោត្តម ។

**គ – លេស : ការបដិសេធរបស់ព្រះមហាក្សត្រ នរោត្តម**

សារទូរលេខមួយច្បាប់ពីអគ្គទេសាភិបាល ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ ១៨៩៣ [១៧] បានជម្រាបដល់រដ្ឋមន្ត្រីអាណានិគមថា ៖ "លោក Pavic និងខ្ញុំបានព្រមព្រៀងគ្នាទាំងស្រុងទៅលើការរៀបចំប្រទេសលាវ នៅក្នុងលក្ខខ័ណ្ឌដូចតទៅនេះ ៖...

តំបន់ខាងក្រោមទី៣ ដែលត្រូវបានបដិសេធដោយដាក់លាក់ ដោយព្រះមហាក្សត្រ និងមន្ត្រីជាន់ខ្ពស់របស់បារាំងនៅកម្ពុជានោះ ត្រូវបានភ្ជាប់ទៅកូសាំងស៊ីន" ។

បន្ទាប់ពីនៅក្នុងលិខិតពីរចុះថ្ងៃទី ២៨ ខែមេសា ឆ្នាំ ១៨៩៤ [១៨] និងថ្ងៃទី ៨ ខែមិថុនា ១៨៩៤ [១៩] ព្រះមហាក្សត្របានបញ្ជាក់ចំណុចនេះ ដើម្បីនាំយកនូវការយល់ព្រមរបស់រដ្ឋមន្ត្រីដែលមានការលាក់លៀម [២០] ។

**ក– ការពន្យល់ជាផ្លូវការចំពោះការបដិសេធន៍របស់ព្រះមហាក្សត្រ ទេសាភិបាលបានផ្តល់នូវការពន្យល់ជាសំខាន់អំពីការបដិសេធរបស់ព្រះមហាក្សត្រដូចតទៅនេះ ៖**

– ការអាក់អន់ព្រះទ័យដែលព្រះមហាក្សត្រអង្គនេះបានទទួលរងនោះ គឺការមិនបានមកវិញនូវខេត្តបាត់ដំបង និងខេត្តសៀមរាប តាមសន្ធិសញ្ញាឆ្នាំ ១៨៩៣ ។

– ការលាក់លៀមនៅចំពោះមុខ ការទទួលបន្ទុកបញ្ហាហិរញ្ញវត្ថុ ដែលបានបណ្តាល

(១៦) / ចំណារនៅលើលិខិត របស់អគ្គទេសាភិបាល ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ ១៨៩៣ ។
(១៧) / សៀម ៥៣ ។
(១៨) / ឥណ្ឌូចិន D 831 ។
(១៩) / ដូចគ្នា ។
(២០) / Cf.Supra ចំណារលើលិខិត ចុះថ្ងៃទី៨ ខែមិថុនា ។

ឲ្យមានការគ្រប់គ្រងតំបន់ទាំងឡាយដែលត្រូវបានថ្វាយដល់ព្រះអង្គនោះ ។

ទេសាភិបាលបានសរសេរដូច្នេះថា ៖ "នៅពេលឃើញដំបូងនូវការអនុប្បវាទរបស់ប្រទេសកម្ពុជា នៅក្នុងការជ្រៀតជ្រែករបស់យើងនៅប្រទេសលាវ និងនៅក្នុងការកំណត់ឲ្យនូវទឹកដីនានា ហាក់ដូចជាមិនមែនធម្មតា ។ នៅក្នុងការទាមទាររបស់យើងចំពោះសៀម យើងមិនគ្រាន់តែផ្អែកលើមូលដ្ឋាននៃច្បាប់នៃអាណាចក្រខ្មែរបានស្ថិតនៅដាច់ដោយឡែកពីរឿងនេះទាំងស្រុង និងដោយស្ម័គ្រចិត្ត ។ ម្យ៉ាងទៀតវាមានលក្ខណៈងាយស្រួលដើម្បីពន្យល់អំពីហេតុផលទាំងឡាយដែលបានជម្រុញមហាក្សត្រនរោត្តម ឲ្យបដិសេធនូវការចូលរួមទាំងអស់របស់ព្រះអង្គនៅក្នុងកិច្ចចុងក្រោយ ។ ព្រះមហាក្សត្រអង្គនេះ ទ្រង់បានយល់ព្រមនៅលើចំណុចនេះ ជាមួយប្រជារាស្ត្រទាំងមូលរបស់ព្រះអង្គ ដែលនៅក្នុងនោះមនោសញ្ចេតនាជាតិបានកើតមានដោយពិតប្រាកដ និងតែងតែបានបបោសអង្អែលនូវក្ដីសង្ឃឹមថាខេត្តអង្គរ និងបាត់ដំបង នឹងត្រូវបានប្រគល់ថ្វាយព្រះអង្គវិញ ឬក៏ចំពោះកំហុសរបស់ខ្លួន ហើយនិងនៅក្នុងការរង់ចាំនូវការផ្ដុំឡើងវិញ ដែលជាការចង់បានដ៏ខ្លាំងក្លានូវខេត្តទន្លេរពៅ និងម្លូព្រៃ ដែលស្ថិតនៅត្រើយខាងស្ដាំនៃទន្លេមេគង្គ ហើយនិងប្រឆាំងនូវការកាន់កាប់នោះ ព្រះអង្គតែងតែធ្វើការតវ៉ាជានិច្ច ។ ដោយយល់ថា ការពេញចិត្តណាមួយត្រូវបានផ្ដល់ចំពោះតែសេចក្ដីប្រាថ្នាចង់បានរបស់ព្រះអង្គ និងថាការប្រមូលផ្ដុំទៅជាភូមិខ្មែរនូវទឹកដីខ្លះដែលព្រះអង្គលែងតោងទាមទាំងស្រុងនោះ វាមានផលវិបាកតែនៅក្នុងការបញ្ចូលបញ្ហាហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្រតែប៉ុណ្ណោះ ដោយពុំមានការបំពេញព្រះទ័យអាស្មិមានៈណាមួយនោះឡើយ ដែលព្រះអង្គបានវៀរលែងទាំងស្រុងហើយនោះ ។ ការសម្រេចព្រះទ័យរបស់ព្រះអង្គ គឺប្រកបដោយគតិបណ្ឌិត ហើយយើងនឹងមិនបន្ទោសព្រះអង្គឡើយ ប៉ុន្តែវាបានអនុញ្ញាតឲ្យយើង ដើម្បីពិនិត្យមើលបញ្ហានៅក្រោមទស្សនៈមួយផ្សេងទៀត ។ វាហាក់ដូចជាចម្លែកណាស់ដែលកូសាំងស៊ីនបានគ្រប់គ្រងនូវចម្ងាយដីហួសកំណត់នូវតំបន់ទាំងឡាយដែលរហូតមកដល់ពេលនេះ ពុំមានទំនាក់ទំនងដោយផ្ទាល់ណាមួយជាមួយអ្នកស្រុករបស់តំបន់ទាំងនេះ ហើយអារ្យធម៌ក៏មានការខុសគ្នាទាំងស្រុង ពីលើទឹកដីកម្ពុជា ដែលផ្លូវថ្នល់គមនាគមន៍ ទោះផ្លូវទឹកក្ដី ផ្លូវ



គោកក្ដី ជាមួយដីដែលមានថ្មីត្រូវបង្ខំចិត្តឲ្យឆ្លងកាត់ទីនោះ" (២១) ។

ការពិតបញ្ហាទាំងអស់នេះ ហាក់ដូចជាមិនសូវឲ្យជឿ ហើយគេត្រូវតែសួរខ្លួនឯងអំពីការពិតនៃព្រះរាជបដិសេធ និងអំពីអត្ថន័យពិតប្រាកដនៃការប្រព្រឹត្តនេះ ។

## ១ – ការពិតនៃបដិសេធរបស់ព្រះមហាក្សត្រ

គឺជាការបដិសេធដាច់ខាតរបស់ព្រះមហាក្សត្រ គឺឈរនៅលើមូលដ្ឋាននៃការភ្ជាប់ទន្លេមេគង្គកណ្ដាលទៅកូសាំងស៊ីន ដែលអគ្គទេសាភិបាលបានបញ្ជាក់នៅក្នុងឆ្នាំ ១៨៩៣ (២២) ។ ហើយមិនបាច់សង្ស័យទេថា រដ្ឋមន្ត្រីអាណានិគមមានការជឿជាក់ក្នុងខ្លួន និងផ្អើលឆ្ងល់ចំពោះការបដិសេធរបស់ព្រះមហាក្សត្រនេះ ។

ដើម្បីធ្វើឲ្យជឿបញ្ហានេះ គេគ្រាន់តែអានចំណាររបស់លោករដ្ឋមន្ត្រីនៅលើលិខិតរបស់ទេសាភិបាលចុះថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ១៨៩៤ (២៣) ។ គេគ្រាន់តែមើលផងដែរនូវការឃើញសបិត្ត ដែលនៅក្នុងនោះ សេចក្ដីសម្រេចនេះ ឬក៏សេចក្ដីសម្រេចដែលប្រាថ្នាចង់បាននេះត្រូវបានទទួល គឺថា នៅលើលិខិតមួយរបស់លោកអគ្គទេសាភិបាលចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ១៨៩៣ លោករដ្ឋមន្ត្រីបានចារនូវសេចក្ដីសង្កេតដូចតទៅនេះ ៖ "ទោះដូចម្ដេចក្ដីក៏ការតស៊ូរបស់ ព្រះបាទ នរោត្តម គឺជាការតស៊ូដែលកើតមានមែនទែនគឺ ៖

១ – សេចក្ដីអាក់អន់ព្រះទ័យ ដែលបណ្ដាលមកពីហេតុការណ៍នេះ ដែលគេពុំបានផ្ដុំឲ្យដូចដើមឡើងវិញ ថ្វាយព្រះអង្គនូវទឹកដីអង្គរ និង ខេត្តបាត់ដំបង ។

២ – ចំពោះឥទ្ធិពលរបស់លោក Verneville ដែលតែងតែបង្ហាញនូវភាពជាសត្រូវចំពោះកិច្ចចាត់ការចុងក្រោយ ហើយដែលត្រូវបានបង្ហាញដោយការប្រឆាំងនិងការចង់បានដ៏អាក្រក់របស់ខ្លួន ។ ដូច្នេះ ទោះដូចម្ដេចក្ដី ក៏ការតស៊ូទាំងនេះ ហាក់ដូចជាត្រឹមត្រូវដែលប្រទេសកម្ពុជាបានជួយចេញជាវិភាគទានដល់ប្រទេសដទៃទៀតនៅក្នុងសហភាពនូវសោហ៊ុយកាន់កាប់ ហើយដែលបានដាក់បង្ខំទៅលើសេចក្ដីត្រូវ

---

*(២១) / លិខិតរបស់អគ្គទេសាភិបាល ឥណ្ឌូចិន ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ ១៨៩៤ ផ្ញើទៅរដ្ឋមន្ត្រីអាណានិគម ។ ឥណ្ឌូចិន D 831 ។*

*(២២) / Cf.supra*

*(២៣) / Cf.supra*

ការមួយផ្នែកនៃការចំណាយទាំងឡាយ (២៤) ។

ប៉ុន្តែគេបានស្រាវជ្រាវរកដោយឥតប្រយោជន៍នៅខាងក្រៅនៃការបញ្ជាក់អះអាងនេះនូវស្លាកស្នាមនៃការបដិសេធន៍ដ៏ជាក់លាក់នេះ ។ តាមការពិតវាមានតែបញ្ហាអវត្តមាននៃការតវ៉ា និងការអនុបវាទនោះទេ ដែលមានការខុសគ្នានេះ ។

ម្យ៉ាងទៀតវាមានការច្របូកច្របល់បន្តិចដែរ ដើម្បីពិនិត្យមើលថា នៅឆ្នាំ ១៨៩៤ លោក Pavie ដដែលនេះ ដែលបានធ្វើជាអ្នកធានាចំពោះការភ្ជាប់ប្រជាជនកូសាំងស៊ីននៅក្នុងសារទូរលេខរបស់អគ្គទេសាភិបាលនៅឆ្នាំ ១៨៩៤ ដែលបានសរសេរទៅកាន់រដ្ឋមន្ត្រីក្រសួងការបរទេសដូចតទៅនេះ (២៥) ÷ គឺ " នៅក្នុងអំឡុងពេលសន្ទនាដែលខ្ញុំបានធ្វើជាមួយព្រះមហាក្សត្រកម្ពុជា និងលោក Verneville ខ្ញុំអាចយល់បានថា ព្រះមហាក្សត្រ និងលោក Verneville បានព្រមទទួលដោយស្ម័គ្រ ព្រះទ័យ និង ចិត្ត ដើម្បីទទួលបន្ទុកចំពោះអតីតខេត្តកម្ពុជាទាំងឡាយនៅត្រើយខាងឆ្វេងទន្លេមេគង្គ ដែលការយល់ព្រមចំពោះកូសាំងស៊ីន គឺជាលទ្ធផលនៃការស្តាប់មិនបានមួយ..." ។

តើការស្តាប់មិនបាននេះឬ ដែលបានធ្វើឲ្យបាត់នូវអត្ថន័យទាំងអស់នៃការបដិសេធរបស់ព្រះមហាក្សត្រនោះ ? យើងនឹងរកបញ្ហានេះ ដោយពិនិត្យការពន្យល់ដ៏ពិតប្រាកដអំពីឥរិយាបថរបស់ព្រះមហាក្សត្រ ។

### គ – ការពន្យល់អំពីព្រះរាជឥរិយាបថរបស់ព្រះមហាក្សត្រ

១ – មិនមែនជាការភ្ជាប់អតីតខេត្តកម្ពុជាទាំងឡាយ ដែលព្រះមហាក្សត្របានសម្រេចព្រះទ័យបដិសេធបញ្ហានេះដោយសភាពស្ងប់ស្ងៀមរបស់ព្រះអង្គនោះទេ ប៉ុន្តែដំណោះស្រាយមួយដែលបានប្រឌិតដោយទេសាភិបាល de Lanessan ដែលមិនព្រមទទួលយកនូវទស្សនៈជាតិ និងដោយបញ្ហាសេដ្ឋកិច្ចនោះហើយ ដែលជាការជំរុញទៅនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ។

អគ្គទេសាភិបាល de Lanessan បានស្នើការភ្ជាប់ទៅប្រទេសកម្ពុជាតែមួយគត់

(២៤) / ចំណារបស់រដ្ឋមន្ត្រីអាណានិគមទៅលើលិខិតរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ១៨៩៣ ។
(២៥) / លិខិតរបស់ក្រុងហាណូយចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ១៨៩៤ – សៀម ៤៩ ។



នៃផ្នែកទី ១ នៃផ្នែករងទាំងពីរ ដែលរួមមានទន្លេ និងកោះទាំងឡាយ ។ ចំពោះផ្នែករង ទី ២ ដែលរួមមានខេត្តស្ទឹងត្រែង សៀមប៉ាង និងអាតតូពើនោះ លោក de Lanessan មិនដែលបានបើកចំហរការភ្ជាប់ទៅនឹងប្រទេសកម្ពុជានោះឡើយ ជំនួយទៅវិញ លោកបានប្រគល់ការទុកចិត្តតាំងពីដំបូងចំពោះរដ្ឋាភិបាលកូសាំងស៊ីន "ដែលនៅក្នុងនោះ ផ្លូវថ្នល់ពីធូយ៉ូម៉ូត (Thudaumot) ទៅកាន់ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលបានស្ថាបនាស្ទើរតែបានសម្រេចរួចហើយនោះ បានតភ្ជាប់យ៉ាងងាយស្រួលបំផុត (២៦) ។ ប្រាកដមែនហើយ ព្រះមហាក្សត្រមិនអាចស្ងប់ព្រះទ័យចំពោះការរួមបញ្ចូល នេះ ដែលបានទុកឲ្យប្រទេសកម្ពុជាត្រួតត្រានូវទន្លេ និង កោះទាំងឡាយដែលស្ទើរតែគ្មានមនុស្សនៅ គ្មានធនធាន ដែលនឹងនាំទៅរកការចំណាយដ៏ច្រើនសម្បើមនោះ ។ ដោយមូលហេតុអវត្តមាននៃមធ្យោបាយខាងសម្ភារៈ និងដោយហេតុថា ព្រំដែននៃប្រទេសកម្ពុជានៅលើត្រើយខាងស្តាំនៃទន្លេមេគង្គដែលនៅក្នុងនោះ គឺស្ថិតនៅខាងក្រោមនៃកោះទាំងឡាយនោះការទទួលបន្ទុករបស់ខ្លួន បានចោទនូវបញ្ហាដ៏ធ្ងន់ធ្ងរដែលប្រទេសកម្ពុជាខ្លួនឯងមិនជាអ្នកដោះស្រាយផងនោះ ។ ជាពិសេសដើម្បីអនុវត្តនូវបេសកកម្មមួយដ៏មានប្រសិទ្ធភាពនៅលើកោះទាំងឡាយនោះ គេចាំបាច់ត្រូវតែធ្វើដំណើរតាមផ្លូវទឹក ។ ប៉ុន្តែកម្រមាននាវាដើរដោយចំហាយទឹកមានសមត្ថភាពបើកឡើងបញ្ច្រាសចរន្តខ្សែទឹកដ៏ខ្លាំងបង្គួរនៅក្នុងតំបន់នេះណាស់ ដែលបង្កើតបានជាឧបសគ្គដ៏សំខាន់មួយ ។

ដូច្នេះវាមិនមែនជាការភ្ញាក់ផ្អើលអ្វីឡើយ ដែលព្រះមហាក្សត្របានបំបែកចេញមិនមែនជាការភ្ជាប់ទៅវិញ ដូចដែលទេសាភិបាលបានអះអាងនោះទេ ប៉ុន្តែដំណោះស្រាយដោយផ្នែកៗនេះបានប៉ះពាល់ដល់ច្បាប់ទាំងឡាយរបស់ប្រទេសកម្ពុជា និងជំទាស់ទៅនឹងផលប្រយោជន៍ផ្ទាល់របស់កម្ពុជា ។ ចំពោះអវត្តមានរបស់ព្រះអង្គក្នុងការតវ៉ានេះ គេត្រូវតែបង្ហាញនៅក្នុងក្របខ័ណ្ឌនៃអាកប្បកិរិយាអនុបវាទទូទៅ ដែលបានធ្វើឡើង ក្រោយឆ្នាំ ១៨៨៤ ជារបៀបនៃការតវ៉ារបស់ព្រះអង្គប្រឆាំងនឹងការរំលោភពីអាជ្ញាធរដែលជាអ្នកការពារនោះ ។

(២៦) / លិខិតថ្ងៃទី១២ ខែធ្នូ ឆ្នាំ ១៨៩៣ របស់អគ្គទេសាភិបាលផ្ញើទៅជូនអនុរដ្ឋលេខាធិការ អាណានិគមដែលបានរៀបរាប់ពីលើ ។

**២** - ប្រហែលជាមានមូលហេតុផ្សេងទៀតផងដែរ ដែលពន្យល់អំពីព្រះរាជកិរិយាបថនេះ ព្រះរាជអាកប្បកិរិយានេះបានទូន្មានដល់យើងតាមរយៈលិខិតចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ១៩០៥ ដែលផ្ញើដោយលោកអគ្គទេសាភិបាល Beau ទៅរដ្ឋមន្ត្រីអាណានិគម ។

លោកអគ្គទេសាភិបាល បន្ទាប់ពីបានគូសបញ្ជាក់ថា លោកពុំមាន " កិច្ចព្រមព្រៀងជាលាយលក្សអក្សរណាមួយ" នោះ និងថាការព្រមព្រៀងគ្នានេះ " បើសិនជាវាអាចកើតឡើងមែន" នោះ វាគ្រាន់តែបញ្ចេញឲ្យឃើញ " ដោយមាត់ទទេ" ការផ្ដើមទាក់ទងដែលបើសិនជាព្រះករុណា នរោត្តម មិនបានទ្រង់ព្រះលិខិតជំទាស់ដោយដាក់លាក់នេះក៏ដោយ តែ"ព្រះមហាក្សត្រអង្គនេះមានបំណងចង់ជួយដល់ការរៀបចំអភិបាលរបស់ប្រទេសជិតខាងនិងបានចាត់ទុកវិធានការនេះមានសារៈសំខាន់បណ្ដោះអាសន្ន" តែប៉ុណ្ណោះ [២៧] ។

## ការសន្និដ្ឋាន

### អ្វីដែលមានពីមុននេះ មានលទ្ធផលដូចតទៅនេះ គឺ :

**ក** / មួយផ្នែកធំនៃទឹកដីនៅត្រើយខាងឆ្វេងទន្លេមេគង្គដែលផ្ដុំដោយប្រទេសសៀមតាមសន្ធិសញ្ញាឆ្នាំ ១៨៩៣ គឺជាខេត្តរបស់ប្រទេសកម្ពុជាដែលត្រូវតែប្រគល់មកឲ្យប្រទេសកម្ពុជាវិញជាបន្ទាន់ ។

**ខ** / ដែលចរិតលក្ខណៈរបស់កម្ពុជានៅលើទឹកដីទាំងនេះ ត្រូវបានទទួលស្គាល់ដោយអាជ្ញាធរបារាំងខ្លួនឯង ។

**គ** / ដែលព្រះមហាក្សត្រ នរោត្តម មិនដែលបានបដិសេធការភ្ជាប់ទឹកដីនេះទេ ។

**ឃ** / តែថា ព្រះអង្គបានបំបែកចេញនូវដំណោះស្រាយជាកណ្ដាលមួយដែលដាក់បង្ខំដោយអគ្គទេសាភិបាល de Lanessan ដែលមិនទទួលស្គាល់ច្បាប់របស់ប្រទេស។ ប៉ុន្តែបញ្ហានេះ មិនបានរួមបញ្ចូលនូវការព្រមលះបង់ណាមួយរបស់ព្រះមហាក្សត្រនោះឡើយ ។

(២៧) / លិខិតលេខ ៣០០ ចុះថ្ងៃទី ១៧-២-១៩០៥ ឯកសារឥណ្ឌូចិន ៦១៦ ។



## ផ្នែកទី II

## ការភ្ជាប់ទៅប្រទេសលាវ

**នៅទីនេះ គេត្រូវតែញែកចេញនូវដំណាក់កាលពីរខុសគ្នាដែលទាក់ទងទៅនឹងការវិវត្តន៍នៃប្រទេសលាវខ្លួនឯង ។**

### ១ - ពី ខែមិថុនា ឆ្នាំ ១៨៩៥ ទៅ ខែកុម្ភៈ ឆ្នាំ ១៨៩៩

**ទ្វិកនិយម (dualisme) នៃលាវខាងលើ និងលាវខាងក្រោម ÷**

ផលអាក្រក់នៃការបែងចែកប្រទេសលាវជាបីតំបន់ដែលការគ្រប់គ្រងត្រូវប្រគល់ទៅឲ្យប្រទេសបីនោះមិនយូរទេ វានឹងបញ្ចេញឲ្យឃើញ ។ ការរៀបចំនេះត្រូវបានវិនិច្ឆ័យភ្លាមៗដោយអ្នកបន្តវេនពីលោកអគ្គទេសាភិបាល de Lanessan ថាមិន ធម្មតា និងមិនបានផលទៀតផង ។

ការពិតប្រទេសលាវខាងជើងដែលនៅក្រោមអំណាចតុងកឹង ត្រូវបានខ័ណ្ឌដោយទឹកដីដ៏ធំសម្បើមដែលស្ទើរតែគ្មានមនុស្សនៅ និងគ្មានផ្លូវថ្នល់ ។ ចំណងតែមួយគត់ដែលមានរវាងលួងប្រាបាង និង តុងកឹង គឺជាការរួមវិភាគទានរបស់ក្រុង តុងកឹងទៅលើចំណាយទាំងឡាយរបស់លួងប្រាបាង និងដើមកំណើតអ្នករដ្ឋការដែលចាត់ទុកឲ្យទៅធ្វើការនៅក្នុងប្រទេសក្រោមអាណាព្យាបាលថ្មី ។

ប្រទេសលាវកណ្ដាលដែលស្ថិតនៅក្នុងចំណុះសមត្ថកិច្ចប្រទេសអណ្ណាមត្រូវបានខ័ណ្ឌទិក្រុងវេ ដោយជួរភ្នំដ៏ខ្ពស់ៗ ។ ហើយប្រទេសអណ្ណាមខ្លួនឯងមិនមែនជាប្រទេសអ្នកមានប៉ុន្មានទេ ដើម្បីទទួលបន្ទុកការចំណាយនៅប្រទេសលាវនោះ ។

ការបែងចែកប្រទេសលាវជាបីផ្នែកនេះ ត្រូវបានផ្ដុំឡើងវិញ ក្រោយពីការញែកចេញដោយអ្នកដែលបានបង្កើតនោះ ។ អគ្គទេសាភិបាលឥណ្ឌូចិនថ្មី បានយកអនុក្រឹត្យចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ ១៨៩៥ [២៨] ដើម្បីរៀបចំប្រទេសលាវទៅជាតំបន់ គឺប្រទេសលាវខាងលើ និងប្រទេសលាវខាងក្រោម ដោយបានប្រគល់ការដឹកនាំប្រទេសលាវនីមួយៗទៅឲ្យមេបញ្ជាការជាន់ខ្ពស់មួយរូប ។ មេបញ្ជាការជាន់ខ្ពស់ទាំងពីររូបនេះទាក់ទងដោយផ្ទាល់ជាមួយអគ្គទេសាភិបាល ។ ប៉ុន្តែស្ដីពីការខ្វល់ខ្វាយចំពោះនយោ

(២៨) / J.O.I ១៨៩៥ ភាគទី២ ទំព័រ ២៧៧ ។

បាយទូទៅវិញ ការឯកភាពក្នុងការមើល និងការធ្វើសកម្មភាព គឺខានមិនបានដែលមេបញ្ជាការនៃប្រទេសលាវខាងលើ និងទទួលនូវការណែនាំចាំបាច់ពីមេបញ្ជាការ នេះ ។ ដូចដឹងស្រាប់ហើយ ទឹកដីកម្ពុជាស្ថិតនៅក្រោមចំណុចនៃមណ្ឌលខុង (Khong) ។

## ២ – កំណើតនៃកងឯកភាពរដ្ឋបាលលាវ

ការចែកប្រទេសលាវជាពីរតំបន់នៅតែមិនទាន់ចាំបាច់នូវការលំបាកទាំងឡាយនៅក្នុងការគ្រប់គ្រងប្រទេសនេះ ។ ផលវិបាកដ៏សំខាន់នោះ គឺមេបញ្ជាការជាន់ខ្ពស់ទាំងពីរនាក់ ស្ថិតនៅឆ្ងាយពីគ្នាចំនួន ១៥០០ គ.ម ពុំមានទំនាក់ទំនងរវាងគ្នានិងគ្នាពុំមានគមនាគមន៍ដោយផ្ទាល់ តភ្ជាប់ជាមួយទឹកដីដែលលាតសន្ធឹងពីសាវណ្ណាខេត្តទៅវៀងច័ន្ទ ព្រមទាំងនៅលើបណ្តាញផ្លូវទឹកកណ្តាលនៃទន្លេមេគង្គ ដែលមានប្រវែងរហូតដល់៧០០គ.ម ហើយដែលវាត្រូវបានខណ្ឌដោយជួរ (កន្លែងទឹកហូរខ្លាំងនៃទន្លេ) ដែលមិនអាចឆ្លងកាត់បាននៅក្នុងមួយភាគធំនៃឆ្នាំ(ប្រមាណ៥ខែ)ដែលធ្វើឲ្យពួកគេមិនអាចបំពេញ បេសកកម្មបានសមដូចបំណងនោះ [២៩] ។

ដើម្បីកែបំបាត់នូវសភាពការណ៍នេះលោក Paul Doumer អគ្គទេសាភិបាលបានគិតថា លោកអាចធានាឲ្យមានសកម្មភាព និងឯកភាពឲ្យបានខ្លាំងជាងពីអតីតកាលចំពោះសកម្មភាពរបស់បារាំងនៅប្រទេសលាវដោយដាក់ប្រទេសនេះឲ្យស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានតែមួយគត់ដែលស្នាក់នៅឯសាវណ្ណាខេត្ត ទន្ទឹមនឹងការរក្សាទុកនូវភ្នាក់ងារទាំងឡាយនៅក្នុងចំនួនខ្ពស់គ្រប់គ្រាន់នៅលួងប្រាបាងនិងនៅខុង ។ ហេតុដូច្នេះហើយតាមអនុក្រឹត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី៦កុម្ភៈ ឆ្នាំ១៨៩៩ [៣០] បានចែងថា "ការគ្រប់គ្រងប្រទេសលាវត្រូវស្ថិតនៅក្រោមអាជ្ញាធររបស់រ៉េស៊ីដង់ជាន់ខ្ពស់(នាយឯកាធិបតី) (Résident Supérieur) " (មាត្រាទីមួយ) ។

ការប្រើប្រាស់មេបញ្ជាការជាន់ខ្ពស់នៅប្រទេសលាវខាងលើ និងប្រទេសលាវខាងក្រោមត្រូវបានលុបចោល (មាត្រា២) ។

*(២៩) / របាយការណ៍របស់ក្រសួងអាណានិគមផ្ញើទៅជូនលោក ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៨៩៩ ឯកសារអាណានិគម បញ្ជីនៃច្បាប់ និងក្រឹត្យខែមេសា – ឧសភា កំណត់លេខ ១៦៤ ។*

*(៣០) / J.O.I ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ១៨៩៩ ទំព័រ ១៣៣ ។*



ជាមួយអនុក្រឹត្យនេះដែរត្រូវបានបញ្ជាក់ដោយក្រឹត្យរបស់លោកប្រធានាធិបតីនៃសាធារណរដ្ឋបារាំង ចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៨៩៩ [៣១] បានធ្វើឲ្យបានសម្រេចនូវការរួបរួមឲ្យមានតែមួយនូវនយោបាយ និង រដ្ឋបាលនៃប្រទេសលាវ ។

ប៉ុន្តែប្រទេសលាវនៅក្នុងឆ្នាំ ១៨៩៩ មិនមានតែទឹកដីប្រទេសលាវខ្លួនប៉ុណ្ណោះទេ ។ ប្រទេសនេះបានបញ្ចូលផងដែរនូវទឹកដីមួយផ្នែករបស់កម្ពុជាដែលរួមមានខេត្តស្ទឹងត្រែង សៀងបាំង និងអាតតូពើ ដែលពីមុនជាខេត្តរបស់ខ្មែរ ។

ប៉ុន្តែយើងរំលឹកឡើងវិញម្តងទៀតថា ខេត្តទាំងនេះត្រូវបានផ្តុំឲ្យដូចដើមឡើងវិញដោយប្រទេសសៀម បន្ទាប់ពីការទាមទារដែលបានធ្វើឡើងនៅក្នុងនាមប្រទេស កម្ពុជា ។ ការបញ្ចូលខេត្តទាំងនេះនៅក្នុងប្រទេសលាវចាប់ពីឆ្នាំ ១៨៩៩ មកដែលមិនដែលបានទទួលការសុខចិត្តយល់ព្រមពីព្រះរាជាណាចក្រខ្មែរនោះ គ្រាន់តែអាច ត្រូវបានចាត់ទុកថា ជាវិធានការណ៍រដ្ឋបាលមួយដែលពុំមានអំណាចអ្វីដើម្បីនាំទៅដល់លក្ខន្តិកៈជាតិនៃទឹកដីទាំងនោះឡើយ ។

ម្យ៉ាងទៀត ហេតុការទាំងនេះ ត្រូវបានទទួលស្គាល់ជាបន្តមកទៀត នៅក្នុងអំឡុងពេលការផ្តុំឡើងវិញ ដែលបានធ្វើឡើងនៅប្រទេសកម្ពុជា ។ មានតែនៅក្នុងចន្លោះពេលប៉ុណ្ណោះ ដែលផ្នែកមួយនៃតំបន់ទាំងនេះ ត្រូវបានបញ្ជូនឲ្យទៅនៅក្រោមអំណាចរបស់អាណ្ណាម ។

## ផ្នែកទី III

## ការធ្វើឱ្យដូចដើមឡើងវិញនូវភាគខ្លះនៃអធិបតេយ្យរបស់កម្ពុជា

### ១– សេចក្តីស្នើរបស់លោក Pavie

ការផ្តុំឡើងវិញនូវខេត្តទាំងឡាយរបស់ប្រទេសកម្ពុជា នៅលើត្រើយខាងឆ្វេងទន្លេមេគង្គត្រូវបានស្នើឡើងដោយលោក Auguste Pavie នៅឆ្នាំ១៨៩៤ ។ នៅក្នុងលិខិត

*(៣១) / ឯកសារអាណានិគមបញ្ជីច្បាប់ និងក្រឹត្យដែលបានរៀបរាប់ពីមុនគ្រាន់តែអាចត្រូវបានចាត់ទុកថាជាវិធានការរដ្ឋបាលមួយដែលពុំមានអំណាចអ្វីដើម្បីនាំទៅដល់លក្ខន្តិកៈជាតិនៃទឹកដីទាំងនោះឡើយ ។*

*ម្យ៉ាងទៀតហេតុការណ៍នេះត្រូវបានទទួលស្គាល់ជាបន្តមកទៀត នៅក្នុងអំឡុងពេលការផ្តុំឡើងវិញដែលបានធ្វើឡើងនៅប្រទេសកម្ពុជា ។ មានតែនៅក្នុងចន្លោះពេលប៉ុណ្ណោះ ដែលផ្នែកមួយនៃតំបន់ទាំងនេះ ត្រូវបានបញ្ជូនឲ្យទៅនៅក្រោមអំណាចរបស់អណ្ណាម ។*

ផ្ញើទៅរដ្ឋមន្ត្រីក្រសួងការបរទេសដែលយើងបានរៀបរាប់រួចហើយ ក្រោយពីបានសន្មត់ទៅលើការស្តាប់គ្នាមិនបានចំពោះការបដិសេធន៍របស់ព្រះមហាក្សត្រ [៣២] លោក Pavie បានលើកការស្នើ "ដោយមានការព្រមព្រៀងជាមួយលោក Chavassieux " ផងនៃដំណោះស្រាយដូចតទៅនេះគឺ ៖

"ភ្ជាប់ទៅប្រទេសកម្ពុជានូវត្រើយខាងឆ្វេងនៃទន្លេមេគង្គ (ស្ទឹងត្រែង និង ខុង) រហូតដល់កម្ពស់នៃព្រំដែនទឹកដីរបស់ប្រទេសកម្ពុជានៅត្រើយខាងស្តាំដែលយើងមានសិទ្ធិដើម្បីពិភាក្សាអំពីការកាន់កាប់របស់សៀម"... [៣៣] ។

ប៉ុន្តែសេចក្តីស្នើរបស់លោក Pavie មិនត្រូវបានរក្សាទុកឡើយ ។ គេត្រូវរង់ចាំរហូតដល់ ១០ឆ្នាំ ដើម្បីគេផ្តល់នូវការយល់ព្រមនោះ ។

**២ – អនុក្រឹត្យចុះថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ១៩០៤ ស្តីពីការប្រគល់ឲ្យវិញ គឺនៅខែធ្នូ ឆ្នាំ១៩០៤ ប៉ុណ្ណោះ ដែលអគ្គទេសាភិបាលឥណ្ឌូចិនបានយល់ព្រមផ្តាច់ខេត្តស្ទឹងត្រែងចេញពីការគ្រប់គ្រងរបស់ប្រទេសលាវ ។**

សេចក្តីសម្រេចនេះត្រូវបានធ្វើឡើងដោយអគ្គទេសាភិបាល Paul Beau ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នាត្រឹមត្រូវតាមច្បាប់របស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ។

នេះគឺជារបាយការណ៍ដែលលោក Paul Beau បានរាយការណ៍នៅក្នុងពេលបង្ហាញសេចក្តីសម្រេចរបស់លោក ដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីអាណានិគម ៖

"នៅក្នុងពេលនៃការរៀបចំឡើងវិញជាលើកដំបូងរបស់ពួកគេ ទឹកដីប្រទេសលាវត្រូវបានប្រមូលផ្តុំទៅជាមណ្ឌលស្វយ័តពីរ ។ លោកអគ្គទេសាភិបាល Rousseau ប្រហែលជាដើម្បីធ្វើឲ្យមូលនូវមណ្ឌលខាងត្បូងដែលទីប្រជុំជន គឺស្ថិតនៅខុងនោះ ជឿថាត្រូវដាក់ខេត្តស្ទឹងត្រែងរបស់កម្ពុជាឲ្យនៅក្រោមអំណាចរបស់មេបញ្ជាការជាន់ខ្ពស់នៅប្រទេសលាវខាងក្រោម (អនុក្រឹត្យចុះថ្ងៃទី១ ខែមិថុនា ១៨៩៥)។ ពុំមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរណាមួយបានធ្វើឡើងនៅក្នុងពេលនោះទេចំពោះបញ្ហានេះ ហើយវាបានធ្វើឲ្យយើងជឿថា បើសិនជាការព្រមព្រៀងគ្នា អាចត្រូវបាន

*(៣២) / Cf.supra*

*(៣៣) / លិខិតរបស់លោក Pavie ចុះកាលបរិច្ឆេទថ្ងៃទី១៩ កញ្ញា ១៨៩៤ នៅទីក្រុងហាណូយ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងការបរទេសសៀម ៤៩ ។*



បង្កើតឡើងដោយមាត់ទទេរវាងអគ្គទេសាភិបាល និងព្រះករុណា នរោត្តមនោះ ក៏ដោយសារតែព្រះមហាក្សត្រអង្គនេះបានមានបំណងដើម្បីជួយរៀបចំការងាររដ្ឋបាលរបស់ប្រទេសជិតខាង ហើយបានចាត់ទុកវិធានការនេះថា មានសារៈសំខាន់បណ្តោះអាសន្នតែប៉ុណ្ណោះ ។ ការពិតចាប់តាំងពីសម័យនោះមកគេពុំឃើញមានការតវ៉ាជាផ្លូវការឡើយ ប៉ុន្តែរដ្ឋាភិបាល និងប្រជារាស្ត្រកម្ពុជាបានសម្តែងចេញនៅក្នុងគ្រប់កាលៈទេសៈដែលពួកគេនឹងបានឃើញប្រកបដោយក្តីសប្បាយនូវការវិលត្រឡប់នូវកាលៈទេសៈធម្មតាមកវិញនោះ ។ ម្យ៉ាងទៀតរដ្ឋការរបស់ប្រទេសលាវត្រូវបានរួបរួមគ្នាឡើងវិញ ដោយក្រឹត្យចុះថ្ងៃទី ១៩ ខែមេសា ឆ្នាំ ១៨៩៩ ហើយទីប្រជុំជនក៏បានផ្ទេរទៅនៅវៀងច័ន្ទវិញ វាពុំមានមូលហេតុណាមួយឡើយ ក្នុងការមិនឆ្លៀតឱកាសនៅពេលដំបូងដែលគេមានដើម្បីផ្តល់នូវសេចក្តីពេញចិត្តចំពោះឆន្ទៈដែលត្រឹមត្រូវតាមច្បាប់នោះឡើយ ។ ចំពោះយោបល់របស់ខ្ញុំវាជាការពិបាក ដើម្បីជ្រើសរើសនូវពេលវេលាមួយដែលអនុគ្រោះបំផុតក្នុងការផ្តុំឲ្យដូចដើមឡើងវិញនូវអតីតខេត្តទាំងឡាយរបស់កម្ពុជាដែលថៃបានកាន់កាប់ ។ តក្កវិជ្ជាបានបញ្ជាមិនឲ្យកាត់ដៃជើងរបស់យើងផ្ទាល់នោះទេ គឺទឹកដីដែលយើងទើបនឹងផ្តុំឡើងវិញ ដែលយើងបានខិតខំយ៉ាងខ្លាំងនោះ ។ ខ្ញុំសូមបន្ថែមថា ទឹកដីដែលបានបញ្ចូលជាឧបសម្ព័ន្ធនៅត្រើយខាងស្តាំនៃទន្លេមេគង្គ គឺស្ថិតនៅខាងជើងខេត្តស្ទឹងត្រែង ការរក្សាទុកនូវមណ្ឌលចុងក្រោយនេះ នៅក្រោមចំណុះលោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសលាវ មិនគ្រាន់តែជាការមិនសមហេតុសមផលប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការប្រព្រឹត្តខុសឆ្គងខាងភូមិសាស្ត្រផងដែរ" [៣៤] ។

ហេតុដូច្នេះហើយបានជានៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ១៩០៤ លោកអគ្គទេសាភិបាល Paul Beau បានយកអនុក្រឹត្យមួយ ( ឧបសម្ព័ន្ធ១) [៣៥] ដែលនៅក្នុងលិខិតខណ្ឌនៃអនុក្រឹត្យនោះ "ត្រូវបានប្រគល់ទៅឲ្យប្រទេសកម្ពុជាវិញនូវទឹកដីខេត្តស្ទឹងត្រែង

*(៣៤) / លិខិតរបស់អគ្គទេសាភិបាលចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ១៩០៥ ផ្ញើទៅជូនរដ្ឋមន្ត្រី អាណានិគមឥណ្ឌូចិន A 30 (១០៩) ។*

*(៣៥) / J.O.I ១៩០៥ ឆមាសទី២ ទំព័រ ១៥០០ ។*

ដែលបច្ចុប្បន្ននេះស្ថិតនៅក្រោមចំណុះប្រទេសលាវ " ។ ប៉ុន្តែគួរឲ្យស្តាយ ការផ្តុំឡើងវិញនេះ ត្រូវបានធ្វើឡើងដោយ " ហួតយកនូវផ្នែកខាងស្តាំនៃព្រែកដែលគេហៅថា N. Thamm (ផែនទីនៃក្រុមភូមិសាស្ត្រឥណ្ឌូចិនខ្នាត ១/១.០០០.០០០ បោះពុម្ពផ្សាយខែមេសា ឆ្នាំ ១៩០៣ (មាត្រាទី ១) ។

មាត្រាទី ២ បានកំណត់ថា "តំបន់ដែលហៅថា សៀមប៉ាំង ដែលព្រំដែនខាងកើតនិងខាងជើងត្រូវបានគូសបង្ហាញជាពណ៌លឿងនៅលើផែនទីខ្នាត ១/៣.០០០.០០០ ដែលបានបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តាច់ចេញពីខេត្ត ខុង (លាវ) និងបានបញ្ចូលទៅក្នុងទឹកដីខេត្តស្ទឹងត្រែង" ។

តើអនុក្រឹត្យនេះធ្វើឲ្យបានសម្រេចនូវការប្រគល់ខេត្តស្ទឹងត្រែងមកឲ្យប្រទេសកម្ពុជាវិញនៅក្នុងបូរណភាពរបស់ខ្លួនដែរឬទេ ? តើអ្នកធ្វើអនុក្រឹត្យនេះបានទៅដល់គោលដៅដែលខ្លួនចង់បានក្នុងការផ្តុំឡើងវិញនូវទឹកដីទាំងអស់របស់ខ្មែរដែលរដ្ឋនេះមាន និងមិនឲ្យមានកាត់ដៃជើងរបស់ខ្លួនឯងចេញ គឺទឹកដីដែលយើងទើបនឹងបានផ្តុំឡើងវិញនោះ បានឬទេ ? "

វាហាក់ដូចជាឥតប្រយោជន៍ ដើម្បីផ្តល់នូវការចង្អុលបង្ហាញផ្សេងៗទៀតនោះ ។ មាត្រាទី ១ នៃសេចក្តីសម្រេចនេះបានបញ្ជាក់ច្បាស់គ្រប់គ្រាន់ដែរហើយ ។ មានតែប្រគល់ឲ្យប្រទេសកម្ពុជាវិញនូវផ្នែកនៃទឹកដីខេត្តស្ទឹងត្រែងនោះទេ ដែលមិនធ្វើឲ្យប៉ះពាល់ដល់ការកាត់ដៃជើងដែលបានធ្វើឡើង ដោយអំណាចនៃអនុក្រឹត្យចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ ១៨៩៩ ដើម្បីបង្កើតស្នងការដ្ឋាននៅ Darlac នោះ ។ ផ្នែកនៃទឹកដីនេះដែលបានដណ្តើមយកពីខេត្តស្ទឹងត្រែង ហើយជាផ្នែកមួយនៃទឹកដីរបស់ប្រទេសកម្ពុជានោះ មិនដែលបានប្រគល់ឲ្យប្រទេសកម្ពុជាវិញសោះឡើយ ។ យើងនឹងពិនិត្យមើលបញ្ហានេះនៅក្នុងពេលឥឡូវនេះ ។

## ផ្នែកទី IV
## ការភ្ជាប់ទៅប្រទេសអណ្ណាម នៃទឹកដីកម្ពុជា នៅដារឡាក់



ការភ្ជាប់ទៅប្រទេសអណ្ណាមនូវទឹកដីកម្ពុជាមួយផ្នែក ដែលនឹងត្រូវប្រគល់មកឲ្យប្រទេសខ្មែរវិញនៅក្នុងឆ្នាំ ១៨៩៣ នោះ បានធ្វើឡើងជាពីរដំណាក់កាល ។

នៅក្នុងដំណាក់កាលទី១ ផ្នែកនៃទឹកដីដែលជាមូលហេតុនៅទីនេះ ត្រូវបានប្រមូលផ្តុំជាមួយគោលសំខាន់ៗផ្សេងៗទៀតនៃទឹកដី នៅក្នុងអង្គភាពរដ្ឋបាលស្វយ័ត គឺស្នងការដ្ឋាននៃដារឡាក់ (Darlac) ។

នៅក្នុងដំណាក់កាលទី២ Darlac ត្រូវបានកំណត់ឲ្យទៅអណ្ណាម ។

### ១ – ការបង្កើតស្នងការ Darlac

នៅក្នុងឆ្នាំ ១៨៩៩ នៅពេលដែលមេបញ្ជាការ Tournier ត្រូវបានតែងតាំងជារ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅប្រទេសលាវ លោកបានស្នើថា ប្រជាជនអន្តោគ្រាម (ប្រជាជនកើតក្នុងស្រុក) ទាំងអស់ក្រៅពីជនជាតិអណ្ណាម (ប្រជាជនអណ្ណាម) ដែលបានរស់នៅ ក្នុងតំបន់ដែលគ្មានការកំណត់ នៅចន្លោះប្រទេសលាវ និងប្រទេសអណ្ណាម ត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួន ជាពិសេសគឺដើម្បីអាចឲ្យលោកចងទំនាក់ទំនងជាមួយពួកកុលសម្ព័ន្ធម៉យ (mois) ។

ដើម្បីឆ្លើយតបចំពោះនយោបាយរបស់លោករ៉េស៊ីដង់ត៍ ជាន់ខ្ពស់ Tournier នេះតាមអនុក្រឹត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ១៨៩៩ [៣៦] "លោកបានបង្កើតមណ្ឌលរដ្ឋបាលមួយនៅប្រទេសលាវ ដោយកំណត់ឈ្មោះថា ជាស្នងការ Darlac ហើយដែលរួមមានផ្នែកទាំងអស់នៃខេត្តស្ទឹងត្រែង ដែលមានកំណត់ព្រំដែនខាងជើងដោយខ្សែបែងចែកទឹករវាងអាងនៃទន្លេ Houé Tiamal និងទន្លេ Houé Tiaba ។ ផ្លូវទឹកទន្លេស្រែពករហូតដល់ ប៉ាក់ឡាដរ៉ាង (Pak - Ladrang) ខ្សែបន្ទាត់បែងចែកទឹក រវាងអាង ណាមឡាដរ៉ាង (Nam Ladrang) និងអាង ណាមលៀ (Nam Lieou)" ។ (មាត្រាទី១) ។

ប៉ុស្តិ៍រដ្ឋបាលនៅបានដុង (Bandon) ដែលបង្កើតឡើងដោយអនុក្រឹត្យចុះថ្ងៃទី២១ ខែមករា ឆ្នាំ ១៨៩៩ ហើយដែលស្ថិតនៅក្រោមចំណុះស្នងការដ្ឋានខេត្តស្ទឹងត្រែងនៅក្នុងស្នងការថ្មី (Darlac) ដោយលុបចោលនូវ (មាត្រា២) ។

(៣៦) / J.O.I ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៨៩៩ ទំព័រ ៣៩៤ ។

ដូចដែលនៅក្នុងអំឡុងពេលនៃការបង្កើតរបស់ខ្លួន ស្នងការដ្ឋាន Darlac ត្រូវបានបង្កើតឡើងដោយគ្មានរួមបញ្ចូលនូវមួយផ្នែកនៃទឹកដី នៃខេត្តស្ទឹងត្រែងនោះឡើយ ។

ផ្ទុយនិងអ្នកដែលបានរង់ចាំនោះ ការរៀបចំរដ្ឋបាលថ្មីនេះ បានផ្តល់នូវលទ្ធផលដ៏អាក្រក់ ។ មណ្ឌលនេះធំសម្បើមណាស់ ហើយពួកកុលសម្ព័ន្ធ Moïs ដែលស្ថិតនៅឆ្ងាយពីការត្រួតត្រាឲ្យបានជិតដល់នោះ បានគេចចេញពីការត្រួតត្រាទាំងអស់ ។

រដ្ឋការឥណ្ឌូចិន បានពិចារណាឡើងវិញ នូវបញ្ហានេះ ហើយបានវាយតម្លៃថា "ការចូលទៅ Darlac ត្រូវធ្វើតាមរយៈអណ្ណាម ឬក៏គ្រាន់តែអាចចាប់ផ្តើមតាមផ្លូវគមនាគមន៍ " (៣៧) ។

## ២ – ការភ្ជាប់ផ្នែករដ្ឋបាលនៅដារឡាក់ ទៅក្នុងអាណាព្យាបាលអណ្ណាម : អនុក្រឹត្យចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤

ផលវិបាកដែលយើងបានឲ្យដឹងនេះ បានកំណត់ឲ្យអគ្គទេសាភិបាលចាប់យកអនុក្រឹត្យចុះថ្ងៃទី២២ ខែវិច្ឆិកា ១៩០៤ (៣៨) នៅក្នុងលក្ខខ័ណ្ឌដែល"ខេត្តដារឡាក់ត្រូវបានបំបែកចេញពីប្រទេសលាវ និងដាក់នៅក្រោមអំណាចរដ្ឋបាល និងនយោបាយរបស់រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម " (មាត្រាទី១) ។

ហេតុដូច្នេះទឹកដីមួយត្រូវបានបំបែកចេញពីខេត្តស្ទឹងត្រែងឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម ។

ប៉ុន្តែគេត្រូវមើលឃើញឲ្យច្បាស់ថា គេមិនត្រូវធ្វើដូច្នេះទេ ហើយគេគ្រាន់តែអាចធ្វើនូវការភ្ជាប់មួយផ្នែករដ្ឋបាលដែលឆ្លើយតបចំពោះអង្គការអាណានិគម ។

ចំពោះការគ្រប់គ្រងដោយផ្ទាល់នូវដែនដីកូសាំងស៊ីន បន្ទាប់មកចំពោះរ៉េស៊ីដង់ត៍នៅប្រទេសលាវ ត្រូវបានដាក់ជំនួសការគ្រប់គ្រងផ្ទាល់ដោយរ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម ។ ភាពត្រឹមត្រូវតាមច្បាប់នៃការគ្រប់គ្រងដោយផ្ទាល់នេះ អាចត្រូវបានជំទាស់នៅក្នុងនាមអនុសញ្ញា ឆ្នាំ ១៨៩៣ ។ ប៉ុន្តែវាធ្វើបានតែដោយប្រទេសកម្ពុជាដែលមានអធិបតេយ្យតែមួយគត់នៅលើទឹកដីកម្ពុជា ដែលត្រូវបានប្រគល់ឲ្យដោយសៀម ។

(៣៧) / ការសិក្សាអំពីការភ្ជាប់ Darlac ទៅក្នុងអាណាព្យាបាលរបស់អណ្ណាម, ឥណ្ឌូចិន n°៦១៦ ។
(៣៨) / J.O.I ឆមាសទី២ ១៩០៤ ទំព័រ ១៤៤៦ ។



ជាពិសេស ការភ្ជាប់ការគ្រប់គ្រងទៅអណ្ណាមមិនមែនងាយអូសទាញឲ្យមានមុខងារខ្លះដែលមានសមត្ថភាព នៅក្នុងអាជ្ញាធរអណ្ណាម នៅទីក្រុងវ៉េ នោះទេ ។

នោះគឺជាការទទួលស្គាល់របស់រ៉េស៊ីដង់ នៅអណ្ណាមខ្លួនឯង : គឺការភ្ជាប់នេះមិនសំដៅទៅលើ "ទស្សនៈនយោបាយនៃអធិបតេយ្យភាពនោះឡើយ" (៣៩) ។

យូរក្រោយមក នៅពេលបញ្ហានយោបាយ នៃការកំណត់អធិបតេយ្យភាពត្រូវបានគេសិក្សានោះ អំពើនេះនៅតែត្រូវបានគូសបញ្ជាក់នៅឡើយ ។ នៅក្នុងកំណត់សម្គាល់មួយចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៣០ (៤០) ផ្ញើទៅជូននាយកកិច្ចការនយោបាយ នាយការិយាល័យទី៣បានបង្ហាញថា អនុក្រឹត្យចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤ ពុំមាននិយាយអ្វីអំពីការភ្ជាប់ដារឡាក់ ទៅអណ្ណាមនោះឡើយ ប៉ុន្តែគ្រាន់តែបានដាក់ដារឡាក់ឲ្យស្ថិតនៅក្រោមរបបគ្រប់គ្រងដោយផ្ទាល់របស់រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម តែប៉ុណ្ណោះ ។

## ៣ – ការវិវត្តន៍នៃអភិបាលកិច្ច និងនយោបាយនៅដារឡាក់ : អនុក្រឹត្យចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩០៥ និងថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩២៣

ដារឡាក់ មិនស្ថិតនៅក្នុងកំណត់ព្រំដែនទឹកដី ដែលបានដកចេញពីខេត្តស្ទឹងត្រែងនោះទេ ។ នៅឆ្នាំ ១៩០៥ អនុក្រឹត្យមួយបានធ្វើអន្តរាគមន៍រហូតដល់បន្ថែមនូវទឹកដីថ្មីទៅឲ្យខេត្តនេះ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះវាបានធ្វើឲ្យលក្ខន្តិកៈនយោបាយរបស់ខ្លួនមានសភាពចម្រុះ ។

នៅដារឡាក់ពីមុន ត្រូវបានបន្ថែមជាជំនួយនូវទឹកដីនៃតំបន់លើ ។ ដូច្នេះមណ្ឌលថ្មីនេះរួមមាន "មួយភាគនៃទឹកដីខេត្តស្ទឹងត្រែង និងតំបន់ព្រៃភ្នំដែលពួកកុលសម្ព័ន្ធជនជាតិ Moïs ដែលមិនចុះចូលបានរស់នៅ ។ ខេត្តនេះមានព្រំប្រទល់ខាងជើងទល់នឹងខ្សែបន្ទាត់បែងចែកទឹករវាងអាង Houé - Tiamal និង Houé - Tiaba ផ្លូវទឹកទន្លេស្រែពករហូតដល់ Pak - Ladrang ហើយនិង Nam - Lieou ខាងកើតទល់នឹងជួរភ្នំអណ្ណាម ខាងលិច

(៣៩) / លិខិតរបស់រ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាមចុះថ្ងៃទី២៥ ខែមេសា ១៩២៩ ផ្ញើទៅអគ្គទេសាភិបាលឥណ្ឌូចិន ឥណ្ឌូចិន ៦១១ ។
(៤០) / ឥណ្ឌូចិន ៦១៦ Minicolomies ។

ទល់នឹងព្រែកដាក់ដាំ (Dakdam) ខាងត្បូងទល់នឹងជួរភ្នំទាំងឡាយដែលទន្លេ Song - Ba បានចាប់ប្រភព" [៤១] ។

ដូច្នេះខេត្តដារឡាក់ ត្រូវបានបង្កើតឡើងនូវទឹកដីពីរចំណែកដែលស្ថិតនៅក្រោមលក្ខន្តិកៈពីរខុសគ្នា ។ នៅពេលដែលផ្នែកនៅខាងត្បូងត្រូវបានបំបែកចេញពីខេត្តស្ទឹងត្រែងហើយដែលមានទីប្រជុំជន បានមេធ្វួត (Banméthuot) នោះ គឺគ្រាន់តែ "ដាក់ឲ្យស្ថិតនៅក្រោមអំណាចរដ្ឋបាលនិងនយោបាយរបស់រ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាម" តែប៉ុណ្ណោះ ផ្នែកខាងជើងដែលគ្របដណ្ដប់តំបន់កុនទុម (Kontum) ត្រូវបានគ្រប់គ្រងដោយអនុក្រឹត្យចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩០៥ [៤២] នៅក្នុងលក្ខខណ្ឌ ដែល "តំបន់ព្រៃភ្នំ រួមមានទឹកដីសម្រាប់ធ្វើដំណើរ និងផ្លូវក្រឡាដី ដែលស្ថិតនៅបែកខ្ញែកគ្នារបស់កុលសម្ព័ន្ធ ដែលមានឈ្មោះថាSédang ,Halang , Rognac , Bahnar , Djaraï ហើយនិងក្រុម រាយរងទាំងឡាយ នៅក្នុងគ្រួសារតែមួយត្រូវបានប្រគល់ឲ្យវិញនៅក្នុងទឹកដីអណ្ណាម និង ត្រូវបានបង្កើតទៅជាខេត្តស្វយ័ត " (មាត្រាទី១) ។

នៅពេលក្រោយមកមានបទបញ្ញារៀបចំ ខេត្តដារឡាក់ ត្រូវបានបង្កើតឡើង ហើយបានសម្រេចដល់ការបង្កើតអនុក្រឹត្យចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩២៣ [៤៣] ។ ទីប្រជុំជនរដ្ឋបាលដារឡាក់ត្រូវបានតាំងនៅខេត្ត Moï និង ដាក់នៅក្រោមអំណាចរបស់អ្នកអភិបាលម្នាក់គឺរ៉េស៊ីដង់ នៃប្រទេសបារាំងនៅ Banmethuot "បានមេធ្វួត ។

### ៤ – ការទាមទារព្រះរាជវាំងនៅវេ

#### ក/– និក្ខេបបទរបស់ Camat

រដ្ឋាភិបាលអណ្ណាម មិនបានធ្វើការតវ៉ានៅក្នុងឆ្នាំ១៨៩៩ ទេ នៅពេលដែលមានការបង្កើតស្ថានការដ្ឋាន នៅដារឡាក់នោះ ។ ឥរិយាបថនេះ គឺគេយល់ច្បាស់លាស់ ពីព្រោះមណ្ឌលថ្មីនេះត្រូវបានបង្កើតឡើងដោយទឹកដី ដែលមិនមែនជារបស់អណ្ណាម ។

ចាប់ពីឆ្នាំ១៩២៣ រដ្ឋាភិបាលអណ្ណាមបានទាមទារ ប៉ុន្តែមិនមែនជាផ្លូវការ នូវអធិប-តេយ្យភាពនៅលើដារឡាក់នោះទេ និងបានទាមទារការចូលរួមគ្រប់គ្រងនៃខេត្តនេះ ។

(៤១) / ការសិក្សានំពីបញ្ហាភ្ជាប់ដារឡាក់ ដូចបាននិយាយពីមុន ។
(៤២) / J.O.I ១៩០៥ ត្រីមាសទី ១ ទំព័រ ៩១១ ។
(៤៣) / J.O.I ១៩២៣ ត្រីមាសទី ២ ទំព័រ ១២៥៩ ។



ប៉ុន្តែទើបតែនៅក្នុងឆ្នាំ ១៩២៥ នោះទេ បានការទាមទារនេះត្រូវបានបញ្ជាក់ និងត្រូវបានធ្វើឡើងដោយចំហរ ដោយសំឡេងរបស់លោក Comat [៤៤] ។ នៅក្នុងឱកាសនៃការ កម្រិតលក្ខន្តិកៈបុគ្គលនិងទឹកដី Moïs នោះ អាណាព្យាបាលដែលមានបំណងដើម្បីកំណត់ជាស្ថាពរនូវមុខការនៃរដ្ឋបាលទាំងពីរ ដែលត្រូវដាក់ជូនសុំទិដ្ឋាការពីលោក Comat នូវគម្រោងបញ្ញត្តិរៀបចំទុកដាក់ជនជាតិ Moïs និងពលរដ្ឋដែលស្ថិតនៅក្នុងខេត្តនឹងត្រូវបានគ្រប់គ្រងដោយផ្ទាល់ដោយរដ្ឋការក្នុង" [៤៥] ។ Comat បានតវ៉ាយ៉ាងខ្លាំងក្លានិងបានគាំទ្រថា ជនជាតិ Moïs គឺជាមនុស្សរបស់ព្រះចៅ អធិរាជ ហើយដោយហេតុនេះ ដារឡាក់ នៅតែអាចស្ថិតនៅក្រោមរបបរបស់ព្រះ ចៅអធិរាជ ហើយដោយហេតុនេះ ដារឡាក់ នៅតែអាចស្ថិតនៅក្រោមរបបរបស់អាណាព្យាបាល" ។ ចំពោះចំណុចនេះ ការសំអាងហេតុពុំមានភាសាសរសេរចំពោះជនជាតិ Moïs នឹង ឯកសារដែលមានតម្លៃមិនអាចប្រកែកបាននោះ វាជាការពិបាកដើម្បីកំណត់វិធានការដែលនៅក្នុងនោះពួកមនុស្សដែលមិនសូវមានអារ្យធម៌នៅតំបន់ខ្ពស់តាមប្រវត្តិសាស្ត្របានរស់នៅក្នុងចំណុះប្រទេសអណ្ណាម និងបណ្ដារដ្ឋដែលនៅជាប់ព្រំ ប្រទល់ដូចជាប្រទេសសៀម កម្ពុជា ប្រទេសលាវ ដែលមានក្សត្រជាប្រមុខដឹកនាំ ឬបានបង្កើតទៅជាសហគម៍ឯករាជ្យ" [៤៦] ។

ប៉ុន្តែ Comat បានគាំទ្រនិក្ខេបបទផ្សេងទៀតដែរ គឺទឹកដីនៅត្រើយខាងឆ្វេងទន្លេមេគង្គដែលត្រូវបានទាមទារអោយប្រទេសសៀមនៅលើច្បាប់នៃអធិបតេយ្យរបស់ប្រទេសកម្ពុជានិងប្រទេសអណ្ណាម ។ Comat គិតថា អាចទាញបាននូវហេតុផលនូវការពិតដែលថា ទឹកដីទាំងឡាយដែលត្រូវបានផ្ដុំឡើងវិញ ដោយប្រទេសសៀមនោះត្រូវបានទាមទារដោយប្រទេសបារាំង នៅក្នុងនាមព្រះចៅអធិរាជអណ្ណាម (ព្រមពេលជាមួយគ្នានៅក្នុងព្រះបរមនាមរបស់ព្រះមហាក្សត្រ ប្រទេសកម្ពុជាផងដែរ ។ ប៉ុន្តែបញ្ហានេះ Comat បាននៅសៀម) ។ ដោយពិត ការណែនាំទាំងឡាយរបស់លោកអនុរដ្ឋលេខាធិការអាណានិគមដែលផ្ដល់ទៅឲ្យលោកអគ្គទេសាភិបាលឥណ្ឌូចិន នៅ

(៤៤) / ក្រុមប្រឹក្សាសម្ងាត់របស់ព្រះរាជវាំង វេ ។
(៤៥) / ការសិក្សានំពីការភ្ជាប់ដារឡាក់ ដែលបាននិយាយពីមុន ។
(៤៦) / ការសិក្សានំពីការភ្ជាប់ ដាឡាក់ ដែលបាននិយាយពីមុន ។

មុខការបរបាបារាំង-សៀម មិនបានទុកនូវការសង្ស័យណាមួយចំពោះរឿងនេះទេ ។ "ការបរបាទាំងឡាយ នឹងបន្តធ្វើនៅក្នុងនាម និងដើម្បីជាផលប្រយោជន៍របស់រដ្ឋាភិបាលអណ្ណាម និងកម្ពុជា ។ ហេតុដូច្នេះវាជាប្រការដែលខានមិនបានដែលប្រមុខនៃបេសកកម្មត្រូវមានជាប់ជាមួយនូវការប្រទានអំណាចពីព្រះករុណា តាន់ ថាយ (Tan Thai) និងពីព្រះករុណាព្រះបាទនរោត្តម នៅក្នុងរបៀប ដើម្បីខ្លួនអាចរៀបចំឡើងវិញនៅក្នុងនាមរបស់ពួកគេនូវទឹកដីទាំងឡាយដែលជំទាស់និងសន្សារ៉ាប់រងនៅទូទាំងការប្រឡងប្រជែងរបស់ប្រជាជនអណ្ណាម និងប្រជាជនកម្ពុជា ។ ដោយហេតុនេះ លោកនឹងស្នើដោយគ្មានការយឺតយ៉ាវទៅទីក្រុងវ៉េ និងទីក្រុងភ្នំពេញ ដើម្បីប្រគល់ឲ្យនូវកិច្ចការដែលបានបំពេញជាលាយល័ក្សអក្សរ និងពិតប្រាកដរបស់ព្រះចៅអធិរាជអណ្ណាម និងរបស់ព្រះមហាក្សត្រកម្ពុជា និងបញ្ជូននូវរឿងនេះឲ្យបានដល់ដៃលោក Pavie នៅមុនពេលលោកចេញដំណើរទៅកាន់លួងប្រាបាង [៤៧] " ។ ប៉ុន្តែដូច្នេះហើយ បានជាយើងនឹងបានឃើញ ដោយពិនិត្យនូវនិក្ខេបបទរបស់រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម វត្តមាននៃគណៈកម្មការពីរនេះ មិនបានបង្ហាញនូវអ្វីដែលជាអធិបតេយ្យភាពរបស់អណ្ណាម នៅលើទឹកដីដែលមានបញ្ហានោះឡើយ ។

**១ – ជំហររបស់រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាម**

***ក/ –*** *និក្ខេបបទ ស្តីពីការទទួលស្គាល់អធិបតេយ្យភាពអណ្ណាម*

លោក រ៉េស៊ីដង់ ជាន់ខ្ពស់នៅអណ្ណាម បានឃើញនូវនិក្ខេបបទអណ្ណាមនេះមានលក្ខណៈខ្លាំងណាស់ និងបានស្នើឲ្យប្រគល់ការទាមទាររបស់ Comat គឺនៅក្នុងឆ្នាំ ១៨៨៩ គេបានចោទសួរនូវសំណួរអំពីការកែប្រែឥណ្ឌូចិន នូវទឹកដីដែលមានវិវាទ ដែលហេតុដូច្នេះវាបង្កើតបាននូវប្រទេសលាវ និង Hinterland អណ្ណាមនោះ ត្រូវបានទាមទារដោយរដ្ឋាភិបាលបារាំងនៅក្នុងនាមព្រះចៅអធិរាជអណ្ណាម ។

"គឺព្រោះតែនៅសម័យនោះ យើងអាចបង្កើតបាននូវការជំទាស់ចំពោះប្រទេសសៀមនូវអត្ថិភាព នៃអធិបតេយ្យមួយរបស់ព្រះរាជវាំងវ៉េ នៅលើទឹកដីភាគច្រើន

*(៤៧) / លិខិតរបស់អនុរដ្ឋលេខាធិការនៃអាណានិគមផ្ញើទៅលោកអគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៨៨៩ ដោយរំលឹកនៅក្នុងការសិក្សាដែលបាននិយាយខាងដើម ។*



របស់ប្រទេសជិតខាងនោះហើយ ដែលសន្ធិសញ្ញាទាំងឡាយបាននាំមកឲ្យទន្លេមេគង្គនូវខ្សែបន្ទាត់នៃព្រំដែននោះ ។

"វាច្បាស់ណាស់ថា បន្ទាប់ពីបានប្រកាសនិងធ្វើបានជោគជ័យយ៉ាងល្អប្រសើរនូវការទទួលស្គាល់នៃអធិបតេយ្យភាពនៃប្រទេសអណ្ណាមអំពីព្រំដែនរួមនៃអាណាចក្ររបស់ខ្លួនមកនោះ វាបានក្លាយទៅជាការពិបាក ដើម្បីបដិសេធព្រះចៅអធិរាជដដែលនេះ គឺជាសិទ្ធិមួយដែលយើងបានគាំទ្រចំពោះមុខបរទេស" [៤៨] ។

***ខ/–*** *ការរិះគន់របស់លោកអគ្គទេសាភិបាល*

តើយោបល់របស់រ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាមនេះ គួរយកជាការបានទេ ? ចំពោះយើង យើងសូមវាយតម្លៃថា និក្ខេបបទនេះមានតម្លៃ ([៤៨**ស្ទួន**]) សម្រាប់តែមួយ–ភាគ នៃទឹកដីដែលបានបង្កើតខេត្តដារឡាក់ គឺថាចំណែកទឹកដីនៅភាគខាងជើង ។ ការពិតតំបន់ខាងត្បូងដែលបានផ្តាច់ចេញពីខេត្តស្ទឹងត្រែង ដើម្បីបង្កើតស្ទង់ការដ្ឋានដារឡាក់ នៅក្នុងឆ្នាំ ១៨៩៩ ត្រូវបានគេទាមទារដូចជាផ្នែកដទៃទៀត នៃទឹកដីកម្ពុជានៅត្រើយខាងឆ្វេងនៃទន្លេមេគង្គដែរ នៅក្នុងនាមព្រះមហាក្សត្រកម្ពុជា និងឈរនៅលើមូលដ្ឋាននៃច្បាប់របស់ប្រទេសកម្ពុជា ។ ភាពត្រឹមត្រូវនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់ នៅក្នុងលិខិតចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៨៨៩ របស់លោកអនុរដ្ឋលេខាធិការទទួលបន្ទុកប្រទេសអាណានិគម [៤៩] ។

***គ/–*** *និក្ខេបបទនៃការទូទាត់សំណង*

លោក រ៉េស៊ីដង់ ជាន់ខ្ពស់ នៅអណ្ណាម បានធ្វើអន្តរាគមនូវទឡ្ហីករណ៍មួយទៀត គឺការបញ្ចូលជាឧបសម្ព័ន្ធ នៃទឹកដីដារឡាក់ ទៅក្នុងអណ្ណាមត្រូវបានចាត់ទុកដូចជាការទូទាត់សងមួយទៅឲ្យប្រទេសលាវ នូវតំបន់ទាំងឡាយនៃ Tran Ninh . Hua Panh និង Sam Neua ។ ទោះបីជាទឹកដីទាំងនេះត្រូវបានទាមទារដោយរដ្ឋាភិបាលបារាំង ទុកដូចជាទឹកដីចំណុះនៃរាជាធិរាជ ហើយក៏ដោយ ក៏តំបន់ Tran Ninh,Hua Panh និង Sam Neua

*(៤៨) / លិខិតរបស់រ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាម ២៥–៤–១៩២៩ ដែលបាននិយាយខាងដើម ។*

*(៤៨ស្ទួន) / តើវានៅតែសមស្របដែរឬទេ ដែលត្រូវធ្វើការបម្រុងទុកនូវការពិតនៃច្បាប់ទាំងឡាយរបស់អណ្ណាម នៅលើតំបន់ខ្ពស់ទាំងនេះ ដែលបានគេបរបញទាំងស្រុងពីការធ្វើអាណានិគមរបស់អណ្ណាម ។*

*(៤៩) / Cf. supra ។*

ត្រូវបានបំបែកចេញពីការគ្រប់គ្រងរបស់អណ្ណាមដែរ ។ ដូច្នេះវាហាក់ដូចជាថា តាមការទូទាត់សំណងនេះ យើងអាចផ្ទៀតទាញយកគុណប្រយោជន៍របស់ព្រះមហាក្សត្រ ដើម្បីការពង្រីកឥទ្ធិពលរបស់បារាំងទៅខាងជនជាតិ Moïs នៅផ្នែកខាងត្បូង [៥០] ។

និក្ខេបបទនៃការទូទាត់សងនេះ ត្រូវបានចាប់ផ្តើតទៅទៀត ដោយអគ្គទេសាភិបាលឥណ្ឌូចិន ដែល"ស្ថិតនៅក្នុងក្រុមរបស់ឯកឧត្តម (សមាជិករបស់ Comat ) នូវអ្វីដែលបានព្រមព្រៀងជាមួយ រ៉េស៊ីដង់ត៍ជាន់ខ្ពស់ដែលលោកបានរៀបបម្រុង ដើម្បីទទួលយល់ព្រមថា ទឹកដីដារឡាក់ ត្រូវបានផ្តល់ទៅឲ្យព្រះរាជវាំង អណ្ណាម ដើម្បីជាការសងទូទាត់ទឹកដី Sam Neua ដែលភ្ជាប់ទៅឲ្យប្រទេសលាវ" [៥១] ។

**ឃ/-** *ការឆ្លើយបដិសេធចំពោះនិក្ខេបបទទីពីរនេះ*

ប៉ុន្តែទឡ្ហីករណ៍ នៃការសងទូទាត់នេះអាចទ្រាំទ្របានដែរឬទេ ? យើងគិតថាវាមិនអាចទៅរួចទេ ។ ការសងទូទាត់អាចទៅរួចបានតែនៅក្នុងករណីដែលភាគី ជាប់ពាក់ព័ន្ធជាអ្នកទទួលផលផងដែរ នៅក្នុងអំពើនេះ ជាម្ចាស់កម្មសិទ្ធិនៃបញ្ហាទាំងពីរ ដែលស្ថិតនៅក្នុងកម្មវត្ថុនៃការសងទូទាត់ ។ ភាគីមួយនោះបានទទួលជំនួសនូវអ្វីដែលខ្លួនបានប្រគល់ឲ្យ ។ ចំពោះករណីដែលយើងទទួលបន្ទុកនោះ គឺទឹកដី ឬពិតប្រាកដមែនទែន គឺមួយចំណែកនៃទឹកដី ដែលបានឲ្យទៅអណ្ណាម ជាជំនួសនឹងទឹកដីទាំងឡាយដែលក្លាយទៅជាទឹកដីលាវ ដូចជា Sam Neua មិនមែនជារបស់ប្រទេសលាវនោះទេ ។ វាជារបស់ប្រទេសកម្ពុជា ដែលប្រទេសមិនបានទទួលអ្វីទាល់តែសោះ ជាជំនួសនូវទឹកដីដែលត្រូវបានគេដកហូតនោះឡើយ ។

### ៥ – ការភ្ជាប់នយោបាយទៅអណ្ណាម

**ក/-** *អនុក្រឹត្យចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩២៩ (ឧបសម្ព័ន្ធ២)(ទំព័រ២៣១)*

ការទាមទាររបស់អណ្ណាម ដែលនៅក្នុងនោះ រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅអណ្ណាមបានព្រមព្រៀងផ្តល់ការគាំទ្ររបស់ខ្លួន បានបណ្តាលឲ្យមានការបញ្ជូនទៅដល់ទីកន្លែងនូវទីប្រឹក្សារបស់រដ្ឋ លោករីចាដ ដែលទទួលបន្ទុកធ្វើការអង្កេតស្តីអំពីច្បាប់ទាំងឡាយ

*(៥០) / លិខិតរបស់រ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាម ចុះថ្ងៃទី ២៥-៤-១៩២៩ ដែលបាននិយាយខាងដើម ។*
*(៥១) / កំណត់ហេតុនៃសម័យប្រជុំរបស់អគ្គទេសាភិបាលជាមួយសមាជិករបស់ Comat នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩២៩ ។*



របស់អណ្ណាមស្តីអំពីដារឡាក់ ។

សេចក្តីសន្និដ្ឋានទាំងឡាយ នៃរបាយការណ៍នេះត្រូវបានរំលឹកឡើងវិញ ដោយនាយកត្រួតពិនិត្យនៅក្នុងអំឡុងពេលពិនិត្យក្រឹត្យដែលមានទំនោរសំដៅធ្វើឲ្យបានសម្រេចនូវការបញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីដារឡាក់ទៅក្នុងអណ្ណាម គឺ :

ការដឹកនាំ ការត្រួតពិនិត្យ ដែលបានពិគ្រោះយោបល់ ដែលត្រូវបានគេចាត់ ទុកថាជាបញ្ហានយោបាយមួយ និងជាកាលានុវត្តភាព (កាលៈទេសៈដ៏គួរ) ( opportunité )នោះបានឆ្លើយតបដោយ មិនជឿដោយត្រូវបដិសេធនូវទិដ្ឋាការរបស់ ខ្លួននោះទេ ។ ប៉ុន្តែការសន្និដ្ឋាន នេះបានហៅការយកចិត្តទុកដាក់នៃការដឹកនាំនេះ (កិច្ចការនយោបាយនៅក្រសួងនៃអាណានិគម) ថាស្ថិតនៅលើលក្ខខណ្ឌនៃរបាយការណ៍របស់គណៈកម្មការ ដែលដឹកនាំដោយក្រុមប្រឹក្សារដ្ឋ Richard នៅក្នុងឆ្នាំ ១៩២៧ ។ ឯកសារបានបង្ហាញអំពីភាពមិនច្បាស់លាស់នៃច្បាប់រៀងៗខ្លួនរបស់ប្រទេសបារាំង និងអាណាចក្រអណ្ណាមអំពីតំបន់ខ្ពស់នៅខាងក្នុងប្រទេស ។ ម្យ៉ាងទៀតវាច្បាស់ណាស់ថា រដ្ឋាភិបាលអណ្ណាមមិនដែលអាចបង្កើតបានអាជ្ញាធររបស់ខ្លួនដែលមានប្រសិទ្ធភាពទៅលើប្រជាជន Moïs នៅដារឡាក់នោះទេ ហើយរដ្ឋាភិបាលនេះ ក៏នឹងគ្មានសមត្ថភាពផងទៅទៀត ដើម្បីធ្វើបញ្ហានេះនៅក្នុងពេល បច្ចុប្បន្ននេះដែរ" [៥២] ។

ថ្វីបើការសង្កេតដ៏សមហេតុ សមផលទាំងឡាយរបស់ទីប្រឹក្សា Richard ( Conseilles d'Etat Richard) ក៏ដោយ ក៏អគ្គទេសាភិបាលឥណ្ឌូចិន លោក Pierre Pasquier បានយកអនុក្រឹត្យមួយចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩២៩ ដែលបានលុបចោលអនុក្រឹត្យចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩០៧ (មាត្រាទី១) និងបានប្រកាស "ប្រគល់" ឲ្យវិញនូវខេត្តដារឡាក់ នៅក្នុងទឹកដីអណ្ណាម (មាត្រាទី២) [៥៣] ។ អនុក្រឹត្យនេះនឹងត្រូវផ្តល់សច្ចាប័នដោយក្រឹត្យចុះថ្ងៃទី១២ ខែ មេសា ឆ្នាំ ១៩៣២ របស់ប្រធានាធិបតីសាធារណរដ្ឋបារាំង [៥៤] ។

*(៥២) / ការសិក្សាអំពីការភ្ជាប់ខេត្តដារឡាក់ទៅក្នុងអាណាព្យាបាលអណ្ណាម (មាននិយាយពីខាងដើម) ។*
*(៥៣) / ឥណ្ឌូចិន លេខ ៦១៦ ។*
*(៥៤) / ដូចគ្នា (ឥណ្ឌូចិន លេខ ៦១៦) ។*

### ១/– តម្លៃ នៃការភ្ជាប់ខាងនយោបាយ

គេត្រូវតែកត់សម្គាល់នៅទីនេះ ៣ចំណុច គឺអនុក្រឹត្យចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩២៩ បានបង្ហាញនៅចំពោះភ្នែករបស់អ្នកបង្កើតរបស់វានូវអំណាចការពារដូចជាសកម្មភាពនយោបាយមួយ មិនគ្រាន់តែជាបញ្ហារដ្ឋបាលនោះឡើយ ។ វាបានកើតឡើងទៅតាមការស្នើរបស់ព្រះរាជវាំងវើ ។ វាបានឆ្លើយតបទៅនឹងការទាមទារអធិបតេយ្យភាពរបស់ព្រះរាជវាំងវើនេះឯង ។ ដូច្នេះវាមានបំណងចង់បាននូវចរិតលក្ខណៈជាអន្តរជាតិដោយពិតប្រាកដ ។ វាបានបង្ហាញខ្លួនដូចជារូបមន្តមួយនៃ"ការប្រគល់ឲ្យវិញ" ដែលបានប្រើប្រាស់រួចហើយចំពោះអនុក្រឹត្យឆ្នាំ ១៩០៤ ដែលបានផ្គុំតំបន់ខេត្តស្ទឹងត្រែងមក ប្រទេសកម្ពុជាវិញ ។ នៅទីបញ្ចប់អនុក្រឹត្យនេះក៏បានបង្ហាញដូចជាវិធានការមួយនៃការទុកជានិរាករណ៍នូវអនុក្រឹត្យចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤ ⁽⁵⁵⁾ ដែលទាក់ទងទៅនឹងទឹកដីរបស់កម្ពុជា ដែលត្រូវបានបំបែកចេញនូវខេត្តស្ទឹងត្រែង និងដែលពីមុនត្រូវបានបង្កើតទៅជាស្នងការដ្ឋាន ដារឡាក់ តាមអនុក្រឹត្យចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ១៨៩៩ ។

សេចក្តីសង្កេតបីដងនេះ អាចឲ្យយើងបញ្ជាក់បានថា អនុក្រឹត្យចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩២៩ គឺផ្ទុយនឹងវិចារណញ្ញាណ មិនត្រឹមត្រូវតាមច្បាប់ និងប្រហែលជាមិនមានទៀតផង ។

អនុក្រឹត្យនេះវាផ្ទុយនឹងវិចារណញ្ញាណ ព្រោះថា ពាក្យប្រគល់ឲ្យវិញមានរួមបញ្ចូលនូវគំនិតនៃការត្រឡប់ទៅរកសភាពការណ៍ពីមុន ឬក៏ថាដារឡាក់ មិនដែលជារបស់កម្ពុជា ⁽⁵⁶⁾ ទាំងនៅក្រោមអំណាចរបស់បារាំង និងទាំងមិនមែនជាផ្នែកមួយរបស់អណ្ណាមកាលពីពេលមុន ។ ដូច្នេះគេនឹងមិននិយាយអំពីការប្រគល់ទឹកដីទៅឲ្យប្រទេស មួយដែលខ្លួនមិនដែលបានកាន់កាប់អធិបតេយ្យភាព នៅលើទឹកដីទាំងនេះនោះទេ ។

បើសិនជាគេចង់និយាយអំពីការវិលត្រឡប់ទៅរកសភាពការណ៍មុនឆ្នាំ ១៩០៤

---

(៥៥) / អត្ថបទទី១ នៃអនុក្រឹត្យចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩២៩ ការពិតបានចែងថា "អនុក្រឹត្យចុះថ្ងៃទី២២ ខែវិច្ឆិកា ត្រូវបានលុបចោល" ។

(៥៦) / យើងប្រើពាក្យនេះ ដើម្បីលំអនូវសេចក្តីរាយការណ៍ ។



នោះ គឺវាអាចមានតែការវិលត្រឡប់មួយនៃអធិបតេយ្យភាព លាវ ដែលមាននៅក្នុងសម័យនោះ ប៉ុន្តែវាស្ថិតនៅលើចំណុចនៃការបញ្ចប់រួចទៅហើយ នៅក្នុងពេលមួយខែក្រោយមក ។

ម្យ៉ាងទៀតអនុក្រឹត្យ ឆ្នាំ ១៩២៩ ក៏មិនត្រឹមត្រូវតាមច្បាប់ចំពោះផ្នែកនៃច្បាប់ផ្ទៃក្នុងរបស់បារាំង និងចំពោះផ្នែកនៃច្បាប់អន្តរជាតិ ពីព្រោះវាបានជំទាស់ទៅនឹងសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៨៩៣ ដែលបានរួមបញ្ចូលនៃការប្រគល់មកឲ្យប្រទេសកម្ពុជាវិញ នូវទឹកដីទាំងឡាយ ដែលបានទាមទារនៅក្នុងនាមប្រទេសកម្ពុជា ។

ម្យ៉ាងទៀតចំពោះច្បាប់អន្តរជាតិ គេអាចអះអាងទៀតថា វាមិនមានឡើយពីព្រោះវាបានទៅដល់ការផ្ទេរសិទ្ធិ (aliénation) មួយដោយអាជ្ញាធរជាអ្នកការពារដើម្បីជាគុណប្រយោជន៍មួយភាគបីនៃក្បាលដីទាំងឡាយ ដែលមានលក្ខណៈកម្ពុជាមិនអាចប្រកែកបានដោយគតិយុត្ត នៅក្នុងឆ្នាំ ១៩២៩ បើសិនជាគ្មានការយល់ព្រមពីរដ្ឋដែលជាអ្នកការពារទេនោះ ។

ហេតុដូច្នេះ បារាំងមិនទទួលស្គាល់នូវកាតព្វកិច្ចរបស់ខ្លួនជាអ្នកការពារនិងបានចាត់ចែងនូវអ្វីដែលខ្លួនមិនមានជារបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិត្រឹមត្រូវពេញច្បាប់នោះ ។

គំនិតនៃការសងទូទាត់ ការពិនិត្យពិចារណាអំពីកាលានុវត្តភាពនយោបាយដែលអះអាងដោយទេសាភិបាល Pasquier គឺឥតបានផលឡើយ ។

ការពិតអធិបតេយ្យភាពនៃប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩២៩ គឺមិនអាចប្រកែកបានឡើយ ។ អធិបតេយ្យភាពនេះថែមទាំងត្រូវបានទទួលស្គាល់យ៉ាងច្បាស់ប្រាកដប្រជាដោយអនុក្រឹត្យចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩០៤ (ទោះជាដោយប្រយោលក៏ដោយ)នូវ"ការប្រគល់" (នៅទីនេះពាក្យនេះ គឺត្រឹមត្រូវ) នូវខេត្តស្ទឹងត្រែងមកឲ្យកម្ពុជាវិញ ។ តាមការពិតខេត្តនេះ មិនស្ថិតនៅក្នុងការផ្គុំឡើងវិញនូវទឹកដីកម្ពុជាដែលដាក់នៅក្រោមចំណុះប្រទេសអណ្ណាមនោះទេ (ទឹកដីដែលត្រូវបានកំណត់ទៅឲ្យអណ្ណាមនៅឆ្នាំ ១៩២៩) ។

ការមិនបញ្ចូលនៅក្នុងឆ្នាំ ១៩០៤ ត្រូវបានទុកជាត្រូវ នៅក្នុងវិធានការដែលជាវិធានការរដ្ឋបាលធម្មតាមួយ ។ ម្យ៉ាងទៀតវាជាបញ្ហានៃការគ្រប់គ្រងធម្មតាមួយ របស់អាណានិគម ដែលជាមូលដ្ឋាននៃកិច្ចការទាំងអស់របស់ដារឡាក់ ចាប់តាំងពីការបង្កើតរបស់វាលើកលែងតែសកម្មភាពចុងក្រោយ គឺសកម្មភាពនៅឆ្នាំ ១៩២៩ (៥៣) ។

## សេចក្តីសន្និដ្ឋាន
## គេអាចសង្ខេបនូវសេចក្តីសំអាងហេតុផលរបស់យើងបានដូច្នេះថា :

នៅក្នុងឆ្នាំ ១៨៩៣ ទឹកដីរបស់ប្រទេសកម្ពុជានៅត្រើយខាងឆ្វេងទន្លេមេគង្គត្រូវបានលួចយកចេញដោយប្រទេសបារាំង ទៅឲ្យប្រទេសសៀម នៅលើមូលដ្ឋាននៃច្បាប់របស់ប្រទេសកម្ពុជា ។

ខេត្តទាំងនេះ បន្ទាប់ពីការយល់ព្រមនោះមកបញ្ហានេះមិនត្រូវបានតវ៉ាភ្លាមៗពីព្រះមហាក្សត្ររបស់ប្រទេសកម្ពុជានោះទេ និងបានស្គាល់នូវជោគវាសនាផ្សេងៗ ។

*(៥៣) / តាមរបាយការណ៍របស់អគ្គទេសាភិបាលចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩០៧ (ឥណ្ឌូចិន A 20-52 ) ។ លោក Tournier បានធ្វើជាមួយរេសិដកម្មការគួលិក នូវកិច្ចសន្យាបណ្តោះអាសន្នមួយដែលហាក់ដូចជាមិនបានជោគជ័យគឺ :*

*រេសិដកម្មបានរក្សាទុកការដឹកនាំជាបន្ទាន់របស់ប្រទេស និងបានទទួលនូវការឲ្យបញ្ជូនសម្រាប់ភូមិទាំងអស់ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួន បានទទួលប្រាក់ ១៥០០ ពីយ៉ាស្ត្រ (Piastre)សម្រាប់ការជារស្ពានផ្លូវ អាវុធការ៉ាប៊ីន គំរូ ១៨៧៤ ចំនួន៣៥ដើម ជាមួយនិងគ្រាប់២០០គ្រាប់ ក្នុងមួយដើម និងការអនុញ្ញាតឲ្យថែទាំនូវកម្លាំងប៉ូលិស ។ ការគ្រប់គ្រងខាងយុត្តិធម៌សម្រាប់កិច្ចការស៊ីវិលទាំងអស់ត្រូវបានប្រគល់ឲ្យរេសិដកម្ម ។*

** រេសិដកម្មនេះបានទទួលមកវិញនូវការជួយសម្រួលការកិច្ចរបស់វេស៊ីដង់ជាន់ខ្ពស់ ដោយបានផ្តល់ព័ត៌មានដ៏ទៀងទាត់ អំពីហេតុការណ៍សំខាន់ៗនៃតំបន់ ។*

*ប៉ុន្តែរេសិដកម្មបានរំលោភ និងបានធ្វើឲ្យលេចច្បាស់នូវអំណាចរបស់ខ្លួនដែលធ្វើឲ្យអំពល់ដល់អគ្គទេសាភិបាលឥណ្ឌូចិន ហើយដែលលោកបានសម្រេចប្រគល់ការគ្រប់គ្រងតំបន់នេះ ទៅឲ្យអ្នកគ្រប់គ្រងដែលបញ្ជូនមកពីអណ្ណាម ។*

*ជាការគួរឲ្យស្តាយចំពោះកាលបរិច្ឆេទនេះ ត្រង់កន្លែងនៃការជម្រះបញ្ជីរដ្ឋបាល នៅលើមូលដ្ឋាន នៃការគោរពច្បាប់អន្តរជាតិនោះ គេបានបាត់បង់ធ្វើសារលិខិតមួយ ដោយរំលោភសុទ្ធសាធ និងដោយការដណ្តើមយក ដែលគួរឲ្យស្តាយ គឺជាដើមកំណើតនៃសភាពការណ៍នៃការពិតបច្ចុប្បន្ន ។*



ប៉ុន្តែការយល់ព្រមជាដំបូងត្រូវបានទទួលស្គាល់យ៉ាងឆាប់រហ័ស និងបានជួសជុលឡើងវិញ យ៉ាងអាក្រក់នៅក្នុងឆ្នាំ ១៩០៤ ។

លើកលែងតែមួយផ្នែកនៃតំបន់ទាំងនេះទេ ដែលត្រូវបានផ្តាច់ចេញពីបណ្តាខេត្តទី១ តាមទម្រង់បែបបទរាជការ នៅពេលញែកចេញពីគ្នា ហើយបន្ទាប់មកត្រូវបានភ្ជាប់ឡើងវិញ តាមទម្រង់រាជការដដែល ទៅដោយអណ្ណាម ហើយនៅទីបញ្ចប់ត្រូវបានកំណត់នូវអធិបតេយ្យភាពទៅឲ្យប្រទេសនេះនៅក្នុងឆ្នាំ ១៩២៩ ដោយសារលិខិតមួយដែលនៅក្នុងនោះ ប្រទេសកម្ពុជា គឺជាប្រទេសក្រៅ ដែលគេអាចចាត់ទុកបានថា មិនមានឬក៏គ្មានសោះតែម្តង ។

ដូច្នេះសភាពការណ៍គឺជាច្បាប់បញ្ហាដោយការទាមទារនៃអនុសញ្ញាឆ្នាំ ១៨៩៣ ដែលបានទទួលនៅក្នុងឆ្នាំ ១៩០៤ តែការអនុវត្តនូវផ្នែកខ្លះ ហើយដែលត្រូវបានរំលោភដោយដាក់ស្តែងនៅក្នុងឆ្នាំ ១៩២៩ ។

# ភាគ II
# ព្រំដែនរវាងប្រទេសកម្ពុជា
# និង ព្រះរាជាណាចក្រ បាសាក់
# (ប្រទេសលាវ បច្ចុប្បន្ន)
# ផ្នែកដែលរាប់បញ្ចូលរវាងភ្នំដងរែក
# និងទន្លេមេគង្គ ( ១៩០៤ - ១៩០៥ )

## ១- ការបំបាត់អំណាចគ្រប់សក្តិរបស់សៀម: អនុសញ្ញាថ្ងៃទី១៣ ខែកុម្ភៈ ១៩០៤

តាមអនុសញ្ញាថ្ងៃទី៧ ខែតុលា ឆ្នាំ ១៩០២ ដែលបានសម្រេចឡើងរវាងប្រទេសបារាំង និងសៀមនោះ សៀមបានធ្វើនៅក្នុងនាមប្រទេសកម្ពុជា និងក្នុងឋានៈជាកម្លាំងការពារ និងអ្នកនាំពាក្យឲ្យផលប្រយោជន៍របស់ប្រទេសដែលត្រូវការពារបានប្រគល់ទៅឲ្យប្រទេសបារាំងនូវខេត្តម្លូព្រៃ និងទន្លេរពៅ របស់កម្ពុជា ដែលតាមការពិតសៀមបានបញ្ចូលជាឧបសម្ព័ន្ធនិងបានរំដោះព្រះរាជាណាចក្របាសាក់នូវចំណងដាក់ក្នុង

ចំណុះដែលខ្លួនបានដាក់បង្ខំឲ្យអនុវត្ត ( មាត្រា ១, ៤,១) ។

គេដឹងហើយថា អនុសញ្ញានេះ មិនត្រូវបានផ្តល់សច្ចាប័ន ពីរដ្ឋសភាបារាំងឡើយ ប៉ុន្តែ ១- សំខាន់ទាំងឡាយដែលទាក់ទងទៅនឹងផ្នែកនៃទឹកដីនេះ ត្រូវបានដាក់ឡើងវិញ នៅក្នុងមាត្រាទី១ នៃអនុសញ្ញា ដែលបានសម្រេចនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩០៤ រវាងប្រទេសទាំងពីរអនុសញ្ញាដែលធ្វើឡើងគ្រាន់តែជាការបង្គ្រប់កិច្ច ដោយហេតុថា លិខិតឲ្យសច្ចាប័នរបស់អនុសញ្ញានេះបានធ្វើឡើងប្រកបដោយសុពលភាពអន្តរជាតិមួយពេញលេញ ។

តាមការស្រាវជ្រាវដែលដឹកនាំធ្វើទៅនឹងកន្លែងដោយលោក Doudart de Lagrée បានឲ្យដឹងថា ពីដើមព្រះរាជាណាចក្របាសាក់ គឺជាផ្នែកមួយរបស់ប្រទេសកម្ពុជា ។ មានបូជនីយដ្ឋានមួយចំនួនធំ នៅក្នុងស្រុកសម័យអង្គរ ហើយដែលប្រាសាទបាក់បែកទាំងឡាយបានគង់វង់នៅឡើយ រហូតមកដល់សព្វថ្ងៃនេះ និងបានបញ្ជាក់ថា មានវត្តមាននៃអធិបតេយ្យភាពរបស់ខ្មែរនៅលើតំបន់ទាំងនោះ នៅក្នុងសម័យមួយដ៏យូរមកហើយ ។ វាហាក់ដូចជាថា ទឹកដីនេះនឹងត្រូវធ្លាក់បន្តមកទៀតនៅក្រោមអំណាចរបស់ចាម [១] ។ តែថាខេត្តទន្លេរពៅ និងម្លូព្រៃ ដែលមិនដែលជាទឹកដីរបស់ព្រះរាជាណាចក្របាសាក់នោះ គឺតែងតែស្ថិតនៅជាទឹកដីដ៏ត្រឹមត្រូវរបស់ប្រទេសកម្ពុជារហូតដល់ត្រូវបានបញ្ចូលដាក់នៅក្នុងចំណុះប្រទេសសៀម ។

ទោះជាយ៉ាងណាក៏ដោយ អនុសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩០៤ បានផ្តាច់ចេញពីការគ្របសង្កត់របស់សៀមនូវទឹកដីពីរ ដោយលក្ខន្តិកៈគតិយុត្តខុសគ្នា គឺខេត្តទាំងឡាយរបស់ប្រទេសកម្ពុជា ដែលត្រូវបានទាមទារនៅក្នុងនាមព្រះរាជាណាចក្រដែលស្ថិតនៅក្រោមការការពារ និងអង្គភាពស្វយ័តមួយ គឺព្រះរាជាណាចក្របាសាក់ដែលបន្ទាប់មកបានក្លាយទៅជាគោលសំខាន់មួយនៃភាពសាំញ៉ាំខាងគតិយុត្ត នៃប្រទេសលាវបារាំង (du Laos Français) បន្ទាប់មកជាព្រះរាជាណាចក្រលាវ ។

វានៅសល់តែការកម្រិតព្រំដែនរវាងការព្រមព្រៀង (ensemble) ទាំងពីរនេះ ។ ការពិតនេះមិនបានបណ្តាលឲ្យមានបញ្ហាអ្វីសោះឡើយ ចំពោះឧបករណ៍នៃច្បាប់

(១) / របាយការណ៍ក្រោយរបស់លោក doudart de Legrée ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ ១៨៦៦ រេចញពីខេត្តស្ទឹងត្រែង ផ្ញើទៅទេសាភិបាលឥណ្ឌូចិន ។



អន្តរជាតិនេះ នោះគឺអនុសញ្ញាឆ្នាំ ១៩០៤ ។

**២ – ការកម្រិតព្រំដែន :**

**អនុសញ្ញាថ្ងៃទី២៨ ខែមីនា ឆ្នាំ ១៩០៥**

*ក/– ច្បាប់គតិយុត្តនៃការកំណត់ព្រំដែន*

**១ –** គឺជាអនុក្រឹត្យមួយរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ១៩០៥ (ឧបសម្ព័ន្ធ ៣) (ទំព័រ ២៣២) ដែលបានប្រព្រឹត្តទៅដោយលក្ខណៈត្រឹមត្រូវក្នុងការកំណត់ព្រំដែនរវាងព្រះរាជាណាចក្របាសាក់និងព្រំដែនថ្មីរបស់ប្រទេសកម្ពុជា ។

**២ –** ខ្លឹមសារនៃអនុក្រឹត្យចុះថ្ងៃទី២៨ មីនា : អនុក្រឹត្យនេះបានចាប់ដំណើរពីទន្លេរពៅធ្វើជាព្រំដែនរវាងព្រះរាជាណាចក្រទាំងពីរ ។ មាត្រាទី១ របស់អនុសញ្ញានេះបានបញ្ជាក់ថា :

"ព្រំដែនគោលរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្របាសាក់ "លាវ" នៅលើត្រើយខាងស្តាំនៃទន្លេមេគង្គចេញពីមាត់ពាមនៃព្រែក Selam - Pao ( ឬទន្លេ រពៅ) ឡើងទៅដៃធំ នៃព្រែកនេះ ដោយតម្រង់ទៅជួរភ្នំដងរែក ស្មើរតែធម្មតា ហើយបានបញ្ចប់នៅទិសពាយ័ព្យនៃច្រកភ្នំ Prea - Cham-Bock " ។

**៣ –** លក្ខណៈបច្ចេកទេសនៃការកម្រិតព្រំដែននេះ : អ្វីដែលចង្អុលចរិតលក្ខណៈនៃការកម្រិតព្រំដែនដែលបានធ្វើឡើងដោយអនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា នោះ គឺទាក់ទងទៅនឹងការចាប់អារម្មណ៍របស់វា ។ ជាពិសេសអនុក្រឹត្យនេះមិនបាននិយាយថា បើសិនជាការគូសនេះត្រូវធ្វើតាមត្រើយខាងស្តាំឬត្រើយខាងឆ្វេងនៃទន្លេរពៅ ឬក៏ការដោះស្រាយតាមអន្តរការីបែបណាមួយទៀតនោះ ។

នៅចំពោះមុខការស្មៀមស្ងាត់នេះ តើគេត្រូវបកស្រាយការរៀបចំនេះដូចម្តេច ?

ជាធម្មតា កាលណាខ្សែទឹកមួយត្រូវបានជ្រើសរើស ដើម្បីធ្វើការកម្រិតព្រំដែននោះ គឺមានលទ្ធភាពជ្រើសរើសតាមលក្ខណៈព្រំដែន៣ គឺព្រំដែនតាមត្រើយទន្លេ ព្រំដែននៅចំកណ្តាលទន្លេ និងព្រំដែនតាមជ្រលងភ្នំ (Le thalweg) ។

– ព្រំដែនតាមត្រើយទន្លេត្រូវបានគេអនុវត្តជាញឹកញាប់នៅក្នុងអតីតកាល ប៉ុន្តែគេកម្រអនុវត្តណាស់ក្នុងពេលបច្ចុប្បន្ននេះ ។ ក្នុងករណីនេះ ផ្លូវទឹកគឺជារបស់រដ្ឋមួយ

ដោយផ្ដាច់មុខនៅក្នុងចំណោមរដ្ឋទាំងពីរ ។

– ខ្សែកណ្ដាល គឺជាខ្សែរេខាគណិត ដែលត្រូវបានអនុវត្តជាទូទៅនៅតាមព្រែកទាំងឡាយដែលមិនអាចធ្វើនាវាចរបាន ។

– ខ្សែតាមជ្រលងភ្នំ ដែលជ្រៅបំផុតអាចផ្ដល់នូវអត្ថន័យ៣យ៉ាងគឺ:

. ខ្សែក្នុងអត្ថន័យ ដែលសំអាងលើហេតុការណ៍ ខ្សែជ្រលងភ្នំដែលជ្រៅបំផុត គឺជាអ័ក្សនៃជ្រលងដែលមានលក្ខណ:ប្រាកដប្រជាបំផុត និងអាចឲ្យនាវាដែលធំបំផុតចូលទៅជិតបាន ។ ទីនេះការបកស្រាយ គឺមានលក្ខណ:ងាយស្រួលបន្តិច ពីព្រោះថាអត្ថន័យមិនសូវត្រឹមត្រូវនិងពាក្យពេចន៍ក៏មិនច្បាស់លាស់ខ្លាំងដែរ ។

. នៅទីបញ្ចប់សន្ធិសញ្ញាខ្លះបានប្រើនូវពាក្យ "កណ្ដាលខ្សែទឹកសំខាន់" ។ ប៉ុន្តែពាក្យថា "ខ្សែទឹកសំខាន់" អាចបើកឱកាសឲ្យមានការបកស្រាយខុសគ្នា និងមានការវិវាទជំទាស់ [៣] ។

ចំពោះករណីរបស់យើងនេះ វាហាក់ដូចជាថា អ្នកធ្វើអនុក្រឹត្យនេះចង់យកព្រំដែននៃខ្សែជ្រលង នៃដៃសំខាន់នៃទន្លេរពៅ និងត្រូវបានកំណត់ដោយខ្សែជ្រលង ឬមួយតាមខ្សែស្នូងជម្រៅទឹកដែលជ្រៅបំផុត ឬមួយតាមអ័ក្សនៃជ្រលងដែលនាវាធំបំផុតអាចចូលទៅដល់បាន ពីព្រោះថា អគ្គទេសាភិបាលនៅក្នុងសម័យនោះចង់បានដោយប្រាកដណាស់ឲ្យប្រជាជននៅត្រើយទន្លេទាំងពីរ ដែលស្ថិតនៅក្រោមអាជ្ញាធរបារាំងអាចទទួលបានផលប្រយោជន៍ដូចគ្នា ក្នុងការប្រើប្រាស់ទឹកនៃទន្លេរពៅ ។

**៤ –** លក្ខណ:គតិយុត្តនៃច្បាប់កម្រិតព្រំដែន

អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា គឺជាច្បាប់ផ្ទៃក្នុងដោយសុទ្ធសាធជាច្បាប់រដ្ឋបាល និងជាច្បាប់ឯកតោភាគីដោយម៉ឺងម៉ាត់ ។

– ជាបឋមគឺជាច្បាប់មួយនៃច្បាប់ផ្ទៃក្នុងដ៏សុទ្ធសាធ ។ ថ្វីបើយោងទៅរកអនុ–សញ្ញា បារាំង–សៀម ដែលមាននៅក្នុងទិដ្ឋាការ នៅករណីណាក៏ដោយ ក៏មិនត្រូវបានចាត់ទុកថា ជាវិធានការប្រតិបត្តិមួយនៃអនុសញ្ញានេះដែរ ។ ការពិតប្រហែលជាបញ្ហាមួយនេះ គឺជាផលវិបាកនៃបញ្ហាមួយទៀត ប៉ុន្តែវាគ្មានចំណងគតិយុត្តរវាង

(៣) / មើល La Pradelle ,opus cité ។



បញ្ហាទាំងពីរនេះទេ ។ ប្រទេសបារាំងគ្រាន់តែបានគូសការបែងចែករវាងទឹកដី ដែលផ្ដាច់ចេញពីការគ្របសង្កត់របស់សៀមទៅឲ្យឈ្មោះផ្សេងៗ ប៉ុន្តែចាប់ពីពេលនេះតទៅវានៅតែស្ថិតនៅក្រោមចំណុះអាជ្ញាធរបារាំងដដែល ។

– គឺជាច្បាប់នៃធម្មជាតិនៃការអភិបាល គឺវាមានកំណើតចេញពីអាជ្ញាធរគ្រប់គ្រងរបស់អាណានិគមគឺអគ្គទេសាភិបាលឥណ្ឌូចិន វាមិនមែនចេញពីអាជ្ញាធរនៃរដ្ឋាភិបាលបារាំងនោះឡើយ (ដែលគេហ៊ានបង្ហាញគួរឲ្យយកជាការបាននូវលក្ខណ:ខុសគ្នាបែបនេះ) ។ វាបានឆ្លើយតបទៅនឹងក្ដីអំពល់ទាំងឡាយនៃការត្រួតត្រារបស់អាណានិគមដោយសុទ្ធសាធ (Cf.infra§3) ។ គឺជាបន្ទាត់នៃមណ្ឌលគ្រប់គ្រងអាណានិគមនៅក្នុងក្របខ័ណ្ឌសហព័ន្ធឥណ្ឌូចិន ដែលត្រូវបានបង្កើតឡើងដូច្នេះនៅលើការទាក់ទង និងយោបល់របស់អាជ្ញាធរបារាំងនៅក្នុងស្រុក (ពួករ៉េស៊ីដង់ទាំងឡាយ) ។

– គឺជាច្បាប់មួយដែលមានលក្ខណ:ឯកតោភាគីទាំងស្រុង ។ម្យ៉ាងទៀត វាស្ថិតនៅក្នុងតក្កវិជ្ជានៃលក្ខណ:រដ្ឋបាលនៃអនុក្រឹត្យ ។ គ្មានផ្នែកណាមួយដែលអាជ្ញាធរទាំងកម្ពុជា ទាំងអាជ្ញាធរបាសាក់ត្រូវបានគេហៅឲ្យផ្ដល់នូវការយល់ព្រម ឬក៏ផ្ដល់នូវយោបល់របស់ខ្លួននោះឡើយ ។ រហូតដល់ការប្រតិបត្តិនូវអនុក្រឹត្យ ក៏ត្រូវបានគេលួចហូតចេញពីគ្រប់សកម្មភាពទាំងអស់របស់អាជ្ញាធរជាតិ (cf.មាត្រា២) ។ គ្មានករណីណាមួយដែលអនុក្រឹត្យមិនបានគិតទៅដល់លក្ខណ:ដ៏តិចតួចនៃអនុសញ្ញាដែលត្រូវបានឆ្លងកាត់ឬមួយរវាងប្រទេសដែលត្រូវគេការពារ ឬអាជ្ញាធរជាអ្នកការពារ ឬមួយរវាងអាជ្ញាធរដែលត្រូវបានគេការពារទាំងពីរ នៅក្រោមការឧបត្ថម្ភរបស់អ្នកការពាររួមគ្នារបស់ពួកគេនោះទេ ។

*ខ/– ហេតុផលនៃការជ្រើសរើសយកទន្លេរពៅធ្វើជាខ្សែព្រំដែន*

វាច្បាស់ណាស់ថា ការយកទន្លេរពៅធ្វើជាព្រំដែនរវាងព្រះរាជាណាចក្របាសាក់និងកម្ពុជា ចំពោះទស្សន:នៃការគ្រប់គ្រងរបស់អាណានិគម គឺជាដំណោះស្រាយមួយដ៏ងាយបំផុត ។ ដូច្នេះគេស្ថិតនៅចំពោះមុខនៃព្រំដែនធម្មជាតិមួយ ដែលបង្កើតឡើងដោយខ្សែទឹកដែលស្ថិតនៅលើកត្តាភូមិសាស្ត្រងាយស្រួលក្នុងការសម្គាល់ ។

ការជ្រើសរើសបន្ថែមនេះ អាចបង្ហាញនូវអត្ថប្រយោជន៍ មិនគ្រាន់តែចំពោះពួក

អាជ្ញាធរជាអ្នកត្រួតត្រាប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកដែលត្រូវគ្រប់គ្រងផងដែរ ។ ពួកអ្នកស្រុកដែលរស់នៅត្រើយខាងឆ្វេងនៃទន្លេរពៅ ស្ថិតនៅក្រោមចំណុះទីប្រជុំជននៃបាសាក់ ចំណែកអ្នកនៅត្រើយខាងស្តាំវិញ ស្ថិតនៅក្រោមចំណុះទីប្រជុំជន កំពង់ធំដែលនៅឆ្ងាយបំផុត ។ គ្មានអ្នកណាមួយនៅត្រើយទាំងសងខាងនេះបានឆ្លងទន្លេ ដើម្បីមូលហេតុរដ្ឋបាលនោះឡើយ ។

ម្យ៉ាងទៀតនៅក្នុងទស្សនវិស័យអាណានិគមការគូសព្រំដែនរវាងអង្គភាពពីរដែលស្ថិតនៅក្រោមចំណុះអាជ្ញាធរបារាំង និងប្រមូលផ្តុំនៅក្នុងក្របខ័ណ្ឌរដ្ឋបាលតែមួយគឺសហព័ន្ធឥណ្ឌូចិននោះវាបានបង្ហាញនូវប្រតិបត្តិការមួយដែលមានសារប្រយោជន៍តិច។

***គ/– ការរិះគន់និងផលវិបាក***

ផ្ទុយទៅវិញការជ្រើសរើសនេះ ត្រូវបានគេយកធ្វើការពិចារណាផ្សេងទៀតគឺ :

– ជាដំបូងការពិចារណាតាមលក្ខណៈភូមិសាស្ត្រច្រើនជាងលក្ខណៈសង្គម គឺនៅឥណ្ឌូចិន ទឹកទន្លេ មិនអាចផ្តាច់ចេញពីគ្នាបានឡើយ ផ្ទុយទៅវិញវាស្ថិតនៅជាប់គ្នា ។ វាបង្កើតបានជាផ្លូវចេញចូលដ៏ងាយស្រួលសម្រាប់ប្រជាជនដែលមានទម្លាប់រស់នៅលើទឹកច្រើនជាងប្រជាជនដែលរស់នៅលើដី ។ ជាទូទៅវាមានអត្តសញ្ញាណមួយនៃប្រជាភិវឌ្ឍន៍ ( peuplement ) ខាងពូជសាសន៍ ភាសា រវាងប្រជាជននៃត្រើយទាំងពីរ ។

១– ទី២ ខាងជាតិពន្ធ វាមានផលវិបាកដោយផ្ទាល់ចំពោះការពិចារណាជាទូទៅខាងលើនេះ ។ ទន្លេរពៅ មិនបង្កើតបាននូវខ្សែបែងចែករវាងប្រជាជនកម្ពុជា និងប្រជាជនបាសាក់នោះទេ ។

– នៅទីបញ្ចប់តាមហេតុការណ៍ប្រវត្តិសាស្ត្រ និងនយោបាយ គឺព្រំដែនពីមុនស្ថិតនៅខាងជើងឆ្ងាយពីទន្លេរពៅ ក្នុងចម្ងាយមួយដែលឆ្ងាយបង្គួរពីមាត់ពាមនៃព្រែកនេះ ក៏ដូចជាការដែលបានបង្ហាញនៅលើផែនទីនៃបេសកកម្មរុករករបស់លោក Doudart de Lagrée [៤] និងផែនទីដែលបានបង្កើតឡើងក្រោមការមើលខុសត្រូវរបស់តំណាង រាស្ត្រ Deloncle [៥] នៅឆ្នាំ ១៨៨៩ ( C.f ផែនទីឧបសម្ព័ន្ធ) (ទំព័រ ២៥៨) ។

***(៤) / ផែនទីភ្ជាប់ជាមួយនិងរបាយការណ៍របស់លោក F.Garnier ចុះថ្ងៃទី១ ខែតុលា ឆ្នាំ ១៩៧៨ ។ ឥណ្ឌូចិន C.19(79) ។***

***(៥) / ផែនទីនយោបាយឥណ្ឌូចិនរបស់លោក F.Deloncle ធ្វើឡើងនៅក្នុងខែតុលា ឆ្នាំ ១៨៨៩ ដោយរោងពុម្ព F.Appel ,Parrot និង Cie , ប៉ារីស ។***



តែថាសភាពនៃច្បាប់ពីមុននេះបានបម្រើធ្វើជាគ្រឹះនៃការទាមទារដែលធ្វើឡើងនៅប្រទេសថៃ ដោយប្រទេសបារាំងនៅក្នុងនាម នៃប្រទេសកម្ពុជា ។ បើសិនជា អនុសញ្ញា ឆ្នាំ១៩០៤មិនបានគិតគូរអ្វី នៅក្នុងការគូសព្រំដែនរវាងព្រះរាជាណាចក្រ បាសាក់ និងប្រទេសកម្ពុជាទេនោះ គ្រឹះនៃការធ្វើអនុប្បទាន ( Cession ) នូវទឹកដីដែលបានឧទ្ទិសដល់នោះ គឺឥឡូវនេះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងទៅតាមទឹកដីដែលគេបានបោះបង់ចោល ។ ជាពិសេសគឺខេត្តម្លូព្រៃ និងទន្លេរពៅទាំងពីរ គឺត្រូវបានទាមទារមកវិញនៅក្នុងនាមនៃប្រទេសដែលស្ថិតនៅក្រោមការការពារហើយហេតុការណ៍នេះនឹងត្រូវបានបញ្ជាឲ្យមានការបែងចែកដែលធ្វើឡើងបន្ទាប់មកទៀតនៅក្រោមការ មើលខុសត្រូវរបស់បារាំងនូវទឹកដីដែលបានប្រគល់ឲ្យ ។

តែថា ហេតុនៃការជ្រើសរើស ទន្លេរពៅធ្វើជាមណ្ឌលជាច្រើនរបស់កម្ពុជាដោយការធ្វើប្រជាភិវឌ្ឍន៍របស់ខ្លួននោះ ដែលការទាមទារត្រូវបានធ្វើឡើងនៅប្រទេស សៀម នៅលើមូលដ្ឋាននៃច្បាប់ទាំងឡាយរបស់កម្ពុជានោះ គឺត្រូវតែឆ្លងកាត់តាម អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា នៅក្រោមអាជ្ញាធរបាសាក់ [៥ស្ទួន] ។

នេះបង្កើតបានដោយពិតប្រាកដនូវប្រភេទនៃការគេបំបាត់ពីខាងអាជ្ញាធរជាអ្នកការពារការមិនទទួលស្គាល់ដោយប្រយោលនូវគ្រឹះទាំងឡាយនៃអនុសញ្ញាឆ្នាំ ១៩០៤ នោះ គឺជាការរំលោភមួយនៃអនុសញ្ញានេះ ។

ហើយគេអាចយកលេសថា អគ្គទេសាភិបាលឥណ្ឌូចិន បានធ្វើដោយល្ងង់ខ្លៅឬដោយភាន់ច្រឡំ ព្រោះលោកបានធ្វើឲ្យទៅជាផ្លូវការក្នុងរបៀបបំពាននៃច្បាប់នេះ ។

**៣ – ការកាត់ចេញដោយចេតនានូវទឹកដីជាតិកម្ពុជា :**

**អនុក្រឹត្យ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩០៥ (ឧបសម្ព័ន្ធ៤) (ទំព័រ ២៣៣)**

អនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩០៥ គឺមានបំណង ដើម្បីបញ្ជាក់ដោយប្រាកដប្រជាក្នុង "ការភ្ជាប់មួង ( muong ) ផ្សេងៗនៅក្នុងប្រទេសកម្ពុជាទៅឲ្យខេត្តនៃបាសាក់ (លាវ) " [៦] ។

***(៥ស្ទួន) / មណ្ឌលទាំងនេះគឺ ១° ផុន ថុង (Phon-Thong) ២° ប៉ាសា (Pasah) ៣° ស៊ូ ឃុម (Sou Khoume) ៤° អ៊ូ ធុម (Outhoum) ៥° មូឡា ពូម៉ុក (Moula Poumok) ៦° សាផាង ភូហ្វា (Saphang Phoufa) ៧° សេឡាមប៉ាវ (Selampao) ខាងជើង (Cf.មាត្រាទី១ នៃអនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩០៥ ) ។***

***(៦) / ពាក្យ មួង Muong គឺមានន័យស្មើនឹងពាក្យកម្ពុជាថា ស្រុក (arrondis sement) ។***

## ១ – មូលហេតុនៃអនុក្រឹត្យនេះ

គេអាចកត់សម្គាល់នូវការភ្ញាក់ផ្អើល ខ្លះនៅចំពោះមុខអនុក្រឹត្យបែបនេះ ដែលផលប្រយោជន៍របស់វាមិនបានលេចឡើងនៅពេលដំបូងនោះឡើយ ។ ការកំណត់ទឹកដីនៃព្រះរាជាណាចក្របាសាក់ បានបណ្ដាលឲ្យមានភាពច្បាស់លាស់គ្រប់គ្រាន់តាមលក្ខណៈភូមិសាស្ត្រ នៃអនុក្រឹត្យទីមួយ ដើម្បីកុំឲ្យវាមានភាពចាំបាច់ ដើម្បីបញ្ជាក់នូវដែនអំណាចនៃមណ្ឌលថ្មី ។

អនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា អាចពន្យល់បានតែនៅក្នុងវិធានការដែលថា នាំមកនូវកត្តាថ្មីមួយ តើកត្តាថ្មីនេះអាចជាអ្វីទៅ ? គេមិនបេះតែសង្ស័យពេកទេ ការបកស្រាយតែមួយគត់ដែលមានលទ្ធភាពនោះគឺគោលបំណងនៃអនុក្រឹត្យនេះ គឺដើម្បីបញ្ចូលឲ្យនៅក្រោមអាជ្ញាធរនៃអ្នកគ្រប់គ្រងនៅបាសាក់នូវតំបន់ទាំងឡាយដែលរហូតមកដល់ពេលនេះថ្វីបើការកម្រិតព្រំដែន ដែលត្រូវបានសម្រេចធ្វើឡើង ដោយអនុក្រឹត្យចុះថ្ងៃទី២៨ មីនា ក៏ដោយ ក៏តែងតែបានគេចចេញពីអាណាចក្រនៃអាជ្ញាធរបាសាក់ដែរ ។ វាសមជាការពិតណាស់ នៅពេលដែលគេអាចសម្គាល់ឃើញថាស្របទៅតាមសភាពការណ៍ពីមុន តំបន់ទាំងនេះបានបន្តគេចចេញពីឥទ្ធិពលរបស់ លោករ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសលាវ ដែលលោកបានទទួលពីអគ្គទេសាភិបាល ឥណ្ឌូចិននូវអត្ថបទមួយដែលបានកំណត់ផ្ដល់ឲ្យលោកនូវវិស័យមួយនៃសមត្ថកិច្ចស្របទៅតាមគំនូសនៃព្រំដែនទាំងឡាយ ដែលបានធ្វើឡើងកាលពីប៉ុន្មានខែមុននេះ ។ វាគ្រប់គ្រាន់ដើម្បីធ្វើឲ្យគេជឿ និងដើម្បីសម្គាល់ឃើញថា អនុក្រឹត្យត្រូវបានធ្វើឡើងតែទៅតាមការស្នើតែមួយគត់របស់លោក រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៅប្រទេសលាវ ដោយគ្មានការបញ្ជាក់ណាមួយ ដែលធ្វើឡើងដោយអាជ្ញាធរណាមួយរបស់ជាតិកម្ពុជា ឬក៏អាជ្ញាធរជាអ្នកការពារនោះឡើយ ។ ប៉ុន្តែខ្សែបន្ទាត់នេះ វាបានបញ្ជាក់យ៉ាងប្រត្យក្សនូវលក្ខណៈនៃការរំលោភព្រំដែនទន្លេរពៅ ដែលបើតាមការសំអាងរបស់អនុក្រឹត្យថ្មីក៏ដោយ ក៏វាមិនបានត្រូវគ្នាជាមួយព្រំដែននៃជាតិពន្ធ ឬព្រំដែននៃភាសានោះដែរ ហើយវាបានកែប្រែនូវសភាពការណ៍នៃការអភិបាលដែលមានមកពីមុន ។ គេអាច



និយាយឲ្យកាន់តែច្បាស់ទៀតថា គឺជាការកាត់យកទឹកដីនៃប្រទេសកម្ពុជា ដើម្បី ជាគុណប្រយោជន៍ដល់ខេត្តបាសាក់ (ចំប៉ាសាក់) ។

## ២ – តម្លៃគតិយុត្តរបស់អនុក្រឹត្យចុះថ្ងៃទី ១៦ ខែមីនា

ជាដំបូង គេត្រូវតែគូសបញ្ជាក់ថា អនុក្រឹត្យនេះ គឺគ្រាន់តែជាច្បាប់រដ្ឋបាលផ្ទៃក្នុងធម្មតាមួយនិងមានលក្ខណៈជាឯកតោភាគីតែប៉ុណ្ណោះ ។ នេះក៏បង្ហាញដោយប្រត្យក្សនូវហេតុការណ៍ថា អត្ថបទនេះថែមទាំងមិនបានបង្ហាញនូវទិដ្ឋភាពនៃទំនាក់ទំនងដែលបានតុល្យភាព ដែលចង្អុលចរិតលក្ខណៈ ដោយអនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនានោះទេ ។ ពុំមានអាជ្ញាធរកម្ពុជាណាមួយទាំងព្រះមហាក្សត្រ ទាំងលោករ៉េស៊ីដង់ត៍ជាន់ខ្ពស់ ទាំងក្រុងប្រឹក្សានៃអាណាព្យាបាល ពុំត្រូវបានគេពិគ្រោះយោបល់ឡើយ ។ គឺជាការបំពេញចិត្តមួយផ្ដល់ទៅឲ្យការទាមទារមួយរបស់លោក រ៉េស៊ីដង់ត៍ជាន់ខ្ពស់នៃប្រទេសលាវ ។

ដូច្នេះគឺជាច្បាប់មួយដែលគ្មានតម្លៃ នៅចំពោះភ្នែកនៃច្បាប់អន្តរជាតិ ។ វាគ្រាន់តែតំណាងឲ្យការបែងចែកនៃសមត្ថកិច្ចទាំងឡាយ នៃការអភិបាលដោយសុទ្ធសាធនៅក្នុងក្របខ័ណ្ឌមួយរបស់អាណានិគម ។

## ៣ – ការទាក់ទងរវាងអនុក្រឹត្យ ចុះថ្ងៃទី១៦ ខែឧសភា និងអនុក្រឹត្យចុះថ្ងៃទី ២៨ ខែមីនា

បើសិនជាអនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា បានបង្ហាញខ្លួនដោយឡែកនោះ សភាពការណ៍ គឺងាយស្រួលណាស់: គេគ្រាន់តែសម្គាល់ឃើញថា អត្ថបទមួយដែលតាមការសំអាងរបស់ខ្លួនផ្ទាល់ បានលួចហូតនូវសមត្ថកិច្ចរបស់អ្នកអភិបាលបារាំងនៅប្រទេសកម្ពុជានូវស្រុកទាំងឡាយរបស់កម្ពុជា ប្រហែលជាត្រឹមត្រូវតាមច្បាប់ដោយឥតខ្ចោះនៅលើឋានៈនៃការគ្រប់គ្រងរបស់អាណានិគម ប៉ុន្តែវាមិនអាចជំទាស់ចំពោះរដ្ឋដែលត្រូវបានការពារ នៅពេលដែលក្របខ័ណ្ឌរដ្ឋបាល អាណានិគមត្រូវបានលុបបោលនោះ ។

អ្វីដែលធ្ងន់ធ្ងរបំផុតនោះ គឺមានតែអនុក្រឹត្យ ចុះថ្ងៃទី១៦ ខែឧសភានោះទេ ដែលបានផ្ដល់នូវសារសំខាន់ខាងផ្នែករដ្ឋបាល នៃគំនូសព្រំដែនដែលបានកំណត់ដោយអនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា ។ ដូច្នេះវាមានការទាក់ទងជាមួយអនុក្រឹត្យនេះ ដោយ

ផ្តាច់ចេញដោយឡែកពីគ្នា ។

ន័យគតិយុត្តរបស់អនុក្រឹត្យទាំងពីរនេះ និងតម្លៃរបស់វាមិនដូចគ្នាបេះបិទនោះឡើយ ។ ដូច្នេះគេត្រូវតែបង្ខំចិត្ត ដើម្បីទទួលស្គាល់ផងដែរ នូវច្បាប់ស្តីពីការកំណត់ព្រំដែនទន្លេរពៅ (អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា) ថាជាតម្លៃនៃការកម្រិតព្រំដែនរដ្ឋបាលរបស់អាណានិគម ។

ដើម្បីបដិសេធនូវការវិភាគនេះគេបានផ្ទាញ់ផ្ទាល់ (acculé) ដើម្បីប្រកាសថា អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា ដែលបានបំភ្លឺដោយអនុក្រឹត្យ ចុះថ្ងៃទី១៦ ខែឧសភា គឺបានរំលោភយ៉ាងច្បាស់និងដោយចេតនាទៅលើអនុសញ្ញាបារាំង-សៀម ឆ្នាំ១៩០៤ ដែលតាមពិត អនុសញ្ញានេះមានគោលបំណង ដើម្បីប្រគល់ឲ្យមកប្រទេសកម្ពុជានូវអតីតខេត្តទាំងនេះ ។ តែថា អនុក្រឹត្យក្រោយៗមកទៀត មិនបានទទួលស្គាល់ព្រំខាងក្រៅនៃទឹកដីរបស់ខេត្តទាំងនេះទេ ។ អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា គេមិនបាននិយាយ អនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា គេបាននិយាយ ។ វាបានបង្កើតនូវសភាពនៃហេតុការណ៍ថ្មី នៅពេលដែលគេត្រូវពិនិត្យមើលនូវស្ថានភាពដែលមានមកពីមុន ។ ដូច្នេះគេត្រូវបានបង្ខំឲ្យមើលឃើញតែច្បាប់ដែលគ្មានតម្លៃ ។

### ៤ – សេចក្តីសន្និដ្ឋាន

**អ្វីដែលបាននិយាយពីមុន បានបង្ហាញនូវលទ្ធផលថា :**

១ – អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា ១៩០៥ (និងដោយបន្ទាប់បន្សំអនុក្រឹត្យចុះថ្ងៃទី១៦ ខែឧសភា ១៩០៥ ) មិនមែនជាច្បាប់អន្តរជាតិទេ ប៉ុន្តែគឺជាច្បាប់ផ្ទៃក្នុងរបស់បារាំងដោយសុទ្ធសាធ ។

២ – នៅក្នុងវិធានការដែលគេបានយកលេសថា ត្រូវបានប្រកាន់យកក្នុងការអនុវត្តអនុសញ្ញាបារាំង សៀម ឆ្នាំ ១៩០៤ និងកំណត់នូវព្រំដែនអន្តរជាតិមួយរវាងទឹកដីដែលត្រូវបានប្រគល់ឲ្យវិញ ដោយអនុសញ្ញា នៅព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានការពារ និងព្រះរាជាណាចក្របាសាក់ ដែលត្រូវបានបោះបង់ដោយប្រទេស បារាំង អត្ថបទទាំងនេះដែលតាមការសំអាងរបស់អនុក្រឹត្យមួយនោះ បានកាត់នូវទឹកដីរបស់កម្ពុជាដែលត្រូវបានប្រគល់ឲ្យវិញ បានធ្វើឲ្យខូចមិនគ្រាន់តែនៅចំពោះ



ផ្នែកនៃច្បាប់អន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅចំពោះផ្នែកនៃច្បាប់ផ្ទៃក្នុងរបស់បារាំងទៀតផង (ហើយប្រហែលទាំងគ្មានទៀតផង ) ។

អវត្តមាននៃតម្លៃអន្តរជាតិនេះ ត្រូវបានធ្វើឲ្យលេចច្បាស់ដោយការពិតថា អ្នកអាណាព្យាបាលបារាំងបានធ្វើដោយពុំបានពិគ្រោះយោបល់ជាមួយប្រទេសដែលត្រូវការពារទាំងប្រឆាំងនិងផលប្រយោជន៍របស់ប្រទេសនេះទៀតផង (៣) ។

នៅក្នុងវិធានការដែលអត្ថបទទាំងនេះបានបង្កើតនូវមណ្ឌលត្រួតត្រាធម្មតារបស់អាណានិគមបារាំង ដែលមិនបានប៉ះពាល់ដល់បញ្ហានៃអធិបតេយ្យភាពនៃទឹកដីប្រហែលជាវាបានបង្កើតនូវច្បាប់គតិយុត្ត ដែលគួរយកជាការបាន ប៉ុន្តែគឺជាច្បាប់ ផ្ទៃក្នុងរបស់បារាំងដោយសុទ្ធសាធ គឺគ្មានន័យអន្តរជាតិឡើយ ច្បាប់នោះវាត្រូវតែធ្វើឲ្យប្រើការបានដោយប្រាកដប្រជាដោយមានការទទួលស្គាល់ពីបណ្តាប្រទេសដែលមានព្រំដែនជាប់គ្នានិងដែលបានត្រឡប់មករកឯករាជ្យវិញនោះ ។

ដោយអវត្តមាននៃការទទួលស្គាល់បែបណាមួយនោះ ព្រំដែននៅតែត្រូវគូសដដែលគឺវាស្ថិតនៅជាប់ច្បាប់ដែលកំណត់ដោយកត្តា នៃលំដាប់ខាងប្រវត្តិសាស្ត្រ ខាងភាសានិងខាងជាតិពន្ធ ដូចដែលយើងបានឃើញហើយ និងថែមទាំងការសំអាងរបស់អាជ្ញាធរអាណានិគមផងនោះ បានបញ្ហានូវការគូសព្រំដែនមួយដែល អនុគ្រោះបំផុតនៅប្រទេសកម្ពុជា ។

(៣) / នៅក្នុងសម្មតិកម្មនេះ ប្រទេសបារាំងត្រូវធ្វើជាពីរដំណាក់កាល គឺនៅក្នុងកម្រិតនៃទំនាក់ទំនងជាមួយសៀម បារាំងត្រូវដើរដែក ច្បាប់នៃប្រទេសកម្ពុជា ដើម្បីទទួលបាននូវការប្រគល់នៃទឹកដី ។ នៅកម្រិតនៃការប្រតិបត្តិនៃកិច្ចព្រមព្រៀងដែលទទួលបាន ដូច្នេះបារាំងត្រូវដណ្តើមយកធនធាននៃប្រទេសកម្ពុជា ។ គឺដោយសារការពិនិត្យឃើញនេះហើយ ដែលត្រូវបានបង្ខំឲ្យទៅដល់ការទទួលស្គាល់នូវតម្លៃអន្តរជាតិមួយនៃព្រំដែនទន្លេរពៅ ។ តាមការពិត វាជាការជាក់ស្តែង ដែលបារាំងជាមហាអំណាចអាណានិគម មិនបានកំណត់នូវសារសំខាន់ពិសេសណាមួយឡើយ ដែលនៅចំពោះភ្នែករបស់ខ្លួនវាគ្រាន់តែជាគំនូសផ្ទៃក្នុងមួយតែប៉ុណ្ណោះ ។

## ភាគ III
## ព្រំដែនរវាង តាន់ អាន , ត្រាង បាង និង តៃ និញ (កូសាំងស៊ីន) មួយផ្នែក និងស្វាយរៀង ព្រៃវែង និងកំពង់ចាម (កម្ពុជា) មួយផ្នែកទៀត
## (១៨៦៩ ~ ១៨៧២)

ការកម្រិតខ្សែបន្ទាត់នៃផ្នែកព្រំដែននេះ ត្រូវបានកើតមានឡើងនៅក្នុងឆ្នាំ ១៨៦៩ ។ ផ្នែកទីមួយនៃការងារពិនិត្យឲ្យស្គាល់ និងការបោះគោលដី ត្រូវបានអនុវត្តនៅក្នុងឆ្នាំ ១៨៧០ ហើយផ្នែកទីពីរ នៃការងារនេះត្រូវបានធ្វើឡើងរវាងឆ្នាំ១៨៧០ និងឆ្នាំ ១៨៧២។

**យើងនឹងពិនិត្យមើលនៅក្នុងជំពូកពីរ ជាបន្តបន្ទាប់ គឺ :**

- ការបង្កើតព្រំដែន
- តម្លៃគតិយុត្ត នៃខ្សែគំនូសដែលបានជ្រើសរើសយក

គេត្រូវតែកត់សម្គាល់ថា វិធីនៃការពិភាក្សាដែលយើងបានជ្រើសរើសយកទៅទីនេះ (និងជាវិធីដែលយើងជ្រើសរើសយកនៅក្នុងជំពូកបន្ទាប់ទៀតផងដែរនោះ) គឺមានលក្ខណៈខុសគ្នាពីវិធីដែលយើងបានដើរតាមពីមុន គឺយើងនឹងញែកចេញនៃសេចក្តីរាយការណ៍នៃប្រវត្តិសាស្ត្រស្តីពីការបង្កើតព្រំដែន(ជំពូក ı) និងការពិភាក្សាខាងគតិយុត្ត ដោយចំតែម្តង (ជំពូក ıı) ។

យើងយល់ស្របតាមការដោះស្រាយនេះព្រោះថា ម្យ៉ាងវាហាក់ដូចជាថា ប្រវត្តិសាស្ត្រនៃការធ្វើអាណានិគមដោយខ្ជាប់ខ្ជួននោះ គឺមានការណែនាំដោយពិសេស និងត្រូវបាត់បង់នូវកម្លាំងរបស់ខ្លួនដែលធ្វើឲ្យគេជឿតាម បើសិនជាវាត្រូវបានប្រមូលផ្តុំទៅលើការពិភាក្សាតែខាងគតិយុត្តនោះ ។

ម្យ៉ាងទៀតប្រវត្តិសាស្ត្រនេះ មានលក្ខណៈស្មុគស្មាញគ្រប់គ្រាន់ ដើម្បីញុំាងមិនឲ្យធ្វើអ្វីកើតនូវកម្លាំងទឡ្ហីកម្មគតិយុត្ត បើសិនជាកម្លាំងនេះត្រូវដើរតាមដោយផ្ទាល់នូវកម្លាំងមួយទៀត ។



## ជំពូកទី I
## ការបង្កើតព្រំដែន
## ផ្នែក I
## សភាពការណ៍នៅមុនពេលការងារចាប់ផ្តើមអនុវត្តន៍

នៅដើមដំបូងនៃការធ្វើសញ្ជ័យ (ការច្បាំងដណ្តើមយកទឹកដី) របស់បារាំងនូវខេត្តទាំង៣ នៅភាគខាងកើតនៃកូសាំងស៊ីន ក្រោមឧត្តមនាវី មេបញ្ជាការនៃកងទ័ព និងជាទេសាភិបាល នៃកូសាំងស៊ីន បានចូលកាន់កាប់ បន្ទាយទាំងឡាយដែលត្រូវបានកាន់កាប់ដោយពួកអណ្ណាម។ ចំណុចទាំងនេះបានក្លាយទៅជាប៉ុស្តិ៍ជួរមុខរបស់បារាំង ។ នៅក្នុងតំបន់ដែលយើងចាប់អារម្មណ៍នោះ ប៉ុស្តិ៍ទាំងនេះរួមមាន បៀន ហ្វា (Bien Hoa) ជាមួយនឹងឧបសម្ព័ន្ធពីរទៀតរបស់ប៉ុស្តិ៍នេះ គឺ ធូ-យ៉ាវ-ម៉ូត (Thu-Yao-Mat ឬ Thudaumot ) និងបារៀ (Baria) (១) ។ ហើយនិងតៃនិញ (Tay-Ninh) ដែលស្ថិតនៅទិសពាយ័ព្យដ៏ឆ្ងាយ : "យើងមានទឹកដីដែលមានជីវជាតិបំផុតនៅព្រះរាជាណាចក្រអណ្ណាម ហើយយើងបានកាន់កាប់ផុតពីការលុកលុយទាំងអស់ពីសត្រូវដោយសារមធ្យោបាយនៃបន្ទាយទាំងឡាយនៅតៃនិញ នៅព្រំដែនរួមគ្នានៅកម្ពុជា នៅ Toueyn - Mot ( Thudaumot ) នៅលើទឹកដី បៀនហ្វា ដែលនៅតាមមាត់ទន្លេ..." (២)។

ប៉ុន្តែព្រំដែនរវាងកូសាំងស៊ីន និងប្រទេសកម្ពុជា បានកំណត់ដោយមិនច្បាស់លាស់ "ព្រំដែនរបស់យើងត្រូវបានកំណត់ ដោយមិនច្បាស់លាស់ឬមិនសូវច្បាស់លាស់ ។ គឺមានតែពេលវេលា និងបន្ទាប់ពីយើងអាចចងនូវទំនាក់ទំនងឲ្យបានខ្ជាប់ខ្ជួនចំពោះបញ្ហានេះទេ ទើបវាផ្តល់ឲ្យយើងកំណត់បានដោយច្បាស់លាស់ និងនៅក្នុងរបៀបមួយដ៏ប្រាកដប្រជា នូវបញ្ហាព្រំដែនដ៏សំខាន់នេះ" (៣) ។

---

*(១) / លិខិតចុះថ្ងៃទី៨ មករា ១៨៦៣ របស់ទេសាភិបាលកូសាំងស៊ីនផ្ញើទៅក្រសួងជើងទឹក ។ ឥណ្ឌូចិន A 200 (1) ។*

*(២) / លិខិតរបស់លោកឧត្តមនាវីទោ សារណើរ (Charner) ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ១៨៦១ ផ្ញើទៅជូនក្រសួងជើងទឹក ។ ឥណ្ឌូចិន A 30 (2) ។*

*(៣) / លិខិតរបស់លោកឧត្តមនាវីត្រី de la Grandiere ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ១៨៦៣ ផ្ញើទៅជូនក្រសួងជើងទឹក ។ ឥណ្ឌូចិន A 30 (60) ។*

ថ្វីបើព្រំដែនទាំងឡាយមិនច្បាស់លាស់ក៏ដោយ ក៏ឯកសារជាផ្លូវការទាំងឡាយនៅក្នុងសម័យនោះ បានផ្ដល់ព័ត៌មានដល់យើងអំពីចំណុចទាំងឡាយដែលបានបញ្ចប់ទឹកដីកូសាំងស៊ីន ហើយដែលបានចាប់ផ្ដើមនូវទឹកដីនៃប្រទេសកម្ពុជា ។

### ក – នៅទិសប្លិសាន

ព្រំដែននៅក្នុងតំបន់នេះ បានកំណត់តាមផ្លូវថ្នល់ដែលត្រូវបានស្ថាបនាឡើង នៅក្នុងឆ្នាំ ១៨៦៨ ដែលបានតភ្ជាប់ តៃ និញ ទៅបារៀ ដោយមានការវាងនៅធូយូវម៉ូត : "ខ្ញុំបានឲ្យគេធ្វើផ្លូវយុទ្ធសាស្ត្រ ដែលបត់តាមព្រំដែនរបស់យើងពី តៃ និញ ទៅបារៀ ដើម្បីឲ្យកងទ័ពរបស់យើងអាចដឹកជញ្ជូន ពីចំណុចមួយទៅចំណុចមួយទៀត" [៤] ។ ឆ្ងាយជាងនេះទៅទៀត នៅក្នុងលិខិតដដែលនេះ ទេសាភិបាលឥណ្ឌូចិនបានបញ្ជាក់ថា "ដើម្បីឲ្យកងទ័ព របស់យើងទៅកាន់កន្លែងណាមួយបានឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជា និងដើម្បីធ្វើចរាចរឲ្យបានងាយស្រួលនៅតាមព្រំដែនខាងជើងបំផុត នៃការកាន់កាប់របស់យើងខ្ញុំ បានធ្វើឲ្យផ្លូវថ្នល់ពីព្រៃនគរទៅមីថ(Mytho) មានសភាពល្អពេញលេញ ព្រមទាំងបានបង្ហើយបញ្ចប់ផ្លូវថ្នល់ពីបារៀ ទៅតៃនិញផងដែរ" ។

### ខ – នៅខាងជើងតៃនិញ

របាយការណ៍ទាំងឡាយរបស់លោកមេបញ្ជាការ Alleyron [៥] ស្ដីអំពីឧទ្ទាមកម្ម ដែលបានបង្កចលាចល នៅក្នុងឆ្នាំ១៨៦៦ នៅតៃនិញ តាមមេឧទ្ទាមកម្ពុជាឈ្មោះ ពោរកំពោ (Pou-kombo) បានឲ្យយើងដឹងថា ស្ទើរតែទាំងអស់ ឬពុំនោះទេ គឺភូមិទាំងអស់ដែលស្ថិតនៅក្រោមចំណុះអាជ្ញាធរកម្ពុជា ។

### ១ – ភូមិទាំងឡាយរបស់កម្ពុជា

ភូមិទាំងឡាយរបស់កម្ពុជាដែលបាននិយាយនៅក្នុងរបាយការណ៍ទាំងនេះ គឺមានភូមិ :

១°. អុំ បុក (Om Boc) "លោក (លោក de larclause) [៦] បានរកឃើញនៅឆ្ងាយ

(៤) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី៣០ កញ្ញា ១៨៦៨ ផ្ញើទៅក្រសួងជើងទឹក ។ ឥណ្ឌូចិន A 20 (6) ។

(៥) / របាយការណ៍ចុះថ្ងៃទី២២ មិថុនា និងថ្ងៃទី៥ កក្កដា ១៨៦៦ ផ្ញើទៅនាយសេនាធិការ និងទៅឧត្តមនាវីទេសាភិបាលកូសាំងស៊ីន ។

(៦) / អធិការទទួលបន្ទុកកិច្ចការប្រជាជនអន្នាមក្រោម នៅតៃនិញ ។



បន្តិចពីអុំបុក នៅរ៉ាបាវ(Rabao) [៧] នូវការបោះជំរំ ជាសញ្ញាថា ជារបស់ពួកឧទ្ទាម ។ លោក de Larclause បានបំផ្លាញចោលនៅយប់ទី៣ ដល់យប់ទី៤ ។ នៅក្នុងឱកាសដដែលនេះ លោកអាចចាប់បានជនកម្ពុជាចំនួន៤នាក់ នៅភូមិ អុំបុក ដោយបាននាំមកជាមួយ ខ្លួននូវឈ្លើយសឹក ទៅតៃនិញ នៅក្នុងថ្ងៃទី៤ " ។ (**កកន** ប្រវត្តិសាស្ត្របានសរសេរថាខ្មែរក្រោកឡើងតស៊ូនាំឲ្យបារាំងខឹងសម្បារក៏បែងចែកទឹកដីផ្នែកនោះទៅឲ្យអណ្ណាម ទៅប្រហែលជាក្នុងនោះមានពោធិកំពោ ជាមេដឹកនាំ...?) ។

២°. បាវ ស៊ុត (Bao Sut) : "ថ្ងៃទី១១ ក្រោយពីបានដុតបំផ្លាញភូមិស្ដុល (Sdoll) គេបានតម្រង់ទៅភូមិ បាវ ស៊ុត [៨] ជាភូមិមួយ ដែលលូ ផានសាន (Lou-Phan-San) មេអាទិករកម្ពុជាខាងប៉ះបោរដ៏សំខាន់ម្នាក់រស់នៅ" ។

៣°.ស្រុកធាតុ (Srok Thiet)បាវ អារ៉ាក្ស(Bao-Arack) ស្រុក ហុំ (Srok Hom) [៩]។ "គេបានដឹងតាមរយៈកុលសម្ព័ន្ធចេង(Cheng) ដែលនៅតែស្មោះត្រង់នឹងយើងនោះថា ពេលល្ងាចនៅតៃនិញ ពួកឧទ្ទាមដែលបានចាកចេញពីត្រាវីយ៉ុង (Traviong) [១០] នៅពេលព្រឹកថ្ងៃទី១១ បានតម្រង់ទៅកាន់ស្រុកធាតុ បាវអារ៉ាក្ស និងស្រុកហុំ ដែលជាភូមិរបស់ លូ ខា ហុម (Lou - Kha - Hôm) " [១១] ។

៤°. វាំង ហា (Viang hà) [១២] "គេបានឈប់នៅភូមិកម្ពុជាឈ្មោះ វីយ៉ាំង ហា ដែលពួកឧទ្ទាមមួយផ្នែកបានរត់គេចខ្លួននៅជិតយើង" ។

៥°.ត្រាត្រាវ (Tra - Trau) "យើងបានទៅដល់ត្រាត្រាវនៅវេលាម៉ោង៥ល្ងាច ។ ភូមិនេះ នៅតែមានប្រជាជនកម្ពុជាខ្លះកាន់កាប់ដែលពួកគេបានរត់គេចខ្លួននៅពេលដែលយើងបានទៅដល់ជិតពួកគេ" [១៣] ។

(៧) / ឈ្មោះ រ៉ាច បៅ (Rach Bau) នៅលើផែនទី A - Rousseau (១៨៩៦) នៅខាងលិចតៃនិញ ។

(៨) / នៅលើផែនទី ដែលបាននិយាយពីមុន ភូមិនេះសរសេរថា Bau Suc ។

(៩) / នៅលើផែនទី ដែលបាននិយាយពីមុន ឈ្មោះទាំងនេះ សរសេរថា : Soc . Thiet , Bau - A - Rach , Socom ។ ភូមិទាំងនេះស្ថិតនៅទិសពាយ័ព្យ នៃតៃនិញ ។

(១០) / នៅលើផែនទី ដែលបាននិយាយពីមុន ត្រា វ៉ុន (Travon) ។

(១១) / រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនជើងគោក ដែលស្ថិតនៅក្នុងចំណែកជាប់មុខ (Cf.infra , note 17) ។

(១២) / នៅលើផែនទី ឈ្មោះនេះសរសេរថា Bau - Vang - hà ។

(១៣) / គ្មានចុះនៅក្នុងផែនទី ប៉ុន្តែត្រូវស្ថិតនៅខាងជើង តាជាក ។

៦°. តាដាក (Tadac) [១៤] "ថ្ងៃស្អែកឡើង នៅលើផ្លូវត្រាត្រាវ នៅភូមិតាដាកមានស្នាមរថយន្តជ្រៅៗជាច្រើនបើកកាត់ និងដែលយើងបានជួបប្រទះនោះបានបង្ហាញយើងថា ក្បួនរថយន្តកម្ពុជា គឺមានច្រើនសន្ធឹកសន្ធាប់និងបានធ្វើដំណើរទៅតាមទិសដៅដូចយើងដែរ ។ តាដាក ត្រូវបានគេបោះបង់ចោល ប៉ុន្តែវាគ្រាន់តែស្ថិតនៅជិតយើងតែប៉ុណ្ណោះ ។ គឺជាភូមិដ៏មានសម្បត្តិមួយរបស់កម្ពុជា និងស្ថិតនៅលើដីទួលដ៏តូចមួយដែលមានព្រៃនៅជាប់ពីខាង ។ យើងបានរកឃើញធនធានគ្រប់ប្រភេទទាំងអស់ហើយនៅពេលដែលម្នាក់ៗត្រូវបានផ្តល់ស្បៀងបរិបូរណ៍ហើយនោះ ខ្ញុំបានដាក់បញ្ជាឲ្យកាប់ដើមឈើដល់គល់ បំផ្លាញវប្បធម៌ទាំងឡាយ និងដុតបំផ្លាញខ្ទមទាំង ឡាយ និងស្រូវដែលទុកបម្រុងដែលគេលាក់ទុកនៅក្នុងព្រៃ" ។

៧°. សេរ៉ុក – ថ្រាន (Seroc - Thran) [១៥] "យើងបានជួបដោយចៃដន្យនូវព្រឹទ្ធាចារ្យពិការម្នាក់ ដែលលាក់ខ្លួននៅក្នុងគម្ពោតព្រៃដែលនៅពេលនោះ យើងទទួលបាននូវព័ត៌មានដ៏ល្អប្រសើរ គឺ : លោកតានោះបាននិយាយប្រាប់យើងថា កងទ័ពរបស់ពួកឧទ្ទាមមិនបានឆ្លងកាត់ទាំងនៅត្រាត្រាវ ទាំងនៅតាដាកនោះទេ ប៉ុន្តែពួកគេបានបញ្ជូនបេសកជនទាំងឡាយឲ្យមកនាំប្រជាជនបះបោរ ហើយដែលពួកគេបានស្នាក់នៅភូមិ Seroc . Thran ដែលស្ថិតនៅលើទឹកដីកម្ពុជា..." ។

" Seroc - Thran គឺជាភូមិកម្ពុជាមួយ ដ៏ល្អឆើតឆាយ និងមានសម្បត្តិណាស់ទៀត ផងខ្ទមទាំងឡាយបានបញ្ចេញឲ្យឃើញថា មានទ្រព្យសម្បត្តិគ្រប់គ្រាន់ដែលភាគច្រើនក្នុងនោះត្រូវបានប្រែក្លាយទៅជាជង្រុកស្រូវ ។ ដូចជានៅតាដាកដែរ ខ្ញុំឲ្យគេបំផ្លាញ និងដុតចោលទាំងអស់" ។

ប្រាកដហើយ របាយការណ៍ទាំងឡាយរបស់មេបញ្ជាការ Alleyron មិនបានរៀបរាប់ភូមិកម្ពុជាគ្រប់ទាំងអស់នោះទេ ។ របាយការណ៍នេះបានបង្ហាញតែភូមិទាំងឡាយដែលមានព្រឹត្តិការណ៍កើតឡើង ។ ប៉ុន្តែបើសិនជាគេនឹកដល់ផែនទីរបស់លោក

(១៤) / នៅលើផែនទី នៃវិទ្យាស្ថានភូមិសាស្ត្រជាតិខ្នាត ១/៤០០.០០០ ឈ្មោះសរសេរថា តា ដាត (Ta-Dath) ជាភូមិមួយនៅខាងជើង តៃនិញ ។

(១៥) / នៅលើផែនទីរបស់ A.Rousseau ឈ្មោះនេះសរសេរថា ស្រុក – ត្រាញ់ (Srok Tranh) ជាភូមិមួយដែលឥឡូវនេះស្ថិតនៅក្នុងទឹកដីវៀតណាម នៅជិតព្រំដែនប្រទេសកម្ពុជា ។



A.Rousseau ដែលបានរៀបចំនៅក្នុងឆ្នាំ ១៨៩៦ គឺថា ៣០ឆ្នាំ ក្រោយរបាយការណ៍របស់មេបញ្ជាការ Allegron នោះ គេនឹងថាតំបន់នេះ មិនសូវមានមនុស្សរស់នៅច្រើនទេ និងមានតែភូមិបួនដប់ប៉ុណ្ណោះ ។

សូម្បីតែនៅក្នុងឆ្នាំ ១៩១០ ក៏ដោយ គឺថា ៤៤ឆ្នាំយូរក្រោយមកទៀត នៅភាគខាងជើង តៃ និញ គឺមានប្រជាជនរស់នៅដោយតិចតួច ។ នោះគឺជាអ្វីដែលយើងបានដឹងជាភស្តុតាងរបស់អធិការ Bougourd ដែលមាននៅក្នុងរបាយការណ៍របស់លោកលេខ ៦៣ រៀបរាប់ នៅក្នុងឆ្នាំ ១៩១០ ថា : "ខេត្ត តៃ និញ មានវិសាលភាពធំធេង ប៉ុន្តែគេត្រូវតែចាត់ទុកថា ផ្នែកទាំងអស់ដែលស្ថិតនៅខាងជើងទីរួមខេត្ត គឺស្ទើរតែគ្មានមនុស្សនៅ ។ ភូមិទាំង១០ ដែលមានព្រៃឈើផងនោះ នៅក្នុងតំបន់នេះ គឺមានឈ្មោះនៅក្នុងបញ្ជីតែ ១១៦៤ នាក់ប៉ុណ្ណោះ [១៦] " ។

របាយការណ៍របស់លោកមេបញ្ជាការ Alleyron បានសរសេរអំពីភូមិរបស់កម្ពុជាជាង ១០ ដែលស្ថិតនៅខាងជើង តៃ និញ ។ ជិតកន្លះសតវត្សរ៍ក្រោយមក លោក Bougourd បានផ្តល់នូវតួលេខដដែល ។ ព័ត៌មានទាំងនេះបានបញ្ជាក់ឲ្យឃើញថា ត្រូវចំពោះនិក្ខេបបទរបស់យើង ដែលនៅក្នុងនោះតំបន់ដែលស្ថិតនៅខាងជើងតៃ និញ គឺមានតែប្រជាជនកម្ពុជារស់នៅ និងជាផ្នែករួមបញ្ចូល នៃទឹកដីកម្ពុជា ។ លើសពីនេះទៅទៀត វាមិនគ្រាន់តែមានប្រជាជនកម្ពុជារស់នៅប៉ុណ្ណោះទេ វាថែមទាំងមានអាជ្ញាធរកម្ពុជាជាអ្នកអភិបាលទៀតផង ។

## ២ – អាជ្ញាធរ កម្ពុជា

ខេត្តតៃ និញ ដែលបានឈ្មោះជាកម្ពុជាថា រោងដំរី (Rong Damrey) នោះគឺជាទឹកដីរបស់រដ្ឋមួយ [១៧] ។ ការគ្រប់គ្រងរបស់ខេត្តនេះ ត្រូវបានប្រគល់ឲ្យរដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនមួយរូប ដែលមានងារជាកម្ពុជាថា លោកក្រឡាហោម (Lok Cralahom) ។ លោកក្រឡាហោម [១៨] មាននិវេសនដ្ឋានរបស់លោកនៅក្នុងតំបន់នៃភូមិ ស្រុកធាតុ

(១៦) / ឯកសារលេខ D 1020 ។

(១៧) / រដ្ឋ ជាសាមីនីមួយៗ បានប្រគល់ការគ្រប់គ្រងទៅឲ្យខេត្តមួយចំនួនដែលរដ្ឋនោះបានទទួលនូវផលខុន ។ រដ្ឋនោះបានគ្រប់គ្រងខេត្តទាំងនោះតាមរយៈអន្តរការី នៃរដ្ឋមន្ត្រីរបស់ខ្លួន ដែលមានបទាសម្ព័ន្ធស្ទើរតែដូចគ្នា និងរដ្ឋមន្ត្រីរបស់ព្រះរាជា ។

(១៨) / នៅក្នុងរបាយការណ៍របស់មេបញ្ជាការ Alleyron ងារនេះសរសេរថា ឡុន ខា ហូម (Lon Kha Hôm) ។

បាវ អារ័ក្ស ស្រុកហូម។ លោកក្រឡាហោម មានមន្ត្រីស្ថិតនៅក្រោមបញ្ជារបស់លោក គឺប្រធានមណ្ឌលរដ្ឋបាល ដែលមានងារថា លោក ប៉ាន សាន (Lok Pan San) [១៩] ។ ប្រធានមណ្ឌលរដ្ឋបាលមួយនោះដែលមានលំនៅស្ថានរបស់ខ្លួននៅភូមិបាវស៊ុត (Bao - Sut) (Bao - Suc នៅលើដែនដីរបស់លោក A.Rousseau) គឺជាភ្នាក់ងារដ៏សំខាន់នៃការបះបោររបស់ពោរកំបោ ដែលបានផ្ទុះឡើងនៅ តៃ និញ នៅក្នុងខែកក្កដា ឆ្នាំ១៨៦៦ "គឺវាមានពិតប្រាកដណាស់ គឺថាចាប់តាំងពីច្រើនខែមកហើយ ប្រជាជនកម្ពុជា នៃកុលសម្ព័ន្ធ លូ ផាន សាន បានប្រមូលផ្តុំគ្នា នៅត្រាវីយ៉ុង" Traviong [២០] ។ គឺគាត់នេះហើយដែលបានបញ្ជូនបេសកជនទាំងនាមកព្រៃនគរ ដើម្បីកំណត់ឲ្យពោរកំបោរត់គេចខ្លួននៅថ្ងៃទី៤ខែឧសភា ឆ្នាំ ១៨៦៦ ចេញពីទីក្រុងនេះ ដែលគាត់ស្ថិតនៅក្នុងលំនៅស្ថាន ក្រោមការឃ្លាំមើល ។ គឺមនុស្សរបស់គាត់ និងមនុស្សរបស់លោកក្រឡាហោម ដែលបានបង្កើតក្រុមមនុស្សដំបូង នៃកងទ័ពរបស់ពោរកំបោ : " នៅថ្ងៃទី៩ គេបានដឹង ជាវិជ្ជមានដោយការចូលមកវិញនៅភូមិចាម (Cham) [២១] នៃ ដុងតាអែសា (Dong Taè xà) ថាក្រុមកម្ពុជា គឺជាផ្នែកមួយដ៏ធំ ដែលរួមមានមនុស្ស រស់ លូ ខា ហូម និង លូ ផាន សាន " [២២] ។

ដូច លោក ប៉ាន សាន (Lok Pan San) នៅបាវស៊ុតដែរ អ្នកផ្សេងៗទៀតដែលតំណាងឲ្យអាជ្ញាធរកម្ពុជា បាននៅក្រោមអំណាចលោកក្រឡាហោម : "នៅពេលដែលសំឡេងនៃការបះបោរត្រូវបានលេចឮនៅតៃនិញនោះ លោកក្រឡាហោម មិនបានសង្ស័យថា ពួកគេនៅទីបំផុត បានស្គាល់លោក De Larclause ដែលគាត់បានទទួលនូវការព្រមានដ៏ធ្ងន់ធ្ងរជាច្រើនលើកនោះទេ ។ រហូតដល់ពេលចុងក្រោយ លោក De Larclause ដែលមានទំនាក់ទំនងជាញឹកញាប់ជាមួយប្រធានកម្ពុជាទាំងអស់ ដែលជាច្រើននាក់នៅក្នុងពួកគេទាំងនោះ មានការស្រឡាញ់លោកយ៉ាងជ្រាលជ្រៅហើយលោកបានរស់នៅ នៅក្នុងចំណោមពួកគេជាយូរមកហើយនេះ បានឃើញថាពួកគេមិនរឹង

(១៩) / មេបញ្ជា Alleyron សរសេរថា លូ ផាន សាន ។

(២០) / របាយការណ៍ថ្ងៃទី២២ ខែមិថុនា ១៨៦៦ របស់មេបញ្ជាការ Alleyron ។

(២១) / ចាម (Cham) ជាសម្ព័ន្ធញាតិរបស់ម៉ាឡេ ដែលត្រូវបានគេចាត់ទុកដូចជាប្រជាជនកម្ពុជាមានសញ្ជាតិកម្ពុជា ។

(២២) / របាយការណ៍ដែលបាននិយាយពីមុន ។



រូសនិងបេះស្តាប់បង្គាប់នោះ បានជឿថា ការនិយាយរៀបរាប់នេះ គឺជាការនិយាយពន្លើស និងភូតកុហក [២៣] ។

លោកក្រឡាហោម មានកម្លាំងកងទ័ពដ៏សំខាន់បង្គួរ ដើម្បីធានាអំណាចរបស់ខ្លួននៅលើទឹកដីដែលខ្លួនទទួលបន្ទុក "ថ្ងៃទី៣ ខែមិថុនា លោក De Larclause បានសម្រេចទៅធ្វើការបញ្ជាក់ដល់ទីកន្លែងនូវព័ត៌មានទាំងឡាយ ដែលគេបានរាយការណ៍ជូនលោក និងប្រឹងប្រែងធ្វើឲ្យពួកគេគោរព ព្រមទាំងបានចាប់ប្រធានខ្លះ ដែលគេបានឲ្យការណ៍ ថាជាមេដឹកនាំនៃចលនានេះ ។ លោកក្រឡាហោមបានស្នើឲ្យនាយទាហានដែលបញ្ជាបន្ទាយនៅ តៃ និញ គឺលោកអនុសេនីយ៍ឯក Pinault ជាមួយនិងទាហានអមការពារចំនួន១៥នាក់ និងពលបាលត្រីម្នាក់ផង និងលោកបានបញ្ជូនបញ្ជាទៅមេកម្ពុជា គឺ លូ ខា ហូម ឲ្យដាក់នៅក្រោមកិច្ចការរបស់លោកនូវមនុស្សចំនួន ១៥០ នាក់ នៅក្នុងចំណោមមនុស្សរបស់ខ្លួនដែលមានអាវុធ..." ។

ហេតុដូច្នេះយើងឃើញថា ទឹកដីខេត្តតៃ និញ នៅក្នុងឆ្នាំ ១៨៦៦ ស្ទើរតែរស់នៅដោយប្រជាជនកម្ពុជាទាំងស្រុង និងស្ថិតនៅក្រោមអំណាចអាជ្ញាធរ ដែលតំណាងឲ្យរាជការកម្ពុជា ។

## គ – នៅខាងលិចប៉ុស្តិ៍ តៃ និញ

តំបន់ទាំងអស់ដែលស្ថិតនៅខាងលិចបន្ទាយ តៃ និញ គឺជាផ្នែកនៃទឹកដីកម្ពុជា ។ ទន្លេវ៉ៃ គោ(Vaïco)ខាងកើតឬក៏ទន្លេវ៉ៃគោធំ [២៤] គឺជាទឹកដីរបស់ខ្មែរ ។ ដើម្បីឲ្យគេជឿ គេត្រូវតែនឹកដល់សក្ខីកម្មរបស់លោកឧត្តមនាវី de la Grandière ទេសាភិបាលនៃកូសាំងស៊ីន ដែលមានកាលបរិច្ឆេទនៅឆ្នាំ១៨៦៧ គឺថា៣ឆ្នាំមុនការងារបោះគោលដី : "ខ្ញុំមិនចង់ និយាយអំពីការលេចឡើងថ្មីៗនៅលើច្រាំងទល់មុខទន្លេវ៉ៃគោធំ ដែលជារបស់ប្រទេសកម្ពុជានោះទេ ដែលមានគ្រួសារកម្ពុជាដ៏ច្រើនបង្គួរ ដែលបានគេចខ្លួននៅចំពោះមុខពោរកំបោ" [២៥] ។

(២៣) / របាយការណ៍ដែលបាននិយាយពីមុន ។

(២៤) / ទន្លេវ៉ៃគោខាងកើតបានឈ្មោះថា ទន្លេវ៉ៃគោធំ (de Lanessan ឥណ្ឌូចិន បារាំង ប៉ារីស ១៨៨៩ ) ។

(២៥) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី២៨ មិថុនា ១៨៦៧ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងជើងទឹកឥណ្ឌូចិន A . 30 (12) ។

ម្យ៉ាងទៀតគឺនៅលើច្រាំងទន្លេវ៉ៃគោខាងកើត ដែលព្រះកែវហ្វា (Prea Keofa) (ឬព្រះមហាក្សត្រទី២) [២៦] ត្រូវបានថ្វាយអំណាចជាមេបញ្ជាការនៃខេត្តបាភ្នំ "ខ្ញុំបានគាំពារព្រះកែវហ្វា នៅក្នុងអំឡុងការចូលកាន់កាប់របស់ព្រះអង្គជាមេបញ្ជាការនៅលើត្រើយនៃទន្លេវ៉ៃគោធំ ដោយទាហានខ្លះរបស់យើងដែលស្ថិតនៅ ហ្គោ–ហ្វាយ (Go-Huai) ដែលនៅទីនោះព្រះអង្គបានរុលទៅមុខនៅក្នុងខេត្តបាភ្នំ [២៧] ។

ព័ត៌មានដែលបានរាយការណ៍ខាងលើនេះ បានឲ្យយើងដឹងថា តំបន់ដែលស្ថិតនៅខាងលិច ខាងជើង នៃបន្ទាយតៃ និញ និងនៅទិសឦសាន នៃផ្លូវទីមួយដែលបានស្ថាបនាឡើងនៅក្នុងឆ្នាំ ១៨៦៨ ដើម្បីតភ្ជាប់ពី តៃ និញ ទៅបារៀ គឺជាផ្នែកនៃទឹកដីកម្ពុជា ។ ព័ត៌មានទាំងនេះត្រូវបានបញ្ជាក់ដោយអធិការទទួលបន្ទុកប្រជាជនអន្តោប្រវេសន៍ (sic: អន្តោគ្រាម) នៅតៃនិញ ដែលជាតំណាងម្នាក់នៃរាជការកូសាំងស៊ីន នៅក្នុងគណៈកម្មការកម្រិតព្រំដែនដែលបានរួមប្រជុំក្រោយមក (Cf.infra) ។ គាត់បានសរសេរនៅក្នុងឆ្នាំ ១៨៧២ គឺពីរ ឆ្នាំក្រោយការងារបោះគោលដី : "គេមិនត្រូវភ្លេចថា ប្រទេសនេះ គឺជារបស់កម្ពុជារហូតដល់បៀនហ្វា" [២៨] ។

## ផ្នែកទី II
## ការរៀបចំ

### ក – គោលបំណង នៃការបោះគោលដី

ក្នុងការសម្រេចនូវការកម្រិតនិងការបោះគោលដីនៃព្រំដែននៅក្នុងតំបន់នេះ ទេសាភិបាលកូសាំងស៊ីន បានបន្តអនុវត្តនូវគោលបំណងមួយខាងបែបបទរដ្ឋបាល គឺលោកចង់ជួយសម្រួលដល់ការទារពន្ធដារ និងរារាំងកុំឲ្យអ្នកស្រុកនិយាយព្រមគ្នាថាជាអាណិកជននៅកូសាំងស៊ីនផង និងជាប្រជារាស្ត្ររបស់ព្រះមហាក្សត្រនៃប្រទេសកម្ពុជាផង : "ព្រំដែនកូសាំងស៊ីន និងព្រំដែនកម្ពុជា ស្ថិតនៅទិសខាងលិចនៃការត្រួត

(២៦) / អនាគតព្រះមហាក្សត្រ ស៊ីសុវត្ថិ ។

(២៧) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី២៨ មិថុនា ១៨៦៧ ដែលបាននិយាយពីមុន ។

(២៨) / លិខិតរបស់អធិការ Rheinard ផ្ញើទៅនាយកក្រសួងមហាផ្ទៃ ចុះថ្ងៃទី ២៣ ខែមីនា ១៨៧២ ។



ពិនិត្យរបស់តៃនិញ របស់ តាន អាន គឺមានការគូសមិនសូវល្អ ។ នៅក្នុងពេលនេះ ខ្ញុំសូមធ្វើការកម្រិតតាមធម្មជាតិ ទន្ទឹមនិងការរៀបចំផលប្រយោជន៍របស់ប្រទេសកម្ពុជា និងផលប្រយោជន៍របស់យើង ដែលអាចផ្តល់ដល់ព្រំដែននេះនូវភាពមិនប្រែប្រួលមួយដែលមិនដែលមាន និងដើម្បីរារាំង *កុំឲ្យអ្នកភូមិខ្លះនិយាយភាសាចារាំង នៅពេលដែលមន្ត្រីរបស់ព្រះមហាក្សត្រទៅទារពន្ធដារពីពួកគេ និងកុំឲ្យនិយាយភាសាខ្មែរនៅពេលដែលយើងទៅទាមទារពន្ធដារ ពីពួកគេ ។ វាបានបណ្តាលឲ្យកាលៈទេសៈនេះ* មានការច្របូកច្របល់ខ្លះដែលគួរតែបញ្ឈប់កុំឲ្យមានដូច្នេះ" [២៩] ។

### ១ – សំណើរបស់អធិការ តាន អាន និងត្រាង បាង

នៅមុនការងារបោះគោលដីនេះ ទេសាភិបាលកូសាំងស៊ីន បានស្នើសុំដល់អធិការ៣នាក់ឲ្យសិក្សាអំពីគំនូសព្រំដែន និងឲ្យដាក់ជូនគាត់ពិនិត្យនូវសេចក្តីស្នើរបស់ពួកគេ។

អធិការទាំង៣នាក់ គឺលោក ដឺ បាស្តារ (de bastard) លោក ឡាប៊ូស៊ីយ៉ែរ (Labussière) និងលោក បេណូ៌ស (Benoist) ដាក់ជូននូវសេចក្តីស្នើនេះដែលគេសង្ខេបបានដូចតទៅនេះ :

#### ១ – អធិការកិច្ចនៅ តាន អាន

"លោកអធិការ នៅ តាន អាន បានវាយតម្លៃថា ព្រំដែនបច្ចុប្បន្ន គឺឥតខ្ចោះពីព្រោះថា ព្រំដែននេះត្រូវបានកំណត់តាមលក្ខណៈភូមិសាស្ត្រតាម Rach Cai Co នៅមាត់ពាមដែលនៅទីនោះ "គេបានដាក់ ប៉ុស្តិ៍ត្រួតពិនិត្យថ្មីមួយនៅ Hung Nguyen" [៣០] ។

#### ២ – អធិការកិច្ចនៅ ត្រាង បាង

លោកអធិការ នៅត្រាយ បាង បានប្រកាសថា ទឹកដីរបស់ប្រទេសកម្ពុជាបានលូតទៅមុខយ៉ាងវែង ឆ្ពោះទៅទិសខាងត្បូងវាង ម៉ុក ហ្វា (Moc Hoa) និងយ៉ាយ ហ្វា (Gai-Hoà ) ។ បន្ទាប់ពីការស្នើរបស់លោក "ប្រកបដោយលក្ខណៈភូមិសាស្ត្រនោះមកព្រំដែនអាចត្រូវបានកំណត់ តាម ហ្វាយ មី (Goai Mi) (R.Bao) ចាប់តាំងពី វីយ៉ាម (Viam) នៃ Cai . Co រហូតដល់ដីចុងក្រោយ នៃឃុំនិងភូមិ ឡុង ខាញ់ (Long - Khanh) ។

(២៩) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី ១៥ កក្កដា ១៨៦៩ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងដែនដីក្រៅប្រទេស (អណ្ណូចិន) A - 20 (៩) ។

(៣០) / របាយការណ៍របស់អធិការទាំង៣ ភ្ជាប់ជាមួយលិខិតរបស់នាយកនៃក្រសួងមហាផ្ទៃចុះថ្ងៃទី ៦ ខែកញ្ញា ១៨៦៩ ផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន ។

ព្រំដែនថ្មីនេះព័ទ្ធជុំវិញតំបន់ព្រៃ ដែលព័ទ្ធជុំវិញខ្ពង់រាបតូចៗ ដែលខ័ណ្ឌទឹកនៃទន្លេវ៉ៃគោទាំងពីរ ដែលរស់នៅដោយប្រជាជនកម្ពុជាសុទ្ធសាធ" ។

តើចំណែកនៃទឹកដីកម្ពុជា ណាដែលលោកអធិការ Labussière បានស្នើបញ្ចូលទៅក្នុងកូសាំងស៊ីន ? ទឹកដីនោះបង្កើតបាននូវចំណែកដីដែលគេដាក់ឈ្មោះ នៅពេលបច្ចុប្បន្ននេះថា "ចំពុះទា" ពីព្រោះដីនេះវាដូចចំពុះនៃសត្វទា ដែលលយទៅក្នុងទឹកដីវៀតណាម ។ ចំណែកនេះរួមមានទឹកដីនៃស្រុក ស្វាយទាប ហើយនិងទឹកដីនៃប៉ុស្តិ៍រដ្ឋបាលនៅកំពង់រោទិ៍ ។

ព្រំដែនត្រូវបានកំណត់ដោយខ្សែទឹកនៃទន្លេ រ៉ាច បូ (Rach Bau) និងខ្សែបន្ទាត់មួយដែលបន្តយ៉ាងវែងតម្រង់ឆ្ពោះទៅរហូតដល់ (ស្រុក) កំពង់ចម្លង ។

**៣ – អធិការកិច្ចនៅ តៃ និញ**

លោកអធិការនៅ តៃ និញ បានផ្តល់ព័ត៌មានដូចតទៅនេះ នៅតំបន់ដែលលោកចាប់អារម្មណ៍ "ពួកអណ្ណាម ដែលជាអ្នកធ្វើសញ្ជ័យ និងពួកទាហានជើងទឹក បានធ្វើដំណើរតាមផ្លូវទឹកព្រែកនៅតាមច្នេរទាំងឡាយដែលពួកគេបានបង្កើតឡើង ដោយបានដេញច្រានប្រជាជនកម្ពុជាឲ្យមកនៅក្នុងទឹកដីខាងក្នុង ។ គឺនៅក្នុងផ្នែកនៃទឹកដីកូសាំងស៊ិន បារាំងនេះផងដែរ ដែលប្រជាជនមានសភាពច្របូកច្របល់ ។ សង្កាត់ជនជាតិអណ្ណាមដែលស្ថិតនៅតាមច្នេរនៃព្រែកមួយបានទាមទារនូវផ្នែកនៃទឹកដីព្រៃរបស់ខ្លួនដែលពួកកុលសម្ព័ន្ធរបស់កម្ពុជានៅព័ទ្ធជុំវិញ ហើយពួកកុលសម្ព័ន្ធទាំងនេះក៏បានធ្វើការតវ៉ាម្តងម្កាលដែរនោះ ។

**ដូច្នេះលោកបានស្នើថា :**

**ក/–** ចាប់ពីព្រំដែន Gia - Hoa ទៅដល់ Cai - Cay ដោយគ្មានព្រែកជីកនោះផ្លូវថ្នល់ធំពី Baplan ( Bos - Pleang បុសភ្លៀង) ទៅស្ពានតាហាញ់ (Spien - Tahanh) (ស្ពានឈើឆ្លងព្រែក Cai - Cay) ត្រូវបានគេជ្រើសរើសធ្វើជាខ្សែកំណត់ព្រំដែន ។

**ខ/–** គេបានធ្វើដំណើរតាមដងព្រែក Cai-Cay រហូតដល់Ngaba (កំពង់តាសាង) ។ តាមយោបល់របស់លោកអធិការរូបនេះ គឺថា " ទឹកដីកូសាំងស៊ិន នឹងបាត់បង់ទឹកដី នៃឃុំ Long Phu នៅខាងលើស្ពាន–តាហាញ់ " (កំពង់បាត្រាស – បាក់ (Kompong-Batras-Bac) នៅក្នុងឃុំពាមមេត្រី) ប៉ុន្តែផ្ទុយទៅវិញ កូសាំងស៊ិន បានចំណេញនូវដី បរិព័ទ្ធភូមិ (enclave) នៃ Xverat នៅជិត Bing - Cu ស្រុក Nang - Hin និងស្រុកដទៃខ្លះទៀត នៅតាមបណ្តោយព្រែក Cai - Cay ។

**គ/–** បន្ទាប់មកទៀត គំនូសព្រំដែន នឹងបន្តគូសតាមជ្រលងដ៏ជ្រៅនៃ Cai-Bac រហូតដល់ Bengo (កំពង់មានជ័យ) ដែលនៅទីនោះគេឃើញមានភូមិតូចចុងក្រោយ របស់អណ្ណាម ។

ដូច្នេះ កូសាំងស៊ិន នឹងបាត់បង់ "ត្រើយខាងស្តាំនៃ Cai - Bac ដែលឃុំអណ្ណាមទាមទារចង់បានកាន់កាប់នូវព្រៃទាំងឡាយ" ។

**ឃ/–** ឆ្ពោះទៅទិសខាងជើង គេត្រូវតែជម្រុញរហូតដល់រួមបញ្ចូលនូវតំបន់ដែលមានពួក Moïs រស់នៅ : "ឆ្ពោះទៅទិសខាងជើងដែលយើងត្រូវតែស្ថិតនៅដោយមានទំនាក់ទំនងជាមួយប្រជាជន Moïs ដែលដៃទាំងពីរនៃស្ទឹង ព្រៃនគរ បានហូរ ដោយបញ្ឆៀងឆ្ពោះទៅទិសខាងត្បូង ហើយដែលមានផលវិបាកដោយមិនអាចកម្រិតព្រំដែនតាមលក្ខណៈភូមិសាស្ត្របាននោះ យើងត្រូវរើសយកព្រំដែនដោយការសន្មត ឧទាហរណ៍ខ្សែស្របដែលកាត់តាម Bengo និង ស្ពានចាម ជាស្ពានធម្មជាតិ ឆ្លងកាត់ ព្រែក R.Lamac ( Xamat នៅលើដែនទី) ជាដៃច្វេងនៃ Cai . Bac " ។ អធិការតៃ និញ បានទាយទុកជាមុនថា នៅទីនោះនឹងមានវិវាទកម្មគ្នាពីព្រោះថា ប្រហែលជាតំបន់មួយដែលមានតែប្រជាជនកម្ពុជារស់នៅ និងគ្មានប្រជាជនអណ្ណាមណាម្នាក់រស់នៅឡើយ : "ជាពិសេសវានឹងមានការទាស់ទែងគ្នានៅទីនោះ" ។

ប៉ុន្តែនៅក្នុងការទូទាត់នូវការលំបាកទាំងនេះ គេត្រូវតែយកជ័យជំនះលើកូសាំងស៊ិន ដែលបានចំណេញនូវទឹកដីដ៏ធំទូលាយ ដែលជាទឹកដីរបស់កម្ពុជា "ដូច្នេះយើងនឹងបញ្ចូលនូវសាសន៍ទាំងឡាយ នៃខេត្តកម្ពុជា នៅ Cho - Ba - Den ( Chong-Badèn) នូវអតីតអ្នកនៅក្នុងចំណុះជើង និងពួកកុលសម្ព័ន្ធតាមូន (Tamoun) នៅ Nga Vu និងនៅ Cheman ហើយជាពិសេសយើងនឹងស្ថិតនៅទាក់ទងជានិច្ចជាមួយពួកកុលសម្ព័ន្ធMoïs"។

**គ – ការវិភាគអំពីសេចក្តីស្នើទាំងនេះ**

គេត្រូវតែពិនិត្យ ដែលនៅក្នុងនោះ សេចក្តីស្នើទាំងនេះត្រូវបានធ្វើឡើង ។ ការបារម្ភដែលគ្របសង្កត់នោះ ហាក់ដូចជាបានផ្តល់អត្ថប្រយោជន៍ដល់កូសាំងស៊ិន នៅ

មុនអ្វីៗទាំងអស់ ។

អធិការនៅត្រាំងបាង ហេតុអ្វីបានជាលោក ស្នើកាត់ចេញពីប្រទេសកម្ពុជានូវទឹកដីទាំងអស់ ដែលបច្ចុប្បន្នកាន់កាប់ដោយស្រុកស្វាយទាប (ខេត្តស្វាយរៀង) ថ្វីបើលោកបានទទួលស្គាល់ហើយថា ទឹកដីនេះមានតែប្រជាជនកម្ពុជារស់នៅក៏ដោយនោះ ?

អធិការនៅ តៃ និញ លោកចង់បញ្ចូលទៅក្នុងកូសាំងស៊ីន នូវទឹកដីទាំងអស់ដែលមានភូមិអណ្ណាមតិចសោះ ហើយទោះបីជាទឹកដីនេះមិនមានប្រជាជនអណ្ណាមរស់នៅក៏ដោយចុះ គឺជាកម្មវត្ថុនៃក្តីប្រាថ្នាចង់បានរបស់ពួកអណ្ណាមដែរ ។

ក្តីកង្វល់ទី២ របស់អធិការនៅតៃនិញ គឺត្រូវពង្រីកទៅទិសខាងជើងថែមទៀតតាមដែលអាចធ្វើបាន ដើម្បីលើកព្រំដែនឲ្យទៅឆ្ងាយពីព្រៃនគរ និងដើម្បីពង្រឹងនូវសន្តិសុខរបស់ខ្លួន។

គាត់តម្រង់ទិសដៅរហូតដល់បញ្ចូលពួកកុលសម្ព័ន្ធ ស្ទៀង ដែលពួកគេបានផ្តល់នូវការគាំទ្រ និងការជួយដ៏ច្រើនសន្ធឹកដល់មេឧទ្ទាម ពោរកំបោ នៅក្នុងឆ្នាំ ១៨៦៦ ។

ព្រំដែនដែលបានស្នើ មិនមែនជាព្រំដែនដែលលោកទេសាភិបាលកូសាំងស៊ីន បានឲ្យយោបល់នោះឡើយ នោះគឺការកម្រិតព្រំដែន ដើម្បីជួយសម្រួលក្នុងការទារពន្ធដារ ។ វាបានតម្រង់ទិស នៅរកគោលបំណងមួយផ្សេងទៀត នោះគឺការពង្រីកឲ្យកាន់តែធំនូវទឹកដីកូសាំងស៊ីន និង ដើម្បីធានាឲ្យទឹកដីនេះមានសន្តិសុខជាអតិបរមា ។

នៅពេលដែលគេនិយាយអំពីការសម្រួល នៃបញ្ហានេះដែលនៅក្នុងនោះពួកអណ្ណាមបានធ្វើប្រតិបត្តិការ ដោយរំលោភ និងបានផ្សាយអំពីការទាមទារចង់បាននូវទឹកដីកម្ពុជានោះ គេបានដឹងនូវការលំបាកទាំងអស់ដែលនឹងត្រូវធ្លាក់មកលើប្រជាជនកម្ពុជា ការរៀបចំអធិការទាំងឡាយតែងតែត្រូវបានត្រៀមទុកមុនជាស្រេច ដើម្បីទទួលរ៉ាប់រងការទាមទាររបស់វៀតណាម ។ សូមនិយាយនៅទីនេះថែមទៀត អំពីយោបល់របស់អ្នកគ្រប់គ្រងម្នាក់នៅក្នុងសម័យអាណានិគម " ដោយបានទទួលការលើកទឹកចិត្ត ដោយប៉ុស្តិ៍តូចៗដែលឥតប្រយោជន៍នៅ Thai - Binh , Hung Nguyen (គឺជាប៉ុស្តិ៍ដែលកាន់កាប់ដោយពួកអណ្ណាម) នោះ ពួកអណ្ណាមដែលបានមកបោះទីតាំងនៅលើទឹកដីកម្ពុជា បានធ្វើឲ្យកើតឡើងនូវការលំបាកទាំងឡាយរវាងអ្នកមានមុខមាត់របស់ពួកគេ និងអាជ្ញាធរកម្ពុជា ។ បន្ទាប់មកបើសិនជាពួកគេមិនឈ្នះនោះ ពួកគេក៏



ស្រែកថា ពួកគេមានការឈឺចាប់ខ្លាំងណាស់ និងបានទាមទារឲ្យភ្ជាប់ទឹកដីរបស់ពួកគេទៅកូសាំងស៊ីន ។ ពួកគេបានដឹងថា បំណងប្រាថ្នាដែលបានសម្តែងចេញ ដោយពួកគេគឺដើម្បីគេចផុតពីការអាក់អន់ចិត្ត នៅក្រោមម្លប់នៃទង់ជាតិរបស់យើង តែបានបញ្ឆេចបញ្ឆៀរដល់យើង និងជាការឆបោក ដើម្បីព្យាយាមគេចចេញពីភាពយុត្តិធម៌មួយដែលពួកគេបានយល់ព្រមទាំងនៅលើទឹកដីកម្ពុជានោះ" ។

សេចក្តីស្នើទាំងឡាយរបស់អធិការនៅ តាន អាន, ត្រាំង បាង និងតៃ និញ ដែលគាំទ្រដោយនាយកក្រសួងមហាផ្ទៃ នៃទេសាភិបាលឥណ្ឌូចិន ត្រូវបានដាក់ជូនទៅលោកទេសាភិបាល ពិនិត្យហើយដែលលោកបានយល់ព្រមនោះ ។ ពេលនោះ គេបានស្នើទៅព្រះមហាក្សត្រនៃប្រទេសកម្ពុជា ដើម្បីចាត់តាំងតំណាងឲ្យចូលរួមនៅក្នុងគណៈកម្មការចម្រុះមួយ ដើម្បីកម្រិតព្រំដែន ។

## ផ្នែកទី III
## ដំណាក់កាលទីមួយនៃការខារបោះគោលដី

### ១ – ការងាររបស់គណៈកម្មការ

គណៈកម្មការចម្រុះដែលមានអធិការ បីនាក់ (៣១) និងបេសកជនទាំងឡាយរបស់ព្រះមហាក្សត្រ នៃប្រទេសកម្ពុជាបានចាប់ផ្តើមបំពេញការងាររបស់ខ្លួននៅដើមឆ្នាំ ១៨៧០ ។ ប៉ុន្តែភារកិច្ចនៃគណៈកម្មការនេះ គឺមិនសូវកំណត់អំពីគំនូសព្រំដែន ជាងការដាក់គោលព្រំដែន នៅតាមបណ្តោយព្រំដែន ដែលស្នើឡើង ដោយអធិការទាំង ៣នាក់ នេះទេ និងត្រូវបានយល់ព្រមដោយទេសាភិបាល គឺ : "នៅខាងជើង ព្រំដែនដែលបានយល់ព្រមនោះ គឺខ្សែស្របនៅចម្ងាយ ៦២ គ.ម ខាងជើងតៃ និញ (ដែនទីបានដាក់ ស្ពាន ចាម ដោយខុសនៅលើខ្សែស្របនេះ ស្ពាន នេះស្ថិតនៅចម្ងាយ ២៥ គ.ម ទៅទិសខាងត្បូងឆ្ងាយ)" (៣២) ។

*(៣១) / អធិការទទួលបន្ទុកកិច្ចការជនអន្តោប្រវេសន៍ នៅតៃនិញ លោក Benoist ត្រូវបានផ្លាស់ចេញ និងត្រូវបានដាក់ជំនួស ដោយលោកអធិការ Rheinart ។*

*(៣២) / របាយការណ៍របស់អធិការ : Rheinart Labussière , de Bastard ។*

គណៈកម្មការនេះបានធ្វើដំណើរតម្រង់ទៅទន្លេជ្រៅ (Tonlé - Chru) ជាភាសាខ្មែរ គឺទន្លេជ្រៅ ដៃខាងកើត នៃស្ទឹងព្រែកគរ ជាចំណុចខ្ពស់បំផុត នៃព្រំដែនដែលបានយល់ព្រមដោយទេសាភិបាល ។ គណៈកម្មការបានឡើងតាមទន្លេជ្រៅ រហូតដល់ខ្សែស្រប ដែលបានចង្អុលបង្ហាញ ហើយចេញពីនោះគណៈកម្មការបានរុលទៅទិសខាងលិច" ដោយចេញពីផ្លូវថ្នល់ដែលបានដើរ និងដោយដាំទូវបង្គោលបង្ហាញពីចន្លោះមួយទៅចន្លោះមួយ" (៣៣) ។

ថ្ងៃទីមួយ ការទទួលស្គាល់ព្រំដែន ត្រូវបានធ្វើឡើង ដោយពួកអធិការទាំង៣នាក់តែប៉ុណ្ណោះ ចំណែកខាងភាគីកម្ពុជាវិញ ពួកគេបានវង្វេងផ្លូវ គឺ "ខាងកម្ពុជាបានធ្វើដំណើររុលទៅមុខដោយឃឹតៗដោយពុំមានអ្នកនាំផ្លូវនោះ ពួកយើងក៏បានវង្វេងផ្លូវទៅ" ។ ពួកអធិការទាំង៣នាក់ បានទៅដល់ចំណុចដែលពួកគេបានស្វែងរក ប៉ុន្តែពួកគេត្រូវរង់ចាំខាងភាគីកម្ពុជារហូតដល់ ២៤ម៉ោង ។

លុះដល់ថ្ងៃទី២ ពួកគេមានអ្នកនាំផ្លូវ គឺអ្នកនាំផ្លូវជាជនជាតិកម្ពុជា ។ ប៉ុន្តែពួកគេជាអ្នកនាំផ្លូវទាំងនេះ ប្រហែលជានៅក្នុងក្តីកង្វល់ចង់សន្សំសំចៃទឹកដីជាតិរបស់ខ្លួន ពួកគេបាននាំទៅរកផ្លូវមួយដែលស្ថិតនៅចម្ងាយពី ៦ ទៅ ៨ គ.ម នៅខាងត្បូងខ្សែស្រប ដែលបានកំណត់ : "អ្នកនាំផ្លូវរបស់យើងបានចាប់ផ្តើមឲ្យយើងចុះដើរ តាមផ្លូវចម្ងាយពី ៦ ទៅ ៨ គ.ម នៅពីក្រោយខ្សែស្រប ដែលត្រូវធ្វើតាម " (៣៤) ។ ជាការប៉ុនប៉ងដោយឥតប្រយោជន៍ ពួកអធិការដែលមានផែនទី នៅក្នុងដៃបានយកចេញមកពិនិត្យ ហើយពួកអ្នកនាំផ្លូវបាន "ប្រកាសនៅពេលនោះថា យើងត្រូវរកផ្លូវថ្នល់មួយនៅពេលខាងមុខនេះ ដែលអាចនាំយើងទៅរកទិសដៅទីមួយរបស់យើង" ។

តំបន់ដែលបានធ្វើដំណើរទៅ គឺក្រខ្លាំងណាស់ "មានជនជាតិភាគតិចស្បៀងរស់នៅ (៣៥) និងប្រជាជនកម្ពុជា ដែលជាងពាក់កណ្តាលជាមនុស្សព្រៃរស់នៅ" ។ គឺជាទឹកដីមួយដែលបានយកចេញពីប្រទេសកម្ពុជា គឺពុំមានប្រជាជនអណ្ណាមម្នាក់ឡើយ ។

(៣៣) / របាយការណ៍ដែលបាននិយាយពីមុនរួចហើយ ។

(៣៤) / ដូចគ្នា ។

(៣៥) / កុលសម្ព័ន្ធព្រៃ នៅក្រោមចំណុះអាជ្ញាធរ នៃព្រះមហាក្សត្រកម្ពុជា ។



នៅទីបញ្ចប់ គេបានទៅដល់និគម បែន ជ្រុំម (Ben Chrum) (៣៦) ដែលគ្រប់គ្រងដោយមន្ត្រីកម្ពុជាម្នាក់ដែលមានគោរមងារថា ស្នង (Snang) ភូឈួយ ចៅហ្វាយខេត្តកម្ពុជានៅស៊ីធរ និងដែលបានទទួលការតែងតាំងជាមេ (Mé) "ឆ្ងាយទៅទៀត យើងបានទៅដល់ទឹកដីរបស់សេណុង (Senong) (Snang) (៣៧) មន្ត្រីឋានៈទាបម្នាក់ដែលតែងតាំងដោយ ភូ (Phu) (៣៨) នៅស៊ីធរ" (៣៩) ។

ដោយសារនិគមកម្ពុជាទាំងនេះមានធនធាននោះ ពួកអធិការបារាំងក៏បានបញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន ។ ស្នងមេយល់ថា មានគ្រោះថ្នាក់លោកក៏បានព្យាយាមខិតខំគ្រប់បែបយ៉ាង ដើម្បីសង្គ្រោះទឹកដីដែលលោកទទួលបន្ទុក "ស្នងមេភ័យខ្លាចថាប្រទេសរបស់ខ្លួននឹងត្រូវធ្លាក់ទៅនៅក្រោមការត្រួតត្រារបស់យើងនោះ គាត់ក៏បានផ្តល់អនុសាសន៍ដល់អ្នកនាំផ្លូវឲ្យយើងដើរពទ្ធ វាលតាមទិសខាងត្បូងដោយទុកវាលនេះឲ្យប្រជាជនកម្ពុជា" (៤០) ។

ប៉ុន្តែមធ្យោបាយដែលប្រើដោយស្នងមេ គឺឥតបានការពីព្រោះថា ពួកអធិការបារាំងបានបដិសេធបោះបង់ចោលនូវបំណងរបស់ពួកគេ "ដើម្បីកាន់កាប់នូវភូមិខ្លះនៅតាមព្រំដែនដែលមានប្រយោជន៍យ៉ាងខ្លាំងសម្រាប់យើង និងដើម្បីភាពសុខសាន្តរបស់ប្រទេស" ។ ជាដំបូងពួកគេចង់សម្រុះសម្រួលស្នងមេឲ្យធ្វើតាមគំនិតរបស់ពួក គេដោយវិធីទន់ភ្លន់ ប៉ុន្តែពួកគេមិនបានសម្រេចតាមបំណងរបស់ពួកគេឡើយ : "យើងចង់ឲ្យមានការព្រមព្រៀងគ្នាជាមួយស្នងមេ និងទាមទារកាន់កាប់កម្មសិទ្ធិ បានជ្រុំ (Ban Chrum) ប៉ុន្តែគាត់នៅខាងក្រោយឆ្ងាយណាស់ ជាមួយនឹងបេសកជនរបស់ព្រះមហាក្សត្រ កាត់បានអញ្ជើញពួកគេឲ្យឈប់នៅកន្លែងរបស់គាត់" ។

ពួកអធិការ បានសម្រេចថាយក បានជ្រុំ ឲ្យទាល់តែបាន "យើងបានសម្រេចដាក់ព្រំដែនទៅខាងជើង បានជ្រុំ " ពេលនោះស្នងមេ បានបញ្ចេញប្រតិកម្មដោយខ្លាំងក្លា

(៣៦) / នៅក្នុងរបាយការណ៍ ឈ្មោះនេះសរសេរថា បានជ្រុំម (Ban-Chrum) ។ ការខុសគ្នានេះគឺបណ្តាលមកពីអធិការបារាំងបានចម្លងខុស ។

(៣៧) / ងារដែលគេហៅនៅក្នុងអតីតរដ្ឋការកម្ពុជា គឺភូឈួយខេត្ត ។

(៣៨) / ឈ្មោះអណ្ណាម ដែលមានន័យថា ជាប្រធាននៃមណ្ឌលរដ្ឋបាលមួយ ។

(៣៩) / របាយការណ៍ដែលបានរៀបរាប់ពីមុន ។

(៤០) / របាយការណ៍ដែលបានរៀបរាប់ពីមុន ។

ប្រឆាំងនឹងការរំលោភនេះ "សេណុងមេ ដែលក្តៅក្រហាយ ដោយឃើញគេដកហូតនូវអ្វីដែលគាត់ចាត់ទុកថា ជាទ្រព្យសម្បត្តិរបស់ខ្លួននោះ មុនដំបូងបានបដិសេធមិនព្រមជូនយើងទេ និងថែមទាំងមិនព្រមផ្តល់មនុស្សដែលយើងត្រូវការនោះឡើយ ។ ពួកអធិការត្រូវប្រើការគម្រាម ដើម្បីឲ្យគាត់ផ្តល់ឲ្យ "យើងបានគម្រាម ដើម្បីឲ្យគេចាប់ឃុំគាត់ បើសិនជាគាត់នៅតែតស៊ូយូរទៅទៀតនោះ នៅទីបញ្ចប់គាត់ក៏បានចុះចាញ់ ប៉ុន្តែនៅព្យាយាមបំភាន់យើងទៀត ដោយបានបែងចែកពីរផ្លូវដើរ ដើម្បីដើរព័ទ្ធភូមិទាំងឡាយ និងទុកឲ្យមើលលែង ឃើញតែម្តង" ។

នៅទីបញ្ចប់ គណៈកម្មការ បានទៅដល់ និគមស្រុកត្រាញ់ (Srok Tranh) ជាមណ្ឌលរដ្ឋបាលរបស់កម្ពុជាមួយទៀត ។ និគមស្រុកនេះត្រូវបានបញ្ចូលទៅឲ្យកូសាំងស៊ីន ព្រោះថា "វាមានភាពសំខាន់យ៉ាងច្រើន ដោយមាននៅតាមព្រំដែន នូវភូមិដែលបន្តគ្នា និងរួបរួមគ្នានេះ" ។

ទីបញ្ចប់ គេបានទៅដល់ Cai Bach (Cai Bat នៅលើដែនទី) ។ ចាប់តាំងពីនោះមកវត្តមាននៃប្រជាជនកម្ពុជា គឺមិនមានប្រយោជន៍អ្វីឡើយ ពីព្រោះថា ព្រំដែនដែលត្រូវធ្វើតទៅទៀត ដូចដែលត្រូវបានកម្រិត ជាឯកតោភាគី ដោយគណៈប្រតិភូបារាំងនោះ ខ្សែផ្លូវទឹកទាំងពីរ (Cai - Back និង Cai-Cay) ដែលពួកអធិការទទួលបន្ទុកលើកទៅដាក់រហូតដល់តាសាង (Tasang) គេបានសម្រេចថា ផ្លូវទឹកទាំងពីរនេះ គឺជារបស់កូសាំងស៊ីន ។

ចាប់ពីតាសាងទៅ ពួកអធិការ ដោយយល់ថា កូសាំងស៊ីន "ត្រូវបានប្រគល់ឲ្យនូវទឹកដី រវាង Cai - Bach នឹង Cai - Cay នោះ បានសម្រេចថា ព្រំដែនដែលបត់តាមបន្ទាត់ត្រង់ដោយសំដៅត្រង់ពីតាសាង ទៅប៉ុស្តិ៍ Hung - Nguyen នោះ ដូច្នេះបានរាប់បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន នូវទឹកដីកម្ពុជា ដែលគេឲ្យឈ្មោះថា "ចំពុះទា" ។

ចាប់ពីចំណុចនេះទៅ "ព្រំដែនបានទៅតាម Cai - Cayរហូតដល់និគមCanloបន្ទាប់មក Rach - Hiep - An រហូតទៅដល់ Rach - Tra - Du " ។ ប៉ុន្តែគេបានសម្រេចថាព្រែកជីកទាំងពីរនេះ ដូចព្រែកជីកពីរពីមុនដែរ គឺជារបស់កូសាំងស៊ីន ។ "ចំពោះព្រែកជីកទាំងពីរនេះ យើងជឿថា ត្រូវតែចែងនៅក្នុង ១- សំខាន់ដូចគ្នា នឹង Cai-Cay និង



Cai-Bach ដែរគឺថា ផ្លូវទឹកទាំងនេះ គឺជារបស់បារាំង ហើយពុំមានទីស្នាក់ការគយណាមួយ ឬក៏ឡូតិ៍នេសាទណាមួយអាចត្រូវបានបង្កើតឡើង ដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាលបារាំងនោះទេ" ។

## ២ – ការពិនិត្យព្រំដែនដែលបានបង្កើតឡើង

### ក/– ការបាត់បង់ខាងកម្ពុជា

នៅក្នុងសេចក្តីស្នើដែលធ្វើឡើងដោយលោកអធិការនៅតៃនិញ គឺលោក Benoist ព្រំដែនខាងជើងនៃកូសាំងស៊ីន បានដើរតាមខ្សែស្របដោយកាត់តាម Bengo (ឈ្មោះកម្ពុជា គឺកំពង់មានជ័យ) ។ ព្រំដែនដែលបានស្នើឡើងរួចហើយ តាមយោបល់ផ្ទាល់របស់អធិការ Benoist បានព័ទ្ធជុំវិញជនជាតិភាគតិច Moïs នៃខេត្តកម្ពុជានៅ Chong-Ba - Den និងពួកកុលសម្ព័ន្ធ Tamoun នៅ Nga - Vu និង Chemna ។ ប៉ុន្តែព្រំដែនដែលបានសម្រេចធ្វើរួចហើយនៅលើដី បានឆ្លងកាត់ទៅទិសខាងជើងកាន់តែខ្លាំងថែមទៀតចេញពីខ្សែស្របនេះ ។ ដូច្នេះការបាត់បង់ខាងកម្ពុជាមានលក្ខណៈសំខាន់ណាស់ ។

តើការបាត់បង់ខាងទឹកដីរបស់កម្ពុជាមានអ្វីខ្លះ ? ការបាត់បង់នេះមានដូចតទៅ :

– នៅទិសឦសាន តំបន់ដ៏សំខាន់មួយដែលរាប់បញ្ចូលរវាងបន្ទាយ តៃ និញ និងស្ទឹងព្រៃនគរ ហើយដែលមាន "តែភូមិរស់នៅដោយជនជាតិស្បៀង និងប្រជាជនកម្ពុជា" ។

– នៅទិសខាងជើង ដីដ៏ធំទូលាយមួយ ដែលមានផ្លូវទឹកខាងលើ នៃទន្លេវ៉ៃគោ ខាងកើតនិងដីដែលស្ថិតនៅតាមមាត់ទន្លេទាំងពីរនេះ ។

– នៅទិសខាងលិច តំបន់ទាំងអស់ដែលបង្កើតបានជា "ចំពុះទា" ។

### ១/– មូលហេតុនៃការបាត់បង់នេះ

យើងបានបញ្ជាក់រួចហើយអំពីក្តីកង្វល់របស់អាជ្ញាធរ កូសាំងស៊ីន ដែលធ្វើជាអធិបតីក្នុងការកម្រិតនូវព្រំដែននេះ (Cf. Supra) នោះគឺជាផលប្រយោជន៍របស់អាណានិគមដែលត្រូវមាន "ភូមិមួយចំនួនដែលចាប់អារម្មណ៍ធ្វើឲ្យមានសភាពស្ងប់ស្ងាត់របស់ប្រទេស ហើយដែលមានផលប្រយោជន៍យ៉ាងខ្លាំងសម្រាប់ប៉ូលិសយើង គឺថា ដើម្បីជួយសម្រួលដំណើរទស្សនាការនានាដោយប្រើប្រាស់ធ្វើជាស្នូល" និងដើម្បីស្ថិតនៅ

ក្នុងទំនាក់ទំនងជាមួយពួកកុលសម្ព័ន្ធព្រៃ គឺពួកស្ទៀង និងម៉ុយ (Moïs) ។

ប៉ុន្តែនៅក្នុងអំឡុងពេលធ្វើប្រតិបត្តិការនេះ ពួកស្នងការបារាំងបានធ្វើការពិនិត្យពិច័យនូវកត្តាមួយទៀត គឺផលប្រយោជន៍ខាងសេដ្ឋកិច្ច ។ ពួកគេមិនអាចតស៊ូចំពោះបំណងនៃការដាក់បញ្ចូលជាឧបសម្ព័ន្ធទៅឲ្យកូសាំងស៊ីននូវទឹកដីមួយដែលមានភោគទ្រព្យ និងមានជីវជាតិដូច្នេះបានទេ គឺ "នៅថ្ងៃមួយនៅទន្លេចាម នៅទិសខាងលិចប្រទេសបេះតែរាបទៅ។ ចំនួនអូរសំខាន់ៗទាំងឡាយបានថយចុះ ព្រៃមានលក្ខណៈល្អបំផុត គេបានឃើញដើមឈើធំៗ ប៉ុន្តែមិនសូវមានសារសំខាន់គួរឲ្យចាប់អារម្មណ៍ទេ។ ការស្ថិតនៅឆ្ងាយពីទន្លេដែលអាចបណ្តែតក្បូនបាននោះ បានបណ្តាលឲ្យការធ្វើអាជីវកម្មជួបការលំបាកយ៉ាងខ្លាំង ។ ខាងនេះបន្តិចខាងនោះបន្តិច គេបានជួបប្រទះនូវដីក្រហមដូចគ្នា [៤១] ដូចនៅបាវៀ ភាពមានជីវជាតិ នៃដី គឺមិនគួរឲ្យជឿបានឡើយ នៅបែនជ្រុំ(Ben-Chrum) និងស្រុកត្រាញ់ ដីមានលក្ខណៈទាប" ។ គេបានភ្ជាប់តំបន់នេះទៅកូសាំងស៊ីន ថ្វីបើតំបន់នេះជារបស់កម្ពុជាហើយ ដែលមានតែប្រជាជនកម្ពុជារស់នៅក៏ដោយ ។ (ប្រទេសដែលមានប្រជាជនតិច និងមានប្រជាជនកម្ពុជាខ្លះៗបានរស់នៅនិងសុទ្ធតែជាកសិករ") និងគ្រប់គ្រងដោយមន្ត្រីទាំងឡាយដែលបញ្ជូនទៅពីភ្នំពេញមិនបានស្គាល់ប្រទេសនិងពឹងពាក់ព័ត៌មានផ្សេងៗ ចំពោះមន្ត្រីរបស់ប្រទេសខ្លួនផ្ទាល់") ។ ដូច្នេះវាមិនមែនជាការកំណត់ព្រំដែន ប៉ុន្តែគឺជាការកាត់ទឹកដីទោះបីជាមានការតវ៉ាដ៏ខ្លាំងក្លា ពីអាជ្ញាធរកម្ពុជាក៏ដោយ ការបាត់ទឹកដី ដែលអាចសម្រេចបានតែដោយសារការប្រើប្រាស់នូវការគំរាមចាប់ឃុំខ្លួនតែប៉ុណ្ណោះ ។

### ៣ – តួនាទីរបស់ស្នងការកម្ពុជា

#### ក/– ការលុបចោលរបស់ពួកគេ

នៅក្នុងអំឡុងបំពេញការងារកម្រិតព្រំដែន រវាងខេត្តពោធិសាត់ បាត់ដំបង ដែលបានអនុវត្តធ្វើឡើង នៅដើមឆ្នាំ ១៨៦៨ ដោយអនុវត្តទៅតាមសន្ធិសញ្ញា បារាំង–សៀម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៦៧ លោកអនុសេនីយ៍ឯក Laurent ដែលបានចូលរួមនៅខាងផ្នែកគណៈប្រតិភូកម្ពុជាបានពិនិត្យឃើញថា គណៈប្រតិភូកម្ពុជា "មិនដឹង

*(៤១) / ដីក្រហម កើតចេញពីកំរែលភ្នំភ្លើង មានជីវជាតិបំផុត និងត្រូវបំផុតចំពោះដំណាំកៅស៊ូ ។*



នូវបញ្ហាទាំងអស់ដែលគេត្រូវធ្វើនោះទេ និងចំពោះការស្គាល់ព្រំដែន ខ្ញុំមិនដឹងថា តើពួកគេអាចដឹងដែរឬទេនោះ" ។ នៅចំពោះមុខអាកប្បកិរិយានេះ លោកអនុសេនីយ៍ឯក Laurent ត្រូវ"ដើរតួធ្វើជាអាជ្ញាកណ្តាល"ដើម្បីធ្វើជា"អ្នកជួយការពារនិងជាទីប្រឹក្សា"។

អាកប្បកិរិយាដូចគ្នានេះ បានប្រតិបត្តិតាមម្តងទៀត នៅឆ្នាំ ១៨៧០ នៅខាងរាជគណៈប្រតិភូ ដែលបានចាត់តាំងឡើង ដើម្បីចូលរួមនៅក្នុងគណៈកម្មការបោះគោលដីរវាងកូសាំងស៊ីន និងកម្ពុជា ។ ពួកអធិការទាំង៣នាក់ បានរាយការណ៍ថា "ដោយពួក គេ (ស្នងការកម្ពុជា) ហាក់ដូចជាមិនយល់នូវអ្វីដែលពួកគេត្រូវធ្វើនោះ យើងត្រូវពន្យល់ពួកគេ អំពីគោលបំណង នៃបេសកកម្មរបស់ពួកគេ" ។

ភាពល្ងង់ខ្លៅរបស់គណៈប្រតិភូកម្ពុជានេះ បណ្តាលឲ្យមានផលវិបាកដ៏អាក្រក់ ។ នៅឆ្នាំ ១៨៧០ សភាពការណ៍មិនដូចគ្នា ទាល់តែសោះនឹងឆ្នាំ ១៨៦៧ ។ ការពិតនៅក្នុងពេលកម្រិតព្រំដែនជាមួយសៀម គណៈប្រតិភូបារាំង បានតាំងខ្លួនធ្វើជា "អ្នកការពារ" ហើយដូច្នេះអាចជៀសវាងបាននូវផលវិបាកដែលធ្វើឲ្យខូចដល់អត្ថប្រយោជន៍នៃប្រទេសកម្ពុជាដែលបារាំងមានបេសកកម្ម ដើម្បីការពារនូវផលប្រយោជន៍ទាំងនេះ ។ ប៉ុន្តែនៅក្នុងឆ្នាំ ១៨៧០ ពួកអធិការបារាំង មិនបានដើរតួដូចជាលោកអនុសេនីយ៍ឯក Laurent ទៀតទេ ។ ពួកគេមិនបានកាន់ជើងប្រទេសកម្ពុជាទេ ប៉ុន្តែផ្ទុយទៅវិញពួកគេបានការពារផលប្រយោជន៍របស់កូសាំងស៊ីន ដែលជាខេត្តរបស់បារាំង នៅចំពោះមុខប្រទេសកម្ពុជាដែលជាប្រទេសស្ថិតនៅក្រោមការការពាររបស់ពួកគេនោះ ។ វាជាអំពើមនុស្សជាតិបំផុត និងធម្មតាបំផុត ដែលពួកអធិការបារាំង បានការពារបុព្វហេតុរបស់មាតុភូមិរបស់ពួកគេនោះ ។ ប៉ុន្តែវាអភ័ព្វណាស់ដែលប្រទេសកម្ពុជា ត្រូវបានតំណាងដោយអ្នកដែលគ្មានសមត្ថភាព ដែលលើកនេះពួកគេត្រូវពិភាក្សាជាមួយអ្នកតំណាងខាងបារាំង ដែលមានសមត្ថភាព បើពុំនោះទេ គឺអសមត្ថភាពជាងពួកអ្នកដែលបានការពារកាលពីពីរឆ្នាំមុននេះទៅទៀត ។ ដូច្នេះគេអាចយល់អំពីតួនាទីដ៏តិចតួចដែលពួកគេបានអនុវត្តនៅក្នុងគណៈកម្មការនេះ ។

#### ខ/– ការនិយាយដោះសាររបស់ពួកគេ

ប៉ុន្តែថាតើនេះគឺជាកំហុសមួយរបស់ភាគីកម្ពុជាឬ? យើងមិន(បានគិត)ដូច្នេះទេ។

ពីព្រោះគេមានអារម្មណ៍អំពីភាពទន់ខ្សោយរបស់គេ អំពីអសមត្ថភាពរបស់គេ ដើម្បីការពារប្រឆាំងនឹងអ្នកជិតខាងរបស់ខ្លួនដែលខ្លួនបានទទួលយកអាណាព្យាបាលបារាំង ។ អាណាព្យាបាលនេះបានរួមបញ្ចូលនូវអំណាចឲ្យអ្នកការពារនូវករណីយកិច្ច ដើម្បីការពារអ្នកនៅក្រោមការការពាររបស់ខ្លួន ។ នេះគឺជាហេតុផលរបស់ស្ថាប័ននេះផងដែរ ។ ចេញពីគំនិតនេះវាហាក់ដូចជាមិនអាចទទួលយកបានទេ ដែលអ្នកការពារអាចឆ្លៀតឱកាស នៃភាពល្ងង់ខ្លៅនេះ ឬក៏ភាពទន់ខ្សោយនេះ ដើម្បីប្រព្រឹត្តនូវអំពើទាំងឡាយដែលនាំឲ្យខូចប្រយោជន៍ដល់ប្រទេសដែលស្ថិតនៅក្រោមការឧបត្ថមគាំពាររបស់ខ្លួន។

កាតព្វកិច្ចនេះ គឺគ្មានអ្វីក្រៅពីបែបបទនៃសីលធម៌នោះទេ គឺវាប្រកបដោយ គតិយុត្ត ។ ចំពោះការងារបោះគោលដីទាំងនេះ វាជាការគួរឲ្យសង្ស័យខ្លាំងណាស់ ដែលពួកស្នងការបារាំងបានអនុញ្ញាតឲ្យស្នងការកម្ពុជា ដែលជាអ្នកនៅក្រោមការការពាររបស់ពួកគេបញ្ចេញនូវការទាមទារណាមួយក៏ដោយ ។ តួនាទីរបស់ស្នងការកម្ពុជាទាំងនេះ ហាក់ដូចជាបានទប់កុំឲ្យផ្ដល់នូវអ្នកនាំផ្លូវ និងឲ្យបង្ក្រាបនូវការទាមទារទាំងឡាយរបស់ពួកមន្ត្រីក្នុងស្រុក និងអ្នកស្រុកកម្ពុជា ដើម្បីអនុញ្ញាតឲ្យគណៈកម្មការដាំបង្គោល ដី គឺ"ពួកគេត្រូវជូនយើង ដើម្បីដោះស្រាយជាមួយយើងនូវបញ្ហាលំបាកទាំងអស់ ដែលនឹងអាចកើតមាន" [៤២] ។ ដូច្នេះផ្ទុយពីការធ្វើការ ដើម្បីការពារផលប្រយោជន៍របស់ប្រទេសខ្លួនពួកគេ ត្រូវបង្ក្រួញនូវមុខងាររបស់ពួកគេ ដោយសុខចិត្តនៅស្ងៀមមិននិយាយអ្វីចំពោះការទាមទារស្រចច្បាប់របស់ជនរួមជាតិរបស់ខ្លួន ។ ហេតុដូច្នេះហើយ បានជាគេបង្ខំឲ្យពួកគេប្រព្រឹត្តទៅលើស្នងមេ គឺ"ដូច... ព្រះរាជបេសកជន មិនអាចមានមូលហេតុនោះយើង (ស្នងមេ) បានគំរាម ដើម្បីឲ្យគេចាប់ខ្លួនលោក..." ។

ផលប្រយោជន៍ដ៏តិចតួច ដែលប្រតិភូកម្ពុជា ត្រូវទទួលបានចំពោះយុទ្ធនាការនេះ តើពិតជាមានដើមកំណើត ពីភាពល្ងង់ខ្លៅនេះឬ ? និក្ខេបបទនេះ វាមិនមែនពិតប្រាកដណាស់នោះទេ។ បញ្ហាមួយទៀត គឺអាចទៅរួចហើយ យើងឈរនៅលើមូលដ្ឋាននៃរបាយការណ៍របស់លោក អធិការ Rheinart [៤៣] ដើម្បីឲ្យគេជឿថា ជាការពិតបាន ។

(៤២) / របាយការណ៍របស់អធិការទាំងពីរនាក់ ដែលបានរៀបរាប់មកហើយ ។

(៤៣) / លិខិតរបស់លោកអធិការ Rheinart នៅកែ និញ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៨៧២ ផ្ញើទៅជូននាយកនៃក្រសួងមហាផ្ទៃ ។



ការលាក់លៀមនេះ ចេញមកពីសភាពការណ៍របស់ប្រទេសដែលស្ថិតនៅក្រោមការការពារ ដែលមានដៃគូជាអ្នកការពាររបស់ពួកគេនោះឯង ។ មនោសញ្ចេតនាដែលគ្មានអានុភាពនេះបានជំរុញឲ្យពួកគេលែងយកចិត្តទុកដាក់ក្នុងការងារនេះស្ទើរតែទាំងស្រុង គឺ"ដោយមិនទទួលបាននូវសេចក្ដី ពេញចិត្តនោះ ពួកគេ (មន្ត្រីកម្ពុជា) នឹងស្ថិតនៅដូចជាអ្នកមើលធម្មតាតែប៉ុណ្ណោះ តួនាទីដែលមិនសូវមានប្រយោជន៍" [៤៤] ។ ព្រោះហេតុនោះហើយបានជានៅថ្ងៃដំបូងពួកគេត្រូវស្ថិតនៅឆ្ងាយពីពួកអធិការបារាំង ហើយដែលពួកគេបានទៅជួបវិញ នៅក្នុងរយៈពេល២៤ម៉ោងក្រោយមក ។ នៅបាង-ជ្រុម (Bang Chrum) ពួកគេបានឈប់នៅកន្លែងស្នងមេទុកឲ្យពួកស្នងការបារាំងទៅតែពួកគេទៅ ។ ដូចគ្នានេះដែរ ចំពោះព្រំដែនដែលនៅសល់ពួកគេផ្លាស់ប្ដូរកន្លែងដោយឡែក "យើងបានហៅមកវិញនូវបេសកជនរបស់ព្រះមហាក្សត្រ ដែលពួកគេត្រូវតែជួបយើងជាប់ជាប្រចាំ" ។ នៅ Cai-Bach ពួកគេត្រូវបានឲ្យត្រឡប់ទៅវិញបានន័យថា "វត្តមានរបស់កម្ពុជាទៅដល់ Cai - Cay ខាងលើបានក្លាយទៅជាឥតប្រយោជន៍នៅលើព្រំដែនដែលត្រូវដើរតាមផ្លូវទឹកទាំងពីរ ដោយពួកគេបានធ្វើដំណើរតាមផ្លូវដី ក្នុងពេលដែលពួកយើងគូរផែនទី នៃព្រែកដីកទាំងពីរ " ។

## ៤ – តវិយាបថរបស់ព្រះមហាក្សត្រ

### ក/– ការតវ៉ា

ព្រះមហាក្សត្រ ត្រូវបានផ្ដល់ការប្រកាសភាពអាសន្នស្ដីពីការកាត់ទឹកដីនៅខាង តែនិញ ដោយស្នងមេ ដែលបានផ្ញើថ្វាយព្រះអង្គនូវពាក្យបណ្ដឹងមួយច្បាប់ [៤៥] ។ ព្រះអង្គមានការរំជួលព្រះរាជហឫទ័យពន់ពេក ។ហើយការរំជួលព្រះរាជហឫទ័យរបស់ព្រះអង្គកាន់តែខ្លាំងថែមទៀតនោះ គឺនៅពេលដែលរដ្ឋាភិបាលកូសាំងស៊ីន បានបង្ហាញដល់ព្រះអង្គនូវផែនទីមួយដែលមានរាប់បញ្ចូលនៅក្នុងផែនទីនេះ នូវបរិព័ទ្ធភូមិ (enclave) របស់កម្ពុជាដ៏វែងដែលកាន់កាប់ ដោយប្រទេសដែលមាននៅចន្លោះទន្លេ

(៤៤) / លិខិតរបស់លោកអធិការ Rheinart នៅកែ និញ ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៨៧២ ផ្ញើទៅជូននាយកនៃក្រសួងមហាផ្ទៃ ។

(៤៥) / របាយការណ៍របស់អធិការទាំងពីរ ដែលបាននិយាយពីមុន ។

វ៉ៃគោទាំងពីរ" ។ ការពិតគំនូសព្រំដែនដែលភ្ជាប់ តាសាង (Ta Sang) ចំណុចមួយដែលស្ថិតនៅលើ Cai - Cay [៤៦] នៅ Hung - Nguyen ប៉ុន្តែដែលស្ថិតនៅទិសប្រសព្វមុខ នៃ Cai-Cai [៤៦] ជាមួយវ៉ៃគោខាងលិច ដោយបានដកចេញពីប្រទេសកម្ពុជានូវខេត្ត ធំៗពីរគឺ "យើងបានដកចេញពីព្រះមហាក្សត្រនូវខេត្តរំដួល និងខេត្តស្វាយទាប ព្រះអង្គបានសម្គាល់ឃើញថា ការងារនេះគឺចប់ហើយ ហើយព្រះអង្គក៏បានតវ៉ា" [៤៧] ។ ដូច្នេះព្រះមហាក្សត្រ ក៏បានបញ្ជូនពួកមន្ត្រីទៅកាន់ព្រៃនគរ ដើម្បីដាក់បង្ហាញនូវការតវ៉ារបស់ព្រះអង្គ ។ ការតវ៉ានេះមិនគ្រាន់តែនិយាយអំពីភូមិបរិព័ទ្ធ ដែលមាននៅចន្លោះទន្លេវ៉ៃគោប៉ុណ្ណោះទេ ប៉ុន្តែក៏នៅមណ្ឌល តៃ និញ ទាំងមូលផងដែរ [៤៨] ។ ទឹកដីនេះ គឺជាការសំអាងផ្ទាល់របស់លោកអធិការ Rheinart ចំពោះកម្ពុជានៅមុនពេលដែលប្រតិបត្តិការ បោះគោលដី ត្រូវបានប្រព្រឹត្តធ្វើឡើង : "គេមិនត្រូវភ្លេចទេថា ប្រទេសនេះ គឺជា ប្រទេសខ្មែរ រហូតដល់បៀនហ្វា (Bien hoa) ។ បើសិនជាពួកមន្ត្រីបានធ្វើតាមការងារនោះ ពួកគេនឹងអាចធ្វើបានតែបញ្ហាមួយប៉ុណ្ណោះ នោះគឺការតវ៉ាកាន់កាប់ទន្លេវ៉ៃគោ និងបន្ទាប់មកទៀត គឺស្ទឹងព្រៃនគរ" [៤៩] ។

### ១/– លទ្ធផលនៃការតវ៉ារបស់ព្រះអង្គ

តើលទ្ធផលនៃព្រះរាជតម្រិះតវ៉ា បានអ្វីខ្លះ ? គឺបានទទួលនូវការពេញចិត្តដោយផ្នែក ។ រដ្ឋាភិបាលកូសាំងស៊ីន បានយល់ព្រមកែប្រែគំនូសព្រំដែនពីតាសាង ទៅ Hung - Nguyen "ព្រំដែនទៅទិសខាងលិច នឹងត្រូវបានកែប្រែ : ការងារត្រូវបានទុកជា មោឃៈ បង្គោលដីត្រូវបានដកយកចេញ" [៥០] ប៉ុន្តែគេបានរក្សាទុកនូវបង្គោលដែលមាននៅចន្លោះទន្លេជ្រៅ និងតាសាង ។

### ៥ – សេចក្តីសម្រេចចុះថ្ងៃទី៩ ខែកក្កដា ១៨៧០ (ឧបសម្ព័ន្ធ៥) (ទំព័រ ២៣៤)

ដើម្បីអាចរក្សាទុកការបោះគោលដី ដែលបានធ្វើឡើង នៅផ្នែកខាងជើងនោះ នាយកនៃក្រសួងមហាផ្ទៃនៃរដ្ឋាភិបាលកូសាំងស៊ីន លោក Vial និងអធិការ Rheinart

*(៤៦) / ផ្លូវទឹកពីរខុសគ្នា មួយគឺជាដៃទន្លេ វ៉ៃគោ ខាងកើត មួយទៀតគឺដៃទន្លេវ៉ៃគោ ខាងលិច ។*

*(៤៧) / លិខិតរបស់លោកអធិការ Rheinart ចុះថ្ងៃទី២៣ មីនា ១៨៧២ ដែលបាននិយាយរួចហើយ ។*

*(៤៨) / ដូចគ្នា ។*

*(៤៩) / លិខិតរបស់លោកអធិការ Rheinart ចុះថ្ងៃទី២៣ មីនា ១៨៧២ ដែលបាននិយាយមកហើយ ។*

*(៥០) / ដូចគ្នា ។*



បានយកព្រមគ្នានៅក្នុងនាមនៃទេសាភិបាលកូសាំងស៊ីន នូវសេចក្តីសម្រេចមួយ គឺសេចក្តីសម្រេចចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ ១៨៧០ ដែលពួកគេបានដាក់ ថ្វាយសុំសេចក្តីយល់ព្រមពីព្រះមហាក្សត្រកម្ពុជា និងពីទេសាភិបាល កូសាំងស៊ីន ។

I- តាមសេចក្តីនេះ ត្រូវបានរក្សាទុកការបោះគោលដី ដែលបានធ្វើឡើងនៅចន្លោះទន្លេជ្រៅ និង តាសាង (បង្គោលពីលេខ១ ដល់លេខ ១៦) : "ព្រំដែនបានស្ថិតនៅដដែលដូចដែលគេបានគូស ដោយគ្មានការផ្លាស់ប្តូរណាមួយឡើយ ចាប់តាំងពីបង្គោលលេខ១ (នៅមាត់ពាមនៃពាមព្រាន) រហូតដល់បង្គោលលេខ ១៦ (នៅតាសាងនៅលើ Cai - Cay)" ។

ដូច្នេះគំនូសព្រំដែននេះ បានទុកឲ្យកូសាំងស៊ីននូវដីកម្ពុជានៅតៃ និញ ទាំងអស់ ជាពិសេសតំបន់ដែលមានភោគទ្រព្យ នៅបឹងជ្រៃ ស្រុកត្រាញ់ ចុងបាដែង (Chong-Ba-Den) ដែលអធិការ Rheinart បានទទួលស្គាល់ថា ជាផ្នែកនៃទឹកដីរបស់កម្ពុជា និងទន្លេវ៉ៃគោខាងកើតដែលពាធឆ្នាំក្រោយមក លោកឧត្តមនាវី de la Grandière ទេសាភិបាលកូសាំងស៊ីន បានប្រកាសដោយជាក់លាក់ថា ជាទឹកដីរបស់ប្រទេសកម្ពុជា ។

ដើម្បីបង្ហាញភស្តុតាង នៃការកាត់ទឹកដី ដែលបានធ្វើឡើង ថ្វីបើមានការតវ៉ាពីអជ្ញាធរក្នុងស្រុក និងពីព្រះមហាក្សត្រក្តី ក៏គេបានថ្លែងថា "ទឹកដីនេះមាននៅចន្លោះ Cai-Bach និងCai - Cay ដែលជាផ្នែកនៃទឹកដីបារាំង (ហើយដែលផលទុនប្រចាំឆ្នាំមានចំនួនប្រហែល១០០០ហ្វ្រង់)នឹងត្រូវបានយល់ព្រមឲ្យប្រទេសកម្ពុជាដើម្បីជាការសងទូទាត់ចំពោះផ្ទះប្រហែល ៤៨៦ ខ្នង ដែលបង្កើតបានទៅជាភូមិទាំងឡាយដែលស្ថិតនៅឯស្រុកត្រាំង (Srok Trang)និងបឹងជ្រូម"។ ដូច្នេះនិគមដីធំទូលាយនិងមានជីវជាតិពីររបស់កម្ពុជានោះតាមគេអះអាងថា ត្រូវបានប្តូរជាមួយនឹងដីមួយដុំតូចនិងក្រគ្មានអ្នកស្រុករស់នៅដែលពួកអធិការបានទុកដាក់ដោយរំលោភថាជា "ទឹកដីបារាំង" តាមហេតុការណ៍តែមួយគត់ ដែលថាមានអត្ថិភាព នៃការទាមទាររបស់ពួកគេ ។

តើការទាមទារទាំងនេះឆ្លើយតបទៅនឹងផ្លូវច្បាប់ដែរឬទេ ?

ដើម្បីឆ្លើយតបទៅនឹងសំណួរនេះ គេត្រូវតែរំលឹកឡើងវិញថា ទឹកដីដ៏ធំទូលាយទាំងអស់នៃ តៃ និញ ដែលបានរួមបញ្ចូលនូវទឹកដីដែលមានបញ្ហានេះ និងបានលាត

សន្ទឹងទៅឆ្ងាយនោះ គឺជាទឹកដីរបស់កម្ពុជា ។ ឃុំ Hoa - Duc តាមការពិត គឺមិនមានអ្វីផ្សេងក្រៅពីភូមិអណ្ណាមមួយ ដែលតាំងនៅក្នុងទឹកដីកម្ពុជា ។

II - និយាយពីតំបន់កម្ពុជាដ៏ទូលាយនៅ Chong Ba Den វិញ ក៏ត្រូវបានដាក់បញ្ចូលជាឧបសម្ព័ន្ធផងដែរ ប៉ុន្តែគេមិនបាននិយាយអំពីសំណួរនេះទេ ។

III - ប៉ុន្តែគេបានផ្តល់នូវការបំពេញចិត្តនូវភាគខ្លះ ទៅតាមការទាមទាររបស់ព្រះមហាក្សត្រ គឺ : "បង្គោលលេខ១៧ និងលេខ ១៨ និងបង្គោលបន្តបន្ទាប់មកទៀត ត្រូវបានលុបចោលរហូតដល់ Hung - Nguyen គឺប្រទេសកម្ពុជា នឹងរក្សាទុកនូវខេត្តទាំងអស់របស់ប្រទេសដែលបច្ចុប្បន្នរស់នៅដោយប្រជាជនខ្មែរ ដូចជាខេត្តព្រៃវែង បូនីហ្វុល (Bonifuol , សុកជៀត Socthiet) " ។

ប៉ុន្តែការបំពេញចិត្តនេះ មានកម្រិត ! តាមការពិតចំពោះផ្នែកនៃទឹកដីនេះ តើគេសុខចិត្តទុកឲ្យប្រទេសកម្ពុជា នូវអ្វីៗទាំងអស់ដែលជារបស់ខ្លួនដែរឬទេ គឺថា "បរិព័ទ្ធដ៏វែងរបស់ដែលនៅក្នុងប្រទេស នៅចន្លោះទន្លេវៃគោទាំងពីរនេះ" ? គឺអត់ទេ ។ ទឹកដីកូសាំងស៊ីន បានបំរុងទុកនូវចំរៀកដីទាំងពីរ នៅតាមបណ្តោយទន្លេវៃគោទាំងពីរ គឺថាតំបន់ដែលមានជីវជាតិបំផុត ពីព្រោះថា វាស្ថិតនៅតាមមាត់នៃផ្លូវទឹកដ៏ធំទាំងពីរនេះ "ព្រំដែននឹងត្រូវបានគូសនៅពេលខាងក្រោយ ។ ហើយគេនឹងទុកបំរុងសម្រាប់ឲ្យបារាំងកាន់កាប់នូវចំរៀកទឹកដី សៀរតាមបណ្តោយទន្លេវៃគោ ដែលត្រូវបានកាន់កាប់ដោយពួកអណ្ណាម ឬក៏ធ្វើអាជីវកម្មដោយពួកគេ" ។ ចំរៀកដីទាំងនេះ ត្រូវបានទទួលស្គាល់ជាច្រើនដង ដោយពួកអធិការថា ជារបស់កម្ពុជា ប៉ុន្តែដោយមានហេតុការណ៍តែមួយ គឺមានប្រជាជនអណ្ណាមខ្លះរស់នៅ ឬក៏មានទឹកដីខ្លះដែលគ្រាន់តែពួកអណ្ណាមធ្វើអាជីវកម្មនោះ គេក៏បានផ្តាច់ពីប្រទេសកម្ពុជា ដើម្បីរាប់បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន ។ ក្នុងពេលដែល"ប្រជាជនកម្ពុជា អាងលើច្បាប់ពីមុនដែលមានគោលបំណងរុញច្រានពួកអណ្ណាមឲ្យទៅវិញនេះ ឯចំណែកពួកអណ្ណាមវិញ គិតតែពីទន្ទ្រានដណ្តើមយកទឹកដីរបស់ប្រជាជនកម្ពុជា ដោយឥតឈប់ឈរ" គេបានសម្រេច ធ្វើពលិកម្មខាងប្រជាជនកម្ពុជា គឺធ្វើច្បាប់ទាំងឡាយ ដើម្បីជាគុណប្រយោជន៍ដល់ការទន្ទ្រានយករបស់អណ្ណាម ។



## ផ្នែកទី IV
## ដំណាក់កាលទី២ នៃប្រតិបត្តិការបោះគោលដី

នៅក្នុងពេលឥឡូវនេះ គឺជាការកំណត់ព្រំដែននៃចំរៀកដីដែលស្ថិតនៅតាមបណ្តោយទន្លេវៃគោទាំងពីរ ខាងកើតនិងខាងលិច ។ ប្រតិបត្តិការកំណត់ព្រំដែនដីនេះត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៨៧២ ។

### ១ – អវត្តមានរបស់ស្នងការកម្ពុជា

ការងារនេះត្រូវបានបំពេញដាច់ខ្សែតែដោយពួកអធិការបារាំងដែលមានជំនួយពីអ្នកភូមិអណ្ណាម "យើងអាចធ្វើដោយខ្លួនឯងបាន ដោយមានជំនួយពីអ្នកភូមិរបស់យើងពីព្រោះថា យើងស្វែងរកតែទឹកដីដែលកាន់កាប់ឬក៏ធ្វើអាជីវកម្មដោយពួកគេ"(៥១) ។

ដូច្នេះវាគ្រាន់តែឲ្យអ្នកភូមិវៀតណាម ចង្អុលបង្ហាញជាឯកតោភាគី នូវការទាមទាររបស់ពួកគេ ដើម្បីឲ្យពួកអធិការបារាំងធ្វើឲ្យបានសម្រេចតែប៉ុណ្ណោះ ។

ដូច្នេះអាជ្ញាធរកម្ពុជា មិនបានចូលរួមចំណែកទេ "គឺគេមិនបានដាក់បញ្ញត្តិឲ្យរង់ចាំការជួយដែលគ្មានប្រយោជន៍ពីអាជ្ញាធរកម្ពុជានោះទេ " ។ វត្តមានរបស់អាជ្ញាធរកម្ពុជាវាមិនគ្រាន់តែឥតប្រយោជន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យទោសទៀតផងពីព្រោះថា វាធ្វើឲ្យកាន់តែស្មុកស្មាញនូវបញ្ហាដូចនៅក្នុងឆ្នាំ ១៨៧០ ។

### ២ – អាកប្បកិរិយារបស់អធិការបារាំង

តើនៅក្នុងស្មារតីអ្វីដែលពួកអធិការទាំងនេះ បានដឹកនាំធ្វើប្រតិបត្តិការទាំងនេះ ? យើងបាននិយាយរួចហើយថា ព្រំដែនបានរួមបញ្ចូលនូវទឹកដី ដែលកាន់កាប់ឬក៏ធ្វើអាជីវកម្មដោយប្រជាជនអណ្ណាម ។ សេចក្តីផ្ទុយពីនេះត្រូវបានគេមិនយកចិត្តទុកដាក់ទាំងស្រុង "ភូមិបីរបស់ (កម្ពុជា) ដែលត្រូវបានបង្កើតឡើងនៅកណ្តាលភូមិអណ្ណាមនៅជិតទន្លេវៃគោ ត្រូវបានដាក់បញ្ចូលជាឧបសម្ព័ន្ធ ពួកគេនឹងទទួលបានមកវិញហើយនឹងមិនបានបាត់បង់អ្វីឡើយ" (៥២) ។

---

*(៥១) / របាយការណ៍ថ្ងៃទី ២៣ មីនា ១៨៧២ របស់អធិការ Rheinart ដែលបាននិយាយរួចហើយ ។*

*(៥២) / របាយការណ៍ចុះថ្ងៃទី២៣ ខែមីនា ១៨៧២ របស់អធិការ Rheinart ដែលបានរៀបរាប់រួចមកហើយ ។*

ហើយតើព្រោះមូលហេតុអ្វីដែលគេបានធ្វើពលីកម្មនូវភូមិទាំងឡាយរបស់កម្ពុជានោះ ? លោកអធិការ Rheinart បានបញ្ជាក់បញ្ហានេះថា "ដោយយើងពុំមានជម្រើសណាផ្សេងទៀតជាជាងការទុកចំណែកភូមិអណ្តាម ដីធំសម្បើមថ្វាយព្រះមហាក្សត្រ (នេះ គឺវាធ្វើឲ្យខូចដល់ផលប្រយោជន៍របស់យើង និងការពិនិត្យពិចារណារបស់យើងយ៉ាងខ្លាំងបំផុត)ឬក៏ការបញ្ចូលជាឧបសម្ព័ន្ធនូវភូមិទាំង៣នេះ គឺខ្ញុំមិនមានការរារែកទេ" ។ "ភូមិទាំងនេះមានផ្ទះស្លឹកចំនួន ៣៤០ខ្នង" ។

នៅទីបញ្ចប់យើងអាចសង្ខេបគំនិតគ្របសង្កត់របស់លោកអធិការ Rheinart ដោយសារជំនួយនៃប្រយោគទាំងពីររបស់លោក គឺ "ការងារដែលសហការីរបស់ខ្ញុំ និងរូបខ្ញុំបានធ្វើនោះ គឺគ្រាន់តែជាប្រតិបត្តិការខាងឋានលេខាសាមញ្ញមួយ ដែលពួកមន្ត្រី និងព្រះមហាក្សត្រផ្ទាល់ ពុំបានយល់ដឹងអ្វីធំដុំនោះ...។ ខ្ញុំមិនពន្យល់ទេ អំពីគម្រោងអ្វីនៅក្នុងអនាគត និងថាតើគំនិតអ្វីខ្លះ ដែលអាចថ្វាយដល់ព្រះមហាក្សត្រ ដែលធ្វើឲ្យព្រះអង្គងាយស្រួលបំផុតនូវការយល់ព្រមរបស់ព្រះអង្គនោះ" [៥៣] ។

ហេតុដូច្នេះហើយបានជាពួកអធិការ បានកម្រិតព្រំដែននៃចំរៀកដីនៅតាមបណ្តោយទន្លេវ៉ៃគោទាំងពីរ ហើយដែលត្រូវបានភ្ជាប់ទៅទឹកដីកូសាំងស៊ីននោះ ។

## ជំពូកទី II
## តម្លៃគតិយុត្ត នៃគំនូសព្រំដែន

ប្រវត្តិសាស្ត្រដ៏វែងអន្លាយនៃការបោះគោលដីនេះ ដែលយើងនឹងរៀបរាប់ដោយលំអិតនោះ នឹងនាំមកឲ្យយើងនូវកត្តាមូលដ្ឋានទាំងឡាយដែលនឹងជួយដល់ការពិភាក្សាប្រកបដោយគតិយុត្ត ។

***យើងសូមសង្ខេបនូវវិន្ទន័យទាំងឡាយនៃការចាប់ផ្តើមដូចតទៅ :***

**១.** – បន្ទាត់ព្រំដែនដែលបានរៀបចំឡើងរវាងបណ្តាឆ្នាំ ១៨៧០ និងឆ្នាំ ១៨៧២ ដែលបានបំបែកនៅក្នុងពេលដែលបន្ទាត់ព្រំដែននេះត្រូវបានរៀបចំទឹកដី ដែលដាក់

*(៥៣) / ដូចគ្នា ។*



នៅក្រោមការគ្រប់គ្រងផ្ទាល់របស់បារាំង នៅអាណានិគមកូសាំងស៊ីន និងទឹកដីទាំងឡាយដែលស្ថិតនៅក្រោមការសហគ្រប់គ្រងរបស់អាជ្ញាកម្ពុជា និងអាជ្ញាធរបារាំងដែលជាអ្នកការពារ ។

**២.** – គំនូសនេះត្រូវបានចាប់ផ្តើមធ្វើឡើងដោយអាជ្ញាធរបារាំងនៅកូសាំងស៊ីន ដើម្បីមូលហេតុនៃបែបបទខាងសារពើពន្ធ ។

**៣.** – គំនូសនេះត្រូវបានសិក្សាជាមុន ពុំនោះទេត្រូវបានរៀបចំជាមុនក្នុងរបៀបជាឯកតោភាគី ដោយអាជ្ញាធរបារាំង ដោយពុំមានការព្រមព្រៀង និងថែមទាំងពុំមានការពិភាក្សាជាមួយអាជ្ញាធរកម្ពុជានោះផងទេ ។

**៤.** – ស្តីពីការរៀបចំសម្ភារៈបង្គោលព្រំដែន ពួកអធិការបារាំងបានទៅហួសក្របខ័ណ្ឌ នៃគម្រោងដើមដំបូងដោយបានបង្ហាញនូវរូបភាពជាចក្រពត្រនិយមដោយពិតប្រាកដ និងបានបង្ហាញនូវក្តីកង្វល់មិនគ្រាន់តែនៅខាងផ្នែកសារពើពន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខាងផ្នែកយោធា នយោបាយ និងសេដ្ឋកិច្ចផងដែរ ។

**៥.** – អ្នកតំណាងខាងកម្ពុជា ត្រូវបានគេនាំឲ្យចូលរួមក្នុងប្រតិបត្តិការបោះគោលដីដែរ ប៉ុន្តែនៅក្នុងអំឡុងនៃការងារនេះ ពួកគេបានបង្ហាញនូវភាពល្ងង់ខ្លៅទាំងស្រុងអំពីបញ្ហានេះ ហើយពួកគេគឺជាសាក្សី ឬជាកម្មវត្ថុនៃការគាបសង្កត់ និងការគំរាមកំហែងពីពួកអធិការបារាំង ។

**៦.** – វាគ្មានការប្រកែកជំទាស់ដោយអ្នកណាឡើយ ប៉ុន្តែផ្ទុយទៅវិញគេបានទទួលយល់ព្រមថា គំនូសនេះបានធ្វើឲ្យទឹកដីសំខាន់ៗរបស់កម្ពុជាត្រូវបានដកហូតដែលតាមប្រវត្តិសាស្ត្រប្រជាជននិងរបបគ្រប់គ្រង គឺជារបស់ប្រទេសកម្ពុជាសុទ្ធសាធ ។

**៧.** – ការរកឃើញ ដោយព្រះមហាក្សត្រនូវការកាត់ទឹកដីទាំងនេះបាននាំឲ្យមានការតវ៉ាចំពោះអាជ្ញាធរបារាំង ។

**៨.** – ចំពោះផ្នែកនៃព្រំដែន ដែលស្ថិតនៅរវាងបង្គោលពីលេខ១ ទៅបង្គោលលេខ១៦ គំនូសដែលបានរៀបចំឡើងនេះ ត្រូវបានរក្សាទុកដោយពួកអាជ្ញាធរបារាំងដោយសំអាងលើការតាំងខ្លួនជាអ្នកសង់ប៉ះប៉ូវនូវទឹកដីដែលមិនអាចតស៊ូបានក្នុងការ ពិនិត្យនូវហេតុការណ៍ទាំងឡាយ ។

**៩.** – ចំពោះគំនូសដែលនៅសល់ (បង្គោលលេខ ១៧ និង បង្គោលតៗទៀត) គោលការណ៍នៃការកែប្រែនូវចម្ងាយដែលបានកំណត់នោះត្រូវបានទទួលស្គាល់យល់ព្រម (អនុសញ្ញា ថ្ងៃទី៩ ខែកក្កដា ឆ្នាំ ១៨៧០) ។

**១០.** – ការបោះគោលដីថ្មីនៅពេលនោះត្រូវបានរៀបចំឡើងជាឯកតោភាគីដោយប្រទេសបារាំង ។

គំនូសនេះ តើត្រូវបានចាត់ទុកថា ជាព្រំដែនអន្តរជាតិមួយឬក៏គ្រាន់តែជាបន្ទាត់រដ្ឋបាលធម្មតាមួយប៉ុណ្ណោះ ? តើអ្វីទៅជាលក្ខន្តិកៈនៃទឹកដីកម្ពុជាដែលបារាំងបានទុកឲ្យទៅកូសាំងស៊ីន ? ទាំងនេះគឺជាសំណួរដែលយើងនឹងឆ្លើយតបនៅលើមូលដ្ឋាននៃទិន្នន័យទាំងនោះ ។

## ផ្នែកទី I
## ព្រំដែន អន្តរជាតិ ?

### ១– ក្របខ័ណ្ឌទូទៅនៃបញ្ហា

គេត្រូវចោទសួរនូវគោលការណ៍មួយនៅពេលចាប់ផ្តើម គឺថាប្រទេសកម្ពុជា និងប្រទេសបារាំងអាចរៀបចំរវាងគ្នានិងគ្នា នូវព្រំដែនអន្តរជាតិមួយបានឬទេ? ។ ចំពោះបញ្ហានេះ វាមិនមានឧបសគ្គខាងគតិយុត្តណាមួយឡើយ ។ សមត្ថកិច្ចខាងកម្ពុជាដើម្បីចូលរួមចំពោះបញ្ហានេះ ដែលគួរយកជាការបាននោះ គឺសារសំខាន់នៃការតស៊ូលើអធិបតេយ្យភាពខាងក្នុងរបស់ខ្លួន និងនៅលើបុគ្គលិកលក្ខណៈនៃភាពជារដ្ឋ ។

បារាំងមិនអាចធ្វើដោយឯកតោភាគីបានទេ ប៉ុន្តែការយល់ព្រមដោយស្ងៀមស្ងាត់និងជាក់លាក់របស់ប្រទេសដែលត្រូវបានការពារ គឺងាយធ្វើឲ្យកើតឡើងនូវការផ្ទេរដែលគួរយកជាការបាននូវទឹកដី និងអធិបតេយ្យភាព ។

ចំពោះបញ្ហានេះ មានតែត្រូវបំពេញនូវល័ក្ខខ័ណ្ឌខ្លះ ឬក៏ត្រូវបំពេញនូវល័ក្ខខ័ណ្ឌមួយនៃល័ក្ខខ័ណ្ឌពីរដូចតទៅនេះ :

#### *ក/– ល័ក្ខខ័ណ្ឌស្មើភាព :*

វាបានរួមបញ្ចូលថា ការចរចាទាំងឡាយព្រមទាំងការងារនៃការកំណត់ព្រំដែន



ត្រូវតែធ្វើឲ្យឃើញច្បាស់នូវលក្ខណៈស្មើភាពដ៏ពេញលេញរវាងភាគីទាំងពីរ ។

ការត្រូវការនូវគំនិតស្មើភាពនេះមានច្រើនណាស់ គឺ :

– ភាគីទាំងពីរត្រូវតែមានចំណេះដឹងលើបញ្ហាទាំងឡាយដូចជាខាងបច្ចេកទេសនិងខាងផ្លូវច្បាប់ស្មើគ្នា ។

– គ្មានភាគីណាមួយ នៅក្នុងភាគីទាំងពីរអាចដាក់បង្ខំនូវទស្សនៈរបស់ខ្លួនទៅឲ្យភាគីមួយទៀតបានឡើយ ។

– នៅក្នុងសភាពការណ៍នៃអាណាព្យាបាល សេចក្តីត្រូវការទាំងនេះត្រូវបានបំពេញដោយកម្រពីខាងភាគីរដ្ឋ ដែលត្រូវបានការពារ ។ ប៉ុន្តែសភាពការណ៍នេះ មិនបានធ្វើឲ្យបញ្ហាមិនអាចដោះស្រាយបាននោះទេ ។ ដើម្បីជំនះនូវការលំបាកនេះ គឺរដ្ឋជាអ្នកការពារត្រូវតែឧបត្ថម្ភក៏ការពារនូវការប្រព្រឹត្តរបស់ខ្លួន ចំពោះផលប្រយោជន៍ស្របច្បាប់របស់រដ្ឋដែលត្រូវបានការពារ ដែលពុំនោះទេនឹងធ្លាក់មកនៅក្រោមអំណាចរបស់ខ្លួន ។

គេអាចយល់បានថា សេចក្តីត្រូវការនេះដែលបានភ្ជាប់ទៅនឹង "សីលធម៌" របស់អាណាព្យាបាល ត្រូវតែបានបំពេញ ។

ប៉ុន្តែបើសិនជាសេចក្តីត្រូវការនេះ មិនអាចទៅរួចទេ ការបំពេញនូវល័ក្ខខ័ណ្ឌទីពីរនៅតែមានលទ្ធភាព ដើម្បីធ្វើឲ្យមានតម្លៃនូវការបែងចែកទឹកដីដែលបានអនុវត្ត ។

#### *ខ/– ការឲ្យសច្ចាប័ននៅពេលចប់អាណាព្យាបាល*

តាមអត្ថន័យ អាណាព្យាបាល គឺជាស្ថាប័នបណ្តោះអាសន្នមួយ ដែលត្រូវតែបញ្ចប់វា ។ ក្នុងល័ក្ខខ័ណ្ឌនៃស្ថាប័ន គឺអាចធ្វើអន្តរាគមន៍ក្នុងរបៀបនៃការសុំចាញ់របស់អាណាព្យាបាលសំដៅធ្វើឲ្យបានការនូវសកម្មភាពទាំងឡាយរបស់អ្នកការពារ។ ក្នុងរឿងនេះគេត្រូវទទួលយល់ព្រមថា បើសិនជាការធ្វើឲ្យបានទទួលការអន្តរាគមន៍នៅទីបញ្ចប់នៃអាណាព្យាបាលនោះវាផ្តល់នូវផលប្រតិសកម្មនូវតម្លៃ នៃខ្សែបន្ទាត់អន្តរជាតិ ចំពោះអ្វីដែលគ្រាន់តែជាគំនូសរដ្ឋបាលបណ្តោះអាសន្ននោះ ។

### ២ – ការអនុវត្តន៍

#### *ក.–តើគេអាចរកឃើញនូវការយល់ព្រមរបស់អាជ្ញាធរកម្ពុជាដែរឬទេ ?*

ចំពោះសំណួរនេះ គេត្រូវតែឆ្លើយថា យល់ព្រមដោយមិនបាច់សង្ស័យឡើយ វាបានសម្តែងចេញនៅក្នុងអនុសញ្ញាថ្ងៃទី៩ ខែកក្កដា ឆ្នាំ ១៨៧០ ប៉ុន្តែ :

**ក/–** ជាដំបូងការយល់ព្រមនេះ មិនត្រូវបានផ្តល់ឲ្យដោយគ្មានការពិបាកនោះទេ ។

**ខ/–** វាមានលក្ខណៈសព្វគ្រប់ចំពោះចំណែកនៃព្រំដែន ដែលមានវវាំងបង្គោលលេខ ១ និងលេខ១៦ ។

**គ/–** វាអាចប្រកែកបានចំពោះផ្នែកនៃព្រំដែន ដែលមានវវាំងបង្គោលទាំងឡាយ ដែលត្រូវបានបោះតែនៅខាងក្រោយពេលមានអនុសញ្ញា និងស្ថិតនៅខាងក្រៅវត្តមានរបស់គណៈប្រតិភូកម្ពុជា ។

ប៉ុន្តែនៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធវិសមភាពរបស់អាណាព្យាបាល ការយល់ព្រមតែម្នាក់ឯងនោះ នឹងមិនអាចយកជាការបានទាំងអស់នោះឡើយ ។ វាមានតម្លៃលុះត្រាតែវាសំដៅចំពោះប្រតិបត្តិការមួយដែលឆ្លើយតបទៅនឹងការទាមទារនូវសមភាពរបស់ដៃគូទាំងឡាយ ។

### ខ.–តើបារាំងបានធានាឲ្យប្រទេសកម្ពុជាមានជំហរស្មើភាពដែរឬទេ ?

នៅទីនេះ គេត្រូវតែបែងចែកឲ្យច្បាស់អំពីទិដ្ឋភាពខាងផ្លូវការ និងទិដ្ឋភាពខាងសម្ភារៈ ។

១ – ជាផ្លូវការ ភាពស្មើភាពហាក់ដូចជាត្រូវបានរក្សា គឺជាគណៈកម្មការចម្រុះបារាំង–កម្ពុជា ដែលបានរៀបចំព្រំដែនយ៉ាងហោចណាស់ក៏សម្រាប់ផ្នែកដែលត្រូវបានឲ្យសច្ចាប័នដោយអនុសញ្ញាឆ្នាំ ១៨៧០ ដែរ ។

ចំពោះផ្នែក ដែលបានបោះគោលសីមា នៅឆ្នាំ ១៨៧២ ការងារនេះត្រូវបានធ្វើជាឯកតោភាគី ដោយប្រទេសបារាំង ដែលយកចិត្តទុកដាក់ដើម្បីជៀសវាងនូវការលំបាកទាំងឡាយ ដែលអាចនឹងធ្វើឲ្យអូសប្រទាញ "ដូចនៅឆ្នាំ ១៨៧០" ចំពោះវត្តមាន "ដោយឥតប្រយោជន៍" របស់ស្ថានការទាំងឡាយរបស់កម្ពុជា ។ ដូច្នេះការកំណត់ព្រំដែនត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងជាមួយអាជ្ញាធរ "អណ្តាមនៅក្នុងស្រុក" ។



**២** – ជាការពិត ? ប្រវត្តិសាស្ត្រនៃការរៀបចំព្រំដែន ដែលយើងបាននិយាយនៅក្នុងជំពូក I បានរៀបចំដោយគ្រប់គ្រាន់ថា សភាពការណ៍សមភាព មិនដែលបានគោរពឡើយ ចំពោះទស្សនៈនេះ ដែលជាប្រការដ៏សំខាន់បំផុតមិនអាចប្រកែកបានទេ។

ក្នុងបញ្ហានេះ គេត្រូវតែរំលឹកឡើងវិញ អំពី :

– ការហៅរកចំពោះភាគីកម្ពុជា ត្រូវបានធ្វើឡើង តែនៅក្នុងកម្រិតនៃការបោះគោលសីមា គឺថាប្រតិបត្តិការខាងសម្ភារៈដោយអនុវត្តទៅតាមសេចក្តីសម្រេចជាគោលការណ៍ដែលប្រកាន់យកជាឯកតោភាគីដោយអាជ្ញាធរបារាំង ។

– អសមត្ថភាពរបស់ស្ថានការកម្ពុជា ។

– ការគម្រាមកំហែងដែលបានប្រព្រឹត្តទៅលើមន្ត្រីខ្លះរបស់កម្ពុជា ។

– មានការកង្វល់តែខាងភាគីអធិការបារាំង ។

– ការអះអាងដោយប្រញាប់ប្រញាល់ ដើម្បីកុំឲ្យនិយាយពាក្យកុហក នៃអនុសញ្ញាឆ្នាំ ១៨៧០ ដែលទាក់ទងទៅនឹងការទាមទារនូវ "ការសងទូទាត់" ។

### គ.– តើមានការឲ្យសច្ចាប័ន នៅក្នុងក្របខ័ណ្ឌនៃអាណាព្យាបាលឬទេ ?

ទេ ! ផ្ទុយទៅវិញគេត្រូវរំលឹក អំពីការតវ៉ាជាច្រើនរបស់កម្ពុជា

### គ.– ការសន្និដ្ឋាន

ដូច្នេះគេពុំមានលទ្ធភាព បានឃើញនៅក្នុងខ្សែបន្ទាត់បោះគោលដី ទាំងនៅក្នុងឆ្នាំ ១៨៧០ និងឆ្នាំ ១៨៧២ នូវព្រំដែនអន្តរជាតិ ពិតប្រាកដបានឡើយ ។ អនុសញ្ញាដែលចាប់បង្ខំ ដើម្បីសុំការយល់ព្រមពីព្រះមហាក្សត្រនរោត្តម នៅក្នុងឆ្នាំ ១៨៧០ ចំពោះបញ្ហានេះ គឺពុំមានតម្លៃឡើយ ។

## ផ្នែកទី II
## ការកំណត់ព្រំដែនរដ្ឋបាល ?

### ១ – វិន្ទន័យទូទៅ

ការកំណត់ព្រំដែនរដ្ឋបាល អាចចាប់កំណើតតាមរបៀបពីរ គឺ : ដោយការព្រមព្រៀងរួមគ្នា ឬដោយឯកតោភាគី ។

### ក/- ដោយកិច្ចព្រមព្រៀងរួម :

*ប្រទេសដែលត្រូវទទួលការការពារអាចបដិសេធដោយស្ម័គ្រចិត្ត និងដោយបានដឹងនូវមូលហេតុទាំងស្រុងចំពោះអធិបតេយ្យភាពជាគោលការណ៍ និងយល់ព្រមចំពោះការភ្ជាប់មួយផ្នែកនូវទឹកដីរបស់ខ្លួន ទៅឲ្យទឹកដីរបស់អ្នកការពារ ឬទៅឲ្យប្រព័ន្ធរដ្ឋបាលរបស់អ្នកការពារដែលតាំងនៅលើទឹកដីរបស់ប្រទេសមួយផ្សេងទៀតដែលស្ថិតនៅក្រោមការការពារ ។*

ប៉ុន្តែគេក៏ប្រកាន់យកនូវតម្លៃនៃការកំណត់ព្រំដែនផងដែរ ការកំណត់ព្រំដែននៃទឹកដីដែលមិនទាន់ហើយ ដោយមូលហេតុនៃវិសមភាពដែលធ្វើជាប្រធានចំពោះការរៀបចំរបស់ពួកគេ ។

សភាពការណ៍ទាំងនេះ ត្រូវបានបញ្ចប់ជាចាំបាច់ជាមួយនឹងអាណាព្យាបាលដែលបានអូសទាញ ឬមួយក៏ប្រគល់នូវទឹកដីទាំងឡាយ ដែលការគ្រប់គ្រងបានបោះបង់ចោលនៅក្នុងករណីទីមួយ (លក្ខណៈរដ្ឋបាលជាក់លាក់) ឬមួយក៏ទាមទារនូវការបញ្ជាក់មួយ ឬបើគ្មានការចរចាថ្មីនៅក្នុងករណីទី២ (ករណីកំណត់ព្រំដែនមិនទាន់ហើយ) ។

### ខ/- ដោយឯកតោភាគី

នោះគឺជាវិធានការដ៏បរិសុទ្ធទាំងឡាយ ដែលគ្មានតម្លៃគតិយុត្តនិងមិនអាចប្រឆាំងបានចំពោះប្រទេសដែលត្រូវការពារនោះទេ ។

### ២ - ការអនុវត្តន៍

ព្រំដែនដែលជាកម្មវត្ថុ នៃជំពូកនេះ បានបង្ហាញនូវលក្ខណៈទាំងឡាយនៃខ្សែបន្ទាត់រដ្ឋបាលដែលលើកឡើងនូវប្រភេទច្បាប់រដ្ឋបាលទាំងពីរនេះ ។

ពីបង្គោលលេខ ១ ដល់បង្គោលលេខ ១៦ គេស្ថិតនៅចំពោះមុខនៃការផ្ទេរសមត្ថកិច្ចខាងរដ្ឋបាល ដែលបានយល់ព្រមចំពោះប្រទេសបារាំងដែលមានអធិបតេយ្យភាពលើកូសាំងស៊ីន ។

ទិដ្ឋភាពរដ្ឋបាលនៃគំនូសនេះ មិនមែនជាលទ្ធផលដែលបណ្តាលមកពីឆន្ទៈដោយចេតនារបស់ដៃគូនោះទេ ប៉ុន្តែគ្រាន់តែបណ្តាលមកពីលក្ខណៈមិនគ្រប់លក្ខណៈ នៃការប្រគល់ឲ្យនូវទឹកដីដែលបានអនុវត្ត ។



អនុសញ្ញាឆ្នាំ ១៨៧០ អាចធ្វើយុត្តិកម្ម នៃការប្រព្រឹត្តរបស់រដ្ឋការបារាំង ដោយផ្ទាល់នៅលើទឹកដីទាំងនេះ ។

ប៉ុន្តែអនុសញ្ញានេះមិនអាចធ្វើយុត្តិកម្មអ្វីបានឡើយនូវការផ្ទេរជាខាងក្រោយមកទៀតទៅឲ្យរដ្ឋការវៀតណាម នៅក្នុងអំឡុងពេលនៃការកំណត់ជាឯកតោភាគី នូវខេត្តនេះ (ហើយនិងភាពនៅក្នុងចំណុះខាងរដ្ឋបាលរបស់ខ្លួន) នៅវៀតណាម ។

គឺនៅក្នុងសម័យនោះបន្ទាត់ដែលបានគូសត្រូវបាត់បង់នូវតម្លៃទាំងអស់ ។ បញ្ហានេះនាំអូសទាញឲ្យមានការចរចា ឬក៏យ៉ាងហោចណាស់ក៏គោលការណ៍របស់ពួកគេនឹងត្រូវបានចោទសួរ ។ *ម្យ៉ាងទៀតរដ្ឋាភិបាលកម្ពុជាមិនបានភ្លេចតវ៉ា នៅលើដែនការទូទៅប្រឆាំងនឹងការលះបង់ឲ្យវៀតណាម នូវទឹកដីកូសាំងស៊ីន ដែលនៅខាងផ្នែកគតិយុត្ត គឺជាទឹកដីកម្ពុជានោះ* [៥៣ស្ទួន] ។

ចំណែកខ្សែបន្ទាត់ដែលចេញពីបង្គោល ១៧ ដោយមូលហេតុនៃលក្ខណៈឯកតោភាគីនៃការគូសរបស់ខ្លួន គេអាចទទួលស្គាល់គំនូសនេះ តែតម្លៃនៃវិធានការមួយដែលមានលក្ខណៈពិតសុទ្ធសាធ ដែលមិនអាចប្រឆាំងបានចំពោះរដ្ឋាភិបាលកម្ពុជា ។

## ផ្នែកទី III
## សភាពការណ៍ គតិយុត្តនៃទឹកដីដែលបានភ្ជាប់

សភាពការណ៍នេះត្រូវបានដាក់បង្ខំដោយសន្ធិសញ្ញាបារាំង-សៀម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៦៧ ដែលបានបញ្ញត្តិដូចខាងក្រោមនេះ :

"ព្រះករុណា អធិរាជនៃប្រជាជនបារាំងបានសន្យាថា មិនដណ្តើមយកព្រះរាជាណាចក្រនេះ (ប្រទេសកម្ពុជា) ដើម្បីបញ្ចូលទៅជារបស់កូសាំងស៊ីនទេ" ។

គឺអនុសញ្ញានេះហើយដែលទេសាភិបាលកូសាំងស៊ីន **Le Myre de Villers** បានឲ្យឈ្មោះថា ជាសន្ធិសញ្ញា "ចង្រៃ" ព្រោះថាវាបានរារាំងមិនឲ្យបញ្ចូលជាឧបសម្ព័ន្ធ

---

***(៥៣ស្ទួន) /*** *Cf. 167* ***បញ្ជីនៃការតវ៉ារបស់កម្ពុជាប្រឆាំងនឹងការបោះបង់ចោលកូសាំងស៊ីនឲ្យវៀតណាមដោយប្រទេសបារាំង ។***

ទៅក្នុងទឹកដីកូសាំងស៊ីន នូវកោះ **Catrey** ដែលស្ថិតនៅមាត់ពាមនៃព្រែកកំពត ដែលលោកទេសាភិបាលបានទទួលនូវការប្រគល់ឲ្យប្រទេសបារាំង បន្ទាប់ពីការគោរពសង្កត់ទៅលើព្រះករុណានរោត្តម "ខ្ញុំត្រូវអំពាវនាវចំពោះការយកចិត្តទុកដាក់របស់លោកទៅលើមាត្រាទី៣ នៃអនុសញ្ញាចង្រៃចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៦៧ នេះ នៅក្នុងល័ក្ខខ័ណ្ឌដែលអធិរាជណាប៉ូឡេអុង ទីIII បានសន្យាចំពោះប្រទេសថៃ មិនឲ្យបញ្ចូលប្រទេសកម្ពុជាទៅក្នុងការកាន់កាប់របស់កូសាំងស៊ីន" (៥៤) ។

ដោយហេតុថា កូសាំងស៊ីន មិនអាចបញ្ចូលជាឧបសម្ព័ន្ធ នូវកោះ Catrey ដោយមូលហេតុនៃកិច្ចសន្យានេះ ចុះតើគេអាចប្រព្រឹត្តខុសច្បាប់ចំពោះការហាមឃាត់នេះចំពោះទឹកដីតៃ និញ របស់កម្ពុជា ហើយនិងមាត់ច្រាំងនៃទន្លេវ៉ៃគោឬទេ ? ការពិតគឺមិនអាចទេ ។ ដូច្នេះ ទឹកដីទាំងនេះបានបន្តស្ថិតនៅក្រោមអធិបតេយ្យភាពនៃប្រទេសកម្ពុជា ។ បើសិនជាពេលមួយទឹកដីនេះត្រូវបានដាក់នៅក្រោមរដ្ឋការរបស់រដ្ឋាភិបាលរបស់អ្នកការពារហើយ នៅពេលចប់ការអាណាព្យាបាល ទឹកដីនេះនឹងត្រូវបានវិលមកម្ចាស់កម្មសិទ្ធិវិញ ។

## ភាគ IV
## ព្រំដែនខាង ធូ យ៉ូវម៉ុត (THU DAU MOT) មួយផ្នែក និងកំពង់ចាម និងក្រចេះ មួយផ្នែកទៀត
## (១៨៧១ ‑ ១៩១៤)
## ជំពូកទីមួយ
## ការរៀបចំ ព្រំដែន

ការងាររបោះគោលព្រំដែន ឆ្នាំ១៨៧០ បានឈប់ នៅទិសខាងកើត នៅកន្លែងប្រសព្វមុខនៃទន្លេជ្រៅ ជាមួយនឹងព្រែកព្រាន ។ បង្គោលដីលេខ ១ នៅខាងស្តាំនៃទន្លេ

(៥៤) / *លិខិតរបស់លោក Le Myre de Villers ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៨៨២ ផ្ញើទៅរដ្ឋមន្ត្រីអាណានិគម ឥណ្ឌូចិន A 30 (៥៧) ។*



ជ្រៅ នៅជិតនិងនៅខាងក្រោមព្រែកព្រាន នៅលើទឹកដីបារាំង ។ បង្គោលដីនេះមានការចង្អុលបង្ហាញដូចតទៅ ដែលដៅក្រិត្យដោយថ្នាំលាបពណ៌ស ។ នៅមុខខាងកើត "លេខ ១ ព្រំប្រទល់នៃធូយ៉ូវម៉ុត" ។ នៅមុខខាងត្បូង "ព្រំប្រទល់នៃ តៃ និញ ១៦មីនា ១៨៧០ " ។ នៅមុខខាងជើងសរសេរជាភាសាកម្ពុជា "ព្រំប្រទល់នៃប្រទេសកម្ពុជា ថ្ងៃទី១៥ នៃខែទី២ ឆ្នាំម្សាញ់ ១២៣១ (១) " ។

កំណត់ហេតុ បានបញ្ជាក់បន្ថែមទៀតថា "បង្គោលដែលបាននិយាយនេះត្រូវបានប្រើប្រាស់ ដើម្បីកំណត់ព្រំដែនខាងជើងនៃទឹកដីរបស់បារាំង" កាន់កាប់ ។

តាមអក្សរបារិកនេះ គេបានធ្វើការវិនិច្ឆ័យទុកជាមុនរួចហើយ ដោយពុំបានធ្វើការទទួលស្គាល់ជាមុន នូវព្រំដែនខាងជើងនៃខេត្តធូយ៉ូវម៉ុតនោះទេ ។ តាមអំពើនេះ គេបានរាប់បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន នូវទឹកដីរបស់កម្ពុជាដែលស្ថិតនៅឯនាយផ្លូវថ្នល់ដែលតភ្ជាប់ពីតៃនិញ ទៅបារៀ ដោយឆ្លងកាត់តាមធូយ៉ូវម៉ុត ជាផ្លូវថ្នល់ដែលព្រំដែនចុងបំផុតរបស់កូសាំងស៊ីន បានឆ្លងកាត់តាមនោះ ។ (Cf.Supra) ។

នៅខែវិច្ឆិកា ឆ្នាំ ១៨៧១ ទេសាភិបាលឥណ្ឌូចិន បានផ្ញើនូវសារាចរមួយច្បាប់ (២) ទៅឲ្យអធិការទទួលបន្ទុកប្រជាជនអន្ទោគ្រាម នៅធូយ៉ូវម៉ុត ដើម្បីស្នើសុំឲ្យលោកទទួលស្គាល់នូវព្រំដែននេះ ជាមួយនិងការជួយជាធម្មតាពីអ្នកស្រុកអណ្ណាម ដោយគ្មានការចូលរួមពីកម្ពុជា : "លោកមិនបានដាក់បញ្ហាឲ្យរង់ចាំការជួយដែលគ្មានប្រយោជន៍ពីអាជ្ញាធរកម្ពុជាសោះឡើយ" (៣) ។

**យើងនឹងធ្វើការសិក្សាជាបន្តបន្ទាប់ដូចតទៅនេះ :**

- សភាពការណ៍របស់ប្រទេស នៅក្នុងបណ្តាទសវត្សរ៍ ១៨៧០
- វិធានការជាបន្តបន្ទាប់ដែលមានទំនោរ ទៅរកការដាក់បញ្ចូលជាឧបសម្ព័ន្ធ ។
- អនុក្រិត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី ៣១ ខែកក្កដា ១៩១៤ ។

(១) / *កំណត់ហេតុបោះគោលសីមា ថ្ងៃទី១៦ ខែមីនា ឆ្នាំ ១៨៧០ ។*

(២) / *សំបុត្ររបស់លោកអធិការ Rheinart ចុះថ្ងៃទី ២៣-៣-១៨៧២ ផ្ញើទៅជូននាយកនៃអធិការដែលបានរៀបរាប់រួចហើយ ។*

(៣) / *ដូចគ្នាខាងលើ ។*

## ផ្នែកទី I
## សភាពការណ៍របស់ប្រទេសនៅក្នុងឆ្នាំ ១៨៧០

របាយការណ៍របស់លោកអធិការ Rheinart ដែលបានរៀបចំឡើង នៅក្រោយពេលដែលការងារបោះគោលដី ឆ្នាំ ១៨៧០ បានផ្តល់ឲ្យនូវការពិពណ៌នាមួយអំពីតំបន់ដែលស្ថិតនៅតាមកន្លែងទាំងឡាយដែលត្រូវបានដាំបង្គោលលេខ ១ "នៅឯទន្លេជ្រៅ និងទន្លេចាម ស្ថានភាពដីមានលក្ខណៈរលកអង្កាញ់ ដោយគ្មានជ្រលងភ្នំដែលហាក់ដូចជាមានទិសដៅទូទៅដូចគ្នា ដីហាក់ដូចជាមិនជ្រៅប៉ុន្មាន ហើយមានតែដើមឈើមានដំរដុះរេញៗ មានលក្ខណៈរង្វើលពីមួយដើមទៅមួយដើម ។ នៅក្នុងជ្រលងភ្នំ និងនៅគ្រប់ទីកន្លែងដែលដីមិនសូវទាបពេកប៉ុន្មាន គេឃើញមានឫស្សី ដុះជាច្រើន និងមានព្រៃគម្លោតដុះខាងនេះខ្លះ ខាងនោះខ្លះ ប៉ុន្តែមិនមែនជាព្រៃមែនទែនឡើយ ។

"មានភូមិមិនច្រើនប៉ុន្មានទេ ដែលជនជាតិស្ទៀង និងប្រជាជនកម្ពុជាបានរស់នៅ ភូមិនីមួយៗព័ទ្ធជុំវិញទៅដោយរបងចម្រឹង និងដើមឈើ ដើម្បីការពារ ការវាយប្រហាររបស់ពួកចោរលួចមនុស្ស ដែលកើតមានភាគច្រើននៅក្នុងព្រៃទាំងនោះ" ។

នៅខាងត្បូងឆ្ងាយ ប្រជាជនកម្ពុជាបានរស់នៅឬមួយដោយបែកពីគ្នា ឬមួយក៏ដោយលាយឡំគ្នាជាមួយជនជាតិ ស្ទៀង និងជនជាតិ ម៉យ (Moïs) នៅក្នុងស្រុក គូវអាន (Cuu-An) មិញ ង៉ាយ (Minh-Ngai) ក្វាងឡើយ (Quang Loi) និង ថាញ់ អាន (Thanh An) ដែលបានបន្តទៀត ទៅទិសខាងកើតទៀតនៅស្រុក បឹងជ្រិម របស់ កម្ពុជា ដែលត្រូវបានដាក់ បញ្ចូលជាឧបសម្ព័ន្ធទៅឲ្យខេត្ត តៃនិញ នៅឆ្នាំ១៨៧០ ។

## ផ្នែកទី II
## ដំណាក់កាល នៃការកាត់ទឹកដីកម្ពុជា
### អនុផ្នែកទី I
### ដំណាក់កាល ទីមួយ (១៨៩០)
### ផែនទីដែលមានចំណងស្ទាត់កំបាំង



### វដ្តការមួយដែលមានការរាំរែក :
### វាសនានៃស្រុក គូវ អាន, មិញ ង៉ាយ, ក្វាង ឡើយ (Quang-Loi) និងថាញ់ អាន

### ១ – ទិន្នន័យ នៃផែនទីរបស់ក្រុមភូមិសាស្ត្រ ឥណ្ឌូចិន

ដូចដែលយើងបាននិយាយរួចហើយ ក្នុងការចារិកនៅលើមុខមួយនៃបង្គោលលេខ១ "ព្រំដែនធូយ៉ូវម៉ូត" និងម្យ៉ាងទៀតក្នុងការបញ្ជាក់ថា បង្គោលនេះ "ត្រូវប្រើប្រាស់ដើម្បីកំណត់ព្រំដែនខាងជើងនូវទឹកដីដែលកាន់កាប់ដោយបារាំង" នោះ គេបានសំអាងដោយធ្វើការវិនិច្ឆ័យជាមុនថា ទឹកដីទាំងអស់ដែលស្ថិតនៅខាងត្បូងនៃបង្គោលនេះ គឺជារបស់កូសាំងស៊ីន ។

គឺនៅក្នុងបន្ទាត់នៃគំនិតនេះហើយដែលនៅក្រោមការដឹកនាំរបស់អគ្គទេសាភិបាលឥណ្ឌូចិន ផែនទីរបស់ប្រទេសកម្ពុជា (បោះពុម្ពឆ្នាំ ១៨៩០ មាត្រាដ្ឋាន ១/៥០០.០០០ និងផែនទី ធូយ៉ូវម៉ូត) (បោះពុម្ពឆ្នាំ ១៨៩០ មាត្រាដ្ឋាន ១/១០០.០០០) ត្រូវបានរៀបចំឡើងដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន (៣សូន) ។

ផែនទីទាំងនេះ បានគូរព្រំដែនឆ្លងកាត់ស្ទើរតែនៅក្នុងទិសដៅខាងកើត ខាងលិចទាំងអស់ ដោយភ្ជាប់ពីបង្គោលលេខ១ ទៅភ្នំភូដិន (Phnom-Phu-Den) ។ ចាប់ពីភ្នំភូដិន ព្រំដែនបានចុះទៅទិសខាងត្បូងដោយយកទិកខាងជើង – ខាងត្បូង – ខាងកើត ។

ព្រំដែននេះបានរាប់បញ្ចូល នៅក្នុងកូសាំងស៊ីន នូវស្រុកកម្ពុជាខ្លះ ដោយគ្មានការព្រមព្រៀងណាមួយត្រូវបានធ្វើអន្តរាគមរវាងកូសាំងស៊ីន និងកម្ពុជានោះឡើយ ។

ដូច្នេះព្រំដែនដែលមាននៅក្នុងផែនទី ឆ្នាំ ១៨៩០ បានដាក់ខេត្តជើងព្រៃ (Choeung-Preas) នៅក្នុងទឹកដីកម្ពុជានៅឡើយ ។

ប៉ុន្តែផែនទីនេះបានបញ្ចូលនូវស្រុកខ្លះរបស់កម្ពុជាទៅក្នុងកូសាំងស៊ីនរួចហើយ (ស្រុក គូវ អាន , មិញ ង៉ាយ , ក្វាង ឡើយ និង ថាញ់ អាន ) ។

### ២ – លក្ខណៈភាន់ច្រឡំរបស់វា

ផែនទីប្រទេសកម្ពុជា ដែលបានរៀបរាប់ពីមុន បានបង្ហាញនូវទឹកដីដែលស្ថិតនៅត្រើយខាងឆ្វេងនៃ D.Glum ដូចជាប្រទេសស្ទៀងឯករាជ្យ ។ ប៉ុន្តែការចង្អុលបង្ហាញនេះ

(៣សូន) / cf. ផែនទីឧបសម្ព័ន្ធ ។

មិនត្រឹមត្រូវឡើយ ។ តំបន់នេះគឺជាផ្នែករបស់ប្រទេសកម្ពុជា និងស្ថិតនៅក្រោមចំណុះអាជ្ញាធរកម្ពុជា លិខិតរបស់លោក អ៊ុង (Ung) អតីតមន្ត្រីរបស់ គិរីពុទ្ធបាទ (Kiriputhbat) ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៨៩៨ ផ្ញើទៅជូនលោកនាយករដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋមន្ត្រី នៃប្រទេសកម្ពុជា ហើយដែលយើងសូមផ្តល់ជូននូវការដកស្រង់ដ៏វែងមួយបន្ទាប់ទៅនេះដែលបានបញ្ជាក់ថា :

## "ថ្ងៃទី៥ ខែឧសភា ឆ្នាំ ១៨៩៨"

យើងឧកញ៉ា មន្ត្រីគិរីពុទ្ធបាទ [៤] អ៊ុង ជនជាតិកម្ពុជា កើតនៅឆ្នាំខាល អាយុ៥៦ឆ្នាំ និងឧកញ៉ា ប្រ៊ុង ជនជាតិស្ទៀង (មិនបានចាំពីអាយុរបស់លោក) ដែលបានចុះហត្ថលេខាខាងក្រោមមានទីលំនៅ នៅភូមិពុយជរ (Puchor) ខេត្តជើងព្រៃ (នៅចុងខេត្តត្បូងឃ្មុំ) " ។

"មានកិត្តិយស សូមដាក់ជូននូវសេចក្តីស្នើសុំនេះចំពោះ ឯកឧត្តម អគ្គមហាសេនា [៥] និងក្រុមប្រឹក្សារដ្ឋមន្ត្រី គឺ :

"ខ្ញុំឧកញ៉ាមន្ត្រី ពុទ្ធបាទ អ៊ុង ជាកូនប្រុសរបស់ទ្វា ម៉ា (Thvea Ma) នៅខេត្តត្បូង ឃ្មុំ ។ កាលពីនៅក្មេង ខ្ញុំបានទៅរកស៊ីចិញ្ចឹមជីវិត នៅខេត្តជើងព្រៃ ដែលមានជនជាតិស្ទៀងជាច្រើនបានរស់នៅទីនោះ ។ ខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយនារីស្ទៀងម្នាក់ ឈ្មោះ ខៀវ (Khiev) នៅភូមិពុយជ័យ " ។

"នៅមុនការបះបោររបស់ឈ្មោះ អា លាក់ (A Leac) ដែលបានយកគោរមងាវជាពោរកំបោ [៦] មានចៅហ្វាយខេត្តម្នាក់មានងារជាឧកញ៉ា រាជាចាំន សាន [៧] និង

(៤) / ឧកញ៉ាមន្ត្រី គឺជាងាររបស់មន្ត្រី ។ គិរីពុទ្ធបាទគឺជាឈ្មោះរបស់មណ្ឌលរដ្ឋបាលជាភាសាបាលីដែលប្រែថាជាភ្នំនៅជើងរបស់ព្រះ ។ នៅលើផែនទីដែលបាននិយាយពីមុនស្តីពីប្រទេសកម្ពុជាពាក្យនេះសរសេរថា : ភ្នំជើងព្រះ ។ នៅលើផែនទីដែលបាននិយាយពីមុនស្តីពីប្រទេសកម្ពុជាពាក្យនេះសរសេរថា : ភ្នំជើងព្រះ (ជាពាក្យរបស់ខ្មែរ ដែលមានន័យថា ភ្នំនៅជើងរបស់ព្រះ) ។

(៥) / នាយករដ្ឋមន្ត្រី ។

(៦) / ការបះបោរនេះបានកើតឡើងនៅឆ្នាំ ១៨៦៦–១៨៦៧ ។

(៧) / នៅទីនេះយើងមានងារដូចគ្នានឹងងាររបស់ចៅហ្វាយខេត្តតែនិញដែលជាមេគំនិតម្នាក់ដ៏សំខាន់នៅក្នុងការបះបោរនេះ ។



មានឈ្មោះថា ប៊ិន (Ben) ដែលបានទារពន្ធស្នែងរមាស ភ្លុកដំរី និងអាចម៍ល័ខ ដែលរស់នៅជើងម្តែង (Choeung - Modeng) ។ ដោយបានទទួលតំណែងពីរដ្ឋធានី លោកបានគ្រប់គ្រងជនជាតិស្ទៀងនៅខេត្តជើងព្រៃ ដែលមាន ៥៧ ភូមិ និងមានប្រជាជនប្រហែល ៥០០នាក់ ដែលបានរស់នៅ និងដែលស្ថិតនៅខាងក្រៅព្រំដែន កូសាំងស៊ីននោះ ពួកគេមិនដែលស្ថិតនៅក្រោមចំណុះពន្ធដារណាមួយរបស់កូសាំងស៊ីនឡើយ ។ កាលពីពេលមុន បើតាមទំនៀមទម្លាប់ពីសម័យបុរាណ ចៅហ្វាយខេត្តបាននាំយកសួយសារអាករទៅជូនលោក ឧកញ៉ា ភក្តី នាយក [៨] មន្ត្រីរបស់រដ្ឋធានីស្ថិតនៅក្រោមបញ្ជារបស់ឧកញ៉ា វាំង [៩] ។

"ឧកញ៉ា រាជា ចាំនសាន បេន បានតែងតាំងខ្ញុំជាឧកញ៉ាមន្ត្រី គិរីពុទ្ធបាទ បាឡាត់ [១០] នៅទ្វារ ហុច (Threa Hoch)" ។

"ចំណែកខ្ញុំ ឧកញ៉ា ប្រ៊ុង ភរិយាខ្ញុំឈ្មោះ នាង ស្វា (Zoi) ជាកូនប្រុសរបស់ឧកញ៉ា ភិត និងជីទាវនាង ខ្វា មានទីលំនៅ នៅភូមិពុយជរ។ ឧកញ៉ា រាជាចាំន សាន បានតែងតាំងខ្ញុំជាឧកញ៉ា ប្រ៊ុង គិរីពុទ្ធបាទនិងឧកញ៉ា ប្រ៊ុង មេស្រុក[១០ស្ទួន]របស់ជនជាតិស្ទៀង"។

"ទាំងពីរនាក់ (ឧកញ៉ា មន្ត្រី គិរីពុទ្ធបាទ នឹងឧកញ៉ាប្រ៊ុង ម្នាក់ជា បាឡាត់ ឯម្នាក់ទៀតជាមេស្រុក) យើងជាអ្នកទទួលបន្ទុក គាត់យកពន្ធដារ ដោយមានការព្រមព្រៀងគ្នាជាមួយឧកញ៉ា រាជា ចាំន សាន រហូតដល់មានការបះបោររបស់ឈ្មោះ អាលាក់ ហៅពោរកំបោ (ប្រហែលជាង៣៥ឆ្នាំ) " [១១] ។

"លោកឧកញ៉ា រាជា ចាំន សាន បានទទួលមរណភាព ជាបន្ទាប់មកហើយក៏ពុំមានចៅហ្វាយខេត្តទៀតឡើយ យើងបានបញ្ឈប់មកដល់ត្រឹមនេះ នូវមុខការរបស់យើង ដើម្បីទៅប្រកបការងាររកស៊ីចិញ្ចឹមជីវិតតទៅទៀត ។ ពួកស្ទៀងនៅគ្រប់ភូមិទាំងអស់ និងយើងបាននាំគ្នាធ្វើស្រែចំការ [១២] និងចំការពោត យើងបានរស់នៅដោយ

(៨) / ងាររបស់មន្ត្រី ។

(៩) / រដ្ឋមន្ត្រីព្រះបរមរាជវាំង ដែលទទួលបន្ទុកកាន់កាប់ហិរញ្ញវត្ថុក្នុងពេលជាមួយគ្នា ។

(១០) / ភូឈ្លួយ ។

(១០ស្ទួន) / មេឃុំ ។

(១១) / គឺចាប់តាំងពី ៣២ឆ្នាំ ។

(១២) / ចំការ ។

ស្ងប់ស្ងៀម និងដោយឯករាជ្យចាប់តាំងពីយូរឆ្នាំមកហើយ នៅក្នុងខេត្តជើងព្រៃ ។

"ប៉ុន្តែចាប់តាំងពីពីរ ឬបីឆ្នាំមក មានប្រជាជនឡាវមកតាំងទីលំនៅ នៅក្នុងខេត្តរបស់យើង ហើយដែលបានសង្កត់សង្កិនយើងដោយប្រព្រឹត្តនូវអំពើហិង្សាប្រឆាំងនឹងយើង។ ពួកឡាវបានបាញ់កាំភ្លើងមកលើយើង ពួកឡាវបានចាប់យើងយកប្រពន្ធកូនយើង ។ តើជនជាតិស្ទៀងប៉ុន្មាននាក់ទៅដែលត្រូវបានគេជិះជាន់សង្កត់សង្កិននិងមិនសប្បាយចិត្តនោះ ។ ពួកគេមិនដឹងថា តើត្រូវសុំទៅអ្នកណា ដើម្បីឲ្យជួយការពារនោះទេ ។

"ឧកញ៉ាទាំងពីរនាក់ បានស្គាល់មនុស្សម្នាក់ឈ្មោះ ពញា ម៉ុញ (Monh) កើតនៅឆ្នាំឆ្លូវអាយុ ៥៨ឆ្នាំ ភរិយាឈ្មោះ នាង ម៉ុក មានកូនបីនាក់ មានទីលំនៅ នៅភូមិបាទិ ខេត្តស៊ិធរកណ្ដាល [១៣] ជាកូនរបស់លោក ពញា រស់ និង នាង ច្រិម ជនជាតិកម្ពុជា ដែលមានទម្លាប់ទៅរកស៊ីនៅក្នុងខេត្តជើងព្រៃ ។ យើងបានស្រឡាញ់គាត់និងពួកគេទាំងអស់គ្នា ហើយយើងបានស្នើសុំឲ្យ ឈ្មោះ រាជា ចាំន សាន ធ្វើចៅហ្វាយខេត្តនៅខេត្តរបស់យើង ។ លោកក៏បានស្នាក់នៅគ្រប់គ្រងយើងនិងផ្ដល់ដល់យើងទាំងអស់គ្នានូវក្ដីសុខសាន្ត និងភាពស្ងប់ស្ងៀម ។

"ដូច្នេះយើងបានសម្រេចដាក់ជូនទៅរដ្ឋាភិបាល ទោះជាយើង ជិទាស់ទៅនឹងថ្នាំងដៃរបស់យើងក៏ដោយ (thnang - day [១៤] ។ "ភូមិទាំង៥៧ គឺ..." (មើលតាមឈ្មោះនៃភូមិទាំងនេះ)" ។

### ៣ – ការរាវរករបស់អាជ្ញាធរបារាំង

ពាក្យបណ្ដឹងស្នើសុំនេះ ត្រូវបានបញ្ជូនទៅឲ្យលោក រ៉េស៊ីដង់ នៃប្រទេសបារាំង នៅខេត្តកំពង់ចាម ពិនិត្យ ។ លោករ៉េស៊ីដង់នេះ នៅក្នុងលិខិតរបស់លោក ចុះថ្ងៃទី២៥ ឧសភា ១៨៩៨ ដែលផ្ញើទៅជូនលោក រ៉េស៊ីដង់ ជាន់ខ្ពស់នៃប្រទេសកម្ពុជា បានឆ្លើយតបដូចតទៅនេះ :

"ប៉ុន្តែ ចំពោះតំបន់ ដែលគាត់បាននិយាយ នៅក្នុងពាក្យបណ្ដឹងសុំនេះ គឺស្ថិតនៅ

*(១៣) / នៅក្នុងខេត្តព្រៃវែង ។*
*(១៤) / ស្នាមម្រាមដៃ ។*



ខាងត្បូងទន្លេចាម រវាងផ្លូវទឹកនេះ និង សុងបែ (Song - Bé ) ខ្ញុំមិនអាចធ្វើនូវសេចក្ដីស្នើណាមួយចំពោះលោកបានឡើយ" ។

"ប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងតំបន់នោះ ហាក់ដូចជាមិនសូវបានគេយកចិត្តទុកដាក់ជាយូរឆ្នាំមកហើយ ក្រុមមនុស្សប្រព្រឹត្តអំពើអាក្រក់ដែលបានរកឃើញដីល្អបានទាក់ទាញការយកចិត្តទុកដាក់របស់អ្នកគ្រប់គ្រងនៅ តៃ និញ និង ធូ យ៉ូវម៉ុត ជាច្រើនលើក ហើយនៅក្នុងឆ្នាំ ១៨៩៥ (ខ្ញុំជឿ) កូសាំងស៊ីន បានចាត់ទុកប្រជាជនទាំងនេះជាប្រជាជនឯករាជ្យ និងបានដាក់បញ្ចូលជាឧបសម្ព័ន្ធទៅក្នុងនិគម ធូ យ៉ូវម៉ុត និងបានរៀបចំទៅជាស្រុក" ។

"ការបញ្ចូលជាបក្សសម្ព័ន្ធ ទៅក្នុងកូសាំងស៊ីន ប្រហែលជាមិនបានផ្ដល់ទៅឲ្យអ្នកស្រុកនូវសន្តិសុខដែលពួកគេមានសិទ្ធិរង់ចាំនោះទេ ពីព្រោះពួកគេតែងតែត្អូញត្អែរថាមិនត្រូវឲ្យមានការគ្រប់គ្រងដូច្នេះទេ..." ។

"ប្រហែលជា សម្រាប់ប្រទេសកម្ពុជា ដែលប្រជាជនមានសភាពដូចគ្នា ច្រើនជាងជាតិសាសន៍អណ្ណាម ជាមួយនឹងតំបន់ដែលត្រូវបានដាក់បញ្ចូលជាឧបសម្ព័ន្ធដោយកូសាំងស៊ីននូវឱកាសអនុគ្រោះមួយ ដើម្បីទាមទារនូវសិទ្ធិរបស់ខ្លួនដែលគេមិនទទួលស្គាល់នោះ" ។

## អនុផ្នែកទី ២
## ដំណាក់កាលទីពីរ (១៨៩៣)
## អនិត្យានុកូលភាព
## នៃ រដ្ឋការ កូសាំងស៊ីន
## និងការតស៊ូ របស់កម្ពុជា
## ទាសនានៃស្រុក ឡុក និញ និង តៀក ឡេ

### ១ – អនុក្រឹត្យរបស់ទេសាភិបាល កូសាំងស៊ីន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ១៨៩៣ (ឧបសម្ព័ន្ធ ៦)

ដើម្បីឲ្យសច្ចាប័ននូវការបញ្ចូលជាឧបសម្ព័ន្ធ នូវសង្កាត់ទាំងឡាយរបស់កម្ពុជា ដែលស្ថិតនៅខាងត្បូង នៃព្រំដែនដែលមាននៅលើផែនទី ឆ្នាំ ១៨៩០ ទេសាភិបាលកូសាំងស៊ីន បានប្រកាន់យកជាឯកតោភាគី នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៨៩៣ [១៥] នូវអនុក្រឹត្យមួយដែលបានកំណត់នៅក្នុងមាត្រាទីមួយរបស់ខ្លួនថា "ស្រុកកម្ពុជានៅ ថាញ់ អាន (Thanh-An) ស្រុក តាមួន និងកម្ពុជា នៅ គូវ អាន (Cuu-An) សង្កាត់ទាំងឡាយរបស់ជនជាតិ Moïs នៅមិញ ង៉ាយ (Minh - Ngai) និង ក្វាងឡើយ (Quang Loi) ហើយនិងស្រុកស្ទៀង នៅ ឡុក និញ (Loc - Ninh) និង ភឿកឡេ (Phuoc - Lê) ដែលបានប្រមូលផ្តុំទៅជា "huyen មួយដែលត្រូវបានកំណត់នៅក្រោមឈ្មោះថា ជា huyen នៃកានឡេចៀម (Can-Les-Chiam)" ។ ប៉ុន្តែអនុក្រឹត្យចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៨៩៣ ដែលបានប្រមូលផ្តុំទៅជា Huyen មួយនៃ "កាន់-ឡេ-ចៀម" នោះ មិនគ្រាន់តែជាស្រុករបស់កម្ពុជានៅ ថាញ់ អាន ស្រុកកម្ពុជា និងតាមួន (Tamoun) នៅ គូវ អាន ហើយនិងសង្កាត់ទាំងឡាយដែលគេសន្មតថា ជារបស់ជនជាតិស្ទៀង នៅមិញ ង៉ាយ និងនៅ ក្វាង ឡើយ ដែលផែនទីទាំងឡាយនៅឆ្នាំ ១៨៩០ ត្រូវបានដាក់ដោយរំលោភទៅនៅខាងត្បូងព្រំដែន នៅក្នុងទឹកដីកូសាំងស៊ីន ប៉ុន្តែនៅមានសង្កាត់ពីរផ្សេងទៀត គឺ ស្រុក ឡុក និញ និង ភឿក ឡេ (Phuoc Lê) ដែលនៅលើផែនទីដូចបានរៀបរាប់មកហើយបានគូរដូចជាផ្នែករួមបញ្ចូលនៃប្រទេសកម្ពុជា ។

ដូច្នេះ តាមអនុក្រឹត្យចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៨៩៣ ទេសាភិបាលកូសាំងស៊ីន បានប្រកាន់យកនូវសេចក្តីសម្រេចមួយដែលទាក់ទងទៅនឹងទឹកដីដែលនៅក្នុងនោះលោកពុំមានសមត្ថកិច្ចនោះ ។

យើងហាក់ដូចជាថា វាពុំមានប្រយោជន៍នោះទេ ដើម្បីស្រាវជ្រាវរកឲ្យស្គាល់នូវមូលហេតុ និងកាលៈទេសៈនៃការបញ្ចូលជាឧបសម្ព័ន្ធនេះ និងផលវិបាកទាំងឡាយរបស់ខ្លួននោះ ។

## ២ – មូលហេតុនៃការធ្វើអនុក្រឹត្យនេះ លក្ខណៈនៃការរំលោភរបស់វា

យើងនឹងពិនិត្យមើល នៅក្នុងដំណាក់កាលពីរ : មុនដំបូងសម្រាប់ស្រុក បួន ដែល

*(១៥) / JOI ឆ្នាំ ១៨៩៣ ទំព័រ ៧៤២ ។*



ស្ថិតនៅខាងត្បូងព្រំដែន នៅឆ្នាំ ១៨៩០ បន្ទាប់មកទៀត គឺសម្រាប់ស្រុកពីរទៀត (ឡុក និញ និង ភឿក ឡេ) ។

### I.- សម្រាប់ស្រុកបួន ដែលស្ថិតនៅខាងត្បូងព្រំដែននៅឆ្នាំ ១៨៩០

ចាប់តាំងពីឆ្នាំ ១៨៦២ មក រដ្ឋាភិបាលកូសាំងស៊ីន ត្រូវបានគេចាប់អារម្មណ៍លើធនធានព្រៃឈើ ដែលមាននៅក្នុងតំបន់ បារៀ និង បៀនហ្វា ។ នៅដើមឆ្នាំ ១៨៦២ [១៦] បេសកកម្មមួយដែលបញ្ជាដោយអនុសេនីយ៍ឯក កងកាំភ្លើងធំ ត្រូវបានចាត់តាំងឡើង ដើម្បីទៅពិនិត្យឲ្យស្គាល់ព្រៃឈើនៅខេត្តទាំងពីរនេះ ។

បេសកកម្មនេះ បានធ្វើដំណើររុលទៅមុខរហូតដល់ធូយ៉ូវម៉ូត និងបានចង្អុលបង្ហាញអំពីសារសំខាន់ដ៏ធំ នៃ "ភាពសម្បូរណ៍បែបខាងព្រៃឈើនៅក្នុងប្រទេស" ។ ប៉ុន្តែវាបានទាក់ទាញជាពិសេសនូវការយកចិត្តទុកដាក់របស់អាជ្ញាធរទៅលើអត្ថិភាពព្រៃឈើដែលមានច្រើនបំផុត និងមានលក្ខណៈងាយស្រួលបំផុត ក្នុងការធ្វើអាជីវកម្ម នៅធូយ៉ូវម៉ូត ជាងនៅបារៀ និងនៅបៀនហ្វា ។ បេសកកម្មនេះ បានសន្និដ្ឋានថា : "ប៉ុន្តែមានផលប្រយោជន៍ដ៏ធំមួយបានភ្ជាប់ទៅនឹងការរុករកមួយនៅលើព្រៃទាំងនេះត្រូវបានធ្វើឡើង នៅខាងផ្នែកនៃទន្លេ ធូ យ៉ូវ ម៉ូត (Thudaumot) ដែលឈើត្រូវបានដឹកតាមនោះព្រោះថាព្រៃទាំងនេះមានដើមឈើជាច្រើនដែលគេហៅថា ដើម Go និងដើម Sao ដែលជាដើមឈើផ្តល់ប្រេងដ៏ល្អបំផុត និងប្រើប្រាស់បានគ្រប់មុខ" ។

ទេសាភិបាលកូសាំងស៊ីន ដោយចាប់អារម្មណ៍ខ្លាំងទៅលើព័ត៌មាននៅក្នុងរបាយការណ៍នេះបានបញ្ជូនរបាយការណ៍នេះទៅក្រសួងជើងទឹក ដោយបានបន្ថែមយោបល់របស់លោកថា ដើម្បីអាចធ្វើអាជីវកម្មព្រៃទាំងនេះបាននោះ គឺត្រូវរៀបចំឲ្យមានសន្តិភាពឲ្យបានឆាប់រហ័ស បើមិនអ៊ីចឹងទេ ការធ្វើអាជីវកម្ម នឹងប្រព្រឹត្តទៅបាននៅក្នុងភាពរដាក់រដុបតែប៉ុណ្ណោះ នៅកូសាំងស៊ីន មានកំណប់កប់លាក់ទុកចោលឥតប្រយោជន៍ ប៉ុន្តែគេត្រូវតែចំណាយសោហ៊ុយ ដើម្បីដាក់ធ្វើអាជីវកម្មវា [១៧] ។

ដូច្នេះ វាហាក់ដូចជាថា ភាពសម្បូណ៌ នៃធនធានព្រៃឈើទាំងនេះ គឺជាមូលហេតុមួយនៃការធ្វើដំណើរទៅមុខរបស់ អាជ្ញាធរកូសាំងស៊ីន ឆ្ពោះទៅតំបន់ទាំងនេះ ។

*(១៦) / របាយការណ៍រុករកព្រៃនៅបៀនហ្វា ថ្ងៃទី៣០ ខែមីនា ១៨៦២ Indo Chine A 30 (៣) ។*
*(១៧) / សេចក្តីសង្កេតរបស់ទេសាភិបាលកូសាំងស៊ីនទៅលើរបាយការណ៍បេសកកម្មដែលបានរៀបរាប់ពីមុន ។*

ចំពោះបញ្ហានេះ គេត្រូវបន្ថែមអំពីបំណងរបស់ពួកគេ ដែលបានសម្តែងចេញ នៅក្នុងពេលប្រតិបត្តិការបោះគោលដី នៅតែនិញ ដើម្បី "ស្ថិតនៅទាក់ទងជានិច្ចជាមួយជនជាតិភាគតិចម៉ុយ (Moïs) ។

## II. - សម្រាប់ទឹកដី ដែលស្ថិតនៅខាងជើងព្រំដែន នៅឆ្នាំ ១៨៩០

**ក/ –** បំណងដើម្បីសម្រួលការកសាងផ្លូវថ្នល់ពីធូយ៉ូវម៉ូតទៅក្រចេះ ។ សូមរំលឹក ថា បេសកកម្មរុករកទន្លេមេគង្គនៅឆ្នាំ១៨៦៨ បានស្នើឡើងពីការសាងសង់ផ្លូវមួយ តភ្ជាប់សាយហ្គន ទៅប្រទេសលាវខាងត្បូង ។

ផ្លូវថ្នល់នេះ គឺអគ្គទេសាភិបាល de lanessan បានឲ្យសាងសង់នៅឆ្នាំ ១៨៩៣ ។ ប៉ុន្តែការងារសាងសង់ មានជួបការលំបាកនៅលើទឹកដីកម្ពុជា ការលំបាកជាសំខាន់ទំនងរវាងទន្លេមេគង្គក្រោម និងទន្លេមេគង្គលើ ខ្ញុំបានឲ្យគេកសាងផ្លូវថ្នល់មួយចេញពីធូយ៉ូវម៉ូត នៅកូសាំងស៊ីន ទៅដល់ក្រចេះ ។ ផ្នែកដែលស្ថិតនៅលើទឹកដីកូសាំងស៊ីនត្រូវបានសាងសង់រួចហើយ ។ វានៅតែពុំទាន់មានស្ពាននៅឡើយ ។ គេបានសាងសង់ផ្នែកទាំងឡាយដែលស្ថិតនៅលើទឹកដីកម្ពុជា ។ ខ្ញុំបានធ្វើការសិក្សានូវផ្លូវមួយទៀតដែលចេញពីក្រចេះទៅខេត្តស្ទឹងត្រែង ប៉ុន្តែនៅលើទឹកដីកម្ពុជាកម្រមានប្រជាជនណាស់ដូច្នេះមានការលំបាកខ្លាំងណាស់ ក្នុងការរកកម្លាំងពលកម្មសម្រាប់ធ្វើការងារនេះ" (១៨) ។

ដើម្បីជំនះពុះពារការលំបាកទាំងនេះ លោកអធិការ Outrey នៅធូយ៉ូវម៉ូត ត្រូវបញ្ជូនភ្នាក់ងារបារាំង នៅកូសាំងស៊ីនឲ្យធ្វើកំណែនកម្លាំងពលកម្មនៅកម្ពុជា ។ ប៉ុន្តែរដ្ឋការ កូសាំងស៊ីន មិនចង់បានរបៀបធ្វើកំណែនទាំងនេះទេ ។ កូសាំងស៊ីនបានចាត់ចែងឲ្យបញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីខ្មែរ ។ នេះគឺជាសក្ខីកម្មទាំងឡាយរបស់លោក រ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជាចំពោះបញ្ហានេះ (១៩) "នៅខាងផ្នែកនៃមណ្ឌលធូយ៉ូវម៉ូត ការទន្ទ្រានយកទឹកដីនៅតែមានសភាពខ្លាំងក្លានៅឡើយ ។ នៅខាងផ្នែកនេះ

*(១៨) / លិខិតរបស់អគ្គទេសាភិបាល de lanessan ចុះថ្ងៃ ៩-៦-១៨៩៣ ផ្ញើទៅជូនអនុរដ្ឋលេខាធិការអាណានិគម សៀម ៤២ ។*

*(១៩) / លិខិតរបស់លោករេស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជាផ្ញើទៅឲ្យទេសាភិបាលកូសាំងស៊ីនចុះកាលបរិច្ឆេទ ឆ្នាំ ១៨៩៥ ។*



ព្រំដែននៃប្រទេសកម្ពុជា បានស្ថិតនៅក្រោមការកំណត់ដោយបន្ទាត់ត្រង់មួយចេញពីបង្គោលមួយ ដែលស្ថិតនៅត្រើយខាងស្តាំនៃទន្លេទ្រូ (Tonlé Trou) (២០) នៅជិតនិងខាងក្រោមមាត់ពាម ព្រែកព្រាល និងកំពូលនៃភ្នំជិន (២១) ។

នៅក្នុងឆ្នាំ ១៨៩៣ នៅក្នុងពេលសាងសង់ផ្លូវថ្នល់ ពីក្រចេះទៅ ធូយ៉ូវម៉ូត លោកអភិបាល Outrey បានបញ្ជូននូវភ្នាក់ងារបារាំងនិងភ្នាក់ងារក្នុងស្រុកជាច្រើននាក់ នៅក្នុងភូមិទាំងឡាយរបស់កម្ពុជា និងជនជាតិស្ទៀង ដោយមានបេសកកម្មស្វែងរកដោយគ្រប់មធ្យោបាយឲ្យបានកម្មករជាច្រើននាក់ ដែលពួកគេត្រូវការ ។ ពួកអ្នកស្រុកដែលនៅតាមភូមិទាំងឡាយ ដែលស្ថិតនៅក្នុងរង្វង់ទឹកដី ចម្ងាយពី ២៥ ទៅ ៣០ គ.ម បានធ្វើការសាងសង់ផ្លូវថ្នល់ក្នុងរយៈពេល៣ខែ ប៉ុន្តែគ្មានអ្នកណាម្នាក់បានទទួលប្រាក់ខែឡើយ ដូច្នេះពួកគេទាំងអស់គ្នា បានបោះបង់ចោលការងារ និងរត់ចេញពីការដ្ឋាន ។ ដើម្បីសម្រួលភារកិច្ចរបស់ភ្នាក់ងាររបស់ខ្លួន អភិបាលនៅធូយ៉ូវម៉ូត បានកោះប្រជុំនៅឆ្នាំ១៨៩៤ (ដែលមិនបានធ្វើនៅក្នុងឆ្នាំ១៨៩៣) នូវប្រធានភូមិសំខាន់ៗទាំងឡាយ ដើម្បីដាក់ឲ្យពួកគេស្ថិតនៅក្រោមអំណាចរបស់ភូ (២២) ទៅតាមជម្រើសរបស់ខ្លួន ។ម្យ៉ាងទៀត លោកបានតែងតាំងមន្ត្រីក្នុងស្រុកដទៃទៀត និងបានរៀបចំទៅជា huyen ដែលបាន ឈ្មោះថា ប៊ិន ឡាយ គឺជាទឹកដីរបស់កម្ពុជាដោយសុទ្ធសាធ ។

"ហើយបញ្ហានេះ មិនបានធ្វើឲ្យលោក ឡើង ឆ្ងល់ ច្រើននោះទេ លោក ភូ ឈួយ ទេសាភិបាល ខ្ញុំបានបន្ថែមថា ភូ នេះត្រូវបានចូលកាន់ការងារយ៉ាងឆាប់រហ័ស ដោយពួកអ្នកនៅក្រោមការត្រួតត្រាថ្មីរបស់ខ្លួន នូវចំនួនទឹកប្រាក់ដែលមានការផ្លាស់ប្តូរញឹកញាប់ពី ១០ ទៅ ៦០ ញ៉ាស្ត្រ ក្នុងភូមិមួយ ។..." ។

ហេតុដូច្នេះ បន្ទាប់ពីព័ត៌មានទាំងឡាយ ដែលផ្តល់ឲ្យដោយលោក រ៉េស៊ីដង់ ជាន់ខ្ពស់នៅកម្ពុជា ការបារម្ភរបស់អ្នកគ្រប់គ្រងអភិបាលOutreyនៅធូយ៉ូវម៉ូត ដើម្បីអាចជ្រើសរើសដោយងាយស្រួលពួកអ្នកស្រុក ដែលរស់នៅក្នុងទឹកដីកម្ពុជា ដើម្បីកសាង

*(២០) / ឈ្មោះនៃផ្លូវទឹកនេះ ជួនកាលសរសេរថា ទន្លេជ្រៅ ជួនកាលថា ទន្លេទ្រូ ។ ការខុសគ្នានេះ គឺមកពីការចម្លងមិនត្រូវ ។ ឈ្មោះពិតប្រាកដគឺទន្លេជ្រៅ ។*

*(២១) / គឺព្រំដែនដែលមានចុះនៅក្នុងផែនទីឆ្នាំ ១៨៩០ ។ ឈ្មោះនៃភ្នំនេះសរសេរថា ភ្នំ ភូ ជិន ។*

*(២២) / ឈ្មោះអណ្ណាម ដែលមានន័យថា ជាងាររបស់ចៅហ្វាយខេត្ត ។*

ផ្លូវថ្នល់ដែលបាននាំឲ្យទេសាភិបាលកូសាំងស៊ីនបញ្ចូលជាឧបសម្ព័ន្ធនូវសង្កាត់ទាំងពីររបស់ខ្មែរ ។

**១/** – ចន្ទះដើម្បីពង្រីកទឹកដីនៃលក្ខន្តិកៈ អាណានិគមនៅកូសាំងស៊ីន ប៉ុន្តែវាមិនទាន់អស់នៅឡើយទេ ដើមកំណើតនៃការបញ្ចូលជាឧបសម្ព័ន្ធនេះ វាមានមូលហេតុមួយផ្សេងទៀត គឺបំណងប្រាថ្នារបស់លោក អគ្គទេសាភិបាល ដើម្បីពង្រីកទឹកដីកូសាំងស៊ីន ឲ្យទៅជាខេត្តមួយរបស់បារាំង ។ ដើម្បីបញ្ជាក់នូវការអះអាងនេះ វាជាការ ចាំបាច់ដើម្បីលើកឡើង ចំពោះយើងនូវសក្ខីភាពទាំងឡាយរបស់ទេសាភិបាលកូសាំង ស៊ីន ។ នៅឆ្នាំ ១៨៩៣ ការងារសាងសង់ផ្លូវថ្នល់ពី ធូយ៉ូវម៉ុត ទៅក្រចេះ បាននាំរដ្ឋការ (កូសាំងស៊ីន) ឲ្យដូចទៅខាងនាយព្រំដែន ដែលបានចង្អុលបង្ហាញខាងលើបំផុត (គឺថាព្រំដែនដែលបានកំណត់នៅលើផែនទីឆ្នាំ ១៨៩០) ។

"ការរៀបចំនូវផ្លូវថ្នល់នេះ ត្រូវបានសម្រេចដោយលោកអគ្គទេសាភិបាល de Lanessan ដែលលោកចង់ឃើញនូវអ្វីដែលបានប្រព្រឹត្តទៅនៅឯនាយព្រំដែនរបស់យើងនិងបានពោលអះអាងនៅក្នុងប្រទេសនេះអំពីអំណាចរបស់យើងចំពោះលក្ខណៈខ្វះយ៉ាំងប្រត្យក្ស...។

"គំនូសដែលបានសិក្សានិងយកជាការបាន ព្រមទាំងឥណទានត្រូវបានបើកចំហផង នោះ គេក៏បានចាប់ផ្តើមអនុវត្តការងារ ហើយប៉ុន្មានអាទិត្យក្រោយមក គេបានទៅដល់ព្រំដែនខាងជើងនៃមណ្ឌល ធូយ៉ូវម៉ុត ដែលចង្អុលបង្ហាញដោយបង្គោលលេខ ១ ដែលត្រូវបានគាស់យកចេញដោយភ្នាក់ងារម្នាក់របស់យើង ទៅតាមបញ្ជារបស់ លោក Outrey ប្រធានមណ្ឌល ។

"តាមព័ត៌មានដែលប្រមូលបាន លោកអភិបាលនេះត្រូវបានអនុញ្ញាតឲ្យដកយកចេញនូវបង្គោលនេះ ដោយលោក de lanessan ដែលបាននិយាយនៅកន្លែងនោះតែម្តងថា កន្លែងនៃបង្គោលនេះ គឺស្ថិតនៅខាងនាយ Can - Lé - Chiam (ទន្លេចាម)[២៣] " ។ តើគេត្រូវទន្ទេញនូវផ្នែកដែលបានរៀបរាប់មកហើយ នៅក្នុងលិខិតនេះយ៉ាងដូចម្តេច ? ដូចដែលបានចង្អុលបង្ហាញដោយលោក រ៉េស៊ីដង់ ជាន់ខ្ពស់នៃប្រទេស

**(២៣) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៨៩៥ ផ្ញើទៅជូនអគ្គទេសាភិបាលឥណ្ឌូចិន ។**



កម្ពុជារួចមកហើយថា មុនអ្វីៗទាំងអស់ ព្រំដែនខាងជើង ធូយ៉ូវម៉ុត ត្រូវបានចង្អុលបង្ហាញដោយបង្គោលលេខ ១ ។

ហើយហេតុការណ៍នេះ មិនមែនមានតែទេសាភិបាលកូសាំងស៊ីនតែម្នាក់ឯងដែលបានទទួលស្គាល់នោះទេ គឺលោកបានសរសេរនៅក្នុងកំណត់ហេតុឆ្នាំ ១៨៧០ជាអក្សរទាំងអស់ថា "បង្គោលដែលបាននិយាយនេះត្រូវតែបានប្រើប្រាស់ ដើម្បីកំណត់ព្រំដែនខាងជើងនូវទឹកដីទាំងឡាយដែលបារាំងកាន់កាប់" ។ ការចង្អុលបង្ហាញនេះត្រូវបានបញ្ជាក់ដោយផែនទីនានា ដែលបានរៀបចំឡើង នៅក្នុងឆ្នាំ ១៨៩០ ។ ដោយហេតុថា ព្រំដែនបានភ្ជាប់បង្គោលលេខ ១ ទៅភ្នំភូដិន នោះ ស្រុកឡុកនិញ និង ភឿក ឡេ គឺស្ថិតនៅក្នុងទឹកដីកម្ពុជា ។

១-ទីពីរ ការដកចោលបង្គោលលេខ ១ ត្រូវបានសម្រេចជាឯកតោភាគី ដោយអគ្គទេសាភិបាល de lanessan ដើម្បីអាចដាក់ឲ្យប្រតិបត្តិនូវបំណងរបស់លោកក្នុងការពង្រីកនៃការធ្វើឲ្យខូចប្រយោជន៍ដល់ទឹកដីកម្ពុជា ។

នៅចំពោះមុខភាពជាក់ស្តែងនេះ ទេសាភិបាលកូសាំងស៊ីនត្រូវតែសុខចិត្តទទួលសារភាព។ លោកបានសរសេរលិខិតទៅលោក អគ្គទេសាភិបាលដូច្នេះថា "ជាការសង់ស៊ឹកទៅនឹងការទទួលសារភាពរបស់លោកអភិបាលនៅ ធូយ៉ូវម៉ុត នូវការបំបាត់ចោលនូវបង្គោលទាំងឡាយ ដែលធ្វើដោយរំលោភនោះ នឹងបានធ្វើឲ្យមាននៅក្នុងទឹកដីកូសាំងស៊ីននូវសង្កាត់ជនជាតិ Moïs ពីរដែលជារបស់កម្ពុជាដោយពិតប្រាកដ ។[២៤]" ។

សង្កាត់ Moïs ឬក៏សង្កាត់កម្ពុជា ? ដើម្បីដោះស្រាយបញ្ហានេះ យើងជឿថា យើងអាចអំពាវនាវរករបាយការណ៍របស់អ្នក វេខាគណិតដើម គឺលោក Girardin ប្រធានផ្នែកសុរិយោដី នៃប្រទេសកម្ពុជា ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៨៩៥ ដែលពាក្យទាំងនោះផ្ទាល់ត្រូវបានគេយកទៅសរសេរឡើងវិញ នៅក្នុងលិខិតដែលបានរៀបរាប់ពីមុន (Supra note 19) របស់លោក រ៉េស៊ីដង់ ជាន់ខ្ពស់ដែលផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន ។

**(២៤) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ១៨៩៥ ផ្ញើទៅជូនអគ្គទេសាភិបាលឥណ្ឌូចិន ឥណ្ឌូចិន ឥណ្ឌូន A . 20 (៤២) ។**

"នៅឆ្នាំ ១៨៩៣ នៅក្នុងពេលស្ថាបនាផ្លូវថ្នល់ លោកអភិបាល Outrey បានបញ្ជូនភ្នាក់ងារបារាំង និងប្រជាជនកើតក្នុងស្រុកជាច្រើននាក់ នៅក្នុងភូមិកម្ពុជា និងភូមិស្ទៀងទាំងឡាយ ដើម្បីយកកម្មករជាចាំបាច់សម្រាប់សាងសង់ផ្លូវថ្នល់ ។ ភូមិទាំងអស់នៅក្នុងរង្វង់កាំចម្ងាយពី ២៥ ទៅ ៣០ គ.ម នៅខាងស្ដាំ និងនៅខាងឆ្វេង បានធ្វើការរយៈពេល២ ខែនៅឆ្នាំ ១៨៩៣ និង៤០ ថ្ងៃនៅឆ្នាំ ១៨៩៤ ។ ពុំមានកម្មករណាម្នាក់បានទទួលប្រាក់ឡើយ លោកអភិបាល ធូយ៉ូវម៉ូត ដើម្បីសម្រួលការងារឲ្យភ្នាក់ងាររបស់ខ្លួនបានប្រមូលផ្ដុំនៅក្នុង ឆ្នាំ ១៨៩៤ (ការពិតគឺនៅក្នុងឆ្នាំ ១៨៩៣ ) នូវប្រធានភូមិ នៃភូមិដ៏សំខាន់បំផុតទាំងឡាយ និងបានដាក់ឲ្យនៅក្រោមអំណាចរបស់ Huyenមួយ......(ស្រុក១).....................ស្រុកកម្ពុជា បានយកឈ្មោះថា ប៊ិញ ឡាយ ។ នៅដំណាច់ឆ្នាំ ១៨៩៤ Huyen បានឲ្យភូមិផ្សេងៗដាក់ចំនួនដែលមានការផ្លាស់ប្ដូរជាញឹកញាប់ពី ១០ ទៅ ៦០ ញ៉ាស្រ្ត ក្នុងមួយភូមិ ។

"យ៉ាងនេះគឺមានលទ្ធភាពថា ពួកជនអន្តោគ្រាម នៅតាមទេសភូមិ (Contrée) ទាំងនេះនឹងបោះបង់បោលភូមិរបស់ពួកគេ ដើម្បីដកថយទៅទិសខាងកើត បើសិនជាពួកគេនៅតែធ្វើការសាងសង់ផ្លូវថ្នល់នៅក្នុងលក្ខខណ្ឌទាំងឡាយដែលដូចគ្នា ។

**"ឈ្មោះភូមិសំខាន់ៗ :"**

– តាទៀត (Ta Teat) កម្ពុជា ១០ គ្រួសារ
– ចាំផ្ដៅ (Cham Phdau) កម្ពុជា ១០ គ្រួសារ
– ក្រៀល (Kreal) កម្ពុជា ១៥ គ្រួសារ
– ត្រី ដែង (Trey Deng) កម្ពុជា ២០ គ្រួសារ
– ស្រែ ចាម (Srè Cham) កម្ពុជា ៣០ គ្រួសារ
– ទន់ ជីល (Ton Chil) កម្ពុជា ៣៥ គ្រួសារ
– ម៉ុក សៀរ (Moc Sir) ស្ទៀង ៣០ ទៅ ៤០ គ្រួសារ
– បា ខ្លង (Ba Khlong) កម្ពុជា ២០ គ្រួសារ
– ង៉ួន (Nguon) ស្ទៀង ៤០ គ្រួសារ
– ឡុម ពុយ (Lom Puy) កម្ពុជា ២៥ គ្រួសារ



– ជុង រាក់ (Chung Reak) កម្ពុជា ៣០ គ្រួសារ
– ប៉ូ តាម (Po Tam) ស្ទៀង ១៥ គ្រួសារ
– ចាម៉ាត (Chamat) ស្ទៀង ៤០ គ្រួសារ
– ច្រឡិច (Chralech) ស្ទៀង ១៥ គ្រួសារ
– ចារ៉ាម (Charam) ស្ទៀង ១៨ គ្រួសារ
– បូនួយ (Bonui) ស្ទៀង ១០ គ្រួសារ
– ណែរ (Ner) កម្ពុជា ១៥ គ្រួសារ
– ស្នួល (Snoul) កម្ពុជា ៣០ គ្រួសារ
– សំរាំង (Sam Rang) កម្ពុជា ១២ គ្រួសារ

នៅតាមភូមិទាំង ១៩ ដែលបានរៀបរាប់ដោយអ្នករេខាគណិត Girardin គឺមានភូមិស្ទៀងចំនួនតែ ៧ ភូមិប៉ុណ្ណោះ ដែលដំណាងឲ្យប្រហែល ១/៣ ។

តាមការពិត ការបញ្ចូលជាឧបសម្ព័ន្ធនូវសង្កាត់ទាំងឡាយរបស់កម្ពុជា គឺមានទំនោរទៅរកគោលដៅដាក់ជាក់លាក់ ពួកគេត្រូវការ :

– ឲ្យមានមនុស្សក្នុងមួយលើក ១០ នាក់ "ដែលនឹងត្រូវបានផ្ដាច់ចេញដូចជាទាហាននៅប៉ុស្តិ៍ត្រួតពិនិត្យ នៅ Can - Le - Chiam" (មាត្រា២ នៃអនុក្រឹត្យចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៨៩៣) ។

– "ធ្វើការជម្រះស្មៅ និងជួសជុលផ្លូវថ្នល់ពីក្រចេះ ចាប់ពី ចុន ថាញ់ (Chon Thanh) រហូតដល់ព្រែកជ្រីវ (Prec Chrieu) " ដើម្បីជាការទូទាត់សងការខូចខាតនៃការអនុញ្ញាតឲ្យរួចពីពន្ធដារទាំងអស់ (មាត្រា៣) ។

**៣ – ផលវិបាកនៃការបញ្ចូលជាឧបសម្ព័ន្ធ : ការចលាចល**

ការបញ្ចូលជាឧបសម្ព័ន្ធនេះបានបណ្ដាលឲ្យមានផលវិបាកខាងនយោបាយយ៉ាងធ្ងន់ធ្ងរ ដោយហេតុថា ពួកអ្នកស្រុកនៅក្នុងតំបន់បានបដិសេធការភ្ជាប់ទៅជាមួយកូសាំងស៊ីន ។

ទេសាភិបាល កូសាំងស៊ីន បានឲ្យសញ្ញាដល់ទេសាភិបាលឥណ្ឌូចិនថា "ការលំបាកទាំងឡាយ និងឧបទ្ទវហេតុនានានៃបញ្ហាព្រំដែន ជាមួយប្រទេសកម្ពុជាបានឡើងទៅ

ដល់ការអនុវត្តន៍នៃអនុក្រឹត្យនេះ និងបានកើនឡើង...។ ការប្តឹងផ្តល់ ឬការទាមទារ ដែលទទួលបានពីតៃ និញ និងធូយ៉ូវម៉ូត បានបង្ហាញថា តើតំបន់នេះមានភាពជ្រួល ច្របល់យ៉ាងណា..." [២៥] ។

ខាងផ្នែករបស់ខ្លួន លោក រ៉េស៊ីដង់ ជាន់ខ្ពស់នៃប្រទេសកម្ពុជា ដោយបានទទួលនូវពាក្យបណ្តឹងជាច្រើន និងសភាពការណ៍បានកើនឡើង យ៉ាងធ្ងន់ធ្ងរផងនោះ បានផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន នូវការតវ៉ាដែលមានលក្ខណៈគម្រាមកំហែង ។ ដើម្បីផ្តល់នូវគំនិតមួយនៃយោបល់របស់តំណាងប្រទេសបារាំង នៅប្រទេសកម្ពុជា ។ ចំពោះមុខនៃព្រឹត្តិការណ៍ទាំងនេះ យើងជឿថា ការបង្ហាញម្តងទៀត នូវពាក្យទាំងឡាយ នៅក្នុងសារទូរលេខមួយច្បាប់របស់លោក ដែលបានផ្ញើទៅជូនទេសាភិបាលកូសាំង ស៊ីន គឺ :

"អាជ្ញាធរកម្ពុជា នៅខេត្តត្បូងឃ្មុំ ដែលបច្ចុប្បន្ន នៅភ្នំពេញ បានស្នើខ្ញុំជាថ្មីនូវបញ្ហាទាំងឡាយដូចតទៅនេះ នូវអ្វីដែលត្រូវបានផ្តល់ឲ្យទៅតាមការទាមទាររបស់ពួកគេស្តីអំពី :

**១.–** ការបញ្ចូលជាឧបសម្ព័ន្ធដែលធ្វើឡើង ដោយកូសាំងស៊ីន នូវផ្នែកមួយនៃទឹកដីកម្ពុជា ដែលគេស្គាល់នៅក្រោមឈ្មោះថា ស្រុក [២៦] ទ្វាររោង [២៧] ដែលមាន៥ ភូមិ [២៨] ដែលជាភូមិកម្ពុជាដោយពិតៗ ។

**២.–** អំពីការតែងតាំងនូវអ្នក មានមុខមាត់ជាច្រើន ដែលធ្វើឡើង នៅក្នុងភូមិទាំងឡាយដោយ Huyen Noc នៅ ធូយ៉ូវម៉ូត ។

**៣.–** ការពិន័យដាក់ទោសទៅលើភូមិដដែលដោយមន្ត្រីរូបនេះ ។

"ខ្ញុំសូមអង្វរលោកឲ្យខ្ញុំដឹងជាបន្ទាន់ នូវកិច្ចការជាបន្តទាំងឡាយដែលលោកបានផ្តល់ឲ្យទៅតាមការទាមទារទាំងនេះ ដែលត្រូវបានប្រគល់ទៅឲ្យលោករួចហើយគឺ :

*(២៥) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៨៩៦ ផ្ញើទៅជូនអគ្គទេសាភិបាលឥណ្ឌូចិន ដែលបានរៀបរាប់រួចហើយ ។*

*(២៦) / Arrondissement ។*

*(២៧) / ឈ្មោះរបស់កម្ពុជា នៃអតីតមណ្ឌលត្បូងនិញ ។*

*(២៨) / វៀតណាម គឺ ៥ ឃុំ ។*



**១ –** តាមទូរលេខដែលផ្ញើដោយអ្នកស្តីទីមុនខ្ញុំ ចុះថ្ងៃទី២៧ កុម្ភៈ ១៨៩៤

**២ –** ដោយរូបខ្ញុំផ្ទាល់តាមលិខិតចុះថ្ងៃទី៣១ ខែធ្នូ កន្លងមក និងដោយមានកំណត់ហេតុគាំទ្រផង ។

"ទោះយ៉ាងណាក៏ដោយ ខ្ញុំសូមជម្រាបលោកថា ខ្ញុំមិនព្រមទទួលខុសត្រូវអ្វីទាំងអស់បើសិនជានៅមុនការដោះស្រាយ កិច្ចការនេះ ដែលមានការយឺតយ៉ាវជាយូរមកហើយផងនោះ នូវជម្លោះអំពីបញ្ហាខ្លះ ដែលនឹងត្រូវកើតឡើង" [២៩] ។

ដោយការតវ៉ារបស់ពួកគេ ពុំបានទទួលភ្លាមៗ ហើយភាពពុះកញ្ជ្រោលរបស់ប្រជាជនបានបន្តនោះ លោករ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជា បានឲ្យលោកទេសាភិបាលកូសាំងស៊ីនដឹងថា លោកនឹងបញ្ជូនដំណឹងអំពីសភាពការណ៍ទៅឲ្យអគ្គទេសាភិបាលឥណ្ឌូចិន ។

"ការប្តឹងផ្តល់ជាច្រើន ដែលខ្ញុំបានទទួលពីអ្នកស្រុកនៅភូមិទាំងអស់នេះ ចំពោះពាក្យបណ្តឹងភាគច្រើន ដែលត្រូវបានបញ្ជូនទៅឲ្យលោកអំពីការទាមទារកាន់តែធំឡើងៗ ដែលប្រព្រឹត្តដោយមន្ត្រីអណ្ណាមរបស់លោក Outrey ជារៀងរាល់ថ្ងៃនោះ ត្រូវបានកំណត់ឲ្យលោកប្រកាន់យកនូវវិធានការចាំបាច់ទាំងឡាយ ដើម្បីធ្វើឲ្យបាត់បង់ឲ្យបានដាច់រហ័សតាមដែលអាចធ្វើទៅបាននូវស្ថានភាពនៃបញ្ហាទាំងនេះ ដែលចង្រៃយ៉ាងខ្លាំង ចំពោះផលប្រយោជន៍ទាំងអស់ដែលលើសពីសេចក្តីត្រូវការ និងដោយហេតុនេះ ដាក់បញ្ចូលមកវិញនៅក្នុងទឹកដីកម្ពុជា នូវភូមិទាំងឡាយ ដែលមិនត្រូវបានដកហូតយកចេញទាល់តែសោះនោះ ។

"នៅក្នុងលក្ខខ័ណ្ឌទាំងនេះ ខ្ញុំយល់ឃើញថា នេះគឺជាករណីយកិច្ចរបស់ខ្ញុំ ដើម្បីឲ្យគេបញ្ជូន នូវច្បាប់ចម្លងនៃលិខិតនេះទៅលោកអគ្គទេសាភិបាល ដើម្បីឲ្យលោកជ្រាបនូវហេតុការណ៍ពិតទាំងឡាយ ដែលលោកមិនត្រូវធ្វើមិនដឹងមិនឮយូរពេកទេ" [៣០] ។

ទេសាភិបាលកូសាំងស៊ីនខ្លួនលោកផ្ទាល់ ដែលព្រួយបារម្ភអំពីភាពចលាចលដែល

*(២៩) / ទូរលេខរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៨៩៥ ផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន ។*

*(៣០) / លិខិតរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជាចុះកាលបរិច្ឆេទ ឆ្នាំ ១៨៩៥ ផ្ញើទៅទេសាភិបាលកូសាំងស៊ីន ។*

ស្ថិតនៅយូរនេះ បានប្តឹងចំពោះអគ្គទេសាភិបាលឥណ្ឌូចិន និងបានរាយការណ៍ជូនលោកនូវអាកប្បកិរិយា ដែលប្រកាន់យកដោយលោក រ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជា : "ចំពោះការទាក់ទងគ្នាដែលលោកបានធ្វើនោះ រ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជាបានឆ្លើយតបថា លោកមិនត្រូវជឿងឆ្ងល់ទេ ចំពោះការបានដឹងនូវហេតុការណ៍ពិតទាំងនេះ និងថែមទាំងធ្វើឲ្យមានការជឿងឆ្ងល់ទៀតផង ចំពោះយោបល់របស់ លោកគឺថាសូមកុំឲ្យឧបទ្ទវហេតុរបៀបនេះមានច្រើន យ៉ាំងដូច្នេះ ឬក៏កុំឲ្យកើតមានឡើងជាញឹកញាប់ដូច្នេះទៀត ។ លោក De Verneville [៣១] បានបន្ថែមថា "ម្យ៉ាំងទៀតភាពពុះកញ្ជ្រោលនៅក្នុងចំណោមប្រជាជននៅក្នុងបញ្ហានេះ ចាប់តាំងពីថ្ងៃដែលលោក ភូ ឈួយ ទេសាភិបាល អ្នកកាន់ការងារមុនរបស់លោក បានជឿថា អាចប្រកាន់យកនូវអំណាចផ្ទាល់របស់លោកនូវអនុក្រឹត្យមួយ ដែលបានភ្ជាប់ទៅទឹកដីកូសាំងស៊ីននូវផ្នែកនៃទឹកដីកម្ពុជាជាច្រើនពាន់គីឡូម៉ែត្រ ក្រឡា ដែលខ្ញុំបានទទួលបន្ទុកខុសត្រូវនូវសកម្មភាពទាំងឡាយប្រភេទនេះរបស់ពួកអ្នកដែលបានឲ្យការណ៍អំពីលិខិតរបស់ប្រធានស្រុក បានជ្រួង (Ban-Chruong) [៣២] ហើយម្យ៉ាំងទៀតលោកបានទាយទុកជាមុនថា ភាពស្ងប់ស្ងាត់មិនបានកើតមានឡើងវិញទេ នៅមុនដំណោះស្រាយមួយ ដែលខ្ញុំបានទាមទារជាច្រើនដង ដោយឥតបានការនិងមិនត្រូវបានធ្វើអន្តរាគមន៍ ដើម្បីរៀបចំឡើងវិញ នូវព្រំដែនចាស់រវាងប្រទេសទាំងពីរ" [៣៣]។

ដូច្នេះអ្វីដែលយើងទើបនឹងបានឃើញ បានឲ្យយើងដឹងថា ការបញ្ចូលជាឧបសម្ព័ន្ធដោយរំលោភនូវសង្កាត់ទាំងឡាយរបស់កម្ពុជានៅឡុកនិញនិងភឿក ឡេ បានបណ្តាលឲ្យមានការតវ៉ាយ៉ាំងខ្លាំងក្លាពីសំណាក់អ្នកស្រុកនៅតំបន់ដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធពីអាជ្ញាធរកម្ពុជា និងថែមទាំងពីលោករ៉េស៊ីដង់ ជាន់ខ្ពស់នៅកម្ពុជាទៀតផង ។

---

*(៣១) / ឈ្មោះរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់ នៅប្រទេសកម្ពុជា ។*
*(៣២) / គឺបឹងច្រូង (Beng Chrong) ទឹកដីដែលស្ថិតនៅខាងលិចទឹកដីដែលមានបញ្ហា ។*
*(៣៣) / លិខិតរបស់ទេសាភិបាល កូសាំងស៊ីន ផ្ញើទៅជូនអគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៨៩៦។*



## អនុផ្នែកទី ៣
## ការបញ្ជាក់
## អំពីការដកហូតយកទឹកដីកម្ពុជា :
## អនុក្រឹត្យរបស់លោកអគ្គទេសាភិបាល
## ឥណ្ឌូចិន ចុះថ្ងៃទី៣១ ខែកក្កដា ១៩១៤
## (ឧបសម្ព័ន្ធ ៧ ) (ទំព័រ ២៣៧)

បន្ទាប់ពីការទាមទារទាំងនេះមក គណៈកម្មការមួយត្រូវបានតែងតាំងឡើងដោយក្រឹត្យរបស់លោកអគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ ១៨៩៧ "ចំពោះឥទ្ធិពលនៃការរៀបចំគម្រោងមួយ នៃការកំណត់ព្រំដែនកូសាំងស៊ីន "ជាមួយប្រទេសកម្ពុជា និងជាមួយប្រទេសអណ្ណាម ។

វាហាក់ដូចជាថា គណៈកម្មការនេះ មិនអាចបំពេញបាននូវបេសកកម្មរបស់ខ្លួន ទេ ។

ម្យ៉ាំងទៀត អគ្គទេសាភិបាលឥណ្ឌូចិន បានផ្តល់សច្ចាប័ន ចំពោះការបញ្ចូលជាឧបសម្ព័ន្ធនេះកាន់តែកើនឡើងជាលំដាប់ ។ ហេតុដូច្នេះហើយបានជាផែនទីឆ្នាំ ១៩០៣ ខ្នាត ១/១.០០០.០០០ ដែលរៀបចំឡើងដោយ ក្រុមភូមិសាស្ត្រឥណ្ឌូចិន បានចង្អុលបង្ហាញតំបន់ដែលមានបញ្ហានេះដោយការបញ្ជាក់ជាអក្សរថា "ជនជាតិសៀងដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ" ។ ប៉ុន្តែព្រំដែននៅក្នុងផ្នែកនេះ នៅតែបន្តចង្អុលបង្ហាញដោយបន្ទាត់ត្រង់មួយ ពីលិចទៅកើតដោយតភ្ជាប់បង្គោលលេខមួយទៅកាន់ភ្នំភូដិន ។

មានតែចាប់ពីឆ្នាំ ១៩១០ មកនោះទេ គឺបន្ទាប់ពីការគាបសង្កត់ដោយកាលទេសៈដែលយើងនឹងបានដឹង លោកអគ្គទេសាភិបាលឥណ្ឌូចិន បាននិយាយជាថ្មីឡើងវិញអំពីបញ្ហានេះ ។

### ១ – ដើមកំណើតនៃអនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ១៩១៤ : ការអភិវឌ្ឍន៍នៃដំណាំកៅស៊ូ និងការតែងតាំងអនុសញ្ញាកំណត់ព្រំដែន (១៩១០)

### ក/- ដំណាំកៅស៊ូ

នៅក្នុងឆ្នាំ ១៩១០ មានការអំណោយផលយ៉ាងខ្លាំងក្នុងការដាំដើមកៅស៊ូ ។ ដំណាំនេះត្រូវគ្នានឹងដីក្រហម ហើយដីក្រហមនេះស្ថិតនៅតំបន់ហៀនហ្វា ធូយ៉ូវម៉ុត និង ឡុកនិញ ។

ក្រុមហ៊ុនទាំងឡាយដែលមានប្រាក់ទុន ដ៏សំខាន់បានវាយលុកទេសាភិបាលកូសាំងស៊ីនសុំធ្វើសម្បទានលើដីធ្លី "ចំការកៅស៊ូ និងជាពិសេសដើមកៅស៊ូ បានបន្តអភិវឌ្ឍន៍យ៉ាងសម្បើម ។ ជារៀងរាល់ថ្ងៃ មានក្រុមហ៊ុនថ្មីៗដែលមានប្រាក់ទុនដ៏សំខាន់ត្រូវបានបង្កើតឡើង ហើយការស្នើសុំដីសម្បទានបានកើនឡើងយ៉ាងច្រើន ដែលរួមមានទាំងប្រជាជនអឺរ៉ុប ទាំងប្រជាជនក្នុងស្រុក ដែលបានសម្តែងចេញនូវការទុកចិត្តរបស់ខ្លួននៅក្នុងអនាគតក្នុងការធ្វើឲ្យដីនេះមានតម្លៃ ដែលរហូតមកដល់ថ្ងៃនេះ ដីនេះពុំមានដាំអ្វីសោះនោះ" (៣៤) ។

អគ្គទេសាភិបាលឥណ្ឌូចិន មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះដំណាំនៅក្នុងអនាគតនិងគាំទ្រ នូវការខិតខំប្រឹងប្រែងទាំងឡាយ ដែលធ្វើឡើងដោយទេសាភិបាលកូសាំងស៊ីន នៅក្នុងវិស័យនេះ "ការធ្វើសម្បទានជាច្រើនត្រូវបានយល់ព្រមផ្តល់ទៅឲ្យក្រុមហ៊ុនចំការកៅស៊ូជានា នៅកូសាំងស៊ីន និងចំពោះអ្នកដែលគ្រប់លក្ខណៈតាមអនុសញ្ញាចុះកាលបរិច្ឆេទថ្មីៗ ដែលអនុម័តជាមួយរដ្ឋាភិបាល IndesNéer landaises បានមានលទ្ធភាពផ្តល់នូវកម្មករស្ម័គ្រចិត្តនិងមានបទពិសោធន៍ " (៣៥) ។

១/- បញ្ហាហិរញ្ញវត្ថុ

ការអភិវឌ្ឍន៍ចំការកៅស៊ូ ដែលនៅតែត្រូវបានចាត់ទុកថា ជាការសន្យាមួយនៃការរកស៊ីមានបាននៅក្នុងអនាគតនោះ បានចោទដល់រដ្ឋាភិបាលកូសាំងស៊ីននូវបញ្ហាហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរនៅពេលចាប់ផ្តើមបើកផ្លូវថ្នល់ទាំងឡាយដែលអាចជួយសម្រួលដល់ការធ្វើដំណើរចូលទៅកាន់ដីដែលត្រូវបានផ្តល់ឲ្យជាសម្បទាននេះ ។

***(៣៤) / លិខិតអគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩១០ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងអាណានិគម ឥណ្ឌូចិន A.20 (៦៣) ។***

***(៣៥) / លិខិតរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២ ខែឧសភា ១៩១១ ផ្ញើទៅរដ្ឋមន្ត្រីក្រសួងអាណានិគម ឥណ្ឌូចិន A.20 (៦២) ។***



អាណានិគមជនត្រូវទទួលបន្ទុកមួយផ្នែកនៃសោហ៊ុយ ដែលនាំទៅរកការអនុវត្តន៍ការងារនេះ គឺ "នៅក្នុងបណ្តាខេត្តទាំងឡាយដែលស្ថិតនៅក្នុងតំបន់ដីក្រហម ដោយមូលហេតុនៃការពង្រីកទឹកដីកាន់តែធំទៅៗដែលធ្វើឡើងដោយ អ្នកដាំកៅស៊ូ នៅក្នុងតំបន់ទាំងឡាយដែលពីមុនគ្មានមនុស្សនៅនោះ ការពង្រីកនូវបណ្តាញផ្លូវថ្នល់ខេត្តដ៏សំខាន់មួយវាមានសារសំខាន់ខ្លាំងណាស់ទៅពេលអនាគត។វាជាការពិបាកសម្រាប់ខេត្តទាំងឡាយក្នុងការប្រឈមមុខនូវការចំណាយថ្មីទាំងនេះ ដែលនឹងត្រូវសងទូទាត់យូរអង្វែងដែលពុំមានការរីកចំរើនណាមួយ ឆ្លើយតបទៅនឹងប្រាក់ចំណូល ។ ដូច្នេះអាណានិគមជន ដែលយកចិត្តទុកដាក់នឹងការងារនេះ និងការថែទាំនូវផ្លូវថ្នល់ថ្មីទាំងនេះ ត្រូវចូលរួមនៅក្នុងការចំណាយ" (៣៦) ។

### គ /- បញ្ហារដ្ឋបាល

រដ្ឋាភិបាលកូសាំងស៊ីនបានបង្ហាញនូវការលំបាកទាំងឡាយ មិនគ្រាន់តែចំពោះការសាងសង់ផ្លូវថ្នល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះទម្រង់បែបបទរដ្ឋបាល ដែលទាក់ទងទៅនឹងការធ្វើសម្បទានទឹកដី ជាពិសេសចំពោះទឹកដីដែលស្ថិតនៅក្នុងតំបន់ដែលមានទំនាស់ ។ សភាពការណ៍នៃទឹកដីមិនទាន់ជម្រះមិនត្រូវបានកំណត់ទុនដ៏សំខាន់សម្រាប់ការធ្វើវិនិយោគដោយងាយស្រួលនោះឡើយ ។ ដូច្នេះគេត្រូវតែសម្រេចដោះស្រាយបញ្ហានេះ ។ ហើយដើម្បីធ្វើបញ្ហានេះ អគ្គទេសាភិបាលឥណ្ឌូចិនបានយកអនុក្រឹត្យមួយចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ១៩១០ តែងតាំងនូវគណៈកម្មការមួយ "ដើម្បីសិក្សាបញ្ហាកំណត់ព្រំដែន កូសាំងស៊ីន និងព្រំដែនកម្ពុជា" ។

### គ – អនុក្រឹត្យចុះថ្ងៃទី៨ ធ្នូ ១៩១០

អនុក្រឹត្យនេះបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសេចក្តីថ្លែងហេតុរបស់ខ្លួនដូចតទៅនេះគឺ : "ដោយបានពិនិត្យឃើញផលប្រយោជន៍ដែលមាននៅក្នុងតំបន់នេះ ទៅលើការពង្រីកដំណាំកៅស៊ូនោះ ការកំណត់ព្រំដែនកូសាំងស៊ីន និងព្រំដែនកម្ពុជាត្រូវធ្វើឲ្យបានត្រឹមត្រូវ..." ។

***(៣៦) / លិខិតរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ ១៩១០ ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងអាណានិគម ឥណ្ឌូចិន A.20 (៦៣) ។***

គណៈកម្មការមានសមាសភាពដូចតទៅនេះគឺ :

- លោក Debernardi អធិការខាងកិច្ចការស៊ីវីល...ប្រធាន
- ពួកអភិបាលខេត្ត ដែលមានការពាក់ព័ន្ធនៅកូសាំងស៊ីន ... សមាជិក
- អ្នកស្រុកនៅតាមខេត្តដែលពាក់ព័ន្ធនៅប្រទេសកម្ពុជា...សមាជិក
- មន្ត្រីអន្តោប្រាមពីរនាក់ ទទួលបន្ទុកកិច្ចការក្នុងស្រុកនៅកូសាំងស៊ីននៅតាមការចាត់តាំងរបស់លោកភូឈួយខេត្ត...សមាជិក
- មន្ត្រីអន្តោប្រាមពីរនាក់ ទទួលបន្ទុកកិច្ចការក្នុងស្រុកនៅកម្ពុជា ទៅតាមការចាត់តាំងរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់...សមាជិក
- លោក ឡឺ ប្រឹង (Lebrun) អ្នកគ្រប់គ្រងថ្នាក់លេខ ៥ ទទួលបន្ទុកខាងកិច្ចការស៊ីវីល...លេខាធិការ

**២ -ដំណើរការរបស់គណៈកម្មការឆ្នាំ១៩១០ អនុក្រឹត្យចុះថ្ងៃទី៣១ កក្កដា ១៩១៤**

គណៈកម្មការបានធ្វើការងារនេះជាងមួយឆ្នាំ ។ នៅក្នុងឆ្នាំ ១៩១២ គណៈកម្មការនេះបានដាក់ជូនទូវសេចក្តីស្នើទាំងឡាយទៅលោកអគ្គទេសាភិបាលដែលលោកបានយល់ព្រមចំពោះសេចក្តីស្នើទាំងនេះ និងបានតែងតាំងគណៈកម្មការ បោះគោលដីដើម្បីដំណើរការ ដាំបង្គោលព្រំដែន ដែលត្រូវបោះសញ្ញានូវព្រំដែនថ្មី" ។

ព្រំដែនថ្មី មិនមែនជាព្រំដែនណាក្រៅពីព្រំដែនដែលមានរាប់បញ្ចូលនូវចំណែកទឹកដីកម្ពុជាដែលបានដាក់បញ្ចូលជាឧបសម្ព័ន្ធទៅក្នុងកូសាំងស៊ីន នៅក្នុងឆ្នាំ ១៨៩៣ នោះឡើយ ហើយដែលជាកម្មវត្ថុ នៃការជំទាស់រវាងលោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា និងទេសាភិបាលឥណ្ឌូចិន ជាច្រើនឆ្នាំមកហើយនោះ ។

ក្រោយពីការបោះគោលដីនេះមក គេបានដាក់សុំឡាយព្រះហស្តលេខាពីព្រះមហាក្សត្រនៃប្រទេសកម្ពុជានូវព្រះរាជប្រកាស [៣៧] ដែលបានបញ្ជាក់ដោយលំអិតថា "ការកំណត់ព្រំដែនថ្មីដែលនឹងត្រូវធ្វើឡើងរវាងខេត្តកំពង់ចាម និងធូយ៉ូវម៉ូតដែលនឹងទុកឲ្យកូសាំងស៊ីន នូវសង្កាត់ពីរ គឺឡុក និញ និង ភឿក ឡេ ដែលពីមុនពួកកុលសម្ព័ន្ធបានរស់នៅដោយឯករាជ្យនោះ" ។

***(៣៧) / ព្រះរាជប្រកាស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ (ឧបសម្ព័ន្ធ ៨) ។***



តើព្រះរាជប្រកាសនេះ បាននាំមកឲ្យយើងនូវអ្វីខ្លះ ? វាបានបញ្ជាក់ម្តងទៀតថាសង្កាត់ទាំងពីរនេះ គឺជារបស់កម្ពុជា ។ បើសិនជាវាមិនមែនទេនោះ គេមិនបានបង្ខំឲ្យព្រះមហាក្សត្រនៃប្រទេសកម្ពុជា ប្រកាសនូវការលះបង់នោះទេ " ។ បើសិនជាព្រះមហាក្សត្រមានអំណាច"ទុកឲ្យកូសាំងស៊ីន" នូវស្រុកទាំងពីរនេះនោះវាបានបង្ហាញថាស្រុកទាំងពីរគឺជារបស់កម្ពុជា ។ បច្ចុប្បន្នកាលវារំលឹកអតីតកាល ។

ប៉ុន្មានខែក្រោយមក អគ្គទេសាភិបាលបានយកអនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ [៣៨] ដែលមាត្រា ៣ បានប្រកាសថា : "ព្រំដែនថ្មីរវាងខេត្ត ធូយ៉ូវម៉ូត និងខេត្តកំពង់ចាម (មណ្ឌលក្រចេះ) ចេញដំណើរពីកន្លែងប្រសព្វមុខ នៃ Can - Lé Cham និង Can - Lé - Tru (ព្រែកព្រៃនគរ) សៀរតាម Can - Lé - Cham រហូតដល់ចំណុចដែលទន្លេនេះបានបែកចេញពីទិសខាងជើង ដើម្បីបត់ទៅទិសខាងកើតបានជាកែងមួយដ៏ធំ ។ ចំណុចនេះត្រូវបានគូសជាសញ្ញាអក្សរ A នៅលើផែនទីដែលភ្ជាប់ជាឧបសម្ព័ន្ធ ទៅនឹងច្បាប់ដើមនៃអនុក្រឹត្យ ។

"ពេលនោះព្រំដែននេះបានទៅដល់ចំណុច B ជាខ្សែបន្ទាត់ត្រង់នៅកន្លែងប្រសព្វមុខនៃព្រែកជ្រៅ និងផ្លូវថ្នល់ទៅក្រចេះ បត់ទៅទិសខាងកើត សៀរតាមផ្លូវទឹកព្រែកជ្រៅ រហូតដល់ប្រភពដើមរបស់វា (ចំណុច C ) ។ ព្រំដែននេះបានបន្តទៅទៀតជាបន្ទាត់ត្រង់ទៅដល់ចំណុច D ដែលនៅចំណុចនេះវាបានជួប ព្រែកមាន ឬ Djerman ដែលបានដើរតាមផ្លូវទឹកនេះរហូតដល់ប្រភពរបស់វា ដើម្បីបានទៅដល់ទីប្រសព្វមុខនៃ Dar - Klé និង Dar - Hoyt បន្ទាត់មកវាបានដើរតាមផ្លូវទឹកនេះ រហូតដល់ប្រភពរបស់វា" ។

ដូច្នេះអនុក្រឹត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩១៤ ធ្វើឡើងដើម្បីគ្រាន់តែបញ្ជាក់ឧបសម្ព័ន្ធ ដែលធ្វើឡើងដោយទេសាភិបាលកូសាំងស៊ីន ដោយអាស្រ័យអំណាចនៃអនុក្រឹត្យរបស់ខ្លួនចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៨៩៣ ។ វាមិនមែនឥតប្រយោជន៍ទេ សម្រាប់យើង ដើម្បីស្វែងយល់ដឹងថា តើផ្អែកទៅលើកត្តាណាដែលត្រូវវាយតម្លៃចំពោះសេចក្តីសម្រេចដែលត្រូវបានប្រកាសនេះនោះ ។

***(៣៨) / J.O.I ឆ្នាំ ១៩១៤ ទំព័រ ១២៥៨ ។***

### ៣ – គោលសំខាន់ទាំងឡាយនៃការវាយតម្លៃអនុក្រឹត្យចុះថ្ងៃទី៣១ កក្កដា ១៩១៤

គោលសំខាន់ទាំងឡាយនៃការវាយតម្លៃ គឺនៅក្នុងរបាយការណ៍ដែលបង្ហាញដោយគណៈកម្មការដែលតែងតាំងដោយអនុក្រឹត្យចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ១៩១០ ។

គណៈកម្មការនេះ មិនពិនិត្យសិទ្ធិទាំងឡាយរបស់ម្នាក់ៗនោះទេ ប៉ុន្តែបែរជាផ្អែកតែទៅលើសភាពការណ៍នៃហេតុការណ៍ដែលកើតមាននៅក្នុងឆ្នាំ ១៩១០ ។ ដូច្នេះវាគ្រាន់តែបានធ្វើឲ្យរំលោភដល់ការផ្តល់សច្ចាប័នដែលបានធ្វើឡើងនៅក្នុងឆ្នាំ ១៨៩៣ គឺ "ព្រំដែននៃប្រទេសកម្ពុជា និងខេត្តធូយ៉ូវម៉ូត មិនដែលត្រូវបានកំណត់ក្នុងរបៀបជាក់លាក់នោះទេ ។ ប៉ុន្តែអនុក្រឹត្យមួយរបស់ទេសាភិបាលចុះថ្ងៃទី២៦ កក្កដា ១៨៩៣ (មែនទែន គឺអនុក្រឹត្យរបស់ទេសាភិបាលកូសាំងស៊ីន) បានបង្កើតនៅក្នុងតំបន់ព្រំដែននៃស្រុកឡុក និញ និង ភឿក ឡេ ដែលតាមការពិតត្រូវបានគ្រប់គ្រងដោយកូសាំងស៊ីន ។ ប្រធាន និងអនុប្រធានស្រុកទាំងនេះ តាមការពិត គឺត្រូវបានតែងតាំងដោយប្រធានគ្រប់គ្រងក្នុងស្រុក ហើយប្រាក់ខែរបស់ពួកគេត្រូវបានចុះនៅក្នុងបញ្ជីនៃថវិកាក្នុងស្រុក ។ម្យ៉ាងទៀត ជនជាតិស្បៀង និងជនជាតិម៉ុយ (Moïs) ដែលបានរស់នៅក្នុងស្រុកទាំងនេះ ត្រូវបានចុះនៅក្នុងបញ្ជីស្តីអំពីតួនាទីនៃប្រាក់ពន្ធរបស់ខេត្ត ធូយ៉ូវម៉ូត ។ ពួកគេបានធ្វើការដូចជាអ្នកជាប់តាវកាលិក ធម្មជាតិ (Prestataire) នៅក្នុងការកសាងផ្លូវថ្នល់ពីចុនថាន់ (Chon - Than) ទៅក្របេះ ផ្លូវថ្នល់នេះដែលត្រូវបានក្រាលថ្មប្រវែង ៨០ គ.ម លាតសន្ធឹងពីបេនកាត (Bencat) រហូតដល់ចំការកៅស៊ូ ឡុក និញ ត្រូវបានស្ថាបនាឡើងទៅលើការចំណាយរបស់កូសាំងស៊ីន និងខេត្ត ធូយ៉ូវម៉ូត" ។

ដើម្បីពិនិត្យមើលនូវអ្វីដែលទើបតែត្រូវបានលើកឡើងនេះ យើងអាចនិយាយបានថា គណៈកម្មការនេះមិនបានធ្វើការដែលខ្លួនត្រូវធ្វើនោះទេ គឺថាត្រូវធ្វើការសិក្សាដោយសមធម៌ អំពីសិទ្ធិរបស់ប្រទេសនីមួយៗ ។ ផ្ទុយទៅវិញ គេបានខិតខំតែទៅលើការស្វែងរកទឡ្ហីករណ៍ទាំងឡាយដើម្បីបង្ហាញភស្តុតាងឲ្យឃើញថា ត្រឹមត្រូវនឹងដើម្បីរក្សាការរំលោភនៅពេលខាងមុខទៀត ។

ប៉ុន្តែទឡ្ហីករណ៍ទាំងឡាយដែលគណៈកម្មការបានបង្ហាញនេះ បានឆ្លុះបញ្ចាំងនូវ



គំនិតមួយដែលចម្លែកបំផុតចំពោះផ្លូវច្បាប់ ។ ចំពោះគណៈកម្មការនេះ ដែលសុទ្ធតែជាអ្នកបង្កើតច្បាប់នោះបានបង្ហាញថា ហេតុការណ៍នៃការយកអនុក្រឹត្យ ដើម្បីបញ្ចូលជាឧបសម្ព័ន្ធនូវអាជ្ញាធរនៃទឹកដីមួយដែលជារបស់ប្រទេសជិតខាងមួយ ហើយបន្ទាប់មកឆ្លៀតឱកាសយកមុខតំណែងដែលមានអភ័យឯកសិទ្ធិ ដែលបានបង្កើតឡើងដោយសន្ធិសញ្ញារបស់អាណាព្យាបាលឆ្នាំ ១៨៦៣ នេះ ដើម្បីអនុវត្តនៅលើទឹកដីដូចបាននិយាយនេះ នូវសកម្មភាពគ្រប់គ្រងទាំងឡាយ (ការតែងតាំងប្រធានអនុប្រធានស្រុក ការចុះបញ្ជីប្រជាជនឲ្យបង់ពន្ធ ) និងជាពិសេសហេតុការណ៍ដែលបានចូលរួមនៅក្នុងការចំណាយទាំងឡាយ ដើម្បីកសាងផ្លូវមួយនៅលើទឹកដីរបស់អ្នកឯទៀត ។

មានតែគណៈកម្មការដែលបញ្ជាក់ថា គឺមានតែចាប់ពីឆ្នាំ ១៨៩៣ មកនោះទេ ដែល "កូសាំងស៊ីនបានអនុវត្តទៅលើតំបន់ឡុកនិញ និងភឿក ឡេ ដែលពីមុនជាស្រុកឯករាជ្យនូវច្បាប់កម្មសិទ្ធិ ដែលបានធ្វើឲ្យទៅជាពិត ដោយការងារធំៗក្នុងការបញ្ចូល និងដោយដាក់ឲ្យនៅក្រោមបង្គាប់របស់ប្រជាជនដែលកើតនៅក្នុងស្រុក" ។

នៅទីនេះទៀត គណៈកម្មការបានរំលោភទៅលើការពិត នៅពេលដែលគណៈកម្មការនេះបានយកលេសថា តំបន់ ឡុក និញ និង ភឿកឡេ ពីមុនគឺជាតំបន់ឯករាជ្យ។ គណៈកម្មការនេះស្ថិតនៅក្នុងភាគីរួមបញ្ចូល នៃប្រទេសកម្ពុជា ហើយបញ្ហានេះត្រូវបានបង្ហាញដោយភស្តុតាងជាច្រើន ដែលយើងបានរៀបរាប់មកហើយ និងជាពិសេសដោយដែនទីឆ្នាំ ១៨៩០ ហើយជាពិសេសដោយការសារភាពរបស់ទេសាភិបាលកូសាំងស៊ីន លោក Ducos តែម្តង ។

ប៉ុន្តែគណៈកម្មការមានចិត្តបរិសុទ្ធ ក្នុងការសារភាពដោយមិនដឹងខ្លួនអំពីការពិតនេះនៅពេលដែលគណៈកម្មការនេះបានថែងថា ខ្លួនបានភ្ជាប់តំបន់នេះទៅឲ្យកូសាំងស៊ីនជាស្ថាពរ"។ តាមនោះគណៈកម្មការនេះបានទទួលស្គាល់ថា ទឹកដីនេះមិនមែនជារបស់កូសាំងស៊ីននោះទេ ប៉ុន្តែទឹកដីនេះត្រូវបានភ្ជាប់ទៅឲ្យកូសាំងស៊ីន ។ គណៈកម្មការនេះគ្រាន់តែបានស្នើឡើងថា ការភ្ជាប់នេះដែលនៅតែស្ថិតនៅមិនទាន់ជម្រះ" នោះបានក្លាយទៅជាទឹកដីរបស់កូសាំងស៊ីនជាស្ថាពរ ។

ម្យ៉ាងទៀត គណៈកម្មការនេះ បានបញ្ជាក់អំពីហេតុផល ដែលគណៈកម្មការនេះត្រូវបង្ខំចិត្ត ដើម្បីបង្ហាញឲ្យឃើញថា ការភ្ជាប់នេះពិតជាត្រឹមត្រូវ ស្រុកទាំងពីរ គឺ ឡុក និញ និង ភើកឡេ ដែលនឹងត្រូវបញ្ចូលជាឧបសម្ព័ន្ធទៅកូសាំងស៊ីននោះ គឺមានផ្ទៃក្រឡាប្រហែល ១៤៧.០០០ ហ.ត ។ ស្រុកទាំងនេះត្រូវបានរស់នៅដោយជនអន្តោប្រាវេសន៍ ដែលមានសាសន៍ផ្សេងៗគ្នា និងស្ទើរតែជាអ្នកស្រុកព្រៃ ព្រមទាំងមានចំនួនមិនសូវជាច្រើនប៉ុន្មានទេ ។ ពួកគេបានទទួលផលប្រយោជន៍ជាពិសេសដោយសារផ្លូវថ្នល់ខេត្តក្រចេះ ព្រមទាំងភ្នំតូចៗដែលមានដីក្រហម និងស្ថិតនៅក្នុងទឹកដីរបស់ពួកគេ ។ ដោយសារផ្លូវថ្នល់នេះ និងដោយសារដីមានដីជាតិល្អត្រូវនឹងដំណាំកៅស៊ូនោះ តំបន់នេះហាក់ដូចជាមានការលូតលាស់ខ្លះខាងវិស័យសេដ្ឋកិច្ច" ។ របាយការណ៍នេះបានបង្ហាញច្បាស់ថា ការទន្ទ្រានកាន់កាប់ទឹកដីតំបន់នេះ ដោយកូសាំងស៊ីន ទើបតែបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៨៩៣ នោះទេ ។

II . ការទន្ទ្រានយកទឹកដីនេះ តើត្រូវបានបង្ហាញភស្តុតាងនៅក្នុងសម្មតិកម្មដែលប្រទេសកម្ពុជាមានតំបន់នេះជារបស់ខ្លួន ហើយបើតាមការអះអាងរបស់លោករ៉េស៊ីដង់នៃប្រទេសបារាំង នៅកំពង់ចាមនោះ តើនឹងអនុវត្តសមត្ថកិច្ចរដ្ឋបាលរបស់ខ្លួនបានដែរឬទេ ? យើងសូមឆ្លើយថា វាមិនអាចទៅរួចទេ ។

តាមការពិត បើតាមសន្ធិសញ្ញា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៨៦៣ ប្រទេសបារាំងត្រូវចូលរួមការពារព្រះមហាក្សត្រ នៃប្រទេសកម្ពុជា និងបណ្តារដ្ឋរបស់ខ្លួនប្រឆាំងនឹងភាពចលាចលទាំងឡាយនៅក្នុងប្រទេស និងការវាយប្រហារនៅក្រៅប្រទេស (មាត្រា១ និងមាត្រា ១៦) ។ បើសិនជាការគ្រប់គ្រងតំបន់នេះ មិនអាចត្រូវបានធានាដោយសមគួរទេនោះ ការខ្វះខាតនេះកើតចេញមកពីឧទ្ទាមកម្មដែលនាំបះបោរដោយ ពោរកំបោ នៅឆ្នាំ ១៨៦៦- ១៨៦៧ ហើយដែលការបង្ក្រាបបានស្ថិតនៅលើករណីយកិច្ចផ្ទាល់របស់បារាំង ។ បារាំងត្រូវបង្ក្រាបបានស្ថិតនៅលើករណីយកិច្ចផ្ទាល់របស់បារាំង ។ បារាំងត្រូវបង្ក្រាបការចលាចលនៅកូសាំងស៊ីន ក្នុងនាមជាទឹកដីដែលមានអធិបតេយ្យភាព ។ ចំណែកនៅប្រទេសបារាំងត្រូវ :

– ជួយរដ្ឋាភិបាលប្រឆាំងនិងការបះបោរ និងជាពិសេស



– កុំទាញយកលេសណាមួយ ដើម្បីពង្រីកការបះបោរ និងដើម្បីរឹបអូសយកទឹកដី ។

III . ប៉ុន្តែអកុសលចំពោះប្រទេសកម្ពុជា នៅពេលដែលសំណួរស្តីអំពីផ្នែកនៃព្រំដែននេះ ត្រូវបានដាក់ជូនក្រុមប្រឹក្សាអាណាព្យាបាលពិនិត្យនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩១៤ (៣៩) ប្រទេសនេះមិនឃើញអ្នកការពារដូចនៅក្នុងឆ្នាំ ១៨៩៣-១៨៩៦ ទេ គឺលោករ៉េស៊ីដង់ជាន់ខ្ពស់ de Verneville ។

លោក រ៉េស៊ីដង់ បារាំង នៅកំពង់ចាម និយាយដោយប្រុងប្រយ័ត្ន ប៉ុន្តែក្រុមប្រឹក្សាបានធ្វើរំលង ។

ម្យ៉ាងទៀត បើសិនជាលោក រ៉េស៊ីដង់ ជាន់ខ្ពស់ de Verneville មានវត្តមាននៅក្នុងឆ្នាំ ១៩១៤ តើលោកអាចធ្វើអ្វីកើតនៅចំពោះមុខឆន្ទៈរបស់ទេសាភិបាលដែលលោកចង់ មិនគ្រាន់តែការពិនិត្យច្បាប់របស់ប្រទេសវៀងៗខ្លួនប៉ុណ្ណោះទេ ប៉ុន្តែគ្រាន់តែធ្វើឲ្យត្រឹមត្រូវតាមច្បាប់នៃការបញ្ចូលជាឧបសម្ព័ន្ធនោះ ?

ដើម្បីលុបចោលអពមង្គលនេះ លោកមិនគ្រាន់តែ មិនមានវត្តមានរបស់លោករ៉េស៊ីដង់ ជាន់ខ្ពស់ de Verneville នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែនៅមានជោគវាសនារបស់ព្រះរាជាណាចក្រផងដែរ ដែលកាន់តែមានសភាពធ្ងន់ធ្ងរឡើងដោយសារវត្តមានដូចជាលោករ៉េស៊ីដង់ជាន់ខ្ពស់ de Outrey លោកនេះនៅក្នុងឆ្នាំ ១៨៩៣ នៅពេលដែលលោកនៅធួយ៉ូវម៉ូត បានធ្វើការដោយចចេសក្នុងការបញ្ចូលជាឧបសម្ព័ន្ធទៅឲ្យកូសាំងស៊ីន នូវស្រុកទាំងពីរនេះ , គឺលោកនេះផ្ទាល់តែម្តង ដែលនៅក្នុងឆ្នាំ ១៩១៤ បានចុះហត្ថលេខាលើរបាយការណ៍ដាក់បង្ហាញលោកអគ្គទេសាភិបាលព្រមទាំងដាក់ជូនលោកនូវគម្រោងសន្ធិសញ្ញា (៤០) ។

(៣៩) / របាយការណ៍នៃការពិភាក្សារបស់ក្រុមប្រឹក្សាអាណាព្យាបាលចុះថ្ងៃទី៣ មីនា ១៩១៤ ឥណ្ឌូចិន D.46(៩) ។

(៤០) / អនុសញ្ញា ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩១៤ គ្រាន់តែធ្វើឲ្យបាប់អនុវត្តឡើងវិញនូវអនុសញ្ញាមិនស្របច្បាប់ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៨៩៣ របស់ទេសាភិបាលកូសាំងស៊ីន ដែលបានបញ្ចូលជាឧបសម្ព័ន្ធទៅឲ្យអាណានិគមនូវស្រុក ៦ របស់កម្ពុជា ដែលក្នុងនោះស្រុកពីរមានលក្ខណៈជាស្រុករបស់កម្ពុជាដោយប្រាកដ-ប្រជានៅក្នុងអនុក្រឹត្យចុងក្រោយនេះ (ស្រុកគួអាន និងថាញ់អាន) និងស្រុកពីរទៀត ទទួលស្គាល់ដោយទេសាភិបាលកូសាំងស៊ីនថា ជាផ្នែករួមបញ្ចូលនៃប្រទេសកម្ពុជា (ស្រុកឡុក និញ និងស្រុក ភើក ឡេ) ។
"ប៉ុន្តែចំពោះការសោរភាពរបស់អភិបាល ធួយ៉ូវម៉ូត នូវការបំបាត់បង្គោលសីមាដោយរំលោភនោះនឹងធ្វើឲ្យគេយល់ថា នៅក្នុងទឹកដីកូសាំងស៊ីន មានស្រុកពីរដែលមានប្រជាជន Moïs រស់នៅដែលជាស្រុករបស់កម្ពុជាពិតប្រាកដ" (Ducos) ។

## ជំពូក II
## តម្លៃគតិយុត្តនៃព្រំដែន

យើងបានរកឃើញវិញនៅទីនេះនូវគំនូរបំព្រួញនៃការពិភាក្សាប្រកបដោយគតិយុត្តដូចគ្នានៅឡើយ ចំពោះព្រំដែននៅតែនិញ ។ ដូច្នេះគេបានសុំទោសយើងកុំឲ្យយកការពិចារណាទាំងស្រុងដែលបានស្គាល់រួចហើយ និងអាចផ្លាស់ប្តូរកន្លែងបានដោយងាយស្រួលយើងពេញចិត្តនឹងទទូចទៅលើចំណុចសំខាន់ៗនៃទឡ្ហីករណ៍ និងម្យ៉ាងទៀត គឺឲ្យសញ្ញាអំពីកត្តាថ្មីមួយចំនួន ។

ប៉ុន្តែនៅទីនេះដដែល នៅពេលចេញដំណើរ គេត្រូវតែរំលឹកអំពីទិន្នន័យមូលដ្ឋានទាំងឡាយដែលបាននាំប្រវត្តិសាស្ត្រមកឲ្យយើង :

**១.–** ការពិតព្រំដែនត្រូវបានរៀបចំឡើង នៅខាងក្រៅកិច្ចព្រមព្រៀងទាំងអស់ជាមួយអាជ្ញាធរកម្ពុជា ដោយមិនរវល់ដល់ការតវ៉ាទាំងឡាយរបស់អាជ្ញាធរបារាំងនៅប្រទេសកម្ពុជា ។

**២.–** គំនូសរបស់វា បានឈានទៅដល់ការបញ្ចូលទឹកដីកម្ពុជា ដែលមិនអាចប្រែកែកបាន និងដែលស្ថិតនៅចំណុះអាជ្ញាធររដ្ឋបាលកម្ពុជា ។

**៣.–** នៅក្នុងដំណាក់កាលទីមួយ ព្រំដែននេះត្រូវបានសម្រេចដោយអាជ្ញាធរមួយដែលគ្មានសមត្ថភាពនៅគ្រប់ចំណុចទាំងអស់ ។ គឺទេសាភិបាលកូសាំងស៊ីន ។

**៤.–** ការរំលោភអំណាច ដែលបានសម្តែងចេញនេះ បានបណ្តាលឲ្យមានចលាចលជាច្រើន ដែលតម្រូវឲ្យមានការសម្រេច ពីអគ្គទេសាភិបាល ។

**៥.–** លោកអគ្គទេសាភិបាលរូបនេះ បានដាក់កម្រិតនៅក្នុងអនុក្រឹត្យរបស់ខ្លួនចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩១៤ ដើម្បីពង្រឹងសភាពការណ៍ដែលមានស្រាប់ និងដែលបំពានដោយទេសាភិបាលកូសាំងស៊ីន ។

**៦.–** នៅមុនអនុសញ្ញារបស់អគ្គទេសាភិបាល ព្រះមហាក្សត្រនៃប្រទេសកម្ពុជាត្រូវបានបង្ខិតបង្ខំឲ្យយកព្រះរាជប្រកាសស្តីពីការឲ្យសច្ចាប័នលើការកាត់ទឹកដីដែលព្រះរាជាណាចក្ររបស់ព្រះអង្គបានទទួលរង ។



*ហេតុការណ៍ពិតទាំងនេះ អាចឲ្យគេគាំទ្រនូវទឡ្ហីករណ៍គតិយុត្តមួយដែលគេបានធ្វើឲ្យឃើញច្បាស់ថា ខ្សែបន្ទាត់ព្រំដែន ដែលមានពិតៗនៅក្នុងពេលបច្ចុប្បន្ន វាមិនអាចជាព្រំដែនមួយនៃទឹកដីទាល់តែសោះ ប៉ុន្តែវាគ្រាន់តែជាខ្សែបន្ទាត់រដ្ឋបាលមួយតែប៉ុណ្ណោះ ដែលនឹងត្រូវគេបោះបង់ចោលនៅក្នុងពេលដែលផ្ទុះឡើងនៅឥណ្ឌូចិន ។*

– ដែលទឹកដីកម្ពុជា ដែលស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម មិនដែលបាត់បង់នូវភាពចំណុះរបស់ខ្លួន ចំពោះអធិបតេយ្យភាពរបស់ខ្មែរនោះឡើយ ។

បញ្ហានេះមានភស្តុតាងបង្ហាញច្បាស់លាស់ដោយហេតុថា គេមិនបានឃើញនូវការព្រមព្រៀង ឬក៏ការយល់ព្រមណាមួយពីកម្ពុជានោះឡើយ ។

– ដោយហេតុថា ប្រទេសបារាំងមិនអាចបញ្ចូលជាឧបសម្ព័ន្ធនៅក្នុងច្បាប់អន្តរជាតិ នូវចំណិតដីតូចរបស់កម្ពុជានោះបានឡើយ ។

– ដោយហេតុថា ទម្រង់បែបបទ ដែលត្រូវបានប្រើប្រាស់ ទោះបីជាយ៉ាងណាក៏ដោយមិនត្រូវបានអនុញ្ញាតឡើយ ដោយធៀបនឹងច្បាប់ផ្ទៃក្នុងរបស់បារាំង ដើម្បីធ្វើឲ្យបានសម្រេចនូវការបញ្ចូលជាឧបសម្ព័ន្ធបែបនេះនោះ ។

### ១ – ការគ្មានការយល់ព្រមពីកម្ពុជា

#### ក/– ការគ្មានការអន្តរាគមន៍ពីប្រជាជនកម្ពុជា

នេះចាត់ទុកដូចជាភស្តុតាងដ៏ល្អប្រសើរចំពោះការគ្មានការយល់ព្រមរបស់ប្រជាជនកម្ពុជា ចំពោះការកែប្រែទឹកដីដែលត្រូវបានអនុវត្ត ។

បញ្ហានេះមិនត្រូវបានធ្វើអន្តរាគមន៍នៅដំណាក់កាលណាមួយឡើយ ។ ទាំងនៅក្នុងការរៀបចំព្រំដែន ពុំមានដំណាក់កាលណាមួយរបស់ខ្លួន ទាំងនៅក្នុងគណៈកម្មការសិក្សាដែលបានប្រជុំក្នុងបច្ឆាកាល (a posteriori) ទាំងពុំបានឮនៅក្នុងអំឡុងពេលនៃការសម្រេចមិនត្រឹមត្រូវតាមច្បាប់របស់ទេសាភិបាលកូសាំងស៊ីន ។

តាមការពិត គេអាចនិយាយថា ប្រជាជនកម្ពុជាបានធ្វើអន្តរាគមន៍តែនៅក្នុងដំណាក់កាលមួយប៉ុណ្ណោះ នោះគឺការបះបោរដោយឯកឯងរបស់ប្រជាជនខ្មែរប្រឆាំងនឹងអំពើរំលោភដែលបានយាយីពួកគេ ។

##### ១/– អាកប្បកិរិយារបស់តំណាងទាំងឡាយនៅប្រទេសកម្ពុជារបស់អាជ្ញាធរ

**អ្នកការពារ**

អ្នកតំណាងទាំងនេះ មិនដែលភ្លេចក្នុងការតវ៉ាយ៉ាងហោចណាស់ក៏ប្រឆាំងនិងការរំលោភអំណាចរបស់អាជ្ញាធរកូសាំងស៊ីនដែរ ។ ហើយយើងបានឃើញថា ជួនកាលការតវ៉ានេះ មានលក្ខណៈស្វាហាប់ទៀតផង ។

ជាអកុសលវាហាក់ដូចជាថា អាកប្បកិរិយាដ៏ក្លាហានរបស់លោក វ៉ឺស៊ីដង់ de Verneville មិនត្រូវបានរកឃើញឡើងវិញ នៅក្នុងក្របខ័ណ្ឌនៃគណៈកម្មការដែលបានដើរមុនការសម្រេចរបស់អាជ្ញាកណ្ដាលនៅឆ្នាំ ១៩១៤ នោះឡើយ ។

ម្យ៉ាងទៀត វាមិនត្រូវឆ្ងល់ទេថា លោកវ៉ឺស៊ីដង់ ក្នុងសម័យនោះ មិនបានធ្វើការតវ៉ានៅក្នុងនាមរបស់ប្រទេសកម្ពុជា រវាងការកាត់ទឹកដីដែលធ្វើបានសម្រេចរួចហើយនោះ ពីព្រោះថា លោកវ៉ឺស៊ីដង់រូបនេះ មិនមែនអ្នកណាក្រៅពីអតីតអភិបាលខេត្តធូយ៉ូវម៉ូត ជាអ្នកផ្ដួចផ្ដើមឲ្យមានអនុក្រឹត្យឆ្នាំ ១៨៩៣ ដ៏អភ័ព្វនេះ ។

### ក/- ព្រះរាជប្រកាសចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩១៤ (ឧបសម្ព័ន្ធ ៨)

គេអាចមើលឃើញនូវការយល់ព្រមមួយរបស់ប្រជាជនកម្ពុជានៅក្នុងព្រះរាជប្រកាសនេះដែលបានប្រគល់ទៅឲ្យកូសាំងស៊ីននូវទឹកដីកម្ពុជា ។ នេះ គឺនៅតែមានការបំភ្លេចនៅឡើយ អំពីវត្តមាននៃលទ្ធភាពប្រឆាំងចំពោះឆន្ទៈ នៃអំណាចរបស់អ្នកការពារដែលបានបន្សល់ទុកឲ្យព្រះមហាក្សត្រកម្ពុជាក្រោយឆ្នាំ ១៨៨៤ ។

ហើយគេមិនព្រមឲ្យតម្លៃបន្តិចណាសោះចំពោះការយល់ព្រមពិតប្រាកដទៅលើច្បាប់ដែលមានលក្ខណៈគ្រាន់តែជាទម្រង់ដោយសុទ្ធសាធនេះ [៤០ស្ទួន] ។

### ២ – ភាពមិនអាចទៅរួចនៃអន្តរជាតិក្នុងការបញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីកម្ពុជា

យើងបានរកឃើញនូវទីនេះនូវការត្រូវការនៃសន្ធិសញ្ញា បារាំង-សៀមឆ្នាំ១៨៦៧ ដែលបានហាមប្រាមនៅក្នុងមាត្រាមួយស្ដីពីបារាំងបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងអាណានិគមកូសាំងស៊ីនរបស់ខ្លួននូវព្រះរាជាណាចក្រកម្ពុជា ។ ច្បាស់ជាច្បាប់មួយអាចមានតម្លៃប្រហែលតែចំពោះផ្នែកនៃបទបញ្ញាផ្ទៃក្នុងរបស់បារាំង ដោយជិទាស់នឹង

*(៤០ស្ទួន) / នៅលើការខ្វះខាតទាំងស្រុងនូវសេរីភាពរបស់ព្រះមហាក្សត្រកម្ពុជានៅក្នុងការយល់ព្រមតាមព្រះរាជប្រកាស Cf.Pinto វិជ្ជភាពគតិយុត្ត នៃការវិវត្តន៍របស់រដ្ឋាភិបាលឥណ្ឌូចិន បារាំង ។ Paris Serey 1947 ។*



សន្ធិសញ្ញានេះ ។ ប៉ុន្តែច្បាប់នេះពុំមានតម្លៃជាអន្តរជាតិឡើយ និងជាពិសេសវាមិនមែនជាច្បាប់ទេ ប៉ុន្តែគឺជាអនុក្រឹត្យមួយដែលបានដំណើរការនូវការផ្ទេរនេះ ។

### ៣ – ភាពមិនប្រក្រតីផ្ទៃក្នុងនៃការបញ្ចូលជាឧបសម្ព័ន្ធ

អនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ ត្រូវបានយល់ព្រមដោយក្រឹត្យចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩១៥ ។ ប៉ុន្តែយើងគិតថា ការបញ្ចូលគ្នានូវអត្ថបទទាំងពីរនេះវាពុំមានអានុភាពឡើយ ដែលអាចអនុញ្ញាតឲ្យនៅក្នុងច្បាប់បារាំងនៅក្នុងសម័យនោះនូវការបន្ថែមទឹកដីដោយពិតប្រាកដ ដែលគេបានអះអាងថា នឹងធ្វើបានសម្រេចនោះ ។

#### ក/- គោលការណ៍នៃច្បាប់រដ្ឋធម្មនុញ្ញបារាំង

ការពិតមាត្រា ៨ នៃច្បាប់រដ្ឋធម្មនុញ្ញចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ១៨៧៥ បានចែងថា "គ្មានការប្រគល់ឲ្យ គ្មានការផ្លាស់ប្ដូរ និងការបន្ថែមទឹកដីណាមួយអាចប្រព្រឹត្តទៅបានដោយមិនអាស្រ័យនៃអំណាចច្បាប់នោះឡើយ " ។

ប៉ុន្តែការបញ្ចូលជាឧបសម្ព័ន្ធនៃទឹកដីកម្ពុជាទៅឲ្យកូសាំងស៊ីន ដែលពេលនោះជាអាណានិគមបារាំង គឺជាការបន្ថែមមួយនៃទឹកដីដែលក្នុងនោះតម្រូវការនៃច្បាប់គឺជាការចាំបាច់ ។

ច្បាស់ជាអាណានិគមមានការសប្បាយរីករាយនឹងរបបនីតិប្រតិបត្តិ និងបន្តរស់នៅក្រោមឥទ្ធិពល នៃអំណាចត្រឹមត្រូវតាមបទបញ្ញា ។

ប៉ុន្តែការដាក់បញ្ញាផ្ទុយនេះ មិនតម្រង់ និងមិនអាចតម្រង់ទិសដៅតែទៅលើរបបការិយកិច្ចនៃសមត្ថកិច្ចរបស់រដ្ឋស្ដីពីទឹកដីអាណានិគមប៉ុណ្ណោះទេ ហើយក៏មិនមែនជាការកំណត់ព្រំដែននៃទឹកដីទាំងនេះទេ ។ ចំពោះគំនូសព្រំដែនតម្រូវការនៃរដ្ឋធម្មនុញ្ញ គឺដូចគ្នានិងការធ្វើរបស់អាណានិគម ឬប្រទេសចំណុះ (metropole) នេះគឺអាស្រ័យដោយអំណាចនៃគោលការណ៍ឯកភាពគ្នា និងភាពចែកមិនបាននៃទឹកដីនោះតែម្ដង [៤១] ។

*(៤១) / ម្យ៉ាងទៀត តើគេអាចរៀបរាប់ ឧទាហរណ៍ប្រតិបត្តិនៅក្នុងន័យផ្ទុយ និងថាក្រឹត្យ ឆ្នាំ១៩១៥ ដែលអនុក្រឹត្យនេះផ្ទាល់បានចាត់ចែងនូវទម្រង់បែបបទនៃការផ្លាស់ប្ដូរទឹកដី នៅឥណ្ឌូចិន ដែលមានភាពមិនត្រូវគ្នាជាមួយនិងគោលការណ៍នេះបានដែរឬទេ ។*

### ខ/- កោះ Catrey ពីមុន

តម្រូវការនៃច្បាប់ត្រូវបានទទួលស្គាល់នូវគំនិតស្តីពីការប៉ុនប៉ងនៃការបញ្ចូលជាឧបសម្ព័ន្ធនូវកោះកាត្រី (Catrey) ដែលស្ថិតនៅមាត់ពាមនៃព្រែកកំពត ។ ព្រះមហាក្សត្រកម្ពុជា ក្រោមការគាបសង្កត់របស់ទេសាភិបាលកូសាំងស៊ីន Le Myre de Vilers បានចុះហត្ថលេខាលើអនុសញ្ញាប្រគល់កោះនេះ ទៅឲ្យបារាំង ។ ជាបន្តមកទៀតមានការចោទនូវសំណួរនៃការដាក់ជូននូវអនុសញ្ញានេះទៅឲ្យសភាបារាំងបោះឆ្នោត ដើម្បីឲ្យទឹកដីដែលបានប្រគល់ឲ្យនេះ អាចក្លាយទៅជាផ្នែករួមបញ្ចូលនៃទឹកដីរបស់បារាំង [៤២]។

ក្រសួងការបរទេស ដែលក្រសួងអាណានិគមបានស្នើសុំយោបល់នោះ បានបញ្ជាក់អំពីភាពចាំបាច់ នៃការបោះឆ្នោតនេះ ប្រសិនបើគេចង់បន្ថែមកោះនេះ ទៅឲ្យអាណានិគមកូសាំងស៊ីន ប៉ុន្តែដោយបានវាយតម្លៃអំពីហេតុផលនៃស្ថានការណ៍ល្អ ដែលគេគ្រាន់តែត្រូវទទួលបន្ទុកការគ្រប់គ្រងកោះ និងពិនិត្យពិចារណាអំពីការបង្កើតនូវភ្នាក់ងារបារាំង"ធ្វើជាវិធានការមួយនៃការគ្រប់គ្រង និងជាប៉ូលិសផ្ទៃក្នុង" ។

ដូច្នេះ កោះ Catrey ស្ថិតនៅជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ។

### គ/- សភាពការណ៍ដូចគ្នាបេះបិទរបស់ស្រុក ឡុក និញ និង ភឿក ឡេ

ចំពោះស្រុក ឡុក និញ និង ភឿក ឡេ របស់កម្ពុជា គឺដូចគ្នាបេះបិទ និងករណីនៃកោះ Catrey ដែរ ។ វត្តមាននៃព្រះរាជប្រកាសថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ បានបែងថា ស្រុកទាំងពីរនេះ នឹងត្រូវទុកឲ្យកូសាំងស៊ីន នៅក្នុងការ"កំណត់ព្រំដែន" នៅក្នុងពេលខាងមុខនោះ គឺគ្មានផលប៉ះពាល់ទៅលើលក្ខន្តិកៈជាតិនៃទឹកដីទាំងនេះឡើយ ។

ម្យ៉ាងទៀត សេចក្តីត្រូវការនៃច្បាប់មួយត្រូវបានគេមើលឃើញ នៅក្នុងម័យនោះគឺនៅក្នុងសម័យប្រជុំ នៃគណៈកម្មការអចិន្ត្រៃយ៍របស់រដ្ឋាភិបាលឥណ្ឌូចិន នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ សមាជិកម្នាក់គឺលោក M. de Monpezat បានចោទនូវសំណួរថា "បើសិនជាមិនត្រូវបានឲ្យសច្ចាប័ន ដោយរដ្ឋសភានូវការប្រគល់ឲ្យនៃ

(៤២) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៨៨២ ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងអាណានិគម ឥណ្ឌូចិន A.30 (៥៧) ។



ទឹកដីនេះ" ។ លោកអគ្គទេសាភិបាលស្តីទី បានធ្វើការកត់សម្គាល់ថា "គម្រោងដែលបានដាក់ស្នើទៅគណៈកម្មការអចិន្ត្រៃយ៍ មិនមែនជាការប្រគល់ឲ្យនូវទឹកដីនោះទេ ។ កូសាំងស៊ីនមិនបានប្រគល់នូវចំណិតដីណាមួយមកឲ្យប្រទេសកម្ពុជាទេ ។ វាគ្រាន់តែជាការកែតម្រូវព្រំដែនជួសជុលនូវការភាន់ច្រឡំដែលបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការកំណត់ព្រំដែនលើកទីមួយប៉ុណ្ណោះ ។ ដូច្នេះគម្រោងការនេះមិនមែនជាច្បាប់បង្វែរកម្មសិទ្ធិនោះទេ ប៉ុន្តែវាគ្រាន់តែជាច្បាប់ដែលមានការប្រកាសស្តីពីការសម្គាល់ឃើញនូវអ្វីដែលមានរួចហើយក្នុងពេលកន្លងមក" ។

ប្រសិនបើយើងពិនិត្យមើលចម្លើយនេះ យើងនឹងបានឃើញថា ប្រកបដោយការរិះគន់ដូចតទៅនេះ :

- ប្រាកដ ជាគ្មានការប្រគល់ឲ្យនូវទឹកដីបារាំងមកឲ្យកម្ពុជាទេ ។ ប៉ុន្តែវាច្បាស់ជាមានការកាត់ទឹកដីខ្លះរបស់ខ្មែរដែលគេបានបន្ថែមទៅឲ្យកូសាំងស៊ីនបារាំង ។
- ការ"កំណត់ព្រំដែន" លើកទី១ គឺថា ប្រតិបត្តិការ បោះគោលដី ដែលបានធ្វើឡើងរវាងឆ្នាំ ១៨៧០ និងឆ្នាំ ១៨៧៦ មិនមែនជាការធ្វើតែម្តងនោះទេ ។ នោះគឺជាការបោះគោលដីផ្នែករដ្ឋបាលដោយសុទ្ធសាធ ។
- តើគេអាចប្រាប់លក្ខណៈបានយ៉ាងណាអំពី "ច្បាប់ដែលបានប្រកាស និងការសម្គាល់ឃើញនូវអ្វីដែលមានរួចហើយ" នូវអត្ថបទមួយដែលបានឲ្យសច្ចាប័ននូវច្បាប់ទាំងឡាយដែលប្រកាន់យកដោយខុសច្បាប់ ដើម្បីប្រកាសនូវការបញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីកម្ពុជានៅក្នុងលក្ខខ័ណ្ឌដែលផ្ទុយនឹងច្បាប់ជាក់ស្តែង [៤៣] ។
- ដោយមិនមានការប្រកាសជាក់ស្តែងនោះ យើងគិតថា បានបង្ហាញនូវភស្តុតាងនៃការកែប្រែទឹកដី នឹងត្រូវបានធ្វើឲ្យសម្រេចឡើង ដោយច្បាប់មួយដែលស្ថិតនៅក្រោមលក្ខណៈមួយជាមោឃភាព ។ លោកទេសាភិបាលខ្លួនឯង បានទទួលស្គាល់ដោយមិនបាច់បែងឲ្យច្បាស់ នៅក្នុងវិធានការដែលលោកត្រូវពឹងផ្អែកទៅលើការពោលអះអាង ដោយភូតកុហក ដើម្បីគេចចេញពីតម្រូវការនៃគតិយុត្តនេះ ។ ការ

(៤៣) / គេត្រូវគូសបញ្ជាក់ថា ទង្វើករណីប្រកបដោយគតិយុត្តនេះ នៅក្នុងក្របខ័ណ្ឌនៃច្បាប់ផ្ទៃក្នុងរបស់បារាំង អាចធ្វើទៅបានតែនៅក្នុងវិធានការទាំងឡាយដែលបានធ្វើអន្តរាគមន៍ក្រោយឆ្នាំ ១៨៧៥ ។

ភូតកុហក ឬក៏ការភាន់ច្រឡំត្រូវបានបង្ហាញ ដូច្នេះវានៅសល់តែការសារភាពអំពីភាពមិនត្រឹមត្រូវតាមច្បាប់តែប៉ុណ្ណោះ ។

## ការសន្និដ្ឋាន

នៅក្នុងផ្នែកនេះដែរ មានសេចក្តីរាយការណ៍អំពី ហេតុការណ៍ពិតច្រើនជាងការពិភាក្សាខាងគតិយុត្ត ដែលគេត្រូវសន្និដ្ឋានថា នោះគឺជាបំណងរបស់អ្នកបង្កើតរបស់វា គំនូសព្រំដែនបច្ចុប្បន្នមិនអាចជាគំនូសរដ្ឋបាលដែលមិនអាចមានលក្ខណៈជាខ្មែរ នូវទឹកដីទាំងឡាយដែលភ្ជាប់តាមទម្រង់ការ ទៅឲ្យកូសាំងស៊ីននោះទេ ។ សភាពការណ៍នេះនឹងត្រូវបានចុះអន់ថយ ឬមួយនៅក្នុងអំឡុងពេលនៃការលុបចោលអាណាព្យាបាល ឬមួយនៅក្នុងអំឡុងពេលដែលត្រូវបានផ្តល់សច្ចាប័ននៅក្នុងកាលបរិច្ឆេទចុងក្រោយ ដោយប្រទេសកម្ពុជា ។ គេដឹងថា វាពុំមានអ្វីជួយពីនេះឡើយ ។

ដូច្នេះប្រទេសកម្ពុជាបានរក្សានៅក្នុងទ្រឹស្តីនូវអធិបតីភាពរបស់ខ្លួនទៅលើទឹកដីទាំងនេះ ។

## ភាគ V

## ព្រំដែន វៀង ចូវ ដុក
## និង ហាទៀន មួយផ្នែក និងព្រៃវែង,កណ្តាល
## តាកែវ និង កំពត មួយផ្នែកទៀត
## (១៨៧៣ ‿ ១៩១៤ )

គំនូសនៃផ្នែកព្រំដែននេះ ត្រូវបានកំណត់នៅក្នុងឆ្នាំ ១៨៧៣ និងធ្វើឲ្យក្លាយទៅជាមានរូបរាង ពីទិសខាងកើតទៅទិសខាងលិច ដោយបង្គោលលេខ ៦០ ទៅលេខ ១២៤ និងបន្ទាប់មកទៀត ដោយខ្សែទូរលេខភ្ជាប់ យ៉ាងថាញ់ (Giang Thanh) ជាមួយ



ហាទៀន ។

នៅក្នុងភាគនេះយើងក៏នឹងពិនិត្យមើលផងដែរ នូវជំពូកជាបន្តបន្ទាប់ដូចតទៅនេះគឺ:

- **ជំពូក I : ប្រវត្តិសាស្ត្រនៃការបង្កើតព្រំដែន**
- **ជំពូក II : តម្លៃគតិយុត្តរបស់វា**

## ជំពូកទី I
## ប្រវត្តិសាស្ត្រ នៃការរៀបចំព្រំដែន

## ផ្នែកទី I
## សភាពការណ៍មុនពេលការខារ ចាប់ផ្តើមដំណើរការ

នៅដើមសតវត្សរ៍ទី ១២ ទឹកដីទាំងអស់ ដែលបង្កើតបានកូសាំងស៊ីនខាងក្រោម គឺជាទឹកដីរបស់កម្ពុជា ។ គឺទើបតែចាប់តាំងពីពាក់កណ្តាលសតវត្សរ៍នេះទេ ដែលពួកអណ្ណាមឆ្លៀតឱកាសនៃការចុះខ្សោយរបស់កម្ពុជា ដែលបណ្តាលមកពីសង្គ្រាមមិនឈប់ឈរជាមួយប្រទេសសៀម និងបណ្តាលមកពីជម្លោះផ្ទៃក្នុងផងនោះ បានដកហូតបណ្តាខេត្តដែលមានទាំងនេះ ម្តងមួយ! ម្តងមួយ! ។

យើងមិនមានបំណង ដើម្បីធ្វើការស្រាវជ្រាវប្រវត្តិសាស្ត្រចាប់តាំងពីដើមមកនោះទេ ។ វាហាក់ដូចជាមិនសូវមានប្រយោជន៍ក្នុងការនិយាយដដែលៗនូវអ្វីដែលមានអ្នកនិពន្ធជាច្រើនបានរាយការណ៍ចំពោះបញ្ហានេះរួចហើយនោះទេ ។

គោលបំណងរបស់យើង គឺគ្រាន់តែធ្វើការសិក្សាដោយមានជំនួយពីឯកសារផ្លូវការស្តីពីសភាពការណ៍ដែលកើតមានក្រោយពីការកាន់កាប់របស់បារាំងនូវទឹកដីកូសាំង-ស៊ីនខាងក្រោម ។

យើងនឹងពិនិត្យសភាពការណ៍ជាបន្តបន្ទាប់ពីទិសខាងកើតទៅទិសខាងលិច ។

### ក.– Tadeu [១] (តាជី) ត្រូវបានបញ្ចូលទៅក្នុងទឹកដីកម្ពុជា

---

*(១) / លើផែនទី ឈ្មោះនេះសរសេរថា ត្រា ឌូ (Tra-Du)*

នៅឆ្នាំ ១៨៦៥ ទេសាភិបាលកូសាំងស៊ីន ត្រូវបានគេធ្វើឲ្យឈឺចិត្តយ៉ាងខ្លាំងដោយការសង់ប៉ុស្តិ៍គយអណ្ណាមមួយនៅតាជី (ទីប្រសព្វមុខទន្លេមេគង្គជាមួយនិងព្រែកត្រាឌូ (Prek-Tra-Du) ដើម្បីទារសិទ្ធិស្ដីពីផលយានធ្វើដំណើរចូលមកកម្ពុជា ។ តាមការពិតលោកឧត្ដមនាវី បាន វិនិច្ឆ័យថា លោកមិនបានទទួលស្គាល់ថា Tadeu ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា អាចជា របស់អណ្ណាមនោះទេ គេបានសួរថា ហេតុអ្វីបានជា តាជីដែលនៅក្នុងបរិព័ទ្ធនៃទឹកដីកម្ពុជា និងដែលស្ថិតនៅខាងជើងព្រំដែនបារាំង វាជារបស់អណ្ណាមទៅវិញ" (២) ។

ចាប់តាំងពីឆ្នាំ១៨៦៣មក ប្រទេសបារាំងបានកាន់កាប់ខេត្តបីនៅខាងកើតកូសាំង-ស៊ីន គឺថាខេត្តដែលស្ថិតនៅខាងជើងព្រំដែនបារាំង គឺជារបស់កម្ពុជា ។ នៅក្នុងពេលនោះ ដោយសារថា ប្រទេសកម្ពុជា ត្រូវបានការពារដោយប្រទេសបារាំងនោះ លោកឧត្ដមនាវី បានទទួលបន្ទុកការពារផលប្រយោជន៍របស់ខ្លួនប្រឆាំងនឹងការទន្ទ្រានយកទឹកដី ដោយអាជ្ញាធរអណ្ណាមនៅខេត្ត ចូវ ដុក ដែលស្ថិតនៅខាងក្រៅការត្រួតត្រារបស់បារាំងនៅឡើយ ។ លោកបានបញ្ជូន " Mitraille " (៣) ឲ្យទៅយកមេបញ្ជាការ de Lagrée នៅកំពង់លួង ដើម្បីនាំយកគាត់មក តាជី (Tadeu) ដើម្បីឲ្យគាត់ធ្វើការព្រមានយ៉ាងតឹងរ៉ឹងចំពោះមន្ត្រីអណ្ណាម ។

បន្ទាប់ពីការបង្ហាញនេះមក ប៉ុស្តិ៍ត្រាឌូ បានទទួលពួកអាជ្ញាធរនៅចូវ ដុក នូវ "បទបញ្ជាដើម្បីកុំឲ្យទារពន្ធនាំចូលពីប្រជាជនកម្ពុជាដែលជាការតម្រូវដោយអយុត្តិធម៌ " (៤) នោះ ក៏ដូចជាពន្ធខាងគយផងដែរ ។

លោក ទេសាភិបាលដោយយកបេសកកម្មនេះ ដើម្បីបង្ហាញថា"ការការពារដែលបានយល់ព្រមផ្ដល់ឲ្យប្រទេសកម្ពុជា មិនមែនឥតបានការ ឬក៏ជាការចង់បំភាន់នោះឡើយ" ។

**១.– រវាងចូវ ដុក និងហាទៀន**

នៅក្នុងរបាយការណ៍របស់លោកស្ដីអំពីការយកខេត្តបី នៅខាងលិចកូសាំងស៊ីន

*(២) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៨៦៥ ឯកសារលេខ A 30 (8) ។*
*(៣) / ឈ្មោះរបស់នាវាមួយគ្រឿង ។*
*(៤) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៨៦៥ ដែលបានរៀបរាប់ពីមុន ។*



លោក ឧត្ដមនាវី de la Grandière បានថែងថា "ផ្នែកទឹកដីនៃប្រទេស (រវាងចូវ ដុក និងហាទៀន) មានប្រជាជនកម្ពុជារស់នៅច្រើនជាងប្រជាជនអណ្ណាម" ។ (៥) ។

ប្រជាជនកម្ពុជា ដែលរុញច្រានដោយប្រជាជនអណ្ណាមនោះ "បានថយទៅទិសខាងលិចដែលពួកគេបានកាន់កាប់ភូមិមួយចំនួនធំនៅឡើយ ហើយពួកគេបានរស់នៅដាច់ដោយឡែកទាំងស្រុង ពីប្រជាជនអណ្ណាមដែលសភាពសង្គមមានលក្ខណៈខុសគ្នាយ៉ាងដាច់ស្រឡះ ពីប្រជាជនកម្ពុជា ដូច្នេះក្នុងពេលដែលកម្មសិទ្ធិបុគ្គលត្រូវបានបង្កបង្កើតយ៉ាងខ្លាំងនៅកូសាំងស៊ីននោះ ប្រជាជនកម្ពុជាមានដីភូមិរបស់ពួកគេរួមគ្នា ដែលត្រូវបានបែងចែករវាងមេគ្រួសារទាំងឡាយនៅក្នុងដំណាក់កាលដែលបានកំណត់ នៅក្នុងចំណោមពួកគេម្នាក់ៗ..." (៦) ភូមិរបស់ប្រជាជនកម្ពុជាទាំងនេះមានវត្តរបស់ពួកគេ មានអង្គការរដ្ឋបាលរបស់ពួកគេ ។ ពួកគេរស់នៅដោយ "រៀបចំជាស្រុក ជាឃុំ ដូចពួកអ្នកលុកលុយ (អណ្ណាម) របស់ពួកគេដែរឬ (៧) ។

យើងនឹងអាចរៀបរាប់រវាងភូមិដទៃទៀត ស្រុកទ្រីតូង (Triton) (ស្រុកស្វាយទង) ដែលមានលក្ខណៈជាភូមិកម្ពុជាពិតៗ ស្ថិតនៅរវាង ចូវដុក និងហាទៀន ជាប់គ្នា នឹងទឹកដីនៃខេត្តតាកែវ របស់កម្ពុជានិងដែលថែរក្សានូវចរិតលក្ខណៈនេះជាដរាបនោះ"មានការិយាល័យប៉ុស្តិ៍ តំបន់ជាច្រើនដែលការសាងសង់ត្រូវបានចុះក្នុងបញ្ជីចរិការបស់និគមចូវដុក សម្រាប់ការបំពេញការងារធម្មតា នឹងត្រូវបានបង្កើតឡើងនៅភូមិអាន ថាញ់ និង ភូមិទ្រីតូង (ស្វាយទង) នៅចំកណ្ដាលស្រុកទាំងឡាយរបស់កម្ពុជា" (៨) ។

**គ.– នៅក្នុងផ្នែកដទៃទៀត នៃកូសាំងស៊ីន**

ទៅខាងត្បូងឆ្ងាយ មាននិគមខ្លះ មានប្រជាជនកម្ពុជារស់នៅច្រើនជាងប្រជាជនអណ្ណាម។ ដើម្បីផ្ដល់នូវគំនិតមួយស្ដីអំពីតួលេខនៃប្រជាជនកម្ពុជានៅក្នុងនិគមផ្សេងៗ នៅកូសាំងស៊ីន យើងយល់ឃើញថា វាមានប្រយោជន៍ដើម្បីភ្ជាប់នូវស្ថិតិជាមួយ

*(៥) / លិខិតរបស់ឧត្ដមនាវី de la Grandière ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ ១៨៦៥ ដែលបានរៀបរាប់ពីមុន ។*
*(៦) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ១៨៧៣ ឯកសារលេខ A.10 (10) ។*
*(៧) / របាយការណ៍របស់នាយកមហាផ្ទៃ Vial ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ ១៨៦៧ ឯកសារលេខ A.008 ។*
*(៨) / របាយការណ៍របស់ទេសាភិបាល កូសាំងស៊ីន ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ១៨៩៦ ផ្ញើទៅជូនអគ្គទេសាភិបាល ឯកសារលេខ A 20 (42) ។*

និងរបាយការណ៍ដែលបានរាយការណ៍ជាទូទៅ ស្តីអំពីកូសាំងស៊ីន នៅក្នុងឆ្នាំ១៨៧៩ (ឧបសម្ព័ន្ធ៩) ។ គេបានពិនិត្យឃើញថា នៅក្នុងនិគមសុកត្រាំង(ឃ្លាំង) និងត្រាវិញ (ព្រះត្រពាំង)ចំនួននៃប្រជាជនកម្ពុជាថែមទាំងលើសប្រជាជនអណ្ណាមទៀតផង ។

**ឃ.–ហាទៀន (ខេត្តពាម)**

សភាពការណ៍នៃខេត្តហាទៀន គឺមានលក្ខណៈពិសេស និងសមទទួលបាននូវការសិក្សាជាពិសេសផងដែរ ។

នៅមុនការកាន់កាប់ខេត្តទាំងបី នៅខាងលិចកូសាំងស៊ីន ដោយកងទ័ពបារាំងនោះ ព្រះមហាក្សត្រនរោត្តម ទ្រង់បានដាក់សំណើរចំពោះ លោកឧត្តមនាវី de la Grandière នូវការទាមទារយកខេត្តហាទៀន ។ ប៉ុន្តែលោកឧត្តមនាវី បានបង្វែងដាន" ដោយបានប្រកាសថា ប្រទេសបារាំងនឹងមានការពិចារណាចំពោះខេត្តនេះ [៩] ។ ការពិតការកាន់កាប់ខេត្តហាទៀន នឹងជួយពង្រឹងសន្តិសុខទីក្រុង ព្រៃនគរ គឺ "វាច្បាស់ណាស់ថា ការរៀបចំរបស់យើងនៅព្រៃនគរ នៅ មីថ (Mitho) (មេ–ស)បានអូសទាញយើងឲ្យពង្រីកអាណាចក្ររបស់យើងដោយចៀសមិនរួចនៅលើដីទៀបកោះទាំងអស់ដែលត្រូវបានបង្កើតឡើង រវាងកាន់កាវ (Kankao) ឬហាទៀន ដែលជាដីលយចូលទៅក្នុងសមុទ្ររបស់កម្ពុជា និង ជ្រោយ Saint - Jacques " [១០] ។

ព្រះមហាក្សត្រ នរោត្តម ទ្រង់ព្រះរាជលិខិតទាមទារ ខេត្តនេះដែលនៅជាប់ផ្ទាល់នឹងប្រទេសកម្ពុជាពីព្រោះខេត្តនេះមានប្រជាជនកម្ពុជារស់នៅច្រើនជាងប្រជាជនអណ្ណាម ហើយដែលត្រូវបានដណ្តើមយកដោយតុលាការក្រុងវេដោយប្រឆាំងនឹងច្បាប់ទាំងអស់ ។

នៅឆ្នាំ១៨៦៧ ទឹកដីនេះ ស្ទើរតែគ្មានមនុស្សនៅលើកលែងតែRach-Gia (ក្រមួន–ស) ដែលមានប្រជាជនចំនួន ២០.០០០នាក់ រស់នៅជ្រោយកាម៉ៅ (Ca Mau)(ទឹកខ្មៅ) ដែលមានផ្ទះចំនួន៥០ខ្នងហើយនិងទីរួមខេត្តហាទៀន ដែលមានប្រជាជនពី ២.០០០ទៅ៣.០០០នាក់រស់នៅ ។ ផ្នែកនៅសល់នៃទេសភូមិ ជាពិសេសរវាងចូវដុក (មាត់ជ្រូក) និងហាទៀន នៅលើភ្នំដែលមានថ្មបាយក្រៀម "ជាពិសេសភ្នំ ថាត់ សឺន

(៩) / របាយការណ៍របស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ១៨៦៨ ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងជើកដណ្តើន A.20 (9) ។

(១០) / លិខិតរបស់ឧត្តមនាវីជ Charnner ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ១៨៦១ ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងជើក ដណ្តើន A.30 (1) ។



ឬភ្នំប្រាំពីរដែលស្ថិតនៅពាក់ កណ្តាលចម្ងាយរវាងទីក្រុងទាំងពីរនេះ គឺរស់នៅដោយប្រជាជនកម្ពុជា [១១] ។

ចំពោះកាលៈទេសៈទាំងឡាយដែលនៅក្នុងនោះ ខេត្តនេះត្រូវបានកំហែងយកដោយពួកអណ្ណាមនោះ យើងជឿថា វាមានប្រយោជន៍ខ្លាំងណាស់ ដើម្បីរៀបរាប់អំពីការសិក្សាដ៏លំអិតបំផុត ដែលធ្វើឡើងដោយលោក ឆាល បេ.មេបុន (Charles B. May bon) នៅក្នុងសៀវភៅ "ប្រវត្តិសាស្ត្រសម័យទំនើបរបស់ប្រទេសអណ្ណាម (១៥៩២–១៨២០) "របស់លោក [១២] ។

"នៅក្នុង បណ្តាឆ្នាំចុងក្រោយនៃសតវត្សរ៍ទី១២ មានជនជាតិចិន ម្នាក់ឈ្មោះ ម៉ាក់ គូវ (Mac - Cuu) (ឯកសារខ្លះថា ម៉ាក់គីវ) មានដើមកំណើតមកពីខេត្ត ឡេ ឈូ (Lei Tcheou) នៅខាងត្បូង ខេត្តក្វាង ទុង (Kouang Toung) ដែលរូបគាត់ក៏ត្រូវបានគេបណ្តេញចេញពីមាតុភូមិដែរ ដោយសារជ័យជំនះរបស់រាជវង្ស ស៊ីញ ( Ts'ing ) នោះបានឆ្លងកាត់តាមកូសាំងស៊ីន បន្ទាប់មកបានតាំងទីលំនៅ នៅប្រទេសកម្ពុជា ។

"នៅតាម ឆ្នេរនៃឈូងសមុទ្រសៀម នៅក្នុងតំបន់ដែលនៅពេលនោះប្រជាជនកម្ពុជាហៅថា ពាម និង ម៉ាង ខាម (Mang Kham) ពួកអណ្ណាម ហៅថា ភួង ថាញ់ (Phuong - Thanh) ត្រូវបានបង្កើតឡើងនូវមជ្ឈមណ្ឌលមួយ ដែលមិនសូវមានសារសំខាន់ប៉ុន្មាន ហើយដែលប្រជាជនអណ្ណាម ចិន ម៉ាឡេ និងកម្ពុជាបានរកស៊ីរត់ពន្ធតែមិនសូវជាធំដុំប៉ុន្មានទេ ។ គឺនៅទីនោះហើយដែលម៉ាក់គូវបានទៅតាំងទីលំនៅ ។ គាត់បានផ្តល់ការងាររបស់គាត់ដល់មន្ត្រីកម្ពុជាដែលបានរស់នៅទីនោះ ហើយការហូតភាស៊ីល្បែងត្រូវបានប្រគល់ឲ្យគាត់ គាត់រកស៊ីមានបានយ៉ាងឆាប់រហ័ស ។ គាត់បានឲ្យអាណានិគមជន ជាច្រើនចូលមករស់នៅនិងបង្កើតបានភូមិជាច្រើន ដែលមានការរីកចំរើនជាពិសេសខេត្តកំពតនៅកោះ ភូ ក្អុក នៃខេត្តហាទៀន នៅរ៉ាចយ៉ា និងកាម៉ៅ ។ ប៉ុន្តែនៅចំកណ្តាលនៃការជ្រួលច្របល់ដែលបានធ្វើឲ្យរំដើបរំជួលដីទៀងទាត់នៅក្នុងប្រទេសកម្ពុជានោះ អាណានិគមដែលបានកើតឡើងនោះក៏នឹងអន្តរាយទៅវិញដែរ ។

(១១) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ ១៨៦៧ ផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងជើកដណ្តើន A.20 (6) ។

(១២) / លោក Charles B. Maybon ប្រវត្តិសាស្ត្រថ្មី របស់ប្រទេសអណ្ណាម (១៥៩២–១៨៣០) ទំព័រ ១២២ និង ៥ ។

តទៅនេះ គឺជាមូលហេតុខ្លះៗ ។

..."ព្រះអង្គសួរ ដែលបានដាក់រាជ្យ ដើម្បីថ្វាយដល់ព្រះអង្គម្ចាស់ក្សត្រី អ៊ីម នៅក្នុងឆ្នាំ ១៧០០ ដែលត្រូវបានទទួលយកដោយអណ្ណាមនោះ បានកាន់កាប់រដ្ឋាភិបាលឡើងវិញ នៅឆ្នាំបន្ទាប់ និងបានដាក់រាជ្យជាថ្មីនៅឆ្នាំ ១៧០២ ប៉ុន្តែលើកនេះ គឺដើម្បីជាគុណប្រយោជន៍ដល់ព្រះរាជបុត្រផ្ទាល់របស់ព្រះអង្គ ។ នៅក្នុងឆ្នាំ ១៧១៤ ព្រះមហាក្សត្រថ្មីនេះ ព្រះនាមព្រះស្រីធម្មា (Preah Srey Thomea) និងព្រះអនុជរបស់ព្រះអង្គ ព្រះនាមព្រះអង្គទង់ បានធ្វើសង្គ្រាមជាមួយនិងព្រះរាមថ្លៃរបស់ខ្លួន គឺព្រះអង្គអ៊ីម ។ ព្រះអង្គអ៊ីមដោយបានការជួយពីអណ្ណាម និងពីលាវនោះ បានទទួលជោគជ័យក្នុងការរាំងខ្ទប់ព្រះអង្គម្ចាស់ទាំងពីរនេះនៅលង្វែក ។ បន្ទាប់ពីការតស៊ូអស់រយៈពេល៣ខែមក ព្រះអង្គម្ចាស់ទាំងពីរអង្គនេះ បានភៀសព្រះកាយ (គឺព្រះអង្គទាំងពីរបានភៀសព្រះកាយទៅកាន់ក្រុងអាយុធ្យា) នៅអមព្រះមហាក្សត្រសៀម ដើម្បីសាកល្បងលួងលោមព្រះចៅសៀមឲ្យស្ថិតនៅក្នុងផលប្រយោជន៍របស់ព្រះអង្គទាំងពីរ ។ ព្រះអង្គបានសោយរាជ្យនៅឧដុង្គ នៅក្នុងពេលនោះ ។ នៅឆ្នាំ ១៧១៥ កងទ័ពដ៏តូចមួយរបស់សៀមបានធ្វើដំណើរមកកាន់ខេត្តបាត់ដំបង ដើម្បីនាំយកព្រះស្រីធម្មាមកវិញ ។ ពេលនោះព្រះអង្គអ៊ីម បានបដិសេធនូវការសម្រុះសម្រួលទាំងអស់ជាមួយសៀមដែលពួកនេះប្រហែលជាមានអារម្មណ៍ថា ពុំមានកម្លាំងទ័ពគ្រប់គ្រាន់នោះក៏បានត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ប៉ុន្តែនៅឆ្នាំបន្ទាប់មក ពួកគេបានត្រឡប់មកវិញ ជាមួយព្រះអង្គទង់ (Ang Tong) ដែលទទួលភារៈពីព្រះរាមរបស់ព្រះអង្គឲ្យមកបង្កកុប្បកម្មនៅក្នុងប្រទេស ។ ព្រះមហាក្សត្រ អ៊ីម បានយាងចេញជាបន្ទាន់ ជាមួយនឹងកងទ័ពអណ្ណាម ដើម្បីទៅប្រយុទ្ធតតាំងជាមួយពួកអ្នកលុកលុយ ។ ក្នុងការធ្វើសង្គ្រាមនេះ ព្រះអង្គទង់ បានត្រូវរបួស ហើយក៏បានភៀសព្រះកាយទៅគង់នៅលើភ្នំនៃខេត្តពោធិសាត់ ដើម្បីរង់ចាំការជួយសង្គ្រោះជាថ្មីទៀត ។ ពេលនោះព្រះមហាក្សត្រសៀម បានសម្រេចព្រះទ័យធ្វើការវាយប្រហារប្រទេសជិតខាងរបស់ព្រះអង្គតាមពីរផ្លូវ ។ ព្រះអង្គបានបញ្ជូនកងទ័ពមួយកងឲ្យវាយលុកពីទិសខាងកើត ហើយនៅក្នុងពេលនោះ ព្រះអង្គបានដឹកនាំ ដោយផ្ទាល់ព្រះអង្គនូវកងទ័ពចំនួន ៣.០០០នាក់ ចុះទូកដ៏រឹងមាំ សំដៅទៅកាន់ខេត្តហាទៀន ។



ព្រះអង្គបានធ្វើការវាយប្រយុទ្ធនៅហាទៀន។ម៉ាក់គូវ ដែលស្ថិតនៅក្នុងស្ថានភាពការពារដោយឥតសំចៃ ប៉ុន្តែដោយហេតុថា ទីក្រុងដែលទើបតែបង្កើតថ្មី គ្មានជញ្ជាំងព័ទ្ធជុំវិញ គ្មានជំរំលេណដ្ឋាន មិនអាចទប់ទល់បានជាមួយនិងកម្លាំងតស៊ូដ៏ធំធេងរបស់ពួកអ្នកវាយលុកបានឡើយ ។ ទាហានសៀមក៏ដណ្តើមយកបាន និងបានប្លន់ទ្រព្យសម្បត្តិនៅទូទាំងស្រុក ដែលនៅជិតៗនោះ ។ ប៉ុន្តែទូករបស់ពួកគេត្រូវបានបំផ្លាញដោយខ្យល់ព្យុះ ហើយមេទ័ពរបស់ពួកគេបន្ទាប់ពីបានប្រមែប្រមូលបានទូកខ្លះដែលបានគេចផុតពីមហន្តរាយនោះមក បានវិលត្រឡប់ទៅប្រទេសសៀមវិញ ។ នៅក្នុងពេលនោះ កងទ័ពជើងគោកបានមកដល់ក្រុងឧដុង្គ ដែលមានបន្ថែមទាហានខ្មែរមួយចំនួនធំ ។ ព្រះអង្គអ៊ីម បានយាងតម្រង់ទៅរក កងទ័ពនោះ ប៉ុន្តែមិនមែនយាងទៅប្រយុទ្ធជាមួយកងទ័ពជើងគោកនោះទេ ផ្ទុយទៅវិញ ព្រះអង្គអ៊ីម បានទទួលស្គាល់អំណាចរបស់សៀម និងថ្វាយដល់ព្រះមហាក្សត្រ សៀមនូវផ្កាមាស និងផ្កាប្រាក់ ជាជំនួសនៃការសុំចុះចូល ។ កងទ័ពសៀម ដោយបានធ្វើពលីកម្ម ដើម្បីជាផលប្រយោជន៍ដល់ព្រះអង្គម្ចាស់ដែលពួកគេបានមកជួយប្រយុទ្ធការពារនោះ ពេលនោះក៏បានដកថយទៅវិញ ។ លទ្ធផលដ៏សំខាន់នៃយុទ្ធនាការជាបន្តបន្ទាប់នេះ គឺការទទួលស្គាល់នូវឧត្តមភាពរបស់សៀមដោយព្រះមហាក្សត្រ អង្គអ៊ីម គឺព្រះអង្គច្បាស់ជាជឿថា និងបានរកឃើញនូវការតែងតាំងនូវមុខដំណែងមួយនៅក្នុងព្រះរាជវាំងអាយុធ្យា ដែលធ្វើឲ្យអំណាចរបស់ព្រះអង្គបានរីកធំធាត់ទៅលើប្រជារាស្ត្ររបស់ព្រះអង្គ អំណាចដែលត្រូវបានពិភាក្សាដោយឥតឈប់ឈរ ដោយព្រះរាមថ្លៃរបស់ព្រះអង្គ និងអ្នកដើរតាមរបស់ព្រះអង្គ ។ ប៉ុន្តែអធិរាជថ្មីរបស់ព្រះអង្គ មិនអាចការពារ ប្រឆាំងនឹងការទន្ទ្រានយកទឹកដីរបស់អតីតអ្នកការពារបានឡើយ ។ មានការលុកលុយពីរលើក គឺនៅក្នុងឆ្នាំ ១៧៣១ និងឆ្នាំ១៧៣២ ពួកអណ្ណាមបានចូលលុកលុយព្រះរាជាណាចក្រ និងបានធ្វើឲ្យកងទ័ពកម្ពុជារត់គេចខ្លួន និងបានឡើងតាមទន្លេមេគង្គ រហូតដល់ឡុង ហោ (វិញ ឡុង) (រោងដំរី) ។ ពួកគេបានបង្កើតនូវ ខេត្តថ្មីពីរ គឺខេត្ត ឌិញ ធឿង (Dinh Thoung) និងខេត្តឡុង ហោ (Long Ho) ។ នៅ ឆ្នាំ ១៧៣៦ នៅក្រោមរជ្ជកាលរបស់ព្រះរាជបុត្ររបស់ព្រះមហាក្សត្រអ៊ីម ព្រះនាមព្រះសូថា សង្គ្រាមបានផ្ទុះឡើងសារជាថ្មី នៅក្នុងព្រះរាជវង្សានុវង្ស និងពួក អណ្ណាម

ដែលគេនឹងបានដឹងនៅខាងមុខទៀតនោះ ដែលពួកគេបានឆ្លៀតឱកាសនៃការទាស់ទែងគ្នានេះ ដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងៗទៀត ។

"ចំពោះម៉ាក់គូវវិញ ក្រោយពីបានទទួលបរាជ័យ ដោយសារពួកសៀមវាយមកគាត់បានភៀសខ្លួន ប៉ុន្តែសង្គ្រាមបានចប់ហើយ គាត់បានគិតថា : ត្រូវប្រគល់ខ្លួនទៅឲ្យអ្នកការពារម្នាក់ ដែលមានអំណាចខ្លាំងជាងព្រះមហាក្សត្រកម្ពុជា ហើយក៏បានបញ្ជូនគណៈប្រតិភូពីរទៅកាន់ក្រុងវេ ដោយនាំយកនូវលិខិតសុំអនុគ្រោះមួយ ដែលនៅក្នុងលិខិតនោះ គាត់បានសុំឲ្យស្តេច ក្រុងវេ តែងតាំងគាត់ឲ្យធ្វើជាចៅហ្វាយខេត្ត ហាទៀន ។ ស្តេច មិញ វឿង (Minh Vuong) (១៦៩១ – ១៧២៥) ថ្វីបើព្រះអង្គគ្មានសិទ្ធិណាមួយ ក៏ដោយ ក៏ព្រះអង្គប្រញាប់ប្រញាល់យល់ព្រមតាមសេចក្តីស្នើនេះ ហើយយូរក្រោយមក ម៉ាក់ គូវ បានអញ្ជើញទៅកាន់វាំងនៅវេ ដោយផ្ទាល់ខ្លួន ដើម្បីសម្តែងនូវការដឹងគុណចំពោះព្រះអង្គមិញវឿង " ។

ព្រះមហាក្សត្រ អណ្តាម ពុំមានសិទ្ធិណាមួយ ដើម្បីតែងតាំងម៉ាក់គូវ ឲ្យធ្វើជាចៅហ្វាយខេត្តហាទៀន នោះឡើយ ពីព្រោះថាខេត្តនេះគឺជាខេត្តរបស់កម្ពុជា ហើយព្រះរាជ-វាំងវេ ក៏មិនដែលត្រូវបានប្រគល់សិទ្ធិឲ្យដែរ និងគ្មានទាំងការយល់ព្រមពីព្រះមហាក្សត្រកម្ពុជា ទាំងគ្មានការផ្ញើសញ្ញើយ ព្រមទាំងមិនដែលបានកាន់កាប់ខេត្តនោះផង ។ ចំណែកម៉ាក់គូវវិញ ក៏គាត់មិនមានសិទ្ធិណាមួយនៅលើដីនេះដែរ គាត់ក៏មិនមែនជាម្ចាស់ ហើយគាត់ថែមទាំងមិនមែនជាដំណាងរបស់ព្រះមហាក្សត្រកម្ពុជា ដើម្បីគ្រប់គ្រងខេត្តនោះផងទេ។ តើព្រះអង្គមានអំណាចអ្វីដើម្បីចាត់ចែងការងាររបស់អ្នកដទៃ...? តើហេតុអ្វីបានជាព្រះមហាក្សត្រអណ្តាមអាចតែងតាំងម៉ាក់គូវ ឲ្យធ្វើជាចៅហ្វាយខេត្តនៅលើទឹកដីមួយដែលមិនមែនជាព្រះរាជាណាចក្ររបស់ព្រះអង្គ ប៉ុន្តែគឺជាទឹកដីមួយដែលជារបស់ប្រទេសជិតខាងនោះ... ?

សភាពការណ៍ខេត្តហាទៀន មានលក្ខណៈប្រហាក់ប្រហែលគ្នា និងខេត្តទន្លេរពៅ និងម្លូព្រៃរបស់កម្ពុជាដែលត្រូវបានប្រគល់ទៅឲ្យអាជ្ញាធរសៀម ដោយចៅហ្វាយខេត្តកម្ពុជាឈ្មោះ មិញ (Minh) ក្រោយពីការក្បត់ជាតិរបស់គាត់មក ។ ប៉ុន្តែនៅក្នុងករណីចុងក្រោយនេះ មិញ គ្រាន់តែជាអ្នកគ្រប់គ្រងធម្មតាម្នាក់ប៉ុណ្ណោះ ហើយដែល ការពិតនោះគាត់មិនត្រូវបានផ្តល់អំណាចឲ្យ ដើម្បីរៀបចំទឹកដីដែលគាត់គ្រាន់តែទទួលបន្ទុកគ្រប់គ្រងតែប៉ុណ្ណោះ ហើយយ៉ាងហោចណាស់ក៏គាត់មាននាទីជាតំណាងនៃអំណាចរបស់ព្រះមហាក្សត្រខ្មែរ ។ ចំណែកម៉ាក់គូវគាត់មិនមានអ្វីសោះឡើយ ។



ចំពោះករណីខេត្តទន្លេរពៅ និងម្លូព្រៃ អាជ្ញាធរបារាំងបានសម្រេចក្នុងពេលអវត្តមាននៃសិទ្ធិទាំងអស់របស់ប្រទេសសៀម នៅលើទឹកដីទាំងនេះ និងដោយផ្អែកលើច្បាប់ទាំងឡាយដែលមិនអាចផ្ទេរសិទ្ធិបានរបស់ប្រទេសកម្ពុជានោះ គេបានទទួលនូវការប្រគល់មកឲ្យប្រទេសនេះវិញនៅក្នុងឆ្នាំ ១៩០២ ។

សេចក្តីសម្រេចដូចគ្នានេះ នឹងអាចត្រូវបានប្រកាន់យកចំពោះខេត្តហាទៀន ពីព្រោះវាផ្ទុយទៅនឹងភាពសមហេតុសមផលនៃគតិយុត្តដែលដំណោះស្រាយពីរប្រឆាំងគ្នាដាច់ខាតនោះ អាចត្រូវបានប្រកាន់យកនៅក្នុងករណីពីរដែលដូចគ្នា ។

ប៉ុន្តែនៅទីនេះ អំណាចនៃអ្នកការពារបានឃើញនូវការប្រឈមមុខចំពោះផលប្រយោជន៍អាណានិគមរបស់ខ្លួននៅក្នុងន័យត្រឹមត្រូវ ផលប្រយោជន៍ទាំងឡាយនៃការកាន់កាប់របស់ខ្លួននៅកូសាំងស៊ីនមួយផ្នែកនិងផលប្រយោជន៍នៅក្នុងព្រះរាជាណាចក្រដែលស្ថិតនៅក្រោមការការពារមួយផ្នែកទៀត ។ គឺផលប្រយោជន៍របស់អ្នកទីមួយដែលអំណាចនៃអ្នកការពារបានយល់ព្រមផ្តល់នូវការស្រឡាញ់ចូលចិត្តជាង ដោយមិនបានទាមទារនូវខេត្តដែលមានបញ្ហានៅក្នុងនាមនៃប្រទេសកម្ពុជានោះទេ នៅពេល ដំបូងហើយបន្ទាប់មកនៅពេលដែលអំណាចនៃអ្នកការពារនេះ បានទទួលនូវការដកថយនៃការគ្រប់គ្រងរបស់អណ្តាមនោះដោយធ្វើការបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងទឹកដីអាណានិគមរបស់ខ្លួនយ៉ាងនោះគឺជាការប៉ះពាល់ដែលមិនអាចប្រកែកបាន ដល់ច្បាប់ទាំងឡាយរបស់ប្រទេសកម្ពុជាដែលមិនអាចលក់ឬក៏បញ្ចាំបាននោះ ។

ហើយនៅពេលដែលគេត្រូវការបំបែកចេញឲ្យបានច្បាស់លាស់នូវទឹកដីរបស់ប្រទេសកម្ពុជាដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធពីព្រះរាជាណាចក្រខ្មែរនោះ ផលប្រយោជន៍របស់ព្រះរាជាណាចក្រដែលស្ថិតនៅក្រោមការការពារ ត្រូវបានគេមិនទទួលស្គាល់តទៅទៀតឡើយ ។

## ផ្នែកទី II
## ការគូសព្រំដែន

### ១.– ការរៀបចំ

ដូចការគូសព្រំដែនពីលើកមុនដែរ ពួកអធិការបារាំងនៅចូវដុក និងហាទៀនត្រូវបានឲ្យទទួលបន្ទុកធ្វើការសិក្សា ដំឡើងផែនទី និងដាក់បង្ហាញនូវគម្រោងនានា ។

ដើម្បីនឹងសម្រេចនៅក្នុងរឿងនេះ ការសិក្សាទាំងឡាយត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៨៧១ ដោយទេសាភិបាលកូសាំងស៊ីន ។

នៅក្នុងលិខិតមួយចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៨៧១ ផ្ញើទៅជូនតំណាងប្រទេសបារាំងប្រចាំប្រទេសកម្ពុជា ទេសាភិបាលកូសាំងស៊ីនបានចង្អុលបង្ហាញថា វាជាសិទ្ធិរបស់ព្រះមហាក្សត្រ ដើម្បីយល់ព្រមលើការងារកំណត់ព្រំដែននៅពេលដែលការងារនេះត្រូវបានធ្វើរួចស្រេចបាច់ ។

### ២.– អនុសញ្ញា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៧៣ (ឧបសម្ព័ន្ធ១០) និងការចាប់ប្រតិបត្តិការងារ

ការសិក្សារបស់អធិការទាំងពីរនាក់ត្រូវបានធ្វើរួចស្រេចហើយ អនុសញ្ញាមួយត្រូវបានឡាយព្រះហស្តលេខា និងចុះហត្ថលេខាដោយព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងទេសាភិបាលកូសាំងស៊ីន ។

អនុសញ្ញានេះ បានរៀបរាប់អំពីចំណុចសំខាន់ៗថា តើគំនូសព្រំដែននេះត្រូវឆ្លងកាត់តាមណា គឺ "ព្រំដែនរវាងកូសាំងស៊ីនបារាំង និងព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ដោយបង្គោលដែលមានបង់លេខ និងចារិកអក្សរបង្ហាញអំពីកម្មវត្ថុរបស់វា ។ ចំនួនបង្គោលមាន ១២៤ ដើម ។ បង្គោលលេខ១ ត្រូវដាំនៅចុងខាងកើតនៃព្រំដែន ហើយការក្រិត្យនឹងបន្តទៅទិសខាងលិច នៅក្នុងលំដាប់ធម្មជាតិនៃលេខ រហូតដល់បង្គោលលេខ ១២៤ ដាំនៅចម្ងាយ ១២០០ម នៅខាងជើងព្រែកជីក វីញតេ និង ភូមិអណ្ណាម ហ្វាថាញ់ (Hoa - Thanh) " ។

បើតាមការរៀបរាប់នោះ ភូមិទាំងឡាយ ស្ថិតនៅតាមបណ្តោយគំនូសនិងតាមការចង្អុលបង្ហាញនៃទិសរបស់វា ។



ភាគទីមួយគឺរបាយការណ៍ស្តីពីការគូសព្រំដែនដែលធ្វើបានសម្រេចនៅក្នុងឆ្នាំ ១៨៧០ និង ១៨៧២ (ផ្នែក តៃនិញ ត្រាំងបាង និង តាន់អាន) ។ ចំពោះផ្នែកថ្មី (គឺថាចាប់តាំងពីបង្គោលលេខ៦០) ព្រំដែន "បានដើរតាមត្រើយខាងជើងនៃព្រែកជីក ជ្រីអាសី (Chris - Asey) [ ជាភាសាវៀតណាម ហ៊ុងង្វៀន (Hung Nguyen) ] កាត់ ព្រែកជីកនេះនៅមាត់ពាម នៃពាមស្តី (Peam Sdey) [ ជាភាសាវៀតណាម តាឌូ (Ta-du) ] ដើរតាមត្រើយខាងជើងនៃរ៉ាច់ បាណាម (Rach Banam) កាត់ទន្លេខាងក្រោយនៅខាងត្បូងកោះគគី (KoKi) [ ជាភាសាវៀតណាម គូ ឡាវ កាយ សេន (Cu Lao Cai Sen) ] ឆ្លងកាត់ត្រង់កន្លែងប្រសប់មុខនៃព្រែកក្រូច ជាមួយនឹងព្រែកស្លូតដើរតាមខ្សែស្របមួយនៅ វីញតេ នៅខាងជើងទល់នឹងភូមិយ៉ាំងថាញ់ (Giang-Thanh) ហើយចេញពីនោះតម្រង់ទៅហាទៀន ដោយបោះបង់នៅខាងកើតព្រែកជីក នូវ ព្រែកក្រុះ" ។

កំណត់ហេតុមួយ ចុះកាលបរិច្ឆេទដូចគ្នា គឺថាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៧៣ បានផ្តល់នូវការចង្អុលបង្ហាញលំអិតអំពីទីតាំងនៃបង្គោលនីមួយៗ ។

### ៣.– ការសិក្សាពិពណ៌នាអំពីព្រំដែន

#### ក.– ផ្នែកទីមួយ

[ (រវាងទន្លេ សុង តាំ លី (Song Tam Ly) និងទន្លេមេគង្គ) ] (បង្គោលលេខ៦០ ទៅបង្គោលលេខ ៨៣) ។

"បង្គោលលេខ ៦០ ត្រូវបានដាំនៅខាងជើងកន្លែងយកទឹកនៃ គិញ កាយ កូ (King Cai Cô) នៅក្នុងទន្លេ សុង តាំ លី ឬសុងត្រាបិច (ព្រែកត្របែក ជាភាសាកម្ពុជា)"។

"ចាប់ពីបង្គោលលេខ ៦០ ព្រំដែនបានដើរតាមត្រើយខាងស្តាំនៃទន្លេសុងតាំលី រហូតដល់ជួបជាមួយ សុង ឌិញ បា (Song Dinh Ba) ដែលដើរតាមត្រើយខាងជើង រហូតដល់បង្គោលលេខ ៦១" ។

"បង្គោលលេខ ៦១,៦២,៦៣,៦៤,៦៥,៦៦,៦៧, និង ៦៨ ត្រូវបានដាំនៅត្រើយខាងជើង សុងឌិញបា ។

"បង្គោលលេខ៦៨ ត្រូវបានដាំនៅចំណុចមួយដែលព្រែក សុង ឌិញបា បានយក

ឈ្មោះថា សុង សូ ហា (Song So Ha) ។

"ព្រំដែនដែលចុះតាមត្រើយខាងស្តាំ (ខាងជើង) នៃ សុង សូ ហា រហូតដល់កន្លែងបំបែកជាមួយ រ៉ាច់ អា ហ៊ូ (Rach A Hu) បង្គោលលេខ ៦៩ ។

"ពីបង្គោលលេខ ៦៩ ព្រំដែនបានឡើងទៅ រ៉ាច់ អា ហ៊ូ រហូតដល់កន្លែងចាប់ប្រភពរបស់វា ទៅដល់បង្គោលលេខ៧០ រួចចុះទៅរ៉ាច់ ម៉ុក ហា (Rach Moc Ha) រហូតដល់បង្គោលលេខ ៧៣ នៅពីមុខ រ៉ាច់ ត្រា ឌូ (Rach Tra Du) និងបន្តឡើងតាមត្រើយខាងស្តាំនៃ រ៉ាច់ បាណាម ដោយឆ្លងកាត់តាមបង្គោលលេខ ៧៤,៧៥,៧៦,៧៧,៧៨ រហូតដល់បង្គោលលេខ ៧៩ នៅចម្ងាយ ៨០ ម នៅខាងក្រោមដៃ បែកចេញរបស់ រ៉ាច់ បាណាម ជាមួយនឹងរ៉ាច់ មេ កាន ឬព្រែកកាន់ ខ្លី (Prek Kan Cley) ។

"ពីបង្គោលលេខ ៧៩ ព្រំដែនបានតម្រង់ទៅទិសខាងលិច ឆ្លងកាត់តាមបង្គោល លេខ ៨០,៨១,៨២, និង ៨៣ ដោយកាត់តាមវាលភក់ល្បាប់ដ៏ធំមួយដែលមិនអាចធ្វើដំណើរសព្វទិសទីបាន" ។

បង្គោលលេខ ៨៣ ស្ថិតនៅចម្ងាយ ១២៨ ម នៃត្រើយខាងឆ្វេងនៃទន្លេមេគង្គលើ ។

**ការពិនិត្យទូវគំនូសព្រំដែននេះ**

គេត្រូវតែកត់សម្គាល់ថា គំនូសព្រំដែននេះបានទុកឲ្យកូសាំងស៊ីននូវផ្លូវទឹកទាំងអស់ ហើយបញ្ហានេះបានចង្អុលបង្ហាញដល់ភ្នែករបស់ពួកអធិការកិច្ចទាំងពីរនូវផលប្រយោជន៍ទាំងឡាយរបស់ខេត្តបារាំងថា ត្រូវតែប្រសើរជាងខេត្តរបស់ខ្មែរ ដែលជាប្រទេសស្ថិតនៅក្រោមការការពារ ។ ដំណោះស្រាយដែលប្រកាន់យកហាក់ដូចជាតឹងរ៉ឹងណាស់ បើសិនជាគេរំលឹកឡើងវិញចំពោះព្រំដែនរវាងប្រទេសកម្ពុជា និងបាសាក់ ទឹកដីទាំងពីរនេះបានស្ថិតនៅក្រោមអាណាព្យាបាលបារាំងដូចគ្នាអនុក្រឹត្យរបស់លោកអគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩០៥ បានសម្រេចថា ព្រំដែននេះត្រូវដើរតាមខ្សែទឹកទន្លេ រពៅ ដែលនេះអាចអនុញ្ញាតឲ្យអ្នកស្រុកនៅតាមមាត់ទន្លេរបស់ប្រទេសទាំង ពីរប្រើប្រាស់ទឹកនៃផ្លូវទឹកនេះបាន ។ ម្យ៉ាងទៀតតំបន់តាជី (ត្រាឌូ នៅលើដែនទី) ដែលបានដាក់ប៉ុស្តិ៍ គយអណ្តាមមួយនោះ បានធ្វើឲ្យឧត្តមនាវី de la Grandière ឈឺចាប់យ៉ាងខ្លាំងនៅក្នុងឆ្នាំ ១៨៦៥ និងបណ្តាលឲ្យមានការស្តីបន្ទោសយ៉ាងខ្លាំងពីមេបញ្ជាការ



Doudart de Lagrée ចំពោះអាជ្ញាធរអណ្តាមនៅចូវដុកពីព្រោះថា ប៉ុស្តិ៍នេះត្រូវបានស្ថិតនៅក្នុងទឹកដីកម្ពុជា បានស្ថិតនៅក្រោយពីបោះគោលដីនេះ បានរាប់បញ្ចូលទៅក្នុងទឹកដីកូសាំងស៊ីន ។

ហេតុអ្វីបានជាមានការជំទាស់នេះ ? ពីព្រោះថា សភាពការណ៍មានការផ្លាស់ប្តូរ ។ នៅក្នុងឆ្នាំ ១៨៦៥ ទេសាភិបាល កូសាំងស៊ីនត្រូវការពារផលប្រយោជន៍របស់ប្រទេសកម្ពុជា ដែលជាប្រទេសស្ថិតនៅក្រោមការការពាររបស់បារាំងប្រឆាំងនឹងការរំលោភរបស់អាជ្ញាធរអណ្តាមនៅខេត្តចូវដុក ដែលមិនទាន់ក្លាយទៅជារបស់បារាំងនៅឡើយនោះ ។

នៅឆ្នាំ ១៨៧៣ ផលប្រយោជន៍របស់កូសាំងស៊ីនក្រោមទាំងមូល ដែលរួមមានខេត្តចូវ ដុក ត្រូវតែដើរមុខផលប្រយោជន៍របស់ប្រទេសដែលស្ថិតនៅក្រោមការការពារ ។

**១.–ផ្នែកទី២ រវាងបង្គោលលេខ ៨៣ និងលេខ ៨៨ (ពីទន្លេមេគង្គទៅទន្លេបាសាក់)**

"ចាប់ពីបង្គោលលេខ ៨៣ ដែលស្ថិតនៅចម្ងាយ ១២៨ ម ពីត្រើយខាងឆ្វេងនៃទន្លេមេគង្គលើ ព្រំដែនបានដើរជាខ្សែត្រង់ ទៅបង្គោលលេខ ៨៤ នៅត្រើយខាងស្តាំនៃទន្លេ ដោយឆ្លងកាត់តាមដើម Cay gao (Cai gao ជាភាសាវៀតណាមដែលប្រែថាដើមត្របែក) បន្ទាប់មកទៀត ដោយធ្វើដំណើរទៅទិសខាងលិច ដើរតាមខ្សែកាច់ឆ្លងកាត់តាមបង្គោលលេខ៨៥ និងលេខ ៨៦ ត្រើយខាងឆ្វេងនៃរ៉ាច កូ ឡូវ (Rach Co Lau ) និងបង្គោលលេខ ៨៧ រវាងដើមស្វាយពីរដើម នៅលើត្រើយខាងឆ្វេងនៃ រ៉ាច់ បាណាម រហូតដល់បង្គោលលេខ ៨៨ ក្នុងលក្ខណៈទុកឲ្យប្រទេសកម្ពុជានូវភូមិទាំងឡាយ ពីបង្គោលលេខ ៨៨ ទៅមាត់ពាមនៃ រ៉ាច់ បាណាម ជាមួយនឹងទន្លេខាងក្រោម" ។

**ការកែប្រែជាខាងក្រោយ**

ផ្នែកនៃព្រំដែននេះ នៅក្នុងឆ្នាំ ១៩៣៥ បន្ទាប់ពីវិវាទកម្ម រវាងព្រំដែននៃទឹកដីទាំងពីរនោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យបញ្ជាក់ដោយគណៈកម្មការចម្រុះមួយ ដែលបានបើកឱកាសឲ្យអនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩៣៥ (ឧបសម្ព័ន្ធ II) ។

អនុក្រឹត្យនេះមិនបាននាំមកនូវការកែប្រែដ៏សំខាន់ណាមួយឡើយទៅលើគំនូសព្រំដែនមុនដំបូងនោះ ។ វាគ្រាន់តែបានបញ្ជាក់នូវទីតាំងនៃបង្គោលផ្សេងៗ និងសម្រេចការដាំនូវបង្គោលបន្ទាប់បន្សំទៀតរវាងបង្គោលសំខាន់ៗទាំងឡាយ ព្រមទាំងចង្អុលបង្ហាញនូវទីកន្លែងរបស់វា ។

### គ.-ផ្នែករវាងបង្គោលលេខ ៨៨ និង ១០៧

ពីបង្គោលលេខ ៨៨ ទៅបង្គោលលេខ ៨៩ ព្រំដែនបានឆ្លងកាត់ទន្លេក្រោម (ឬបាសាក់) ។

បង្គោលលេខ ៨៩ ត្រូវបានដាំនៅលើត្រើយខាងស្តាំ នៃទន្លេនេះ ។

ព្រំដែនបានឡើងទៅទិសខាងជើងដោយដើរតាមត្រើយខាងស្តាំនៃទន្លេក្រោម ដោយឆ្លងកាត់តាមបង្គោលលេខ ៩០ លេខ ៩១ នៅកន្លែងដៃបែកនៃទន្លេជាមួយរ៉ាច់ ប៊ិញ ហ្គី (Rach Binh Gi) ឆ្លងកាត់ទន្លេនេះ និងបន្តតាមត្រើយខាងស្តាំនៃទន្លេរហូតដល់បង្គោលលេខ ៩២ ។

ពីបង្គោលលេខ ៩២ គំនូសនេះបានដើរតាមត្រើយខាងជើងនៃ រ៉ាច់ ប៊ិញ ហ្គី តាមខ្សែស្របមួយដែលឃ្លាតគ្នាចំនួន ១០០ ម ដោយឆ្លងកាត់តាមបង្គោលលេខ ៩៣ , ៩៤ និង ៩៥ នៅត្រើយខាងឆ្វេងនៃព្រែកចូវដុក ឆ្លងកាត់ព្រែកនេះ រហូតដល់បង្គោលលេខ ៩៦ ដែលស្ថិតនៅត្រើយខាងស្តាំ ។ ដោយតម្រង់ទៅទិសខាងត្បូង ព្រំដែនពេលនោះដើរតាមខ្សែកាច់ ដោយឆ្លងកាត់តាមបង្គោលលេខ ៩៧ , ៩៨ , ៩៩ , ១០០ , និង ១០១ នៅលើត្រើយខាងឆ្វេងនៃ រ៉ាច់ កាមរ៉ា (Rach Camra) និងបង្គោលលេខ ១០២ នៅត្រើយខាងស្តាំនៃទន្លេរ៉ាច់ដដែលនេះ ដោយកាត់តាមវាលរហោឋានដ៏ធំមួយដែលមានតែដើមត្រែងនិងស្មៅធំៗបន្ទាប់មកវាតម្រង់ទៅទិសខាងត្បូងជានិច្ច ទៅដល់បង្គោលលេខ ១០៣ ត្រើយខាងឆ្វេងនៃរ៉ាច់ វិញ កាន ថុង (Rach Ving Can Thong) ឆ្លងកាត់ទន្លេនេះ កាត់តាមបង្គោលលេខ ១០៤ ត្រើយខាងស្តាំនៃទន្លេ រ៉ាច់ វិញ កាន ថុង បង្គោលលេខ ១០៥ ដាំនៅចម្ងាយ៦០ម ពីទន្លេ រ៉ាច់ ចាក កេ (Rach Chak Ké) និងនៅចម្ងាយប្រហែល ៧០០ម នៃដៃបែករបស់វា ជាមួយព្រែកចូវដុក បង្គោលលេខ ១០៦ ដាំនៅត្រើយខាងស្តាំ នៃរ៉ាច់ ចាក រី (Rach chak Ri) ។ ព្រំដែនបានចុះទៅទិស



នីរតី និងនៅចម្ងាយប្រហែល ៦០ ម ពី មុយស៊ុង (Mui Sung) និងនៅចម្ងាយ ១២០០ម នៃត្រើយខាងជើងនៃព្រែកជីកវិញតេ ដោយកាត់តាមវាលដ៏ធំមួយដែលមានតែដើមត្រែង និងស្មៅធំៗនោះ ។

### ការពិនិត្យអំពីព្រំដែននេះ

ដូចគំនូសព្រំដែនពីមុននេះដែរ ខ្សែកំណត់ព្រំដែនបានទុកឲ្យកូសាំងស៊ីនទាំងអស់នូវផ្លូវទឹកនៃព្រែក បឹង យី (Beng Gi) និងព្រែកចូវ ដុក វាមិនគ្រាន់តែរាប់បញ្ចូលនៅក្នុងទឹកដីបារាំង នូវព្រែកទាំងពីរនេះ និងធ្វើឲ្យប្រជាជនកម្ពុជា អាក់ខានមិនបានប្រើប្រាស់ទឹករបស់ព្រែកទាំងពីរនេះប៉ុណ្ណោះទេ ប៉ុន្តែខ្សែកំណត់ព្រំដែននេះវាបានឆ្លងកាត់នូវចន្លោះចម្ងាយមួយដ៏ពិតប្រាកដនៃត្រើយទន្លេ ។

តើការកំណត់នៃគំនូសព្រំដែនក្នុងចន្លោះចម្ងាយដ៏ពិតប្រាកដមួយនៃត្រើយទន្លេឆ្លើយតបបានទៅនឹងការបារម្ភ ដើម្បីទទួលបាននូវព្រំដែននៃជាតិពន្ធុសាស្ត្រមួយបានដែរឬទេ ? គឺគ្មានទាល់តែសោះ ។ យើងទើបតែនឹងបានឃើញហើយថា នៅលើត្រើយទន្លេនេះមានតែវាលដើមត្រែង និងស្មៅធំៗតែប៉ុណ្ណោះ ។ វាហាក់ដូចជាថា ខាងរដ្ឋាភិបាលកូសាំងស៊ីនមានបំណងបន្ថែមទៀត ដើម្បីយកធ្វើជារបស់ខ្លួនដោយផ្តាច់មុខនូវផ្លូវទឹកទាំងនេះ ជាការបារម្ភមួយ ដើម្បីបំរុងទុកនៅលើត្រើយនៃទន្លេកម្ពុជានូវចំរៀកដីមួយ ដើម្បីជាផលប្រយោជន៍នៃសន្តិសុខ និងការធ្វើនាវាចរ នៅលើផ្លូវទឹកនេះ ។

### ការកែប្រែជាខាងក្រោយ

ប៉ុន្តែគំនូសព្រំដែននេះ បានទុកឲ្យប្រទេសកម្ពុជា នូវកោះមួយមិនសូវជាសំខាន់ និងមានប៉ុន្មានទេ ស្ថិតនៅបាសាក់ នៅពីមុខភូមិអណ្តូម ខាញ់ អាន (Khanh An) កោះ គគី (Koki) ដែលត្រូវបានខ័ណ្ឌដោយផ្លូវទឹកដ៏តូចមួយ ។

ដើម្បីអនុញ្ញាតឲ្យភូមិ ខាញ់ អាន មានផ្លូវចូលទៅក្នុងផ្នែកនេះ ដោយតម្រង់ផ្ទាល់ទៅទន្លេក្រោម ឬទន្លេបាសាក់នោះ អនុក្រឹត្យមួយរបស់អគ្គទេសាភិបាលឥណ្ឌូចិន ត្រូវបានប្រកាន់យកនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៤២ (ឧបសម្ព័ន្ធ ១២) ដើម្បីភ្ជាប់កោះ គគី ទៅភូមិខាញ់អាន (មាត្រាទី១) និងផ្តល់នូវការសងទូទាត់ឲ្យប្រទេសកម្ពុជា"ការផ្តុំនៃ បឹងហ៊ី (Beng hi) និងដីមួយចំរៀកមានទទឹង ២០០ម និងមានបណ្តោយប្រហែល

២,៥០០គ.ម ដែលមានរវាង បឹងហ៊ី និងកែងនៃព្រែកបឹងហ៊ី" (មាត្រា២) ។ (សូមមើលក្រមចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៤២) (ឧបសម្ព័ន្ធ ១៣) ។

### ឃ.-ផ្នែករវាងបង្គោលលេខ ១០៧ និងលេខ ១២៤

ចំពោះផ្នែកនេះ គំនូសព្រំដែនបានដើរតាមខ្សែស្របមួយទៅព្រែកជីកវីញតេ ខ្សែដែលស្ថិតនៅចម្ងាយ១២០០ម នៃត្រើយខាងជើងនៃព្រែកជីកនេះ ដោយឆ្លងកាត់វាលរហោឋានមួយ ។

### ការពិនិត្យនៃផ្នែកព្រំដែននេះ

នៅទីនេះក៏ដូចជាគំនូសព្រំដែនពីមុន បានគ្របសង្កត់ការបារម្ភរដ្ឋាភិបាលកូសាំងស៊ីន ដើម្បីបម្រុងទុកនូវការយកទុកជារបស់ខ្លួន និងការប្រើប្រាស់ទឹកនៃព្រែកជីកវីញតេដោយផ្ដាច់មុខ ។

គំនូសព្រំដែននេះបាននាំឲ្យប្រទេសកម្ពុជាខូចខាតនូវផលប្រយោជន៍ជាច្រើន គឺ :

- វាបានទុកឲ្យនៅលើត្រើយម្ខាងទៀតនៃព្រែកជីកវីញតេ នូវស្រុករបស់កម្ពុជាជាច្រើន ដោយមានទាំងអង្គការរដ្ឋបាល និងសង្គមផ្ទាល់របស់ស្រុកទាំងនេះទៀតផងដែលមិនដូចគ្នានិងអង្គការរបស់អណ្ណាមនោះឡើយ ។ ស្រុកទ្រីតូង ដែលស្ថិតនៅទល់មុខទឹកដីកម្ពុជាបច្ចុប្បន្ននេះ គឺជាតំណាងជាគំរូផ្ទាល់នៃស្រុកទាំងនេះដែលនៅតែរក្សារចនាសម្ព័ន្ធសង្គមរបស់កម្ពុជានៅឡើយ ។

- វាបានដកហូតពីប្រជាជនកម្ពុជាដែលរស់នៅលើច្រាំងទន្លេនូវផ្លូវចូលទៅរកព្រែកជីកវីញតេ ដែលសម្រាប់បម្រើតែផលប្រយោជន៍របស់អាណ្ណាមប៉ុណ្ណោះ ។ ដោយហេតុនេះ គំនូសនេះគឺមិនធម្មតាឡើយ ពីព្រោះថា នៅក្នុងការអនុវត្តជាទូទៅរបស់ប្រទេសដែលស្ថិតនៅលើត្រើយទន្លេ នៅពេលដែលប្រទេសទាំងនោះជ្រើសរើសផ្លូវទឹកធ្វើជាព្រំដែន គេបានសម្រេចថា អ្នករស់នៅតាមព្រំដែននៃទឹកដីទាំងពីរអាចទទួលបានផលប្រយោជន៍នៃការប្រើប្រាស់រួមគ្នា នូវទឹកនៃផ្លូវទឹកនេះ ។

- ចំរៀកដីដែលមានទទឹងប្រវែង ១,២០០ម ស្ថិតនៅលើត្រើយខាងឆ្វេង និងជាពិសេសនៅតាមបណ្ដោយព្រែកជីកវីញតេ ត្រូវបានរាប់បញ្ចូលដោយរំលោភទៅក្នុងទឹកដីកូសាំងស៊ីន ។



យើងសូមសួរថា ហេតុអ្វីបានជាគំនូសព្រំដែនបែបនេះ អាចត្រូវបានទទួលដោយទេសាភិបាលកូសាំងស៊ីន ?

ការឆ្លើយចំពោះសំនួរនេះ ហាក់ដូចជាស្ថិតនៅត្រង់ការពិតដែលថា តំណាងនៃប្រទេសបារាំងប្រចាំប្រទេសកម្ពុជាត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ទេសាភិបាលកូសាំងស៊ីន នៅក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ។ យើងបានបង្ហាញរួចហើយនូវផលអាក្រក់ទាំងអស់នៃសភាពការណ៍នេះសម្រាប់ប្រទេសកម្ពុជា ។

នៅក្នុងករណីប្រឆាំងនឹងផលប្រយោជន៍រវាងព្រះរាជាណាចក្រដែលស្ថិតនៅក្រោមការការពារ និងអាណានិគមកូសាំងស៊ីន ទេសាភិបាលនៃអាណានិគមក្នុងពេលជាមួយគ្នាមានមុខងារជាអ្នកគ្រប់គ្រងជាងនិងជាចៅក្រមផង ពីព្រោះថារ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួននោះបានធ្វើពលិកម្មអាណាព្យាបាល ដើម្បីជាគុណប្រយោជន៍ដល់អាណានិគម ។

### ង.-ចំណែកដែលស្ថិតនៅរវាងបង្គោលលេខ ១២៤ និងសមុទ្រ

កំណត់ហេតុនិយាយពីផ្នែកនេះចុះកាលបរិច្ឆេទឆ្នាំ ១៨៧៦ និងបានថ្លែងដូច្នេះថា "ចេញពីដៃបែកនៃព្រែកជីកវីញតេ ជាមួយនិង រ៉ាច់ កៃ ដួ (Rach Cai Dua) ចំណុចកំពូលនៃព្រំដែនប្រទេសកម្ពុជាជាមួយនឹងមណ្ឌលទាំងពីរគឺចូវដុក និងហាទៀន ព្រំដែនបានដើរតាមត្រើយខាងជើងនៃព្រែកជីកវីញតេ រហូតដល់មាត់ទឹកនៃទន្លេ រ៉ាច់ យ៉ាំង ថាញ់ (Rach Giang Thanh) ឬព្រែកក្រោះ (Prek Cros) ប្រើជំនួសឈ្មោះ យ៉ាំង ថាញ់ ឆ្លងកាត់ រ៉ាច់ និងបន្តរត់តាមខ្សែទូរលេខរហូតដល់ជួបខ្សែ ការពារសឹកសត្រូវដែលស្ថិតនៅចុងខាងជើងនិងខ្សែបន្ទាត់ព្រំដែនដែលឆ្លងកាត់ទៅទិសខាងជើងនៃផ្ទាំងថ្មខ្ពស់ចោទដែលហៅថា Bonnet à Poils ។ ចេញពីចំណុចនេះ ព្រំដែនបានរត់តាមខ្សែការពារសឹកសត្រូវ រហូតដល់សមុទ្រ ហុនតា (Hon Ta) " ។

ដូច្នេះ គំនូសព្រំដែននេះ បានរត់តាមចាប់ពីយ៉ាំងថាញ់ តាមខ្សែទូរលេខ រហូតដល់ចំណុចជួបមុខរបស់ខ្លួនជាមួយខ្សែការពារសឹកសត្រូវនៅចុងខាងជើងបំផុត ហើយចេញពីនោះគំនូសព្រំដែននេះបានរត់តាមខ្សែការពារសឹកសត្រូវនេះ រហូតដល់សមុទ្រ ។ កំណត់ហេតុនេះបានបញ្ជាក់ថា ខ្សែការពារសឹកសត្រូវនេះបានឆ្លងទៅទិសខាងជើងនៃ

ផ្ទាំងថ្មចោទដែលហៅថា " Bonnet à Poils " ។

លក្ខណៈនៃគំនូសព្រំដែននេះ គឺបានទុកឲ្យកូសាំងស៊ីនទាំងស្រុងនូវផ្លូវទឹកទាំងអស់នៃយ៉ាង ថាញ់ ។ ដោយមិនយកផ្លូវទឹកនេះធ្វើជាព្រំដែនធម្មជាតិនោះ គេបានសម្រេចថាគំនូសនេះនឹងដើរតាមខ្សែទូរលេខ ។

ប៉ុន្តែព្រំដែននេះដែលបានទុកឲ្យកូសាំងស៊ីនរួចហើយ នូវខេត្តហាទៀន ដែលបានដណ្តើមយកពីកម្ពុជា ដោយមិនវល់ដល់ច្បាប់ទាំងអស់ និងផ្លូវទឹកទាំងអស់នៃយ៉ាងថាញ់ ថែមទាំងមិនត្រូវបានរក្សាការពារជាបន្តមកទៀតផង ។

### ៤.– ការកែប្រែជាខាងក្រោយដែលធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសកម្ពុជា

ចាប់តាំងពីឆ្នាំ ១៨៩១ រដ្ឋាភិបាលកូសាំងស៊ីនបានបញ្ចេញនូវគម្រោងរបស់ខ្លួនដើម្បីពង្រីកទឹកដីទៅខាងផ្នែកហាទៀន ។

#### ក.– ការប៉ុនប៉ងផ្លាស់ប្តូរកន្លែងព្រំដែន រវាងយ៉ាំងថាញ់ និង ហាទៀន លើកទីមួយ

##### ១ – មធ្យោបាយ ដែលបានប្រើប្រាស់

វាច្បាស់ណាស់ថា ព្រំដែនយ៉ាំងថាញ់នៅហាទៀន (រហូតដល់ចំណុចជួបរបស់វាជាមួយខ្សែការពារសឹកសត្រូវ) ត្រូវដើរតាមខ្សែទូរលេខ ដែលភ្ជាប់មណ្ឌលទាំងពីរនេះ ។ ខ្សែទូរលេខនេះរត់តាមផ្លូវថ្នល់ខាងក្នុងចេញពីយ៉ាំងថាញ់ទៅហាទៀន ។

ប៉ុន្តែនៅចន្លោះក្រុងទាំងពីរនេះ មានផ្លូវថ្នល់មួយទៀត ឈ្មោះ "ផ្លូវមន្ត្រី" ឆ្លងទៅចុងខាងជើងនៃផ្លូវទីមួយ និងស្ថិតនៅក្នុងទឹកដីកម្ពុជាទាំងស្រុង ។

នៅក្នុងឆ្នាំ ១៨៩១ អគ្គទេសាភិបាល De Lanessan បានបង្កើតជាឯកតោភាគី នូវផែនទីមួយរួចហើយ ដោយដាក់ព្រំដែនឆ្លងកាត់មិនគ្រាន់តែតាមផ្លូវថ្នល់ខាងក្នុងដែលខ្សែទូរលេខបានរត់តាមនោះទេ ប៉ុន្តែនៅតាមផ្លូវ "ថ្នល់មន្ត្រី" ផងដែរ (ផែនទីរបស់ de lanessan មាត្រាដ្ឋាន ១/១០០.០០០ នៅក្នុងឆ្នាំ ១៨៩១ cf annexes) ។ ដូច្នេះចំរៀកដីដ៏សំខាន់បានស្ថិតនៅរួមបញ្ចូលនៅក្នុងកូសាំងស៊ីន ។

##### ខ.– យុត្តិកម្ម

ដើម្បីធ្វើយុត្តិកម្មការផ្លាស់កន្លែងព្រំដែន រដ្ឋាភិបាលកូសាំងស៊ីនបានសង្កត់ទៅលើ



កំណត់ហេតុមួយដែលបង្កើតឡើងនៅក្នុងឆ្នាំ ១៨៩៣ ដោយអ្នកគ្រប់គ្រង Doceul តំណាងស្រុកកូសាំងស៊ីន គឺហា ថាញ់ និងអ្នកគ្រប់គ្រង Burgnet តំណាងនៃស្រុកថាញ់ យី (Thanh Gi) [១៣] ។

អ្នកគ្រប់គ្រងទាំងពីរនេះ បានសម្រេចដូចតទៅ :

"ចាប់តាំងពីសម័យនោះមក *(៥មេសា ១៨៧៦ កាលបរិច្ឆេទ នៃការកម្រិតព្រំដែន)* ខ្សែទូរលេខត្រូវបានផ្លាស់ប្តូរ និងបង្វិតចូលទៅ ជិត រ៉ាច់ យ៉ាំង ថាញ់ ហើយដោយមិនរត់តាមផ្លូវខេត្តកំពត និងបន្ទាប់មកតាមផ្លូវមន្ត្រីពីដើមនោះទេ ប៉ុន្តែរត់តាមផ្លូវបច្ចុប្បន្នត្រង់ពីហាទៀន ទៅយ៉ាំងថាញ់ ។

"ដោយផ្អែកនៅលើការកែប្រែពីមុននេះ ព្រំដែនបច្ចុប្បន្នរបស់ស្រុក គឺមានដូចតទៅនេះ :

"ចេញពីបង្គោលព្រំដែនលេខ ១ ទៅដែលដាក់នៅលើមាត់សមុទ្រ (ឈូងសមុទ្រសៀម) ទៅដល់កន្លែងកើតនៃខ្សែការពារសឹកសត្រូវនៅហាទៀន បរិវេណខាងលើ និងនៅទិសព្វាយ័ ពីសាន នៃជំរៀលភ្នំ ហុន ទៀវ តាវ (Hon Tieu Tao) ព្រំដែននៃស្រុកជាមួយព្រះរាជាណាចក្រកម្ពុជា បានរត់តាមខ្សែការពារសឹកសត្រូវឆ្លងទៅខាងជើងនៃផ្ទាំងថ្មចោទ ដែលហៅថា Bonnet à Poils រហូតដល់វាបានជួបជាមួយអតីតផ្លូវថ្នល់ទូរលេខ ចេញពីចំណុចនៃការជួបនេះ ព្រំដែនបានរត់តាមផ្លូវថ្នល់ ដែលពួកអណ្ណាមហៅថា ឌឿង ម៉ា គូវ (Duong Ma Cuu) រហូតដល់បង្គោលលេខ ២ ដែលមានតាំងនៅលើដីដោយដំបូកដីដ៏ធំមួយដាក់នៅលើមាត់ខាងលិចនៃទំនាបបឹង ប៊ុង កាន ត្រានញៀប (Bung Can Tran Nhiep) ដែលជាចំណុចរួមជាមួយស្រុក ថាញ់ យី ។

"ចេញពីបង្គោលលេខ ២ ទៅព្រំដែនដែលបានក្លាយទៅជារួមគ្នាជាមួយស្រុកថាញ់យី នោះ បានរត់តាមផ្លូវមន្ត្រីជានិច្ចនៅលើរយៈផ្លូវចម្ងាយប្រហែល ៧ គ.ម និង..." ។

ដូច្នេះ អាជ្ញាធរកូសាំងស៊ីន ដោយផ្អែកទៅលើការអះអាងមួយនៃការផ្លាស់កន្លែងខ្សែទូរលេខនោះ បានសម្រេចជាឯកតោភាគី ផ្លាស់កន្លែងព្រំដែននៃផ្លូវថ្នល់ខាងក្នុង

**(១៣) / កំណត់ហេតុ កំណត់ព្រំដែន នៃស្រុកទាំងពីរ ជាមួយប្រទេសកម្ពុជា ។**

ឬផ្លូវថ្នល់រត់ត្រង់ទៅរកផ្លូវថ្នល់ខាងក្រៅ ឬផ្លូវមន្ត្រី ។

## ៣.–តម្លៃនៃការផ្លាស់កន្លែងព្រំដែន

ការផ្លាស់កន្លែងខ្សែទូរលេខ ដែលបានអះអាងដោយអ្នកគ្រង់គ្រងទាំងពីរនេះ តើកើតមានពិតដែរឬទេ ? ដើម្បីអាចឆ្លើយតបបានបញ្ហានេះ គេចាំបាច់ត្រូវទឹកដល់កំណត់ហេតុដែលធ្វើឡើងដោយគណៈកម្មការមួយដែលមានអ្នកគ្រប់គ្រង និងអ្នករេខា–គណិតបារាំងរបស់ប្រទេសទាំងពីរ ដែលប្រជុំគ្នានៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ ១៨៩៦ នៅតុន ហុន ដើម្បីរាយការណ៍នៅលើដី នូវគំនូសព្រំដែន រវាងខេត្តហាទៀន និងខេត្តកំពតដែលគេបានចែងនៅក្នុងផែនការផ្លូវការដែលធ្វើឡើងនៅក្នុងឆ្នាំ ១៨៧៦ ដោយគណៈកម្មការកម្រិតព្រំដែន កូសាំងស៊ីន និងកម្ពុជា ហើយនិងដើម្បីរៀបចំឡើងវិញ នូវទីតាំងចាស់របស់បង្គោលព្រំដែនដែលបានបាត់ ។

ដើម្បីអាចបំពេញបាននូវបេសកកម្មរបស់ខ្លួន គណៈកម្មការនេះបានផ្អែកទៅលើ "ឯកសារផ្លូវការនិងត្រឹមត្រូវតាមច្បាប់" ។ ប៉ុន្តែនៅក្នុងសំណុំឯកសារ ដែលមានឯកសារទាំងនេះ មានគម្រោងពីរគឺ :

– គម្រោងនៃព្រំដែនកម្ពុជា ជាមួយនឹងមណ្ឌលហាទៀន និងផ្នែកនៃគម្រោងចូវដុក (ផែនការ ឆ្នាំ១៨៧៦) ។

– គម្រោងនៃព្រំដែន រវាងមណ្ឌលហាទៀន និងចូវដុក (រៀបចំខាងក្រោយ) ។

គម្រោងទាំងពីរនេះ" មិនស្របគ្នាឡើយ ចំពោះផ្នែកដែលទាក់ទងនឹងព្រំដែនរវាងរ៉ាច់ ជី យ៉ាង ថាញ់ និងសមុទ្រ" ។

នៅចំពោះមុខភាពផ្ទុយគ្នានេះ គណៈកម្មការនេះបានសម្រេចទឹកគិតទៅដល់គម្រោងដែលរៀបចំឡើងនៅក្នុងឆ្នាំ ១៨៧៦ ហើយដែលមានចែងថា "ព្រំដែនរវាងប្រទេសកម្ពុជា និងអណ្ណាម ពីបង្គោលលេខ ៥៥ ទៅលេខ ១២៤ " ។ ព្រំដែននេះត្រូវ បាន "បញ្ជាក់នៅក្នុងយោបល់នេះ ដោយការពិនិត្យមើលភាគនៃសំណុំឯកសារលេខ ៤៤ ដែលនៅក្នុងនោះលោក រេខាគណិត Gilly និងលោករេខាគណិត Krug បានស្រង់ព្រំដែនដែលបានរៀបរាប់ *នៅក្នុងកំណត់ហេតុនៃការកំណត់ព្រំដែនប្រទេសកម្ពុជា ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ ១៨៧៦*" ។



គណៈកម្មការនេះបន្ទាប់មកបានធ្វើការបញ្ជាក់ឡើងវិញ នៅលើដី នូវគំនូសព្រំដែនឆ្នាំ ១៨៧៦ ។ គណៈកម្មការនេះ "ជាបឋមបានដំណើរការធ្វើការអង្កេតស្រាវជ្រាវ ដើម្បីឲ្យដឹងថា បើសិនជាខ្សែទូរលេខភ្ជាប់ ហាទៀន យ៉ាង ថាញ់ រត់តាមគំនូសព្រំដែន បច្ចុប្បន្នដែលត្រូវបានជ្រើសរើសយកនៅក្នុងឆ្នាំ ១៨៧៦ ធ្វើជាព្រំដែនកូសាំងស៊ីន និងកម្ពុជា ប្រាកដមែន ឬយ៉ាងណា" ។

ដើម្បីឲ្យបានព័ត៌មានពិតប្រាកដនោះ គណៈកម្មការបានប្រមែប្រមូលនូវភស្តុតាងធានាពីមនុស្សទាំងឡាយដែលបានទៅមើល ឬក៏បានចូលរួមនៅក្នុងប្រតិបត្តិការកំណត់ព្រំដែនឆ្នាំ ១៨៧៦ ។ មនុស្សទាំងនោះរួមមាន :

**ក/–** តាំង ដាយ អាន (Tang Dai An) អនុរ័ក្សប៉ុស្តិ៍ប្រៃសណីយ៍ នៅហាទៀនពីឆ្នាំ ១៨៦៩ ទៅឆ្នាំ ១៨៨៥ បន្ទាប់មកជាប្រធានភូមិ មី ឌឹក (My Duc) ភូមិដែលស្ថិតនៅតាមរយៈផ្លូវដែលខ្សែទូរលេខរត់ (កូសាំងស៊ីន) ។

**ខ/–** ប្រធានភូមិនិងអ្នកមានមុខមាត់នៅភូមិធៀន ខាញ់ (Thien Khanh ) នៅជាប់ព្រំដែនប្រទេសកម្ពុជា (កូសាំងស៊ីន) ។

**គ/–** មេស្រុក [១៤] ចាន់ នៅភូមិព្រែកក្រុះ (ប្រទេសកម្ពុជា) ដែលនៅក្នុងឆ្នាំ ១៨៧៦ គាត់ជាអ្នកហែហមមន្ត្រីកម្ពុជាដែលជាសមាជិកគណៈកម្មការកំណត់ព្រំដែន ។

គេបានសម្រេចនូវលទ្ធផលដូចតទៅនេះ គឺ "ការអង្កេតនេះបានពន្យល់ថា ខ្សែទូរលេខបច្ចុប្បន្ន បានកើតមានតាំងពីឆ្នាំ ១៨៧០ ឬឆ្នាំ ១៨៧១ ហើយថា ចាប់តាំងពីពេលនោះមក ខ្សែទូរលេខនេះមិនដែលត្រូវបានផ្លាស់ប្តូរកន្លែងឡើយ " ។

ដូច្នេះការអង្កេតនេះមិនស្របតាមរបាយការណ៍ចុះថ្ងៃទី២៩ខែសីហាឆ្នាំ១៨៩៥[១៥] របស់អ្នកគ្រប់គ្រង Chesne នោះឡើយ ដែលបានអះអាងថា ទីតាំងនៃផ្នែកផ្សេងៗរបស់ខ្សែទូរលេខនេះត្រូវបានកែប្រែជាច្រើនដង ជាពិសេសនៅក្នុងអំឡុងពេលមានការបះបោរនៅក្នុងប្រទេសកម្ពុជា នៅឆ្នាំ ១៨៨៥ " ។

***(១៤) / ពាក្យខ្មែរដែលមានន័យថា មេឃុំ ។***

***(១៥) / ទីក្រុងនៅក្នុងកំណត់ហេតុ ។***

គណៈកម្មការនេះក៏បានពិនិត្យបញ្ជាក់ឡើងវិញ នូវផ្នែកនៃព្រំដែនដែលស្ថិតនៅរវាងចំណុចជួបគ្នា នៃខ្សែទូរលេខ និងកំពែងទីមួយនៃសំណង់ការពារសឹកសត្រូវ " ។

### ៤ – ហេតុផល នៃការផ្លាស់កន្លែងព្រំដែន

យើងហាក់ដូចជាចាប់អារម្មណ៍យ៉ាងខ្លាំង ដើម្បីពន្យល់ថា តើនៅក្នុងផលប្រយោជន៍ណា និងដើម្បីមូលហេតុអ្វី បានជាអាជ្ញាធរកូសាំងស៊ីន ចង់បញ្ចូលជាឧបសម្ព័ន្ធនូវទឹកដីកម្ពុជា ដែលស្ថិតនៅរវាងផ្លូវថ្នល់ទាំងពីរនេះ ។ វាហាក់ដូចជាថា លិខិតចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៨៩២ របស់លោក A.Leclère ដែលជារ៉េស៊ីដង់បារាំងនៅខេត្ត កំពត បានផ្តល់ការពន្យល់អំពីបញ្ហានេះយ៉ាងគ្រាប់គ្រាន់ :

"ប៉ុន្តែមានជនជាតិអណ្ណាម ១២នាក់ មានទីលំនៅ នៅភូមិទៀន ខាញ់ នៅកូសាំងស៊ីន ដែលបានធ្វើស្រែចំនួន ៣៥ ហិកតា នៅលើដីដែលជារបស់កម្ពុជា និងស្ថិតនៅពី ១ ទៅ ២ គីឡូម៉ែត្រ នៃខ្សែទូរលេខ ។

"មានប្រជាជនកម្ពុជាចំនួន១១នាក់ ដែលបានធ្វើស្រែនៅលើផ្ទៃដីចំនួនប្រហែល ២៦ ហិកតា ដែលស្ថិតនៅក្នុងទឹកដីកម្ពុជាផងដែរ ស្ថិតនៅចម្ងាយជាង ២ គ.ម នៃខ្សែទូរលេខ និងដែលបានបង់ថ្លៃពន្ធសរុបចំនួន ៣៨ ព្យ៉ាស្ត្រ និងស្រូវ១០ យ៉ាវ[១៦] ទៅឲ្យអ្នកមានមុខមាត់នៃភូមិ ទៀន ខាញ់ ។

"មានប្រជាជនកម្ពុជា ១៣នាក់ ផ្សេងទៀត និងប្រជាជនអណ្ណាមខ្លះដែលបានធ្វើស្រែដែលស្ថិតនៅលើទីដីកម្ពុជាផងដែរ ប៉ុន្តែស្ថិតនៅរាយប៉ាយ គឺចំនួនប្រហែល៥០ ហិកតា ហើយដែលពួកគេបង់ពន្ធជាធម្មជាតិ ទៅឲ្យពួកអ្នកមានមុខមានមាត់នៅភូមិទៀន ខាញ់ ។

"ដូច្នេះហើយផ្ទៃដីស្រែប្រហែល ១១០ ហ.ត ដែលនឹងត្រូវរួចពន្ធនៅក្នុងប្រទេសកម្ពុជា បែរជាមានអ្នកបង់ពន្ធ ឬមួយត្រូវបង់ទៅឲ្យអ្នកមានមុខមាត់នៅភូមិ ទៀន ខាញ់ នៅកូសាំងស៊ីន ឬមួយក៏ត្រូវបង់ទៅឲ្យរដ្ឋការកូសាំងស៊ីន" ។

វាច្បាស់ណាស់ថា ការប៉ុនប៉ងកែតម្រូវជាឯកតោភាគី នៃគំនូសព្រំដែនដោយទេសាភិបាលកូសាំងស៊ីននោះ គឺពុំមានគោលបំណងអ្វីក្រៅតែពីការធ្វើឲ្យត្រឹមត្រូវ

(១៦) / ស្មើសរង្វាល់ចំណុះរបស់អណ្ណាម ។



តាមច្បាប់នូវការទន្ទ្រានយកទឹកដី ដែលពួកអាជ្ញាធរ ទៀន ខាញ់ បានអនុវត្តនោះទេ ។

### ខ.– ការកែប្រែធ្វើឡើងនៅក្នុងឆ្នាំ ១៩១៤

វាមាននៅក្នុងផ្នែកដែលស្ថិតនៅភាគខាងលិច នៅក្នុងតំបន់នៃខ្សែសំណង់ការពារសឹកសត្រូវ ។

### ១.– ការទាមទាររបស់អណ្ណាម

ប៉ុន្មានឆ្នាំក្រោយពីការទន្ទ្រានយករបស់ពួកគេ នូវទឹកដីដែលមាននៅរវាងផ្លូវថ្នល់ទាំងពីរ ហា ទៀន – យ៉ាង ថាញ់ ពួកអណ្ណាមនៅភូមិទៀន ខាញ់ បានបញ្ចេញនូវការទាមទារផ្នែកមួយទៀត នៅក្នុងតំបន់នៅចំកណ្តាលហា ទៀន ។ នៅក្នុងឆ្នាំ ១៨៩៥ ពួកអណ្ណាម បានតវ៉ាប្រឆាំងនិងរបស់ដែលហៅថា ការសន្មតឲ្យប្រទេសកម្ពុជា "នូវផ្នែកមួយនៃអតីតឃុំរបស់ពួកគេ គឺរបស់អណ្ណាម នៅក្នុងសម័យយូរអង្វែងមកហើយដែលពួកគេបានយកធ្វើជាភស្តុតាង នូវឯកសារក្នុងស្រុក" [១៧] ។

ប៉ុន្តែយើងបានឃើញថា ទាំងនៅក្នុងឆ្នាំ ១៨៧៦ និងឆ្នាំ ១៨៩៣ ការទាមទារទាំងនេះមិនត្រូវបានធ្វើឡើងឡើយ ។ គណៈកម្មការពិនិត្យបញ្ជាក់ឡើងវិញ នៅឆ្នាំ ១៨៩៣ និងឆ្នាំ ១៨៩៦ បានអះអាងថា គំនូសនៃភាគព្រំដែននេះដែលបានឆ្លងកាត់ខ្សែសំណង់ការពារសឹកសត្រូវ ហើយដែលមានសញ្ញាសម្គាល់កន្លែងដាក់លាក់មែនទែន គឺផ្ទាំងថ្មចោទដែលហៅថា Bonnet à Poils ហើយនិងកូនភ្នំដែលស្ថិតនៅមាត់សមុទ្រដែលមានឈ្មោះថា នូយ ហុន ទៀវ តាវ (Nui Hon Tieu Tao) ។

### ២ – ឥរិយាបថរបស់រដ្ឋការបារាំងនៅកូសាំងស៊ីន

ទេសាភិបាលកូសាំងស៊ីន បានទទួលខុសត្រូវនូវកាទាមទារទាំងនេះ ដែលសង្កត់ទៅលើទឡ្ហីករណ៍ដែលថា ទឹកដីដែលបានទាមទារនេះ គឺជាដីរបស់ឃុំអណ្ណាម នៅក្នុងពេលជាយូរមកហើយ ។ ចេញពីនោះ តើលោកទេសាភិបាលកូសាំងស៊ីន ទទួលយកនូវទឡ្ហីករណ៍ទាំងឡាយតាមលំដាប់ប្រវត្តិសាស្ត្រនេះឬ ? ប្រសិនជាលោកជ្រើសរើសយកនូវទឡ្ហីករណ៍នេះធ្វើជាឥរិយាបថ ពេលនោះលោកត្រូវតែធ្វើឲ្យទៅជាទូទៅ

(១៧) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ១៨៩៥ ផ្ញើទៅជូនអគ្គទេសាភិបាលឥណ្ឌូចិន, ឥណ្ឌូចិន A.20 (42) ។

សម្រាប់ទឹកដីកូសាំងស៊ីនទាំងអស់ផងដែរ គឺកូសាំងស៊ីនក្រោមទាំងអស់ គឺជាទឹកដីរបស់កម្ពុជា រហូតដល់ពាក់កណ្ដាលនៃសតវត្សរ៍ទី ១៧ ។ ជាពិសេសខេត្តហា ទៀនត្រូវបានវៀតណាមកំហែងយកដោយគ្មានសិទ្ធិនោះផង ។

វាជាការគួរឲ្យឆ្ងល់ណាស់ដែលគេបានធ្វើច្បាប់ទាមទាររបស់អាណ្ណាមផ្អែកទៅលើទិន្នន័យប្រវត្តិសាស្ត្រ នៅពេលដែលគេបានធ្វើមិនដឹងមិនឮចំពោះច្បាប់របស់កម្ពុជាដែលតាមទស្សនៈនេះ គឺមានលក្ខណៈរឹងមាំណាស់ ។

### ៣. – វិធីដែលគេបានប្រើប្រាស់

តើគេបានប្រតិបត្តិដូចម្ដេច ? គេបានប្រើប្រាស់នូវទឡ្ហីករណ៍ នៃការផ្លាស់កន្លែងខ្សែទូរលេខដូចគ្នា ដែលត្រូវបានបញ្ចេញឲ្យដឹងនៅក្នុងការពិនិត្យបញ្ជាក់ឡើងវិញដែលធ្វើឡើងនៅក្នុងឆ្នាំ ១៨៩៦ និងបានប្រឌិតឡើងនៅគ្រប់ស្ថានភាពទាំងអស់ ។

ការពិនិត្យបញ្ជាក់ឡើងវិញនេះ មិនបានបំពេញចិត្តដល់ទេសាភិបាលឥណ្ឌូចិន ឡើយ ពីព្រោះថា នៅពេលដែលគាត់បានរង់ចាំ ដើម្បីឲ្យគោលបំណងរបស់គាត់បានសម្រេចនោះ ការពិនិត្យបញ្ជាក់នេះបានរារាំងគាត់ទៅវិញ ។ ដើម្បីផ្ដល់ឲ្យអគ្គទេសាភិបាលឥណ្ឌូចិន នូវកត្តាវាយតម្លៃប្រកបដោយការអនុគ្រោះចំពោះនិក្ខេបបទរបស់គាត់នោះ គាត់មិនរារែកក្នុងការប្រើឧបាយកលបោកបញ្ឆោតការពិតក៏ដូចជាការបញ្ចេញឲ្យយើងដឹងដោយការអាននូវរបាយការណ៍បង្ហាញរបស់គាត់ដែលច្បាស់ហើយថា របាយការណ៍នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាអាណានិគម [១៨] នោះ ។

#### ក/–របាយការណ៍របស់ទេសាភិបាលកូសាំងស៊ីន

"គណៈកម្មការមានយោបល់ថា ប្រទេសកម្ពុជាត្រូវសងទៅឲ្យកូសាំងស៊ីន វិញនូវទឹកដីជាអតីតឃុំរបស់អណ្ណាមឈ្មោះសាគី (Saky) ដែលមុននេះជាទឹកដីកូសាំងស៊ីន ហើយដែលត្រូវបានកំណត់ឲ្យមកប្រទេសកម្ពុជាដោយអយុត្តិធម៌ បន្ទាប់ពីការកំណត់ព្រំដែនមួយដែលធ្វើឡើងនៅក្នុងឆ្នាំ ១៨៩៦ (Sic) "។ "មែនទែន វាជាលទ្ធផល នៃការសិក្សានូវឯកសារទាំងឡាយ ដែលទាក់ទងទៅនឹងសំណួរនេះ ដែលនៅក្នុងថ្ងៃស្អែក

(១៨) / *ការពិភាក្សារបស់ក្រុមប្រឹក្សាអាណានិគមនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩១៣ បញ្ជីនៃការពិភាក្សារបស់ក្រុមប្រឹក្សានេះនៅឆ្នាំ ១៩១៣ ។*



នៃការធ្វើសញ្ជ័យ រដ្ឋការបារាំងមានការខ្វល់ខ្វាយ ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវព្រំដែនទាំងឡាយរបស់កូសាំងស៊ីន ជាមួយខេត្តទាំងឡាយរបស់ប្រទេសកម្ពុជាជិត ខាង ។ ហេតុដូច្នេះហើយបានជាអ្នកគ្រប់គ្រងខេត្តហាទៀន លោក Kergaradec ត្រូវបានឲ្យទទួលបន្ទុកស្រង់ព្រំដែននៅក្នុងមណ្ឌលរបស់គាត់ដែលត្រូវបានចុះនៅក្នុងកំណត់ហេតុមួយ ចុះថ្ងៃទី២៣ មករា ឆ្នាំ ១៨៧២ ។ បើតាមកំណត់ហេតុនេះ ព្រំដែននៃខេត្តហាទៀន បានរត់តាមខ្សែទូរលេខ ដែលខ្សែទូរលេខនេះក៏បានរត់តាមផ្លូវថ្នល់មន្ត្រីចាស់ម៉ាក គូវ (Mac Cuu) ដែលស្ថាបនាឡើងនៅក្រោមរជ្ជកាលរបស់អធិរាជយ៉ាឡុង (Gialong) គឺផ្លូវថ្នល់មន្ត្រីម៉ាកគូវនេះហើយដែលជាចំណុចសម្គាល់នៃព្រំដែនរបស់ប្រទេសទាំងពីរ ។ ការកំណត់ព្រំដែននេះត្រូវបានយល់ព្រមដោយអនុសញ្ញាមួយដែលបានសម្រេចនៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៨៧៣ រវាងព្រះករុណាព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងលោកឧត្តមនាវីត្រី Duperré ទេសាភិបាលកូសាំងស៊ីន ។ គណៈកម្មការបោះបង្គោលព្រំដែនមួយត្រូវបានទទួលបន្ទុកអនុវត្តនៅលើដីនូវព្រំដែនដែលបានជ្រើសរើសយក ។ គណៈកម្មការនេះបានកំណត់លទ្ធផលការងារដោយទទួលស្គាល់នៅក្នុងកំណត់ហេតុចុះថ្ងៃទី៥ ខែមេសា ឆ្នាំ ១៨៧៨ ដែលនឹងក្លាយទៅជាអត្ថបទជាស្ថាពរអំពីរឿងនេះ និងបានបញ្ចប់នូវការងារពិបាកៗទាំងអស់ ។

"ប៉ុន្តែជាអភ័ព្វជាការបញ្ជាក់នូវកំណត់ហេតុរបស់ខ្លួន គណៈកម្មការបោះគោលព្រំដែននេះ បានទប់ក្នុងការរៀបចំនូវសេចក្ដីព្រាងមួយដែលមិនសូវច្បាស់នៅពេលដែលគណៈកម្មការនេះត្រូវបានបញ្ជាក់យ៉ាងលំអិតនូវឋានលេខាជាក់លាក់ ព័ត៌មានដែលផ្ដល់ឲ្យដោយទីតាំងនៃបង្គោលខ្សែទូរលេខ ។ នៅក្នុងឆ្នាំ ១៨៨៥ នៅក្នុងអំឡុងពេលមានចលនាបះបោរនៅប្រទេសកម្ពុជា ខ្សែទូរលេខត្រូវបានបំផ្លាញជាច្រើនលើក និងត្រូវបានផ្លាស់កន្លែងដោយយកទៅដាក់នៅទិសខាងត្បូងឆ្ងាយ នៅលើផ្លូវមន្ត្រីថ្មីដែលបង្កើតឡើងដោយ ធូ ឌឹក (Thu Duc) ។ ជាយូរក្រោយមកនៅក្នុងឆ្នាំ ១៨៩៥ ខ្សែទូរលេខនេះត្រូវបានយកទៅដាក់នៅកន្លែងចាស់របស់វាវិញ ។ ការផ្លាស់កន្លែងបង្គោលព្រំដែនដែលធ្វើឡើងនៅក្នុងឆ្នាំ ១៨៨៥ បានធ្វើឲ្យកើតឡើងនូវភាពមិនប្រាកដប្រជាអំពីខ្សែកំណត់ព្រំដែន ។ បន្ទាប់ពីមានឧបទ្ទវហេតុផ្សេងៗមក ជាពិសេស

ការលំបាកទាំងឡាយ ដែលបានកើតឡើងនៅក្នុងឆ្នាំ ១៨៩៥ រវាងបេសកជនរបស់ចៅហ្វាយខេត្តកំពង់ត្រាច ដែលទទួលបន្ទុកចាត់ចែងក្នុងការចាប់ខ្លួនអ្នកបះបោរ ហើយនិងពួកអ្នកមានមុខមាត់អណ្ណាមនៅតុនហុន លោករ៉េស៊ីដង់ នៅកំពត បានស្នើសុំថា គណៈកម្មការកំណត់ព្រំដែនថ្មីមួយ ឬក៏និយាយឲ្យច្បាស់ជាងនេះទៀត គឺការបោះបង្គោលដីត្រូវបានបង្កើតឡើង ដើម្បីអនុវត្តជាថ្មីនៅលើដីនូវព្រំដែនដែលបានកំណត់ដោយអនុសញ្ញាឆ្នាំ ១៨៧៣ ។ គណៈកម្មការនេះត្រូវបានតែងតាំងឡើងនិងបានដំណើរការនៅក្នុងឆ្នាំ ១៨៩៦ ។ ប៉ុន្តែដោយមានការបំភ្លឺមិនគ្រប់គ្រាន់នោះ គណៈកម្មការនេះបានបកស្រាយដោយមិនត្រឹមត្រូវជាក់លាក់នូវពាក្យទាំងឡាយនៅក្នុងអនុសញ្ញាដែលបានសម្រេចឡើងរវាងព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងទេសាភិបាលកូសាំងស៊ីន ។ មែនទែនគណៈកម្មការនេះ ជឿថាខ្សែទូរលេខដែលបានដាក់ឡើងវិញនៅមុននេះបន្តិច នៅលើផ្លូវថ្នល់មន្ត្រី ម៉ាក គូវ បានស្ថិតនៅលើផ្លូវថ្នល់ថ្មី ធូ ឌឹក ដោយហេតុនេះ គណៈកម្មការនេះបានកំណត់ព្រំដែននៅលើផ្លូវថ្នល់ចុងក្រោយនេះ ។ ដូច្នេះកូសាំងស៊ីន បានបាត់បង់ទឹកដីទាំងអស់ ដែលមាននៅរវាងផ្លូវថ្នល់មន្ត្រីទាំងពីរនេះ ។

គឺទឹកដីនេះហើយ ដែលគណៈកម្មការឆ្នាំ ១៩១១ បានស្នើឲ្យសងទៅឲ្យកូសាំងស៊ីន។ ផ្ទៃក្រឡារបស់វាមានប្រហែល៩២៤ហិកតា ដែលក្នុងនោះ២៧៥ហិកតា គឺជាដីស្រែ។ ផ្ទៃដីដែលនៅសល់ គឺជាផ្ទៃដីដែល៤ភាគ៥ គឺសម្រាប់ដាំដំណាំស្រូវ ។ ចំរៀកនៃទឹកដីនេះមានឃុំសាគី ដែលមានអ្នកចុះឈ្មោះក្នុងបញ្ជីចំនួន ៣៥នាក់ ហើយនិងភូមិតូចកាន់ចាន់ឡុត "Kan Chanlot" (Koh Chanlos) (កោះចន្លុះ) ដែលមានប្រជាជនចុះឈ្មោះចំនួន ៦៣ នាក់ ។ ប្រជាជនសរុបមាន ២៩៤ នាក់ " ។

### ខ/– ការអធិប្បាយ

**របាយការណ៍នេះ មានការកត់សម្គាល់ជាច្រើន :**

**ខ–**មួយ គេត្រូវតែស្រង់នូវភាពមិនច្បាស់លាស់ នៃការចង់បាននូវការកំណត់ព្រំដែនមួយដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ ១៨៩៦ ។ គណៈកម្មការឆ្នាំ ១៨៩៦ មានតែបេសកកម្មដើម្បីបញ្ជាក់មើលឡើងវិញនូវព្រំដែនដែលបានសម្រេចធ្វើឡើង



នៅលើដីនៅក្នុងឆ្នាំ ១៨៧៦ ដោយអនុវត្តតាមអនុសញ្ញាឆ្នាំ ១៨៧៣ និងដើម្បីរៀបចំដាក់បង្គោលព្រំដែនដែលបាត់នៅកន្លែងចាស់របស់វាវិញ " ។

គឺគំនូសព្រំដែនឆ្នាំ ១៨៧៦ ដែលត្រូវយកមកសំអាង ។

បញ្ហាត្រូវបានសង្ខេប ដោយការបញ្ជាក់ឡើងវិញ បើសិនជាខ្សែទូរលេខ បានស្ថិតនៅក្នុងទីតាំងរបស់ខ្លួនទាឆ្នាំ ១៨៧៦ ។ នៅលើចំណុចនេះ គណៈកម្មការឆ្នាំ ១៨៩៦ គឺច្បាស់លាស់ ដើម្បីអះអាងថា "ខ្សែទូរលេខបច្ចុប្បន្នកើតមានតាំងពីឆ្នាំ ១៨៧០ ឬឆ្នាំ ១៨៧១ និងថា ចាប់តាំងពីពេលនោះមក ខ្សែទូរលេខនេះមិនដែលត្រូវបានផ្លាស់កន្លែងឡើយ " ។

ដូច្នេះ ទីតាំងនៃខ្សែទូរលេខនេះ គឺខ្សែទូរលេខនៅក្នុងឆ្នាំ ១៨៩៦ គឺស្របគ្នាទៅនឹងគំនូសព្រំដែនឆ្នាំ ១៨៧៦ ។

គណៈកម្មការមួយដែលបានប្រតិបត្តិនៅក្នុងឆ្នាំ ១៩១១ អាចផ្សព្វផ្សាយថា យោបល់មួយអាចយកជាការបាន ដោយនិយាយថា គណៈកម្មការឆ្នាំ ១៨៩៦ បាន "បំភ្លឺដោយមិនគ្រប់គ្រាន់"នោះ ព្រោះថា គណៈកម្មការនេះបានស្រាវជ្រាវទៅលើប្រភពទាំងឡាយ ដ៏ប្រសើរបំផុត គឺថាទៅលើសក្ខីកម្មទាំងឡាយរបស់អ្នកដែលបានដាំបង្គោលខ្សែទូរលេខនេះ គឺមេឃុំពីរនាក់ និងអ្នកមានមុខមាត់អណ្ណាម (មេឃុំទី១នៅក្នុងចំណោមមេឃុំទាំងពីរនាក់នេះ ដើម្បីធ្វើខ្លួនឲ្យទៅជាភ្នាក់ងារ ប្រៃសណីយ៍ទូរលេខនោះបានមើលឃើញ ខ្សែទូរលេខនេះស្ថិតនៅដោយមិនផ្លាស់ប្តូរកន្លែងចាប់តាំងពីការបង្កើតវាឡើង រហូតដល់ឆ្នាំ ១៨៩៦ ) និងមេឃុំកម្ពុជាម្នាក់ ។

គេបានរង់ចាំរហូតដល់ឆ្នាំ ១៩១១ ដែលពួកសាក្សីទាំងនេះប្រហែលជាត្រូវបានស្លាប់ ដើម្បីនិយាយថា គណៈកម្មការឆ្នាំ ១៨៩៦ មិនបានបំភ្លឺដោយគ្រប់គ្រាន់នោះ ។

ហើយសាក្សីម្នាក់ទៀត គឺ A.Leclère រ៉េស៊ីដង់បារាំង នៅខេត្តកំពត គេមិនច្បាស់ ថាគាត់ចង់បានន័យថាយ៉ាងណានោះទេ : " បើសិនជាខ្ញុំមានព័ត៌មានច្បាស់ លាស់នោះគឺព្រំដែននៅជិតខ្សែដែលបានចង្អុលបង្ហាញដោយបង្គោលទូរលេខ" [១៩] ។ លោក

---

*(១៩) / លិខិតរបស់លោក រ៉េស៊ីដង់ ខេត្តកំពត ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៨៩២ ផ្ញើទៅជូន លោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា ។*

A.Leclère គឺជា រ៉េស៊ីដង់ម្នាក់ដែលស្ថិតនៅក្នុងខេត្តកំពតបានយូរជាងរ៉េស៊ីដង់ទាំងអស់និងដែលស្គាល់សភាពការណ៍ច្បាស់លាស់ ។ លោកថែមទាំងបានសរសេរនូវប្រវត្តិសាស្ត្រទៀតផង ។ លោកមិនអាចច្រឡំបានទេ ។

### ៤.- សេចក្តីសម្រេចនិងការខុទ្ទិសខាងគតិយុត្តរបស់ពួកគេ

### ក/- ព្រះរាជប្រកាសថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ (ឧបសម្ព័ន្ធ ៨ )

ថ្វីបើការដាក់ច្បាស់ដែលបាននាំមកនូវព័ត៌មានទាំងអស់នេះក្តីក៏គេបានដាក់ថ្វាយព្រះមហាក្សត្រ ឡាយព្រះហស្តលេខា នូវព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ ដែលនៅក្នុងព្រះរាជប្រកាសនោះ បានចែងថា "នឹងត្រូវសងទៅឲ្យកូសាំងស៊ីន វិញនូវចំរៀកដីដែលលាតសន្ធឹងរវាងខេត្តកំពតនិងខេត្តហាទៀន និងដែលមានឃុំ សាគី ក៏ដូចជាកូនភូមិ កាន់ចាន់ឡូត (កោះចន្ទុះ) ប្រឆាំងនឹងការធ្វើអនុប្បទាននៅប្រទេសកម្ពុជានូវបរិព័ន្ធភូមិ ដែលហៅថា កាយ កៃយ (Cai Cay) [២០] រវាងតៃនិញនិងព្រៃវែង" ។ នោះគឺចំរៀកដីដ៏តូចពីរនៅសៀរមាត់ទន្លេកាយ កៃយ ។

ម្យ៉ាងទៀត គេត្រូវតែធ្វើការកត់សម្គាល់បន្ថែមមួយ ។ ពាក្យនៃព្រះរាជប្រកាសនោះបានធ្វើឲ្យលេចឮថា ជាការប្តូរមួយ ។ គេមិនត្រូវការធ្វើការប្តូរនោះទេ បើសិនជាឃុំសាគី និងភូមិតូច កាន់ចន្ទុះ គឺពិតជារបស់កូសាំងស៊ីនដ៏ពិតប្រាកដនោះ ។ ការសងនេះមានលក្ខណៈគ្រប់គ្រាន់ទៅហើយ ។

បញ្ហាទាំងអស់នេះ បានបង្ហាញនូវភាពមិនប្រាកដប្រជាឬទេ ដែលនៅក្នុងនោះមានអាជ្ញាធរបារាំង និងច្បាប់កូសាំងស៊ីនបានអះអាងនោះ ?

### ខ/- អនុក្រឹត្យចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩១៤

ប៉ុន្មានខែក្រោយពីអនុក្រឹត្យរបស់អគ្គទេសាភិបាលត្រូវបានប្រកាន់យកនៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩១៤ [២១] មក "ព្រំដែនថ្មីដែលខ័ណ្ឌខេត្តហាទៀន និងខេត្តកំពតរវាងអាងសមុទ្រខាងក្នុងនៃខេត្តហាទៀន និងឈូងសមុទ្រសៀមបានរត់តាមខ្សែទូរលេខរហូតដល់ចំណុចដែលព្រំដែននេះបានកាត់ខ្សែនៃសំណង់ការពារសឹកសត្រូវនៅក្នុង

(២០) / បរិព័ន្ធភូមិដែលបានបង្កើតឡើងនៅសៀរមាត់ទន្លេ កីយកាយ នៅក្នុងអំឡុងពេលបំពេញការងារឆ្នាំ១៨៧០។
(២១) / Cf. ឧបសម្ព័ន្ធ ៧ ។



ចម្ងាយពីហាទៀនចំនួន២,២៩៣ម ចំណុចនេះត្រូវបានចង្អុលបង្ហាញដោយអក្សរB ទៅលើគម្រោងនៃការបញ្ចូលជាឧបសម្ព័ន្ធទៅដើមកំណើតនៃអនុក្រឹត្យ ។

ចាប់ពីចំណុច B ព្រំដែនបានដើរតាមលើបណ្តោយចម្ងាយ១,៤៤១ម ព្រំដែនបច្ចុប្បន្ននៃភូមិសាគី ដែលចង្អុលបង្ហាញដោយគំនូសព្រំដែននៃសំណង់ការពារសឹកសត្រូវចាស់ រហូតដល់ចំណុច C បន្ទាប់មកនៅចំណុច D ចំណុចខាងជើងបំផុត នៃភូមិសាគី ដែលបង្កើតឡើងដោយភ្នំប្រជៀវ (ភាសាវៀតណាម Nui Da Dung) ចម្ងាយពី B ទៅ C មាន ៤២៣ម ពី C ទៅ D មានចំនួន ១,០១៨ម ។

"ពី D ទៅ E (ចម្ងាយ ៦៨៨ម) ព្រំដែនបានឆ្លងកាត់បឹង "Beng" ដ៏ជ្រៅមួយ បន្ទាប់មកនៅចំណុច E បានទៅជួបខ្សែការពារសឹកសត្រូវ ដែលវាបានរត់រហូតដល់ចំណុច F ខ្ពស់នៃព្រំដែន នៃទឹកដីសាគី ចម្ងាយពី E ទៅ F មាន ៤៨១ម ។

"ពី F ខ្សែ នៃសំណង់ការពារសឹកសត្រូវដែលបានរកឃើញនៅ E បានបន្តដំណើរដោយគ្មានការបញ្ឈប់រហូតដល់មាត់សមុទ្រ ដែលនៅទីនោះវាបានទៅដល់ចំណុច G បន្ទាប់ពីវាបានរត់ក្នុងរយៈចម្ងាយ FG ដែលមានចំនួន ៣,១៥៨ម" (មាត្រាទី១) ។

ប៉ុន្តែអនុក្រឹត្យនេះ មិនបានចែងអំពីអត្ថិភាពនៃការទាមទារផ្លាស់ប្តូរឡើយ :

វាបានដាក់ព្រំដែន ដើម្បីទុកសម្រាប់មាត្រាមួយ ដោយគ្មានការជាប់ទាក់ទងទៅនឹងអនុក្រឹត្យមុនទេ ចំពោះព្រំដែនថ្មីរវាងខេត្តតៃនិញ និងខេត្តព្រៃវែង គឺ :

"បរិព័ន្ធភូមិដែលមានឈ្មោះថា កាយ កៃយ (Cai Cay) រហូតដល់ទិសប្រសព្វមុខរបស់ កាយ កៃយ ជាមួយ រ៉ាច់ អុង បា (Rach Ong Ba) ត្រូវបានភ្ជាប់ទៅឲ្យប្រទេសកម្ពុជា" ។ នៅទីនោះហើយ គឺជាទឹកដីដែលប្រទេសកម្ពុជាបានទទួលក្នុងលក្ខណៈប្តូរទៅតាមព្រះរាជប្រកាសឆ្នាំ ១៩១៤ ។

## ជំពូកទី II
## តម្លៃគតិយុត្តនៃព្រំដែន

យើងបានជួបនៅក្នុងការពិភាក្សានេះ នូវការខុសគ្នាបន្តិចបន្តួចនៅក្នុងការលាតត្រដាងជាទូទៅ ដែលនៅក្នុងនោះបាននាំឲ្យកើតឡើងនូវផ្នែកនៃព្រំដែនពីមុន នូវអត្ថបទទាំងឡាយ ដែលយើងបានវាយតម្លៃរួចហើយ អំពីន័យពិតប្រាកដ និងតម្លៃគតិយុត្ត ។ ប៉ុន្តែដោយហេតុថា តម្លៃគតិយុត្តនេះ ពឹងផ្អែកជាញឹកញាប់ទៅលើហេតុការណ៍ខាងសម្ភារៈ ដែលបានផ្តល់កំណើតនៃការគូសព្រំដែន និងដោយកាលៈទេសៈនៃហេតុការណ៍នេះបានប្រែប្រួលទៅតាមផ្នែកទាំងឡាយនៃព្រំដែនដែលបានពិចារណានោះដូច្នេះគេត្រូវតែចាប់ផ្តើមធ្វើការវិភាគម្តងទៀត ។

### ផ្នែកទី I
### សេចក្តីសង្ខេបនៃហេតុការណ៍

**១** – ខេត្តទាំងឡាយនៅកូសាំងស៊ីនដែលបច្ចុប្បន្នស្ថិតនៅក្រោមរដ្ឋការវៀតណាម ដែលនៅតាមព្រំដែនខ្មែរវៀតណាម រវាងសមុទ្រនិងបង្គោលព្រំដែនទាំងឡាយនោះ តាមប្រវត្តិសាស្ត្រ គឺជារបស់ព្រះរាជាណាចក្រខ្មែរ ក៏ដូចជាការបញ្ជាក់អំពីការតវ៉ាទាំងឡាយដែលធ្វើឡើងដោយព្រះករុណាព្រះបាទអង្គឌួង នៅក្នុងឆ្នាំ ១៨៥៦ និងដោយព្រះករុណា ព្រះបាទនរោត្តមនៅក្នុងឆ្នាំ ១៨៦៨ ហើយដែលត្រូវបានគេដកយកដោយមិនរវល់គិតដល់ច្បាប់ជាមូលដ្ឋានអ្វីទាំងអស់ ។

**២** – ប៉ុន្តែ ប្រទេសបារាំង ជាមហាអំណាចការពារ ដោយមិនធ្វើការទាមទារការសងទៅឲ្យអណ្ណាម នៅក្នុងនាមនៃប្រទេសកម្ពុជានោះទេ តែបែរជាធ្វើការបញ្ចូលជាឧបសម្ព័ន្ធ ដោយសុទ្ធសាធនិងយ៉ាងងាយទៅក្នុងទឹកដីអាណានិគមរបស់ខ្លួននៅកូសាំងស៊ីន ។

**៣** – ព្រំដែនរវាងទឹកដីកម្ពុជា ដែលបានបញ្ចូលទៅឲ្យកូសាំងស៊ីន និងព្រះរាជាណាចក្រខ្មែរ តាមការពិតត្រូវបានរៀបចំឡើង ជាឯកតោភាគី ដោយប្រទេសបារាំងចាប់តាំងពីឆ្នាំ ១៨៧១ នៅលើមូលដ្ឋាន នៃអនុសញ្ញាមួយដែលបានឡាយព្រះហស្តលេខានិងចុះហត្ថលេខា រវាងព្រះមហាក្សត្រនៃប្រទេសកម្ពុជា និងទេសាភិបាលកូសាំងស៊ីន ។



**៤** – គំនូសព្រំដែនត្រូវបានរៀបចំឡើង ដោយមិនមានការយល់ព្រមជាដាច់ខាតពីប្រទេសកម្ពុជា ។ ជួនកាល វាធ្វើឲ្យខូចប្រយោជន៍ដល់លក្ខណៈសមហេតុសមផល និងតែងតែមិនរវល់គិតដល់សមធម៌ឡើយ នេះបើតាមព្រំដែនធម្មជាតិដែលមាននៅលើដីនោះ ។

**៥** – ផ្នែកនៃព្រំដែននេះ ប្រទេសកម្ពុជាបានស្គាល់នូវការខូចខាតផលប្រយោជន៍របស់ខ្លួនដែលនៅលើមូលដ្ឋាននៃរបាយការណ៍ភូតកុហកនេះដែលត្រូវបានធ្វើឲ្យទៅជាលក្ខណៈច្បាប់នៅក្នុងឆ្នាំ ១៩៤១ ។

ហេតុការណ៍ទាំងនេះ បាននាំឲ្យយើងពិនិត្យមើលឲ្យបានច្បាស់នូវតម្លៃគតិយុត្តនៃព្រំដែនឆ្នាំ ១៨៧៦ និងតម្លៃគតិយុត្តនៃព្រំដែនឆ្នាំ ១៩១៤ ។

### ផ្នែកទី II
### តម្លៃគតិយុត្តនៃព្រំដែនឆ្នាំ ១៨៧៦

សូមរំលឹកថា នៅពេលចាប់ផ្តើមការងារនេះត្រូវបានធ្វើឡើងដោយការបែងចែកនូវទឹកដី ដែលអធិបតេយ្យភាពតែងតែត្រូវបានទាមទារដោយព្រះមហាក្សត្រទាំងឡាយរបស់ប្រទេសកម្ពុជា ហើយដែលមានលក្ខណៈជារបស់ខ្មែរជាប្រវត្តិសាស្ត្រ និងពេញលក្ខណៈច្បាប់ដោយមិនអាចប្រកែកបានឡើយ ។

#### ១.– តម្លៃគតិយុត្តនៃអនុសញ្ញាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៧៣

គេបានរំលឹកថា អនុសញ្ញានេះ ដែលបានដាក់គោលការណ៍ជាទូទៅនៃគំនូសព្រំដែននាពេលអនាគត ត្រូវបានធ្វើអន្តរាគមន៍នៅក្រោយពេលអ្នកគ្រប់គ្រងបារាំងនៅខេត្តនានារបស់អណ្ណាមត្រូវបានដាក់ឲ្យទទួលបន្ទុកធ្វើការសិក្សាបញ្ហានេះ នៅឆ្នាំ ១៨៧១ ។

ដូច្នេះវាមិនមែនជាលទ្ធផលនៃការចរចានិងការស្រាវជ្រាវរួមនោះទេ ប៉ុន្តែវាជាការងារជាឯកតោភាគីមួយ ។

វាមិនមែនជាសកម្មភាពអន្តរជាតិមួយឡើយ តែជាសន្ធិសញ្ញាមួយគឺវាមិនបានឆ្លើយតបអ្វីសោះឡើយ ទៅនឹងតម្រូវការគតិយុត្តនៃសន្ធិសញ្ញាអន្តរជាតិទាំងឡាយ និងជាពិសេសវាមិនត្រូវបានឲ្យសច្ចាប័នដោយរដ្ឋាភិបាលបារាំងស្របទៅតាមតម្រូវការនៃច្បាប់ផ្ទៃក្នុងរបស់បារាំងនោះឡើយ ។

អនុសញ្ញានេះ វាតំណាងឲ្យកិច្ចព្រមព្រៀង ដែលប្រទានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅក្រោមការការពារ ទៅតាមការទាមទារមួយរបស់មហាអំណាចជាអ្នកការពារ ។

ប៉ុន្តែតម្លៃនៃការយល់ព្រមនេះ គឺមានកម្រិត គឺថាព្រះមហាក្សត្រនរោត្តម មិនដែលបាននាំឲ្យមានការបោះបង់ជាដាច់ខាតនូវខេត្តកម្ពុជានៅកូសាំងស៊ីនក្រោមដែលព្រះអង្គបានទាមទារដោយមិនឈប់ឈរនោះឡើយ ។ ដូច្នេះព្រះអង្គបានយល់ព្រមចំពោះអ្វីដែលអ្នកការពារបានរៀបចំនូវខ្សែបែងចែកទឹកដី ដែលនៅតែស្ថិតនៅក្រោមក្រសែភ្នែករបស់ប្រជាជនខ្មែរដែលស្ថិតនៅទាំងសងខាងនៃខ្សែនេះ គឺឯកភាពគ្នាតែមួយ ពីព្រោះថាព្រះអង្គបានចាត់ទុកគំនូសព្រំដែននេះធ្វើជាមូលដ្ឋានបណ្តោះអាសន្ននៃការបែងចែកសមត្ថកិច្ចរដ្ឋបាលនៅក្នុងអំឡុងពេលដែលវាជាដំណាក់កាលនៃការរៀបចំសម្រាប់អាណានិគមកូសាំងស៊ីន និងការរៀបចំឡើងវិញសម្រាប់ព្រះរាជាណាចក្រខ្មែរ ។

**២.-តម្លៃគតិយុត្តនៃគំនូសព្រំដែនដែលធ្វើឡើងជាការអនុវត្តតាមអនុសញ្ញានេះ**

បើសិនជាគេមានការសង្ស័យខ្លះទៅលើន័យគតិយុត្តរបស់អនុសញ្ញាឆ្នាំ ១៨៧៣ នោះ វិធីនៃការធ្វើឲ្យមានរូបរាងឡើងនូវគោលការណ៍ទាំងឡាយដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ គឺវាគ្រប់គ្រាន់ណាស់ទៅហើយសម្រាប់កិច្ចព្រមព្រៀងតែមួយគត់នេះ ដើម្បីធ្វើការចោទប្រកាន់ចំពោះតម្លៃគតិយុត្តនៃព្រំដែន ។

ព្រោះថា នៅដំណាក់កាលនេះ អាជ្ញាធរខ្មែរមិនដែលត្រូវបានគេហៅឲ្យចូលធ្វើអន្តរាគមន៍សោះឡើយ ។

ហើយជាពិសេស អាជ្ញាធរបារាំងមិនដែលបានដើរតួធ្វើជាអ្នកការពារនោះទេ ប៉ុន្តែផ្ទុយទៅវិញ មានតែការរំលោភដណ្តើមយកតែប៉ុណ្ណោះ ។ ផលប្រយោជន៍របស់ប្រទេសកម្ពុជា មិនដែលមានទម្ងន់នៅក្នុងសេចក្តីសម្រេចដែលគេបានប្រកាន់យកនោះឡើយ ។ វាបានផ្តល់នូវគំនូសព្រំដែនជាក់ស្តែងមួយដែលផ្ទុយដាច់ខាងទៅនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រដែលត្រូវការពារ ។

ដូច្នេះគេអាចធ្វើការសន្និដ្ឋានបានថា ព្រំដែនដែលត្រូវបានគូសដូច្នេះនោះមិនបានបញ្ចូលប្រទេសកម្ពុជាទៅក្នុងផ្ទៃអន្តរជាតិឡើយ ។ ផ្ទុយទៅវិញគេគ្រាន់តែអាចប្រើប្រាស់វាជាខ្សែព្រំដែនរដ្ឋបាលក្នុងលក្ខណៈផ្ទៃក្នុងនៅក្នុងអំឡុងនៃសហព័ន្ធឥណ្ឌូចិនតែប៉ុណ្ណោះ ។

## ផ្នែកទី III
## តម្លៃគតិយុត្តនៃព្រំដែនឆ្នាំ ១៩១៤

គេបានជួបប្រទះនៅទីនេះនូវព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ និងអនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ ដែលតម្លៃអនុក្រឹត្យបានទៅហួសផ្នែកនៃព្រំដែននេះ ហើយដែលយើងបានមានឱកាសពិនិត្យនៅក្នុងជំពូកមុនរួចហើយ ។ ដូច្នេះគេអាចពិនិត្យមើលនៅទីនេះទៀតនូវទឡ្ហីករណ៍ទូទៅដែលកាលនោះ យើងបានយកធ្វើជាសំអាង ។

ប៉ុន្តែចំពោះយោបល់របស់យើង ហេតុការណ៍មួយបានធ្វើឲ្យសេចក្តីសម្រេចដែលបានធ្វើអន្តរាគមន៍ក្លាយទៅជាមោឃៈ គឺជាការបន្លំដែលជាដើមកំណើតរបស់វា ។

វាត្រូវបានគេអះអាងដោយខុសច្បាស់ថា ខ្សែទូរលេខដែលបានចង្អុលបង្ហាញព្រំដែនត្រូវបានផ្លាស់កន្លែង ។

បញ្ហានេះត្រូវបានបង្ហាញថា វាមិនមែនជាការអង្កេតអ្វីឡើយ ។

លទ្ធផលនៃការអង្កេតនេះត្រូវបានគេបន្លំដោយករម្រោល និងដោយគិតទុកជាមុន

នៅក្នុងរបាយការណ៍ដែលផ្ញើពីទេសាភិបាលកូសាំងស៊ីន ទៅជូនអាជ្ញាធរជាន់ខ្ពស់ ។

គឺនៅលើមូលដ្ឋាននៃការបន្ទំនេះ ហើយដោយការភាន់ច្រឡំថា សេចក្ដីសម្រេចនៃអនុក្រឹត្យចុះថ្ងៃទី៣១ កក្កដា ១៩១៤ត្រូវបានធ្វើអន្តរាគមន៍នោះ ។ អត្ថបទនេះ មិនបានបង្ហាញនូវរបៀបសមហេតុសមផលស្ដីពីការកែប្រែព្រំដែនដូចជាការដូរមួយនោះទេ ។

ប៉ុន្តែនៅក្នុងកម្រិតថ្នាក់ស្រុក ដែលការពិតត្រូវបានទទួលស្គាល់ដោយរបៀបជាក់ស្ដែងនោះអាជ្ញាធរបារាំងបានដាក់បង្ខំដល់ព្រះមហាក្សត្រនូវព្រះរាជប្រកាសចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ ១៩១៤ បានធ្វើអន្តរាគមន៍ចំពោះគំនិតជួយគ្នា ស្ដីពីការសងវិញនោះម្យ៉ាង និងម្យ៉ាងទៀតអំពីការដូរ ចំពោះប្រតិបត្តិការដដែលនេះ ។

ហេតុដូច្នេះ គេអាចនិយាយបានថា មានការបន្លំពីខាងអាជ្ញាធរកូសាំងស៊ីន ការប្រព្រឹត្តខុសឆ្គងរបស់អាជ្ញាធរកណ្ដាលឥណ្ឌូចិន និងភាពមិនទំនងរបស់រ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា ។

បញ្ហានេះ វាហាក់គ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា គ្មានតម្លៃអ្វីសោះចំពោះព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ និងអនុក្រឹត្យ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ អំពីការផ្លាស់កន្លែងព្រំដែនទៅផ្លូវថ្នល់ទី២ នៃខេត្តហាទៀន និងលះបង់ទៅឲ្យកូសាំងស៊ីន នូវឃុំសាគី និងភូមិតូច កាន់ចាន់ឡូត (Kan Chanlot) ។

នៅក្នុងតំបន់ទាំងនេះ ព្រំដែនឆ្នាំ ១៩១៤ មិនត្រូវបានចាត់ទុកថា ជាព្រំដែនរដ្ឋបាលត្រឹមត្រូវនោះឡើយ ។ ច្បាប់ផ្ទៃក្នុងរបស់បារាំងអនុក្រឹត្យចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ១៩១៤ នឹងអាចត្រូវបានទុកជាមោឃៈនៅក្នុងការរៀបចំរបស់ខ្លួនដែលទាក់ទងចំពោះផ្នែកនៃភាពគ្មានហេតុផលនេះ ។



# ភាគទី VI
# ព្រំដែនសមុទ្រ
## ផ្នែកទី I
## ការទាមទាររបស់វៀតណាមនៅឆ្នាំ ១៩៦០

### ១.– របៀបដោះស្រាយរបស់វា

តាមកំណត់បង្ហាញមួយចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៦០ រដ្ឋលេខាធិការក្រសួងការបរទេសនៃសាធារណរដ្ឋវៀតណាមបានធ្វើការតវ៉ាប្រឆាំងការកាន់កាប់ដោយកងទ័ពកម្ពុជានូវកោះទាំងឡាយដែលអះអាងថា ជារបស់វៀតណាមស្ថិតនៅឈូងសមុទ្រថៃ ។

កំណត់បង្ហាញរបស់វៀតណាមបានអះអាងថា ក្រៅពីកោះ ហន់ ឌួ (Hon Dua) (កោះឆក) ត្រូវបានបញ្ចូលជាឧបសម្ព័ន្ធទាំងស្រុងនិងដោយគ្មានលក្ខខ័ណ្ឌដោយប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៣៨ ។ កងទ័ពកម្ពុជាបានចូលកាន់កាប់ជាបន្តបន្ទាប់នៅក្នុងខែមករា ឆ្នាំ ១៩៥៦ នៅបណ្ដាកោះ ភូ ឌូ (Phu Du) ដែលរួមមាន កោះហន់ ណាង ត្រុង (Hon Nang Trong) (កោះកណ្ដាល) និងកោះ ហន់ ណាង ង៉្វាយ (Hon Nang Ngoai) (កោះទឹក) និងនៅខែកុម្ភៈ ឆ្នាំ ១៩៥៨ កោះ ហន់ តៃ (Hon Tai) (កោះពេជ្រ) និងទីប្រជុំកោះ ហន់ ត្រែ ណាម (Hon Tre Nam) (ទីប្រជុំកោះនៃចោរសមុទ្រខាងជើង)" ។

កំណត់បង្ហាញបានបន្ថែមថា "ប៉ុន្តែតាមប្រវត្តិសាស្ត្រ ក៏ដូចជាតាមលក្ខណៈភូមិសាស្ត្រ និងដោយគតិយុត្តនោះ កោះទាំងនេះ គឺជារបស់វៀតណាមជានិច្ច" ។

គេមិនអាចបដិសេធបានទេថា ការក្រឡេកមើលនៅលើផែនទី វាបានធ្វើឲ្យលេចឡើងនូវយោបល់ថា កោះទាំងនេះស្ថិតនៅតាមបណ្ដោយ និងនៅជិតឆ្នេរសមុទ្ររបស់កម្ពុជាយ៉ាងខ្លាំងវាមិនអាចជារបស់វៀតណាមនោះទេ បើពិនិត្យតាមលក្ខណៈភូមិសាស្ត្រ ។

ចំពោះអ្វីដែលទាក់ទងទៅនឹងទឡ្ហីករណ៍នៃលំដាប់ប្រវត្តិសាស្ត្រ និងគតិយុត្តនោះ យើងនឹងពិនិត្យមើលជាបន្តបន្ទាប់ទៀត ។

### ២.–ការឆ្លើយបដិសេធទៅនឹងទឡ្ហីករណ៍នៃលំដាប់ប្រវត្តិសាស្ត្រ

កំណត់បង្ហាញបាននិយាយថា "នៅឆ្នាំ ១៨២០ អធិរាជ មិញ ម៉ាំង (Ming Mang) ទ្រង់បានបញ្ជាឲ្យធ្វើឲ្យកាន់តែមានតម្លៃឡើងនូវកោះភូ ក្វុក (Phu Quoc) និងបណ្ដាកោះដែលរួមបញ្ចូលជាមួយក៏ដូចជាកោះផ្សេងៗទៀត ដែលស្ថិតនៅក្នុងឈូងសមុទ្រថៃ ហើយដែលត្រូវបានកាន់កាប់ដោយវៀតណាម ចាប់តាំងពីដើមសតវត្សរ៍ទី១៨មកនោះ" ។

បើសិនជាគេស្ថិតនៅលើគម្រោងប្រវត្តិសាស្ត្រ គេត្រូវតែស្រាវជ្រាវឲ្យបានឆ្ងាយខ្លាំងថែមទៀត ដោយគតិយុត្ត ។ មានភស្តុតាងជាច្រើនបានបញ្ជាក់ថា មិនគ្រាន់តែកោះ ភូ ក្វុក ប៉ុណ្ណោះទេ ប៉ុន្តែមានកោះ ពូឡូកុងដ័រ (Poulo Condore) និងទឹកដីទាំងអស់នៅកូសាំងស៊ីនក្រោម គឺជារបស់កម្ពុជា ។

ចំពោះអ្វីដែលទាក់ទងទៅនឹងកោះ ភូ ក្វុក និងបណ្ដាខេត្តនៅខាងលិចកូសាំងស៊ីននោះ ព្រះរាជសាររបស់ព្រះមហាក្សត្រអង្គឌួង ផ្ញើទៅថ្វាយព្រះចៅណាប៉ូឡេអុង (Napoleon) ទីIII [១] បានរាយការណ៍អំពីកាលៈទេសៈទាំងឡាយដែលខេត្តទាំងនេះត្រូវបានគេកំហែងយក គឺនៅពេលដែលព្រះមហាក្សត្រយ៉ាឡុង (Gia long) (ដែលពេលនោះមានព្រះនាមថា ង្វៀន អាញ់ (Nguyen Anh) មានជម្លោះជាមួយគូប្រជែងរបស់ព្រះអង្គនោះ ព្រះអង្គបានអង្វរសុំជំនួយពីប្រទេសសៀម ។ នៅទីនោះព្រះមហាក្សត្រយ៉ាឡុងបានជួបព្រះបិតារបស់ខ្ញុំ និងបានចងសម្ព័ន្ធភាពជាមួយព្រះអង្គរួចហើយបានយាងត្រឡប់ពីប្រទេសសៀម និងប្រទេសកម្ពុជា និងបាននាំកងទ័ព កម្ពុជាមកវាយសត្រូវរបស់ព្រះអង្គ ហើយក៏បានទទួលជ័យជំនះនិងក្លាយទៅជាព្រះមហាក្សត្រតែមួយអង្គគត់នៅកូសាំងស៊ីន ។ បន្ទាប់មកទៀត ព្រះចៅយ៉ាឡុង បានស្នើព្រះបិតារបស់ខ្ញុំឲ្យលើកលែងកំណែននិងសួយសារអាករនៅខេត្តទ្រាំង ដែលនៅក្នុងនោះព្រះអង្គបានចុះកិច្ចសន្យាជំពាក់បំណុល ដើម្បីសម្ដែងនូវការដឹងគុណ ។ ព្រះបិតា របស់ខ្ញុំបានយល់អំពីភាសាសន្តិភាពនេះហើយក៏បានយល់ព្រមឲ្យរួចខ្លួនពីកាតព្វកិច្ចចំពោះខេត្តកម្ពុជានេះ ។ ប៉ុន្មានឆ្នាំក្រោយមកព្រះមហាក្សត្រយ៉ាឡុង បាន

(១) / ព្រះរាជសាររបស់ព្រះមហាក្សត្រ អង្គឌួង ផ្ញើទៅថ្វាយព្រះចៅណាប៉ូឡេអុង ទីIII ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៨៥៦ ដែលបានរាយការណ៍នៅក្នុង "អាណាចក្រទីII នៅឥណ្ឌូចិន" ដោយ Meyniard ទំព័រ ៤២៩ ។



ដណ្ដើមយកខេត្តនេះតែម្ដង ។ យូរក្រោយមកនៅពេលដែលព្រះបិតារបស់ខ្ញុំ បានយាងទៅសុំជំនួយពីព្រះមហាក្សត្រយ៉ាឡុង ហើយដែលខ្ញុំបានដកខ្លួនចេញពីប្រទេសសៀមព្រះអង្គមិញ ម៉ាំង ជាព្រះរាជបុត្រ និងជាអ្នកស្នងរាជ្យពីព្រះមហាក្សត្រអង្គនេះ បានចាត់ចែងឲ្យជីក ព្រែកជីកមួយ ដែលបានបែងចែកប្រទេសកម្ពុជាចាប់តាំងពីហាទៀន រហូតដល់មាត់ជ្រូក (ចូវ ដុក) និងបានដាក់រដ្ឋការឲ្យគ្រប់គ្រងខេត្តដែលបានដណ្ដើមយកនេះ ព្រមទាំងប្រជាជនអណ្ណាម..." ។

ខេត្តកម្ពុជាទាំងឡាយ ដែលអណ្ណាមបានដណ្ដើមយកនោះគឺ ខេត្តដុងណាយដណ្ដើមយកចាប់តាំងពីជាង ២០០ឆ្នាំ ។ ប៉ុន្តែខេត្តជាច្រើនទើបតែដណ្ដើមយកនៅក្នុងពេលថ្មីៗនេះ គឺទីក្រុងព្រៃនគរ ខេត្តឡុងហោ ផ្សារដែក មេ-សព្រះត្រពាំង អុងម័រ (Ong Mor) ក្រមួនស ទឹកខ្មៅ ពាម ឬ ហាទៀន កោះត្រល់[២] និងកោះត្រឡាច[៣] ។

ហើយព្រះមហាក្សត្រអង្គឌួង បានមានបន្ទូលបំរុងទុកជាមុនអំពីទឹកដីនេះនៅអមអធិរាជនៃប្រទេសបារាំង : "បើសិនជាដោយចៃដន្យពួកអណ្ណាមនឹងថ្វាយជូនព្រះករុណានូវទេសភូមិមួយនៃទេសភូមិទាំងនេះ ទូលបង្គំសូមអង្វរព្រះអង្គកុំឲ្យទទួលយកពីព្រោះទេសភូមិទាំងនេះជារបស់កម្ពុជា ។ ទូលបង្គំសូមព្រះអង្គមានសេចក្ដីអាណិតអាសូរដល់ទូលបង្គំនិងប្រជារាស្ត្ររបស់ទូលបង្គំផង ដើម្បីកុំឲ្យទូលបង្គំយើងខ្ញុំបានឃើញនូវការបាត់បង់ទឹកដីទៀត និងដើម្បីកុំឲ្យទូលបង្គំយើងខ្ញុំ ស្ថិតនៅក្នុងសភាពថប់ដង្ហើម នៅក្នុងព្រះរាជាណាចក្រដ៏តូចចង្អៀតនេះ" ។

### ៣.- ការបដិសេធ នូវទឡ្ហីករណ៍តាមលំដាប់គតិយុត្ត

កំណត់បង្ហាញរបស់វៀតណាមបានអះអាងថា "ក្រុមវៀតណាមថ្មីត្រូវបានបញ្ជូនមកដែលរួមផ្សំជាមួយគ្រួសារចិន មួយចំនួននៃប្រជាជនទាំងអស់នៃកោះនេះ ។ ហេតុដូច្នេះហើយ នៅពេលបារាំងបានមកដល់កូសាំងស៊ីននៅឆ្នាំ ១៨៦៩ អាជ្ញាធរបារាំងបានរកឃើញរួចហើយនូវភូមិវៀតណាមទាំងឡាយនៅលើកោះនៃឈូងសមុទ្រថៃ " ។

(២) / កោះ ភូ - ក្វុក ។
(៣) / កោះ ពូឡូកុងដ័រ

របាយការណ៍របស់ទេសាភិបាលកូសាំងស៊ីន ដែលបានផ្ញើទៅជូនរដ្ឋមន្ត្រីក្រសួងជើងទឹកនៅឆ្នាំ ១៨៦៧ ស្តីពីសភាពការណ៍នៃបណ្តាខេត្តនៅខាងលិចកូសាំងស៊ីន ដែលទើបដណ្តើមបានថ្មីៗ បានបញ្ជាក់ថា កោះភូក្កុកនេះ ចៅហ្វាយខេត្តអណ្តាមនៅខេត្តហាទៀន មិនដែលបានមកធ្វើទស្សនកិច្ចឡើយ និងថា កោះទាំងឡាយដែលស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ កូសាំងស៊ីន នៅក្នុងឈូងសមុទ្រសៀម "គឺជាជ្រាំងថ្មចោទ ស្ទើរតែគ្មានមនុស្សរស់នៅនិងមានតែចោរសមុទ្រស្នាក់នៅតែប៉ុណ្ណោះ" ។ តាមការពិតកោះទាំងឡាយនៅឈូងសមុទ្រសៀម ដែលយើងនឹងបានដឹងនៅពេលខាងមុខទៀតនោះ គឺរស់នៅដោយប្រជាជនកម្ពុជា ។

ម្យ៉ាងទៀត និក្ខេបបទ ដែលបាននិយាយថា នៅទីនេះមានប្រជាជននៅលើទឹកដីដែលត្រូវបានចាត់ទុកថា ជាទឹកដីអណ្តាមនោះបាននាំឲ្យយើងអនុវត្តនៅក្នុងន័យបញ្ច្រាស់ទៅវិញថា គឺនៅទីនោះតាមលក្ខណៈសមហេតុសមផល មានតែប្រជាជនកម្ពុជាទេ ដូច្នេះទឹកដីនេះត្រូវតែចាត់ទុកថា ជាទឹកដីកម្ពុជា ។ ដោយហេតុនេះ និគមស្រុកទ្រាំង និងត្រាំវិញ ដែលមានប្រជាជនកម្ពុជាភាគច្រើនរស់នៅនោះ នៅក្នុងច្បាប់នេះ ត្រូវតែទុកឲ្យប្រទេសកម្ពុជា ។ ប៉ុន្តែតាមការពិត គេបានឃើញថា អភិបាលកូសាំងស៊ីន មិនបានជ្រើសយកដំណោះស្រាយនេះទេ នៅក្នុងអំឡុងពេលបោះបង្គោលដីឆ្នាំ ១៨៧៣ – ១៨៧៦ ។

ពួកវៀតណាមបានអះអាងម្យ៉ាងទៀតថា "ការសិក្សាលំអិតអំពីប្រវត្តិសាស្ត្រ (monographie) នៃខេត្តរ៉ាច់យ៉ា និងខេត្តហាទៀន ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងបារាំងនោះតែងតែបានបែងអំពីកោះទាំងនេះថា ដូចជាផ្នែកមួយរបស់ខេត្តទាំងឡាយដែលពួកគេបានទទួលបន្ទុក" ។

នៅលើចំណុចនេះ ទស្សីករណ៍របស់វៀតណាម ហាក់ដូចជាជួយគ្នាជាមួយនឹងព័ត៌មានដូចតទៅនេះ ដែលផ្តល់ឲ្យដោយអ្នកគ្រប់គ្រង Fournier នៅហាទៀន នៅក្នុងឆ្នាំ ១៩១៣ [៤] គឺ "ថ្វីបើមានការស្រាវជ្រាវដោយល្អិតល្អន់បំផុតក៏ដោយ ក៏ខ្ញុំមិនអាចរកឃើញនៅក្នុងឯកសារនៃការត្រួតពិនិត្យបានដែរ នូវឯកសារផ្លូវការមួយ

(៤) / លិខិតរបស់អភិបាលខេត្ត ហាទៀន ចុះថ្ងៃទី៣ ខែមករា ឆ្នាំ ១៩១៣ ផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន ។



ទោះបីជាវាបានចង្អុលបង្ហាញនូវកោះទាំងឡាយ ដែលនៅក្នុងចំណុះរបស់ខេត្តក៏ដោយគឺថា មួយផ្នែកវាកំណត់កោះទាំងឡាយដែលជារបស់កូសាំងស៊ីន និងមួយផ្នែកទៀតវាជាកោះដែលស្ថិតនៅក្រោមអំណាចរបស់កម្ពុជា" ។

ប៉ុន្តែបញ្ហានៃកោះនៅឈូងសមុទ្រថៃ មិនមែនជាបញ្ហាថ្មីនោះឡើយ ។ នៅក្នុងឆ្នាំ ១៩១៣ វាមានការរំដើបរំជួលរួចទៅហើយ ។ ការទាមទារទៅវិញទៅមករបស់រដ្ឋាភិបាលកូសាំងស៊ីន ហើយនិងរដ្ឋការរបស់អាណាព្យាបាលនៅកម្ពុជា គឺជាកម្មវត្ថុនៃការប្តូរដ៏សំខាន់មួយនៃការឆ្លើយឆ្លងគ្នា ។

## **ផ្នែកទី II**
## **ការពិភាក្សាតទល់គ្នា ឆ្នាំ ១៩១៣**

### **១.– ដើមកំណើតនៃការពិភាក្សាតទល់គ្នា**

កិច្ចការនេះមានដើមកំណើតមកពីការទាមទារធ្វើសម្បទានចំពោះកោះទាំងនេះដែល"មានស្រទាប់លោហជាតិដ៏សម្បូរបែបដូចជា ហ្វុសហ្វាត កំបោរ និងរ៉ែដែក" [៥] ។ ចៅហ្វាយខេត្តហាទៀន មិនតិចជាងមួយខែទេ បាន"ទទួលនូវការទាមទារនូវបរិវេណរ៉ែដ៏គួរឲ្យចាប់អារម្មណ៍ចំនួន ១៤ ដោយគ្មានគិតបញ្ចូលនូវកោះទាំងឡាយនៅឈូងសមុទ្រ" [៦] ។

ចំណែកខាងបារាំងវិញ លោករ៉េស៊ីដង់បារាំង នៅខេត្តកំពត បានទទួលនូវការទាមទារការធ្វើសម្បទាននូវដីមួយកន្លែងដែលស្ថិតនៅក្នុងកោះ កាស្តាំង (Kastang)[៧] ។

ដូច្នេះវាជាការចាំបាច់ ដើម្បីអនុញ្ញាតឲ្យអាជ្ញាធររបស់ប្រទេសទាំងពីរ ដើម្បីប្រកាន់យកនូវការសម្រេចរបស់ខ្លួនចំពោះការទាមទារទាំងនេះ និងដើម្បីឲ្យដឹងអំពីទឹកដីណាដែលជារបស់កោះទាំងនេះ ។

(៥) និង (៦) / លិខិតរបស់អ្នកគ្រប់គ្រងខេត្តហាទៀន ផ្ញើទៅជូនទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ ១៩១៣ ។
(៧) / ព្រឹត្តបត្រ ដែលត្រូវតាមរបស់រ៉េស៊ីដង់ជាន់ខ្ពស់ នៃប្រទេសកម្ពុជាផ្ញើទៅទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ១៩១៣ ។

## ២.- ការរាវរករបស់រដ្ឋការបារាំង

ប៉ុន្តែទាំងរដ្ឋការបារាំងនៅកូសាំងស៊ីន ទាំងរដ្ឋការបារាំងនៅប្រទេសកម្ពុជាពុំមានព័ត៌មានច្រាកដប្រជាអំពីកម្មសិទ្ធិនៃកោះទាំងឡាយនោះឡើយ ។ វាហាក់ដូចជាគួរឲ្យចាប់អារម្មណ៍ ដើម្បីបង្ហាញម្តងទៀត ដូចខាងក្រោមនេះ នូវសេចក្តីស្រង់មួយនៃចម្លើយរបស់ទេសាភិបាលកូសាំងស៊ីន ទៅកាន់ព្រឹត្តប័ត្រដែលត្រូវតាមយោបល់របស់លោក រ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា គឺ"តាមលិខិតលេខ ៥១៧ ចុះកាលបរិច្ឆេទទី៣១ ខែមីនា កន្លងមកលោកបានស្នើសុំព័ត៌មានអំពីភាពនៅក្នុងចំណុះនៃសមុទ្រនៃកូសាំងស៊ីននៅក្នុងឈូងសមុទ្រសៀម។ ខ្ញុំមានកិត្តិយសសូមជម្រាបលោកថា ថ្វីបើមានការស្រាវជ្រាវដោយល្អិតល្អន់ដែលលោកបានចាប់ផ្តើមធ្វើក៏ដោយក៏វាមិនមានលទ្ធភាព ដើម្បីប្រមូលផ្តុំនូវកត្តាច្រាកដប្រជាទាំងឡាយ ដែលអនុញ្ញាតឲ្យកំណត់បាននៅក្នុងរបៀបដាច់ខាតមួយនូវសិទ្ធិរៀងៗខ្លួនរបស់កូសាំងស៊ីន និងរបស់ប្រទេសកម្ពុជាទៅលើកោះទាំងឡាយនៃឈូងសមុទ្រសៀម ។

"នៅក្នុងអំឡុងពេលកំណត់ព្រំដែនជាផ្លូវការនៅឆ្នាំ ១៨៧៣ បញ្ហានេះមិនត្រូវបានពិនិត្យមើលឡើយ ហើយចាប់តាំងពីសម័យនោះមកមានតែការព្រមព្រៀងរវាងលោករ៉េស៊ីដង់ខេត្តកំពត និងលោកអភិបាលខេត្តហាទៀន ដែលទាក់ទងទៅនឹងអធិបតេយ្យភាពនៃកោះទាំងនេះ" (៨) ។

ពេលនោះគេបានស្វែងរកប្រមូលនូវសេចក្តីប្រកាសរបស់ប្រជាជន ។ ប៉ុន្តែសេចក្តីប្រកាសនេះមានការជួយគ្នាយ៉ាងខ្លាំង ។

## ៣.- និក្ខេបបទ នៃកូសាំងស៊ីន

**១.–** ពួកអណ្ណាមបានរៀបចំ នូវការទាមទារតាមទំនើងចិត្តយ៉ាងខ្លាំង ។ ពួកគេបានទាមទារ "កាន់កាប់កោះ ហន់ តាង (Hon Tang) (កោះតាង) ម្យ៉ាងទៀតដូចដឹងស្រាប់ហើយថា កោះទាំងនេះស្ថិតនៅឬមួយនៅកណ្តាលសមុទ្រ ឬមួយនៅតាមបណ្តោយឆ្នេរសមុទ្រ ពិតហើយលើកលែងតែកោះទាំងឡាយ ដែលត្រូវបាន

*(៨) / ចម្លើយរបស់ទេសាភិបាលកូសាំងស៊ីន ចំពោះព្រឹត្តប័ត្រដែលត្រូវតាមយោបល់របស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា ។*



ប្រគល់មកឲ្យប្រទេសកម្ពុជានៅក្នុងពេលថ្មីៗនេះ ក្រោយពីសន្ធិសញ្ញាបារាំងសៀមចុងក្រោយនេះ" (៩) ។

**២.–** ការទាមទាររបស់អណ្ណាមទាំងនេះ ជាធម្មតាត្រូវបានទទួលខុសត្រូវដោយទេសាភិបាលកូសាំងស៊ីន ។

**២–១** គេបានសង្កត់ទៅលើហេតុការណ៍ដែលថា ប៉ុស្តិ៍គយដែលនៅក្រោមអំណាចកូសាំងស៊ីន ត្រូវបានបង្កើតឡើង នៅក្នុងកោះទាំងឡាយនោះ ស្ថិតនៅក្រោមឈ្មោះនៃកោះទឹក និងកោះឆក" ។

**៣.–** ប៉ុន្តែនេះមិនមែនជាទឡ្ហីករណ៍ដែលមានតម្លៃនោះទេ ។ ក្រៅពីនេះ (៩ស្ទួន) យើងបានចង្អុលបង្ហាញនៅក្នុងកាលៈទេសៈណាដែលប៉ុស្តិ៍គយត្រូវបានដណ្តើមថ្វាយព្រះមហាក្សត្រនៃប្រទេសកម្ពុជាដោយលោក Charles thomson ដែលត្រូវបានប្រគល់ការទុកចិត្តទៅឲ្យរដ្ឋាភិបាលកូសាំងស៊ីន ដើម្បីបង្កើតទៅជាសហភាពគយមួយរវាងប្រទេសទាំង៤ នៅឥណ្ឌូចិនបារាំង (កូសាំងស៊ីន កម្ពុជា អណ្ណាម តុងកឹង) ។ ប៉ុស្តិ៍គយដែលនៅក្រោមអំណាចរបស់រដ្ឋាភិបាលកូសាំងស៊ីន ត្រូវបានបង្កើតឡើងមិនគ្រាន់តែនៅលើកោះទឹក និងកោះឆក ប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងចំណុចផ្សេងៗទៀតជាច្រើនរបស់ប្រទេសទាំង៤ នៅឥណ្ឌូចិនបារាំង ។ ដូច្នេះ តើគេត្រូវសន្និដ្ឋានថាប្រទេសទាំង៣ផ្សេងទៀត នៅឥណ្ឌូចិនបារាំង ចំពោះហេតុផលដែលថា មានប៉ុស្តិ៍គយស្ថិតនៅក្រោមអំណាចនៃរដ្ឋាភិបាលកូសាំងស៊ីន ស្ថិតនៅក្នុងផ្នែកនៃទឹកដីកូសាំង ស៊ីនឬ ? គេបានទៅដល់សភាពការណ៍មួយដែលមិនទំនងនិងបដិសេធដោយហេតុការណ៍ពិតទាំងឡាយ ។

**៤.–** ទឡ្ហីករណ៍ផ្សេងទៀតដែលបង្ហាញដោយពួកអណ្ណាមនោះគឺថា កោះកណ្តាល "មានភូមិអណ្ណាមមួយដែលត្រូវបានបង្កើតឡើងនៅក្រោមរដ្ឋកាលរបស់មិញ ម៉ាង

*(៩) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២ ខែមករា ឆ្នាំ ១៩១៤ ទៅជូនរ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជា ។*

*(៩ស្ទួន) / សភាពការណ៍នៃប្រទេសកម្ពុជាពីឆ្នាំ ១៨៦៣ ដល់ ១៨៨៤ ។ ស្នាដៃ D.E.S ដើម្បី នៃវិទ្យាសាស្ត្រនយោបាយ ។ ប៉ារីសឆ្នាំ ១៩៦៤ ។*

(១៨២០ ទៅ១៨៤១)" ។ អំពីចំណុចនេះប្រធានផ្នែកសុរិយោដីនៃប្រទេសកម្ពុជាបានផ្តល់នូវព័ត៌មានទាំងឡាយ ដែលទុកជាមោឃៈនូវការអះអាងរបស់អណ្ណាម ។ កោះកណ្តាល មិនមែនដូចដែលទេសាភិបាលកូសាំងស៊ីនចង្អុលបង្ហាញនោះឡើយ ដែលថាមានតែពួកអណ្ណាមរស់នៅនោះ ។ មានប្រជាជនម៉ាឡេប្រហែល៣០នាក់ គឺជាអាណិកជនរស់នៅក្នុងប្រទេសកម្ពុជា ដោយពិតប្រាកដដែលបានទៅតាំង ទីលំនៅនៅទិសពាយ័ព្យ ដើម្បីធ្វើស្រែចំការ ក៏ដូចជាប្រជាជនចិន ជាច្រើននាក់មកពីក្រុមអ្នកកាន់សាសនានៅហៃណានដូចគ្នា ដែលមានដើមកំណើតនៅប្រទេស កម្ពុជា ។ ឈ្មោះ លី ម៉ែន ហម មានទីលំនៅ នៅខេត្តកំពត មាន"នៅក្នុងកោះនេះនូវចំការម្រេចដ៏សំខាន់ និងចុងក្រោយបានដាំនូវដើមកៅស៊ូខ្លះ" [10] ។

**៥.–** ចំណែកកោះផ្សេងៗទៀត ទេសាភិបាលកូសាំងស៊ីន បានបង្ហាញថា កោះនេះស្ទើរតែគ្មានមនុស្សរស់នៅឡើយ "ប៉ុន្តែហាក់ដូចជាមានធនធានក្រោមដីច្រើនគួរសមដែលត្រូវបានវិនិច្ឆ័យដោយ បរិវេណនៃអណ្តូងរ៉ែជាច្រើន ដែលត្រូវបានគេទាមទារ" ។ ម្យ៉ាងទៀត ឆ្នេររបស់កោះទាំងនេះ គឺសម្បូរណ៍ទៅដោយត្រីបំផុត ។ ប្រភពធនធានទាំងនេះនៅមិនទាន់បានធ្វើអាជីវកម្មនៅឡើយ ប៉ុន្តែវាមិនសូវពិតនោះទេ ដែលថា វាតំណាងឲ្យទុនដ៏សំខាន់ដែលថ្ងៃណាមួយវានឹងត្រូវគេធ្វើឲ្យទៅជាមានតម្លៃ ហើយដែលអាណានិគមនឹងទាញបានផលកម្រៃដ៏ពិតប្រាកដជាបន្ទាប់មកទៀតនោះ" [11] ។

**៦.–** ខ- ចុងក្រោយ ទេសាភិបាលកូសាំងស៊ីនដែលទំនងជាជ្រើសរើសទស្សនៈរបស់អណ្ណាមនោះបានបន្ថែមថា "នៅទីបញ្ចប់គេត្រូវកត់សម្គាល់ថា កោះទាំងនេះត្រូវបានធ្វើអាជីវកម្មស្ទើរតែទាំងស្រុង ដោយពួកអ្នកនេសាទវៀតណាម នៅកោះភូ ក្កុក ហើយដែលវាហាក់ដូចជាគួរដល់កាល ចំពោះទស្សនៈនេះ ដើម្បីរក្សាកោះទាំងនេះឲ្យស្ថិតនៅក្រោមអធិបតេយ្យរបស់កូសាំងស៊ីន ដើម្បីការត្រួតត្រាប្រជាជន

---

*(១០) / ចម្លើយរបស់ប្រធានផ្នែកសុរិយោដី នៃប្រទេសកម្ពុជាផ្ញើទៅឲ្យព្រឹក្សបីត្រ ដែលត្រូវតាមលិខិតចុះថ្ងៃទី៩ ខែមករា ឆ្នាំ ១៩១៤ របស់លោក រ៉េស៊ីដង់ជាន់ខ្ពស់ ។*

*(១១) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២ ខែមករា ឆ្នាំ ១៩១៤ ផ្ញើទៅជូនលោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា ។*



ទោះបីជាទឹកន្លែងដែលកោះទាំងនេះស្ថិតនៅក្រោមអំណាចតែមួយនិងដូចគ្នា និងនៅក្រោមបទបញ្ជាតែមួយ" [12] ក៏ដោយ ។

## ៤ – និក្ខេបទកម្ពុជា

ចំពោះទឡ្ហីករណ៍ទាំងនេះ ប្រធានផ្នែកសុរិយោដីរបស់ប្រទេសកម្ពុជាបានឆ្លើយថា មានតែអ្នកស្រុករបស់ប្រទេសកម្ពុជាបានធ្វើអាជីវកម្មកោះទាំងនេះ នៅក្នុងរដូវនេសាទ "ប៉ុន្តែមិនដែលមានពួកអណ្ណាមនៅភូ ក្កុក ទេ ហើយបញ្ហានេះបានកើតមានដោយងាយពីព្រោះពួកគេបានទៅស្វែងរកធនធានដែលស្ថិតនៅឆ្ងាយដែលមាននៅក្នុងប្រទេសជិតខាងខ្លួនដែលនៅជិត ។

រដ្ឋការរបស់អាណាព្យាបាលមានផលប្រយោជន៍តែមួយ ដែលទាក់ទងទៅនឹងការបញ្ចូលនៅក្នុងកម្មសិទ្ធិរបស់ខ្លួននូវកោះទាំងអស់ដែលសម្បូរទៅដោយធនធានរ៉ែ ។ ប៉ុន្តែគេត្រូវតែប្រកាន់យកនូវសេចក្តីសម្រេចមួយ ដើម្បីបញ្ចប់នូវភាពមិនច្បាស់ប្រជាមិនឈប់ឈរនេះ ។

"សភាពការណ៍ភូមិសាស្ត្រនៃកោះទាំងនេះបានភ្ជាប់ទៅជាមួយប្រទេសកម្ពុជាតាំងពីកំណើត ដែលការត្រួតត្រា អាចអនុវត្តបានល្អប្រសើរព្រោះស្ថិតនៅជិតអាជ្ញាធរកម្ពុជា ។

"នៅទីបញ្ចប់ គឺថា ឆក ទឹកសាបបានបំពេញដោយភក់ នៅរៀងរាល់ឆ្នាំ ដោយព្រែកដែលមានឈ្មោះដូចគ្នាបាននាំមក ។ ខ្ញុំបានឆ្លងឆកនេះនៅពេលទឹកនាចក្រោយពីមានគ្រោះថ្នាក់នាវាហើយដែលមានជម្រៅមិនលើសពី ១ម ១០ មានជម្រៅខ្ពស់ជាងខ្សែក្រវាត់បន្តិច ។ ដូច្នេះវានឹងមានលក្ខណៈមិនធម្មតាក្នុងការមើលនៅថ្ងៃណាមួយ កោះកណ្តាលដែលបានភ្ជាប់ទៅនឹងទឹកដីកម្ពុជា ស្ថិតនៅជាទឹកដីកូសាំងស៊ីន នៅពេលដែលសភាពការណ៍ភូមិសាស្ត្រ ដូច្នេះខ្ញុំសូមរំលឹកម្តងទៀតអំពីសម័យនៃការបង្កើត និងនៅក្នុងរបៀបជាទូទៅនូវដើមកំណើត នៃកោះទាំងអស់នេះថ្វីបើការដណ្តើមកោះទាំងនេះដោយកូសាំងស៊ីន បានចង្អុលបង្ហាញដោយច្បាស់លាស់

---

*(១២) / លិខិតរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២ ខែមករា ឆ្នាំ១៩១៤ ដែលបាននិយាយខាងលើ ។*

និងជាធម្មតា ធ្វើជាផ្នែករួមបញ្ចូលនៃកម្មសិទ្ធិរបស់កម្ពុជា" [១៣] ក៏ដោយ ។

កិច្ចការនេះត្រូវបានដាក់ស្នើទៅអគ្គទេសាភិបាល ។ ប៉ុន្តែលោកអគ្គទេសាភិបាល មិនបានដោះស្រាយជាបន្ទាន់ឡើយ ។ ទើបតែដល់ឆ្នាំ ១៩៣៩ ទើបមានចេញសេចក្តីសម្រេចមួយ ។

## ផ្នែកទី III
## សេចក្តីសម្រេចឆ្នាំ ១៩៣៩

### ១-មូលហេតុ និងខ្លឹមសារនៃសេចក្តីសម្រេច

ថ្ងៃទី៣១ ខែមករា ឆ្នាំ ១៩៣៩ លោកអគ្គទេសាភិបាល Brévié បានធ្វើសេចក្តីសម្រេចមួយ តាមសារាចរលេខ ៨៦៧ A P I ។ សារាចររបស់លោក Brévié បានចង្អុលបង្ហាញនូវមូលហេតុជាធំ ចំពោះការជ្រើសរើសនៃដំណោះស្រាយដែលបានយល់ព្រម (ឧបសម្ព័ន្ធ ១៤) ។

"សភាពការណ៍នៃចង្កោមកោះនេះ ដែលស្ថិតនៅតម្រៀបគ្នាជាជួរនៅតាមបណ្តោយឆ្នេរសមុទ្រនៃប្រទេសកម្ពុជា ហើយដែលកោះខ្លះ បានស្ថិតនៅជិតនៃឆ្នេរ នេះ និងដីដុះទាំងឡាយដែលបានបន្តបច្ចុប្បន្ននេះ ហាក់ត្រូវបានតភ្ជាប់គ្នាទៅត្រើយសមុទ្រនៃប្រទេសកម្ពុជា នៅក្នុងអនាគតដ៏ខ្លីនេះ បានហៅដោយសមហេតុសមផល និងប្រកបដោយលក្ខណៈភូមិសាស្ត្រ អំពីភាពចាំបាច់ចំពោះកោះទាំងនេះ ដើម្បីស្ថិតនៅក្រោមចំណុះរបស់ការគ្រប់គ្រងរបស់ប្រទេសកម្ពុជា " ។

សម្រាប់ហេតុផលទាំងនេះ អគ្គទេសាភិបាលបានសម្រេចថា "កោះទាំងអស់ដែលស្ថិតនៅខាងជើងខ្សែកាត់កែងទៅឆ្នេរសមុទ្រដែលចេញពីព្រំដែនរវាងប្រទេស

(១៣) / ចម្លើយ របស់ប្រធានផ្នែកសុរិយោដី នៃប្រទេសកម្ពុជា ផ្ញើទៅព្រឹក្សប័ត្រ ដែលត្រូវតាមលិខិតចុះថ្ងៃទី ៩ ខែមករា ឆ្នាំ១៩១៤ របស់លោក រ៉េស៊ីដង់ ជាន់ខ្ពស់ ដែលបាននិយាយមកហើយ ។



កម្ពុជា និងកូសាំងស៊ីន និងបង្កើតបានជាមុំ ១៤០អង្សា ៦ ជាមួយខាងជើងនៃខ្សែវ៉ណ្ឌ ស្របទៅតាមផែនទីដែលបានបញ្ចូលជាឧបសម្ព័ន្ធនេះ ចាប់ពីពេលនេះតទៅនឹងត្រូវគ្រប់គ្រងដោយប្រទេសកម្ពុជា ។ អាណាព្យាបាល នឹងទទួលបន្ទុកជាពិសេសខាងប៉ូលិសនៅកោះទាំងនេះ ។

"កោះទាំងអស់ដែលស្ថិតនៅខាងត្បូងនៃខ្សែព្រំដែននេះ ដោយរួមទាំងកោះ ភូក្កុកទាំងមូល នឹងបន្តស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូសាំងស៊ីន ។ គេបានឮថា ខ្សែកំណត់ព្រំដែន ដែលបានកំណត់ដូច្នេះ បានរត់ព័ទ្ធខាងជើងកោះ ភូ ក្កុក ដោយឆ្លងកាត់ចំណុចខាងជើងបំផុត នៃកោះនេះចំនួន ៣គ.ម ...។

"ប្រាកដហើយថា គឺមានតែការគ្រប់គ្រងនឹងប៉ូលិស និងបញ្ហានៃភាពនៅក្នុងចំណុះទឹកដីនៃកោះទាំងនេះទេ ដែលស្ថិតនៅបម្រុងទុកទាំងស្រុង..." ។

(សូមមើលផែនទីឧបសម្ព័ន្ធលេខ ២៥) ។

ឃ្លាចុងក្រោយនៃសារាចរនេះ គឺងាយយល់ណាស់ ។ វិធានការដែលគេប្រកាន់ យក គឺទាក់ទងទៅនឹងការគ្រប់គ្រងតែប៉ុណ្ណោះ ។ ចំណែកបញ្ហាអធិបតេយ្យភាពវិញ វាត្រូវបានបម្រុងទុក ។ ប៉ុន្តែបើសិនជាវាត្រូវបានបម្រុងទុក នេះមិនមែនមានន័យ ថា អធិបតេយ្យភាពនេះត្រូវបានសន្មតរួចហើយ ដើម្បីជាផលប្រយោជន៍របស់ប្រទេសណាមួយឡើយ ។ អធិបតេយ្យភាពស្ថិតនៅមិនទាន់ដាច់ស្រេច គឺមិនទាន់ដាច់ស្រេចទាំងស្រុងទេ ។

### ២ – ការបកស្រាយរបស់វៀតណាមអំពីសារាចរ

អ្វីដែលមានពីមុននេះបាននាំឲ្យយើងចាត់ទុកថា ដូចជាមានបំណងស្ទាត់កំចាំង និងការបកស្រាយដោយបំពាន ដែលធ្វើឡើងដោយរដ្ឋាភិបាលសាយហ្គន នៅពេលដែលរដ្ឋាភិបាលនេះនិយាយថា "ច្បាប់នៃកម្មសិទ្ធិរបស់វៀតណាម នៅលើកោះទាំងនេះ ក៏ត្រូវបានទទួលស្គាល់ផងដែរ ដោយសារាចរចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ១៩៣៩ ដោយហេតុផលនៃស្ថានការណ៍រដ្ឋបាល សុទ្ធសាធ ការភ្ជាប់ទៅនឹងទស្សនៈនៃការ

គ្រប់គ្រង និងប៉ូលិសនៅអាណាព្យាបាល នៃប្រទេសកម្ពុជា នូវកោះទាំងឡាយដែលស្ថិតនៅខាងលើខ្សែកាត់កែងទៅនឹងឆ្នេរដែលចេញពីព្រំដែនដីគោក និងបង្កើតបានជាមុំ ១៤០ G ជាមួយទិសខាងជើងនៃខ្សែវីណ្ណ (១៤) "។

គេទើបតែត្រូវការ ដើម្បីគូសបញ្ជាក់នូវពាក្យបណ្តឹងជាគោលការណ៍ដែលមាននៅក្នុងទស្សីករណ៍នេះ ។ ច្បាស់ជាគេអាចមានហេតុផលខ្លះ ដើម្បីបញ្ជាក់ថា សារាចររបស់លោក Brévié មិនបានកែប្រែអ្វីសោះឡើយ អំពីសភាពការណ៍អន្តរជាតិរបស់កោះទាំងឡាយនោះ ប៉ុន្តែគេអាចសម្រេចបញ្ហាកោះទាំងនេះថា ជារបស់វៀតណាមបានតែនៅក្នុងវិធានការដែលបានបង្ហាញថា កោះទាំងនេះ គឺជារបស់វៀតណាមដោយត្រឹមត្រូវនោះតែប៉ុណ្ណោះ ។

ប៉ុន្តែការបង្ហាញចុងក្រោយនេះ មិនទាន់ត្រូវបាននាំមកនៅឡើយទេ ទាំងរដ្ឋការបារាំង នៅកូសាំងស៊ីនទៅឆ្នាំ ១៩១៣ ទាំងរដ្ឋាភិបាលវៀតណាម ។ ផ្ទុយទៅវិញ យើងយល់ថា យើងអាចបង្ហាញតាមលក្ខណៈភូមិសាស្ត្រ (ជាភស្តុតាងផងដែរ) និងតាមលក្ខណៈជាតិពន្ធុថា ថ្វីបើមានវត្តមាននៃជនជាតិភាគតិចអណ្ណាមក៏ដោយក៏តាមលក្ខណៈប្រវត្តិសាស្ត្រ ចំពោះកោះទាំងឡាយនៅឈូងសមុទ្រសៀមនោះ គឺជាកោះកម្ពុជាជានិច្ច ។ មិនគ្រាន់តែកោះទាំងឡាយដែលស្ថិតនៅក្រោម ការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលខ្មែរ បច្ចុប្បន្នដោយពិតៗនោះទេ ប៉ុន្តែក៏នៅមានកោះទាំងឡាយដែលត្រូវបានភ្ជាប់តាមលក្ខណៈរដ្ឋបាលនៅវៀតណាម តាមសារាចរ Brévié នោះផង ដែរ និងជាពិសេសគឺកោះ ភូ ក្វុក ។

ម្យ៉ាងទៀត យើងសូមបន្ថែមថា ការទាមទាររបស់វៀតណាម បានលេចឡើងដូចជាកលល្បិចមួយសំដៅបិទបាំងនូវការទន្ទ្រានយកទឹកដីកម្ពុជារាប់មិនអស់ដែលវៀតណាមជាអ្នកបន្តមរតក និងជាអ្នកបន្តអំណាចរបស់អាណានិគម បានអនុវត្តនៅក្នុងពេលបច្ចុប្បន្ននៅលើប្រទេសកម្ពុជា និងក៏សំដៅផងដែរ ដើម្បីបម្រើ បើតាមបច្ចេកទេសមួយដែលត្រូវបានកែតម្រូវផងដែរ នៅក្នុងពេលនៃការរំលោភរបស់

(១៤) / កំណត់សម្គាល់របស់រដ្ឋលេខាធិការ នៃក្រសួងការបរទេស នៃសាធារណរដ្ឋវៀតណាម ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ ១៩៦០ ផ្ញើទៅជូនក្រសួងការបរទេស នៃប្រទេសកម្ពុជា ។



អាណានិគម នូវការប្តូររូបីយវត្ថុ ដែលមិនបានសម្រេចសោះនៅក្នុងការចរចានាពេលអនាគតជាយថាហេតុនោះ ។

## សេចក្តីសន្និដ្ឋានទូទៅ

តាមសន្ធិសញ្ញាចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៨៦៣ ប្រទេសកម្ពុជា ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមអាណាព្យាបាលនៃសាធារណរដ្ឋបារាំង ដែលត្រូវទទួលបន្ទុកថែរក្សាបូរណភាពទឹកដី នៃព្រះរាជាណាចក្រដែលត្រូវបានការពារ ។ ការធានានេះ ត្រូវបានពង្រឹងដោយការសន្យាយល់ព្រមដោយប្រទេសបារាំង នៅក្នុងសន្ធិសញ្ញាបារាំងសៀមចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៨៦៧ "ដោយមិនត្រូវដណ្តើមយកព្រះរាជាណាចក្រនេះ (ប្រទេសកម្ពុជា)... ដើម្បីបញ្ចូលទៅក្នុងការកាន់កាប់របស់ខ្លួននៅកូសាំងស៊ីនទេ" ។

ដូច្នេះការគង់វង់មានជីវិត និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែបានការពារ ដោយកាតព្វកិច្ចពីរនេះ ពីប្រទេសបារាំង គឺ :

- កាតព្វកិច្ចជាវិជ្ជមាន ដែលត្រូវតែធ្វើ ដើម្បីការពារសិទ្ធិរបស់ប្រទេសដែលត្រូវការពារ ។

- កាតព្វកិច្ចជាអវិជ្ជមាន ដោយមិនត្រូវបញ្ចូលជាឧបសម្ព័ន្ធ ឬក៏ដកហូតយកទៅធ្វើជាផលប្រយោជន៍របស់ខ្លួន នូវផ្នែកទឹកដីនៃប្រទេសកម្ពុជាឡើយ ។

នៅក្នុងឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាដណ្តើមបានមកវិញ នូវអធិបតេយ្យភាពនិងឯករាជ្យទាំងស្រុងរបស់ខ្លួន ។

តើសម្រាប់ប្រទេសកម្ពុជា មរតកទឹកដី នៅក្នុងសម័យអាណាព្យាបាលមានលក្ខណៈយ៉ាងណាដែរ ?

នៅទិសខាងលិច ដែលសភាពការណ៍ ត្រូវបានធ្វើឲ្យមានស្ថិរភាព ដោយគតិយុត្តតាមសន្ធិសញ្ញាអន្តរជាតិនោះ សារសំខាន់នៃច្បាប់របស់ប្រទេសកម្ពុជាត្រូវបានការពារហើយអំណាចរបស់អ្នកការពារបានបំពេញនៅក្នុងកាតព្វកិច្ចរួមរបស់ខ្លួនដោយធានាឲ្យមានការវិលត្រឡប់មកវិញនៅក្រោមអធិបតេយ្យភាពរបស់ខ្មែរ

នូវខេត្តទាំងឡាយដែលសៀមបានផ្តាច់យកដោយមិនគិតរវល់ដល់ច្បាប់អ្វីនោះ ។

ប៉ុន្តែនៅទិសខាងកើត ទិសខាងត្បូង (និងផ្នែកនៃទិសខាងជើងផងដែរ) សភាពការណ៍មានលក្ខណៈខុសគ្នាយ៉ាងច្រើន ។

នៅពាសពេញព្រះរាជណាចក្រ ទឹកដីបានរួមតូចទៅៗ អាជ្ញាធរកម្ពុជាចេះតែថយក្រោយនៅចំពោះមុខការទន្ទ្រានយករបស់ពួកអណ្ណាម ។ តំបន់ព្រៃឈើដ៏ធំទូលាយដែលមានប្រជាជនខ្មែររស់នៅ ត្រូវបានដកហូត ដើម្បីជាគុណប្រយោជន៍នៃអាណាចក្រអណ្ណាម និងអាណានិគមកូសាំងស៊ីន ដែលសាធារណរដ្ឋវៀតណាម ក្នុងពេលបច្ចុប្បន្ននេះជាអ្នកទទួលមរតកដោយផ្ទាល់ ។ ប្រទេសកម្ពុជា ក៏បានបាត់បង់ទឹកដីផងដែរ ជាមួយប្រទេសលាវ ។

តារាងលេខ ១ ដែលភ្ជាប់ជាមួយខាងក្រោយនេះ បានលើកឡើងនូវតុល្យការនៃការបាត់បង់ដែលប្រទេសកម្ពុជាបានទទួលរង និងសង្ខេបនូវល័ក្ខខ័ណ្ឌទាំងឡាយដែលនៅក្នុងនោះ លក្ខខណ្ឌទាំងនេះត្រូវបានធ្វើអន្តរាគមន៍ ។

នៅលើមូលដ្ឋាននៃលទ្ធផល នៃការស្រាវជ្រាវរបស់យើង យើងបានពង្រីកនូវទឡ្ហីកម្មទ្វេ ។

ទឡ្ហីកម្មនៃលំដាប់ទូទៅដែលមានទំនោរ ដើម្បីបង្កើតលក្ខណៈរដ្ឋបាលសុទ្ធសាធនៃព្រំដែន នៅក្នុងសភាពទូទៅរបស់ខ្លួន និងដែលស្ថិតនៅក្នុងកម្រិតនៃគោលការណ៍ទាំងឡាយនៃច្បាប់អន្តរជាតិជាសំខាន់ ។

ទឡ្ហីកម្មទី២ ក្នុងលក្ខណៈនៃភាគខ្លះនិងមានការប្រតិបត្តិបំផុត ដែលតម្រង់ទិសដៅទៅរកផ្នែកព្រំដែនខ្លះ ដែលសកម្មភាពរបស់អំណាចអ្នកការពារ បានវិភាគដូចជាការបញ្ចូលជាឧបសម្ព័ន្ធ ដោយសុទ្ធសាធនិងងាយស្រួល ។

**I - លក្ខណៈរដ្ឋបាល នៃព្រំដែន**

មុនដំបូង មានការលេចឡើងថា ការកាត់យកទឹកដី (ដែលនៅក្នុងនោះយើងបានបង្កើតច្បាប់នៃប្រទេសកម្ពុជា) ដែលគាំទ្រដោយព្រះរាជាណាចក្រនោះជាលទ្ធផលនៃប្រតិបត្តិការខាងសម្ភារៈ និងខាងគតិយុត្តដែលមានលក្ខណៈទូទៅបំផុត ដែលប្រទេសបារាំងជូនកាលបានដើរតួ ជាឯកសិទ្ធិពិសេស ជូនកាលដើរតួគ្របសង្កត់ ។ មានការ



លេចឡើងយ៉ាងច្បាស់លាស់ផងដែរថា ពួកគេមិនបានភ្លេចក្នុងការលើកឡើងនូវបាតុកម្មតវ៉ាជាច្រើនរបស់កម្ពុជានោះទេ ។

ប៉ុន្តែយើងមិនបានទទួលស្គាល់ទេថា នៅក្នុងឱកាសនៃការបញ្ចេញឲ្យឃើញនូវទម្រង់នៃការយល់ព្រមពិតប្រាកដរបស់ខ្មែរ ហាក់ដូចជាការព្រមព្រៀងទ្វេភាគីមួយ ។

នៅពេលនោះ បញ្ហាទីមួយ ដែលគេហៅយើងឲ្យពិភាក្សានោះ គឺមានដូចតទៅនេះ គឺតើនៅក្នុងវិធានការណាដែលការយល់ព្រមរបស់ខ្មែរនៅពេលដែលបានកើតមានមិនបានផ្តល់នូវតម្លៃគតិយុត្តអន្តរជាតិចំពោះខ្សែបន្ទាត់ព្រំដែនដែលបានបង្កើតឡើងនោះ ?

**១ – អត្ថន័យនៃច្បាប់ដែលកើតចេញមកពីអាជ្ញាធរកម្ពុជា**

**ក –** លទ្ធភាពនៃការព្រមព្រៀង ដើម្បីបង្កើតនូវព្រំដែនអន្តរជាតិមួយ

វាហាក់ដូចជាងាយស្រួលណាស់ ដើម្បីបិទបាំងយើងនៅខាងក្រោយទឡ្ហីករណ៍នៃការបោះបង់ចោល ដោយប្រទេសកម្ពុជានូវសមត្ថកិច្ចអន្តរជាតិទាំងឡាយរបស់ខ្លួនទៅក្នុងដៃរបស់បារាំងចាប់ពីឆ្នាំ ១៨៦៣ ដើម្បីបដិសេធចំពោះប្រទេសកម្ពុជាដែលអាចធ្វើការសន្យាគួរយកជាការបានចំពោះប្រទេសបារាំង ។ ផ្ទុយទៅវិញ យើងយល់ថា ប្រទេសកម្ពុជា មិនដែលបានបាត់បង់បុគ្គលិកលក្ខណៈរបស់ខ្លួនជារដ្ឋនោះឡើយ និងអាចយកជាការបាននៅចំពោះភ្នែកនៃច្បាប់អន្តរជាតិ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងឡាយជាមួយប្រទេសបារាំង ។ ជាពិសេសប្រទេសកម្ពុជាអាចយល់ព្រមបោះបង់អធិបតេយ្យភាពទឹកដី សូម្បីតែដើម្បីជាគុណប្រយោជន៍របស់កូសាំងស៊ីនបារាំង ដែលជាអាណានិគមរបស់បារាំងក៏ដោយ (ពិតហើយ គឺនៅក្រោមល័ក្ខខ័ណ្ឌនៃការទាក់ទងគ្នាអំពីការទាមទារខាងគតិយុត្ត នៃសន្ធិសញ្ញា បារាំង–សៀម នៅឆ្នាំ ១៨៦៧ ) ។

**ខ –** ល័ក្ខខ័ណ្ឌទាំងឡាយ

ប៉ុន្តែសុពលភាពអន្តរជាតិ នៃការបោះបង់ទាំងនេះ នៅតែស្ថិតនៅមានល័ក្ខខ័ណ្ឌដោយអត្ថិភាពនៃការព្រមព្រៀងមួយ ដែលគ្មានអ្វីក្រៅតែពីការសម្តែងចេញជាផ្លូវការ និងងាយស្រួលនោះឡើយ ដែលតំណាងឲ្យកិច្ចព្រមព្រៀងសេរី មានសម្បជញ្ញៈ និងមានទិន្នន័យនៅក្នុងល័ក្ខខ័ណ្ឌទាំងឡាយ ដូចដែលទុកឲ្យលេចឡើងនូវសមភាពនៃសភាពការណ៍រវាងដៃគូទាំងពីរ ចំពោះអ្វីដែលទាក់ទងទៅនឹងការធ្វើពលីកម្មទៅវិញ

ទៅមកដែលពួកគេបានយល់ព្រមនោះ ។

**គ** – ការសម្តែងចេញនូវកិច្ចព្រមព្រៀងរបស់កម្ពុជា ឆ្លើយតបទៅនឹងការទាមទារទាំងនេះដែរឬទេ ?

យើងបានរកឃើញនៅចំពោះមុខ នូវឯកសារបី ដែលស្ថិតនៅក្នុងលំដាប់នៃកាលប្បវត្តិ គឺការយល់ព្រមដែលប្រធានដោយព្រះករុណា ព្រះនរោត្តម ចំពោះសេចក្តីសម្រេចរបស់ទេសាភិបាល កូសាំងស៊ីន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៨៧០ ។

– អនុសញ្ញា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៧៣ ដែលបានសម្រេចឡើងរវាងព្រះករុណានរោត្តម និងទេសាភិបាលកូសាំងស៊ីន ។

– ព្រះរាជប្រកាសលេខ ២៥ ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ១៩១៤ ។

តើនៅក្នុងវិធានការណាដែលច្បាប់ទាំងនេះអាចភ្ជាប់ប្រទេសកម្ពុជានៅលើផ្លូវអន្តរជាតិបាន ?

**១** – ការយល់ព្រមនៃសេចក្តីសម្រេចចុះថ្ងៃទី៩ ខែកក្កដា មិនអាចមានតម្លៃគតិយុត្តជាងសេចក្តីសម្រេច ដែលបានយល់ព្រមដោយខ្លួនឯងនោះឡើយ ។ ប៉ុន្តែយើងបានដឹងហើយថា សុពលភាពនៃសេចក្តីសម្រេចនេះ អាចត្រូវបានជំទាស់នៅក្នុងនាមជាច្បាប់អន្តរជាតិ ពីព្រោះ :

**ក/–** វាសម្រាប់លទ្ធផលនៃការគាបសង្កត់ខ្លះ ការគម្រាមកំហែង និងសេចក្តីសម្រេចដោយរំលោភ ជាឯកតោភាគី ដោយស្នងការបារាំង ។

**ខ/–** វាបានវាយតម្លៃដោយខុសឆ្គងនូវទិដ្ឋភាពខ្លះនៃការបែងចែកទឹកដី ការរៀបចំនូវការប្តូរ ហើយហេតុដូច្នេះវាបានធ្វើឲ្យមានការសៅហ្មងមានការខុសឆ្គងនៅលើមូលហេតុទាំងឡាយ ។

**គ/–** វាបានប្រព្រឹត្តទៅដោយភាពស្ងៀមស្ងាត់នូវការបញ្ចូលជាឧបសម្ព័ន្ធខ្លះទៅឲ្យកូសាំងស៊ីន ដែលជួយទៅនឹងសន្ធិសញ្ញាបារាំង សៀម ឆ្នាំ១៨៦៧ ដែលបានធ្វើឲ្យសម្រេចឡើង ដោយមិនបាច់បែងឲ្យច្បាស់នូវគំនូសព្រំដែន ដែលគេបានទទួលស្គាល់ (តំបន់ចុង–បាដែន) នោះឡើយ ។

**ឃ/–** វាមានលក្ខណៈមិនច្បាស់លាស់ និងមិនបានគ្រោងទុកនូវនីតិវិធីជាទ្វេភាគីណាមួយឡើយ ដើម្បីធ្វើការកំរិតជាស្ថាពរនូវផ្នែកនៃព្រំដែន ដែលការកំណត់ព្រំដែនលើកទី១ខុសច្បាប់ត្រូវបានទុកជាមោឃៈ ហើយនឹងត្រូវបានកំណត់ជាបន្ទាប់មកទៀតក្នុងរបៀបជាឯកតោភាគី និងខុសច្បាប់ដោយអាជ្ញាធរកូសាំងស៊ីនទៅលើការអះអាងរបស់អណ្ណាម (ផ្នែកចាប់ពីបង្គោលលេខ១៧) ។



**២** – អនុសញ្ញា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៧៣ បានបញ្ចូលនៅក្នុងក្របខ័ណ្ឌទូទៅនៃអនុសញ្ញាទាំងនេះ ត្រូវបានផ្តាច់យកចេញដោយការគាបសង្កត់យ៉ាងឃោរឃៅចំពោះព្រះមហាក្សត្រកម្ពុជា ហើយដែលត្រូវរកឃើញនូវលទ្ធផលរបស់ពួកគេ នៅក្នុងអនុសញ្ញាដ៏ល្បីល្បាញ thomson ឆ្នាំ ១៨៨៤ ដែលត្រូវបានបង្កើតឡើងចំពោះវិធីនៃការទទួលបានរបស់ខ្លួននូវប្រភេទដែលមានចរិតលក្ខណៈបំផុត ។

– អនុសញ្ញានេះមានកម្មវត្ថុពីរ : វាបានបញ្ជាក់អះអាងអំពីគំនូសព្រំដែន ដែលរៀបចំឡើងនៅក្នុងក្របខ័ណ្ឌនៃសេចក្តីសម្រេច ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៨៧០ (បង្គោលពីលេខមួយ ទៅលេខ ៦០ ) ។

វាបានគ្រោងទុកនូវគំនូសព្រំដែន ដែលត្រូវរៀបចំបង្គោល ៦០ ទៅសមុទ្រ ។

– នៅក្នុងកម្មវត្ថុទីមួយរបស់ខ្លួន អនុសញ្ញា មិនអាចផ្តល់តម្លៃអន្តរជាតិ ចំពោះព្រំដែន ដែលបានធ្វើសេចក្តីសម្រេចចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៨៧០ ខ្លួនឯងនោះទេ ។ ព្រោះថា :

**ក/–** វាតម្រង់ទិសដៅទៅរកការប្រតិបត្តិដែលយើងអាចឃើញថា វិធីនៃការបំពេញ បានផ្តល់នូវសុពលភាពគួរឲ្យសង្ស័យ ។

ខ/– ដោយបានផ្តល់នូវសមតា នៃកម្លាំងនៅចំពោះមុខ និងវិធីនៃសេចក្តីសន្និដ្ឋាននៃអនុសញ្ញាបារាំង–ខ្មែរ ជាទូទៅនោះ វាមិនបានជំណាងឲ្យអ្វីសោះឡើយ ចំពោះការប្រតិបត្តិការផ្តល់សច្ចាប័ន ដោយសេរីមួយដែលប្រឡាក់ដោយភាពមិនប្រក្រតី ។

– នៅក្នុងកម្មវត្ថុទី២របស់ខ្លួន វាបានដាក់នូវការណែនាំជាទូទៅដែលបានធ្វើពលិកម្ម នូវច្បាប់ទាំងឡាយរបស់ប្រទេសកម្ពុជា ដែលបានទាមទារកាលពីលើកមុនដោយព្រះករុណា ព្រះនរោត្តម និងចំពោះចំណុចខ្លះដែលទទួលស្គាល់ដោយមហាអំណាចជាអ្នកការពារ តាមរយៈសំឡេង នៃតំណាងរបស់ខ្លួន នៅកូសាំងស៊ីន គឺលោក

ឧត្តមនាវី La Grandière ។

ប៉ុន្តែការណែនាំជាទូទៅនេះ នឹងត្រូវបានអនុវត្តក្នុងរបៀបជាឯកតោភាគី ដោយអាជ្ញាធរបារាំងនៅកូសាំងស៊ីន និងការធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសកម្ពុជា ជាយថាហេតុ ។ ហើយម្យ៉ាងទៀត នៅលើផ្នែកខ្លះ គំនូសព្រំដែនដែលមិនអនុគ្រោះនេះ ថែមទាំងមិនត្រូវបានគោរពដោយអាជ្ញាធរបារាំងទៀតផង និងត្រូវបានកែប្រែដោយរំលោភ និងជាឯកតោភាគី ដោយសុទ្ធសាធ ។

ដូច្នេះយើងអាចសន្និដ្ឋាន ដោយត្រឹមត្រូវតាមច្បាប់ដូចតទៅ :

- ថា អនុសញ្ញាចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ១៨៧៣ មិនបានតំណាងឲ្យប្រទេសកម្ពុជា នូវការសន្យាអន្តរជាតិមួយ ដែលមានតម្លៃនៅក្នុងគោលការណ៍របស់ខ្លួននោះឡើយ។

- ថា កិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលផ្តល់ឲ្យនេះមិនមានតម្លៃក្នុងការឲ្យសច្ចាប័ន ចំពោះវិធានការប្រតិបត្តិទាំងឡាយ ដែលបានប្រកាន់យកនិងដែលមិនអនុគ្រោះទាល់តែសោះចំពោះប្រទេសកម្ពុជា ។

**៣ –** ព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ ។ ព្រះរាជប្រកាសនេះត្រូវបានបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃសេចក្តីសម្រេចប្រកបដោយគតិយុត្តជាតិទាំងនេះ ដែលត្រូវបានតាក់តែងដោយក្រុមលោករ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា ហើយចំពោះឋានៈនេះ វាពុំដែលមានន័យអ្វីឡើយ ដែលធ្វើជាភស្តុតាង នៃការយល់ព្រមមួយរបស់កម្ពុជា ដែលអាចយកជាការបាននោះ ។

ប៉ុន្តែដោយហេតុការណ៍នៃព្រះរាជប្រកាស ឆ្នាំ ១៩១៤ គ្មានទាក់ទងនៅក្នុងវិធានការដែលគេចង់បានឲ្យមានការបញ្ជាក់ថា ជាព្រំដែនអន្តរជាតិមួយនោះឡើយ ដែលមានមូលហេតុទុកជាមោឃៈ និងមានលក្ខណៈដោយឡែក និងដែលបានសង្កត់នូវលក្ខណៈបំភ័ន្តចំពោះការយល់ព្រមរបស់កម្ពុជានោះ ។

***ក/*** មុនដំបូង ព្រះរាជប្រកាសនេះ មានភាពផ្ទុយគ្នា នៅផ្នែកក្នុងដែលបានបកស្រាយអំពីការព្រួយបារម្ភរបស់អ្នកតាក់តែងបារាំងរបស់ខ្លួន គឺប្រតិបត្តិការដូចគ្នា នេះត្រូវបានវាយតម្លៃផ្ទុយគ្នា ស្តីអំពីការសង និងការប្តូរគ្នា (ការសង មិនមែនការប្រគល់ឲ្យ) ។



**ខ/ វាបានធ្វើឲ្យមានការសៅហ្មងដោយការភ័ន្តច្រឡំ៣ដង ស្តីអំពីមូលហេតុ :**

- ចំពោះចំរៀកដី រវាងខេត្តកំពត និងខេត្តហាទៀន ការងារស្រាវជ្រាវត្រូវបានធ្វើឡើងដោយពួកបារាំងផ្ទាល់ បានបង្ហាញថា វាពុំដែលមានការផ្លាស់ទីកន្លែងនៃព្រំដែនឡើយ ហើយហេតុដូច្នេះវាពុំមានអ្វីដែលត្រូវសងនោះទេ ។

- ចំពោះ "ការប្រគល់ឲ្យក្នុងលក្ខណៈជាការប្តូរ" នូវបរិព័ទ្ធភូមិ Cai-Cay រវាងតៃនិញ និងព្រៃវែង មានទឹកដីកម្ពុជាមួយ ដែលមិនដែលត្រូវបានដណ្តើមយកធ្វើជាអធិបតេយ្យភាព របស់កម្ពុជាឡើយ ។ ដូច្នេះវាមិនអាចជាការប្រគល់ឲ្យនោះឡើយ ។

- និយាយពីស្រុកឡុកនិញ និងភឿក ឡេ គឺជាការខុសឆ្គងដែលស្រុកទាំងនេះត្រូវបានវិនិច្ឆ័យថា (ដែលជាមូលហេតុនៃការកំណត់ទៅឲ្យកូសាំងស៊ីន) "ពួកកុលសម្ព័ន្ធដែលពីមុនបានឯករាជ្យនោះបានរស់នៅ " ។ ការពិតស្រុកទាំងពីរនេះត្រូវបានរស់នៅជានិច្ចកាល ដោយប្រជាជនកម្ពុជា និងគ្រប់គ្រងដោយរបៀបធូររលុងបន្តិរ ប៉ុន្តែគឺដោយអាជ្ញាធរកម្ពុជា ដោយមិនអាចប្រកែកបានឡើយ ។

**គ/–** នៅទីបញ្ចប់ព្រះរាជប្រកាសនេះ គឺគ្មានតម្លៃអ្វីសោះ ចំពោះការឲ្យសច្ចាប័ន គឺលទ្ធផលនៃកលល្បិច បោកប្រាស់ (ការបញ្ជាក់អះអាងដោយភូតកុហក ស្តីពីការផ្លាស់ប្តូរខ្សែទូរស័ព្ទនៅខាងផ្នែកហាទៀន) និងជាសកម្មភាពរំលោភមួយដែលបានសម្តែងចេញ ការបញ្ចូលជាឧបសម្ព័ន្ធ ដោយទេសាភិបាលកូសាំងស៊ីននូវទឹកដី ឡុកនិញ និង Phuoc Le (ភឿក ឡេ) ។

ដូច្នេះគេអាចនិយាយបានថា ពុំមានសកម្មភាពណាមួយរបស់រដ្ឋាភិបាលកម្ពុជា ដែលអាចធ្វើការវិភាគបានថា ដូចជាការព្រមទទួលយកមួយដោយរដ្ឋាភិបាលកម្ពុជា នូវទឹកដីបច្ចុប្បន្នក្នុងឋានៈជាទឹកដីអន្តរជាតិ ។

**ឃ/– តម្លៃរដ្ឋបាល សុទ្ធសាធនៃសកម្មភាពគតិយុត្តកម្ពុជា**

បើសិនជាគេចង់កំណត់នូវតម្លៃអន្តរជាតិទៅលើការសម្តែងចេញពាយ៉ាងដែលយើងនឹងរំលឹកអំពីការយល់ព្រមរបស់ខ្មែរទៅលើសេចក្តីសម្រេចទាំងឡាយរបស់មហាអំណាចអ្នកការពារនោះគេបាននាំទៅដល់ការធ្វើសន្និដ្ឋាន ដោយច្បាស់លាស់អំពីមោឃៈភាពរបស់វា ។

តាមការពិត បើសិនជាសេចក្តីសម្រេចទាំងឡាយរបស់ព្រះមហាក្សត្រកម្ពុជា មានតម្លៃខ្លះ និងអាចទទួលនូវការអនុវត្តមួយនោះ គឺក្នុងនាមនៃការសម្តែងចេញនូវការយល់ព្រមមួយរបស់ខ្មែរ ចំពោះនយោបាយគ្រប់គ្រងរបស់មហាអំណាចអាណានិគមនៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធឥណ្ឌូចិន ។ ពេលនោះសេចក្តីសម្រេចទាំងនេះ គឺតំណាងឲ្យការធ្វើឲ្យត្រឹមត្រូវតាមច្បាប់ធម្មតាចំពោះផ្នែកនៃលំដាប់គតិយុត្តផ្ទៃក្នុងរបស់ខ្មែរនូវវិធានការនៃលំដាប់រដ្ឋបាលផ្តាច់មុខ ដែលលក្ខខ័ណ្ឌទាំងឡាយនៃសុពលភាពមានការខុសគ្នាយ៉ាងខ្លាំង និងមិនសូវតឹងរ៉ឹង ដូចសេចក្តីសម្រេចដែលទាក់ទងទៅនឹងច្បាប់អន្តរជាតិ ពីព្រោះថា សេចក្តីសម្រេចនេះមិនបានចោទប្រកាន់ចំពោះគោលការណ៍ដូចគ្នានេះទេ ។

លក្ខណៈរដ្ឋបាលសុទ្ធសាធ នៃការយល់ព្រមរបស់ខ្មែរនេះត្រូវបានគូសបញ្ជាក់ដោយអ្នករដ្ឋការបារាំងខ្លះ ហើយយើងគ្រាន់តែធ្វើការរំលឹកចំពោះការវិភាគអំពីព្រះរាជអាកប្បកិរិយា ដែលផ្តល់ដោយអគ្គទេសាភិបាល P. Beau នៅក្នុងឆ្នាំ ១៩០៥ ចំពោះនយោបាយ ទឹកដី បារាំង នៅប្រទេសលាវ ហើយវាហាក់ដូចជាអាចអនុវត្តបានក្នុងរបៀបជាទូទៅមួយ ចំពោះព្រះរាជអាកប្បកិរិយា នៅក្នុងកាលៈទេសៈទាំងនេះ គឺព្រះមហាក្សត្រ មានបំណងដើម្បីសុំឲ្យមានការជួយ អំពីការរៀបចំរដ្ឋបាលរបស់ប្រទេសជិតខាង និងបានចាត់ទុកវិធានការនេះ ថាជាលក្ខណៈបណ្តោះអាសន្នជាសារវន្ត" ។

លក្ខណៈបណ្តោះអាសន្នសុទ្ធសាធ ការយល់ព្រមទាំងឡាយរបស់ខ្មែរ ចំពោះគំនូសព្រំដែន ដែលរៀបចំឡើងដោយប្រទេសបារាំងនៅក្នុងក្របខ័ណ្ឌនៃសហព័ន្ធឥណ្ឌូចិន ភាពអវត្តមាននូវន័យចំពោះបញ្ហានៃអធិបតីភាពទឹកដីបានលេចឡើងជាភស្តុតាង បើសិនជាគេដាក់ឲ្យស្របគ្នា នូវជំហរមិនចេះប្រែប្រួលរបស់ប្រទេសកម្ពុជា ចំពោះកូសាំងស៊ីន ឬក៏ត្រឹមត្រូវបំផុតនោះចំពោះអ្វីដែលយើងបន្តកំណត់ដោយពាក្យខ្មែរនៅកម្ពុជាក្រោម ។

*ពីឆ្នាំ ១៨៥៦ កាលបរិច្ឆេទ នៃការតំរាមកំហែងការពារសេចក្តីសម្រេចរបស់ព្រះមហាក្សត្រអង្គឌួង ចំពោះអធិរាជ ណាប៉ូឡេអុងទី III មកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមិនដែលឈប់សោះឡើយ ក្នុងការទាមទារកូសាំងស៊ីន ដែលជាទឹកដីរបស់ខ្មែរ ។*[១] ។



ចំពោះហេតុការណ៍នេះខ្សែព្រំដែន នៅគំនូសដែលអាជ្ញាធរខ្មែរ បានយល់ព្រមដោះស្រាយដោយចាំបាច់នៅចំពោះផ្នែករបស់អាជ្ញាធរទាំងនេះ នៅចំកណ្តាលនៃទឹកដី ជាតិ ។ ដូច្នេះវាគ្រាន់តែជាការកំណត់ព្រំដែនរដ្ឋបាល ដោយគ្មានឧបទ្ទវហេតុនៅលើបញ្ហានៃអធិបតេយ្យភាពនោះឡើយ ។

ហេតុដូច្នេះ ព្រំដែនបច្ចុប្បន្ន មិនអាចសង្កត់ទៅលើការទាមទារការព្រមទទួលរបស់អាជ្ញាធរកម្ពុជានោះឡើយ ។ តើគេអាចរកឃើញនូវគ្រឹះគតិយុត្តដែលមានតម្លៃបំផុត នៅក្នុងសកម្មភាពទាំងឡាយរបស់អាជ្ញាធរបារាំងបានដែរឬទេ ?

## ២ – ន័យគតិយុត្តនៃច្បាប់របស់អាជ្ញាធរបារាំង

ច្បាប់របស់អាជ្ញាធរបារាំងមានច្រើនណាស់ ។ វាបានសម្តែងចេញជាផ្លូវការនូវអំណាចនៃសេចក្តីសម្រេចពិតប្រាដក ។

ជួនកាលបើតាមបែបបទផ្សេងៗដែលបន្ថែមឡើង នោះវាជាការយល់ព្រមរបស់ខ្មែរ ដែលយើងបានថ្លឹងថ្លែងអំពីសារៈសំខាន់ជួនកាលវាតំណាងដូចជាឯកតោភាគីដោយសុទ្ធសាធ ។

### ក – នៅក្នុងវិធានការណាដែលប្រទេសបារាំងអាចរៀបចំនូវព្រំដែនអន្តរជាតិមួយគួរយកជាការបាន និងអាចជំទាស់ចំពោះប្រទេសនៅក្នុងការឧបត្ថម្ភការពារ

*(១) / ដំណើរការតឹតគូររបស់ព្រះមហាក្សត្រ នរោត្តម នៅអមលោកឧត្តមនាវី de la Grandière ចំពោះខេត្តហាទៀន និង ប៉ូវជុក នៅឆ្នាំ ១៨៦៤ ។*
*– សេចក្តីប្រកាសចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៤៥ របស់ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហនុ ។*
*– ព្រះរាជសារលិខិត ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៤៨ របស់ព្រះករុណា ព្រះមហាក្សត្រ នរោត្តម សីហនុ ផ្ញើទៅជូនស្ននការជាន់ខ្ពស់នៃសាធារណរដ្ឋបារាំង ។*
*– សេចក្តីប្រកាសរបស់ព្រះករុណា នរោត្តម សីហនុ នៅក្នុងអំឡុងពេលចុះហត្ថលេខាលើសន្ធិសញ្ញាបារាំង – ខ្មែរ ចុះថ្ងៃទី៨ ខែវិច្ឆិកា ១៩៤៩ ។*
*– សេចក្តីរបស់ឯកឧត្តម សឺន សាន ផ្ញើទៅស្នងការជាន់ខ្ពស់នៃសហភាពបារាំង (ថ្ងៃទី២៩ និង៣០ ខែវិច្ឆិកា ឆ្នាំ១៩៥១) ។*
*– សេចក្តីតវ៉ារបស់ឯកឧត្តម ទេព ផន ផ្ញើទៅសន្និសីទទីក្រុងហ្សឺណែវចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៥៤ ។ នៅលើចំណុចទាំងនេះគេនឹងអាចរកសេចក្តីពន្យល់របស់ ហ៊ួ នឹម សភាពការណ៍គតិយុត្តរបស់កម្ពុជាក្រោម (កូសាំងស៊ីនក្រោម) ។ ស្នារតីសម្រាប់ D.E.S នៃច្បាប់សាធារណៈ ។ ភ្នំពេញ ១៩៦៣ ។*

**ក/–** ចំពោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសមួយ នៅខាងក្រៅសហភាពឥណ្ឌូចិន តើនេះមិនធ្វើឲ្យមានការសង្ស័យទេឬ ? ប្រទេសបារាំងមហាអំណាចអ្នកការពារដែលកាន់កាប់សមត្ថកិច្ចអន្តរជាតិរបស់ព្រះរាជាណាចក្រដែលត្រូវការពារនោះនិងអាចសន្និដ្ឋាន ដែលគួរយកជាការបានទូវកិច្ចព្រមព្រៀងទាំងឡាយដែលមានសារៈសំខាន់ចំពោះទឹកដី គឺជាការកំណត់ព្រំដែនក្នុងលក្ខណៈដែលមានការប្រកាសការពង្រីក ឬក៏ការបោះបង់ ។ ប្រតិបត្តិការទាំងនេះ នៅពេលនោះបំពាក់ទូវរូបភាពជាឧបករណ៍សន្ធត់នៃច្បាប់អន្តរជាតិ ។

**ខ/–** ចំពោះព្រំដែនខាងក្នុងនៅឥណ្ឌូចិនបារាំង គេត្រូវតែធ្វើឲ្យបានច្បាស់លាស់នូវសកម្មភាពទាំងឡាយ ដែលមានទំនោរទៅរកការកំណត់ព្រំដែនមិនច្បាស់លាស់នៅលើមូលដ្ឋាននៃច្បាប់របស់ភាគីនានា និងសកម្មភាពទាំងឡាយដែលមានទំនោរដើម្បីបំពេញនូវការប្តូរទឹកដី ។

**១/–** ការកំណត់ព្រំដែននៅលើមូលដ្ឋាន នៃច្បាប់របស់ភាគីនានា គឺតែងតែអាចធ្វើបានដោយពិតប្រាកដ នៅក្នុងលក្ខខ័ណ្ឌដែលការកំណត់នេះបានប្រកាន់យកនូវច្បាប់ទាំងនេះដោយពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋាននៃការងារដែលត្រូវបំពេញ ។

**២/–** ការប្តូរទឹកដីអំពាវនាវនៅក្រោមភាពខុសគ្នាមួយ : **ក)** នៅក្នុងរបាយការណ៍ទាំងឡាយរបស់ប្រទេសកម្ពុជា និងរបស់កូសាំងស៊ីន បារាំង ប្រទេសបារាំងបានប៉ះទង្គិចទៅនឹងការទាមទាររបស់អនុសញ្ញាបារាំងសៀម ឆ្នាំ ១៨៦៧ ដែលបានហាមឃាត់នូវរាល់ការបញ្ចូលជាឧបសម្ព័ន្ធនៃប្រទេសកម្ពុជា ដោយប្រទេសបារាំង ។ **ខ)** នៅក្នុងរបាយការណ៍ជាមួយបណ្តាប្រទេសផ្សេងទៀត នៅក្នុងសហព័ន្ធ ការប្តូរនៃអធិបតីភាពទឹកដី អាចធ្វើទៅបានលុះត្រាតែឆ្លើយតបទៅនឹងលក្ខខ័ណ្ឌមួយនៃលក្ខខ័ណ្ឌទាំងពីរដូចតទៅនេះ :

- ត្រូវបានឲ្យសច្ចាប័នដោយការយល់ព្រមមួយពីខ្មែរពិតប្រាកដ ។
- ត្រូវមានការកង្វល់ជាសំខាន់អំពីការការពារនូវផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់របស់ប្រទេស ដែលស្ថិតនៅក្រោមការការពារ ។

គេបានឃើញនូវការទាមទារនូវលក្ខខ័ណ្ឌមួយនៃលក្ខខ័ណ្ឌទាំងពីរនេះ ដោយ



ផ្លាស់គ្នាចំពោះព្រំដែនរវាងប្រទេសកម្ពុជា និងកូសាំងស៊ីន បើសិនជាគេវាយតម្លៃថាសន្ធិសញ្ញាបារាំងខ្មែរមិនបានធ្វើឲ្យកើតមាននូវច្បាប់ ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រទេសកម្ពុជានោះ ។

### ១ – តើប្រទេសបារាំងបានបង្កើតនូវព្រំដែនអន្តរជាតិមួយដែរឬទេ ?

**ក/–** លក្ខខ័ណ្ឌនៃការឲ្យសច្ចាប័នដោយសេរី ដែលយើងយល់ថា យើងបានបង្ហាញដោយទូលំទូលាយនោះ គឺមិនដែលបានជួបប្រទះទាល់តែសោះជួនកាលដោយហេតុថាអាជ្ញាធរកម្ពុជា មិនត្រូវបានគេពិគ្រោះយោបល់ជាមួយ ជួនកាលដោយហេតុថាកិច្ចព្រមព្រៀងដែលបានធ្វើឡើងគ្រាន់តែតំណាងឲ្យការព្រមទទួលនូវគំនូសព្រំដែនរដ្ឋបាលមួយ (វាបានសៅហ្មងដោយភាពមោឃៈ បើសិនជាគេចង់ធ្វើការវិភាគដោយដាច់ខាតដូចជាការយល់ព្រមចំពោះគំនូសព្រំដែនអន្តរជាតិមួយជាដើម) ។

**ខ/** តើលក្ខខ័ណ្ឌសំដៅការពារផលប្រយោជន៍របស់ប្រទេសដែលស្ថិតនៅក្រោមការការពារបានបំពេញហើយឬនៅ ?

យើងយល់ថា យើងបានសម្រេច ដើម្បីធ្វើឲ្យគេជឿថា គេមិនបានធ្វើអ្វីឡើយ ។ ការពិនិត្យពិច័យអំពីការបាត់បង់ទឹកដី ដែលមិនបានសងទូទាត់ដែលទទួលរងដោយប្រទេសកម្ពុជា នៅតាមបណ្តោយព្រំដែនដែលអាចឲ្យគេសន្មតនូវចម្លើយជាអវិជ្ជមានរួចទៅហើយ ។

ប៉ុន្តែការពិនិត្យ នូវលក្ខខ័ណ្ឌទាំងឡាយ ដែលនៅក្នុងនោះត្រូវបានធ្វើឲ្យសម្រេចនូវការបាត់ខាងកម្ពុជា ដែលយើងរំលឹកនៅក្នុងតារាងលេខ១២ នៅខាងក្រោយនេះ ដែលអាចបញ្ជាក់បាននូវការសន្មតនេះ ។

ខ្សែព្រំដែនដែលគូសដោយអាជ្ញាធរបារាំង មិនអាចត្រូវបានអះអាងប្រាប់លក្ខណៈថាជាព្រំដែនអន្តរជាតិ ដែលគួរយកជាការបានទេ ព្រោះថាព្រំដែននេះវាមិនអនុគ្រោះដល់ប្រទេសកម្ពុជាឡើយ ។ ដើម្បីធ្វើឲ្យបានសម្រេចនូវបំណងទាំងនេះ (?) អាជ្ញាធរអាណានិគមមិនបានរារែកក្នុងការពឹងផ្អែកលើការគម្រាមកំហែងនោះឡើយ (ចំពោះស្នងការកម្ពុជា) នៅពេលដែលការប្រតិបត្តិ មានរូបភាពជាទ្វេភាគីពិតប្រាកដនោះ ចំពោះការរំលោភ ចំពោះការលួចបន្លំនិងចំពោះការភូតកុហក នៅពេល

ដែលគេត្រូវបង្ហាញភស្តុតាងនៃការប្រតិបត្តិនៅចំពោះភ្នែករបស់អាជ្ញាធរជាន់ខ្ពស់ (អគ្គទេសាភិបាលឬរដ្ឋមន្ត្រីក្រសួងអាណានិគម) ។

ច្បាប់គតិយុត្តទាំងឡាយដែលបានកើតចេញពីអាកប្បកិរិយានេះ ជាទូទៅបានស្ថិតនៅលើមូលហេតុដែលពុំមានដែលភាន់ច្រឡំឬក៏ដួយពីអ្វីដែលបានបញ្ចេញឲ្យដឹងដោយកំហុសនៃការប្រាប់លក្ខណៈផ្តល់ឲ្យចំពោះកិច្ចប្រតិបត្តិការ ដែលបានបំពេញ (ការប្តូរដែលមិនបានសម្រេច លិខិតដែលមានការប្រកាស" ស្តីអំពីប្រតិបត្តិការប្តូរការបញ្ចូលដោយស្រមើស្រមៃ ការសងវិញដែលប្រឌិតឡើងនៅគ្រប់ផ្នែកនិងនៅក្នុងរបៀបបន្ទំ) ។

លិខិតបែបនេះមានលក្ខណៈជាមោឃៈដាច់ខាត (ហើយប្រហែលថែមទាំងពុំមានទៀតផង) និងថែមទាំងក្នុងក្របខ័ណ្ឌនៃគោលការណ៍ទូទៅនៃច្បាប់ផ្ទៃក្នុងរបស់ ប្រទេស ។

នៅចំពោះភ្នែកនៃច្បាប់អន្តរជាតិ គឺជាភាពទទេ ពីព្រោះថា ប្រទេសជាអ្នកការពារជាទូទៅតែងតែគិតគូរពីផលប្រយោជន៍របស់ខ្លួន ដែលជាការប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់ច្បាប់របស់ប្រទេស ដែលគេមានបេសកកម្ម ដើម្បីការពារ ។ ដូច្នេះវាអាចជាការប្រឆាំងចំពោះប្រទេសកម្ពុជា ដែលបានទទួលឯករាជ្យឡើងវិញ ។

***ក/*** ម្យ៉ាងទៀត បើសិនជាយើងចចេសចង់ស្គាល់នូវខ្លឹមសារអន្តរជាតិពិតប្រាកដចំពោះការសម្តែងចេញនូវការរំលោភបំពានទាំងនេះរបស់អាណានិគម វានឹងធ្លាក់នៅក្រោមការប៉ះទង្គិចនៃការទាមទារគតិយុត្ត និងសីលធម៌នៃការធ្វើអាណានិគមនិយមដែលបង្កបង្កើតបាននូវប្រភេទនៃអត្តសគតិយុត្តរួមនៃអតីតប្រទេសដែលស្ថិតនៅក្នុងចំណុះ ។

ប៉ុន្តែតើការប្រព្រឹត្តទាំងនេះរបស់ប្រទេសបារាំងមកស្រាយនូវជន្ទះនៃការបញ្ចូលជាឧបសម្ព័ន្ធ អាណានិគម នៅក្នុងន័យត្រឹមត្រូវដែរឬទេ ? ការអធិប្បាយរបស់យើងពីមុនអាចធ្វើឲ្យមានការសង្ស័យចំពោះរឿងនេះ ។

### គ – តើប្រទេសបារាំងមានបំណងរៀបចំនូវព្រំដែនអន្តរជាតិមួយដែរឬទេ ?

យើងរំលឹកឡើងវិញថា បញ្ហានេះមិនសូវត្រូវគ្នាទេ បើតាមសីលធម៌និងគតិយុត្ត



ជាមួយនឹងកាតព្វកិច្ចនៃការការពារ ដែលជាលទ្ធផលនៃសន្ធិសញ្ញាឆ្នាំ ១៨៦៣ ។

### ១ – សភាពការណ៍ផ្សេងៗ

***ក)*** ប៉ុន្តែនៅក្នុងករណីមួយ ដែលបានលេចឡើង នៅក្នុងគំនិតរបស់បារាំង : នៅក្នុងការ "បញ្ចូល" Darlac (ជាមួយនឹងភាពនៅក្នុងចំណុះកម្ពុជា) នៅក្រោមអធិបតីភាពអណ្ណាម ។ វាហាក់ដូចជាថា ប្រទេសបារាំងបានធ្វើឡើងនៅក្រោមការគាបសង្កត់នៃការទាមទាររបស់អណ្ណាម និងដោយធ្វើមិនដឹងមិនឮ ។ គេនៅកត់សម្គាល់នូវការរារែកខ្លះទៀត គណៈកម្មការ Richard ដោយបានបង្ហាញនូវភាពឥតប្រយោជន៍នៃច្បាប់របស់អណ្ណាម ស្តីអំពីទឹកដី និងប្រជាជនដែលតែងតែបានគេបចេញពីការដកហូតដីរបស់ខ្លួន ។ ប៉ុន្តែនោះវាបានបញ្ឈប់នូវការជំទាស់របស់គណៈកម្មការ ហើយគណៈកម្មការនេះ មិនបានជំរុញនូវការស៊ើបអង្កេតរបស់ខ្លួនរហូតដល់ការស្រាវជ្រាវអំពីអធិបតីពិតប្រាកដរបស់ប្រទេសកម្ពុជា ។

***ខ)*** ផ្ទុយទៅវិញ នៅក្នុងផ្នែកមួយទៀត អំណាចនៃអ្នកការពារបានគូសបញ្ជាក់យ៉ាងច្បាស់លាស់អំពីលក្ខណៈរដ្ឋបាលដាច់ខាតនូវសេចក្តីសម្រេចរបស់ខ្លួន ការបែងចែកកោះទាំងឡាយដែលធ្វើឡើងតាមសារាចររបស់លោក Brévié នៅឆ្នាំ ១៩៣៩ ។

***គ)*** រវាងករណីទាំងពីរ ដ៏ខ្លាំងបំផុតនេះ អត្ថបទផ្ទាល់មិនបានបញ្ចេញឲ្យដឹងឲ្យបានច្បាស់លាស់នូវគោលបំណងទាំងឡាយរបស់បារាំងនោះទេ ។

ប៉ុន្តែគេអាចសន្មត់ជាមុនដោយត្រឹមត្រូវតាមច្បាប់ថា អត្ថបទទាំងនោះ គឺមានលំដាប់រដ្ឋបាលជានិច្ច ។

នៅក្នុងករណីខ្លះការស្មានបានមាននៅក្នុងអត្ថបទទាំងឡាយ : ដូច្នេះនៅពេលដែលមានការភ្ជាប់ទៅប្រទេសលាវ ឬទៅកូសាំងស៊ីន នូវមួង (muong) ឬស្រុកទាំងឡាយរបស់កម្ពុជា (អនុក្រឹត្យរបស់អគ្គទេសាភិបាល ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ ១៩០៥ និងអនុក្រឹត្យរបស់អគ្គទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៨៩៣) ។

ប៉ុន្តែនៅក្នុងរបៀបជាទូទៅមួយ គេអាចទាញហេតុផលពីការធ្វើវិចារណកិច្ច នូវបរិបទប្រវត្តិសាស្ត្រ ។

### ២ – ការខ្វាយខ្វល់របស់អាណានិគម

តើគេយល់ព្រមទទួលថា មកដល់ចំណុចកំពូលរបស់អាណានិគមការប្តូរទឹកដីជាច្រើន នៅក្នុងប្រទេសដែលបានទទួលស្គាល់ដោយសហភាពឥណ្ឌូចិននោះ ត្រូវបានគ្របសង្កត់ ដោយគំនិតដែលគេបានគូសវាស ព្រំដែនអន្តរជាតិ រវាងអង្គភាពទាំងឡាយ ដោយរក្សាទុកនូវឧបនិស្ស័យ ចំពោះឯករាជ្យដែរឬទេ ? តើអ្នកគ្រប់គ្រងណាដែលអាចត្រូវបានញាំងដោយទស្សនវិស័យដែលធ្វើឲ្យផ្ទុះឡើងនូវអនាគតមួយនៃសហព័ន្ធ ? សូម្បីតែនៅក្នុងចំណោមអ្នកសង្កេតការណ៍ដែលសេរីបំផុតក៏ដោយក៏គេបានគិតដោយស្មោះត្រង់ដែរថា អាណាព្យាបាលនៃប្រទេសកម្ពុជាមានលក្ខន្តិកៈអន្តរ-ជាតិរបស់រដ្ឋ ដ៏ស៊ីជម្រៅនិងពិតប្រាកដមួយដែលបាននាំទៅរកការសន្មតិនូវតម្លៃពិសេសមួយ ចំពោះព្រំដែនដែលខ័ណ្ឌលំនៅដ្ឋាន នៃខេត្តទាំងឡាយ ដែលនៅត្រង់ព្រំប្រទល់កូសាំងស៊ីន ។

ចំពោះលោកអគ្គទេសាភិបាល ចំពោះរដ្ឋមន្ត្រី ចំពោះអ្នកអភិបាលទាំងឡាយ វាពុំមានបញ្ហានៃព្រំដែននោះឡើយ ប៉ុន្តែគ្រាន់តែមានក្តីកង្វល់អំពីការរៀបចំខាងរដ្ឋបាលតែប៉ុណ្ណោះ ។

បើសិនជា "ច្បាប់"ទាំងឡាយ របស់ប្រទេសជាសមាជិក ដែលជួនកាលបានដាក់នៅពីមុននោះ គឺស្ថិតនៅក្នុងវិធានការតែមួយគត់ ដែលប្រទេសទាំងនោះបានបម្រើនូវសេចក្តីសម្រេចនូវនយោបាយរដ្ឋបាលមួយដ៏ជាក់លាក់ ។ គំនូសព្រំដែនមិនបានបកស្រាយនូវសមតា នៃអធិបតេយ្យភាពទាំងពីរនោះទេ ប៉ុន្តែការប្រកួតប្រជែងរបស់អ្នកអភិបាលបារាំង បានប៉ះទង្គិចដល់មហិច្ឆតារដ្ឋបាលផ្ទាល់ខ្លួន ។

ត្រង់ចំណុចនេះរបាយការណ៍របស់អគ្គទេសាភិបាល ចុះថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩០៤ ដែលទាក់ទងទៅនឹងបញ្ហា Darlac ហាក់ដូចជាបានពិពណ៌នាដ៏អស្ចារ្យចំពោះ យើងនូវអាកប្បកិរិយាទាំងឡាយ ដែលជាដើមកំណើតនៃសភាពការណ៍បច្ចុប្បន្ន ។

"ចាប់តាំងពីការបង្កើត រ៉េស៊ីដង់ជាន់ខ្ពស់ នៅប្រទេសលាវមកវាហាក់ដូចជា... ថាលោករ៉េស៊ីដង់ជាន់ខ្ពស់...មានគោលបំណងដាក់ឲ្យនៅជាប់ដោយឡែក តាមលទ្ធភាពដែលអាចធ្វើទៅបាននូវប្រទេសដែលស្ថិតនៅក្រោមចំណុះអាជ្ញាធររបស់ខ្លួនដោយរុញថយក្រោយនូវព្រំដែនដោយសភាពហួសហេតុ" ។



រដ្ឋបាលចក្រពត្តិនិយមនេះ គឺជាមូលដ្ឋាននៃការរំលោភ ដែលធ្វើឲ្យប្រទេសកម្ពុជារងគ្រោះ ដែលត្រូវបានដណ្តើមយកនៅរវាងតំបន់ដែលទាក់ទងនឹងសន្តិសុខនៅតំបន់ខ្ពស់ដែលអាជ្ញាបញ្ជាខាងយោធាត្រូវដណ្តើមយក និងកូសាំងស៊ីន ដែលអាជ្ញាធររដ្ឋបាលបានស្ថិតនៅយូរមកហើយជាច្បាប់តាមឋានានុក្រមខ្ពស់ជាងច្បាប់របស់អាណាព្យាបាល និងបានស្ថិតនៅជាការពិតនៅទូទាំងជីវិតរបស់សហភាពឥណ្ឌូចិន ។

ការវិភាគដោយស៊ីជម្រៅអំពីចរិតរបស់បារាំង និងសមតា នៃកម្លាំងរដ្ឋបាលនៅក្នុងក្របខ័ណ្ឌ នៃសហភាពឥណ្ឌូចិន បានសម្តែងចេញដោយជាក់ស្តែងដែលអាជ្ញាធរអាណានិគម មិនដែលមានបំណងអ្វីក្រៅពីរៀបចំព្រំដែន នៃមណ្ឌលរដ្ឋបាលនោះឡើយ ។

### ៣ – ទឡ្ហីករណ៍គតិយុត្ត

ឧបករណ៍គតិយុត្តនេះ ដែលចាប់ពីឆ្នាំ ១៩១៥មក បានបម្រើ ដើម្បីធ្វើឲ្យបានសម្រេចនូវការប្តូរទឹកដី រវាងបណ្តាប្រទេសទាំងឡាយរបស់សហភាពម្យ៉ាងទៀតក្រឹត្យចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩១៥ មាត្រា១ មិនអនុញ្ញាត ដើម្បីធ្វើឲ្យសម្រេចនូវការផ្ទេរអធិបតេយ្យភាពនៃទឹកដីនោះឡើយ ។ យើងទប់មិនឲ្យផ្តល់លក្ខណៈដោយឆាប់រហ័សនៅទីនេះ នូវទឡ្ហីករណ៍ ដែលមានលក្ខណៈផ្ទុកក្នុងរបស់បារាំងដោយសុទ្ធសាធនេះទេ ដែលយើងបានអធិប្បាយ (Supra p-119) ។

### ៤ – ផលវិបាក

នៅក្នុងទស្សនវិស័យនេះ ល័ក្ខខ័ណ្ឌនៃការរៀបចំនូវព្រំដែនដែលទាមទារមិនហៅថាជាការរិះគន់ដូចគ្នានោះទេ ពីព្រោះថា សារសំខាន់នៃប្រតិបត្តិការ មិនដូចគ្នាសោះឡើយ ។ វាមិនមែនជាសកម្មភាពរំលោភរបស់អាណានិគមឡើយ ជាការជួយទៅនឹងការសន្យាអន្តរជាតិពីមុន ជាការជួយទៅនឹងតម្រូវការនៃច្បាប់របស់មនុស្ស ចំពោះការសន្យាជាឧឡារិក ដើម្បីការពារដែលបានប្រកាន់យកនៅក្នុងឆ្នាំ ១៨៦៣ ។ ឧបាយកល នៃការបោកប្រាស់ ការភ័ន្តច្រឡំ មធ្យោបាយពិតបានបាត់បង់មួយផ្នែកធំនៃអត្ថន័យរបស់វា ។

***ព្រំដែនរដ្ឋបាលមួយ មិនត្រូវបានគូសឡើយ បើតាមច្បាប់របស់អ្នកនៅក្រោមការត្រួតត្រា គឺជាការបង្កើតដោយសេរីមួយក្នុងមុខងារអាជ្ញាបញ្ជានៃរដ្ឋបាល ហើយ***

*ឧបាយកលរបស់ពួកអ្នកគ្រប់គ្រងដែលគិតតែពីផលប្រយោជន៍របស់ខ្លួន ដែលអាចរិះគន់បាននោះ គឺពួកគេផ្ទាល់មិនធ្វើឲ្យមានគ្រោះថ្នាក់ដល់សុពលភាពនៃគំនូសព្រំដែនមួយ ដែលបើតាមអត្ថន័យ គឺមានលក្ខណៈសេរីដាច់ខាតនូវទស្សនៈគតិយុត្តមួយ ហើយវាដាក់ឲ្យមានលក្ខខណ្ឌតែទៅតាមតម្រូវការនៃវិទ្យាសាស្ត្រខាងរដ្ឋបាលតែប៉ុណ្ណោះ ។*

*ដើម្បីសង្ខេប យើងយល់ថា ខ្សែព្រំដែនបច្ចុប្បន្ន គឺជាខ្សែព្រំដែនរដ្ឋបាល និងមិនមែនជាខ្សែព្រំដែនទឹកដីនោះឡើយ ។ វាមានលក្ខណៈនេះដោយពិតយ៉ាងច្បាស់នូវលក្ខខណ្ឌនៃការបង្កើតរបស់វា វាស្ថិតនៅតែក្នុងគំនិតនៃហេតុការណ៍នៃឆន្ទៈរបស់ភាគីជាសាម៉ី គឺប្រទេសបារាំង និងប្រទេសកម្ពុជា ។*

**៣ – កាតព្វកិច្ចនៃការពិនិត្យមើលឡើងវិញ**

***ក)*** វាចេញមកអំពីលក្ខណៈរដ្ឋបាលនៃព្រំដែន ការពិតគេត្រូវទាញហេតុផលទាំងឡាយពីសភាពការណ៍នេះ ។ ព្រំដែនរដ្ឋបាលអាណានិគម ការបំបែកនូវអង្គភាពរួមផ្សំទាំងឡាយ នៃសហភាពឥណ្ឌូចិន នឹងត្រូវបានចោទប្រកាន់ឡើងវិញ នៅក្នុងពេលនៃការរំលាយសហព័ន្ធ ។ ព្រំដែននេះបានផ្តល់កំណើតដល់ការចរចា ដើម្បីឲ្យបានដល់ការព្រមព្រៀងមួយដោយសេរី ដែលយល់ព្រមដោយភាគីទាំងឡាយ នៅលើមូលដ្ឋាន នៃច្បាប់ទាំងឡាយដែលគ្មានអាជ្ញាយុកាលដោយមានឋានៈដូចគ្នា នឹងការរំលាយនៃការផ្សាររួមរបស់សហព័ន្ធ ។ ភាគីមួយក៏ដូចជាភាគីផ្សេងទៀត បានជាប់ទាក់ទងទៅនឹងលក្ខន្តិកៈអាណានិគម ដែលត្រូវបានលុបចោល ។ វាជាបរមតិដែលទិដ្ឋភាពមួយ នៃទិដ្ឋភាពទាំងឡាយ នៃលក្ខន្តិកៈនេះត្រូវបានរក្សាទុក ។

លក្ខខណ្ឌទាំងឡាយដែលធ្វើឲ្យផ្ទុះឡើងនូវសហព័ន្ធឥណ្ឌូចិន មិនបានអនុញ្ញាតឲ្យប្រទេសបារាំង ដើម្បីចាត់ចែងចំពោះការដោះស្រាយនេះនិងចំពោះការដាក់ឲ្យទៅជាសភាពដើមវិញនោះទេ ។ វាជារបស់នៃប្រទេសជាសាម៉ី ហើយគេត្រូវតែជម្រះបញ្ជីជានិច្ចនូវមរតកអាណានិគមនេះដែលបំណុលសរុប គឺធ្ងន់ធ្ងរណាស់សម្រាប់ប្រទេសកម្ពុជា។

នេះគឺជាតម្រូវការគតិយុត្តបន្ទាប់បញ្ហា ដែលមកអំពីអាកប្បកិរិយារដ្ឋបាលនៃព្រំដែនខាងក្នុងនៃឥណ្ឌូចិន ។ ព្រំដែនទឹកដីក្នុងតម្លៃអន្តរជាតិ នៅតែស្ថិតនៅ ដើម្បី



គូសនៅលើមូលដ្ឋាន នៃច្បាប់ដែលមានស្រាប់នៅក្នុងពេលនៃការធ្វើអន្តរាគមន៍របស់បារាំង ។

**ខ)–** វាមកអំពីតម្រូវការនៃការដោះលែងពីអាណានិគម ម្យ៉ាងទៀត ភាពចាំបាច់នៃការចោទប្រកាន់ឡើងវិញ នូវព្រំដែនបច្ចុប្បន្ន ក៏ចេញមកពីតម្រូវការនៃការដោះលែងពីអាណានិគមផងដែរ ។ បើសិនជាគេចង់មើលនៅក្នុងឃ្លានេះគឺគ្មានអ្វីក្រៅពីពាក្យស្លោកមិនច្បាស់លាស់មួយ នៃការធ្វើប្រជាភិថុតិអន្តរជាតិ គេត្រូវតែទទួលស្គាល់ថា ការដោះលែងពីអាណានិគមមានរួមបញ្ចូលនូវផលវិបាកខាងគតិយុត្តមួយចំនួនដែលគ្របសង្កត់នូវឧត្តមគតិនៃសីលធម៌ ។ ការដោះលែងពីអាណានិគមមានរួមបញ្ចូលនូវការជម្រះបញ្ជីនៃការប្រព្រឹត្តរបស់អាណានិគមដែលបានធ្វើឲ្យប៉ះពាល់ដល់ច្បាប់នៃបណ្តាប្រទេសស្ថិតនៅក្នុងចំណុះ ។ វាតម្រូវឲ្យមានការស្រាវជ្រាវរកនូវសមតាថ្មីមួយរវាងប្រទេសទាំងឡាយ ដែលបានស្គាល់សហគមន៍មួយ ដែលស្ថិតនៅក្នុងចំណុះគេ សមតា ដែលបង្កើតឡើងនៅលើការឧទ្ទិសនៃច្បាប់ទៅវិញទៅមករបស់ភាគីទាំងឡាយ ។ វាបានរួមបញ្ចូលនូវការបំបាត់ជាដាច់ខាតនូវវិធានការទាំងអស់ដែលអាចត្រូវបានផុសគំនិតដោយការដឹងខ្លួនតិចឬច្រើន ដោយចំណង់ ដើម្បីអនុគ្រោះដល់ភាគីម្ខាងដោយធ្វើឲ្យខូចប្រយោជន៍ដល់ភាគីម្ខាងទៀត ។ ការដោះលែងពីអាណានិគមនៅឥណ្ឌូចិន (ដែលត្រូវបានសម្រេចនៅលើផែនការនយោបាយ) បានទាមទារឲ្យមានការដោះលែង ពីអាណានិគមទាំងស្រុងនូវព្រំដែនខាងក្នុងរបស់សហព័ន្ធដែលការដោះលែងពីអាណានិគមនេះ នៅតែស្ថិតនៅ ដើម្បីបំពេញទៀត ។

នៅទីបញ្ចប់បណ្តាប្រទេសជាអ្នកទទួលផលនៃអាកប្បកិរិយាអាណានិគមគ្រាន់តែចេះគិតដល់ការដោះខ្លួននៅខាងក្រោយការស្មានច្បាប់អន្តរជាតិមួយនោះគឺ l'uti possidetis ដើម្បីគេចវេះពីកិច្ចការចាំបាច់នេះ ។

***គ)*** វាមិនបានប៉ះពាល់ដល់គោលការណ៍នៃ L'uti possidetis ទេ

**១ –** L'uti possidetis ដែលយើងបានជួបប្រទះនៅក្នុងបុព្វយោគរបស់យើង មិនអាចសមស្របនៅទីនេះទេ ព្រោះថាមុនដំបូងវាមិនមែនជាវិន័យទូទៅនៃច្បាប់អន្តរជាតិជាវិជ្ជមាននោះឡើយ ហើយថាការចាប់ប្រតិបត្តិ នឹងអាចទទួលបាន

លទ្ធផលតែដោយការយល់ព្រមពីភាគីនានានោះទេ ។

**២ –** ប៉ុន្តែ ការយល់ព្រមនេះ មិនអាចផ្តល់បានឡើយ ព្រោះថាសភាពការណ៍ឥណ្ឌូចិន មិនបានបង្ហាញនូវចរិតណាមួយ ដែលបាននាំទៅដល់ការព្រមទទួលយកនៃគោលការណ៍នោះឡើយ ។

***ក)*** រដ្ឋទាំងឡាយនៅឥណ្ឌូចិន មិនបានស្ថិតនៅក្នុងក្របខ័ណ្ឌនៃរដ្ឋការអាណានិគមដូចនៅក្នុងសភាពការណ៍ស្មើភាពម៉ឺងម៉ាត់ ដែលបានចង្អុលចរិតលក្ខណៈរបស់អាមេរិកអេស្ប៉ាញ៉ុលនោះឡើយ ។ រដ្ឋទាំងនោះបានស្គាល់នូវលក្ខន្តិកៈផ្សេងៗដែលបានបណ្តាលឲ្យមានភាពមិនស្មើគ្នា នៃការប្រព្រឹត្តពីខាងភាគីមហាអំណាចអ្នកអភិបាល ។

***ខ)*** រដ្ឋទាំងឡាយនេះ បានបង្កើតនូវអង្គភាពជាតិ រួបរួមគ្នាដែលអត្ថិភាព និងច្បាប់មានទៅវិញទៅមក គឺនៅមុនការធ្វើអាណានិគមនិយម ។

***គ)*** ចំពោះភាពខុសគ្នា នូវអ្វីដែលបានកើតមាននៅអាមេរិកខាងត្បូងនោះគឺព្រំដែនអាណានិគមមិនបានចែកនូវទឹកដីដ៏ធំធេងដែលគ្មានដំាដំណាំ និងគ្មានប្រជាជនរស់នៅនោះទេ ប៉ុន្តែផ្ទុយទៅវិញដីដែលមានជីវជាតិនិងរស់នៅដោយមនុស្សមានពូជអម្បូរ មានគំនិតមារយាទ និងទម្លាប់ល្អ មានភាសា និងវប្បធម៌ជាក់លាក់ ។ ព្រំដែននេះបានមានប្រយោជន៍ចំពោះប្រជាជនទាំងនេះ និងបានទទួលស្គាល់នូវធនុះរបស់មនុស្សទាំងនេះ នៅក្នុងវិធានការដែលគេទាមទារឲ្យមានការយល់ព្រមនៅពេលបច្ចុប្បន្ននេះនូវតម្លៃមួយដែលគេពុំមាននៅពេលដំបូង ។

***ឃ)*** នៅទីបញ្ចប់ សភាពការណ៍ឥណ្ឌូចិន តម្រូវឲ្យធ្វើការកែប្រែដោយអន្លើ និងដោយសាមញ្ញ ដែលមិនងាយធ្វើឲ្យភ័ន្តប្រែនូវសមតា និងវចនាសម្ព័ន្ធនយោបាយជាមួយគ្នា នៅអាស៊ីអាគ្នេយ៍នោះឡើយ ។

ចំពោះបញ្ហានេះ វាមានការខុសគ្នាខ្លាំងណាស់នៅអាហ្វ្រិក ដែលការគោរព L'uti possidetis យ៉ាងហោចណាស់ក្នុងសភាពបណ្តោះអាសន្ន បានលេចឡើងដូចជាការចាំបាច់មួយនៅក្រោមការប្រឹងប្រែង ដើម្បីធ្វើការចោទប្រកាន់ឡើងវិញ នូវអត្ថិភាពផ្ទាល់នៃរដ្ឋទាំងឡាយនៅពេលបច្ចុប្បន្ននេះ ហើយដែលសភាពការណ៍មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំង ដែលការជម្រះបញ្ជីនៃការបែងចែករបស់អាណានិគមមិនអាច



បង្កើតបានតែនៅក្នុងក្របខ័ណ្ឌនៃការបង្កើតនូវការឯកភាពអាហ្វ្រិកមួយនោះទេ ។

## II – ការបញ្ចូលជាឧបសម្ព័ន្ធ

ដោយគ្មានការទាក់ទងជាមួយ និងទស្សិករណ៍ទូទៅដែលយើងទើបនឹងធ្វើសំយោគ ហើយដែលទាមទារឲ្យមានការចោទប្រកាន់ទាំងស្រុង នូវគំនូសព្រំដែនមួយ ដែលមិនអនុគ្រោះដាច់ខាតចំពោះប្រទេសកម្ពុជានោះ វាមានមធ្យោបាយគតិយុត្តទី២ ដែលមធ្យោបាយនេះក៏ដឹកនាំទៅរកកម្រិតផ្សេងៗផងដែរ ទៅតាមផ្នែកភូមិសាស្ត្រចំពោះភាពចាំបាច់ ដើម្បីកែតម្រូវព្រំដែនបច្ចុប្បន្ន និងដើម្បីបង្កើតនៅព្រះរាជាណាចក្រខ្មែរ នូវតំបន់ទឹកដីដែលមានការបញ្ជាក់ទាំងស្រុង ។

### គោលរឿងទូទៅនៃទស្សិកម្មទីពីរនេះ

វាមានលក្ខណៈងាយស្រួលបំផុត ការបង្កើតនូវព្រំដែនមួយរវាងប្រទេសកម្ពុជា និងទឹកដីផ្សេងៗទៀត ដែលស្ថិតនៅក្រោមអំណាចនៃអាជ្ញាធរបារាំង នៅក្រោយឆ្នាំ ១៨៦៣ នៅក្នុងល័ក្ខខ័ណ្ឌទាំងឡាយ ដែលបានសម្រេចកាត់ទឹកដីជាតិ ដែលមាននៅមុនកាលបរិច្ឆេទនេះត្រូវបានវិភាគដូចជាការបញ្ចូលជាឧបសម្ព័ន្ធមួយ ។

មានការបញ្ចូលជាឧបសម្ព័ន្ធនៅពេលដែលប្រតិបត្តិការកំណត់ព្រំដែន ត្រូវបានបង្ហាញជាផ្លូវការ និងនៅក្នុងរបៀបដែលភ័ន្តច្រឡំដូចជាមានការប្រកាសដ៏ងាយស្រួលនូវច្បាប់ទាំងឡាយដែលមានស្រាប់ (ដែលមានជាញឹកញាប់នៅក្នុងករណីនេះ) ។

មានការបញ្ចូលជាឧបសម្ព័ន្ធជាពិសេសទៅទៀត នៅពេលដែលអាជ្ញាធរបារាំងបានប្រកាសយ៉ាងច្បាស់លាស់ថា សកម្មភាពរបស់ពួកគេមានអានុភាព ដើម្បីភ្ជាប់ទឹកដីកម្ពុជា ទៅអង្គភាពផ្សេងៗទៀត នៅឥណ្ឌូចិន (អនុក្រឹត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩០៥ ដោយបានភ្ជាប់ Muongs (ស្រុក) ផ្សេងៗរបស់ប្រទេសកម្ពុជា ទៅឲ្យខេត្តបាសាក់ អនុក្រឹត្យទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី២២ កក្កដា ១៨៩៣ ដែលបានទទួលវិញ នៅក្នុងបន្ទុករបស់ខ្លួន ដោយអនុក្រឹត្យរបស់អគ្គទេសាភិបាលចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤) ។

នៅទីបញ្ចប់ មានការបញ្ចូលជាឧបសម្ព័ន្ធ នៅពេលដែលគេមកប្រជុំនៅក្នុងការធ្វើការកែតម្រូវដែលមានគោលបំណងវិលត្រឡប់ទៅរកសភាពនៃការទាមទារពីមុន

ដែលស្ថិតនៅលើការអះអាង ភូតកុហក (ចំរៀកដីរវាងផ្លូវទាំងពីរ ហាទៀន – យ៉ាំង ថាញ់ (Hatien Giang Thanh) ។

នៅក្នុងសម្មតិកម្មទាំងអស់នេះ យើងស្ថិតនៅចំពោះមុខនៃការបញ្ចូលជា ឧបសម្ព័ន្ធ ដែលធ្វើឡើងដោយមហាអំណាចអ្នកការពារ ដើម្បីជាគុណប្រយោជន៍ ផ្ទាល់របស់ខ្លួន ឬក៏ដើម្បីជាគុណប្រយោជន៍របស់ប្រទេសដែលស្ថិតនៅក្រោមការពារ ផ្សេងទៀត នៅសហព័ន្ធឥណ្ឌូចិន ដែលយើងនឹងបានឃើញថា វានឹងប៉ះពាល់ដល់ ឧបសគ្គគតិយុត្តទាំងឡាយ ដែលផ្តល់នូវសុពលភាពគួរឲ្យសង្ស័យ ហើយនៅសភាព នៃមូលហេតុទាំងអស់ ដែលវានឹងបាត់ក្នុងពេលនៃការដោះលែងពីអាណានិគម ។

**១ – ការបញ្ចូលជាឧបសម្ព័ន្ធតើអាចទៅរួចដែរឬទេ ?**

នៅទីនេះ គេត្រូវតែវែកញែករវាងការបញ្ចូលជាឧបសម្ព័ន្ធពិតប្រាកដ ដែលបាន ធ្វើឡើង ដោយប្រទេសបារាំង នូវភាគតូចនៃទឹកដីកម្ពុជា ទៅឲ្យអាណានិគមកូសាំង ស៊ីន នឹងការកំណត់ឲ្យទៅប្រទេសអណ្ណាម និងប្រទេសលាវ នូវទឹកដីកម្ពុជា ដែលធ្វើ ឡើងដោយប្រទេសបារាំង ។ ការពិតចំពោះបញ្ហាទី១ នេះ គេបានជួបកត្តាមួយនៃ ច្បាប់អន្តរជាតិ ជាក់លាក់ដែលមកពង្រឹងការពិចារណាជាទូទៅ ។

***ក) ភាពមិនអាចទៅរួច នៃការបញ្ចូលជាឧបសម្ព័ន្ធនូវភាគតូចនៃទឹកដីកម្ពុជាទៅឲ្យកូសាំងស៊ីន***

បញ្ហានេះ ចេញមកពីតម្រូវការនៃសន្ធិសញ្ញាបារាំង សៀម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៦៧ ។

យើងបានយកធ្វើជាសំអាងរួចហើយ នូវសន្ធិសញ្ញានេះនៅក្នុងទឡ្ហីករណ៍ទីមួយ របស់យើង ប៉ុន្តែដើម្បីធ្វើការដកហូតតែមួយគត់នូវការទាមទាររបស់ពួកគេ ដែល ប្រទេសបារាំងអាចនិងចង់បង្កើតរវាងប្រទេសកម្ពុជា និងកូសាំងស៊ីននោះគឺគ្មានអ្វី ក្រៅពីព្រំដែនរដ្ឋបាលនោះឡើយ ។

ប៉ុន្តែបើសិនជាគេបដិសេធនូវការវិភាគទី១មួយនេះ យើងបានឃើញរួចហើយ គេ បានបង្ខិតបង្ខំ ដើម្បីឲ្យប្រាប់លក្ខណៈនៃការបញ្ចូលជាឧបសម្ព័ន្ធ ការផ្ទេរទឹកដី ដែល បានធ្វើឡើង ដើម្បីធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសកម្ពុជា ប៉ុន្តែបញ្ហានេះ គឺជួយទៅ



នឹងការសន្យាជាអន្តរជាតិ ដែលប្រកាន់យកដោយប្រទេសបារាំងនៅក្នុងឆ្នាំ ១៨៦៧ ។ មានការរំលោភទៅលើវិន័យជាវិជ្ជមានមួយនៃច្បាប់អន្តរជាតិ ដែលសារៈសំខាន់ត្រូវ បានទទួលស្គាល់ដោយប្រទេសបារាំង នៅក្នុងកាលៈទេសៈផ្សេងៗទៀត (cf.Affaire de l'ile de Catrey) ។

***ខ) ភាពមិនអាចទៅរួចនៃការបញ្ចូលជាឧបសម្ព័ន្ធ (ប៉ះពាល់ដល់បូរភាពទឹកដីកម្ពុជា) ដោយផ្ទៀបនឹងសន្ធិសញ្ញា ឆ្នាំ ១៨៦៣***

**១ –** ភាពមិនអាចប៉ះពាល់បាននៃការគាំទ្រទឹកដី របស់អាណាព្យាបាលសន្ធិសញ្ញា នៃអាណាព្យាបាលមានផលគ្រាន់តែ ដើម្បីផ្ទេរទៅឲ្យមហាអំណាចជាអ្នកការពារ កាន់ កាប់នូវសមត្ថកិច្ចមួយចំនួនរបស់រដ្ឋ ដែលត្រូវការពារ ប៉ុន្តែសមត្ថកិច្ចទាំងនេះ ត្រូវ បំពេញនៅក្នុងក្របខ័ណ្ឌនៃទឹកដី ដែលមានស្រាប់នៅក្នុងពេលនៃការចុះហត្ថលេខា លើសន្ធិសញ្ញា ។ សន្ធិសញ្ញានៃអាណាព្យាបាល មិនបាននាំទៅដល់លទ្ធភាពសម្រាប់ មហាអំណាចអ្នកការពារ ដើម្បីកែប្រែជាឯកតោភាគី នូវវិសាលភាពនៃទឹកដីដែល ស្ថិតនៅក្រោមការការពារនោះឡើយ ។ ប្រាកដហើយ ភាពមិនអាចប៉ះពាល់បាននៃ ទឹកដីរបស់រដ្ឋដែលស្ថិតនៅក្រោមការការពារ ដែលជាលទ្ធផលនៃសភាពការណ៍នេះ មិនមែនដាច់ខាតនោះឡើយ ហើយមហាអំណាចអ្នកការពារដែលជាអ្នកតំណាងឲ្យរដ្ឋ ដែលស្ថិតនៅក្រោមការការពារនៅក្នុងទំនាក់ទំនងអន្តរជាតិនោះ អាចយល់ព្រមនូវ ការធ្វើពលិកម្មខ្លះ ការបោះបង់ទឹកដីខ្លះនៅក្នុងនាមនៃប្រទេសដែលស្ថិតនៅក្រោម ការការពារ ប៉ុន្តែគេនៅតែត្រូវឲ្យការបោះបង់ទាំងនេះ មិនមានសញ្ញានៃការមិន ទទួលស្គាល់ដោយចេតនា នូវកាតព្វកិច្ច នៃការការពារដែលធ្លាក់ទៅលើអ្នក ការពារនោះឡើយ ។ នេះហើយគឺជាករណីនៅក្នុងរឿងនេះ ។

**២ –** មោឃៈភាពនៃការបញ្ចូលជាឧបសម្ព័ន្ធ គឺជាលទ្ធផលនៃកាតព្វកិច្ច នៃការ ការពារ ការបាត់បង់ទឹកដី ដែលប្រទេសកម្ពុជាបានទទួលរងនោះ គឺជាលទ្ធផលនៃ សេចក្តីសម្រេចទាំងឡាយ ដែលតាមការពិត គឺធ្វើឡើងជាឯកតោភាគី ដោយ ប្រទេសបារាំង ដោយគ្មានសំណងពិតប្រាកដសម្រាប់ព្រះរាជាណាចក្រដែលស្ថិតនៅ ក្រោមការការពារនោះឡើយ បាននិងបញ្ចូលជាឧបសម្ព័ន្ធទៅឲ្យកូសាំងស៊ីន នូវទឹកដី

កម្ពុជា ឬក៏បានកំណត់ទឹកដីទាំងនោះទៅឲ្យប្រទេសលាវ ឬទៅឲ្យប្រទេសអណ្ណាម ។ នៅក្នុងកិច្ចប្រតិបត្តិការទាំងនេះ មិនដែលមានផលប្រយោជន៍ណាមួយរបស់ប្រទេសកម្ពុជាត្រូវបានការពារនោះទេ ហើយការខិតខំប្រឹងប្រែងទាំងអស់របស់អាជ្ញាធរជាអ្នកការពារបានសំដៅនោះ ជួនកាល ដើម្បីបិទបាំងនូវចរិតពិតប្រាកដនៃប្រតិបត្តិការជួនកាលដើម្បីធ្វើឲ្យទទួលយកដោយអាជ្ញាធរខ្មែរដែលគ្មានអាវុធ ។ ការទាមទាររបស់ប្រជាជនអណ្ណាម ឬក៏ការលោភលន់របស់អ្នកគ្រប់គ្រងបារាំង គឺតែងតែមានប្រៀបលើការពិចារណាទៅលើផលប្រយោជន៍របស់កម្ពុជា ។ នៅក្នុងល័ក្ខខ័ណ្ឌទាំងនេះគេអាចសន្និដ្ឋានថា ការបញ្ចូលជាឧបសម្ព័ន្ធបានសម្រេចដែលវាជុយទៅនឹងកាតព្វកិច្ចនៃការការពារដែលធ្វើឲ្យសន្ធិសញ្ញាឆ្នាំ ១៨៦៣ ក្លាយទៅជាគ្មានតម្លៃ ។

## ២ – ការបញ្ចូលជាឧបសម្ព័ន្ធនិងការដោះលែងពីអាណានិគម

ការដោះលែងពីអាណានិគមត្រូវបានធ្វើវិភាគដូចជា ការលុបចោលមួយនៃការបញ្ចូលជាឧបសម្ព័ន្ធទឹកដី ដែលធ្វើឡើងដោយមហាអំណាចអាណានិគមនៅក្នុងពេលនៃការធ្វើសញ្ជ័យ ។ ដូច្នេះការលុបចោលនេះត្រូវតែនាំទៅរកដោយចាំបាច់ នៅគ្រប់វិធានការទាំងអស់នៃលទ្ធភាពប្រគល់ឲ្យនៅក្នុងសភាពពីមុន ជាពិសេសនៅពេលដែលការធ្វើអាណានិគមបានចាប់កើតមានរូបរាង ដូចជាករណីសម្រាប់ប្រទេសកម្ពុជានិងប្រទេសវៀតណាម ការលេបយកប្រជាជាតិដែលវាអត្ថិភាពនៅមុនការធ្វើអាណានិគម ។

ដូច្នេះការដោះលែងពីអាណានិគម នៃឥណ្ឌូចិន មានរួមបញ្ចូលនូវការធ្វើឲ្យដូចដើមវិញនូវឯករាជ្យរបស់ពួកគេ ចំពោះរដ្ឋទាំងឡាយ ដែលបានបង្កើតសហព័ន្ធនៅក្នុងក្របខ័ណ្ឌនៃព្រំដែនទឹកដីពីមុនរបស់ពួកគេ ។ ការដោះលែងពីអាណានិគមរួមបញ្ចូលនូវការធ្វើឲ្យដូចដើមឡើងវិញ នៅវៀតណាមនូវទឹកដីចាស់របស់ខ្លួន ដែលប្រែក្លាយទៅជាខេត្តរបស់បារាំង លើកលែងតែផ្នែកនៃទឹកដីខ្មែរ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងខេត្តទាំងនេះ នៅក្នុងអំឡុងសម័យអាណានិគម ។

គោលការណ៍នៃការដោះលែងពីអាណានិគមផ្ទាល់មិនអាចស្រុះស្រួលចិត្តចំពោះការផ្ទេរទៅឲ្យរដ្ឋថ្មីមួយ (ក្នុងរឿងនេះ គឺប្រទេសវៀតណាម) នូវទឹកដីដែលត្រូវបាន



ផ្តាច់ចេញពីប្រទេសជិតខាងរបស់ខ្លួន នៅក្នុងក្របខ័ណ្ឌនៃការបញ្ចូលជាឧបសម្ព័ន្ធ នោះ ។ គេបានឃើញនូវអំពើអាក្រក់នៅលើផែនការនៃគោលការណ៍ទាំងឡាយ តើគេនឹងអាចធ្វើតាមបែបផ្សេងបានដូចម្តេច ។

## ៣ – សភាពខុសគ្នានៃសភាពការណ៍ច្បាស់លាស់

បើសិនជាគោលការណ៍ទាំងឡាយ ដឹកនាំទៅរកការយល់ព្រមនូវមោទនភាពដោយមិនអាចប្រកែកបាននូវការបញ្ចូលជាឧបសម្ព័ន្ធ ដែលទទួលរងដោយប្រទេសកម្ពុជា និងការទាមទារនូវការធ្វើឲ្យដូចដើមឡើងវិញ ទៅលើផែនការប្រតិបត្តិ គេបានប៉ះទង្គិចទៅនឹងការលំបាកមួយចំពោះភាពមិនច្បាស់លាស់នៃព្រំដែនកាលពីពេលមុន ចំពោះគំនូសព្រំដែនអាណានិគម ។ ប៉ុន្តែភាពមិនច្បាស់លាស់នេះ គ្រាន់តែសម្រាប់បម្រើនូវលេស ដើម្បីរក្សានូវសភាពការណ៍អាណានិគម ដើម្បីធ្វើឲ្យខូចប្រយោជន៍ដល់ប្រទេសកម្ពុជា ។

***ក)*** តាមរបៀបជាទូទៅ ការប៉ះពាល់ចំពោះច្បាប់ទាំងឡាយរបស់ប្រទេសកម្ពុជានៅក្នុងអំឡុងពេលនៃការបង្កើតព្រំដែនដែលប្រកាសថា ជាការទាមទារដោយត្រឹមត្រូវជាលទ្ធផលដោយមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ស្តីអំពីលក្ខណៈទាំងអស់នៃព្រំដែននៃការសិក្សា ដែលយើងបានធ្វើ ដើម្បីឲ្យគេអាចទាមទារដោយត្រឹមត្រូវតាមច្បាប់នូវការបើកការចរចាសំដៅបង្កើតតាមរបៀបសមតា នូវព្រំដែនទាំងនេះនៅលើមូលដ្ឋាននៃច្បាប់របស់ប្រទេសនីមួយៗ ។

***ខ)*** ម្យ៉ាងទៀត វាជាផ្នែកព្រំដែនដែលទទ្ធិករណ៍នៃភាពមិនច្បាស់លាស់នៃព្រំដែនពីមុននេះ ចំពោះការធ្វើអន្តរាគមន៍របស់អាណានិគមថែមទាំងមិនអាចត្រូវបានសំអាងលើផងនោះ គឺជាផ្នែកទាំងឡាយដែលព្រំដែនត្រូវបានបង្កើតឡើងនៅពេលក្រោយមកទៀត ចំពោះការធ្វើស្ថិរភាពភាវូបនីយកម្មអាណានិគម ដោយការដាក់ធ្វើជាមូលហេតុជាឯកតោភាគី ជាមួយនឹងមធ្យោបាយ ដោយគតិយុត្ត ដែលមិនមាននិងចេះតែសង្ស័យខាងផ្លូវចិត្ត នូវការបែងចែកទីមួយនូវសមត្ថកិច្ចទឹកដី ដែលធ្វើឡើងដោយប្រទេសបារាំង ។ ផ្នែកទាំងនេះដែលកុសលនៃការបង្កើតច្បាប់នៃប្រទេសកម្ពុជាបានលេចឡើងជាមួយនឹងកម្លាំងពិសេសមួយ គឺ :

**ក)** ផ្នែកនៃខ្សែបន្ទាត់ ហាទៀន-យ៉ាំង ថាញ់

**១)** ផ្នែកនៃស្រុកទាំងឡាយនៅ ថាញ់ អាន, គូ អាន, មិញ ង៉ាយ, ក្វាងឡើយ ឡុក និញ និង ភឿក ឡេ ។

តំបន់ទាំងឡាយដែលទាមទារដោយប្រទេសកម្ពុជា គឺជាតំបន់ដែលមានប្រជាជនខ្មែររស់នៅដោយមិនអាចប្រកែកបាន តំបន់ទាំងនោះត្រូវបានប្រជាជនរស់នៅ និងនៅតែរស់នៅដោយប្រជាជនខ្មែរ ដែលប្រជាជនទាំងនោះនៅមុនការបង្កើតអាណាព្យាបាល និងនៅក្នុងអំឡុងបណ្តាទសវត្សរ៍ទីមួយ នៃសម័យអាណានិគម គឺគ្រប់គ្រងដោយអាជ្ញាធរកម្ពុជា ភាពនៅរួមរបស់ពួកគេនៅក្នុងព្រះរាជាណាចក្រត្រូវបានទទួលស្គាល់ដោយច្បាស់លាស់ ដោយប្រទេសបារាំង ជួនកាលនៅក្នុងអនុក្រឹត្យនៃការបញ្ចូលជាឧបសម្ព័ន្ធ ជួនកាលនៅក្នុងផែនទីដែលបង្កើតឡើងដោយអាជ្ញាធរបារាំងផ្ទាល់ ជួនកាលនៅក្នុងអំឡុងពេលនៃការកំណត់ព្រំដែនលើកទីមួយ ។ គឺដោយសារសកម្មភាពរំលោភ ហើយដែលអមដោយឧបាយកលបន្លំលួចផងនោះហើយដែលតំបន់នោះត្រូវបានបញ្ចូលជាឧបសម្ព័ន្ធ ដោយប្រទេសបារាំងទៅក្នុងទឹកដីអាណានិគមកូសាំងស៊ីន ។

## III - វិបាកនៅទីបញ្ចប់

នៅទីបំផុតការដាក់ធ្វើជាមូលហេតុនូវព្រំដែនបច្ចុប្បន្នរបស់ប្រទេសកម្ពុជាដែលមិនត្រូវបានកំណត់ដោយសន្ធិសញ្ញាអន្តរជាតិនោះ គឺជាការចាំបាច់មួយនៃគតិយុត្តដាច់ខាត និងជាតម្រូវការចំបងនៃការវិលត្រឡប់ទៅរកឯករាជ្យ ។

- វាជារបៀបទូទៅមួយ បើសិនជាគេយល់ព្រមនូវអ្វីដែលយើងបានគិតថា វាមិនដែលមានព្រំដែនអន្តរជាតិពិតប្រាកដជាមួយប្រទេសទាំងឡាយ នៃអតីតសហព័ន្ធឥណ្ឌូចិន ប៉ុន្តែគ្រាន់តែជាសេចក្តីសម្រេចរដ្ឋបាល ដែលបានប៉ះពាល់ដល់បូរណភាពទឹកដីកម្ពុជា ។ នៅក្នុងសម្មតិកម្មនេះ ព្រំដែនពិតប្រាកដនៅតែស្ថិតនៅដើម្បីគូសតទៀត និងមិនអាចគ្រាន់តែជាលទ្ធផល នៃការចរចាដោយសេរីមួយរវាងភាគីជាសាមីនោះទេ ។

- វាស្ថិតនៅក្នុងវិធានការដែលគេអះអាងថា ប្រទេសបារាំងបានបង្កើតនូវព្រំដែនពិតប្រាកដ ព្រោះថាគេបានឃើញនៅពេលនោះ នៅចំពោះមុខនៃការបញ្ចូលជាឧបសម្ព័ន្ធអាណានិគមនូវទឹកដីកម្ពុជា ។ វានឹងជាបរមតិ ដែលយល់ព្រមថា ការផ្ទេរទៅឲ្យតតិយរដ្ឋ (រដ្ឋទី៣) អាចមានផល ដើម្បីធ្វើឲ្យរួចពីការដោះលែង ពីអាណា និគម ។ ជាពិសេសបើសិនជា តតិយរដ្ឋទាំងនេះ គឺខ្លួនឯងផ្ទាល់ជារដ្ឋ ដែលបានដោះលែងពីអាណានិគម ។



ត្រង់ចំណុចនេះ ការដោះលែងពីអាណានិគម មានតម្រូវការពីរគឺការសងមកវិញទាំងអស់ និងជាបន្ទាន់នូវទឹកដីដែលមានកំណត់ព្រំដែនយ៉ាងច្បាស់ ដែលត្រូវបានដណ្តើមយកពីប្រទេសកម្ពុជា នៅពេលក្រោយ ចំពោះការបែងចែកទឹកដីលើកទីមួយដែលយល់ព្រមដោយមហាអំណាចអាណានិគម ។

ការកំណត់ព្រំដែនថ្មី តាមផ្លូវចរចាស្តីពីព្រំដែនទីមួយដែលនៅក្រោមម្លប់នៃលិខិតដែលមានប្រកាសបានកាត់យកចេញពីប្រទេសកម្ពុជា ។

***គាំទ្រភាពផ្ទុយ គឺជាជំហរមួយដែលមិនអាចទប់ទល់បាន ។ នៅត្រង់ចំណុចនេះ មានតែលទ្ធភាពសមហេតុសមផល៣យ៉ាង ដែលបានផ្តល់ទៅឲ្យវៀតណាម ។***

***ក) អះអាងរួមគ្នាស្តីពី ការប្រព្រឹត្តរបស់អាណានិគម ដែលអាចប្រកែកបាន និងទទួលខុសត្រូវលើមរតករបស់ខ្លួន គឺមរតករបស់ខ្លួនទាំងអស់ ។***

***ខ) ផ្តន្ទាទោស នូវការអនុវត្តទាំងឡាយរបស់អាណានិគម ដែលខ្លួនបានទាមទារម្យ៉ាងទៀតថា មានការឈឺចាប់ និងផ្តល់ដោយឯកឯងចំពោះកិច្ចព្រមព្រៀងទាំងឡាយដើម្បីដោះលែងពីអាណានិគម នូវទឹកដីដែលដកយកចេញពីអធិបតេយ្យភាពរបស់ ខ្មែរដោយអយុត្តិធម៌ ។***

***គ) ទទួលស្គាល់ជាកណ្តាល និងគ្មានការលំអៀងទាល់តែសោះថា បារាំងមិនបានកាត់ផ្តាច់ មិនបានទាមទារ ដើម្បីកាត់ផ្តាច់នូវបញ្ហាអធិបតេយ្យភាពទឹកដីដែលជារបស់បរទេសនោះទេ ចំពោះក្តីកង្វល់របស់ខ្លួន និងផ្តល់ឲ្យមានការចរចា ដើម្បីបង្កើតនូវព្រំដែនអន្តរជាតិពិតប្រាកដ នៅលើមូលដ្ឋាននៃការគោរពច្បាប់គ្មានអាជ្ញាយុកាលនៃរដ្ឋទាំងពីរ ។ គឺជំរើសនៅពេលត្រូវរហូតក្រោយនេះហើយ ដែលយើងប្រាថ្នាចង់បាននិងអាកប្បកិរិយាដែលនៅក្នុងនោះ យើងមិនបានលាក់ទុកនូវចំណូលចិត្តរបស់យើងនោះទេ ។***

# តារាងសរុប

| ផ្នែកនៃព្រំដែន | ការបាត់បង់របស់ប្រទេសកម្ពុជា | ប្រតិបត្តិការរៀបចំជាមុនចំពោះការបង្កើតព្រំដែន | ច្បាប់គតិយុត្តនៃការសន្មតបារាំង-ខ្មែរ | ច្បាប់ផ្ទៃក្នុងរបស់ខ្មែរ | ច្បាប់ឯកតោភាគីរបស់បារាំង | ប្រតិបត្តិការសម្ភារៈដើម្បីផ្ដើមដាក់ | ការតវ៉ារបស់កម្ពុជា |
|---|---|---|---|---|---|---|---|
| ត្រើយខាងឆ្វេងនៃទន្លេមេគង្គ (រវាងទន្លេនេះនិងប្រភពDer-Hoyt) | -ទឹកដីនៃអតីតស្នងការដ្ឋានដារឡាក់ | ដោយផ្ទាល់ : គ្មានដោយប្រយោល : ការងាររបស់បេសកកម្ម Doudart de Lagrée ដើម្បីបង្កើតច្បាប់នៅប្រទេសកម្ពុជានៅលើមូលដ្ឋានដែលតំបន់ទាំងនេះត្រូវបានសងមកវិញដោយប្រទេសសៀម (មិនទទួល | គ្មាន | គ្មាន (១) | -អនុក្រឹត្យរបស់ G-G ចុះថ្ងៃទី២ – ១១–១៨៩៩ ដើម្បីបង្កើតស្នងការដ្ឋានដារឡាក់ភ្ជាប់ទៅប្រទេសលាវ ។ -អនុក្រឹត្យរបស់G-G ចុះថ្ងៃទី២១–១១–១៩០៤ភ្ជាប់ដារឡាក់ទៅឲ្យរដ្ឋការរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់ | ? | អគ្គទេសាភិបាល P.Beau បានឲ្យការណ៍នៅក្នុងឆ្នាំ១៩០៥ថា "រដ្ឋាភិបាលនិងប្រជាជនកម្ពុជាបានធ្វើការតវ៉ានៅគ្រប់កាលៈទេសៈទាំងអស់ដែលគេនឹងបានឃើញដោយក្ដីសប្បាយរីករាយនូវការត្រឡប់ |



| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ស្គាល់តាមគំនូសបច្ចុប្បន្ន) -ការបែងចែកដោយរំលោភដែលជាលទ្ធផលនៃបំណងដើម្បីបង្កើតនូវមណ្ឌលរដ្ឋបាលរួបរួមគ្នានៅតំបន់ខ្ពស់ ។ | | | នៅអណ្ណាម -អនុក្រឹត្យរបស់ G-G ចុះថ្ងៃទី៣០–៤–១៩២៩ ដែលឲ្យសច្ចាប័នដោយក្រឹត្យចុះថ្ងៃទី១២ -៤– ១៩៣២ ស្ដីអំពីការបញ្ចូលទៅឲ្យអណ្ណាមនូវខេត្តដារឡាក់ | | មកវិញនូវសភាពធម្មតា" (i.e. ការសងមកឲ្យប្រទេសកម្ពុជានូវទឹកដីខ្មែរនៅត្រើយខាងស្ដាំនៃទន្លេមេគង្គដែលសៀមបានយកនៅក្នុងឆ្នាំ ១៨៩៣ ) ។ |
| ត្រើយខាងស្ដាំនៃទន្លេមេគង្គ (នៅចន្លោះទន្លេនេះនិងភ្នំដងរែក) ។ | – ស្រុក<br>– ជុន ចុង<br>– ប៉ា សា<br>– ស៊ូ យូម<br>– អ៊ូ ធូម<br>– មូឡាពូណុក<br>– សាជាង់កូហ្វា | -ដោយប្រយោលៈ ការងាររបស់បេសកកម្ម Dou-dart de La grée (cf ខាងលើ) មិនទទួលស្គាល់តាមគំនូសបច្ចុប្បន្ន | គ្មាន | គ្មាន (១) | -អនុក្រឹត្យរបស់ G-G ចុះថ្ងៃទី១២–៣–១៩០៥ -អនុក្រឹត្យចុះថ្ងៃទី ១៦–៥–១៩០៥ ស្ដីពីការភ្ជាប់ស្រុកនានារបស់ប្រទេស | ? | ? (១) |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | -សេឡាមចាវ់ | | | | កម្ពុជាទៅឲ្យខេត្តចាសាក់ (លាវ) | | |
| ព្រៃដែនវាងតាន អាន - ត្រាង បាង និងតៃនិញមួយ-ផ្នែក និងស្វាយរៀង,ព្រៃវែង, កំពង់ចាមមួយផ្នែកទៀត ។ | -ទឹកដីទាំងអស់នៅខាងជើងប៉ុស្តិ៍តៃនិញជាពិសេសចុង-បាដែន,បឹង, ជ្រូម,ស្រុកត្រាញ់ -ចំរៀកដីទាំងពីរដែលចាប់បញ្ចូលមួយផ្នែកវាងព្រៃដែនបច្ចុប្បន្ននិងទន្លេវ៉ៃគោខាងកើត,មួយផ្នែក | ដោយផ្ទាល់ៈរបាយការណ៍ឯកតោភាគីរៀបចំឡើងនិងគំនិតផ្តួចផ្តើមដោយអាជ្ញាធររបស់បារាំងនៅកូសាំងស៊ីន ។ | គ្មាន (អនុសញ្ញាចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៨៧៣ ផ្តល់សច្ចាប័ននៅពេលក្រោយនៃគំនូសដែលបានបង្កើតឡើង ។ | គ្មាន | សេចក្តីសម្រេចរបស់G-R កូសាំងស៊ីនចុះថ្ងៃទី៩-៧-១៨៧០ , **ក/** បញ្ជាក់អំពីការបោះគោលដីដែលធ្វើឡើងវាងបង្គោលលេខ១ និង លេខ១៦ **ខ/** គ្រោងទុកជាមុនអំពីការបោះគោលដីថ្មីចាប់ពីបង្គោលលេខ១៧ ដែលបានយល់ព្រមដោយព្រះ | ដោយមានការចូលរួមរបស់ស្នងការកម្ពុជានៅក្នុងឆ្នាំ ១៨៧០សម្រាប់ផ្នែកដែលផ្តល់សច្ចាប័នដោយសេចក្តីសម្រេចចុះថ្ងៃទី ៩ - ៧ - ១៨៧០ ដោយគ្មានការចូលរួមពីភាគីខ្មែរនិងទៅតាមការចង្អុល | ការតវ៉ារបស់អាជ្ញាធររដ្ឋបាលបឹងជ្រូម ។ ការបដិសេធការធ្វើសហប្រតិបត្តិការរបស់ស្នងការកម្ពុជា នៅក្នុងអំឡុងពេលកាត់យកទឹកដីនៅឆ្នាំ ១៨៧០ ការតវ៉ារបស់ព្រះមហាក្សត្រនៅពេលដែលព្រះអង្គបានដឹងឮលទ្ធផលការងារ |



| | | | | | | | |
|---|---|---|---|---|---|---|---|
| | ទៀតវាងព្រៃដែនបច្ចុប្បន្ននិងទន្លេវ៉ៃគោខាងលិច ។ | | | | មហាក្សត្រនៃប្រទេសកម្ពុជា ។ | បង្ហាញរបស់អ្នកស្រុកអណ្តូមចាប់ពីបង្គោលលេខ ១៧ ។ | បោះគោលដី ។ |
| ព្រៃដែនវាងធ្លូយ៉ូវម៉ូត មួយផ្នែក កំពង់ចាមនិងក្រចេះមួយផ្នែក ។ | ស្រុក : - ថាញ់អាន ,- គូអាន, - មិញ ផាំយ , - ឡុក និញ , - ភ្មៀក ឡេ , - ក្វាង ឡើយ | ដែនទីដែលគូរឡើងជាឯកតោភាគីដោយផ្នែកភូមិសាស្ត្ររបស់ G.G នៅឆ្នាំ ១៨៩០ ។ - ការបំបាត់ចោលដោយរំលោភតាមបញ្ជារបស់G.G (អគ្គទេសាភិបាល) de Lannessan នូវបង្គោលលេខ១ ដែលរៀបចំឡើង | គ្មាន | ព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤ | -អនុក្រឹត្យរំលោភរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី២២-៧-១៨៩៣ -អនុក្រឹត្យរបស់ G.G ចុះថ្ងៃ៣១-៧-១៩១៤ ផ្តល់សច្ចាប័នដោយក្រឹត្យចុះថ្ងៃទី២០-៩-១៩១៥ ដោយធ្វើនិយតកម្មតាម | ធ្វើឡើងដោយឯកតោភាគីពីអាជ្ញាធរបារាំង | ការចលាចលនិងការបះបោររបស់ប្រជាជនកម្ពុជាដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធដោយរំលោភ ។ ការតវ៉ាដោយហិង្សារបស់លោករ៉េស៊ីដង់ជាន់ខ្ពស់ de Verneville និយាយក្នុងនាម |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | នៅក្នុងឆ្នាំ ១៨៧០ ដែលត្រូវដាក់សញ្ញាការចេញដំណើរព្រំដែន ។ – ការងាររបស់គណៈកម្មការចម្រុះឆ្នាំ១៩១០ ដែលទប់ការពិនិត្យកត់ត្រានូវសភាពនៃការពិតដែលជាលទ្ធផលនៃការរំលោភរបស់កូសាំងស៊ីន ។ | | | ការពិតនូវការរំលោភទាំងឡាយដែលធ្វើឡើងតាមទម្លាប់ពីមុន ។ | | អាជ្ញាធរកម្ពុជា។ |
| ព្រំដែនរវាង.................................... មួយផ្នែក | – ត្រាជី , ចុងបាដែន,បឹងជ្រិម ,ស្រុកត្រាញ់ – | ដោយផ្ទាល់ : របាយការណ៍របស់បារាំង នៅកូសាំងស៊ីន ។ | អនុសញ្ញាជាឯកតោភាគីនៃគំនូសព្រំដែនដែលបាន | គ្មាន | គ្មាន.................................... ៧........ការបោះ | ដោយមានការចូលរួម.................................... | ការទាមទាររបស់ ព្រះមហាក្សត្រ.......................... |



| | | | | | | | |
|---|---|---|---|---|---|---|---|
| – ស្វាយរៀង – ព្រៃវែង និង កំពង់ចាម មួយផ្នែកទៀត | ចំរៀកដីទាំង២ ដែលរាប់បញ្ចូលមួយផ្នែករវាងព្រំដែនបច្ចុប្បន្ននិងទន្លេវ៉ៃគោខាងកើតមួយផ្នែកទៀតរវាងព្រំដែនបច្ចុប្បន្ននិងទន្លេ វ៉ៃគោខាងលិច | | បង្កើតឡើង ។ | | គោលដីដែលរៀបចំឡើងរវាងបង្គោលលេខ១១និងលេខ១៦ ៧ ការគ្រោងទុកជាមុននូវការបោះគោលដីថ្មីចាប់ពីបង្គោលលេខ១៧ ដែលយល់ព្រមដោយព្រះមហាក្សត្រប្រទេសកម្ពុជា ។ | ផ្តល់សច្ចាប័នដោយសេចក្តីសម្រេចចុះថ្ងៃទី៩–៣–១៨៧០ ដោយគ្មានការចូលរួមពីភាគីខ្មែរនិងនៅលើការចង្អុលបង្ហាញរបស់អ្នកស្រុកអណ្តូមចាប់ពីបង្គោលលេខ១៧។ | ព្រះរាជតវ៉ានៅពេលដែលត្រូវបានស្គាល់លទ្ធផលនៃការងារបោះគោលដី ។ |
| ព្រំដែនរវាងធ្លុយ៉ូវម៉ូតមួយផ្នែកកំពង់ចាមនិងក្រចេះមួយផ្នែកទៀត | ស្រុក : – ថាន់ អាន , – គូ អាន , – មិញ ផាំយ , – ឡុក និញ , | ដែនទីដែលគូរជាឯកតោភាគីដោយក្រុមការងារភូមិសាស្ត្ររបស់ G.G នៅឆ្នាំ ១៨៩០ – ការបំបាត់ចោល | គ្មាន | ព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនាឆ្នាំ១៩១៤ | –អនុក្រឹត្យរំលោភរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី ២២ – ៣ – ១៨៩៣ អនុក្រឹត្យរបស់ G.G ចុះថ្ងៃ | ជាឯកតោភាគីដោយអាជ្ញាធរបារាំង | ការចលាចលនិងការបះបោររបស់ប្រជាជនកម្ពុជាដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធដោយ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | - ភ្លើក ឡេ<br>- ក្វាង ឡើយ | ដោយរំលោភតាមបញ្ញារបស់ G.G de Lannessan នូវបង្គោលលេខមួយដែលរៀបចំឡើងនៅក្នុងឆ្នាំ ១៨៧០ ដែលត្រូវឲ្យសញ្ញានៃការចេញដំណើររបស់ព្រំដែន ។<br>-ការងាររបស់គណៈកម្មការចម្រុះនៅឆ្នាំ ១៩១០ ដែលទប់ការពិនិត្យកត់ត្រាសភាពនៃហេតុការណ៍ដែលជា | | | ទី៣១ ខែកក្កដា ១៩១៤ឲ្យសច្ចាប័នដោយក្រឹត្យចុះថ្ងៃទី២០-៩-១៩១៥ ដោយធ្វើនិយតកម្មហេតុការណ៍នៃការរំលោភដែលធ្វើឡើងតាមទម្លាប់ពីមុន | | រំលោភ ។ ការគាំដោយហិង្សារបស់លោករ៉េស៊ីដង់ ជាន់ខ្ពស់ de Verneville ដែលនិយាយក្នុងនាមអាជ្ញាធរកម្ពុជា ។ |



| | | | | | | | |
|---|---|---|---|---|---|---|---|
| | | លទ្ធផលនៃការរំលោភរបស់កូសាំងស៊ីន ។ | | | | | |
| ព្រំដែនរវាងចូវដុកនិងហាទៀនមួយផ្នែកព្រៃវែង,កណ្ដាល, តាកែវនិងកំពតមួយផ្នែកទៀត<br>**ក/** ដំណាក់កាលទី១<br>**ខ/** ការកែតម្រូវជាខាងក្រោយ – រវាងបង្គោល៨៣ទៅ ៨៨ – រវាងបង្គោល៨៨ | - ត្រាជី ,<br>- ចំរៀកដីរវាងគំនូសព្រំដែនបច្ចុប្បន្ន និងព្រែកដីកវីញតេ<br>- ខេត្តហាទៀន<br><br>គ្មានការប្រៀបធៀបទៅនឹងដំណាក់កាលទី១ (ការដាំបង្គោល | ដោយផ្ទាល់ : របាយការណ៍ជាឯកតោភាគីរៀបចំឡើង និងតាមគំនិតផ្ដួចផ្ដើមដោយអាជ្ញាធរបារាំងនៅកូសាំងស៊ីន ។<br><br>ការងាររបស់គណៈកម្មការចម្រុះមួយ | អនុសញ្ញាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៧៣ រវាងព្រះករុណានរោត្តម និងទេសាភិបាលកូសាំងស៊ីន<br><br>គ្មាន | គ្មាន<br><br>គ្មាន (១) | គ្មាន<br><br>អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី ៦-១២-១៩៣៥ | ដោយមានការចូលរួមរបស់ស្នងការកម្ពុជា | ការទាមទាររបស់ព្រះករុណានរោត្តមនៅអមឧត្ដមនាវី de la Grandière |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ទៅ១០៧ (កោះគគីរ) – វាំងជាយនៃខ្សែទូរលេខយ៉ាងថាញ់-ហាទៀន | ដែលនៅក្នុងចន្លោះ) | | | | | | |
| | កោះគគី | | គ្មាន | ក្រមចុះថ្ងៃទី ២៩ ១០ ១៩៤២ | អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី ២៦-៧-១៩៤២ | | |
| | ឃុំ : – កោះចន្លុះ – សាគី | ដែនទីរំលោភទឹកដីខ្មែរគូរឡើងនៅក្នុងឆ្នាំ១៨៩១ – ការផារទុកសម្រាប់ច្បាប់ប្រទេសកម្ពុជារបស់គណៈកម្មការឆ្នាំ ១៨៩៦ (មិនស្គាល់) – ការ | គ្មាន | ព្រះរាជប្រកាសចុះថ្ងៃទី១២ ខែមីនាឆ្នាំ១៩១៤ | អនុក្រឹត្យរបស់ G- G ចុះថ្ងៃ ៣១-៧-១៩១៤ | | អាកប្បកិរិយាតវ៉ារបស់រ៉េស៊ីដង់បារាំងនិយាយក្នុងនាមអាជ្ញាធរកម្ពុជា ។ |



| | | | | | | | |
|---|---|---|---|---|---|---|---|
| | | បញ្ជាក់ដោយភូតកុហករបស់គណៈកម្មការឆ្នាំ១៩១១ | | | | | |
| ព្រំដែនសមុទ្រ | | -ការជជែករកខុសត្រូវវាំងអាជ្ញាធរបារាំង នៅកូសាំងស៊ីននិងនៅប្រទេសកម្ពុជាឆ្នាំ១៩១៣ | គ្មាន | គ្មាន | សារាចររបស់ G.G Brévié ចុះថ្ងៃ៣១-១-១៩៣៩ | | ការបញ្ជាក់មិនឈប់របស់អាជ្ញាធរខ្មែរ និងបារាំងអាណាព្យាបាលនៃអធិបតេយ្យភាពកម្ពុជាស្តីពីកោះទាំងឡាយ |

(១) នៅក្នុងសភាពបច្ចុប្បន្ន នៃការស្រាវជ្រាវរបស់យើង តារាងលេខ ១

| ច្បាប់គតិយុត្ត | ការប្រាប់លក្ខណៈជាក់លាក់ | លក្ខណៈពិតប្រាកដនៃប្រតិបត្តិការ | លក្ខខណ្ឌធ្វើអន្តរាគមន៍នៃច្បាប់ | តម្លៃនៃច្បាប់ក្នុងនាមដែលវាទាមទារបង្កើតព្រំដែនអន្តរជាតិដែលគួរយកជាការបាន |
|---|---|---|---|---|
| អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី៣០ – ៤– ១៩២៩ | – ការបញ្ចូលដាវឡាក់នៅក្រោមអធិបតេយ្យភាពអណ្ណាម<br>– ការសងទូទាត់នៃការកំណត់ឲ្យប្រទេសលាវនូវទឹកដីស្ថិតនៅក្នុងចំណុចនៃរាជាធិរាជ(សាមឡើ) | – ការកំណត់ឲ្យប្រទេសអណ្ណាមនូវទឹកដីដែលយកចេញពីសៀមនៅក្នុងនាមច្បាប់នៃប្រទេសកម្ពុជា ឆ្នាំ ១៨៩៣ | – ការបម្រុងនូវគណៈកម្មការស៊ើបអង្កេតនៅក្រោមអធិបតេយ្យភាពក្រុមប្រឹក្សារដ្ឋ Richard នៅឆ្នាំ ១៩២៧ ។<br>– មិនបានយកមកពិនិត្យពិចារណានូវច្បាប់នៃប្រទេសកម្ពុជាដែលបានសំអាងនៅក្នុងឆ្នាំ១៨៩៣។ | ភាពជាមោឃ :– ចំពោះការខុសឆ្គងនៅលើមូលហេតុ : មិនមានទាំងការបញ្ចូលមិនមានទាំងការសងទូទាត់ និងការរំលោភដោយប្រយោលនៃអនុសញ្ញាបារាំង – សៀម ឆ្នាំ ១៨៩៣ ។ |
| អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី២១–០៣–១៩០៥ | – ការកំណត់ព្រំដែនទឹកដីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្របាសាក់ ។ | – ការភ្ជាប់តាមរដ្ឋបាលទៅឲ្យប្រទេសលាវ នូវទឹកដីដែលគេស្គាល់ថាជាទឹកដីកម្ពុជា ។ | – ការពិនិត្យពិចារណាតាមលំដាប់រដ្ឋបាលសុទ្ធសាធ ។ | ភាពជាមោឃ:<br>– ចំពោះភាពផ្ទុយគ្នារវាងឧបករណ៍គតិយុត្តទាំងពីរ និងការរំលោភ |



| ច្បាប់គតិយុត្ត | ការប្រាប់លក្ខណៈជាក់លាក់ | លក្ខណៈពិតប្រាកដនៃប្រតិបត្តិការ | លក្ខខណ្ឌធ្វើអន្តរាគមន៍នៃច្បាប់ | តម្លៃនៃច្បាប់ក្នុងនាមដែលវាទាមទារបង្កើតព្រំដែនអន្តរជាតិដែលគួរយកជាការបាន |
|---|---|---|---|---|
| អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី ១៦–៥–១៩០៥ | – ការភ្ជាប់ទៅឲ្យខេត្តបាសាក់នូវស្រុកកម្ពុជា | | –មិនបានយកមកពិចារណាអំពីច្បាប់ទាំងឡាយរបស់កម្ពុជាដែលបានសំអាងប្រឆាំងសៀមនៅក្នុងអំឡុងការចរចាឆ្នាំ១៩០៤ ។ | អនុសញ្ញាបារាំង–សៀមចុះថ្ងៃទី ១៣–២–១៩០៤ |
| សេចក្តីសម្រេចរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី៩–៧–១៨៧០ ចុះក្នុងអនុសញ្ញា ថ្ងៃទី ១៥–៧–១៨៧៣ ឡើងវិញ ។ | – ការកំណត់ព្រំដែននៅលើមូលដ្ឋានច្បាប់ដែលមានស្រាប់ (ច្បាប់ដែលមានការប្រកាស)។<br>– ការប្តូរ | – ការកំណត់ទៅឲ្យកូសាំងស៊ីន នូវទឹកដីកម្ពុជា | – ការងារជាឯកតោភាគីរបស់ភ្នាក់ងារបារាំង ។<br>– ការគំរាមប្រឆាំងមន្ត្រីកម្ពុជា ។ | ភាពជាមោឃ :<br>– ចំពោះការខុសឆ្គងស្តីពីច្បាប់របស់កម្ពុជា<br>– ចំពោះការខុសឆ្គងស្តីពីមូលហេតុ (គ្មានការប្តូរ)<br>– ចំពោះការរំលោភ<br>– ចំពោះការរំលោភនៃសន្ធិសញ្ញាបារាំង–សៀមឆ្នាំ១៨៦៧ ហាមឃាត់ការ |

| | | | | |
|---|---|---|---|---|
| | | | | បញ្ចូលជាឧបសម្ព័ន្ធទៅឲ្យកូសាំងស៊ីនទូទឹកដីកម្ពុជា។<br>-ចំពោះការមិនស្គាល់នៃច្បាប់របស់ប្រជាជនដែលចាត់ចែងដោយខ្លួនឯង (ការប្រែចាំងក្នុងស្រុក) |
| អនុក្រឹត្យរបស់ទេសាភិបាលកូសាំងស៊ីនចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៨៩៣<br>- តាមការណ៍ពិតយកទៅដាក់ឡើងវិញនៅក្នុងអនុក្រឹត្យរបស់ G.G ចុះថ្ងៃទី ៣១-០៧-១៩១៤ (នៅក្នុងមាត្រា៣របស់អនុក្រឹត្យនេះមានការទាក់ទងទៅនិងសង្កាត់ឡុកនិញ និង ភៀក ឡេ) | - ការប្រជុំឡើងវិញនៅក្នុងមណ្ឌលរដ្ឋបាលកូសាំងស៊ីនទូវសង្កាត់កម្ពុជា និង"ស្ទៀង"<br>- ការកំណត់ព្រំដែននៅលើមូលដ្ឋាននៃច្បាប់ដែលមានស្រាប់ (ច្បាប់ដែលបានប្រកាស) | - អំពើរំលោភរបស់អាជ្ញាធរដែលគ្មានសមត្ថភាពទាំងស្រុង<br>- ការឲ្យសច្ចាប័នទៅលើការដណ្តើមមួយដោយរំលោភ ។ | - ការផ្លាស់ប្តូរកន្លែងបង្គោលព្រំដែនដោយរំលោភ ។<br>- ការរំលោភអំណាចដោយចង្អុលលក្ខណៈបង្កឲ្យមានចលាចល និង ការបះបោរ ។<br>- យោបល់របស់គណៈកម្មការមួយដែលពិនិត្យកត់ត្រាសភាពនៃហេតុការណ៍ដែលលទ្ធផលនៃ | ភាពជាមោឃៈ<br>- ចំពោះអសមត្ថភាពរបស់ទេសាភិបាលកូសាំងស៊ីន (ច្បាប់ដែលពុំមានស្រាប់)<br>- ចំពោះការបន្លំលួច (ផ្លាស់កន្លែងបង្គោលព្រំដែន ) ។<br>-ចំពោះការរំលោភនៃសន្ធិសញ្ញាបារាំង,សៀម ឆ្នាំ ១៨៦៧ ។ |



| | | | | |
|---|---|---|---|---|
| | | | សកម្មភាពជាដាច់ការស្រាវជ្រាវច្បាប់របស់ភាគីទាំងឡាយ ។ | - ចំពោះកំហុសធ្ងន់ (គណៈកម្មការពិនិត្យកត់ត្រាសភាពនៃហេតុការណ៍ជាដាច់ការស្រាវជ្រាវច្បាប់ ) ។<br>- ចំពោះភាពមិនអាចទៅរួចនៃការបញ្ជាក់នូវច្បាប់ ។ គតិយុត្តិដែលមិនមាន ។<br>- ចំពោះការមិនទទួលស្គាល់នៃគោលការណ៍ច្បាប់របស់ប្រជាជនដែលត្រូវរៀបចំដោយខ្លួនឯង (ការបះបោរ) ។<br>-ចំពោះការមិនទទួលស្គាល់នូវការទាមទារច្បាប់ផ្ទៃក្នុងរបស់បារាំង |

| | | | | |
|---|---|---|---|---|
| | | | | (ភាពចាំបាច់នៃច្បាប់មួយ ដើម្បីប្រកាសនូវការបញ្ចូលជាឧបសម្ព័ន្ធក្រោយឆ្នាំ ១៨៧៥ ) ។ |
| អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ (នៅក្នុងការរៀបចំរបស់ខ្លួនដែលទាក់ទងទៅនឹងខ្សែព្រំដែនហាទៀន យ៉ាងថាញ់) ។ | - ការសងទៅឲ្យកូសាំងស៊ីននូវតំបន់ដែលត្រូវបញ្ចូលជាឧបសម្ព័ន្ធតាមហេតុការណ៍ពិតដោយប្រទេសកម្ពុជា<br>- ការប្តូរ (ដោយមិនបានចែងឲ្យច្បាស់) ។ | - ការកាត់យកដោយសុទ្ធសាធ និងងាយស្រួលនូវទឹកដីកម្ពុជា ។ | - ការអះអាងដោយភូតកុហកស្តីពីការផ្លាស់កន្លែងខ្សែទូរគមនាគមន៍ដែលបម្រើធ្វើជាខ្សែបន្ទាត់ព្រំដែន ។<br>- ការក្លែងដោយបន្លំនូវលទ្ធផលនៃគណៈកម្មការស៊ើបអង្កេតឆ្នាំ១៨៩៦។ | ភាពជាមោឃៈ<br>- ចំពោះការលួចបន្លំ<br>- ចំពោះភាពមិនមាននៃមូលហេតុ ។<br>- ចំពោះការរំលោភសន្ធិសញ្ញា ឆ្នាំ ១៨៦៧ ។<br>- ចំពោះការមិនទទួលស្គាល់នូវការទាមទារនៃច្បាប់ជ្រែកក្នុងរបស់បារាំង។ |
| អនុក្រឹត្យរបស់ G.G ចុះថ្ងៃទី ៦-១២-១៩៣៥ ។ | -ច្បាប់បញ្ជាក់អំពីគំនូសព្រំដែនដែលជាលទ្ធផលនៃអនុសញ្ញាឆ្នាំ១៨៧៣ ។ | | | -Cf- តម្លៃនៃអនុសញ្ញាឆ្នាំ ១៨៧៣ ។ |
| អនុក្រឹត្យរបស់ G.G ចុះ | - ការប្តូរ | - ការកាត់យកទឹកដីខ្មែរ | ការបំពេញចិត្តផ្តល់ឲ្យ | ភាពជាមោឃៈ |



| | | | | |
|---|---|---|---|---|
| ថ្ងៃទី២៦-៧-១៩៤២ ។ | | ដោយគ្មានការសងទូទាត់គួរទទួលបាន<br>- ការប្រឆាំងភាគីដែលស្ថិតនៅក្នុងច្បាប់របស់កម្ពុជារួចហើយ ។ | តាមការទាមទាររបស់អណ្ណាម ។ | - ចំពោះកំហុសធ្ងន់នៅលើមូលហេតុ : មិនមែនជាការសងទូទាត់ទេ ប៉ុន្តែគឺជាការបញ្ចូលជាឧបសម្ព័ន្ធ ។<br>- ភាពជាមោឃៈដែលមិនអាចទៅរួចចំពោះការបញ្ចូលជាឧបសម្ព័ន្ធនៃចំណែកតូចនៃទឹកដីកម្ពុជាដោយមូលហេតុនៃអនុសញ្ញាឆ្នាំ១៨៦៧។ |
| សារាចររបស់Brévié ចុះថ្ងៃទី៣១-១-១៩៣៩ | មិនដែលបានអះអាងទាមទាររៀបចំព្រំដែនទឹកដីឡើយ | | | |

**តារាងលេខ ២**

## I. អត្ថបទនៃឯកសារឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ១

### ***អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩០៤ ភ្ជាប់មកឲ្យទឹកដីប្រទេសកម្ពុជានូវខេត្តស្ទឹងត្រែង (ប្រទេសលាវ) ។***

*(សៀវភៅកត់ហេតុការណ៍ជាផ្លូវការនៅឥណ្ឌូចិនថ្ងៃទី១៥ខែធ្នូឆ្នាំ១៩០៤ទំព័រ១៥០០) ។*

អគ្គទេសាភិបាលឥណ្ឌូចិន officier de la legion d'honneur ។

- បានឃើញក្រឹត្យ ចុះថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៨៩១ ។

- បានឃើញសេចក្ដីប្រកាសចេញផ្សាយដោយក្រុមប្រឹក្សាជាន់ខ្ពស់ឥណ្ឌូចិន នៅក្នុងសម័យប្រជុំថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩០៤ ។

- គណៈកម្មការអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាជាន់ខ្ពស់ឥណ្ឌូចិនដែលបានព្រមព្រៀងហើយ ។

### សម្រេច

**មាត្រា១ –** ត្រូវបានប្រគល់ទៅក្នុងទឹកដីរបស់ប្រទេសកម្ពុជាវិញ នូវខេត្តស្ទឹងត្រែងដែលបច្ចុប្បន្នស្ថិតនៅក្នុងចំណុះប្រទេសលាវ : តិចជាងមួយភាគនៃទឹកដីដែលស្ថិតនៅត្រើយខាងស្ដាំ នៃព្រែកឈ្មោះ អិន.ថាម (N.Thamm) (ផែនទីនៃក្រុមភូមិសាស្ត្រឥណ្ឌូចិន តាមមាត្រាដ្ឋាន ១/១.០០០.០០០ បោះពុម្ពផ្សាយ ខែមេសា ឆ្នាំ ១៩០៣) ដែលនៅក្នុងនោះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមចំណុះរដ្ឋបាលនិងនយោបាយរបស់អណ្ណាម ។

**មាត្រា២ –** តំបន់ដែលហៅថា សៀមប៉ាង (Siem Pang) ដែលព្រំដែនខាងកើតនិងខាងជើងត្រូវបានចង្អុលបង្ហាញដោយពណ៌លឿងនៅលើផែនទីតាមមាត្រាដ្ឋាន ១/៣.០០០.០០០ ដែលត្រូវបានបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងអនុក្រឹត្យបច្ចុប្បន្នត្រូវបានផ្ដាច់ចេញនូវខេត្ត ខុង (Khong) (ប្រទេសលាវ) និងត្រូវបានបញ្ចូលជាថ្មីទៅក្នុងទឹកដីនៃខេត្តស្ទឹងត្រែង ។



**មាត្រា៣ –** លោករ៉េស៊ីដង់ជាន់ខ្ពស់ទាំងឡាយនៅអណ្ណាម នៅប្រទេសកម្ពុជា និងនៅប្រទេសលាវ នឹងបង្កើតដោយការព្រមព្រៀងគ្នានូវគម្រោងនៃបទបញ្ញាដែលទាក់ទងទៅនឹងការកំណត់ព្រំដែននៅលើទឹកដីរបស់មណ្ឌលជាសាមី ។

**មាត្រា ៤ –** លោកអគ្គលេខាធិការឥណ្ឌូចិន លោករ៉េស៊ីដង់ជាន់ខ្ពស់នានានៅអណ្ណាមនៅប្រទេសកម្ពុជា និងនៅប្រទេសលាវ ត្រូវទទួលបន្ទុករៀងៗខ្លួនក្នុងការអនុវត្តនូវអនុក្រឹត្យនេះ ។

**ជូនលោក អគ្គទេសាភិបាល**

**BEAU**

**អគ្គលេខាធិការឥណ្ឌូចិន**

**BRONI**

---

## ឧបសម្ព័ន្ធ ២

### ***អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន លេខ ២១៦ ៩ bis ចុះថ្ងៃទី៣០-៤-១៩២៩***

*(សៀវភៅកត់ហេតុជាផ្លូវការចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ ១៩០៤ ទំព័រ ១៤៤៦ ) ។*

- បានឃើញក្រឹត្យចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ១៩១១ ស្ដីពីការកម្រិតអំណាចរបស់អគ្គទេសាភិបាល និងការរៀបចំហិរញ្ញវត្ថុ និងរដ្ឋបាលនៅឥណ្ឌូចិន ។

- បានឃើញក្រឹត្យចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩២៨ ។

- បានឃើញក្រឹត្យចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤ ស្ដីពីការបំបែកចេញពីប្រទេសលាវ នូវខេត្តដារឡាក់ ។

- បានឃើញក្រឹត្យចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ១៩១៥ ដែលបានយល់ព្រមចំពោះការប្ដូរនេះ ។

- បានឃើញអនុក្រឹត្យចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ១៩១៥ ។

- បានឃើញអនុក្រឹត្យ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩២៣ ស្ដីពីការលុបមណ្ឌល

រដ្ឋបាល បានមេធ្ងួតនិងកសាងដារឡាក់ឲ្យទៅជាខេត្ត ។

- បានឃើញកំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

តាមការស្នើរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅអណ្ណាម នៅក្នុងក្រុមប្រឹក្សាអាណាព្យាបាល ។

គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាទេសាភិបាលបានយល់ព្រមហើយ ។

**សម្រេច**

**មាត្រា ១ –** អនុក្រឹត្យចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤ ត្រូវបានទុកជានិរាករ ។

**មាត្រា ២ –** ខេត្តដារឡាក់ ត្រូវបានបញ្ចូលឡើងវិញ ទៅក្នុងទឹកដីអណ្ណាម ។

**មាត្រា ៣ –** អគ្គលេខាធិការ នៃអគ្គទេសាភិបាលឥណ្ឌូចិន និងលោករ៉េស៊ីដង់ ជាន់ខ្ពស់នៅអណ្ណាមត្រូវទទួលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះរៀងៗខ្លួន ។

***សាយហ្គន ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩២៩***

---

## ឧបសម្ព័ន្ធ ៣

***អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២៨ មីនា ឆ្នាំ ១៩០៥ កំណត់ព្រំដែនទឹកដី រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្របាសាក់ (លាវ) ។***

*(សៀវភៅកត់ហេតុការណ៍ជាផ្លូវការនៅឥណ្ឌូចិនចុះថ្ងៃ ៦-៤-១៩០៥ ទំព័រ៤៥៣ ) :*

អគ្គទេសាភិបាលឥណ្ឌូចិន officier de la légion d'honneur ។

- បានឃើញក្រឹត្យចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៨៩១ ។

- បានឃើញអនុក្រឹត្យចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៨៩៩ កំណត់នូវការសន្មតអំពីការងារទូទៅ និងការងារក្នុងស្រុកនៅឥណ្ឌូចិន និងការទាក់ទងគ្នារវាងការងារទាំងនេះ :

- ការឃើញអនុសញ្ញា បារាំង-សៀម ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩០៤ ។



តាមការស្នើរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា និងនៅប្រទេសលាវ នឹងយោបល់ស្របរបស់អគ្គលេខាធិការឥណ្ឌូចិន ។

-គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាន់ខ្ពស់នៅឥណ្ឌូចិនបានយល់ព្រមរួចហើយ:

**សម្រេច**

**មាត្រា១ –** ព្រំដែនទឹកដីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រ បាសាក់ (លាវ) នៅត្រើយខាងស្តាំនៃទន្លេមេគង្គ ផ្នែកនៃមាត់ពាមនៅក្នុងទន្លេនេះ នៅព្រែកសេឡាមបាំវ (ឬទន្លេរពៅ) ឡើងទៅដៃដីសំខាន់នៃព្រែកនេះ ដែលតម្រង់ស្មើរតែធម្មតាទៅរកភ្នំដងរ៉ែក និងបញ្ចប់នៅទិសពាយ័ព្យនៃច្រកភ្នំព្រាចំបក់ ។

**មាត្រា២ –** លោកអគ្គលេខាធិការឥណ្ឌូចិន និងលោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា និងនៅប្រទេសលាវត្រូវទទួលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះរៀងៗខ្លួន ។

**ហាណូយថ្ងៃទី ២៨ ខែមីនា ឆ្នាំ១៩០៥**

**ជួសអគ្គទេសាភិបាល** : BEAU
**អគ្គលេខាធិការឥណ្ឌូចិន** : BRONI
**រ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសលាវ** : MAHE
**រ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា:** MOREL

---

## ឧបសម្ព័ន្ធ ៤

***អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩០៥ ស្តីពីការភ្ជាប់ស្រុកផ្សេងៗរបស់កម្ពុជា ទៅឲ្យខេត្តបាសាក់ (ប្រទេសលាវ ) ។***

*(សៀវភៅកត់ហេតុការណ៍ផ្លូវការនៅឥណ្ឌូចិនថ្ងៃទី២៥ ឧសភា១៩០៥ ទំព័រ៦៩២) ។*

អគ្គទេសាភិបាលឥណ្ឌូចិន officier de la légion d'honneur ។

- បានឃើញក្រឹត្យចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៨៩១ ។

- បានឃើញអនុសញ្ញាបារាំង-សៀម ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩០៤ ។
- បានឃើញអនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ១៩០៥ ស្ដីពីការកំណត់ព្រំដែនទឹកដីរវាងព្រះរាជាណាចក្របាសាក់ (ប្រទេសលាវ) នៅលើត្រើយខាងស្តាំទន្លេមេគង្គ ។
- តាមការស្នើរបស់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសលាវ និងយោបល់ស្រប របស់អគ្គលេខាធិការឥណ្ឌូចិន ។
- គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាន់ខ្ពស់ឥណ្ឌូចិនបានយល់ព្រមរួចហើយ។

## សម្រេច

**ប្រការ១ –** ស្រុក ផុនថុង (Phon Thong) , ប៉ាសា (Pasah) , ស៊ូ ឃូម (Soukhoume), អ៊ូធូម(Outhoum) , មូឡាពូមុក (Moulapoumouk) , សាផាង ភូហ្វា (Saphangphoufa) និងសេឡាមប៉ាវ (Selampao) ខាងជើងត្រូវបានភ្ជាប់នៅឲ្យខេត្តបាសាក់ (លាវ) ។

**មាត្រា២ –** លោកអគ្គលេខាធិការឥណ្ឌូចិន និងលោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសលាវ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះរៀងៗខ្លួន ។

**ហាណូយ ថ្ងៃទី១៦ ឧសភា ១៩០៥**

**BEAU**

**ជួសអគ្គលេខាធិការឥណ្ឌូចិន : BRONI**
**រ៉េស៊ីដង់ជាន់ខ្ពស់ប្រទេសលាវ : MAHE**

---

## ឧបសម្ព័ន្ធ ៥

**សេចក្ដីសម្រេចរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៨៧០ ស្ដីអំពីការកំណត់ព្រំដែន នៃប្រទេសកម្ពុជា :**



(ព្រឹត្តប័ត្រផ្លូវការរបស់កូសាំងស៊ីនបារាំងឆ្នាំ ១៨៧០ ទំព័រ ២៤៧ )
ចុះថ្ងៃទី៩កក្កដា ឆ្នាំ ១៨៧០ ។

ឧត្តមនាវីត្រី ទេសាភិបាលស្ដីទី អគ្គមេបញ្ជាការ ។

## សម្រេច

គណៈកម្មការ ក្រោយពីបានពិនិត្យគម្រោងនៃការកំណត់ព្រំដែន ដែលដាក់បង្ហាញនៅក្នុងនាមនៃព្រះមហាក្សត្រ និងគម្រោងដែលត្រូវបានស្នើឡើងដោយគណៈកម្មការមួយរបស់បារាំងបានសម្រេច :

ព្រំដែននៅតែស្ថិតនៅដដែល ដូចដែលបានគូសដោយគ្មានការផ្លាស់ប្ដូរឡើយ ចាប់តាំងពីបង្គោលលេខ១ (នៅមាត់ពាមនៃព្រែកព្រាន) (Prek Prien) រហូតដល់បង្គោលលេខ ១៦ (នៅតាសាងនៅលើ កាយ–កៃយ (Caï - Cay) ។

ទឹកដីដែលស្ថិតនៅរវាង កាយ–បាច់ (Caï - Bach) និងកាយ–កៃយ ដែលស្ថិតនៅក្នុងផ្នែកនៃទឹកដីបារាំង (ហើយដែលផលទុនប្រចាំឆ្នាំ បានកើនឡើងប្រហែល ១.០០០ ហ្វ្រង់) នឹងត្រូវបានយល់ព្រមឲ្យប្រទេសកម្ពុជាជាការសងទូទាត់ទៅនឹងផ្ទះចំនួនប្រហែល ៤៨៦ ដែលបង្កើតបាននូវភូមិទាំងឡាយដែលស្ថិតនៅសុកត្រាញ់ (Soctranh ) និងបាង–ជ្រុម (Bang - Chrum) ។

បង្គោលលេខ ១៧ និងលេខ ១៨ និងបង្គោលតៗទៀត នឹងត្រូវបានលុបចោលរហូតដល់ ហ៊ុង ង្វៀន (Hung Nguyen) ។ ប្រទេសកម្ពុជានឹងរក្សាទុកនៅក្នុងប្រទេសទាំង អស់ដែលបច្ចុប្បន្នរស់នៅដោយប្រជាជនកម្ពុជានូវខេត្តព្រៃវែងបូទីហ្ស៊ុល សុកជៀត។

ព្រំដែននឹងត្រូវបានគូសជាខាងក្រោយ ហើយគេនឹងរក្សាទុកសម្រាប់ជាទឹកដីរបស់បារាំងនូវចំរៀកដី នៅសៀរ តាមបណ្ដោយទន្លេវ៉ៃគោ ដែលត្រូវបានកាន់កាប់ដោយពួកអណ្ណាម ឬក៏ធ្វើអាជីវកម្មដោយពួកគេ ។

**សាយហ្គូនថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៨៧០**

**VIAL RHEINART**

**ដាក់ថ្វាយសុំការយល់ព្រមពីព្រះមហាក្សត្រនៃប្រទេសកម្ពុជា**
**ដាក់ជូនសុំការយល់ ព្រមពីលោកឧត្តមនាវីត្រី ទេសាភិបាល ។**

**យល់ព្រម :** **យល់ព្រម :**
**ព្រះហស្តលេខា : នរោត្តម** **ហត្ថលេខា : DE CORNULIER LUCINIERE**

---

## ឧបសម្ព័ន្ធ ៦

អនុក្រឹត្យស្តីពីសង្កាត់ថាញ់អាន, គូអាន , ក្វាងឡើយ,ឡុកនិញ, ភៀក ឡេ ត្រូវបានប្រមូលផ្តុំទៅជាស្រុកមួយហើយ ដែលត្រូវបានគេឲ្យឈ្មោះថា ស្រុកកាន់ ឡេ ។
(ព្រឹត្តប័ត្រ ផ្លូវការរបស់ឥណ្ឌូចិនបារាំង លេខ៤១០ ឆ្នាំ ១៨៩៣ ទំព័រ ៧៤២) ។

**ចុះថ្ងៃទី២៦ កក្កដា ១៨៩៣**

**ភូឈួយ ទេសាភិបាលកូសាំងស៊ីន**
**– បានឃើញ សេចក្តីត្រូវការនៃការងារ**
**– បានឃើញ សេចក្តីស្នើរបស់អ្នកគ្រប់គ្រង**
**ធូយ៉ូវម៉ុតតាមការស្នើរបស់អគ្គលេខាធិការ**
**ក្រុមប្រឹក្សាឯកជនបានយល់ព្រមរួចហើយ**

### សម្រេច

**មាត្រា១** – សង្កាត់កម្ពុជា ថាញ់អាន សង្កាត់តាមួន និងគូអាន សង្កាត់ ម៉ូយ (moïs) មិនង៉ាយ និងក្វាងឡើយ និងសង្កាត់សៀងឡុកនិញ និង ភៀក ឡេ ត្រូវបានប្រមូលផ្តុំទៅជាស្រុកមួយ ដែលឲ្យឈ្មោះថា ស្រុកកាន់ឡេ (Can - Le) ។

**មាត្រា២** – សង្កាត់ផ្សេងៗទាំងនេះ និងផ្តល់មនុស្សសរុបចំនួន១០នាក់ ដែលនឹងត្រូវបានផ្តាច់ឲ្យធ្វើជាទាហាននៅប៉ុស្តិ៍ត្រួតពិនិត្យកាន់ឡេចាម (Can-Le-Cham) ។



**មាត្រា៣** – សង្កាត់ទាំង ៦ របស់ស្រុកកាន់ឡេ ត្រូវបានអនុញ្ញាតឲ្យរួចពន្ធទាំង អស់ ប៉ុន្តែជាការតបវិញ សង្កាត់ទាំងនោះនឹងត្រូវជម្រះស្មៅ និងជួសជុលផ្លូវថ្នល់ខេត្តក្រចេះចាប់ពីចុនថាញ់ (Chon thanh) រហូតដល់ព្រែកជ្រៀវ (Prec - Chriou) ក្នុងមួយឆ្នាំ៣ដង ។

ពេលវេលាដែលនឹងត្រូវអនុវត្តការងារនេះ គឺនៅខែកុម្ភៈ , សីហា , និងខែវិច្ឆិកា ។

ការថែទាំស្ពាន ការងារសិល្បៈ និងការងារថែទាំ ដែលនឹងទាមទារនូវក្រុមកម្មករពិសេសនឹងត្រូវធ្វើឡើងដោយរដ្ឋការ និងការចំណាយត្រូវបានកាត់យកមុន លើឥណទានថែទាំផ្លូវថ្នល់ធូយ៉ូវម៉ុតទៅក្រចេះ ។

មាត្រា៤ – អគ្គលេខាធិការ ត្រូវទទួលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះ ។

**សាយហ្គន ថ្ងៃទី២៦ កក្កដា ១៨៩៣**
**ជ.ភូឈួយ ទេសាភិបាល**
**J.FOURES**
**អគ្គលេខាធិការ**
**ESCOUBET**

---

## ឧបសម្ព័ន្ធ ៧

**អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤**
(សៀវភៅកត់ហេតុការណ៍ផ្លូវការនៅឥណ្ឌូចិនបារាំងឆ្នាំ១៩១៤ ទំព័រ ១២៥៨) ។

អគ្គទេសាភិបាលឥណ្ឌូចិន

– បានឃើញក្រឹត្យចុះថ្ងៃទី២០ តុលា ឆ្នាំ១៩១១ ស្តីពីការកម្រិតអំណាចរបស់អគ្គទេសាភិបាល និងការចាត់ចែងហិរញ្ញវត្ថុ និងរដ្ឋ បាននៅឥណ្ឌូចិន ។
– បានឃើញ ក្រឹត្យចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩១៣ ។
– បានឃើញសារទូរលេខនៃក្រសួងលេខ ៣៥២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩១៣។
– បានឃើញ សារាចររបស់ក្រសួងចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ១៩១១ ។
– បានឃើញការបំភ្លឺរបស់អគ្គទេសាភិបាលចុះថ្ងៃទី៣ ខែមករា ឆ្នាំ ១៩១៤ ។

- បានឃើញអនុក្រឹត្យចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩១០ ឲ្យបង្កើតនូវគណៈកម្មការមួយដើម្បីធ្វើការសិក្សាអំពីបញ្ហានៃការកំណត់ព្រំដែននៃកូសាំងស៊ីន និងកម្ពុជា ។

- បានឃើញកំណត់ហេតុទាំងឡាយរបស់គណៈកម្មការនេះដែលបានតាក់តែងនូវសេចក្ដីស្នើទាំងឡាយដែលមានគោលបំណង ដើម្បីធ្វើការកែប្រែនូវព្រំដែនទាំងឡាយរវាងខេត្តកំពត និងហាទៀន , តៃនិញ និងព្រៃវែង , ធូយ៉ូវម៉ុត និងកំពង់ចាម (មណ្ឌលក្រចេះ) ។

- បានឃើញអនុក្រឹត្យចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ១៩១២ ស្ដីពីការតែងតាំងគណៈកម្មការបោះគោលដី ទទួលបន្ទុកដំណើរការដាក់បង្គោលព្រំដែនដែលត្រូវដាក់សញ្ញាព្រំដែនថ្មីដែលកំណត់ដោយគណៈកម្មការដែលបង្កើតឡើងដោយអនុក្រឹត្យចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩១០ ។

- បានឃើញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាណានិគម នៃឥណ្ឌូចិន ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ១៩១៣ ទាក់ទងទៅនឹងការកំណត់ព្រំដែន កូសាំងស៊ីន និងកម្ពុជា ។

តាមការស្នើរបស់រដ្ឋាភិបាលកូសាំងស៊ីននៅក្នុងក្រុមប្រឹក្សាឯកជន និងរបស់លោករេស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា ។

គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សារដ្ឋាភិបាលនៅឥណ្ឌូចិន បានយល់ព្រមហើយ

## សម្រេច

**ប្រការ១ –** ព្រំដែនថ្មីដែលខ័ណ្ឌខេត្តហាទៀន និងកំពត,រវាងអាងសមុទ្រខាងក្នុងនៅហាទៀន និងឈូងសមុទ្រសៀម បានសៀរតាមខ្សែទូរលេខរហូតដល់ចំណុច ដែលវាបានកាត់ខ្សែសំណង់ការពារសឹកសត្រូវនៅចម្ងាយពីហាទៀនចំនួន ២,២៩៣ម ចំណុចនេះត្រូវបានចង្អុលបង្ហាញដោយអក្សរ B នៅលើផែនការនៃការបញ្ចូលជាឧបសម្ព័ន្ធទៅភាពដើមនៃអនុក្រឹត្យ ។

ចាប់ពីចំណុច B . ព្រំដែនបានសៀរតាមបណ្ដោយព្រំដែនបច្ចុប្បន្ននៃភូមិសាគី ដែលមានប្រវែង ១,៤៤១ម សម្គាល់ដោយគំនូសនៃអតីតខ្សែការពារព្រំដែន រហូតដល់ចំណុច C , បន្ទាប់មកចំណុច D , ចំណុចខាងជើងបំផុតនៃភូមិសាគី ដែលបានបង្កើតឡើងដោយភ្នំប្រជៀវ (ភាសាវៀតណាម : Nui Da Dung) ចម្ងាយពី B ទៅ C មាន ចំនួន ៤២៣ ម ពី C ទៅ D ចំនួន ១,០១៨ ម ។

ពី D ទៅ E (ចម្ងាយ : ៦៨៨ម ) ព្រំដែនឆ្លងកាត់ "បឹង" ជ្រៅមួយបន្ទាប់មកនៅចំណុច E បានទៅជួបខ្សែការពារសឹកសត្រូវដែលវាបានរត់តាមរហូតដល់ចំណុច F កំពូលព្រំដែននៃទឹកដី **សាគី** ចម្ងាយពី E ទៅ F មាន ៤៨១ ម ។

ពី F ជាខ្សែការពារសឹកសត្រូវដែលបានរកឃើញវិញនៅចំណុច E បានបន្តទៅ ទៀតដោយគ្មានការបញ្ឈប់រហូតដល់មាត់សមុទ្រ ដែលវាបានទៅដល់ចំណុច G ក្រោយពីបានរត់អស់រយៈផ្លូវ F.G ៣,១៥៨ ម ។

**មាត្រា២ –** ព្រំដែនថ្មីរវាងខេត្ត តៃនិញ និងខេត្តព្រៃវែង ។ បរិវេទ្ធភូមិដែលហៅថា កាយ–កៃយ (Cai - Cay) រហូតដល់ប្រសព្វមុខនៃ Cai - Cay ជាមួយ rach Ong -Ba ត្រូវបានភ្ជាប់ទៅឲ្យប្រទេសកម្ពុជា ។

ចាប់ពីចំណុចនេះ ព្រំដែនថ្មីមុនដំបូងដើរតាមបន្ទាត់ត្រង់ចម្ងាយ១,៥២៣ ម រហូតដល់ចំណុច B, ព្រំដែននេះបន្ទាប់មកទៀតបានរត់តាមបណ្ដោយខ្សែបន្ទាត់មួយប្រវែង ២០៩ ម ដែលវាបង្កើតបានជាមួយខ្សែព្រំដែនទី១ នូវមុំ ១៩០° ៣០ បន្ទាប់មកបានរត់រហូតដល់ rach តាសូ (rach Ta So) ដែលវាបានរត់តាមរហូតដល់កន្លែងប្រសព្វមុខរបស់វាជាមួយព្រំដែនបច្ចុប្បន្នរបស់កូសាំងស៊ីន និងកម្ពុជាដែលមិនកែប្រែ ។

**មាត្រា៣ –** ព្រំដែនថ្មីរវាងខេត្ត ធូយ៉ូវម៉ុត និងកំពង់ចាម (មណ្ឌលក្រចេះ) ចេញដំណើរពីប្រសព្វមុខនៃ កាន់–ឡេ–ចាម (Can-le-cham) និង កាន់–ឡេ–ទ្រូ (Can-le-Tru) (ស្ទឹងសាយហ្គន) រត់តាម Can Le Cham រហូតដល់ចំណុចដែលវាចាកចេញពីទិសខាងជើង ដើម្បីបង្កើតជាមុំដ៏ធំមួយនៅទិសខាងកើត ។ ចំណុចនេះត្រូវបានដាក់សញ្ញាដោយអក្សរ A នៅលើផែនទី ដែលបានបញ្ចូលជាឧបសម្ព័ន្ធទៅនឹងច្បាប់ដើម នៃអនុក្រឹត្យ ។

ពេលនោះព្រំដែនបានទៅដល់ខ្សែត្រង់ចំណុច B នៅប្រសព្វមុខនៃព្រែកជ្រៀវ និង

ផ្លូវថ្នល់នៃខេត្តក្រចេះ បត់ទៅទិសខាងកើត ដើរតាមផ្លូវទឹកនៃព្រែកជ្រៀវរហូតដល់ប្រភពរបស់វា ( ចំណុច C ) បន្ទាប់មកទៀត ព្រំដែននេះបានបន្តជាខ្សែត្រង់រហូតដល់ចំណុចD ដែលបានជួបព្រែកមានឬ Djerman រួចបានរត់តាមផ្លូវទឹករហូតដល់ប្រភពរបស់វា ដើម្បីទៅដល់កន្លែងប្រសព្វមុខនៃ ដា-ក្លេ ( Dar-klé ) និងដារ ហូយ ( Dar - Hoyt ) រួចព្រំដែននេះ បានរត់តាមផ្លូវទឹកចុងក្រោយនេះ រហូតដល់ប្រភពរបស់វា ។

**មាត្រា៤** – រដ្ឋាភិបាលកូសាំងស៊ីន និងលោករ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះរៀងៗខ្លួន ។

**ហាណូយ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤**
**ជួសអគ្គទេសាភិបាល ដែលទៅបំពេញបេសកកម្ម**
**អវត្តមាន និងក្នុងនាមនៃគណៈប្រតិភូ :**
**អគ្គលេខាធិការ**
**នៃអគ្គរដ្ឋាភិបាលឥណ្ឌូចិន :**
VAN VOLLENHOVEN
**ក្នុងនាមនៃអគ្គទេសាភិបាលរ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា**
E. OUTREY
**(សារទូរលេខ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ ១៩១៣ លេខ ១១១៣)**

**ទេសាភិបាលស្តីទី នៃឥណ្ឌូចិន**
LE GALLEN
**(របាយការណ៍លេខ ១០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ១៩១៤)**

---

## ឧបសម្ព័ន្ធ ៨
## ព្រះរាជបញ្ញត្តិ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤
## ព្រំដែន កូសាំងស៊ីន – កម្ពុជា



នឹងត្រូវសងទៅឲ្យកូសាំងស៊ីន នូវចំរៀកដីដែលលាតសន្ធឹងរវាងខេត្តកំពត និងហាទៀន និងមាន ឃុំសាគី ក៏ដូចជាភូមិ តូច កាន់ ចាន់ឡូត ( Kan Chanlot ) ទល់នឹងការធ្វើសម្បទានឲ្យប្រទេសកម្ពុជាវិញ នូវបរិព័ទ្ធភូមិ ហៅ កាយ កៃយ ( Cai-Cay រវាងខេត្ត តៃនិញ និងព្រៃវែង ) ។

ការកំណត់ព្រំដែនថ្មី នឹងត្រូវធ្វើឡើងរវាងខេត្តកំពង់ចាម និងធ្លូយ៉ូវម៉ូត ដែលនឹងត្រូវទុកឲ្យកូសាំងស៊ីននូវសង្កាត់ពីរ គឺឡុកនិញ និង ភឿក ឡេ ដែលរស់នៅដោយពួកកុលសម្ព័ន្ធដែលពីមុនពួកគេជាកុលសម្ព័ន្ធឯករាជ្យ ។

**ធ្វើនៅភ្នំពេញ , ថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩១៤**

**មានអំណាចប្រតិបត្តិ**
**តាមអនុក្រឹត្យលេខ ៣៩២**
**របស់រ៉េស៊ីដង់ជាន់ខ្ពស់**
**ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ ១៩១៤**

---

# ឧបសម្ព័ន្ធ ៩

## ស្ថិតិប្រជាជនសាំងស៊ីន នៅឆ្នាំ ១៨៧៩

| ស្រុក | អឺរុប | ចិន | តាហ្គាល | ម៉ាឡាបាន | ម៉ាឡេ | | អន្ដោប្រាម | អន្ដោប្រាម | កម្ពុជា | | ម៉ុយ | | ចាម | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ចុះបញ្ជី | មិនបាន ចុះបញ្ជី | ចុះបញ្ជី | មិនបាន ចុះបញ្ជី | ចុះបញ្ជី | មិនបាន ចុះបញ្ជី | ចុះបញ្ជី | មិនបាន ចុះបញ្ជី | ចុះបញ្ជី | មិនបាន ចុះបញ្ជី | | |
| បារៀ................ | ២៩ | ៣៥ | | ១ | | | ១.៧៣៥ | ១៧.៥០០ | | | ៣៣៥ | ១.២៥០ | | | | ២១.១២៦ |
| បេនត្រែ............ | ២៦ | ៩៣៤ | | | | | ១០.៩៩២ | ១.១៧៤ | | | | | | | | ១៦៣.១០០ |
| បៀនត្រា.(ប្រហែល=បៀនហ្វា) | ២៣ | ១.៧០៣ | ៤ | ១ | | | ៥.៣០៥ | ៥៤.៨៤០ | ១២០ | ៣៤០ | | | | | | ៦២.៣១៣ |
| កិនថឺ................ | ១១ | ១.៨៥៩ | | ១ | | | ៦.៨១៩ | ៣៦.៥០០ | ១.២០០ | ៨.០០០ | | | | | ៣.៥០០ | ៥៤.៤១៩ |
| ចូវដុក................ | ២៩ | ១.៣៨៦ | ១ | ២០ | ១.២២៨ | ៨.០០០ | ២.២៥០ | ៧០.០០០ | ៧៣៩ | ១៤.៥០០ | | | | | | ៩៨.១២៤ |
| ចឺឡឹង................ | ៣៨ | ១៣.៩៧៤ | | ១២៣ | | ១៣ | ៩.៩៥៥ | ១២៩.៣៥១ | | | | | | | | ១៥៣.០៥៦ |
| ហ្គោកុង.............. | ៨ | ៤៣៥ | | ១២ | | | ៣.១០៣ | ៣៦.៥២០ | | | | | | | | ៤០.០៧០ |
| ហាទៀន............. | ៩ | ៧៤១ | | | | | ៧០៤ | ៣.១៥០ | ១០០ | ៩០០ | | | | | | ៥.៥៥៥ |
| ឡុងស្វៀន.......... | ២១ | ៦០៥ | | | | | ៣.២៣៥ | ៦១.៤៧៥ | ៥៥ | ១.៥៥១ | | | | | | ៧០.៩០៥ |
| មីថ.................... | ៤២ | ២.០៣២ | ២ | ២ | | ១ | ១០.៦២៩ | ១៥១.២២៥ | | | | | | | | ១៦៣.៨៩១ |
| រ៉ាច់យ៉ា............... | ១០ | ១.១០០ | | | | | ២.០២៧ | ១២.៦៧៦ | ៧៣៤ | ១.៨០០ | | | | | | ១៨.៣៣៧ |
| សាដែក.............. | ២៣ | ១.៦០០ | | ៥ | | | ៥.០៩៧ | ១០៣.៩៧៦ | | | | | | | | ១១០.៦៣៨ |
| សាយហ្គន........... | ១០៨០ | ១២.៣៥៥ | ៦៦ | ៤០២ | | ១០៧ | ១៣.១២៥ | ២២៥.០៣៨ | | | | | | | | ២៥១.១៥៣ |
| សុកត្រាំង............ | ១៤ | ៧.៥៥៣ | | ៥ | | | ២.២៤៣ | ២០.៣០០ | ២.៣៣១ | ២៥.៧០០ | | | | | | ៦២.៥៧២ |
| តាន់អាន............. | ១១ | ៨៣៧ | | ១ | | | ៨.៨៨៥ | ៥០.០០០ | | ៣០ | | | | | | ៥៩.៧៥៧ |
| តៃនិញ............... | ២២ | ៤០៤ | | ១ | | | ១.២២២ | ១២.៧០០ | ៣៣៤ | ៣.២៨០ | | | ២៨ | ២៥០ | | ១៧.៩៤៩ |
| ធូយ៉ូវម៉ូត............ | ១៥ | ៣២៥ | | | | ១ | ៣.០៩៧ | ៨៦.០០០ | ៤៧ | ៧៦០ | ៨០ | ១.៧៤០ | | | | ៩២.០៥០ |
| ត្រាវិញ............... | ១៣ | ២.៥៥៤ | | | | | ២.៥៥៦ | ២៥.៧០០ | ៣.៦០៩ | ៣២.៣០០ | | | | | | ៦៦.៧៥០ |
| វិញឡុង.............. | ៣៧ | ២.៥៨៦ | | ៧ | | | ៦.៥០២ | ១១៥.៣០០ | | | | | | | | ១២៣.៣៥៩ |
| ពូឡូកុងឌ័រ.......... | ១២ | ៥០ | ៦ | | | | | ២៤៤ | | | | | | | | ៣០០ |
| | | | | | | | | | | | | | | | | **១,៥៥៥.៥៤០** |

ប្រភព : របាយការណ៍នៃសេចក្ដីរាយការណ៍ទូទៅនៅកូសាំងស៊ីន នៅឆ្នាំ ១៨៧៩ ( ឯកសារឥណ្ឌូចិន **A 20 C18**

## ឧបសម្ព័ន្ធ ១០

## អនុសញ្ញាដែលបានសម្រេចរវាងព្រះករុណា នរោត្តម និងរដ្ឋាភិបាលកូសាំងស៊ីន ដែលមានកម្មវត្ថុ ដើម្បីកំណត់ព្រំដែនកូសាំងស៊ីននិងព្រះរាជាណាចក្រកម្ពុជា

**( B.C.P ១៥ កក្កដា ឆ្នាំ ១៨៧៣ )**

ព្រំដែនរវាងកូសាំងស៊ីនបារាំង និងព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបានសម្គាល់ដោយបង្គោលទាំងឡាយដែលមានបង់លេខ និងមានអក្សរចារិក ចង្អុលបង្ហាញអំពីកម្មវត្ថុរបស់វា ។ ចំនួននៃបង្គោលនឹងមានចំនួន ១២៤ បង្គោល ។ បង្គោលលេខ១ នឹងត្រូវដាក់នៅចុងខាងកើតបំផុតនៃព្រំដែន និងការក្រឹត្យ នឹងត្រូវបានបន្តទៅទិសខាងលិច នៅក្នុងលំដាប់ធម្មជាតិនៃលេខ រហូតដល់បង្គោល ១២៤ ដែលបានដាក់នៅចម្ងាយប្រហែល ១,២០០ ម នៅខាងជើងនៃព្រែកជីក វីញតេ និងនៅភូមិអណ្ណាម វ៉ាថាញ់ ( Hoa - thanh ) ។

ព្រំដែននេះ នឹងឆ្លងកាត់តាមចំណុចសំខាន់ៗដូចតទៅនេះ : ចំណុចចេញដំណើរគឺបង្គោលលេខ១ ត្រូវបានដាំនៅលើមាត់ទន្លេតូច គឺទន្លេទ្វី ។ ទិសដៅទូទៅនៃព្រំដែនជាបន្តមកទៀត បានតម្រង់ទិសដៅទៅនិរតី និងឆ្លងកាត់តាមភូមិទាំងឡាយ គឺស្រុក ទុន , ស្រុកបាប្លូន , ស្រុកបានជ្រីង , រុងខ្នុច , ស្រុកត្រាញ់ , ស្រុកដុង ង៉ុន , ភូម៉ានដេត, ស្រុកការេ (Câe), ស្រុកកំពង់មានជ័យ (ឬបង់ហ្គោ), បានសៀរតាមមាត់ទន្លេ កែបាក់ឡើងទៅតាមត្រើយខាងឆ្វេងនៃ Cai - Cay ឆ្លងទៅភូមិកំពង់ កាសាំង , ស្រុកតាម៉ែង , ស្រុកតាហុង , ស្រុកបែវបាធូ, ស្រុកម៉ាយ, ស្រុករ៉ាច់ថាញ់ , ស្រុកតានូ , សៀរតាមត្រើយខាងជើងនៃព្រែកជីក ជ្រីះ–អាសី (ជាភាសាវៀតណាម Ta Du) សៀរតាមត្រើយខាងជើងនៃរ៉ាច់ បាណាន កាត់តាមទន្លេខាងក្រោមទៅខាងត្បូងនៃកោះគគី (ជាភាសាវៀតណាម Cu-Lao-Cai-Sen ) ឆ្លងកាត់កន្លែងប្រសព្វមុខនៃព្រែកក្រូច ជាមួយព្រែកស្លូតរត់តាមខ្សែស្របទៅព្រែកជីកវីញតេ ទៅទិសខាងជើង ចេញទៅដល់ភូមិយ៉ាំងថាញ់ ហើយចេញពីនោះបានរត់ទៅ ហាទៀន ដោយទុកចោលនៅទិសខាងកើតនៃព្រែកជីក ព្រែកក្រួស ។

---



## ឧបសម្ព័ន្ធ ១១

### អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៣៥

អគ្គទេសាភិបាលឥណ្ឌូចិន Commandeur de le légion d'honneur ។

– បានឃើញអនុក្រឹត្យចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ១៩១១ ស្តីពីការកំណត់អំណាចអគ្គទេសាភិបាល និងការចាត់ចែងហិរញ្ញវត្ថុ និងរដ្ឋបាលឥណ្ឌូចិន ។

– បានឃើញក្រឹត្យ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ ១៩៣៥ ។

– បានឃើញក្រឹត្យ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ ១៩១៥ ទាក់ទងទៅនឹងការប្តូរទឹកដីរវាងភាគីផ្សេងៗនៃសហភាពឥណ្ឌូចិន ។

– បានឃើញអនុក្រឹត្យលេខ ១៦១៥ ចុះថ្ងៃទី២៨ ឧសភា ១៩៣៥ របស់លោករ៉េស៊ីដង់ ជាន់ខ្ពស់នៅប្រទេសកម្ពុជាស្តីពីការបង្កើតគណៈកម្មការមួយ ដើម្បីសិក្សាបញ្ហាកំណត់ព្រំដែនកូសាំងស៊ីនកម្ពុជា (ផ្នែកមេកុងបាសាក់) ។

– បានឃើញ កំណត់ហេតុរបស់គណៈកម្មការនេះ ។

– បានឃើញកិច្ចព្រមព្រៀងផ្តល់ដោយរ៉េស៊ីដង់ជាន់ខ្ពស់នៃប្រទេសកម្ពុជា និងទេសាភិបាលកូសាំងស៊ីន ។

– បានឃើញយោបល់ព្រមផ្សាយដោយក្រុមប្រឹក្សាអាណានិគម នៅកូសាំងស៊ីន និងក្រុមប្រឹក្សាអាណាព្យាបាលរបស់ប្រទេសកម្ពុជានៅក្នុងសម័យប្រជុំរបស់ខ្លួនរៀងៗខ្លួន ពីថ្ងៃទី២ និងថ្ងៃទី១៥ ខែតុលា ឆ្នាំ ១៩៣៥ ។

ក្រុមប្រឹក្សានៃរដ្ឋាភិបាលឥណ្ឌូចិន បានយល់ព្រមរួចហើយ ។

### សម្រេច

**មាត្រា១ –** ព្រំដែនដែលខ័ណ្ឌខេត្ត ចូវដុក (កូសាំងស៊ីន) និងខេត្តកណ្តាល (កម្ពុជា) រវាងទន្លេមេគង្គ និងទន្លេបាសាក់ រត់តាមខ្សែដែលបានគូសដោយគណៈកម្មការដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៣៥

ដែលបានចង្អុលបង្ហាញខាងលើ នៅលើផែនការបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងច្បាប់ដើមនៃអនុក្រឹត្យនេះ ។

ព្រំដែននេះត្រូវបានបោះតម្រុយដោយ បង្គោលលេខ ៨៤ ៨៥ ៨៦ ៨៧ និង ៨៨ និងដោយចំណុច A , B , C , D ។

**បង្គោល និងចំណុចទាំងនេះត្រូវបានកំណត់ដូចតទៅ :**

**បង្គោលលេខ ៨៤** ត្រូវបានដាំនៅចម្ងាយ ១០ ម នៅខាងត្បូងទិប្រសព្វមុខជាមួយ ទន្លេមេគង្គ នូវព្រែកដីកមួយ រវាងផ្នែកដីដ៏តូច ដែលជារបស់ De Van Cam នៅទិសខាងជើង និងរបស់ Nguyen - Cao - Bang នៅទិសខាងត្បូង ។

**បង្គោល ៨៥** ត្រូវបានដាំនៅលើដាយបឹងឡៀម ខាងកើត នៅទល់មុខផ្នែកខ្នែង ខាងលិច នៃបឹងនេះ ។

**ចំណុចA** - ត្រូវបានកំណត់នៅចម្ងាយប្រហែល ១៤០ម នៅខាងកើត បូ-កា-ត្រា (Bau - Ca - Tra ចំណុចនេះត្រូវបានធ្វើឲ្យមានរូបរាងឡើងដោយគោលមួយតាមវិធីត្រីកោណ ដែលបានដាំនៅក្នុងឆ្នាំ ១៩៣៣ នៅក្នុងអំឡុងពេលនៃការយកចេញនូវភូមិតាណាន់ ) (Tanan) ។

**ចំណុច** B - ត្រូវបានដាក់នៅដាយខាងលិច នៃផ្នែកមួយនៃមួង ឡុង (Muong Lon) តម្រង់ទៅទិសខាងជើងនៅចម្ងាយប្រហែល ១៥០ ម នៃទីប្រសព្វមុខនៃផ្នែកនេះជាមួយ មួងឡុន ខ្លួនឯង ។

**បង្គោល ៨៦** ត្រូវបានដាំនៅលើត្រើយខាងលិចនៃរ៉ាច់កូឡាវ (Rach Co-Lao) នៅទល់មុខទីប្រសព្វមុខនៃ Rach នេះ និង មួងឡុន ។

**ចំណុច** C - ត្រូវបានដាក់នៅភាគខាងត្បូងបំផុតនៃហូ-តា-មី នៅលើចិញ្ចើមនៃផ្លូវរទេះ ដើរតាមត្រើយខាងត្បូងនៃវាលទំនាបនេះ និងនៅចម្ងាយប្រហែល ១គ.ម នៃត្រើយខាងលិចនៃព្រែកបាណាម ។

**បង្គោល ៨៧** ត្រូវបានដាំនៅលើជ្រុងខាងត្បូងនៃផ្លូវលំដែលនេះនៅចម្ងាយប្រហែល ៥៣០ ម នៃផ្លូវលំនេះ ។

**ចំណុច** D - ត្រូវបានកំណត់នៅចម្ងាយប្រហែល ២៥០ ម នៃប្រាំងខាងត្បូងនៃ



ព្រែកបាក់ណាម និងនៅចម្ងាយ ៤៣០ ម នៃអន្លង់ត្រី មួយដែលជារបស់ខៀវ ធី មឹយ (Khieu - Thi - Moi ) ។

**បង្គោល ៨៨** ត្រូវបានដាំនៅលើបាសាក់នៅចុងបំផុត នៃព្រំដែនខាងត្បូងនៃដីបិតស្រា នៅបាក់ណាម ។

**មាត្រា២ –** គណៈកម្មការបោះគោលដីមួយ នឹងត្រូវបានចង្អុលបង្ហាញជាខាង ក្រោយ ដើម្បីចាត់ចែងដំណើរការនៅពេលទឹកនាច នៅពេលដាំបង្គោលដែលត្រូវដាក់សញ្ញាព្រំដែនថ្មីនេះ ។

**មាត្រា៣ –** ទេសាភិបាលកូសាំងស៊ីន និង លោករ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះរៀងៗខ្លួន ។

**ហាណូយ, ថ្ងៃទី៦ ខែធ្នូ ឆ្នាំ ១៩៣៥**

**ហត្ថលេខា René ROBIN**

**ដើម្បីចម្លងថែក**

**ប្រធានការិយាល័យឯកសារ**

**ហត្ថលេខា : GUI GVES**

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ប្រធានការិយាល័យទី១**

**ហត្ថលេខា : អានមិនដាច់**

**(ILLISIBLE)**

## ឧបសម្ព័ន្ធ ១២

### អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិន ចុះថ្ងៃទី២៦ ខែកក្កដា ១៩៤២

**អគ្គទេសាភិបាលឥណ្ឌូចិន**

នាយទាហានជាន់ខ្ពស់ នៃកងអាសាកិត្តិយស

- បានឃើញក្រឹត្យចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ១៩១១ ស្ដីពីការកម្រិតអំណាចរបស់អគ្គទេសាភិបាល និងការចាត់ចែងហិរញ្ញវត្ថុ និងរដ្ឋបាលនៅឥណ្ឌូចិន ។
- បានឃើញក្រឹត្យ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩១៥ ។
- បានឃើញក្រឹត្យ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៤០ ។

តាមសេចក្ដីស្នើដែលមានការព្រមព្រៀងពីទេសាភិបាលកូសាំងស៊ីនគណៈកម្មការចម្រុះនៃក្រុមប្រឹក្សាអាណានិគម និងក្រុមប្រឹក្សាឯកជនបានព្រមព្រៀងរួចហើយ និងពីលោករ៉េស៊ីដង់ជាន់ខ្ពស់ នៅប្រទេសកម្ពុជា ក្រុមប្រឹក្សាអាណាព្យាបាលបានយល់ព្រមរួចហើយ ។

គណៈកម្មការអចិន្ត្រៃយ៍នៃក្រុមប្រឹក្សារដ្ឋាភិបាលបានព្រមព្រៀងហើយ ។

- បានឃើញសារទូរលេខរបស់លោករដ្ឋលេខាធិការអាណានិគមលេខ ៤០៦១ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៩៤២ ។

### សម្រេច

**ប្រការ១** – កូនកោះគគី (ជាភាសាវៀតណាម Culao - Khanh- Hoa) បច្ចុប្បន្ននៅក្នុងចំណុះនៃឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្ដាល (កម្ពុជា) ត្រូវបានភ្ជាប់ទៅឲ្យភូមិខាញ់អាន ខេត្តចូវដុក (កូសាំងស៊ីន) ដែលបានចង្អុលបង្ហាញ នៅក្នុងប្លង់នៃការបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងច្បាប់ដើមនៃអនុក្រឹត្យនេះ ។



**មាត្រា២**–ការប្រមូលផ្ដុំភូមិធំ Bengel (ជាភាសាវៀតណាម Binh Di –ប៊ិញឌី) និងចំរៀកដីមួយដែលមានទទឹង២០០ម និងមានបណ្ដោយប្រហែល២,៥០០គមដែលមានរវាង Benghi និងកែងនៃព្រែក Banghi ខេត្តចូវដុក (កូសាំងស៊ីន) ត្រូវបានភ្ជាប់ទៅឲ្យប្រទេសកម្ពុជាដែលបានចង្អុលបង្ហាញនៅលើប្លង់នៃការបញ្ចូលជាឧបសម្ព័ន្ធទៅក្នុងច្បាប់ដើមនៃអនុក្រឹត្យនេះ ។

ផ្នែកនៃទឹកដី ដែលត្រូវបានភ្ជាប់នោះ មានឡូតិ៍ ១ និងឡូតិ៍ ២ នៅសន្លឹកទី២ នៃ ប្លង់សុរិយោដី នៃភូមិកាញ់ប៊ិញ ។

**មាត្រា៣** – អគ្គលេខាធិការនៃអគ្គទេសាភិបាលឥណ្ឌូចិន ទេសាភិបាលកូសាំងស៊ីន និងរ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជាត្រូវបន្ទុលបន្ទុកអនុវត្តនូវអនុក្រឹត្យនេះរៀងៗខ្លួន ។

**ដាឡាត់ , ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ១៩៤២**
**ហត្ថលេខា : DECOUX**

**សេចក្ដីដកស្រង់របស់ J.M នៅឆ្នាំ ១៩៤២ លេខ ៦១ ទំព័រ ២១១២ ការកែប្រែទឹកដីនៃព្រំដែនកម្ពុជា និងកូសាំងស៊ីនឡើងវិញ ។**

---

## ឧបសម្ព័ន្ធ ១៣

### ព្រះរាជក្រមចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៤២

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧបគោ សុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរដ្ឋ និករោត្តម ធម្មិក មហារាជាធិរាជបរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី ព្រះមហាក្សត្រនៃប្រទេសកម្ពុជា ។

– បានឃើញព្រះរាជក្រមលេខ ១ ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ ១៩៤០ កែប្រែដោយអត្ថបទជាខាងក្រោយ រៀបចំចាត់ចែងឡើងវិញ នូវដំណើរការនៃរដ្ឋាភិបាលកម្ពុជា និងកំណត់តួនាទីនៃរដ្ឋមន្ត្រី ។

– បានឃើញព្រះរាជប្រកាសលេខ **៥៩ ស្ទន** ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ១៩២៥ កែប្រែនិងបំពេញដោយអត្ថបទជាខាងក្រោយ ស្តីពីការរៀបចំឡើងវិញនូវឃុំនៃប្រទេសកម្ពុជា ។

– បានឃើញ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំសំពៅពូន នៅក្នុងសម័យប្រជុំវិសាមញ្ញរបស់ខ្លួនចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤២ ។

– បានឃើញប្រកាសរបស់គណៈកម្មការចម្រុះរបស់ខេត្តកណ្តាលនៅក្នុងការប្រជុំរបស់ខ្លួន នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ ១៩៤២ ។

– បានឃើញប្រកាសរបស់គណៈកម្មការអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៅក្នុងការប្រជុំរបស់ខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ ១៩៤២ ។

– បានឃើញ ការព្រមព្រៀងធ្វើអន្តរាគមន៍រវាងលោករ៉េស៊ីដង់ជាន់ខ្ពស់និងយើង ។

## បង្គាប់

**មាត្រាមួយគត់ –** ត្រូវបានបញ្ចូលទៅក្នុងឃុំសំពៅពូន ស្រុកកោះធំខេត្តកណ្តាល នូវភូមិធំ Benghi និងចំរៀកដី មានទទឹងប្រវែង ២០០ ម និងបណ្តោយប្រវែង ប្រហែល ២,៥០០ម៉ែត្រ=(២គ.ម៥០០) ដែលស្ថិតនៅរវាង Benghi និងកែងនៃ ព្រែក Benghi ដែលពីមុន ស្ថិតនៅចំណុះភូមិខាញ់ប៊ិញ (កូសាំងស៊ីន) ដូចដែលបាន បង្ហាញនៅក្នុងប្លង់នៃឧបសម្ព័ន្ធនេះ ។

**ធ្វើនៅព្រះបរមរាជវាំងរបស់យើងនៅ ភ្នំពេញថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៤២**
**ព្រះហស្តលេខា : នរោត្តម សីហនុ**



**បានឃើញ និងប្រគល់ឲ្យប្រតិបត្តិ**
**ដោយអនុក្រឹត្យលេខ ៣៥១៨ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ ១៩៤២**
**ប្រធានជាន់ខ្ពស់ស្តីទី**
**ហត្ថលេខា : DELENS**

**បម្លងត្រឹមត្រូវតាមច្បាប់ដើម :**
**ប្រធានខុទ្ទកាល័យ BPA**
**អានមិនដាច់**
**(ILLISBLE)**

---

## ឧបសម្ព័ន្ធ ១៤

***លិខិតរបស់អគ្គទេសាភិបាលចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៣៩***

***ទីចាត់ការនៃកិច្ចការសាធារណៈ***
***លេខ : ៨៦៣ – API***
***កម្មវត្ថុ :***
***កោះទាំងឡាយនៅឈូងសមុទ្រសៀម***

***ហាណូយ ថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៣៩***
***អគ្គទេសាភិបាលឥណ្ឌូចិន***
***នាយទាហានជាន់ខ្ពស់នៃកងអាសាកិត្តិយស***
***ផ្ញើជូន***
***លោក ទេសាភិបាល កូសាំងស៊ីន***
***នៅសាយហ្គន***

ខ្ញុំមានកិត្តិយសសូមជម្រាបជូនលោកជ្រាបថា ខ្ញុំទើបតែបានធ្វើការពិនិត្យមើលតាមនីតិវិធីនូវបញ្ហាថ្មីមួយស្តីពីកោះទាំងឡាយនៅក្នុងឈូងសមុទ្រសៀមដែលការកាន់កាប់ត្រូវ បានជំទាស់រវាងប្រទេសកម្ពុជា និងកូសាំងស៊ីន ។

សភាពការណ៍ នៅចង្កោមកោះនេះ ដែលស្ថិតនៅដង្ហែគ្នាតាមបណ្តោយឆ្នេរសមុទ្រកម្ពុជា ហើយដែលមានកោះមួយចំនួនស្ថិតនៅយ៉ាងជិតនៃឆ្នេរសមុទ្រនោះដែលមានដីដុះ បានបន្តរហូតដល់បច្ចុប្បន្នដោយត្រូវតែតភ្ជាប់គ្នាទៅនឹងឆ្នេរសមុទ្រនៃប្រទេសកម្ពុជានៅក្នុងអនាគតមួយដ៏ជិតៗនេះ ចំពោះកោះទាំងនេះមានភាពចាំបាច់សមហេតុសមផល និងតាមលក្ខណៈភូមិសាស្ត្រ ដែលត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ប្រទេសនេះ ។

ខ្ញុំយល់ឃើញថា ពិតវាមិនអាចទៅរួចទេ ដោយទុកឲ្យស្ថិតស្ថេរយូរអង្វែងបាននូវកាលៈទេសៈដែលមានស្រាប់ដែលបង្ខំឲ្យអ្នកស្រុកនៅកោះទាំងនេះនៅក្នុងការជួបប្រាស្រ័យទាក់ទងដែល ជួនកាលត្រូវបង់ខាតក្នុងការធ្វើដំណើរឆ្លងកាត់យ៉ាងវែងមួយតាមទឹកដីកម្ពុជា ទៅឲ្យរដ្ឋការកូសាំងស៊ីននោះឡើយ ។

ដោយហេតុនេះ ខ្ញុំបានសម្រេចថា កោះទាំងអស់ដែលស្ថិតនៅខាងជើងនៃខ្សែកាត់កែងទៅនឹងឆ្នេរសមុទ្រដែលចេញដំណើរពីព្រំដែនរវាងប្រទេសកម្ពុជានិងកូសាំងស៊ីន ហើយបង្កើតបានមុំ ១៤០G ជាមួយទិសខាងជើងនៃខ្សែវីណ្ឌ ស្របទៅតាមផែនទីដែលភ្ជាប់ជាឧបសម្ព័ន្ធនេះ ចាប់ពីពេលនេះតទៅ នឹងត្រូវគ្រប់គ្រងដោយប្រទេសកម្ពុជា ។ អាណាព្យាបាល នឹងទទួលបន្ទុកជាពិសេសបញ្ហាប៉ូលិស នៃកោះទាំងនេះ ។

កោះទាំងអស់ដែលស្ថិតនៅខាងត្បូងនៃខ្សែនេះ ដោយរួមទាំងកោះភូក្កុកទាំងមូលនឹងបន្តគ្រប់គ្រងដោយកូសាំងស៊ីន ។ គេបានព្រមព្រៀងរួចហើយ ខ្សែកម្រិតព្រំដែនដែលបានកំណត់ព័ទ្ធតាមទិសខាងជើងនៃកោះភូក្កុក ដោយឆ្លងកាត់ចម្ងាយ ៣គ.ម ពីចំណុចនៃឆ្នេរខាងជើងបំផុត នៃកោះនេះ ។

អំណាចរដ្ឋបាល និងប៉ូលិស នៅលើកោះទាំងនេះ នឹងត្រូវបានបែងចែកយ៉ាងច្បាស់លាស់រវាងកូសាំងស៊ីន និងប្រទេសកម្ពុជា ធ្វើយ៉ាងណា ដើម្បីជៀសវាងនូវការឈ្លោះគ្នានៅក្នុងពេលអនាគត ។



ច្បាកដហើយថា គឺនៅមានតែបញ្ហារដ្ឋបាល និងប៉ូលិសតែប៉ុណ្ណោះហើយបញ្ហាដែលស្ថិតនៅក្នុងចំណុះទឹកដី នៃកោះទាំងនេះត្រូវរក្សាទុកទាំងស្រុង ។

សូមលោក ទទួលបន្ទុកចាត់ចែង ដើម្បីឲ្យសេចក្តីសម្រេចរបស់ខ្ញុំទទួលបាននូវការអនុវត្តន៍ជាបន្ទាន់ ។

ខ្ញុំសូមលោកផ្តល់ដំណឹងដល់ខ្ញុំស្តីពីការទទួលលិខិតនេះ ។

**ហត្ថលេខា : BREVIE**

# ផែនទី

## ផែនទីចាំបាច់នាំឲ្យងាយដើម្បី
## យល់នូវសៀវភៅនេះ
## ជាកម្មវត្ថុនៃការបោះពុម្ពផ្សាយ
## ដែលមានសារៈសំខាន់ធ្វើឱ្យ
## ងាយស្រួលដល់ការពិនិត្យ
## (ដោយ : សារិន ឆាក)





## ផែនទី : ទី១ ការបាត់បង់ទឹកដីដែលទទួលរងដោយកម្ពុជា




គំនូសនៃផ្លូវ
ធ្វើដំណើររុករក នៅឥណ្ឌូចិនក្នុងឆ្នាំ ១៨៦៦-៦៧-៦៨
នៅក្រោមបញ្ជារបស់អនុសេនីយឯក Frégate de La Grec
(dessiné par Francis Garnier)
Me Nam
KHEMARAT
Se Moun
SISAKET
KORAT
BASSAC
ATTOPEU
Limite du Cambodge Siamois et du Laos Siamois
Limite du Cambodge Siamois et du Laos
PAKIM
BANGKOK
KHONG OU SITANDOR
SING PONG
Tonle Repou
CAMBODGE SIAMOIS
កម្ពុជា សៀម
PROVINCE DE TONLE REPOU
ANCOR OU SIEMRIAP
STUNG TRENG
BATTAMBANG
Limite du Cambodge Français et Cambodge Siamois
COMPONG THOM
Limite encore
PROVINCE DE COMPONG SOAL
SAMBOR
PROVINCE DE SAMBOC.SAMBOR
KRATIEH
PROVINCE DE PURSAT
FRANÇAIS
COMPONG SMONG
GOLFE DE SIAM
HOUBON
Tonly Tom
PROVINCE DE BAP.NOM
CAMBODGE
Limite du Cambodge Français et de la Cochinchine Française
PNUN PUNH
COCHINCHINE FRANÇAISE
PROVINCE DE COMPONG SOM

3 (TITRE 2)

# ផែនទី នយោបាយ ឥណ្ឌូចិន ១៨៨៩



4 (TITRE 3)

# ផែនទី មណ្ឌលតៃនិញ ១៨៩៦




ផែនទីនៃឋានលេខា

នៃ

ស្រុកតៃនិញ

បោះពុម្ពផ្សាយក្រោមការដឹកនាំរបស់លោក Bertaux ប្រធានរេខាគណិត, ប្រធានផ្នែក សុរិយោដី និង ឋានលេខាស្របទៅតាមការណែនាំរបស់ លោក DUCOS ជំនួយទេសាភិបាល, លោក ROUSSEAU អគ្គទេសាភិបាល (១៨៩៦)

# 5 (TITRE 4) ចំណែកព្រំដែន ស្រង់ពីផែនទី នៃប្រទេសកម្ពុជា



6 (TITRE 3)

ផែនទី មណ្ឌល ធូយ៉ូវម៉ូត ១៨៩៦



7 (TITRE 5)

# ផែនទី ប្រាប់កន្លែងដាំបង្គោលព្រំដែន ៥៥-១២៤



# ផែនទី មណ្ឌល ចូវដុក ១៨៩១




**ផែនទីបានលេខា នៃ ស្រុក ចូវដុក អតីត ហាទៀន**

បោះពុម្ពផ្សាយក្រោមការដឹកនាំរបស់លោក Courteaud និងលោក Berteux ប្រធានផ្នែក នៃ ផ្នែកសុរិយោដី ស្របទៅតាមការណែនាំរបស់លោក Danel ភូឈួយទេសាភិបាល, លោក de Lanessan អគ្គទេសាភិបាល (ឆ្នាំ ១៨៩១)

**មាត្រដ្ឋាន : ១/១០០.០០០**

9 (TITRE 5)

# ព្រំដែនកូសាំងស៊ីន និង កម្ពុជា



# ផែនទី កំពត និង ហាទៀន




តារាង ប្រាប់ចម្ងាយ

Tableau des distances

| | |
|---|---|
| A. B. | 2293.30 |
| B. C. | 423.00 |
| C. O. | 1018.20 |
| D. E. | 688.00 |
| E. F. | 481.20 |
| F. G. | 3157.90 |
| Total | 8061.30 |

11 (TITRE 6) ដែនទឹកព្រំដែនកម្ពុជា-កូសាំងស៊ីន តាមសារាចររបស់ Brévié








# មជ្ឈមណ្ឌលសិក្សា
# នៃបណ្ដាប្រទេសនៅចុងបូព៌ា
# នៃ អាស៊ីអាគ្នេយ៍

The Indradevi Publishing

# ព្រំដែននៃប្រទេសកម្ពុជា
## ផែនទី

១– ផែនទីទូទៅស្តីពីការបាត់បង់ទឹកដី ដែលទទួលរងដោយប្រទេសកម្ពុជា ។
២– គំនូរវាស់ (ធ្វើឲ្យងាយ) នៃបេសកកម្ម Doudart de Lagrée ។
៣– សេចក្តីស្រង់ផែនទី នយោបាយឥណ្ឌូចិន ១៨៨៩ (ផែនទី Deloncle) ។
៤– មណ្ឌលតៃនិញ ១៨៩៦ – (សេចក្តីស្រង់ ផែនទីលោក Rousseau) ។
៥– សេចក្តីស្រង់ផែនទី នៃប្រទេសកម្ពុជា Klobukowski - Luce ។
៦– មណ្ឌល ធូយ៉ូវម៉ូត ១៨៩៦ (សេចក្តីស្រង់ផែនទី លោក Rousseau) ។
៧– ព្រំដែននៃប្រទេសកម្ពុជា និងអណ្ណាម បង្គោល ៥៥ ទៅ ១២៤ ។
៨– មណ្ឌលចូវដុក ១៨៩១ (សេចក្តីដក់ស្រង់ផែនទី de lanessan) ។
៩– ព្រំដែនកូសាំងស៊ីន កម្ពុជា (១៨៩៦) ។
១០– ខេត្តហាទៀន ។
១១– ព្រំដែនកម្ពុជា – កូសាំងស៊ីន – តាមសារាចររបស់ BRÉVIÉ ។

# សរុបសៀវភៅដែលនិយាយក្នុងរឿងនេះ
## (Bibliographie)


### I - សៀវភៅទូទៅ

Carré De Malberg (R.) – ការរួមវិភាគទានចំពោះទ្រឹស្តីទូទៅរបស់រដ្ឋភាគ១ និង ភាគ២ , Paris Sirey 1922 ។

Cavare (L.) – ច្បាប់សាធារណៈអន្តរជាតិវិជ្ជមាន – Paris Pédone ,1951 , ភាគ១ និង ភាគ២ ។

Despagnet (F.) – និពន្ធសាកល្បងអំពីអាណាព្យាបាល Larose និងForcel Paris 1899 ។

Despargnet (F.) – ការងារទូតនៃសាធារណរដ្ឋទីIII និងច្បាប់អន្តរជាតិ Larose , Paris 1904 ។

Reuter (F.) – ច្បាប់សាធារណៈអន្តរជាតិ Paris Sirey 1953 ។

Rousseau (Ch.)– គោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ភាគ១ Paris , Pédone 1944 ។

Sibert (N.) – សន្ធិសញ្ញានៃច្បាប់សាធារណៈអន្តរជាតិ, Paris, Dalloz ,1932 ។

របាយការណ៍របស់គណៈកម្មការនៃច្បាប់អន្តរជាតិរបស់អង្គការសហប្រជាជាតិស្តីពីច្បាប់នៃសន្ធិសញ្ញា – ឯកសារ A / C N 4 / 63 ចុះថ្ងៃទី២៤ មីនា ១៩៥៣ ឯកសារ A / C N 4 / 156 ចុះថ្ងៃទី២០ ខែមីនា ១៩៦៣ ។

### II - សៀវភៅពិសេស

Aymonier (E.) – ប្រទេសកម្ពុជា , ភាគ១ , ២ និងភាគ ៣ Paris , E. Leroux, 1900, 1901 , 1904 ។

Barthé Lémy – នៅឥណ្ឌូចិន , Charpentier , Paris ។

Bernard (F.) – ឥណ្ឌូចិន , Charpentier , Paris ។

Colonel Bernard (F.) – នៅសាលាការងារទូត Paris ស្នាដៃតំណាង ១៩៣៣ ។

Colonel Bernard (F.) – ដើម្បីបម្រើឥណ្ឌូចិន , Larose , Paris 1931 ។

Général Catroux – អំពីវិទាដកម្មពីរនៃឥណ្ឌូចិន Plon Paris 1958 ។

Coedès (G.) – រដ្ឋហិណ្ឌូ នៃឥណ្ឌូចិន និងឥណ្ឌូណេស៊ី ។ E.de Broccard , Paris 1948 ។





Coedès (G.) – សិលាចារិក នៃប្រទេសកម្ពុជា បកប្រែដោយ G.Coedès Vol. vi Paris 1954 ។

Amiral Decoux – នៅចំពោះមុខបៅក្រមនៅឥណ្ឌូចិន, Plon , Paris 1954 ។

Detroyat (L.) – សម្បត្តិរបស់បារាំងនៅឥណ្ឌូចិន Delagrave , Paris ។

Paul Doumer – (អនុស្សាវរីយ៍) ឥណ្ឌូចិនបារាំងសែស Vuibert et Neny .Paris , 1905

Paul Doumer – សភាពការណ៍នៅឥណ្ឌូចិន (១៨៩៧–១៩០១) , Hanoï .P.N. Schneider , 1902 ។

Commandant Famin (F.) – នៅតុងកឹង និងនៅលើព្រំដែន នៃ Kvang-Si, Challemel , Paris 1895 ។

Gautier (H.) – បារាំងនៅតុងកឹង Challemel , Paris , 1884 ។

Garnier (F.) – ដំណើររុករកនៅឥណ្ឌូចិនបារាំងសែស, Hachette , Paris 1893 ។

Gour (C.G.) – ស្ថាប័នរដ្ឋធម្មនុញ្ញ និងនយោបាយនៃប្រទេសកម្ពុជា ។ Paris , Delloz 1965 ។

Imbert (J.) – ប្រវត្តិសាស្ត្រនៃស្ថាប័នខ្មែរ ។ ភ្នំពេញ ១៩៦១ ។

Julien (F.) -Doudard de Lagrée នៅប្រទេសកម្ពុជានិងនៅឥណ្ឌូចិន , Challemel , aıné paris 1886 ។

Lanessan (J.M.de ) – គោលការណ៍នៃការធ្វើអាណានិគម Félix Alcan , Paris 1897 ។

Lanessan (J.M.de ) – ការធ្វើអាណានិគមរបស់បារាំងនៅឥណ្ឌូចិន Félix Alcan Paris 1895 ។

Lanessan (J.M.de ) – ការពង្រីកអាណានិគមបារាំង Félix Alcan Paris 1886 ។

Louvet (L.E.) – សម្តេច d'Adran, Delhomme និង Briguet.Paris 1900 ។

Porcé (GUY ) និង Maspiro (Eveline) – ទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្មែរ Paris . payot 1938 ។

Maybon (Charles -B) – ប្រវត្តិសាស្ត្រទំនើបនៃប្រទេសអណ្ណាម , Plon, Paris 1931 ។

Meyniard ( Ch.) – ចក្រភពទី២ នៅឥណ្ឌូចិន Société d'Editions scientifiques Paris 1891 ។

Navarre (Henri) – ដំណើរជិតផុត នៃឥណ្ឌូចិន , Plon Paris 1958 ។

Pavie (A) – បេសកកម្ម Pavie នៅឥណ្ឌូចិន M. Leroux Paris , 1901 ។

Pensri (Suvany - Buke) – ទំនាក់ទំនងរវាងប្រទេសបារាំងនិងប្រទេសថៃ នៅសតវត្សទី១៩ Bangkok 1962 ។

Petit (E.) – ការចាត់ចែងរបស់អាណានិគមបារាំង និងរបស់បណ្ដាប្រទេសជាអាណាព្យាបាល , Berger . Levrault et Cie , Paris , 1894 ។

Morizon (R.) – ឯកលេខនា នៃប្រទេសកម្ពុជា ។ រោងពុម្ពចុងបូព៌ាប្រទេស , ហាណូយ ១៩៣១ ។

Rivière (L.P) – សៀម, J.Peyronnet et Cie , Paris ។

Septans – ការចាប់ផ្ដើមនៃឥណ្ឌូចិនបារាំងសែស Challamel Ainé , Paris ។

Thery (R.) – ឥណ្ឌូចិន បារាំងសែស Paul Beval , Paris , 1931 ។

### III - និក្ខេបបទបណ្ឌិត

Panupong (Arun) – ទឹកដីឥណ្ឌូចិន–ថៃ Paris , Droit 1953 ។

Petit (E.) – ផលនៃអាណាព្យាបាលទាក់ទងទៅនឹងអធិបតេយ្យភាពខាងក្នុងរបស់រដ្ឋដែលត្រូវការពារ Poitiers , Droit , 1900 ។

SIRMAR GIEFF (H.G)–សភាពការណ៍របស់រដ្ឋ ពាក់កណ្ដាលអធិបតេយ្យភាពចំពោះទស្សនៈនៃច្បាប់អន្តរជាតិ Paris , Droit , 1880 ។

A – សៀវភៅដែលបោះពុម្ពផ្សាយដោយក្រសួងការបរទេសបារាំងនៅក្រោមចំណងជើង :

- កិច្ចការ នៃ តុង កឹង



- កិច្ចការ នៃ ប្រទេសចិន
- ប្រទេសចិន
- កិច្ចការ នៃ មេគង្គលើ
- កិច្ចការ នៃ ប្រទេសសៀម និងមេគង្គលើ
- កិច្ចការ នៃ ប្រទេសសៀម

**B** – ឯកសារទាំងឡាយរបស់អតីតក្រសួងនៅឯនាយសមុទ្រ ផ្លូវ Oudinot ។ ឯកសារទាំងនេះត្រូវបានបង្កើតឡើងដោយអក្សរ និងរបាយការណ៍របស់ទេសាភិបាលនៅកូសាំងស៊ីន របស់រ៉េស៊ីដង់ជាន់ខ្ពស់ នៃប្រទេសអាណាព្យាបាលរបស់អគ្គទេសាភិ - បាលឥណ្ឌូចិន ។

ឯកសារទាំងនេះត្រូវបានរៀបចំនៅក្រោមចំណងជើងថា "ឥណ្ឌូចិន" ចំពោះពួកអ្នកដែលចាប់អារម្មណ៍ចំពោះបណ្ដាប្រទេសជាអតីតឥណ្ឌូចិនបារាំងសែស និងនៅក្រោមចំណងជើងថា "ប្រទេសសៀម" ចំពោះពួកអ្នកដែលទាក់ទង និងទំនាក់ទំនងរវាងសៀមមួយផ្នែក និងប្រទេសបារាំងនិងបណ្ដាប្រទេសនៅឥណ្ឌូចិនមួយផ្នែកទៀត ។

**C** – ឯកសារដែលរក្សាទុកដោយបណ្ណាល័យជាតិ នៃប្រទេសកម្ពុជា ដែលបានមកពីបណ្ណាល័យរបស់អតីតរ៉េស៊ីដង់ជាន់ខ្ពស់នៅប្រទេសកម្ពុជា ។ ឯកសារទាំងនេះមិនសូវមានច្រើនទេ ពីព្រោះថា មានសំណុំរឿងជាច្រើនត្រូវបានដកចេញដោយឯកអគ្គរដ្ឋទូតបារាំងនៅប្រទេសកម្ពុជានៅមុនពេលការផ្ទេររបស់ពួកគេ ។ ប៉ុន្តែការស្រាវជ្រាវដ៏អំណត់អាចឲ្យរកឃើញឡើងវិញ នូវឯកសារដ៏កម្រមួយចំនួនដែលគួរឲ្យចាប់អារម្មណ៍ដែលផ្ដល់នូវព័ត៌មានដែលបញ្ជាក់បន្ថែមនូវឯកសារទាំងឡាយដែលមាននៅក្នុងឯកសាររបស់អតីតក្រសួងនៅឯនាយសមុទ្រជាមួយនិងការយកចិត្តទុកដាក់ នេះដែលឯកសារទាំងនេះ ផ្ដល់នូវភាពលំអិតបន្ថែមទៀត ។

# សារបំណ្ណ

អារម្ភកថា សារិន ជាក............................................................... ១១
ព្រះរាជលិខិតជាវរបស់ សម្តេច ព្រះនរោត្តម សីហនុវរ្ម័ន
ព្រះប្រមុខរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជា.......................................... ១៧
អារម្ភកថា របស់លោក Paul Reuter.................................................. ១៩
សេចក្តីផ្តើម ................................................................................ ២២

## ភាគទី ១
## ស្ទឹងត្រែង និង ដាឡាក់

ព្រំដែនខេត្តស្ទឹងត្រែង (ត្រើយខាងឆ្វេងនៃទន្លេមេគង្គ– ផ្នែកដែលមានវាំងទន្លេ មេគង្គ និងប្រភព នៃ Dar - Hoyt ,១៨៩៣ – ១៩២៩ )..................... ៣៨

### ផ្នែកដំបូង

ការលុបបំបាត់ការគ្រប់សង្កត់របស់សៀមៈ សន្ធិសញ្ញាចុះថ្ងៃទី.......... ៣៩

### ផ្នែកទី I

ការភ្ជាប់ទៅអាណានិគម កូសាំងស៊ីន នូវទឹកដីកម្ពុជាដែលបានសងវិញ... ៤០
១– ការបែងចែកជាថ្មីនៃទឹកដីរដ្ឋបាល ......................................... ៤០
២– សភាពការណ៍រដ្ឋបាលនៃទន្លេមេគង្គកណ្តាល .......................... ៤២



### ផ្នែកទី II

ការភ្ជាប់ទៅប្រទេសលាវ ............................................................ ៥៥
១– ពីខែមិថុនា ឆ្នាំ ១៨៩៥ ទៅខែកុម្ភៈ ឆ្នាំ ១៨៩៩ : ទិកនិយម នៃប្រទេសលាវ ខាងលើ និងប្រទេសលាវខាងក្រោម ................................................ ៥៥
២– កំណើតនៃការឯកភាពនៃរដ្ឋបាលលាវ ................................ ៥៦

### ផ្នែកទី III

ការធ្វើឲ្យដូចដើមឡើងវិញនូវភាពខ្វះ នៃអធិបតេយ្យភាពកម្ពុជា....... ៥៧
១– សេចក្តីស្នើ Pavie(១៨៩៤) ................................................ ៥៧
២– អនុក្រឹត្យស្តីពីការប្រគល់ឲ្យវិញចុះថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ១៩០៤........ ៥៨

### ផ្នែកទី IV

ការភ្ជាប់ទៅប្រទេសអណ្ណាមនូវទឹកដីកម្ពុជា Darlac ...................... ៦០
១–ការបង្កើតស្ថានការដ្ឋាន Darlac ........................................ ៦១
២–ការភ្ជាប់ផ្នែករដ្ឋបាលនៅ ដាឡាក់ទៅឲ្យអាណាព្យាបាលអណ្ណាម : អនុក្រឹត្យចុះ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ១៩០៤ ................................ ៦២
៣–ការវិវត្តន៍ផ្នែករដ្ឋបាល និងនយោបាយនៅ Darlac : អនុក្រឹត្យ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ១៩០៥ និងចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩២៣.... ៦៣
៤– ការទាមទាររបស់ រាជវាំង វ៉េ .............................................. ៦៤
៥–ការភ្ជាប់នយោបាយទៅអណ្ណាម ............................................ ៦៨

## ភាគទី ២
## ស្ទឹងត្រែង និង លាវ

ព្រំដែនរវាងកម្ពុជា និងព្រះរាជាណាចក្របាសាក់ (ប្រទេសលាវបច្ចុប្បន្ន) :
ផ្នែក ដែលមានរវាងភ្នំដងរែក និងទន្លេមេគង្គ)............................ ៧៣
១- ការលុបបំបាត់ ការត្រួតត្រារបស់សៀម : អនុសញ្ញាចុះថ្ងៃទី១៣
ខែកុម្ភៈ ឆ្នាំ ១៩០៤ ............................................................ ៧៣
២- ការកំណត់ព្រំដែន : អនុក្រឹត្យចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ១៩០៥... ៧៥
៣-ការកាត់យក ដោយប្រាកដប្រជានៃទឹកដីជាតិរបស់កម្ពុជា :
អនុក្រឹត្យចុះថ្ងៃ ទី១៦ ខែឧសភា ឆ្នាំ ១៩០៥ .............................. ៧៩
៤-សេចក្តីសន្និដ្ឋាន ..............................................................៨២

## ភាគទី ៣
## ស្វាយរៀង ព្រៃវែង កំពង់ចាម និងកូសាំងស៊ីន
## (១៨៦៩_១៨៧២)

ព្រំដែនរវាង តាន អាន , ត្រាង បាង , និងតៃ និញ (កូសាំងស៊ីន) មួយផ្នែក និង
ស្វាយរៀង,ព្រៃវែង និងកំពង់ចាម មួយផ្នែកទៀត............................ ៨៤

### ជំពូកទី I

ការរៀបចំព្រំដែន ............................................................ ៨៥

### ផ្នែកទី I

សភាពការណ៍មុនការអនុវត្តន៍ការងារ ..................................... ៨៥



### ផ្នែកទី II

ការរៀបចំ ............................................................................ ៩២

### ផ្នែកទី III

ដំណាក់កាលទី១ នៃការងារបោះគោលដី ........................................ ៩៧
១- ការងាររបស់គណៈកម្មការ .................................................. ៩៧
២- ការពិនិត្យព្រំដែនដែលបានរៀបចំឡើង ................................ ១០១
៣- តួនាទីរបស់ស្ថានការកម្ពុជា ...................................................១០២
៤- ឥរិយាបថរបស់ព្រះមហាក្សត្រ ...............................................១០៥
៥- សេចក្តីសម្រេចចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ ១៨៧០ ..........................១០៦

### ផ្នែកទី IV

តំណាក់កាលទី២ នៃប្រតិបត្តិការបោះគោលដី.................................១០៩
១-អវត្តមាននៃស្ថានការកម្ពុជា ...................................................១០៩
២-អាកប្បកិរិយារបស់អធិការបារាំង ...........................................១០៩

### ជំពូកទី II

តម្លៃគតិយុត្ត នៃគំនូសព្រំដែន................................................... ១១០

### ផ្នែកទី I

ព្រំដែន អន្តរជាតិ ?.............................................................. ១១២
១-ក្របខ័ណ្ឌទូទៅនៃបញ្ហា ....................................................... ១១២
២-ការអនុវត្តន៍ ...................................................................... ១១៣

## ផ្នែកទី II

ការកំណត់ព្រំដែនរដ្ឋបាល ? ........ ១១៥
១-ទិន្នន័យទូទៅ ........ ១១៥
២-ការអនុវត្តន៍........ ១១៦

## ផ្នែកទី III

សភាពការណ៍គតិយុត្តនៃទឹកដីដែលបានភ្ជាប់ ........ ១១៧

# ភាគទី IV
## កំពង់ចាម ក្រចេះ និង ធុយ៉ុងម៉ុត
(១៨៧១-១៩១៤)

## ជំពូកទី I

ការរៀបចំព្រំដែន........ ១១៨

## ផ្នែកទី I

សភាពការណ៍របស់ប្រទេសនៅក្នុងឆ្នាំ ១៨៧០ ........ ១២០

## ផ្នែកទី II

ដំណាក់កាលនៃការកាត់យកទឹកដីកម្ពុជា ........ ១២០

## អនុផ្នែកទី I

ដំណាក់កាលទី១ (១៨៩០) ........ ១២០
១-ទិន្នន័យនៃដែនទីផ្នែកភូមិសាស្ត្រនៃឥណ្ឌូចិន ........ ១២១
២-លក្ខណៈភាន់ច្រឡំរបស់ពួកគេ ........ ១២១



៣-ការរារែករបស់អាជ្ញាបារាំង ........ ១២៤

## អនុផ្នែកទី II

**ដំណាក់កាលទី ២ (១៨៩៣ )** ........ ១២៥
១-អនុក្រឹត្យរបស់ទេសាភិបាលកូសាំងស៊ីន ចុះថ្ងៃទី........ ១២៥
២-មូលហេតុនៃអនុក្រឹត្យនេះ - លក្ខណៈរំលោភរបស់វា ........ ១២៦
៣-ផលពិបាកនៃការបញ្ចូលជាឧបសម្ព័ន្ធ........ ១៣៣

## អនុផ្នែកទី III

អនុក្រឹត្យរបស់អគ្គទេសាភិបាលឥណ្ឌូចិនចុះថ្ងៃទី........ ១៣៧
១-ដើមកំណើតនៃអនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ : ការពង្រីកនៃដំណាំកៅស៊ូ ........ ១៣៧
២-ដំណើរការនៃគណៈកម្មការ ខ្លឹមសារនៃអនុក្រឹត្យចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤ ........ ១៤០
៣-គោលសំខាន់នៃការវាយតម្លៃអនុក្រឹត្យ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ១៩១៤........ ១៤២

## ជំពូកទី II

តម្លៃគតិយុត្តនៃព្រំដែន........ ១៤៦
១-ការគ្មានសយល់ព្រមរបស់កម្ពុជា ........ ១៤៧
២-ភាពមិនអាចទៅរួចនៃអន្តរជាតិក្នុងការបញ្ចូលជាឧបសម្ព័ន្ធនៃទឹកដីកម្ពុជា ........ ១៤៨
៣-ភាពមិនប្រក្រតី ផ្ទៃក្នុងនៃការបញ្ចូលជាឧបសម្ព័ន្ធ........ ១៤៩

# ភាគទី V
## ព្រៃវែង កណ្តាល តាកែវ កំពត និងហាទៀន
(១៨៧៣ - ១៩១៤ )

ព្រំដែនចូវដុក និងហាទៀន មួយផ្នែក និងព្រៃវែង កណ្តាល តាកែវ និងកំពត មួយផ្នែកទៀត (១៨៧៣-១៩១៤)........................................ ១៥២

### ជំពូកទី I

ប្រវត្តិសាស្ត្រនៃការរៀបចំព្រំដែន ........................................ ១៥៣

### ផ្នែកទី I

សភាពការណ៍មុនការចាប់ផ្តើមការងារ ........................................១៥៣

### ផ្នែកទី II

គំនូសនៃព្រំដែន ........................................ ១៦២
១-ការរៀបចំ ........................................ ១៦២
២-អនុសញ្ញាចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ១៨៧៣ និងការចាប់........ ១៦២
៣-ការសិក្សាពិពណ៌នាអំពីព្រំដែន........................................ ១៦៣
៤-ការកែប្រែជាខាងក្រោយដែលធ្វើឲ្យខូចប្រយោជន៍ប្រទេស........ ១៧០

### ជំពូកទី II

តម្លៃគតិយុត្តនៃព្រំដែន ........................................ ១៨២

### ផ្នែកទី I

សេចក្តីសង្ខេបនៃហេតុការណ៍ ........................................ ១៨២

### ផ្នែកទី II

តម្លៃគតិយុត្តនៃព្រំដែន ឆ្នាំ ១៨៧៦ ........................................ ១៨៣
១-តម្លៃគតិយុត្តនៃអនុសញ្ញា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៨៧៣ ... ១៨៣
២-តម្លៃគតិយុត្តនៃគំនូសព្រំដែនដែលបានធ្វើ ........................................ ១៨៤



### ផ្នែកទី III

តម្លៃគតិយុត្តនៃព្រំដែនឆ្នាំ ១៩១៤ ........................................ ១៨៥

## ភាគទី VI
## ព្រំដែនសមុទ្រ

ព្រំដែនសមុទ្រ........................................ ១៨៧

### ផ្នែកទី I

ការទាមទាររបស់វៀតណាមនៅឆ្នាំ ១៩៦០ ........................................ ១៨៧
១-របៀបដោះស្រាយរបស់ពួកគេ ........................................ ១៨៧
២-ការឆ្លើយបដិសេធនូវទឡ្ហីករណ៍ទាំងឡាយនៃលំដាប់................ ១៨៧
៣-ការឆ្លើយបដិសេធនូវទឡ្ហីករណ៍ទាំងឡាយ នៃលំដាប់............. ១៧៩

### ផ្នែកទី II

ការជជែកតទល់ ឆ្នាំ ១៩១៣ ........................................ ១៩១
១-ដើមកំណើតនៃការជជែកតទល់ ........................................ ១៩១
២-ការរារែករបស់រដ្ឋការបារាំង ........................................ ១៩២
៣-និក្ខេបបទរបស់កូសាំងស៊ីន ........................................ ១៩៥
៤-និក្ខេបបទរបស់កម្ពុជា ........................................ ១៩៦

### ផ្នែកទី III

សេចក្តីសម្រេចឆ្នាំ ១៩៣៩ ........................................ ១៩៦
១-មូលហេតុ និងខ្លឹមសារនៃសេចក្តីសម្រេច ........................................ ១៩៦
២-ការបកស្រាយរបស់វៀតណាម នូវសារាចរ ........................................ ១៩៧

សេចក្ដីសន្និដ្ឋានទូទៅ ........................................ ១៩៩

I – លក្ខណៈរដ្ឋបាល នៃព្រៃដែន........................................ ២០០

II– ការបញ្ចូលជាឧបសម្ព័ន្ធ ........................................ ២១៧

II– ជំហរនៅទីបញ្ចប់ ........................................ ២២២

តារាងសរុប ........................................ ២២៤

១. អត្ថបទទាំងឡាយនៃឧបសម្ព័ន្ធ ........................................ ២៤០

II– ដែនទី ........................................ ២៦៥

សរុបសៀវភៅដែលនិយាយក្នុងរឿងនេះ BIBLIOGRAPHIE ................ ២៧៨

សារប័ណ្ណ ........................................ ២៨២




The Indradevi Publishing